**Declassified to Public**
**17 September 2019**

លេខ៖ D381

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-Juges d'Instruction**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 06 / 2019
ម៉ោង (Time/Heure): 10 : 15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

លេខសំណុំរឿង: ០០៤/០៧-០៩-២០០៩/អ.វ.ត.ក-ក.ស.ច.ស

| | | |
|---|---|---|
| ចំពោះមុខ | ៖ | សហចៅក្រមស៊ើបអង្កេតជាតិ |
| កាលបរិច្ឆេទ | ៖ | ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៩ |
| ភាសាដើម | ៖ | ខ្មែរ |
| ចំណាត់ថ្នាក់ឯកសារ | ៖ | សម្ងាត់ |

# ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ

ផ្ញើជូន

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី យឹម ទិត្យ**
សូ មូស្សេទ្ធី
Suzana TOMANOVIĆ
Neville SRAOB

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវន
ទី ស្រីនណា
វ៉េន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARTI

CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

01619020



# មាតិកា

ទំព័រ

**ជំពូក១. សេចក្តីផ្តើម** ........ ០៤

១. ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ........ ០៤

២. ការកត់សម្គាល់អំពីដីកាដំណោះស្រាយ ........ ០៤

**ជំពូក២. សាវតារនីតិវិធី** ........ ០៨

១. ការរំលឹកឡើងវិញអំពីនីតិវិធី ........ ០៨

២. អនិយតភាពនៃនីតិវិធីលើការស៊ើបអង្កេតបឋម ........ ១៤

៣. អនិយតភាពនៃកិច្ចដែលបំពេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ........ ១៥

៤. នីតិវិធីនៃការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ........ ១៧

**ជំពូក៣. ការកត់សម្គាល់អំពីអង្គហេតុ** ........ ១៩

១. អំពីគោលនយោបាយទូទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ ........ ១៩

ក. ស្ថានភាពទូទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ ........ ១៩

ខ. របបដឹកនាំ ........ ២២

គ. កសិកម្ម-សេដ្ឋកិច្ច ........ ២២

ឃ. សាសនា និងសេរីភាពបុគ្គល ........ ២៥

ង. ការជម្លៀស ........ ២៩



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ច. គោលនយោបាយរៀបការដោយបង្ខំ ....................................................................៣១

ឆ. ការសម្លាប់ ..................................................................................................... ៣២

ជ. សុខមាលភាព ....................................................................................................៣៦

ឈ. គោលនយោបាយចម្លែក ......................................................................................៣៦

២. រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មជ្ឈិមបក្ស ................................................................... ៣៨

ក. គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ........................................................ ៣៨

ខ. គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ....................................................៣៩

គ. ស្ថាប័នដទៃទៀត ................................................................................................ ៤១

ឃ. ខ្សែបញ្ជា ...........................................................................................................៤៤

៣. គោលនយោបាយនៃការបោសសម្អាតនៅភូមិភាគពាយ័ព្យ ..............................................៤៤

៤. រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋាន និងភូមិភាគ ..................................................... ៥៦

៤.១. ភូមិភាគពាយ័ព្យ ............................................................................................ ៥៧

៤.១.១. រចនាសម្ព័ន្ធអំណាចតំបន់១ អំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ...៥៨

៤.២. ភូមិភាគនិរតី ................................................................................................ ៥៩

៤.២.១. លេខាភូមិភាគនិរតី ................................................................................. ៦០

៤.២.២. រចនាសម្ព័ន្ធអំណាចតំបន់១៣ អំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ៦២

៤.២.៣. រចនាសម្ព័ន្ធអំណាចស្រុកគិរីវង់ (តំបន់១៣) ..............................៦៤

៤.២.៤. លេខាស្រុកគិរីវង់ (ស្រុក ១០៩) .................................................... ៦៥

**ជំពូក៤. តួនាទី និងអំណាចរបស់ជនត្រូវចោទ** .................................................... ៦៥

១. សាវតារជនត្រូវចោទ .................................................... ៦៥

២. ការចូលរួមទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្ម .................................................... ៦៦

ក. អង្គហេតុដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ .................................................... ៦៦

១. មន្ទីរសន្តិសុខវត្តប្រធាតុ .................................................... ៦៦

២. មន្ទីរសន្តិសុខក្រាំងតាចាន់ .................................................... ៧០

៣. ទីតាំងសម្លាប់មនុស្សភូមិព្រេល .................................................... ៧៤

៤. ទីតាំងសម្លាប់មនុស្សវត្តអង្គុណា .................................................... ៧៦

៥. ទីតាំងសម្លាប់មនុស្សព្រៃភូមិស្វែង .................................................... ៧៧

៦. ទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមុនី .................................................... ៨០

៧. មន្ទីរសន្តិសុខវត្តគាស់ក្រឡ .................................................... ៨៤

៨. សហករណ៍ធិបតី (រួមមានមន្ទីរសន្តិសុខវត្តធិបតី) .................................................... ៨៨

៩. ការដ្ឋានទំនប់កង្កួត .................................................... ៩១

១០. មន្ទីរសន្តិសុខបាណន់ .................................................... ៩៧

១១. មន្ទីរសន្តិសុខខ្នងគូ .................................................... ១០០

១២. ការដ្ឋានរោងចក្រស្ករសកំពង់គុល .................................................... ១០៥



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION*

១៣. ការរៀបការដោយបង្ខំនៅស្រុកសំឡូត.................................... ១០៩

១៤. មន្ទីរសន្តិសុខភូមិវាល ........................................................ ១១១

១៥. មន្ទីរសន្តិសុខស្វាយជ្រំ........................................................ ១១១

១៦. ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ............................................ ១១៥

១៧. ទីតាំងសម្លាប់មនុស្សព្រៃក្របៅ ................................................១១៧

១៨. ទីតាំងសម្លាប់មនុស្សវត្តចន្ទរង្សី ............................................ ១១៩

១៩. មន្ទីរសន្តិសុខវត្តគិរីរម្យ ........................................................១២០

២០. មន្ទីរសន្តិសុខវត្តសម្តេច ........................................................ ១២៣

២១. ឃុំកំពង់ព្រៀង (រួមមាន ភូមិកាច់រទេះ ភូមិថ្មី ភូមិសាលាត្រាវ និងមន្ទីរ
សន្តិសុខ វត្តពោធិ៍លង្កា).......................................................១២៥

២២. ឃុំរាំងកេសី (រួមមាន វត្តកេសី និងភូមិរាំងកេសី)..............................១២៩

២៣. មន្ទីរសន្តិសុខគុកលេខ ០៨.......................................................១៣១

២៤. ទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជីង.............................................. ១៣៤

ខ. អង្គហេតុមិនដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ .......................................១៣៦

១. មន្ទីរសន្តិសុខវត្តសុបិន .......................................................១៣៦

២. ទីតាំងសម្លាប់មនុស្សភូមិសោម ................................................ ១៣៧

៣. ការដ្ឋានអន្លង់វល្លិប្រេង និង ទីតាំងសម្លាប់មនុស្សឆ្នាល់មាន់........១៣៧



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៤. មន្ទីរសន្តិសុខបន្ទាយត្រែង ........................................ ១៤១

៥. ការដ្ឋានទំនប់ភ្នំត្រជាក់ចិត្ត ........................................ ១៤២

៦. ទីតាំងសម្លាប់មនុស្សបន្ទាយអូរតាក្រៃ ........................................ ១៤៥

៧. ការដ្ឋាន និងមន្ទីរសន្តិសុខទួលម្ទេស ........................................ ១៤៦

៨. ទួលអណ្តែត ........................................ ១៥១

៩. ក្រឡឹងដុំ ........................................ ១៥៣

១០. គុកត្រាចក្រោល ហៅ គុកបឹងបាតកណ្តាល ........................................ ១៥៤

១១. អំពើហិង្សាផ្លូវភេទលើខ្មែរក្រោម និងអ្នកបូព៌ានៅស្រុកបាកាន ........................................ ១៥៧

១២. ទីតាំងសម្លាប់មនុស្សដំណាក់វាំង ........................................ ១៥៨

១៣. មន្ទីរសន្តិសុខវត្តកណ្តាល ........................................ ១៥៨

១៤. មន្ទីរសន្តិសុខវត្តបន្ទាយនាង ........................................ ១៦០

១៥. មន្ទីរសន្តិសុខវត្តធម្មយុត្តិ ........................................ ១៦៣

១៦. មន្ទីរសន្តិសុខ និងការដ្ឋានភ្នំទ្រយោង ........................................ ១៦៥

១៧. ការដ្ឋាន ស្ពានស្រែង និងព្រៃរនាម ........................................ ១៦៧

១៨. ការរំលោភផ្លូវភេទនៅស្រុកព្រះនេត្រព្រះ ........................................ ១៦៨

១៩. វត្តព្រះនេត្រព្រះ ទីតាំងឃុំខ្លួន និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធនានា ........
(ចំការដូង ចំការយាយនឹង ចំការតាលឹង) ........................................ ១៦៩

២០. ទីតាំងសម្លាប់មនុស្សភ្នំមិចក្រី ..................................... ១៧០

២១. ទីតាំងសម្លាប់មនុស្ស ព្រៃតារ៉ុត ..................................... ១៧១

២២. ទីតាំងសម្លាប់ល្អាងគួយយំ ..................................... ១៧២

២៣. ទីតាំងសម្លាប់មនុស្សវត្តចំការខ្នុរ ..................................... ១៧៣

២៤. ការដ្ឋានទំនប់ត្រពាំងថ្ម..................................... ១៧៤

២៥. ទីតាំងសម្លាប់ទួលពោធិ៍ជ្រៃ ..................................... ១៧៧

២៦. ការរៀបការដោយបង្ខំនៅស្រុកសង្កែ..................................... ១៧៩

គ. ចំនួនជនរងគ្រោះ ..................................... ១៨១

**ជំពូក៥. ការពិចារណាលើភ័ស្តុតាង** ..................................... ១៨២

ក. ការធ្វើសម្អាតសន៍ដែលមិនមែនជាកំណត់ហេតុស្តាប់ចម្លើយ ដែលបង្កើតឡើងដោយសហចៅក្រមស៊ើបអង្កេត..................................... ១៨២

ខ. ភ័ស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម..................................... ១៨៤

**ជំពូក៦. ច្បាប់ជាធរមាន ពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលនៅ អ.វ.ត.ក** ..................................... ១៨៤

១. យុត្តាធិការបុគ្គលនៅ អ.វ.ត.ក..................................... ១៨៤

២. អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា៖ យុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និងយុត្តាធិការរឿងក្តីដោយឡែក..................................... ១៨៧

៣. គោលការណ៍ច្បាប់ព្រហ្មទណ្ឌ៖ ប្រសិទ្ធភាពនៃគោលការណ៍ "វិមតិសង្ស័យ បានប្រយោជន៍ដល់ជនជាប់ចោទ" ការបកស្រាយក្នុងន័យចង្អៀត យុត្តាធិការបែបជ្រើសរើស និងការជំនុំជម្រះបែបជ្រើសរើស..................................... ១៩២

* CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

៤. យុត្តាធិការបុគ្គលតូចចង្អៀតត្រូវបានបង្ហាញក្នុងអំឡុងពេលនៃការចរចាបង្កើតអ.វ.ត.ក..... ១៩៦

៥. គោលនយោបាយ និងយន្តការនៃការធ្វើសេចក្តីសម្រេចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ឥទ្ធិពលលើទង្វើនៃកម្មាភិបាល ........................................................................ ១៩៩

**ជំពូក៧. សំអាងហេតុ និងសេចក្តីសន្និដ្ឋានបញ្ហាយុត្តាធិការបុគ្គល លើ យឹម ទិត្យ និងការបិទបញ្ចប់សំណុំរឿង ០០៤ ទាំងមូល** ............... ២១០

ក. សំអាងហេតុ និងសេចក្តីសន្និដ្ឋានបញ្ហាយុត្តាធិការបុគ្គលលើ **យឹម ទិត្យ** ........................ ២១០

ខ. ការបិទបញ្ចប់សំណុំរឿង ០០៤ ទាំងមូល ............................................................ ២១៦

ឧបសម្ព័ន្ធ ក៖ បញ្ជីពាក្យបំព្រួញ

ឧបសម្ព័ន្ធ ខ៖ បញ្ជីឯកសារផ្សេងៗដែលត្រូវបានប្រើដើម្បីសរសេរដីកាដំណោះស្រាយ



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

# យើង យូ ប៊ុនឡេង សហចៅក្រមស៊ើបអង្កេតជាតិនៃ អ.វ.ត.ក

**បានឃើញ៖** ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (ច្បាប់ស្តីពី អ.វ.ត.ក)។

**បានឃើញ៖** វិធាន ៥៥, វិធាន ៦៦, វិធាន ៦៦ ស្ទួន និងវិធាន ៦៧ នៃវិធានផ្ទៃក្នុង អ.វ.ត.ក វិសោធនកម្មលើកទី ៩ (វិធានផ្ទៃក្នុង) ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥។

**បានឃើញ៖** សំណុំរឿងលេខ ០០៤ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩។

**បានឃើញ៖** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ស.ព.អ) ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨។[1]

**បានឃើញ៖** ការបើកកិច្ចស៊ើបសួរទាក់ទងការចោទប្រកាន់ **យឹម ទិត្យ** ដូចខាងក្រោម[2]៖

ក. មនុស្សឃាត ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញលើសាសនាចាម។ ឧក្រិដ្ឋកម្មទាំងនេះជាការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ មាត្រា ៥០១, មាត្រា ៥០៣, មាត្រា ៥០៤, មាត្រា ៥០៥, មាត្រា ៥០៦, មាត្រា ៥០៧, មាត្រា ៥០៨ និង មាត្រា ៥០០ ព្រមទាំង មាត្រា ២០៩ និង មាត្រា ២១០ ដែលត្រូវផ្តន្ទាទោសតាម មាត្រា ៣ (ថ្មី), មាត្រា ២៩ (ថ្មី) និង មាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពី អ.វ.ត.ក ។

ខ. ការធ្វើឃាតកម្ម ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ និងធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា ទៅលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ វណ្ណៈសក្តិភូមិ នាយទុន និងគហបតី "ប្រជាជនថ្មី" អ្នកជាប់សង្ស័យជា "សមាសភាពអាក្រក់" ពុទ្ធសាសនិកជន ជនជាតិចាម និងជនជាតិភាគតិចវៀតណាម និង អំពើអមនុស្សធម៌ដទៃទៀត។ បទឧក្រិដ្ឋទាំងនេះជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ



E.C.C.C * C.E.T.C. * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៥, មាត្រា ២៩ (ថ្មី), និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពី អ.វ.ត.ក។

**បានឃើញ៖** សេចក្តីដកស្រង់របស់អង្គបុរេជំនុំជម្រះ (អ.ប.ជ) ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ លើការខ្វែងយោបល់រវាង សហព្រះរាជអាជ្ញា (ស.ព) ដោយអះអាងថា អ.ប.ជ មិនអាចឈានដល់ការធ្វើសេចក្តីសម្រេចលើការខ្វែងយោបល់ នោះកិច្ចរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ស.ព.អ) ត្រូវតែយកទៅអនុវត្ត។[3]

**បានឃើញ៖** ការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី ៣ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ ដោយ ស.ព.អ ស្នើដល់សហចៅក្រមស៊ើបអង្កេត (ស.ច.ស) សុំឲ្យចាប់ផ្តើមបើកកិច្ចស៊ើបសួរ។[4]

**បានឃើញ៖** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ បន្ថែមទី ១ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១។[5]

**បានឃើញ៖** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទី ២ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤។[6]

**បានឃើញ៖** ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវត្តតាមេះ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៥។[7]

**បានឃើញ៖** ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរលើអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់ ១ និងតំបន់ ៤ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥។[8]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C. *

បានឃើញ៖ សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ យោងតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង អ.វ.ត.ក។[9]

បានឃើញ៖ ដីកាសម្រេចលើសំណើរបស់ យឹម ទិត្យ សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់ នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧ និង ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៧។[10]

បានឃើញ៖ សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ **PAOLO STOCCHI** ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៧។[11]

បានឃើញ៖ សេចក្តីជូនដំណឹងលើកទី២ អំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៧។[12]

បានឃើញ៖ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ យោងតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៨។[13]

បានឃើញ៖ ដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញាជាតិ ទាក់ទងករណី យឹម ទិត្យ នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨។[14] ដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងករណី យឹម ទិត្យ នៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៨។[15]

បានឃើញ៖ ការប៉ាន់ស្មានថិរវេលាចាំបាច់របស់ យឹម ទិត្យ ដើម្បីឆ្លើយតបនឹងដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៨។[16]

បានឃើញ៖ ដីកាសម្រេចលើចំនួនពេលវេលាដែលផ្ដល់ជូនមេធាវីការពារក្ដី ដើម្បីឆ្លើយតបនឹងដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញា ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៨។[17]

បានឃើញ៖ ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨។[18]

## ជំពូក១. សេចក្តីផ្តើម

### ១. ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

១. បន្ទាប់ពីមានសំណើសុំជំនួយជាផ្លូវការពីរាជរដ្ឋាភិបាលកម្ពុជា នាថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៧[19] កិច្ចព្រមព្រៀងមួយត្រូវបានចុះហត្ថលេខានាថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ ដែលប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ (កិច្ចព្រមព្រៀងស្តីពី ការបង្កើត អ.វ.ត.ក)។[20]

២. ជាក់ស្តែង អ.វ.ត.ក ត្រូវបានបង្កើតឡើងជាផ្លូវការនាថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៦ ក្នុងប្រព័ន្ធច្បាប់កម្ពុជា បន្ទាប់ពីមានការប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។[21]

### ២. ការកត់សម្គាល់អំពីដីកាដំណោះស្រាយ

៣. យើងចង់បង្ហាញថា តាមទ្រឹស្តីជនដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាត្រូវបានហៅថា "ជនត្រូវចោទ" រួចទៅហើយ។ ជនត្រូវចោទ គឺមានឋានៈចាប់តាំងពីពេលមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ដោយឡែក ការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យគឺជានីតិវិធីដើម្បីជនត្រូវចោទមានសិទ្ធិដឹង និងពឹងពាក់មេធាវីការពារតទល់នឹងអង្គហេតុដែលសហព្រះរាជអាជ្ញាបានប្តឹង និងជូនដំណឹង



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

ដោយសហចៅក្រមស៊ើបអង្កេត។ យើងបានចុះកំណត់ត្រាខ្វែងយោបល់ពាក់ព័ន្ធនឹងការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ និងមិនបានប្តឹងទៅអង្គបុរេជំនុំជម្រះ។ ការប្រើប្រាស់ឯកសារទទួលបានក្រោយពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យមិនខុសទេ ហើយការប្រើពាក្យជនត្រូវចោទក្នុងដីកាដំណោះស្រាយនេះ ក៏មិនមានអ្វីខុសឆ្គងដែរ។

៤. ដីកាដំណោះស្រាយនេះ ពិចារណាផ្តោតទៅលើថា តើ **យឹម ទិត្យ** ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬទេ? អង្គហេតុដែលត្រូវបានប្តឹងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ជាសត្យានុម័តពិតជាមាន ទោះបីជាយ៉ាងនេះក្តី សហចៅក្រមស៊ើបអង្កេតជាតិនៅតែស៊ើបសួរគ្រប់អង្គហេតុដែលបានចោទ។ ដីកាដំណោះស្រាយនេះត្រូវបានចេញដោយផ្អែកលើភស្តុតាងដែលជាលទ្ធផលនៃការស៊ើបសួរស្របច្បាប់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតជាតិបានពិចារណាជាសំខាន់លើការចូលរួមប្រព្រឹត្តនិងលក្ខខណ្ឌផ្សេងៗទៀតរបស់ជនត្រូវចោទដែលជាកត្តាសំខាន់ផងដែរ ដើម្បីកំណត់ថា "ជនត្រូវចោទ" ជាមេដឹកនាំជាន់ខ្ពស់ ឬ ជាជនទទួលខុសត្រូវខ្ពស់បំផុត។ ក្នុងន័យនេះ ដីកាដំណោះស្រាយនឹងមិនមានភាពចាំបាច់ក្នុងការចាត់បទល្មើសទៅតាមអង្គហេតុ និងសរសេរបញ្ចូលនូវទម្រង់នៃការទទួលខុសត្រូវនោះទេ។

៥. ឯកសារដែលនឹងត្រូវប្រើក្នុងដីកាដំណោះស្រាយនេះរួមមាន៖ ឯកសារទាំងឡាយដែលមានក្នុងសំណុំរឿង ០០៤ ដែលទទួលបានមកពីការស៊ើបសួរ និងការផ្ទេរបញ្ចូលពីសំណុំរឿងដទៃទៀតរួមមាន សំណុំរឿងលេខ ០០១, លេខ ០០២, លេខ ០០៣, លេខ ០០៤/១ និងលេខ ០០៤/២ ផងដែរ។ ឯកសាររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង **Laurent Kasper-ANSERMET** នឹងមិនត្រូវបានប្រើប្រាស់ទេ។ ទោះបីជាយ៉ាងនេះក្តី បន្ទាប់ពីការចាកចេញរបស់ចៅក្រម **Laurent Kasper-ANSERMET** នៅមានឯកសារមួយចំនួនដែលត្រូវបានដាក់បញ្ចូលជាផ្នែកមួយ និងក្នុងក្របខ័ណ្ឌនៃដីកាបង្គាប់ឱ្យស៊ើបសួរជំនួសចេញដោយចៅក្រមរូបនេះ។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតជាតិបានពិចារណាថាដីកាដំណោះស្រាយនេះអាចនឹងប្រើប្រាស់ឯកសារមួយចំនួនដោយច្រឡំជាយថាហេតុ។

៦. ដីកាដំណោះស្រាយនេះប្រើប្រាស់ឯកសារចំនួនប្រហែល ១៣៥៩ (មួយពាន់បីរយហាសិបប្រាំបួន) ចែកចេញជា ២១ (ម្ភៃមួយ) ប្រភេទដូចជា៖ សារទូរលេខ កំណត់ត្រាប្រជុំ

គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មការមជ្ឈិមបក្សកុំម្មុយនីស្តកម្ពុជានៃរបបកម្ពុជាប្រជាធិបតេយ្យ ចម្លើយសារភាពនៃអ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលមានចំនួនច្រើនជាងគេរហូតដល់ ៧៥៤ (ប្រាំពីររយហាសិបបួន) ជាអាទិ៍ (ឧបសម្ព័ន្ធ២)។ ក្នុងប្រភេទឯកសារចុងក្រោយនេះមានចម្លើយរបស់សាក្សីសំខាន់ៗ (insider witness) ដូចជាកម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យមានចំនួនយ៉ាងហោចណាស់ ១៨៣ (មួយរយប៉ែតសិបបី) កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលត្រូវបានបង្កើតឡើងក្នុងក្របខ័ណ្ឌនៃសំណុំរឿង០០៤ នេះ។

៧. នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេត បានប្រកាសបិទការស៊ើបសួរ។[22] ដោយយោងលើភាពស្មុគស្មាញនៃសំណុំរឿង នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានសម្រេចផ្តល់ពេលវេលា ៣០ (សាមសិប) ថ្ងៃ បន្ថែមទៀតសម្រាប់ភាគីទាំងអស់នៅក្នុងសំណុំរឿង០០៤ ដើម្បីស្នើសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម។[23] រហូតដល់ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៧ ទើបសហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីជូនដំណឹងលើកទី២ អំពីការបិទកិច្ចស៊ើបសួរលើ **យឹម ទិត្យ**។[24] បន្ទាប់មក នៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៨ សហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿងទៅឱ្យសហព្រះរាជអាជ្ញាពិនិត្យ ដើម្បីចេញដីកាសន្និដ្ឋានស្ថាពរក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីថ្ងៃទទួលដីកាបញ្ជូនពីសហចៅក្រមស៊ើបអង្កេត។[25] សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ បានចេញដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី **យឹម ទិត្យ** នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨ និងនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៨ រៀងៗខ្លួន។[26] ដើម្បីធានានូវគោលការណ៍សមភាពរវាងភាគី ភាពស្មុគស្មាញនៃសំណុំរឿង បញ្ហានៃការបកប្រែភាសា សហចៅក្រមស៊ើបអង្កេតបានទុកពេលវេលាសមស្របសម្រាប់ **យឹម ទិត្យ** ឆ្លើយតបនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ហើយក្នុងថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ **យឹម ទិត្យ** បានដាក់ឯកសារឆ្លើយតប។[27]

៨. គិតពីថ្ងៃបិទការស៊ើបសួរមកដល់ថ្ងៃចេញដីកាដំណោះស្រាយមានរយៈពេលយូរជាង ប្រសិនបើធៀបនឹងសំណុំរឿង ០០១ សំណុំរឿង ០០២ សំណុំរឿង ០០៤/១ និងសំណុំរឿង ០០៤/២។ តែទោះបីជាយ៉ាងនេះក្តី ការសម្រេចថាមានការរំលោភលើសិទ្ធិសេរីភាព



CO-INVESTIGATING JUDGES *E.C.C.C*C.E.T.C* JUGES D'INSTRUCTION

យឹម ទិត្យ ក្នុងការទទួលបានការកាត់សេចក្តីក្នុងពេលសមស្រប ដោយពិចារណាលើតែរយៈពេលតែមួយមុខពិតជាមិនសមស្របទេ។ សំណុំរឿង ០០៤ ជាសំណុំរឿងធំមានទីតាំងឧក្រិដ្ឋកម្មចំនួន ៥០ ដែលត្រូវបានចោទ បើធៀបនឹងសំណុំរឿង ០០៤/១ និងសំណុំរឿង ០០៤/២។ បន្ថែមពីលើនេះ ក្នុងដំណាក់កាលនៃនីតិវិធីមានបណ្តឹង ឬ ញត្តិជាច្រើនរបស់ភាគីទៅអង្គបុរេជំនុំជម្រះ ដែលការវិនិច្ឆ័យទាំងនោះត្រូវបានធ្វើឡើងតាមកាលបរិច្ឆេទកំណត់ទុកពេលវេលាជូនភាគី ដើម្បីអាចឆ្លើយតប និងធានានូវសមភាព និងតម្លាភាពនៃនីតិវិធី។ ការកំណត់ពេលវេលាចែងក្នុងវិធានផ្ទៃក្នុង ការរង់ចាំលទ្ធផលសម្រេចរបស់ផ្នែកផ្សេងៗរាប់ទាំងការបកប្រែ បានប៉ះពាល់ដល់ដំណើរការ ឬ នីតិវិធីបន្ទាប់របស់ ក.ស.ច.ស។

៩. ដូចដែលមានបង្ហាញជូនក្នុងជំពូកទី៥ ខាងក្រោម សហចៅក្រមស៊ើបអង្កេតជាតិ ពិចារណាថា មិនមានការខុសឆ្គងអ្វីទេក្នុងការបរិយាយអំពីប្រភេទនៃភ័ស្តុតាង និងតម្លៃនៃភ័ស្តុតាងនៅក្នុងដីកាដំណោះស្រាយនេះ។ មាត្រា ៣២១ (ការវាយតម្លៃលើភ័ស្តុតាងដោយតុលាការ) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ និងគោលការណ៍ទទួលភ័ស្តុតាងដោយសេរីនៃប្រព័ន្ធច្បាប់ស៊ីវិលឡូមិនហាមឃាត់ការធ្វើយ៉ាងនេះទេ។ ជាការអនុវត្តជាក់ស្តែង និងសមហេតុផល វាពិតជាមានភាពខុសគ្នារវាងប្រភេទនៃភ័ស្តុតាង (ភ័ស្តុតាងផ្ទាល់ និងភ័ស្តុតាងមិនផ្ទាល់) ឧទាហរណ៍ រវាងភ័ស្តុតាងឮតាមគ្នា និង សក្ខីកម្មសាក្សីដែលបានឃើញព្រឹត្តិការណ៍ផ្ទាល់។ អ្វីជាសំខាន់គឺការពិចារណានូវភ័ស្តុតាងជាក់ស្តែងតាមវិធានកំណត់គឺ ភាពជាប់ពាក់ព័ន្ធ ភាពស្របច្បាប់ និងភាពសត្យានុម័តនៃភ័ស្តុតាង។

១០. ពាក់ព័ន្ធនឹងភ័ស្តុតាងត្រូវបានចោទថា ទទួលបានតាមរយៈអំពើទារុណកម្ម ស.ច.ស.ជ មានឆន្ទានុសិទ្ធិក្នុងការកំណត់វាយតម្លៃភ័ស្តុតាង ដែលប្រមូលបានដោយផ្អែកលើលក្ខណៈសម្បត្តិភ័ស្តុតាង ភាពជាប់ពាក់ព័ន្ធ ភាពស្របច្បាប់ និងភាពសត្យានុម័ត ដោយពិចារណាលើសេចក្តីសម្រេចកន្លងមករបស់អង្គជំនុំជម្រះសាលាដំបូង[28] អង្គជំនុំជម្រះតុលាការកំពូល។[29] បន្ថែមពីលើនេះ ឯកសារត្រូវបានធ្វើមោឃកម្មដោយអង្គបុរេជំនុំជម្រះ ក៏នឹងមិនត្រូវបានប្រើប្រាស់ដែរ។[30]

# ជំពូក២. សាវតារនីតិវិធី

## ១. ការរំលឹកឡើងវិញអំពីនីតិវិធី

១១. នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ យោងតាមវិធាន ៥៣ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអន្តរជាតិ (ស.ព.អ) បានចេញ *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣* (ដីកាសន្និដ្ឋាន) ដោយបានធ្វើការចោទប្រកាន់ផ្សេងៗ ដូចជា **យឹម ទិត្យ** ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។[31] នៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៨ មានកំណត់ត្រាខ្វែងយោបល់រវាង ស.ព លើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ហើយបញ្ហាខ្វែងយោបល់នេះត្រូវបានដាក់ប្ដឹងទៅ អ.ប.ជ។ នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ អ.ប.ជ បានប្រកាសថា ដោយមិនបានទទួលមតិភាគច្រើនដាច់ខាត ហេតុដូច្នេះ កិច្ចរបស់ ស.ព.អ ត្រូវតែយកទៅអនុវត្ត។[32]

១២. នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ ស.ព.អ ស្ដីទី បានជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ និងស្នើឱ្យ ស.ច.ស ចាប់ផ្ដើមបើកកិច្ចស៊ើបសួរ។[33] នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ ស.ច.ស បានចុះកំណត់ត្រាខ្វែងយោបល់អំពីរបៀប និងវិធីសាស្ត្រនៃការស៊ើបសួរ។ ស.ច.ស.ជ បានអះអាងអំពីភាពមិនចាំបាច់ក្នុងការចុះស៊ើបសួរ ហើយបានផ្ដោតលើតែការពិនិត្យឯកសារដែលមានស្រាប់ក្នុងសំណុំរឿង។[34] នៅថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ស.ច.ស.អ) **Marcel LEMONDE** បានចេញនូវដីកាចាត់ឱ្យស៊ើបសួរជំនួស។[35] នៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១០ ចៅក្រម **Marcel LEMONDE** បានលាលែងពីមុខតំណែងដោយមូលហេតុផ្ទាល់ខ្លួន។ នៅថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១០ ស.ច.ស.អ **Siegfried BLUNK** បានចាប់ផ្ដើមចូលបំពេញការងារជាផ្លូវការ។[36] នៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១១ ក.ស.ច.ស ចេញសេចក្ដីប្រកាសព័ត៌មានដោយបានបង្កើតឱ្យមានក្រុមការងាររួមជាច្រើនក្រុម ដើម្បីធ្វើការពិនិត្យនិងវិភាគលើឯកសារនានាក្នុងសំណុំរឿង ជាពិសេសឯកសារដែលមានក្នុងសំណុំរឿងលេខ ០០១ និងសំណុំរឿងលេខ០០២។[37] បន្ទាប់មក ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដោយចោទថា **យឹម ទិត្យ** ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មបន្ថែមទៀត។[38]

១៣. ករណីខ្វែងយោបល់រវាងសហចៅក្រមស៊ើបអង្កេត (ស.ច.ស) នៅក្នុងសំណុំរឿងនេះ បាន ចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣, ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥, ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧ និងថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៩។

១៤. នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ស.ច.ស.អ) បានដាក់ **យឹម ទិត្យ** ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទរំលោភលើមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ (មនុស្សឃាត) អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩។[39] នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ ស.ច.ស.អ បានចេញដីកាសម្រេចកែប្រែបទចោទ ដើម្បីបញ្ចូលទម្រង់នៃការទទួលខុសត្រូវបន្ថែមទៀត។[40]

១៥. នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ ស.ច.ស.អ បានចេញដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ យោងតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង។[41]

១៦. នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេត បានចេញសេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរលើ **យឹម ទិត្យ** (សេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ) ហើយបានជូនដំណឹងភាគីទាំងអស់ថា ភាគីមានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃចាប់ពីពេលជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែម។[42]

១៧. នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧ មេធាវីការពារក្ដី **យឹម ទិត្យ** (មេធាវីការពារ) បានដាក់សំណើសុំពន្យារពេលរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនេះ ឱ្យបានយ៉ាងហោចណាស់ប្រាំមួយខែ (សំណើសុំពន្យារពេល)។[43]

១៨. នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៧ ស.ព.អ បានដាក់សំណើសុំបញ្ជាក់អំពីដីកាសម្រេចរបស់ ស.ច.ស.អ លើសំណើរបស់ ស.ព.អ សុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងរបាយការណ៍វិភាគរបស់ វឿន វិទ្ធី (សំណើសុំការបញ្ជាក់)។[44]

១៩. នៅថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចលើសំណើសុំពន្យារពេលដោយបដិសេធសំណើសុំពន្យារពេលដល់ ៦ (ប្រាំមួយ) ខែ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតអនុញ្ញាតផ្តល់ជូនភាគីនូវរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ថែមវិញ គឺរហូតដល់ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧ ភាគីទាំងអស់អាចស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមបាន (ដីកាសម្រេចលើសំណើសុំពន្យារពេល)។[45]

២០. នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៧ និងនៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៧ ស.ព.អ បានដាក់សំណើសុំបញ្ចូលឯកសារមួយចំនួនចូលក្នុងសំណុំរឿង ០០៤។[46] ស.ច.ស.អ បានចេញដីកាសម្រេចលើសំណើទាំងនោះ នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៧។[47]

២១. នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧ មេធាវីការពារក្តី បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំពន្យារពេល (បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី)។[48]

២២. នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧ ស.ព.អ បានដាក់សំណើចំនួនពីរស្នើសុំបំពេញកិច្ចស៊ើបសួរ៖ សំណើទីមួយ ស្នើសុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងគុកលេខ ០៨ នៅស្រុកកណ្តៀង និងអំពើហិង្សាផ្លូវភេទនៅស្រុកបាកាន (សំណើសុំបំពេញកិច្ចស៊ើបសួរទីមួយរបស់ ស.ព.អ)[49] និងសំណើទីពីរ ស្នើសុំបំពេញកិច្ចស៊ើបសួរដូចបានបង្ហាញនៅក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់ជាមួយសំណើ (សំណើសុំបំពេញកិច្ចស៊ើបសួរទីពីររបស់ ស.ព.អ)។[50]

២៣. នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧ មេធាវីការពារក្តីបានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងការប្រើប្រាស់អង្គការលេខដែលទទួលបានដោយសារការធ្វើទារុណកម្ម (សំណើសុំបំពេញកិច្ចស៊ើបសួររបស់មេធាវី)។[51]

២៤. នៅថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៧ ស.ច.ស.អ បានចេញដីកាសម្រេចផ្នែកខ្លះលើសំណើសុំបំពេញកិច្ចស៊ើបសួរទីពីររបស់ ស.ព.អ។[52]



ECCC CETC CO-INVESTIGATING JUDGES CO-JUGES D'INSTRUCTION

២៥. នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៧ ស.ច.ស.អ បានចេញដីកាសម្រេចលើសំណើរបស់ ស.ព.អ សុំការបញ្ជាក់អំពីដីកាសម្រេចលើកិច្ចស៊ើបសួរ។[53]

២៦. នៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៧ ស.ច.ស.អ បានចេញដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរទីមួយ របស់ ស.ព.អ និងលើផ្នែកសេសសល់ផ្សេងទៀតនៃសំណើសុំបំពេញកិច្ចស៊ើបសួរទីពីរ របស់ ស.ព.អ។[54]

២៧. នៅថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៧ ស.ច.ស.អ បានចេញដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តី។[55]

២៨. នៅថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៧ យើងបានចេញសេចក្តីជូនដំណឹងលើកទី២ អំពីការបិទកិច្ចស៊ើបសួរលើ **យឹម ទិត្យ** ហើយបានជូនដំណឹងភាគីថា មិនមានការផ្តល់ជូនពេលវេលាបន្ថែមទៀតដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរឡើយ(សេចក្តីជូនដំណឹងលើកទី២ អំពីការបិទកិច្ចស៊ើបសួរ)។[56]

២៩. នៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៧ មេធាវីការពារក្តី បានដាក់ពាក្យសុំប្តឹងទៅ អ.ប.ជ ស្នើសុំមោឃភាពឯកសារមួយចំនួនទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី (សំណើសុំមោឃភាពលើកទីមួយ)។[57]

៣០. នៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៧ ស.ច.ស.អ បានអនុញ្ញាតតាមសំណើសុំមោឃភាពទីមួយ ហើយបានបង្គាប់ឲ្យបញ្ជូនសំណុំរឿងជូនទៅ អ.ប.ជ ដើម្បីសម្រេចលើសំណើនេះ។[58]

៣១. នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧ ស.ព.អ បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ ស.ច.ស.អ លើសំណើសុំបំពេញកិច្ចស៊ើបសួរទីមួយរបស់ ស.ព.អ (បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ)។[59]

៣២. នៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៧ មេធាវីការពារក្តី បានដាក់ពាក្យសុំប្តឹងទៅ អ.ប.ជ ស្នើសុំមោឃភាពភ័ស្តុតាងដែលទទួលបានដោយសារការធ្វើទារុណកម្ម (សំណើសុំមោឃភាពលើកទីពីរ)។[60]

៣៣. នៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៧ អ.ប.ជ បានចេញសេចក្តីសម្រេចបដិសេធបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី។[61]

៣៤. នៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៧ ដោយសារថានៅត្រឹមដំណាក់កាលនោះ អ.ប.ជ មិនទាន់មានសេចក្តីសម្រេចលើបញ្ហាចោទស្រដៀងគ្នានៅក្នុងសំណុំរឿង ០០៣ ដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ៣២ ខាងលើ ទើប ស.ច.ស.អ បានអនុញ្ញាតតាមសំណើសុំមោឃភាពលើកទីពីរ ហើយបង្គាប់ឱ្យបញ្ជូនសំណុំរឿងជូនទៅ អ.ប.ជ ដើម្បីសម្រេចលើសំណើនេះ។[62]

៣៥. នៅថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៨ មេធាវីការពារក្តីបានដាក់សំណើសុំកែតម្រូវកំហុសបកប្រែភាសានៅក្នុងកំណត់ហេតុស្តាប់ចម្លើយមួយចំនួននៅក្នុងសំណុំរឿង (សំណើសុំកែតម្រូវរបស់មេធាវីការពារក្តី)។ [63]

៣៦. នៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៨ អ.ប.ជ បានចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាសម្រេចលើសំណុំសុំបំពេញកិច្ចស៊ើបសួរទាក់ទងអំពើហិង្សាផ្លូវភេទនៅគុកលេខ ០៨ និងនៅក្នុងស្រុកបាកាន។[64]

៣៧. នៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៨ ស.ច.ស.អ បានចេញដីកាសម្រេចលើសំណើសុំកែតម្រូវរបស់មេធាវីការពារក្តី និងបានណែនាំឱ្យអង្គភាពបកប្រែភាសា ធ្វើការកែតម្រូវទាំងអស់លើកំណត់ហេតុនៃការស្តាប់ចម្លើយដែលជាប់ពាក់ព័ន្ធ តាមការអនុញ្ញាតនៅក្នុងដីកាសម្រេចនេះ។[65]



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

៣៨. នៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១៨ យោងតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ស.ច.ស បានបញ្ជូនសំណុំរឿង ០០៤ ទៅសហព្រះរាជអាជ្ញា ដើម្បីពិនិត្យ និងចេញដីកាសន្និដ្ឋានស្ថាពរ។[66]

៣៩. នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨ ស.ព.ជ បានដាក់ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី **យឹម ទិត្យ** អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ហើយបានស្នើសុំលើកលែងការចោទប្រកាន់ប្រឆាំង **យឹម ទិត្យ**។[67] នៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៨ ស.ព.អ បានដាក់ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី **យឹម ទិត្យ** អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ហើយបានបញ្ជាក់ការស្នើសុំថា **យឹម ទិត្យ** គួរត្រូវបញ្ជូនទៅជំនុំជម្រះ។[68]

៤០. នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៨ មេធាវីការពារក្តីរបស់ **យឹម ទិត្យ** បានដាក់ការប៉ាន់ស្មានថិរវេលាចាំបាច់របស់ **យឹម ទិត្យ** ដើម្បីឆ្លើយតបនឹងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ ហើយបានស្នើសុំផ្តល់ពេលវេលា ៣ (បី) ខែ ដល់មេធាវីការពារក្តី ដោយចាប់គិតពីថ្ងៃទទួលបានការជូនដំណឹងអំពីសំណៅបកប្រែជាភាសាខ្មែរទាំងស្រុងនៃដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ រួមបញ្ចូលទាំងជើងទំព័រ ដើម្បីឆ្លើយតបជាភាសាអង់គ្លេសជាមុន ហើយសំណៅជាភាសាខ្មែរនឹងដាក់ពេលក្រោយឆាប់ៗតាមដែលអាចធ្វើទៅបាន។[69]

៤១. នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចលើចំនួនពេលវេលាដែលផ្តល់ជូនមេធាវីការពារក្តី ដើម្បីឆ្លើយតបនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ដោយបានសម្រេចផ្តល់ជូនមេធាវីការពារក្តីនូវពេលវេលាចំនួន ៣ (បី) ខែ ដើម្បីឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.ជ និង ស.ព.អ ជាភាសាអង់គ្លេសសិន រាប់ចាប់ពីថ្ងៃជូនដំណឹងអំពីការដាក់សំណៅបកប្រែទាំងស្រុងជាភាសាខ្មែរនៃដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ ដោយសំណៅបកប្រែជាភាសាខ្មែរត្រូវដាក់តាមក្រោយឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។[70]

៤២. នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ មេធាវីការពារក្តី **យឹម ទិត្យ** បានដាក់ចម្លើយតបរបស់ **យឹម ទិត្យ** ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញា



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

អន្តរជាតិប្រឆាំងនឹងគាត់ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ដោយបញ្ជាក់ថា អ.វ.ត.ក ខ្វះយុត្តាធិការបុគ្គលលើ **យឹម ទិត្យ**។[71]

## ២. អនិយតភាពនៃនីតិវិធីលើការស៊ើបអង្កេតបឋម

៤៣. បើទោះបីជាបញ្ហាខ្វែងយោបល់រវាងសហព្រះរាជអាជ្ញាទាំងពីរត្រូវបានដោះស្រាយដោយ អ.ប.ជ ហើយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមានសុពលភាពរួចហើយក្ដី ស.ច.ស.ជ ពិចារណាថា វាជាការចាំបាច់ក្នុងការបង្ហាញដោយសង្ខេបនូវសារវតារនៃបញ្ហានេះ។

៤៤. ស.ព.អ បានបើកការស៊ើបអង្កេតបឋមដោយឯកឯង ខណៈបរិបទច្បាប់នៅ អ.វ.ត.ក គោលការណ៍ "សហ" ត្រូវបានក្លាយជាចំណងតាមផ្លូវច្បាប់ជាល័ក្ខខ័ណ្ឌកំណត់ ទោះបីជាស្ថិតក្នុងដំណាក់កាល ស.ព ក៏ដោយ ស.ព ត្រូវតែធ្វើការរួមគ្នា។ គោលការណ៍នេះតម្រូវជាចាំបាច់ឲ្យគោរពនូវវិធានបញ្ញត្តិតាមច្បាប់ជាធរមានទាំងឡាយ ដូចមានក្នុងកិច្ចព្រមព្រៀង និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ជាអាទិ៍។ ផ្ទុយទៅវិញ ស.ព.អ បានធ្វើការស៊ើបអង្កេតបឋមតែម្នាក់ឯង ដោយប្រមែប្រមូលនូវឯកសារ និងធ្វើការសម្ភាសន៍ផ្សេងៗដោយគ្មានការចូលរួមពី ស.ព.ជ និងមិនឆ្លងកាត់តាមនីតិវិធីនៃការខ្វែងយោបល់ឡើយ។ មូលហេតុទាំងនេះមិនទាន់ពិចារណាដល់កំណត់ហេតុនៃការសួរយកចម្លើយទាំងនោះដោយគ្មានហត្ថលេខារបស់សហព្រះរាជអាជ្ញា និងជនដែលត្រូវបានសួរយកចម្លើយថែមទៀត។

៤៥. នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរជាអត្តនោម័តតែម្នាក់ឯង ក្នុងក្របខ័ណ្ឌនៃសំណុំរឿងនេះដោយបានចោទ **យឹម ទិត្យ** ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្រោមយុត្តាធិការ អ.វ.ត.ក។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះមិនត្រូវបានចាត់ការដោយ ស.ច.ស ភ្លាមទេ ដោយហេតុថាទន្ទឹមគ្នានោះ ស.ព.ជ បានប្ដឹងជំទាស់ឲ្យពិចារណាលើបញ្ហានៃការខ្វែងយោបល់ដែលជាកម្មវត្ថុនឹងត្រូវបានបញ្ជូនទៅ អ.ប.ជ។ ជាលទ្ធផល អ.ប.ជ រកសម្លេងមិនបានដែលការណ៍នេះជាផលវិបាកផ្នែកគតិយុត្តក្នុងបរិបទ អ.វ.ត.ក នាំឲ្យដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមានអានុភាពគតិយុត្តកើតឡើង។ បន្ទាប់មក ស.ព.អ ស្ដីទី បានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមក ស.ច.ស សុំឲ្យបំពេញកិច្ចស៊ើបសួរទៅលើអង្គហេតុក្នុងសំណុំរឿងលេខ ០០៤។



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * JUGES D'INSTRUCTION

៤៦. នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ ស.ច.ស.អ បានធ្វើនីតិវិធីនៃការបង្ហាញខ្លួនលើកដំបូងដោយបានដាក់ យឹម ទិត្យ ឱ្យស្ថិតនៅក្រោមការពិនិត្យ ប៉ុន្តែចំណាត់ការនៃកិច្ចនីតិវិធីនេះត្រូវបានរងនូវការខ្វែងយោបល់ពីសំណាក់ ស.ច.ស.ជ ដោយផ្អែកលើវិធាន ៧២ ចំណុចទី ១ នៃវិធានផ្ទៃក្នុង។[72]

៤៧. ស.ច.ស.ជ មិនបានឯកភាពចំពោះការសម្រេចដាក់ យឹម ទិត្យ ឱ្យស្ថិតនៅក្រោមការពិនិត្យទេ ពីព្រោះថា ស.ច.ស.ជ នៅតែយល់ឃើញថា បើតាមលទ្ធផលដែលទទួលបានពីការស៊ើបសួរនៅមានវិមតិសង្ស័យលើឈ្មោះ យឹម ទិត្យ ពាក់ព័ន្ធនឹងបញ្ហាយុត្តាធិការបុគ្គលដើម្បីដាក់ឈ្មោះនេះឱ្យស្ថិតនៅក្រោមការពិនិត្យ។ បញ្ហាយុត្តាធិការបុគ្គលលើ យឹម ទិត្យ គឺជាបញ្ហាអាទិភាពសំខាន់បំផុតមួយដែលជាកម្មវត្ថុនៃការពិចារណាមុននឹងធ្វើចំណាត់ការលើកិច្ចផ្សេងៗទៀត សម្រាប់បរិបទច្បាប់នៅ អ.វ.ត.ក ដែលជាយុត្តាធិការជ្រើសរើស។

## ៣- អនិយតភាពនៃកិច្ចដែលបំពេញដោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង

៤៨. បន្ទាប់ពីមានការលាឈប់ជាផ្លូវការនៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១១ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ **Siegfried BLUNK** សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង (ស.ច.ស.អ.ប) **Laurent Kasper-ANSERMET** មិនទាន់ទាំងបានមកដល់ អ.វ.ត.ក ភ្លាមទេ ហើយបានចាប់ផ្តើមធ្វើការងារពីកន្លែងការងារចាស់របស់គាត់តាមប្រព័ន្ធអ៊ីនធឺណែតជាស្រេច។ ពេលមកដល់ អ.វ.ត.ក គាត់ចាប់ផ្តើមការងារមួយចំនួនដោយពុំបានធ្វើការពិភាក្សាជាមួយ ស.ច.ស.ជ។ ការណ៍នេះគឺខុសនឹងខ្លឹមសារនៃកិច្ចព្រមព្រៀងដែលចែងអំពីកិច្ចសហការរវាង ស.ច.ស។ ស.ច.ស.ជ បានស្នើឱ្យមានការរង់ចាំជាបណ្តោះអាសន្ននូវការតែងតាំងជាផ្លូវការដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជាជូន ស.ច.ស.អ.ប ដើម្បីក្លាយខ្លួនជា ស.ច.ស.អ ពេញសិទ្ធិ។[73]

៤៩. ទោះបីជាយ៉ាងនេះក្តី ស.ច.ស.អ.ប **Laurent Kasper-ANSERMET** បានបន្តបំពេញកិច្ចស៊ើបសួរមួយចំនួនដូចជា ការជូនដំណឹងបទចោទដល់ជនសង្ស័យ ការដាក់ឱ្យស្ថិតនៅក្រោម ការពិនិត្យ ការសាកសួរសាក្សី ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ជាអាទិ៍



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៥០. ចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា ក្រោយពីមានការស្នើដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ (មាត្រា ២៦ នៃច្បាប់ស្តីពី អ.វ.ត.ក.)។ វិធាន ៧ នៃវិធានផ្ទៃក្នុង ចែងអំពីនីតិវិធីលាលែង ដោយយោងដល់បទប្បញ្ញត្តិមួយចំនួននៃច្បាប់ និងកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក។ មាត្រា ១១ ថ្មី នៃច្បាប់ស្តីពី អ.វ.ត.ក បង្ហាញថា ចៅក្រមអន្តរជាតិបម្រុងត្រូវតែងតាំងផងដែរដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ មាត្រា ៤៦ ថ្មី នៃច្បាប់ស្តីពី អ.វ.ត.ក បានចែងយ៉ាងច្បាស់ថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវតែងតាំងចៅក្រមដើម្បីបំពេញនូវកន្លែងទំនេរនេះ កើតមានក្នុងករណីដែលចៅក្រមអន្តរជាតិពេញសិទ្ធិបានឈាយប់ពីមុខដំណែង ដែលការណ៍នេះខុសស្រឡះពីមាត្រា ១១ ថ្មី ដែលចែងឲ្យប្រធានអង្គជំនុំជម្រះ តែងតាំងចៅក្រមបម្រុងជំនួសចៅក្រមពេញសិទ្ធិនាពេលគាត់អវត្តមាន (មាត្រា ១១ ថ្មី)។ មាត្រា ៤៦ ថ្មី តម្រូវឲ្យមានការតែងតាំងចៅក្រមបម្រុងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីឲ្យក្លាយជាចៅក្រមពេញសិទ្ធិ។ ការតែងតាំងលោកចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង **Siegfried BLUNK, Mark Brian HARMON** និង **Michael BOHLANDER** ជាចៅក្រមពេញសិទ្ធិអនុលោមតាមមាត្រា ៤៦ ថ្មី នេះ មុននឹងបំពេញការងារនៅ អ.វ.ត.ក។ ស.ច.ស.ជ បានធ្វើសេចក្តីប្រកាសព័ត៌មានដោយបានបដិសេធនូវរាល់សកម្មភាពការងាររបស់ ស.ច.ស.អ.ប **Laurent Kasper-ANSERMET** និងអះអាងថា កិច្ចទាំងនោះគ្មានសុពលភាពតាមច្បាប់ទេ ដោយសារវាត្រូវបានធ្វើឡើងនៅខណៈពេលដែល ស.ច.ស.អ.ប មិនទាន់ក្លាយជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិពេញសិទ្ធិ។ អាស្រ័យហេតុនេះ ស.ច.ស.ជ ទាំងក្នុងជំនួបពិភាក្សាផ្ទាល់ និងក្នុងកំណត់ត្រាខ្វែងយោបល់ពាក់ព័ន្ធនឹងឯកសារសំណុំរឿង បានប្រកាន់ជំហរមិនទទួលយកឯកសារបង្កើតដោយ ស.ច.ស.អ.ប មកដាក់ក្នុងសំណុំរឿងទេ ហើយការចុះលេខឯកសារនៃសំណុំរឿងលេខ ០០៤ ត្រូវរាប់បន្តពីឯកសារចុងក្រោយ មុនការលាលែងរបស់ចៅក្រម **Siegfried BLUNK**។ ក្នុងន័យនេះ ដីកាដំណោះស្រាយនឹងមិនចាត់ទុកឯកសារបង្កើតឡើងដោយ ស.ច.ស.អ.ប **Laurent Kasper-ANSERMET** មានតម្លៃគតិយុត្តឡើយ។



ការិយាល័យសហចៅក្រមស៊ើបអង្កេត * E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

## ៤- នីតិវិធីនៃការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ

៥១. ផ្អែកលើវិធានផ្ទៃក្នុង ការស៊ើបសួរត្រូវធ្វើឡើងតែលើអង្គហេតុដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ទោះបីជាយ៉ាងនេះ ការសម្រេចបើកការស៊ើបសួរលើបុគ្គលណាមួយជាឆន្ទានុសិទ្ធិរបស់ ស.ច.ស។ វិធាន ៥៥ (៤) នៃវិធានផ្ទៃក្នុង បានចែងពាក់ព័ន្ធនឹងបញ្ហានេះ "*សហចៅក្រមស៊ើបអង្កេតមានអំណាចបើកការស៊ើបសួរប្រឆាំងនឹងជនទាំងឡាយ ដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតអាចបើកកិច្ចស៊ើបសួរផងដែរ ចំពោះបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់ដែលបញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសរបន្ថែម*"។[74]

៥២. ទោះបីជាវិធាន ៥៥ នៃវិធានផ្ទៃក្នុង បានចែងតម្រូវកម្រិតភ័ស្តុតាង "តម្រុយច្បាស់លាស់និងស៊ីសង្វាក់" សម្រាប់ករណីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យលើបុគ្គល ដែលគ្មានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមក្តី ក៏កន្លងមក ស.ច.ស បានប្រើប្រាស់កម្រិតភ័ស្តុតាងនេះ ដើម្បីដាក់ជនសង្ស័យដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឱ្យស្ថិតនៅក្រោមការពិនិត្យ។ កម្រិតភ័ស្តុតាងនេះ មិនខ្ពស់ដូចជាកម្រិតភ័ស្តុតាងសម្រាប់ដាក់ពិរុទ្ធភាព (ហួសពីវិមតិសង្ស័យ) ដែលសហព្រះរាជអាជ្ញាត្រូវបង្ហាញទេ។[75] ក៏ប៉ុន្តែ កម្រិតភ័ស្តុតាងនេះក៏មិនទាបដែរ ដោយវាតម្រូវឱ្យមានភ័ស្តុតាងច្រើនច្បាស់លាស់ និងគាំទ្រគ្នាទៅវិញទៅមក ដើម្បីបង្ហាញថា ជនសង្ស័យជាជនទទួលខុសត្រូវក្នុងការប្រព្រឹត្ត ព្រមទាំងមានភាពប្រាកដប្រជាខ្ពស់ថា បុគ្គលណាមួយនោះទទួលខុសត្រូវ ហើយនឹងត្រូវបញ្ជូនទៅជំនុំជម្រះសេចក្តីនាពេលអនាគត។[76]

៥៣. នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ចៅក្រមស៊ើបសួរមិនអាចបញ្ជូនជនណាម្នាក់ទៅជំនុំជម្រះ ដោយមិនបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យជាមុនឡើយ។ យុត្តិសាស្ត្ររបស់តុលាការកំពូលបារាំងធ្លាប់បានបញ្ជាក់ដែរថា "*ចៅក្រមស៊ើបសួរមុននឹងចេញដីកាដំណោះស្រាយជាការលើកលែងការចោទប្រកាន់ ចៅក្រមស៊ើបសួរពុំចាំបាច់ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ*



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

*ការស្លាប់ចម្លើយជននោះឡើយ ប្រសិនបើចៅក្រមស៊ើបសួរយល់ថាពិរុទ្ធភាពនៃជននោះនឹងមិនត្រូវបានរកឃើញ*"។[77]

៥៤. ជនត្រូវចោទមានសិទ្ធិចម្បងមួយចំនួនក្នុងដំណើរការសំណុំរឿងក្តីព្រហ្មទណ្ឌដូចជា សិទ្ធិមានមេធាវីដូចមានចែងក្នុងសេចក្តីប្រកាសជាសកល កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយមួយចំនួនទៀតដែលកម្ពុជាជាភាគី។[78] ការមិនដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យលើបុគ្គលណាមួយ ហើយចុងបញ្ចប់បញ្ជូនគាត់ទៅជំនុំជម្រះក្តីអាចបំពារបំពានដល់សិទ្ធិទាំងនេះ ដោយសារជនសង្ស័យមិនមានឱកាសអនុវត្តសិទ្ធិ ជាលទ្ធផលនាំឱ្យសវនាការមិនមានភាពយុត្តិធម៌ទេ។ ការសម្រេចដាក់បុគ្គលជាជនសង្ស័យណាមួយឱ្យស្ថិតនៅក្រោមការពិនិត្យនឹងរុញកិច្ចនៃដំណើរការនីតិវិធីព្រហ្មទណ្ឌឱ្យដើរទៅមុខ ហើយតុលាការនឹងចំណាយពេលវេលាព្រមទាំងធនធានដើម្បីបំពេញតាមកិច្ចនីតិវិធីតម្រូវដោយច្បាប់។ ក្នុងករណីចុងបញ្ចប់ ទោះបីបុគ្គលនោះនឹងត្រូវបានលើកលែងចោទប្រកាន់ ដោយសារតុលាការមិនបានរកឃើញនូវការទទួលខុសត្រូវក្តី ក៏តុលាការបានចំណាយពេលវេលា និងធនធានរួចទៅហើយ។ នេះមិនមែនជាវិធីដ៏ប្រពៃឆ្លើយតបនឹងប្រសិទ្ធភាព និងការសន្សំសំចៃនៃដំណើរការតុលាការ (*Judicial Economy*) ទេ។

៥៥. ចំពោះការសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យលើជនសង្ស័យណាម្នាក់ មិនមែនជាកាតព្វកិច្ចចំណងដល់ ស.ច.ស ឱ្យត្រូវតែប្រតិបត្តិតាមជានិច្ចនោះទេ។ អាស្រ័យហេតុនេះ ដោយឈរលើគោលការណ៍ឯករាជ្យ និងមិនលំអៀង ជាពិសេសគោលការណ៍សច្ចធារណ៍នៃនិរទោស (ការសន្មតជាមុនថាគ្មានទោស) ដែលការពារដល់សិទ្ធិនិងផលប្រយោជន៍ជនសង្ស័យ ស្របតាមគោលការណ៍នៃការទទួលបានការជម្រះក្តីដោយយុត្តិធម៌[79] បើទោះបីជា ស.ច.ស បានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យក្តី ស.ច.ស នៅតែអាចលើកលែងការចោទប្រកាន់បាន ប្រសិនបើល័ក្ខខ័ណ្ឌទាំងឡាយដើម្បីបញ្ជូនជនត្រូវចោទទៅទទួលការជំនុំជម្រះមិនត្រូវបានរកឃើញ។ ការលើកលែងចោទប្រកាន់អាចធ្វើឡើងចំពោះរាល់គ្រប់អង្គហេតុទាំងអស់ដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទ។ បន្ថែមពីលើនេះ ការដាក់បុគ្គលណាមួយឱ្យស្ថិតនៅក្រោមការពិនិត្យ ក៏មិនតម្រូវឱ្យចៅក្រមឃុំខ្លួនបុគ្គលនោះដែរ ប្រសិនបើការឃុំខ្លួនមិនមែនជាការចាំបាច់។

## ជំពូក៣.　ការកត់សម្គាល់ឃើញអំពីអង្គហេតុ

### ១- អំពីគោលនយោបាយទូទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ

### ក- ស្ថានភាពទូទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ

៥៦. តាមការចងក្រងជាសៀវភៅក្រោមចំណងជើងថា "ភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" ដែលចេញផ្សាយដោយក្រសួងសិក្សាធិការនៃរបបកម្ពុជាប្រជាធិបតេយ្យនា ឆ្នាំ ១៩៧៧ បង្ហាញថា កម្ពុជាប្រជាធិបតេយ្យមានប្រជាជនសរុបចំនួន ៧.៧០០.០០០ (ប្រាំពីរលាន ប្រាំពីរសែន) នាក់ ដោយក្នុងនោះ ៨០ (ប៉ែតសិប) ភាគរយ ជាកសិករនៅតាមសហករណ៍ និង ២០ (ម្ភៃ) ភាគរយ ជាកម្មករ សហជីព និងជាយុទ្ធជន យុទ្ធនារីនៃកងទ័ពបដិវត្តន៍កម្ពុជា។[80] ហេតុផលទាំងអប្បាមាណនេះ បានបង្កឲ្យមានការបញ្ឆេះកំហឹងវណ្ណៈ[81] ត្រូវបានកើតឡើងយ៉ាងសន្ធោសន្ធៅជាប់ជានិច្ចទៅលើវណ្ណៈសក្តិភូមិ[82] វណ្ណៈនាយទុនដែលជាវណ្ណៈធ្លាប់កាន់អំណាច ដែលត្រូវរងនូវការចោទប្រកាន់ដោយគេបានឃោសនាថា វណ្ណៈទាំងនេះបានជិះជាន់ប្រជាជនជាង ២.០០០ (ពីរពាន់) ឆ្នាំ កន្លងមក ហើយថែមទាំងចោទប្រកាន់ថា នាពេលកន្លងមកបានលក់ក្បាលកញ្ចះចក្រពត្តិនិងបរទេសនិយម ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន និងបក្សពួកយ៉ាងថោកទាបជាទីបំផុត។[83] ការណ៍នេះបានធ្វើឲ្យក្រុមវណ្ណៈជាន់ទាបបានហក់ឡើងទៅឈានជើងចូលរួម និងក្លាយជាផ្នែកមួយដ៏សំខាន់ក្នុងការកំណត់ជោគវាសនាកម្ពុជាទាំងមូល។[84]

៥៧. ក្រោយពីបានផ្តួលរលំរបបសាធារណៈរដ្ឋខ្មែរ (របប លន់ នល់) របបកម្ពុជាប្រជាធិបតេយ្យត្រូវបានចាប់បដិសន្ធិឡើង និងធ្វើការដឹកនាំប្រទេសជាផ្លូវការចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[85] ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ក្រោមគោលដៅធ្វើការប្រែក្លាយប្រទេសកម្ពុជាទាំងមូលឲ្យទៅជាប្រទេសដែលដើរតាមមាគ៌ាបដិវត្តន៍សង្គមនិយមពិតប្រាកដមួយក្នុងលោកនាចុងសតវត្សទី២០។[86] ការធ្វើបដិវត្តន៍នាពេលនោះ ដើម្បីរំលាយចោលទាំងស្រុងនូវវណ្ណៈនាយទុន វណ្ណៈមូលធន វណ្ណៈសក្តិភូមិ និងពួកប្រតិកិរិយា ដើម្បីឈានទៅសង្គ្រោះប្រជាជនក្រីក្រដែលត្រូវគេជិះជាន់ ដោយបដិសេធចោលទាំងស្រុងនូវការចូលរួមពីសំណាក់



CO-INVESTIGATING ... D.C.C.C

បញ្ញវន្ត និងអ្នកចេះដឹងឲ្យអស់ពីផ្ទៃប្រទេសកម្ពុជាទាំងមូល បើសូម្បីតែនិស្សិតដែលបានកំពុងសិក្សានៅបរទេសក៏ត្រូវបានហៅយកមកសម្លាប់ដែរ។[87]

៥៨. ម្យ៉ាងវិញទៀត នៅមានគោលដៅដ៏សំខាន់មួយទៀតដែរ ដោយជម្រុញ និងធ្វើការលើកកម្ពស់វណ្ណៈជាន់ទាបរួមមាន កសិករ កម្មករ ប្រជាជនក្រីក្រ ហើយបើសូម្បីតែអនក្ខរជនមួយចំនួនធំជាអាទិ៍ បែរជាត្រូវបានទទួលការចាត់តាំងឲ្យធ្វើការគ្រប់គ្រងនិងដឹកនាំ ស្ទើរតែគ្រប់តួនាទីនៅតាមឋានានុក្រមរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេស។[88]

៥៩. ដើម្បីឈានទៅសម្រេចនូវវត្ថុបំណងដ៏សំខាន់បំផុតមួយនេះ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានដាក់ចេញនូវគោលនយោបាយជម្លៀសប្រជាជនទាំងអស់[89] ចេញពីតាមបណ្ដាទីក្រុង និងទីប្រជុំជនឲ្យទៅនៅតាមទីជនបទនានា[90] ដើម្បីចូលរួមធ្វើមហាកសិកម្ម[91] ដែលជាវិស័យដ៏សំខាន់បំផុតមួយក្នុងជំនឿលើវិស័យនេះនឹងក្លាយជាមូលដ្ឋានគ្រឹះ ដើម្បីធ្វើការលើកកម្ពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិឲ្យរីកធំធាត់ជាអតិបរមាក្រោមការគ្រប់គ្រងដឹកនាំ និងការផ្ដល់ការណែនាំយ៉ាងសកម្មពីបក្សផ្ទាល់[92] ដោយឈរលើគោលជំហរ "**ឯករាជ្យ ម្ចាស់ការខ្លួនទីពឹងខ្លួន**"។[93]

៦០. មុនឆ្នាំ១៩៧៥ បក្សធ្វើការជម្លៀសប្រជាជនចេញពីតំបន់មួយចំនួនដែលរំដោះបាន ហើយដែលស្ថិតនៅក្រោមការត្រួតត្រារបស់ខ្លួន។[94] បន្ទាប់មក គេឃើញមាននៅតាមតំបន់រំដោះនីមួយៗ បក្សបានតម្រូវឲ្យប្រជាជនផ្ដើមការរស់នៅតាមបែបសហករណ៍និយម ដោយអ្វីៗទាំងអស់ត្រូវតែជាលក្ខណៈរួមទោះយ៉ាងដូចជា ការរស់នៅ ការធ្វើស្រែចំការ ការប្រមូលភោគផល ការហូបចុក ជាអាទិ៍។ ជារួមបក្សជាអ្នកគ្រប់គ្រង និងប្រមូលផលដែលទទួលបានយកដាក់រួម ទើបបានបែងចែកត្រឡប់វិញ។[95] មិនតែប៉ុណ្ណោះ បក្សបានគ្រប់គ្រងរាល់សកម្មភាពផ្សេងៗរបស់ប្រជាជនរាប់ទាំងការរស់នៅរបស់ប្រជាជន ការប្រាស្រ័យទាក់ទងគ្នា និងការធ្វើដំណើររបស់ប្រជាជនជាដើម។[96]

៦១. មានការលើកឡើងនូវកាលបរិច្ឆេទយ៉ាងច្បាស់លាស់ថា សហករណ៍នេះត្រូវបានបង្កើតដំបូងនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៣ នាពេលនោះប្រជាជនមានការពេញចិត្តមែនទែន។[97] ជាក់ស្ដែង បក្សបានសម្រេចជាផ្លូវការលើបញ្ហាត្រូវចាត់តាំងឲ្យមានជាសហករណ៍[illegible]



E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

២០ ខែ ឧសភា ឆ្នាំ ១៩៧៣។[98] ចំពោះការរៀបចំជាសហករណ៍ធ្វើស្រែ និងប្រមូលផលរួមនេះឃើញថា សម្រាប់កសិករដែលមិនសូវឬគ្មានដីធ្លី មានការត្រេកអរមែនទែន រីឯ កសិករដែលមានដីស្រែច្រើនហិចតា បែរជាខកចិត្តនឹងការកំណត់របស់បក្ស ហើយហាក់ដូចជាមានអារម្មណ៍តានតឹងជាមួយពាក្យថាសហករណ៍នេះ។[99]

៦២. ជាបន្តបន្ទាប់មក មូលដ្ឋានណាមួយត្រូវរំដោះបានភ្លាម គេត្រូវរៀបចំជា "**សហករណ៍**"[100] ក្រោមហេតុផលថា ភាពជាសមូហភាពជាទស្សនៈទានដ៏មានតម្លៃ និងមានលក្ខណៈមនុស្សធម៌ ដោយមនុស្សគ្រប់រូបគួរតែទទួលបានបរិមាណម្ហូបអាហារដូចៗគ្នា។[101] ក្រោមទម្រង់ជាសហករណ៍រួមលើការហូបចុកនេះ ប្រជាជនម្នាក់ៗត្រូវទទួលបានអាហារ ២ (ពីរ) ពេលក្នុង ១ (មួយ) ថ្ងៃដោយបបរ ១ (មួយ) ពេល និងបាយ ១ (មួយ) ពេល។[102] ហេតុដូច្នេះហើយ ទើបសហករណ៍នាពេលនោះត្រូវគេចាត់ទុកថាជាមូលដ្ឋានបង្អែកបដិវត្តន៍ដ៏រឹងមាំ ហើយដែលកើតមានឡើងជាបន្តបន្ទាប់នៅទូទាំងប្រទេស ក្នុងការឈានទៅទទួលបានជ័យជម្នះនៅថ្ងៃ ១៧ ខែ មេសា។[103]

៦៣. ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ថ្នាក់ដឹកនាំក្នុងរបបសាធារណៈរដ្ឋខ្មែរកន្លងមកគ្រប់ជាន់ថ្នាក់ ត្រូវបានដកចេញស្ទើរទាំងអស់ បើសូម្បីតែតំណែងថ្នាក់ភូមិ ឃុំ ក៏ត្រូវគេដកចេញឲ្យទៅជីកប្រឡាយ លើកទំនប់ ធ្វើស្រែ និងឃ្វាលគោ ជាដើម។[104] រីឯ សិស្ស និស្សិត បញ្ញវន្ត សាស្ត្រាចារ្យ និង កងទ័ព ជាអាទិ៍ ត្រូវគេចាប់ឃុំឃាំង និងសម្លាប់ ជាបន្តបន្ទាប់ស្ទើរតែទាំងអស់។[105] បើនិយាយអំពីបញ្ហាសិក្សាធិការ និងអប់រំនាពេលនោះ គ្មានទេគ្រឹះស្ថានអប់រំ គ្មានទេសាលារៀន គ្មានទេគ្រូបង្រៀន។[106] ទន្ទឹមនឹងនោះដែរ ក្រោមការដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ បានធ្វើការផ្លាស់ប្តូរវាក្យស័ព្ទភាសាខ្មែរយ៉ាងគំហុក ស្ទើរតែធ្វើទាំង "**បដិវត្តភាសាខ្មែរ**" ជាមួយនឹងវត្តមាននៃការប្រើប្រាស់ពាក្យពេចន៍ថ្មីៗជាច្រើន។[107] រីឯ ជួរថ្នាក់ដឹកនាំស្ទើរតែគ្រប់ជាន់ថ្នាក់មិនបានលើកគំនិតល្អៗ ដើម្បីថ្លែងក្នុងអង្គប្រជុំនោះទេ ហើយអ្វីដែលគេតែងតែលើកពេលប្រជុំប្រាប់ប្រជាជនមានត្រឹមតែថា "*យើងត្រូវពង្រឹងគោលជំហរ និងខំប្រឹងធ្វើការងារឲ្យបានល្អ* "។[108] ទង្វើផ្ទុត់គំនិតក្នុងការផ្លាស់ប្តូររបត់នៃការដឹកនាំបែបនេះ បាននាំជោគវាសនានាវាកម្ពុជាធ្លាក់ចុះក្នុងមហាគ្រោះមហន្តរាយដែលត្រូវបានគេចារក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិ។

## ខ- របបដឹកនាំ

៦៤. រចនាសម្ព័ន្ធរដ្ឋបាលរបបនេះចាប់ពីថ្នាក់លើចុះមកថ្នាក់ក្រោម និងដល់ថ្នាក់មូលដ្ឋានត្រូវបានបែងចែកយ៉ាងជាក់លាក់លើការសម្រេចចាត់ចែង និងការគ្រប់គ្រង ការងារដែលមានទម្រង់ជា "**សមូហភាពនិយម**"[109] ក្រោមលេសថា ទាល់តែកសាងប្រទេសដោយផ្អែកលើសមូហភាពយ៉ាងដូច្នេះ ទើបអាចធ្វើឱ្យកម្ពុជាអភិវឌ្ឍឆាប់រហ័សគ្មានគូប្រៀប។[110] ម្យ៉ាងវិញទៀត ចំពោះគោលនយោបាយបក្ស ដែលត្រូវបានចេញម្តងៗ ត្រូវបានចូលរួមធ្វើការផ្សព្វផ្សាយឱ្យដល់ប្រជាជននៅទូទាំងផ្ទៃប្រទេស តាមរយៈការប្រជុំកោះប្រជុំនូវគ្រប់កម្រិតចាប់ពីថ្នាក់លើចុះទៅថ្នាក់ក្រោម តាមឋានានុក្រមនៃការដឹកនាំពីមជ្ឈិម ភូមិភាគ តំបន់ស្វយ័ត តំបន់ ស្រុក ឃុំ ភូមិ និងសហករណ៍ ជាដើម។[111]

៦៥. តាមការដឹកនាំបែបកុម្មុយនីស្តនៃរបបនេះ អ្វីៗទាំងអស់ត្រូវបានគេកំណត់យកបក្សជាអ្នកមានឧត្តមានុភាពខ្ពស់បំផុតលើសគេទាំងអស់ ដោយបក្សបានដើរតួជាស្ថាប័នដ៏មានឥទ្ធិពលផុតលេខតែមួយគត់ ហើយដែលត្រូវបានគេស្គាល់ថា "**គណៈកម្មាធិការមជ្ឈិមបក្ស**"។[112] គណៈកម្មាធិការនេះមានសមាជិកប្រមាណ ៣០ (សាមសិប) រូប ត្រូវធ្វើការសម្រេចលើការងារស្នូលសំខាន់ៗ ពាក់ព័ន្ធជោគវាសនារបស់ប្រទេសជាតិ។[113] ខណៈ គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាមានសមាជិកចំនួន ៧ (ប្រាំពីរ) រូបមាន ប៉ុល ពត, នួន ជា, សោ ភឹម, តា ម៉ុក, អៀង សារី, វន វ៉េត, និង សុន សេន។[114] ជាក់ស្តែង ដើម្បីធានាបាននូវដំណើរការប្រតិបត្តិអំណាចប្រចាំថ្ងៃ ការងារនេះត្រូវស្ថិតនៅក្នុងកណ្តាប់ដៃ "**គណៈកម្មាធិការអចិន្ត្រៃយ៍**"[115] បើទោះបីជាមានការលើកឡើងដោយអតីតប្រធានគណៈប្រធានរដ្ឋ[116] ខៀវ សំផន ហៅ ហែម បាននិយាយថា ជាគោលការណ៍អង្គការសំខាន់ជាងគេគឺ "**គណៈកម្មាធិការមជ្ឈិម**"។[117]

## គ- កសិកម្ម-សេដ្ឋកិច្ច

៦៦. ក្នុងវិស័យកសិកម្មនាឆ្នាំ១៩៧៦ បក្សបានកំណត់ទិសដៅ និងដាក់ចេញជាវិធានការស្នូលក្នុងការបង្កើនទិន្នផលស្រូវឱ្យបាន[118] "**បីតោនក្នុងមួយហិចតា**"[119] លើទំហំដីស្រែប្រមាណ ១.៥០០.០០០ (មួយលានប្រាំសែន) ហិចតា នៅទូទាំងប្រទេស ដោយបក្សរំពឹងថានឹង...



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION*

បានទិន្នផលស្រូវរហូតដល់ ៤.៥០០.០០០ (បួនលានប្រាំសែន) តោន ត្រឡប់មកវិញ។[120] ជាក់ស្តែង ស្ទើរតែគ្រប់ក្នុងអង្គប្រជុំនីមួយៗនៅតាមមូលដ្ឋាន ជារឿយៗ គេតែងលើកឡើងថា **"ដីមួយចង្កាម ដាំមិនឱ្យសល់ដី"**។[121] សាក្សីដែលជាអតីតអ្នកវាយអង្គុលីលេខបានអះអាងថា *"ឯកសារភាគច្រើននិយាយពីការធ្វើស្រែឱ្យបានបីតោនក្នុងមួយហិចតា"*។[122] ជាក់ស្តែង ជាមួយនឹងទិន្នផលដែលប្រមូលបានភាគច្រើនបំផុតត្រូវតែប្រគល់ជូនបក្សជាដាច់ខាតដោយខានពុំបាន សម្រាប់បក្សនាំចេញទៅក្រៅប្រទេស។[123]

៦៧. ថ្នាក់ដឹកនាំមូលដ្ឋានត្រូវបានតម្រូវឱ្យធ្វើស្រូវឱ្យបានចំនួន ៣ (បី) តោន ក្នុង ១ (មួយ) ហិចតា។ នេះគឺជាគោលនយោបាយចម្បងមួយ ដែលត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពទូទាំងប្រទេស។ ការណ៍នេះបានធ្វើឱ្យប្រធានសហករណ៍តាមមូលដ្ឋានមួយចំនួនបានបញ្ជូនទិន្នផលស្រូវជាច្រើនទៅថ្នាក់លើ ដើម្បីធ្វើឱ្យបក្សដែលជាអង្គការថ្នាក់លើមើលឃើញថាខ្លួនបានខិតខំប្រឹងប្រែង និងស្មោះត្រង់ជាមួយបក្សដោយឥតងាករេ ខណៈប្រជាជនក្នុងមូលដ្ឋានខ្លួនខ្វះខាតអង្ករបរិភោគជាប្រចាំ។[124] ការធ្វើដូចនេះ ដោយសារខ្លាចអង្គការថ្នាក់លើធ្វើការចាប់ខ្លួនអ្នកនោះយកទៅឃុំឃាំង និងសម្លាប់ចោល។ ជាផលវិបាក ប្រជាជនជួបគ្រោះអត់ឃ្លានស្ទើរពេញផ្ទៃប្រទេស ហើយបានបង្កឱ្យបញ្ហាប្រឈមនេះរុញច្រានឱ្យប្រជាជនកាន់តែត្រូវទទួលរងនូវអំពើអមនុស្សធម៌ផ្សេងៗដូចទាសករ។[125] បញ្ហានេះបានបង្កចេញជាព្យសនកម្មផ្សេងៗ ដូចជាប្រជាជនបានស្លាប់អស់ជាច្រើននាក់ដោយការអត់អាហារបរិភោគ និងជំងឺផ្តងជាដើម។

៦៨. រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានតាំងខ្លួនឯងជាអ្នកដែលមានទម្រង់ដឹកនាំអស្ចារ្យ និងខុសប្លែកពីគេក្នុងលោក។[126] បើសូម្បីតែ អៀង សារី ជាអតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស បានលើកឡើងថា **"បដិវត្តន៍ខ្មែរ គ្មានប្រើគំរូណាមួយពីមុនឡើយ ហើយអ្វីដែលយើងកំពុងសម្រេចទាំងនេះ មិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រពីមុននៅឡើយទេ"**។[127] បើនិយាយពីគោលជំហរវិញ កម្ពុជាប្រជាធិបតេយ្យមានលក្ខណៈដាច់ខាតបំផុត[128] ហើយប្រជាជនត្រូវគេបង្ខំឱ្យធ្វើការងារតាមមូលដ្ឋាន ការដ្ឋាន ទំនប់ ប្រឡាយ ក្នុងស្ថានភាពលំបាកក្រៃលែង[129] ហើយគ្មានការសម្រាកឱ្យបានគ្រប់គ្រាន់ទេ។[130] ចំពោះស្ថានភាពប្រជាជនដែលបានធ្វើការតាមការដ្ឋាន មានការលំបាកស្ទើររកពាក្យនិយាយមិនឃើញ ការហូបចុកក៏មិនគ្រប់គ្រាន់ថែមទៀត សូម្បីតែ ស្លឹកឈើ បន្លែព្រៃ និងដើមចេក ក៏[illegible]



INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * C.E.T.C * C.E.T.C

បានក្លាយជាអាហារចិញ្ចឹមជីវិតមនុស្សដែរ។[131] ការណ៍នេះបានធ្វើឱ្យរាងកាយមនុស្សស្ទើរតែគ្រប់ៗគ្នាមានសភាពស្គមស្គាំង រហូតមានអ្នកខ្លះសល់តែស្បែកដណ្តប់ឆ្អឹងដូច "ស្លាប់ទាំងរស់" ឬ "ការរស់ដើម្បីបន្តជីវិត"។[132] បើទោះបីជាគោលនយោបាយដែលបានដាក់ចេញថា ត្រូវលើកកម្ពស់ស្មារតីសន្សំសំចៃបដិវត្តន៍ខ្ពស់បំផុតគឺ *"សន្សំសំចៃតាំងពីអំបិលមួយគ្រាប់ ស្រូវមួយគួរ ឬកូនខ្មៅខ្លងតូចតាចមួយឡើងទៅ"*។[133]

៦៩. បើនិយាយពីភ្លឺស្រែនាពេលនោះ ត្រូវបានអង្គការតម្រូវឱ្យប្រជាជនលើកភ្លឺស្រែឱ្យបានកម្ពស់ ១ (មួយ) ម៉ែត្រ ខ្នងភ្លឺស្រែ ១ (មួយ) ម៉ែត្រ និងបាតក្រោមឱ្យបានប្រវែង ១,៥ (មួយកៀសប្រាំ) ម៉ែត្រ ដោយក្នុងប្រជាជនម្នាក់ត្រូវលើកឱ្យបានប្រវែង ១០ (ដប់) ម៉ែត្រ ក្នុង១ (មួយ) ថ្ងៃ។[134] នាពេលនោះ បើសូម្បីកុមារអាយុចាប់ពី ៦ (ប្រាំមួយ) ទៅ ១០ (ដប់) ឆ្នាំ ក៏ត្រូវគេបង្ខំឱ្យធ្វើការដែរ ខណៈដែលឪពុកម្តាយគ្រប់រូបមិនហ៊ានឃាត់កូនកុំឱ្យទៅធ្វើការតាមការចាត់តាំងរបស់អង្គការនោះទេ ដោយឪពុកម្តាយត្រូវតែឱ្យកូនរបស់ខ្លួនទៅធ្វើការដោយខានពុំបានជាដាច់ខាត។[135]

៧០. អំពីបញ្ហាសេដ្ឋកិច្ចជាតិទាំងម៉ាក្រូសេដ្ឋកិច្ច និងមីក្រូសេដ្ឋកិច្ចត្រូវប្រឈមមុខនឹងការដាំក្បាលចុះយ៉ាងគំហុកដោយហេតុថាជាប្រទេសជាតិនឹងគេដែរបែរជាគ្មានការចរាចររូបិយវត្ថុជាតិទាំងស្រុង[136] ក្រោមលេសដ៏សាមញ្ញបំផុតថា ការបើកឱ្យមានការប្រើប្រាស់លុយជាមធ្យោបាយបំរើសេដ្ឋកិច្ចទីផ្សារនោះនឹងនាំឱ្យមានការជិះជាន់ គាបសង្កត់ និងជាពិសេសការឈានទៅប្រព្រឹត្តអំពើពុករលួយជាដើម ដែលរបបនេះចាត់ទុកថាជាប្រភពបញ្ហាស្នូលដ៏សំខាន់បំផុតក្នុងការបង្កអស្ថិរភាពដល់ការគ្រប់គ្រងនិងដឹកនាំប្រទេស។[137] ខណៈដែលវត្តមាននៃការចរាចរលុយនេះ ត្រូវបានអ្នកសេដ្ឋកិច្ចវិទូក្នុងលោកចាត់ទុកថា ជាមូលដ្ឋានគ្រឹះចម្បង និងតែមួយគត់សម្រាប់ជាជន្ទល់ដ៏រឹងមាំសម្រាប់សេដ្ឋកិច្ចប្រទេស។

៧១. អង្គប្រជុំនាថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥ នាពហុកីឡាដ្ឋានជាតិអូឡាំពិក បានសម្រេចថាគ្មានទីផ្សារ និងការចាយលុយ។[138] ជាក់ស្តែង សក្ខីកម្មសាក្សីជាអតីតកម្មាភិបាលដែលបានចូលរួមវគ្គនយោបាយបក្សដែលមាន ប៉ុល ពត និង នួន ជា ជាអ្នកឧទ្ទេសនាមបានអះអាងថា *"អ្នកទាំងពីរនេះនិយាយពីនយោបាយរៀបចំសហករណ៍ ហាមមិនឱ្យចាយលុយ [illegible] ទីផ្សារ និងវត្តអារាម ហើយថ្ងៃក្រោយអាចនឹងបើកឱ្យមានវិញ"*។[139] នៅឆ្នាំ ១៩[illegible]



INVESTIGATING JUDGES *CO-JUGES D'INSTRUCTION* E.C.C.C * C.E.T.C

ហ៊ូ នឹម ត្រូវចាប់យកទៅសម្លាប់ ដោយសារគាត់មានយោបល់លើការស្នើឱ្យចាយលុយ និងបើកឱ្យមានទីផ្សារឡើងវិញ ដែលផ្ទុយការសម្រេចកន្លងមករបស់ ប៉ុល ពត, នួន ជា, និង តាម៉ុក ជាអាទិ៍។[140] ប៉ុន្តែ ក្រោយមកនៅចុងឆ្នាំ១៩៧៨ មានសេចក្តីសម្រេចឱ្យមានរូបិយវត្ថុ និងទីផ្សារដែលមិនទាន់ត្រូវបានអនុវត្តចេញជារូបរាងផង របបក៏បានដួលរលំ។[141]

## ឃ- សាសនា និងសេរីភាពបុគ្គល

៧២. ពាក់ព័ន្ធបញ្ហាជំនឿសាសនា បើទោះបីជាព្រះពុទ្ធសាសនាជាសាសនារបស់ជាតិអស់រយៈពេលជាយូរលង់ណាស់មកហើយក៏ពិតមែន ប៉ុន្តែ ការដឹកនាំរបបនេះបែរជាចាប់ផ្សឹកព្រះសង្ឃដោយបង្ខំ[142] បើបដិសេធនឹងត្រូវសម្លាប់[143] រីឯបណ្តាវត្តអារាមស្ទើរតែទាំងអស់ត្រូវរងនូវការបំផ្លិចបំផ្លាញយ៉ាងដំណំ។[144] ក្នុងនាមជាប្រមុខដឹកនាំ ប៉ុល ពត បានអនុវត្តលទ្ធិម៉ាកដាច់ខាតទៅលើសាសនាទាំងអស់នៅកម្ពុជា មិនមែនត្រឹមតែព្រះពុទ្ធសាសនានោះទេ។[145] ជាក់ស្តែង សក្ខីកម្មសាក្សីជាច្រើនរូបអះអាងស្រដៀងៗគ្នាថា គ្រប់សាសនាទាំងអស់ពិតជាត្រូវបានហាមឃាត់ ខណៈដែលវត្តអារាមទាំងឡាយបែរជាត្រូវប្រែក្លាយជារោងបាយ កន្លែងចិញ្ចឹមសត្វ មន្ទីរឃុំឃាំង និងកន្លែងសម្លាប់មនុស្ស ជាដើម។[146] រហូតដល់សាក្សីមួយរូបបានលើកឡើងចំៗបញ្ហាថា *"ពេលនោះគ្រប់សាសនាទាំងអស់ត្រូវបានបំបាត់ចោល គឺមានតែបក្សកុំមុយនីស្តមួយទេដែលត្រូវគោរព។ បក្សកុំមុយនីស្តស្អប់ព្រះសង្ឃ ... ជាងគេ"*។[147] លើសពីនេះ អាចនិយាយបានថា របបកម្ពុជាប្រជាធិបតេយ្យជារបបជាក់ស្តែងនិយមខណៈដែលរបបនេះប្រកាន់គោលជំហរថា "ពួកគេមិនជឿលើហោរាសាស្ត្រទេ"។[148]

៧៣. កម្ពុជាប្រជាធិបតេយ្យបានធ្វើការបែងចែកមនុស្សទៅតាមវ័យ តាមភេទ ជាដើម ហើយតម្រូវឱ្យរស់នៅ និងធ្វើការដោយឡែកៗពីគ្នា ទៅតាមការចាត់តាំងរបស់អង្គការ។[149] ចំពោះអ្នកដែលមានវ័យចំណាស់ គេមិនឱ្យទំនេរទេ ដោយត្រូវមានកាតព្វកិច្ចមើលក្មេងតូចៗ ដោយមូលហេតុឪពុកម្តាយត្រូវរវល់ការងារតាមការដ្ឋាន។[150] បើសូម្បីតែកុមារៗក៏ត្រូវគេបង្ខំឱ្យធ្វើការងារ ដើររើសគួរស្រូវ[151] ឃ្វាលគោ[152] និងប្រមូលអាចម៍គោសម្រាប់ធ្វើជី[153] ហើយពេលទំនេរត្រូវទទួលការអប់រំបដិវត្តន៍។[154] មនុស្សពេញវ័យត្រូវបានគេចាត់ទុកជាកម្លាំងស្រួច ឬ អ្នកមានកម្លាំងខ្លាំង ត្រូវតែចូលរួមឱ្យបានខ្លាំងក្លាក្នុងការធ្វើស្រែ[155] ...

ដាំដំណាំ និងដាំបន្លែ អ្នកខ្លះរែកដី ជីកប្រឡាយ[156] លើកទំនប់[157] ជាដើម។ បើនិយាយពីបញ្ហាធារាសាស្ត្រវិញ បក្សបានឃោសនាថា **"យើងមើលការប្រែប្រួលតែ ២ (ពីរ) ឆ្នាំ នេះគឺលឿនណាស់ប្រៀបធៀបនឹង ១០០ (មួយរយ) ឆ្នាំមុន គ្មានអាងទឹកដូច្នេះឯណាទេ"**។[158]

៧៤. លើសពីនេះទៀត នាពេលនោះប្រជាជនគ្រប់រូបគ្មានសិទ្ធិសេរីភាព[159] គ្មានសិទ្ធិទទួលបានព័ត៌មាន[160] គ្មានសិទ្ធិធ្វើដំណើរ[161] គ្មានទីផ្សារ[162] គ្មានកម្មសិទ្ធិឯកជន[163] មានមន្ទីរពេទ្យ មណ្ឌលសុខភាព និងថ្នាំព្យាបាលជំងឺមិនគ្រប់គ្រាន់[164] ជាអាទិ៍។ ចំពោះការធ្វើដំណើរមានការលំបាកណាស់ បើសូម្បីតែការធ្វើដំណើរពីភូមិមួយទៅភូមិមួយ មនុស្សគ្រប់រូបត្រូវតែសុំការអនុញ្ញាតជានិច្ចដើម្បីទទួលបានសិទ្ធិធ្វើដំណើរដែលគេស្គាល់ជាទូទៅថាជា "លិខិតដើរផ្លូវ"។[165] នៅពេលការសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាត វាអាស្រ័យទៅលើអារម្មណ៍របស់អ្នកសម្រេច។[166]

៧៥. ជាទូទៅ ប្រសិនបើគ្មានការអនុញ្ញាតពីអង្គការ ប្រជាជនពុំមានសិទ្ធិទៅសួរសុខទុក្ខសាច់ញាតិរបស់ខ្លួននោះទេ។[167] លើសពីនេះទៀត ការអវត្តមានពីកន្លែងរស់នៅ ឬកន្លែងការដ្ឋានធ្វើការជាការប្រឆាំងនឹងអង្គការ។ ជាក់ស្តែង ក្រុមគ្រួសារនីមួយៗមានពេលតិចតួចបំផុតដើម្បីបានជួបជុំសមាជិកគ្រួសាររបស់ខ្លួន។[168] ការនិយាយស្តីក៏ត្រូវបានអង្គការរឹតត្បិតខ្លាំងរហូតដល់មានពាក្យថា **"បើចង់រស់ត្រូវចេះដាំដើមគ"** ដែលស្របតាមពាក្យស្លោកពេញនិយមនាសម័យនោះដែលថា **"រក្សាការសម្ងាត់បានគឺឈ្នះ ៥០ (ហាសិប) ភាគរយ ជាស្រេច"**។[169] ក្រោមកម្រងអត្ថន័យដ៏ខ្លីនេះ បានធ្វើឱ្យប្រជាជនរស់នៅក្នុងភាពភិតភ័យ និងតក់ស្លុតយ៉ាងខ្លាំងជានិច្ចស្ទើរតែគ្រប់វិនាទី ដោយសារការនិយាយខ្លះអាចនាំឱ្យអង្គការហៅទៅអប់រំ ធ្វើទារុណកម្ម ឬចាប់យកទៅសម្លាប់ រាប់ទាំងករណីរិះគន់ ឬរអ៊ូរទាំបញ្ហាការហូបចុកមិនគ្រប់គ្រាន់ និងការងារលំបាកជាដើម។[170] សាក្សីឈ្មោះ ប្រាក់ យុត អតីតលេខាស្រុកកំពង់សៀមបាននិយាយថា *"កាលពីគម្រោងធ្វើទំនប់នៅនិរតី ប្រជាជនមិនអាចប្រកែកនឹងបញ្ហាបានទេ បើប្រកែកនឹងយកទៅអប់រំណែនាំ"*។[171]

៧៦. ដើម្បីសម្រេចតាមទិសដៅរបស់អង្គការ ក្នុងការកសាងប្រទេសនាពេលអនាគតឱ្យខ្លាំងក្លា និងឈានទៅរកការដឹកនាំតាមបែបសង្គមនិយម ដែលសំបូរសប្បាយថ្កុំថ្កើង រុងរឿងយ៉ាង[illegible] ឆាប់រហ័សក្រោមពាក្យស្លោក "មហាលោតផ្លោះមហាអស្ចារ្យ"[172] នោះរបបនេះបាន[illegible]



ECCC * CETC * INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

គោលនយោបាយចម្បងៗរួមមាន ការជម្លៀសប្រជាជន ការប្រព្រឹត្តលើក្រុមពិសេស ការងារ ដោយបង្ខំនៅតាមការដ្ឋាន ការរៀបការដោយបង្ខំ និងការបោសសម្អាត ជាអាទិ៍។ មានពេលខ្លះពាក្យថា "**ខ្មាំង**" សំដៅតែលើអ្នកដែលបានប្រព្រឹត្តកំហុសតិចតួចដូចជា ភ្ជួរស្រែបាក់ផ្លែនង្គ័ល[173] កាប់ដីបាក់ចប[174] ហូបបាយបាក់ស្លាបព្រា[175] ធ្វើឱ្យបែកចានឆ្នាំង[176] ស្ទូងស្រូវខុសពូជ[177] លួចអង្ករ[178] លួចហូបស្ករត្នោត[179] លួចផ្លែដូង[180] លួចហូបពោត[181] លួចដំឡូង[182] លួចបូតស្រូវហូបទាំងឆៅ[183] បើកឡានជាន់ហ្វ្រាំងអូសកង់វែង[184] ទៅធ្វើការយឺត[185] រិះគន់អង្គការ[186] ទាំងអស់នេះ ត្រូវគេចាត់ទុកជាអ្នកចង់បំផ្លិចបំផ្លាញអង្គការដែលត្រូវគេចាប់យកទៅសម្លាប់។[187]

៧៧. ប្រជាជននាពេលនោះឃ្លានស្ទើរស្លាប់រហូតដល់មានការដំណាលថា "**ខ្មោចចេះស៊ីបាយ**" ដោយសារអ្នកសែងខ្មោចយកទៅកប់នោះអត់បានធ្វើការរាយការណ៍ថា អ្នកនោះបានស្លាប់នោះទេ ដើម្បីទុកបើករបបអ្នកដែលស្លាប់ទុកហូបចុកដោយខ្លួនឯងដើម្បីបានរស់។[188]

៧៨. ចំណែកឯ នៅភូមិភាគពាយ័ព្យវិញ កម្មាភិបាលថ្នាក់លើតែងដាក់បទបញ្ជាថា "*បើដាំកប្បាសមិនបាន! ដង្កូវស៊ីកប្បាស ដង្កូវនឹងស៊ីមនុស្សទៀត* " ដោយការខ្លាចស្លាប់ប្រជាជនដែលធ្វើការខាងដាំកប្បាស បានខិតខំប្រឹងប្រែងធ្វើការខ្លាំងណាស់ ដោយធ្វើការជាមួយភាពភ័យខ្លាចថាត្រូវគេយកទៅសម្លាប់។[189] ចំពោះការងារដែលថ្នាក់លើបែងចែកឱ្យធ្វើ ប្រសិនបើប្រជាជនរូបណាធ្វើការមិនគ្រប់តាមផែនការ គេនឹងចោទថាជាជនក្បត់ ហើយត្រូវបញ្ជូនទៅដាក់ក្នុង "**កងករណី**" ដែលមានន័យថា "**កងអ្នកមានទោស**"។[190] ចំពោះការដាក់ទណ្ឌកម្មគេឱ្យរែកដីឱ្យបាន ៣ (បី) ម៉ែត្រគូប ទៅ ៣,៥ (បីក្បៀស) ម៉ែត្រគូប នៅពេលអ្នកនោះមិនធ្វើបានគ្រប់ផែនការទេ អ្នកនោះត្រូវគេយកទៅសម្លាប់។[191]

៧៩. អ្វីដែលចម្លែកជាងគេនៅត្រង់ថា បើសូម្បីតែផលដំណាំនៅជុំវិញផ្ទះបន្តិចបន្តួច ក៏ម្ចាស់ពុំអាចហូបបានដែរ ពីព្រោះវាជាកម្មសិទ្ធិផ្តាច់មុខរបស់សហករណ៍ទៅវិញ។[192] ទង្វើនេះឈានទៅការកំណត់បានជាដើមចមនៃបញ្ហា រហូតដល់មានមួយឃ្លាដែលគេនិយាយតៗគ្នាថា "**ជាកម្មសិទ្ធិសមរម្យគឺស្លាបព្រាមួយតួច**"។[193] នៅតាមគ្រួសារនីមួយៗ គ្មានទេទ្រព្យសម្បត្តិឯកជន ផ្អែកលើគោលនយោបាយដែលត្រូវបានដាក់ឱ្យអនុវត្តចាប់តាំងពីមុនថ្ងៃរំដោះ ទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មកម្ល៉េះ។[194] របបកម្ពុជាប្រជាធិបតេយ្យយល់ថា



INVESTIGATING JUDGES * CO-JUGES D'INSTRUCTION
C.E.T.C * C.E.T.C

សម្បត្តិឯកជន[195] ជារបបនាយទុននិយមនាំឱ្យមានអំពើពុករលួយ[196] ឬ ការកេងប្រវ័ញ្ចពីសំណាក់អ្នកមានទ្រព្យធនទៅលើប្រជាជន។[197]

៨០. ដំបូងឡើយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គេបានធ្វើការបែងចែកប្រជាជនជាទូទៅជា ២ (ពីរ) ប្រភេទធំៗរួមមាន ប្រជាជនក្នុងតំបន់រំដោះ និងប្រជាជននៅក្រៅតំបន់រំដោះ។[198] ខណៈដែលគោលនយោបាយដាក់ចេញដោយបក្សដូចបានរៀបរាប់ខាងលើបានបង្ហាញថា នៅទូទាំងប្រទេសកម្ពុជាមានបង្កើតឱ្យមាននូវប្រព័ន្ធតាមដានគ្រប់រូបភាព និងគ្រប់វិនាទី។ ហេតុដូច្នេះ ពាក្យថា "**អង្គការភ្នែកម្នាស់**" ហាក់ដូចជាមធ្យោបាយនៃការរិតត្បិតគ្រប់សព្វ មិនត្រឹមតែលើប្រជាជនធម្មតាទេ បើសូម្បីតែកម្មាភិបាលមួយចំនួនធំរបស់បក្សក៏រងនូវការឃ្លាំមើលដូចគ្នានេះដែរ។[199] ពេលគេចាប់នរណាម្នាក់ទៅសម្លាប់ គេតែងប្រើពាក្យថា អង្គការជាអ្នកឱ្យមកចាប់ ហើយនរណាៗក៏មានចម្លើយដូចៗគ្នា "**អង្គការៗ មិនដឹងអង្គការនៅឯណាទេ**"។[200]

៨១. លើសពីនេះទៀត នៅពេលដែលអ្នកណាមួយមិនដើរស្របនឹងគោលនយោបាយរបស់បក្ស អ្នកនោះច្បាស់ណាស់នឹងក្លាយជាខ្មាំងអង្គការ ឬខ្មាំងបដិវត្ត។ ម្យ៉ាងវិញទៀត អ្នកណាមានតួនាទី និងសាច់ញាតិជាអ្នករដ្ឋការរបបមុនៗត្រូវចាត់ថា អ្នកជាប់និន្នាការមិនល្អ។[201] រីឯអ្នកដែលត្រូវជម្លៀសក្រោយថ្ងៃ ១៧ ខែ មេសា ភ្លាមហើយបានទៅដល់កន្លែងថ្មីត្រូវបានអង្គការហៅថា ប្រជាជនថ្មី[202] ឬ ប្រជាជន ១៧ មេសា។[203] ចំពោះប្រជាជនថ្មីនេះ ត្រូវគេផ្តល់ឋានៈត្រឹមតែជា "ជនបញ្ញើ" ហើយពុំអាចមានតួនាទីក្នុងឋានានុក្រមដឹកនាំក្នុងកម្រិតណាមួយបានឡើយ។[204] ផ្ទុយទៅវិញ សម្រាប់អ្នកទាំងឡាយណាដែលនៅទីតាំងរំដោះស្រាប់ដែលត្រូវគេហៅថា ប្រជាជនចាស់[205] ឬ ប្រជាជន ១៨ មេសា[206] ហើយដែលគេហៅជាទូទៅថា អ្នកមូលដ្ឋាន។[207] ចំពោះអ្នកមូលដ្ឋាននេះ អាចទទួលបានឋានៈជាប្រជាជនពេញសិទ្ធិ ប៉ុន្តែ ពេលខ្លះគាត់ទទួលបានត្រឹមតែជា "ប្រជាជនត្រៀម" នៅពេលណាដែលគាត់មានសាច់ញាតិមានទំនាក់ទំនងជាមួយខ្មាំង។[208]

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៩៨១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៩៨៤១។

## ខ- ការជម្លៀស

៨២. មុនពួកខ្មែរក្រហមវាយរំដោះទីក្រុងភ្នំពេញប្រមាណជាពីរខែគឺ នៅខែ កុម្ភៈ ឆ្នាំ ១៩៧៥ គណៈកម្មាធិការមជ្ឈិមបក្សបានប្រជុំសម្រេចអំពីផែនការត្រៀមជម្លៀសប្រជាជន ក្រោយពេលដែលបក្សទទួលបានជ័យជម្នះពីរបបសាធារណៈរដ្ឋខ្មែរ។[209] ខណៈដែលអង្គប្រជុំនោះត្រូវបានចូលរួមពីបណ្តាមេដឹកនាំជាន់ខ្ពស់សំខាន់ៗមួយចំនួនមានដូចជា៖ ប៉ុល ពត, នួន ជា, អៀង សារី, និង ខៀវ សំផន ដោយបានសម្រេចធ្វើការជម្លៀសប្រជាជនជាលើកដំបូង។[210] ជាទូទៅ ក្រោមការដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ ប្រជាជនមិនត្រូវបានអនុញ្ញាតឲ្យរស់នៅក្នុងភូមិកំណើតរបស់ខ្លួនទេ។[211] ករណីខ្លះ ប្រជាជនគ្រប់រូបមានកាតព្វកិច្ចត្រូវសំដែងនូវភាពស្មោះត្រង់ដល់អង្គការ ដោយតម្រូវឲ្យសរសេរនូវប្រវត្តិរូបសង្ខេបដែលគ្មានការលាក់បាំងប្រវត្តិពិត បូករួមទាំងការដែលមេកងនីមួយៗមានខ្សែស៊ើបការណ៍ថែមទៀត នាពេលនោះគេនឹងអាចរកឃើញអ្នកចេះដឹង បញ្ញវន្ត អ្នករដ្ឋការ នគរបាល កងទ័ព ជាអាទិ៍ ខណៈដែលអ្នកទាំងនោះនឹងក្លាយជាមុខសញ្ញាដែលគេចាប់យកទៅសម្លាប់ជាក់ជាពុំខាន។[212]

៨៣. សក្ខីកម្មសាក្សីដែលបានលើកឡើងនូវការនិយាយប្រាប់ដោយ **តាម៉ុក** ថា៖ *"ប្រជាជនទាំងអស់ត្រូវតែជម្លៀសទៅកាន់ទីជនបទ ដើម្បីកសាងសេដ្ឋកិច្ចជនបទ។ ... ការជម្លៀសប្រជាជនចេញពីទីក្រុងត្រូវបានធ្វើឡើងនៅទូទាំងប្រទេស ដោយការជម្លៀសត្រូវតែឲ្យហើយក្នុងរយៈពេល ២ (ពីរ) ថ្ងៃ"* ។[213] ជាក់ស្តែង ក្នុងអំឡុងពេលគ្រប់គ្រងដោយរបបកម្ពុជាប្រជាធិបតេយ្យ របបនេះបានសម្រេចធ្វើការជម្លៀសប្រជាជនមានដល់ទៅចំនួន ៣ (បី) លើកធំៗ។[214]

៨៤. ការជម្លៀសនៅដំណាក់កាលទីមួយ បន្ទាប់ពីការរំដោះនាថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[215] របបនេះបានសម្រេចធ្វើការជម្លៀសប្រជាជន ក្រោមការចាត់ចែងពីបណ្តាអង្គភាពយោធាសំខាន់ៗ ដែលជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តផែនការនេះ ក្នុងគោលដៅបង្ខំឲ្យប្រជាជនចាកចេញពីលំនៅដ្ឋានរបស់ខ្លួន ហើយត្រូវធ្វើដំណើរចេញទៅតាមផ្លូវជាតិទាំងអស់ ទាំងប៉ែកខាងលិច ខាងកើត ខាងជើង និងខាងត្បូងក្រុងភ្នំពេញ និងពីបណ្តាទីប្រជុំជនខេត្ត និងស្រុកផ្សេងៗទៀត ឆ្ពោះទៅតាមជនបទនានានៅទូទាំងប្រទេសកម្ពុជា។[216] គោលបំណងនៃការសម្រេចឲ្យមានការបណ្តេញប្រជាជននេះ ដើម្បីជម្រុញឲ្យកម្លាំងប្រជាជន

CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C.

ចូលរួមការងារកសិកម្មក្នុងគោលបំណងជម្រុញកំណើនសេដ្ឋកិច្ច តាមរយៈការគ្រប់គ្រង់តាមបែបសមូហភាពនិយមនៅតាមបណ្តាសហករណ៍ទូទាំងប្រទេស ដោយផ្តោតលើការកសាងប្រព័ន្ធធារាសាស្ត្រឱ្យដូចសរសៃឈាម[217] តាមរយៈការជីកព្រែក[218] លើកទំនប់[219] ជីកប្រឡាយ[220] អាងស្តុកទឹក ដើម្បីឱ្យឆ្លើយតបទៅពាក្យស្លោកថា "**បើមានទឹកគឺមានត្រី និងបើមានត្រីគឺមានអ្វីៗទាំងអស់**"។[221]

៨៥. អត្ថិភាពទាំងអប្បមាណនេះ ត្រូវបានរុញច្រានវិស័យនេះតាម ការចូលរួមធ្វើស្រែ និងការបង្កបង្កើតផលផ្សេងៗតាមសហករណ៍[222] មិនតែប៉ុណ្ណោះ អ្វីដែលជាគោលដៅសំខាន់មួយទៀត ហើយដែលត្រូវបានមេដឹកនាំជាន់ខ្ពស់នៃរបបនេះ យកមកធ្វើជាលេសនោះ ក្រោមហេតុផលថា ការបំបែកប្រជាជនចេញទីក្រុងជាការជួយពង្រឹងដល់បញ្ហាសន្តិសុខរបស់របបកម្ពុជាប្រជាធិបតេយ្យដោយផ្ទាល់ ដោយរបបនេះអាចឈានទៅធ្វើការកំណត់បាននូវអត្តសញ្ញាណខ្មាំងរបស់បក្សទាំងក្នុងនិងក្រៅ ដោយផ្តោតជាដំបូងទៅលើកងទ័ព លន់ នល់[223] អ្នករដ្ឋការ[224] ក្រុមសេអ៊ីអា[225] ក្រុមកាហ្សេបេ[226] ក្រុមខ្មាំងយួនបង្កប់[227] និងក្រុមផ្សេងៗទៀត ដែលត្រូវបានរបបនេះចាត់ទុកជាខ្មាំងរបស់បក្ស ដើម្បីគាំពារប្រទេសចេញពីហានិភ័យក្នុងដំណើរការដឹកនាំប្រទេសប្រកបដោយសុវត្ថិភាព និងមានភាពរឹងមាំប្រកបដោយចេរភាព។[228]

៨៦. ការជម្លៀសដំណាក់កាលទីពីរ បានចាប់ផ្តើមពីខែ កញ្ញា ឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៧។ ដោយកំណត់គោលដៅជាប្រជាជន និងកម្មាភិបាលភូមិភាគនិរតី ដែលភាគច្រើនជាអ្នករស់នៅក្នុងខេត្តកណ្តាល និងខេត្តតាកែវ ដោយត្រូវជម្លៀសទៅកាន់ភូមិភាគពាយ័ព្យ ជាពិសេសនៅខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់តែម្តង។[229] ការអនុវត្តផែនការនេះ ដោយផ្អែកលើលទ្ធផលដែលទទួលបានតាមរយៈការធ្វើទស្សនកិច្ចសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ទៅកាន់នៅភូមិភាគពាយ័ព្យ កាលពីអំឡុងខែសីហា-កញ្ញា ឆ្នាំ១៩៧៥ ដោយបានរកឃើញនូវតម្រូវការប្រជាជន ៥០០.០០០ (ហាសិបម៉ឺន) នាក់ បន្ថែមទៀតទៅក្នុងភូមិភាគពាយ័ព្យ[230] ដោយសារភូមិភាគនេះដីមានជីជាតិ និងសម្បូរភោគផល មិនតែប៉ុណ្ណោះ ថែមទាំងអាចទទួលការរ៉ាប់រងចិញ្ចឹមប្រជាជនថ្មីបន្ថែមទៀតបាន។[231] ជាលទ្ធផល ប្រជាជនជាច្រើនម៉ឺននាក់ត្រូវបានដឹកជញ្ជូនតាមរថយន្ត រថភ្លើង និងទូក ឆ្ពោះទៅកាន់គោលដៅនានា ភូមិភាគពាយ័ព្យ។[232]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៨៧. ការជម្លៀសចុងក្រោយបានប្រព្រឹត្តទៅចាប់ចុងឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៨ ។[233] ដោយកំណត់យកប្រជាជន និងអ្នកមុខសញ្ញាខ្មាំងក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀងនៃភូមិភាគបូព៌ាឱ្យទៅរស់នៅភូមិភាគពាយ័ព្យជាបន្ថែមទៀត។[234] អ្នកដែលមកដល់ពាយ័ព្យភ្លាម ត្រូវតម្រូវឱ្យធ្វើប្រវត្តិរូប ដើម្បីបែងចែកទៅតាមសហករណ៍ និងការដ្ឋាននានា។ ទន្ទឹមនឹងនោះ អ្នកខ្លះក៏ត្រូវបានបញ្ជូនទៅឃុំឃាំងនៅមន្ទីរសន្តិសុខ រីឯអ្នកខ្លះក៏ត្រូវបានយកទៅសម្លាប់ភ្លាមៗក៏មាន។[235] ការបែងចែកនេះគឺផ្អែកលើលទ្ធផលនៃកិច្ចប្រជុំមួយនៅខេត្តពោធិ៍សាត់ ដោយមានសមាសភាពសំខាន់ៗចូលរួម រួមមាន៖ តា ម៉ុក ដែលជាលេខាភូមិភាគនិរតី និងជាគណៈកម្មាធិការភូមិភាគពាយ័ព្យ សារុន ជាគណៈកម្មាធិការតំបន់១០៥, រឹម ជាគណៈកម្មាធិការស្រុក និងអ្នកផ្សេងមួយចំនួនទៀត បានសម្រេចធ្វើការចាត់ចែងចំពោះអ្នកមកដល់ភូមិភាគពាយ័ព្យ ហើយនៅបានផ្តល់ការណែនាំធ្វើការប្រុងប្រយ័ត្នឱ្យបានខ្ពស់ទៅអ្នកដែលបញ្ជូនមកទាំងនោះ ដោយហេតុថានៅភ្នំពេញមានខ្លះឆែកឃើញមានកាំភ្លើងយកមកជាមួយ។[236]

## ច- គោលនយោបាយរៀបការដោយបង្ខំ

៨៨. ការរៀបការដោយបង្ខំត្រូវបានអនុវត្តនៅពេញផ្ទៃប្រទេស តាមរយៈការបង្ខំឱ្យយកគូរស្រករ ដើម្បីសម្រេចឱ្យបាននូវការការពារបដិវត្តន៍សង្គមនិយម។[237] ចំពោះការរៀបការនេះ អង្គការតម្រូវឱ្យបុរសនារីជាអ្នកដែលមានឋានៈនយោបាយដូចគ្នាទើបអាចរៀបការជាមួយគ្នាបាន ទន្ទឹមនឹងនោះចំពោះកងទ័ពត្រូវបានទទួលការលើកទឹកចិត្តជាពិសេស[238] ដោយអនុលោមតាមសេចក្តីថ្លែងការណ៍ជាផ្លូវការពីសំណាក់ ប៉ុល ពត ដោយផ្ទាល់។[239] សាក្សីជាច្រើនផ្តល់សក្ខីកម្មថា អ្នកដែលត្រូវបានបង្ខំឱ្យរៀបការមិនហ៊ានតវ៉ាឡើយ។[240]

៨៩. ការជម្រុញឱ្យមានប្តីប្រពន្ធនេះ ដើម្បីសម្រេចបាននូវអ្នកបន្តវេននាពេលខាងមុខ ខណៈដែលសាក្សីមួយរូបបានលើកឡើងពីគោលនយោបាយបក្សថា *"គេគ្រោងនឹងបង្កើនកម្លាំងថ្មី ឬ ក៏ប្រជាជនថ្មីឱ្យដល់ ១៥.០០០.០០០ (ដប់ប្រាំលាន) ទៅ ២០.០០០.០០០ (ម្ភៃលាន) នាក់ នៅក្នុងរយៈពេលពី ១៥ (ដប់ប្រាំ) ទៅ ២០ (ម្ភៃ) ឆ្នាំទៀត"*។[241] មិនតែប៉ុណ្ណោះ ការណ៍នេះ គឺដើម្បីចំណេញនយោបាយគ្រប់គ្រងលើបុគ្គលនិងសេដ្ឋកិច្ច ដោយទុកឱ្យឪពុកម្តាយទៅធ្វើការតាមដ្ឋានការងារ រីឯកូនៗ អង្គការតម្រូវឱ្យចាស់ៗជាអ្នកយកទៅមើលថែទាំឱ្យ។[242]



E.C.C.C * C.E.T.C * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៩០. បើទោះបីជាឪពុកម្ដាយទាំងសងខាងព្រមព្រៀងក៏ដោយ តែបើអង្គការមិនដឹងអំពីការរៀបការនោះ អ្នកទាំងពីរនាក់នោះនឹងត្រូវគេចោទបានខុសសីលធម៌ ហើយត្រូវយកទៅសម្លាប់។[243] ពាក្យថា **"ខុសសីលធម៌"** កាលជំនាន់នោះ មានន័យសំដៅទៅលើការផិតក្បត់ប្ដីប្រពន្ធ ការរំលោភផ្លូវភេទ ឬការរួមភេទមិនមែនជាប្ដីប្រពន្ធ បើទោះបីជាមានការព្រមព្រៀងក៏ដោយ។[244] សាក្សីមួយរូបបានលើកឡើងថា *"ប្រុស និងស្រី លួចស្រឡាញ់គ្នាមិនឱ្យអង្គការដឹង អង្គការនឹងចាប់យកចេញទៅ"*។[245] ចំពោះបុរសទាំងឡាយណាដែលបានបដិសេធមិនព្រមរៀបការរហូតដល់ ២ (ពីរ) លើក ភាគច្រើនអ្នកនោះនឹងត្រូវគេដាក់ទណ្ឌកម្មឱ្យ **"ធ្វើជាកម្លោះមួយជីវិត"**។[246] អំពើខុសសីលធម៌នេះ ប្រសិនបើមានករណីបុរសរំលោភនារី ហើយនារីមិនព្រម នោះគេសម្លាប់តែខាងបុរសទេ ម្យ៉ាងវិញទៀត កាលបើអ្នកទាំង ២ (ពីរ) ពុំមែនជាប្ដីប្រពន្ធនឹងគ្នា ហើយបានព្រមរួមភេទជាមួយគ្នា គេនឹងសម្លាប់អ្នកទាំង ២ (ពីរ) នាក់ នោះចោលតែម្ដង។[247]

## ឆ- ការសម្លាប់

៩១. អំពីគោលនយោបាយធ្វើវិសុទ្ធកម្ម (សម្រិតសម្រាំង ឬបោសសម្អាត)ក្នុងនិងក្រៅបក្ស ត្រូវបានបង្កើតតាំងពីមុនឆ្នាំ១៩៧៥ ក្នុងគោលបំណងបំផ្លាញនូវរចនាសម្ព័ន្ធរបស់របបមុនៗ ជាពិសេស បក្សផ្ដោតលើក្រុមជនដែលបក្សគិតថាជា វណ្ណៈនាយទុន វណ្ណៈសក្តិភូមិជាដើម។[248] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ មាត្រា ១០ចែងថា *"ចំពោះប្រភេទសកម្មភាពប្រឆាំង និងបំផ្លិចបំផ្លាញជាខ្សែសង្វាក់ ហើយគ្រោះថ្នាក់ដល់រដ្ឋរបស់ប្រជាជន ត្រូវផ្ដន្ទាទោសកម្រិតខ្ពស់បំផុត។ ចំពោះបទល្មើសក្រៅពីប្រភេទខាងលើត្រូវអប់រំកសាងក្នុងក្របខណ្ឌអង្គការរដ្ឋ ឬ ក្នុងក្របខណ្ឌអង្គការប្រជាជន"*។[249]

៩២. ជារួម អ្វីៗទាំងអស់មានភាពស្មុគស្មាញ និងពិបាកយល់បញ្ហានៅគ្រប់លំដាប់ថ្នាក់ ខណៈដែលការដាក់ចេញនូវគោលនយោបាយរបស់បក្សជាទូទៅ ហាក់ដូចជាមានលក្ខណៈឆ្វេងនិយមជ្រុល ក្រោមជំហរគោរពតាមមាគ៌ាឯករាជ្យម្ចាស់ការ និងការប្រកាន់តឹងរ៉ឹងហួសហេតុ។[250] តាមរយៈសេចក្ដីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមបក្សនៅឆ្នាំ១៩៧៦ គោលនយោបាយបោសសម្អាតត្រូវបានដាក់ចេញ ដែលពាក់ព័ន្ធសិទ្ធិសម្រេចកម្ទេចក្នុង និងក្រៅបក្ស ដោយបានចែងយ៉ាងជាក់ច្បាស់ថា *"បើនៅក្នុងក្របខណ្ឌមូលដ្ឋានត្រូវ[illegible]*



*E.C.C.C*C.E.T.C* INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

*ភាគសម្រេច ជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមន្ទីរមជ្ឈិមសម្រេច តំបន់ឯករាជ្យត្រូវអចិន្ត្រៃយ៍សម្រេច កងទ័ពមជ្ឈិមត្រូវសេនាធិការសម្រេច* "។[251] ទន្ទឹមនឹងនោះដែរ អតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុច កន្លងមកបានបកស្រាយទាក់ទិននឹងសេចក្តីសម្រេចនាឆ្នាំ១៩៧៦ នេះដែរថា "*អ្នកដែលមានសិទ្ធិនៅមូលដ្ឋាន មិនមែនអចិន្ត្រៃយ៍ភាគទាំងមូលនោះទេ ... លេខាភាគមានសិទ្ធិសម្រេចកម្ទេចអ្នកណា ត្រូវកម្ទេចអ្នកនោះ លេខាភូមិភាគទុកឱ្យអ្នកណារស់គឺ អ្នកនោះរស់ ដូច្នេះអំណាចនៅលើលេខាភាគ* "។[252]

៩៣. ជាក់ស្តែង គ្រប់លេខាភូមិភាគ និងលេខាតំបន់ស្វយ័ត ជាអ្នកមានសិទ្ធិអំណាចគ្រប់គ្រងទាំងកងទ័ព និងកងឈ្លបក្នុងភូមិសាស្ត្រដែលខ្លួនគ្រប់គ្រង។[253] នៅក្រោយឆ្នាំ១៩៧៨ គណៈកម្មាធិការមជ្ឈិមបក្សបានចេញសេចក្តីណែនាំឱ្យដឹងថា ចំពោះថ្នាក់ក្រោមពុំមានសិទ្ធិសម្រេចសម្លាប់មនុស្សទេ ដោយមានតែគណៈកម្មាធិការមជ្ឈិមទេដែលមានសិទ្ធិសម្រេចឱ្យសម្លាប់។[254] តាមការអនុវត្តជាក់ស្តែង សេចក្តីណែនាំរបស់គណៈកម្មាធិការមជ្ឈិមនេះប្រហែលជាមិនត្រូវបានអនុវត្តបានទាំងស្រុងនោះទេ ដោយហេតុថាមានមនុស្សជាច្រើននាក់ត្រូវបានគេសម្លាប់ដោយមិនបានរាយការណ៍ទៅថ្នាក់លើនោះទេ។[255]

៩៤. នៅក្រោមការដឹកនាំរបស់របបកម្ពុជាប្រជាធិបតេយ្យ របបនេះបានបង្កើតឱ្យមានមន្ទីរសន្តិសុខរហូតដល់ ១៩៦ (មួយរយកៅសិបប្រាំមួយ) មន្ទីរសន្តិសុខនៅទូទាំងប្រទេស សម្រាប់ឃុំឃាំង និងសម្លាប់មនុស្ស។ នៅអំឡុងពេលនោះ មន្ទីរសន្តិសុខនេះត្រូវបានគេប្រើជាកន្លែងធ្វើការលត់ដំ អប់រំ កែប្រែ ធ្វើទារុណកម្ម ដើម្បីរកខ្សែក្បត់បក្ស។[256] ជាមួយនឹងវត្តមាននៃមន្ទីរសន្តិសុខជាច្រើនបែបនេះ តម្រូវឱ្យកម្មាភិបាលគ្រប់ជាន់ថ្នាក់ត្រូវតែអនុវត្តឱ្យខានតែបានតាមមាគ៌ាដ៏ភ្លឺស្វាងរបស់បក្ស តាមរយៈការផ្សព្វផ្សាយអំពីគោលនយោបាយបក្សដែលបានដាក់ចេញជាបន្តបន្ទាប់ រួមទាំងត្រូវចូលរួមក្នុងការសម្របសម្រួលលើការចាប់ខ្លួន និងបញ្ជូនខ្លួនតាមបញ្ជាថ្នាក់លើដែលត្រូវគេស្គាល់ជាទូទៅថា "**អង្គការ**"។[257] ក្រោមពាក្យស្លោកដ៏មានប្រជាប្រិយភាព ដែលកម្មាភិបាលតែងតែលើកយកមកនិយាយដដែលៗថា "**កុំធ្វើអ្វីដែលនាំឱ្យខ្ទាស់នឹងអង្គការ ខ្ទាស់នឹងកង់ប្រវត្តិសាស្ត្រ**"។[258] អ្វីដែលគួរឱ្យសង្វេគ គេឃើញនៅមានឆ្អឹងសាកសពនៅជាប់ចំណោងជាច្រើន ស្ថិតនៅរប៉ាត់រប៉ាយស្ទើរគ្រប់ទីកន្លែងនៅទូទាំងប្រទេស ជាពិសេសនៅក្នុងរណ្តៅនៅតាមមន្ទីរសន្តិសុខ។[259]

៩៥. នៅពេលអនុវត្តបទបញ្ជាណាមួយទៅលើប្រជាជន កម្មាភិបាលនាពេលនោះស្ទើរតែគ្រប់រូប ក្រៅពីការប្រើពាក្យថា "**អង្គការ**" គេបានប្រើពាក្យដែលមានការទទួលស្គាល់ជាច្រើនផងដែរ ថា ជាបញ្ជាពី "**ថ្នាក់លើ**"[260] ខណៈថ្នាក់ក្រោមៗទាំងនោះមិនទាំងយល់ពីផែនការ ឬ កម្មវិធីនយោបាយបក្សឱ្យបានស៊ីជម្រៅបន្តិចផង។[261] ប៉ុន្តែ ប្រសិនបើមិនធ្វើតាមគោលនយោបាយថ្នាក់លើ ពួកគេត្រូវចាត់ទុកជា "**ខ្មាំង**" របស់បក្ស[262] ហើយត្រូវចាប់យកសម្លាប់តែម្តង។[263] បរិបទកម្ពុជាប្រជាធិបតេយ្យ ពាក្យថាថ្នាក់លើត្រូវតែគោរពដាច់ខាត ហ៊ានតែបដិសេធ ឬ អនុវត្តមិនបានគ្រប់ជ្រុងជ្រោយ អ្នកនោះនឹងត្រូវចាប់យកទៅសម្លាប់។[264] ទន្ទឹមនឹងនោះ ប្រសិនបើកម្មាភិបាលរូបណាដែលក្លាហានហ៊ានធ្វើការរិះគន់មាគ៌ាបក្ស នោះនឹងត្រូវគេបានអង្គការចាត់ទុកជាជនក្បត់។[265]

៩៦. ក្នុងរបបនោះមាន "**ការប្រជុំស្វ័យទិតៀន**" ដែលគេឱ្យអ្នកធ្វើខុសត្រូវតែនិយាយប្រាប់ពីកំហុសខ្លួនចេញមក ដោយផ្តល់ឱកាសដល់អ្នកចូលរួមប្រជុំជួយជាយោបល់ ដើម្បីបង្ការកុំឱ្យជននោះប្រព្រឹត្តកំហុសសារជាថ្មី។[266] លើសពីនេះទៀត មានការកំណត់ឱ្យមានប្រជុំជីវភាពបក្សជាទៀងទាត់ ក្រោមហេតុផលថា "***បើប្រជុំទៀងទាត់គឺចម្រើន ចម្រើនលឿន ចម្រើនយឺតគឺចម្រើន***"។[267] តាមរយៈការប្រជុំទាំងនោះ បក្សបានឃោសនាពង្រឹងគោលនយោបាយបក្សដល់ប្រជាជនឱ្យខិតខំប្រឹងប្រែងចូលរួមធ្វើការ និងជៀសវាងដាច់ខាតការក្បត់បក្ស និងអង្គការ ប្រសិនបើមិនដូច្នោះទេ បុគ្គលនោះនឹងត្រូវ "**ប្រវត្តិសាស្ត្រថ្កោលទោស**"។[268] នៅពេលដែលអង្គការសម្រេចយកនរណាម្នាក់ទៅធ្វើការអប់រំមិនបាន អ្នកនោះនឹងត្រូវគេបញ្ជូនរៀនសូត្រ ឬបញ្ជូនទៅកសាង ខណៈការដែលពាក្យទាំងនេះមានន័យស្មើនឹងយកទៅសម្លាប់ចោលដោយប្រាប់ថា "**ទុកក៏មិនចំណេញ ដកចេញក៏មិនខាត**"។[269]

៩៧. ស្តាប់ភ្លាមហាក់ដូចជារបបកម្ពុជាប្រជាធិបតេយ្យដើរតាមគន្លងប្រជាធិបតេយ្យ ការពិតវាជាភាពផ្ទុយស្រឡះទាំងស្រុងនឹងការដឹកនាំតាមបែបបប្រជាធិបតេយ្យនោះ។ ម្យ៉ាងវិញទៀត បើទោះបីជា គោលនយោបាយក៏ទំនងជាយកចិត្តទុកដាក់ដល់ប្រជាជន បើសូម្បីតែផ្លូវចិត្តរបស់ប្រជាជន ក៏ទទួលបាននូវការថ្នាក់ថ្នម រហូតដល់មានការដាក់ចេញនូវការពង្រឹងការអនុវត្តនូវ "**នយោបាយសតិអារម្មណ៍**" ឱ្យបានជាប់ជាប្រចាំ ប៉ុន្តែ ជាក់ស្តែង ការធ្វើការងារនយោបាយសតិអារម្មណ៍នេះគឺមានត្រឹមតែកម្រងពាក្យ និងគ្មានខ្លឹមសារចំពោះការប្រតិបត្តិទាល់តែសោះក្នុងបរិបទនោះ។[270]



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

៩៨. ថ្នាក់ដឹកនាំតាមមូលដ្ឋានពេលនោះតែងប្រើគោលនយោបាយបោកបញ្ឆោតដើម្បីយកមនុស្សទៅសម្លាប់រហូតដល់មានអ្នកខ្លះចាញ់ឃោសនាគេ ដោយនិយាយរឿងពិតប្រាប់គេអំពីការងារដែលខ្លួនធ្លាប់ធ្វើនៅសម័យមុនដូចជា ធ្លាប់ធ្វើការអ្នករដ្ឋការធំៗ ទាហានស័ក្តិ៣ ឬ ស័ក្តិ៤ ។ល។ ក្រោយពីបានដឹងហើយ គេប្រាកដជាយកអ្នកទាំងនោះទៅសម្លាប់ចោលទាំងអស់។[271] អ្វីដែលជាការកត់សម្គាល់នៅត្រង់ថា ការហៅនរណាម្នាក់ក្រោមហេតុផលថាទៅជួបអង្គការ គេសង្កេតឃើញស្ទើរតែគ្រប់គ្នា "*ឲ្យតែទៅបាត់ហើយ អត់ដែលឃើញត្រឡប់មកវិញទេ* "។[272] ប្រជាជនរូបណាបានច្រៀងបទចំរៀងបរទេសនឹងត្រូវគេចាប់យកទៅសម្លាប់ចោលភ្លាម។[273] ជាទូទៅ ចំពោះការរាំរែក និងការច្រៀងកំសាន្តត្រូវបានគេហាមឃាត់នៅទូទាំងប្រទេស លើកលែងតែការចាក់ផ្សាយ"**ចំរៀងបដិវត្តន៍**" តាមវិទ្យុ "**សម្លេងកម្ពុជាប្រជាធិបតេយ្យ**" ដែលគេចាក់តាមមេក្រូនៅតាមការដ្ឋាន និងសហករណ៍។[274] នរណាដែលលួចស្តាប់វិទ្យុផ្សាយសំឡេងបរទេសក៏ត្រូវស្លាប់ដែរ។[275]

៩៩. លើសពីនេះ នៅមានការស្លាប់របស់ប្រជាជនដែលកើតចេញពីការបង្ក្រាប តាមរយៈការអនុវត្តន៍នូវគោលនយោបាយវិសុទ្ធកម្ម។ ប្រជាជន និងកម្មាភិបាលដែលត្រូវបានចាត់ថាជាខ្មាំង ឬ មិនគោរពតាមបទបញ្ជារបស់អង្គការក៏ត្រូវបានសម្លាប់។[276] នាពេលនោះ គ្មានទេការបន្ធូរបន្ថយវិធានការវិន័យ ឲ្យតែមិនតាមគោលនយោបាយ បើទោះបីជាកម្មាភិបាលថ្នាក់ណាក៏ត្រូវទទួលទោសកម្ចាត់ចោលដូចជា៖ ហ៊ូ យន់[277], ហ៊ូ នឹម[278], វន វ៉េត[279], កុយ ធួន[280] រស់ ញឹម[281] និង សោ ភឹម[282] ជាដើម។

១០០. ជាក់ស្តែង ក្នុងអំឡុងពេលគ្រប់គ្រងអំណាចរយៈពេល ៣ (បី) ឆ្នាំ ៨ (ប្រាំបី) ខែ ២០ (ម្ភៃ) ថ្ងៃ កម្មាភិបាលជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងតិចចំនួន ៦០ (ហុកសិប) រូប ត្រូវបានចាប់ខ្លួន និងសម្លាប់នៅមន្ទីរសន្តិសុខ ស-២១។[283] បើទោះបីជារបបកម្ពុជាប្រជាធិបតេយ្យជិតមានការដួលរលំក៏ដោយ ក៏ការសម្លាប់នៅបន្តកើតមានជាដដែល ហើយជាមួយនឹងការដាក់ចេញនូវគោលនយោបាយទាំងនោះឃើញថា មានតែមេដឹកនាំជាន់ខ្ពស់តែ ២ (ពីរ) ឬ ៣ (បី) នាក់ប៉ុណ្ណោះនៅថ្នាក់លើអាចបកស្រាយបាន។[284] ម្យ៉ាងវិញទៀត បើសូម្បីតែត្បូងចបកាប់ដី ឬ គល់ឫស្សី ក៏ត្រូវបានគេប្រើជាអាវុធសម្រាប់សម្លាប់មនុស្សអស់ជាច្រើននាក់។[285] ប្រជាជនទូទៅជាសរុបប្រមាណជាង ១.៧០០.០០០[286] (មួយលានប្រាំពីរសែន) នាក់ ត្រូវបានសម្លាប់ និងស្លាប់ដោយសារការអត់ឃ្លាន[287] ជំងឺ[288] និងធ្វើ[illegible]



E.C.C.C * C.E.T.C * INVESTIGATING JUDGES · CO-JUGES D'INSTRUCTION

ហ្នួសកម្លាំង។[289] ជាមួយនឹងអត្រាដ៏ច្រើនសម្បើមបែបនេះ ឆ្អឹង លលាដ៍ក្បាល និងសាកសព ត្រូវបានប្រទះឃើញរប៉ាត់រប៉ាយស្ទើរគ្រប់ទីកន្លែងនៅទូទាំងប្រទេស ជាពិសេសនៅបរិវេណមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស ក្រោយពេលដែលរបបនោះបានដួលរលំភ្លាមៗ។[290] ខណៈដែលការសម្លាប់ទាំងអស់នាពេលនោះសុទ្ធតែកើតឡើងក្រៅប្រព័ន្ធតុលាការ។[291] ការអនុវត្តនូវគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាខាងលើបានបង្ហាញឱ្យឃើញថា ប្រជាជនបានប្រឈមមុខនឹងផលវិបាកជាច្រើនឥតគណនា ពិសេសកង្វះ អាហាររូបត្ថម្ភ និងមានជំងឺ។[292]

## ជ- សុខមាលភាព

១០១. បញ្ហាសុខមាលភាពប្រជាជននាពេលនោះ មិនត្រូវបានគេគិតគូរទេ ដោយហេតុថាភាគច្រើនបំផុតនៃពេទ្យទាំងអស់នាពេលនោះ គ្មានចំណេះដឹងនិងជំនាញខាងការព្យាបាលទេ ដោយចេះតែចាប់ដាក់ៗឱ្យធ្វើជាពេទ្យតែម្តង។[293] សាក្សីមួយរូបបាននិយាយថា "*ពេទ្យគ្មានចំណេះដឹង គ្មានបទពិសោធន៍ទេ អ្នកខ្លះមិនទាំងចេះអក្សរផង*"។[294] ម្យ៉ាងវិញទៀត នៅពេលនោះគ្មានថ្នាំពេទ្យសម្រាប់ព្យាបាលនិង ប៉ុន្តែ អ្វីដែលគេហៅថ្នាំនាសម័យនោះគឺជាប្រភេទទឹកដូង ឬ ថ្នាំដែលគេច្រកក្នុងដបប៉ិបស៊ីដែលគ្របចង់ប្លាស្ទិកចងនឹងកៅស៊ូ ដើម្បីយកទៅចាក់ឱ្យអ្នកជំងឺ អ្នកខ្លះក៏បានស្លាប់ភ្លាមៗក្រោយពេលដកម្ជុល អ្នកខ្លះក៏ឡើងអាប់សែ ហើយមានអ្នកជំងឺតិចតួចបំផុតដែលបានធូរស្រាលឡើងវិញ។[295]

១០២. សាក្សីមួយរូបបានលើកឡើងថា "*មិនចំពោះថាជំងឺអ្វីនោះទេ គឺគេឱ្យថ្នាំដូចតែគ្នាហ្នឹង*"។[296] នៅពេលប្រជាជនឈឺ មិនមានការផ្តល់សេវាពីខាងមណ្ឌលសុខភាព មន្ទីរពេទ្យ និងពេទ្យដែលមានវិជ្ជាជីវៈ ខណៈដែលថ្នាំព្យាបាលវិញក៏មិនមានគ្រប់គ្រាន់ ហើយពេលខ្លះក៏បណ្តាលឱ្យអ្នកជំងឺឈឺកាន់តែធ្ងន់ធ្ងរ និងភាគច្រើនឈានទៅរកសេចក្តីស្លាប់តែម្តង។[297]

## ឈ- គោលនយោបាយចម្លែក

១០៣. ជាទូទៅ ការជ្រើសរើសថ្នាក់ដឹកនាំតាមមូលដ្ឋានរួមទាំងសហករណ៍ឃុំ សន្តិសុខ ឈ្លប និងមុខដំណែងផ្សេងទៀត គឺជ្រើសរើសយកតែមនុស្សដែលមិនមានការយល់ដឹង និងធ្លាប់មានកំហឹងនឹងវណ្ណៈ ដោយសារនៅក្នុងរបបមុនៗជាវណ្ណៈក្រីក្រ។ អង្គការអប់រំសតិអារម្មណ៍...

ប្រព័ន្ធទូទាំងប្រទេស ដើម្បីងាយស្រួលអនុវត្តគោលនយោបាយរបស់ពួកគេ ដែលមានពាក្យស្លោកថា "ពួកខ្មាំងប្រតិកិរិយា ពួកនាយទុន ពួកវណ្ណៈជិះជាន់" ជាអាទិ៍។ ពាក្យទាំងនេះស្រប នឹងទង្វើអនុវត្ត "ខ្មាំងស៊ីរូងផ្ទៃក្នុង" "ទុកមិនចំណេញ ដកចេញមិនខាត" "កម្ទេចពួកខ្មាំង" ជាដើម។ បន្ថែមពីលើនេះ យើងអាចវាយតម្លៃជាសត្យានុម័តភ្ជាប់ជាមួយអង្គហេតុមួយទៀតដែលការបង្កើតចលនាតស៊ូដើមដំបូងមានបញ្ញវន្តជាច្រើនរូបបានចូលរួម ប៉ុន្តែក្រោយជ័យជម្នះ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ បញ្ញវន្តជាអ្នកតស៊ូទាំងនោះត្រូវបានសម្លាប់ជាបន្តបន្ទាប់ ដោយសារពួកគេមិនយល់ស្របនឹងគោលនយោបាយរបស់មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ។

១០៤. ជារួម នយោបាយដឹកនាំរបស់មេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យបានបង្កើតយន្តការតាមដានច្បាស់លាស់ ដាក់សម្ពាធខ្លាំងធ្វើឱ្យរចនាសម្ព័ន្ធថ្នាក់ក្រោមដើរតាមទិសដៅឥតងាករេ បង្កើតបានជាប្រព័ន្ធមួយមិនទុកចិត្តគ្នា តាមដានគ្នាទៅវិញទៅមក បិទបាំងដោយពាក្យអង្គការ អង្គការភ្នែកម្នាស់ ខ្មាំងស៊ីរូងផ្ទៃក្នុង ពួកសេអ៊ីអា កាហ្សេបេ ខ្មាំងប្រតិកិរិយា ទុកមិនចំណេញដកចេញមិនខាត។ អង្គការបានហៅទៅអប់រំ ទៅរៀនសូត្រ ដែលមានន័យថា ស្មើនឹងស្លាប់។

១០៥. អង្គហេតុទាំងអស់ខាងលើនេះមានលក្ខណៈជាសត្យានុម័តដែលដឹងឮជាសាធារណៈពោលគឺប្រជាជនកម្ពុជា ដែលនាពេលនេះមានអាយុចាប់ពី ៥០ (ហាសិប) ឆ្នាំ **(គិតត្រឹមឆ្នាំ២០១៩)** ឡើងទៅ កាលបើរស់នៅក្នុងរបបនោះសុទ្ធតែបានដឹងឮ និងឃើញទាំងអស់ដោយមិនចាំបាច់មានភស្តុតាងបញ្ជាក់។ ឆ្លងកាត់នូវទុក្ខសោកដ៏មហាសោកស្តាយនេះ បើសូម្បីតែសាក្សីតែម្នាក់គត់ក៏បានទទួចថា *"ខ្ញុំសំណូមពរដល់ក្មេងជំនាន់ក្រោយ បញ្ញវន្តជំនាន់ក្រោយ ឱ្យចេះរួបរួមគ្នា ស្រលាញ់គ្នា សាមគ្គីគ្នា ឱ្យចេះស្រលាញ់ទឹកដី ចេះអត់ឱនគ្នា កុំឈ្លោះប្រកែកគ្នា ដើម្បីឱ្យប្រទេសជាតិយើងមានសុខសន្តិភាពមានអ្វីៗគ្រប់បែបយ៉ាង"*។[298]

១០៦. បរិបទនៃការប្រព្រឹត្ត និងទម្រង់នៃការគ្រប់គ្រងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺមានលក្ខណៈខុសពីអ្វីដែលកើតមាននៅប្រទេសយូហ្គោស្លាវី រវ៉ាន់ដា និង សេរ៉ាឡេអូន ដែលនាំឱ្យបង្កើតមាននូវតុលាការព្រហ្មទណ្ឌអន្តរជាតិស្រដៀងគ្នានឹង អ.វ.ត.ក ដែរ។ របបកម្ពុជាប្រជាធិបតេយ្យ គឺជារបបប្រកាន់និន្នាការដឹកនាំរដ្ឋមួយជាក់លាក់ដែលផ្ទុះបង្កើត



E.C.C.C * C.E.T.C * INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

គោលនយោបាយនៃការធ្វើទុក្ខបុកម្នេញកម្រិតជាតិ និងអនុវត្តជាទូទៅនៅទូទាំងប្រទេសក្នុង របចនាសម្ព័ន្ធដឹកនាំសមូហភាពដែលកម្មាភិបាលគ្រប់ជាន់ថ្នាក់ត្រូវតែគោរព និងធ្វើតាមបញ្ជាជាដាច់ខាត។[299]

១០៧. ជាក់ស្តែង ពាក្យថា "**សត្រូវ**" ឬ "**ខ្មាំងបដិវត្ត**" មានវិសាលភាពធំធេង និងគ្របដណ្តប់លើប្រជាពលរដ្ឋស្លូតត្រង់ខ្លួនឯងតែម្តង។ អ្នកទោសស្រីម្នាក់ដែលត្រូវបានគេសម្លាប់នៅមន្ទីរសន្តិសុខភ្នំត្រយោង មុនស្លាប់បានស្រែកថា "*ស្លាប់ចុះបដិវត្តន៍អើយ ! ខ្ញុំមិនស្លាយទេ* "។[300] នេះខុសគ្នានឹងជម្លោះពូជសាសន៍រវាង ហ៊ូទូ (Hutus) និង ទុតស៊ី (Tutsi) ដែលនាំឱ្យមានអំពើប្រល័យពូជសាសន៍នៅប្រទេសរវ៉ាន់ដា (Rwanda)។[301] អ្វីបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នេះក៏ខុសគ្នានឹងអំពើប្រល័យពូជសាសន៍ដោយពួកជាតិនិយមស៊ែប (Serb) ដែលដឹកនាំដោយអតីតប្រធានាធិបតី ស្លូបូដាន ម៉េឡូសូវិច (Slobodan Milosevic) ទៅលើប្រជាជនក្រូអាត (Croat) និង បូស្នៀ (Bosnia)។[302]

## ២- រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មជ្ឈិមបក្ស

### ក. គណៈកម្មាធិការមជ្ឈិមបក្សកុំម្មុយនីស្តកម្ពុជា

១០៨. បក្សកុំម្មុយនីស្តកម្ពុជាត្រូវបានបង្កើតឡើងតាំងតែពីមុនការឡើងកាន់អំណាចនៃរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ មកម្ល៉េះ។[303] របបកម្ពុជាប្រជាធិបតេយ្យជារបបដឹកនាំតាមបែបកុំម្មុយនីស្តដោយមានបក្សជាអ្នកដឹកនាំរដ្ឋ មានន័យថា គ្រប់យន្តការនៃការគ្រប់គ្រងត្រូវតែឱ្យស្របតាមគោលនយោបាយ ដែលបក្សកុំម្មុយនីស្តបានដាក់ចេញជាដាច់ខាត។[304] គោលនយោបាយរបស់ ប.ក.ក មានគោលដៅធ្វើការបោសសម្អាតលើវណ្ណៈសក្តិភូមិ និងបញ្ញវន្ត ជាអាទិ៍ ដែលត្រូវចាត់ទុកជាខ្មាំង ដែលអ្នកទាំងនេះត្រូវបានគេចោទថាធ្លាប់កេងប្រវ័ញ្ច ជិះជាន់ និងសង្កត់សង្កិនលើកម្មករនិងកសិករនាពេលកន្លងមក។[305] ដូច្នេះ ប.ក.ក បានដាក់ចេញនូវគោលនយោបាយជាការសងសឹកចំពោះអ្នកទាំងនោះ។[306]

១០៩. គណៈកម្មាធិការមជ្ឈិមបក្សជាថ្នាក់ដឹកនាំកំពូលរបស់ ប.ក.ក ។[307] ពាក្យថា "បក្ស" សំដៅលើថ្នាក់ដឹកនាំនៃគណៈកម្មាធិការមជ្ឈិមបក្សកុំម្មុយនីស្តកម្ពុជា។[308] គណៈកម្មាធិការនេះ

មានសមាជិកប្រមាណ ៣០ (សាមសិប) រូប[309] មានការកំណត់ការប្រជុំជាទៀងទាត់នៅរៀងរាល់ ៦ (ប្រាំមួយ) ខែម្តង។[310] ការអនុវត្តជាក់ស្តែង គណៈកម្មាធិការមជ្ឈិមបក្សកុំមុយនីស្តកម្ពុជាតែងតែធ្វើការកោះហៅប្រជុំនៅភ្នំពេញ ដោយមានសមាសភាពចូលរួមមានថ្នាក់ដឹកនាំគណៈភូមិភាគ និងគណៈតំបន់ឱ្យមកចូលរួមប្រជុំនៅភ្នំពេញ ជាពិសេសពេលត្រូវធ្វើការប្រកាសផ្សព្វផ្សាយ នូវផែនការនៃការអនុវត្តគោលនយោបាយផ្សេងៗរបស់ ប.ក.ក។[311]

១១០. ការអនុវត្តនូវការសម្រេចចាប់ខ្លួនថ្នាក់ភូមិភាគ ឬ តំបន់ ត្រូវចេញពីគណៈកម្មាធិការមជ្ឈិមបក្ស។[312] សាក្សីឈ្មោះ សែម ហឿន បាននិយាយថា "*អ្នកទោសថ្នាក់ប្រធានតំបន់គឺធំដូច្នេះថ្នាក់ស្រុកមិនអាចទៅចាប់បានទេ។ ដូច្នេះ បញ្ជាត្រូវចេញមកពីថ្នាក់មជ្ឈិមដែលជាថ្នាក់កំពូល* "។[313] ការសម្រេចចាប់ខ្លួនថ្នាក់តំបន់ ជាគោលការណ៍ក្នុងការអនុវត្ត ពេលខ្លះខាងភូមិភាគក៏មិនមានសិទ្ធិក្នុងសម្រេចឱ្យមានការចាប់ខ្លួនទេ មានតែគណៈកម្មាធិការមជ្ឈិមបក្សដែលមានសិទ្ធិចេញបញ្ជាឱ្យចាប់។[314] សាក្សីឈ្មោះ សួន កានិល បង្ហាញថា "*បើមិនមានឯកសារចាប់ខ្លួន គាត់ (កែ ពក) មិនហ៊ានចាប់ខ្លួនទេគឺត្រូវទទួលបញ្ជាពីថ្នាក់លើ* "។[315]

១១១. មានការចោទប្រកាន់ **យឹម ទិត្យ** ថា "ក្នុងនាមជាលេខាតាមព្រឹត្តិហេតុ ឬ តាមនីតិន័យនៃភូមិភាគ ដែលជាភូមិភាគជាយុទ្ធសាស្ត្រមួយដ៏សំខាន់បំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ **តាទិត្យ** អាចក្លាយទៅជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុំមុយនីស្តកម្ពុជា នៅក្នុងមហាសន្និបាតបក្សលើកទី៥"។[316] ជាក់ស្តែង ប.ក.ក មានសមាជិកគណៈកម្មាធិការមជ្ឈិមប្រមាណ ៣០ (សាមសិប) រូប ក្នុងនោះរួមទាំងសមាជិកពេញសិទ្ធិ និងសមាជិកត្រៀមចូលបក្សដែលភាគច្រើនជាលេខាភូមិភាគអនុលេខាភូមិភាគ សមាជិកគណៈភូមិភាគ និងលេខាតំបន់ ក៏ប៉ុន្តែ ជាស្វ័យប្រវត្តិ ពុំមែនអ្នកដែលមានតួនាទីទាំងនេះមានតួនាទីជាសមាជិកគណៈកម្មាធិការមជ្ឈិមទេ។[317]

## ខ. គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុំមុយនីស្តកម្ពុជា

១១២. គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុំមុយនីស្តកម្ពុជា ជាអ្នកដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំការងារប្រចាំថ្ងៃជំនួសឱ្យគណៈកម្មាធិការមជ្ឈិមបក្ស និងជាមេដឹកនាំជាន់ខ្ពស់បំផុត



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

បក្សកុម្មុយនីស្តកម្ពុជា។[318] សមាសភាពគណៈកម្មាធិការអចិន្ត្រៃយ៍បក្សមាន ៧ (ប្រាំពីរ) រូប រួមមាន៖ ប៉ុល ពត, នួន ជា, សោ ភឹម, តា ម៉ុក, អៀង សារី, វន វេត, និង សុន សេន។[319] ខណៈដែល ប៉ុល ពត មានតួនាទីជាលេខាបក្ស[320] រីឯ នួន ជា ជាអនុលេខាបក្ស។[321]

១១៣. ក្នុងចំណោមសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាទាំងអស់គឺមានសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍រហូតដល់ទៅ ៥ (ប្រាំ) រូប រួមមាន៖ ប៉ុល ពត, នួន ជា , អៀង សារី, វន វេត និង សុន សេន ដែលនៅធ្វើការជាប្រចាំនៅភ្នំពេញតែម្តង។[322] អតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុច បាននិយាយថាថ្នាក់ខ្ពស់ទាំង ៤ (បួន) នៃបក្សគឺ៖ ទី១ គណៈកម្មាធិការអចិន្ត្រៃយ៍ ទី២ សមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម ទី៣ សមាជិកបម្រុងនៃគណៈកម្មាធិការមជ្ឈិម និងទី៤ គណៈកម្មាធិការជំនួយការនៃគណៈកម្មាធិការមជ្ឈិម។[323]

១១៤. តួនាទី និងអំណាចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍មជ្ឈិមបក្សត្រូវបានចែងយ៉ាងពិស្តារក្នុងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយផ្តល់ការទទួលបន្ទុក និងធ្វើការតាមដានក្នុងការអនុវត្តនូវគោលនយោបាយរបស់ ប.ក.ក។[324] គណៈកម្មាធិការអចិន្ត្រៃយ៍មជ្ឈិមបក្សមានភារកិច្ចពិនិត្យមើលការខុសត្រូវលើមាគ៌ានយោបាយគ្រប់ខទាំងអស់របស់បក្ស នៅចន្លោះពេលពីមហាសន្និបាតមួយទៅមហាសន្និបាតមួយ។[325] កន្លងមក មហាសន្និបាតបក្សលើកទី១ ធ្វើនៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៦០។[326] នៅឆ្នាំ ១៩៧៧ បក្សកុម្មុយនីស្តកម្ពុជាបានធ្វើមហាសន្និបាតជាតិប្រចាំឆ្នាំរបស់បក្ស។[327] មហាសន្និបាតបក្សទូទាំងប្រទេសជាអង្គការខ្ពស់បំផុតរបស់បក្ស។[328] មហាសន្និបាតលើកទី៥ របស់មជ្ឈិមបក្សត្រូវបានប្រារព្ធធ្វើជាចុងក្រោយមុនការដួលរលំក្នុងនៅថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨។[329]

១១៥. ជាក់ស្តែង ភារកិច្ចត្រូវបានអនុវត្តដោយការិយាល័យនយោបាយមជ្ឈិមបក្សដែលធ្វើការប្រជុំគ្នាជាទៀងទាត់នៅរៀងរាល់ថ្ងៃអាទិត្យ ដើម្បីធ្វើការដោះស្រាយបញ្ហាដែលកើតមានទាំងនៅក្នុង និងក្រៅប្រទេស។[330] ចំពោះសមាសភាពសមាជិកការិយាល័យនយោបាយមជ្ឈិមបក្សមាន ៦ (ប្រាំមួយ) រូប រួមមាន៖ ប៉ុល ពត, នួន ជា, អៀង សារី, វន វេត, សុន សេន និង



* ECCC * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ខៀវ សំផន។[331] ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ គណៈកម្មាធិការអចិន្ត្រៃយ៍ប្រជុំយ៉ាងតិច ១៩ (ដប់ប្រាំបួន) លើក។[332]

១១៦. ចំពោះកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នេះ ភាគច្រើនត្រូវបានធ្វើនៅ ក-១ ឬ ពេលខ្លះនៅ ក-៣។[333] សេចក្តីសម្រេចឲ្យមានកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍បក្សត្រូវសម្រេចដោយលេខាបក្ស ប៉ុល ពត។[334] ទីស្នាក់ការកណ្តាលរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្សត្រូវបានគេស្គាល់ជាទូទៅថាជា "មន្ទីរ៨៧០"។[335]

១១៧. អតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុចក៏ បានលើកឡើងផងដែរថា គណៈកម្មាធិការអចិន្ត្រៃយ៍ គឺជាស្ថាប័នដ៏សំខាន់បំផុតនៅក្នុងបក្ស។[336] មិនតែប៉ុណ្ណោះ គណៈកម្មាធិការនេះមានការត្រួតត្រាទៅលើគោលនយោបាយទាំងអស់របស់បក្ស និងរដ្ឋាភិបាលដោយរាប់ទាំងកិច្ចការសន្តិសុខក្នុង និងក្រៅប្រទេស[337] ដោយបូករួមទាំងវិស័យសំខាន់ៗមាន៖ កសិកម្ម សុខាភិបាល និងសង្គមកិច្ច ជាអាទិ៍។[338] គណៈកម្មាធិការអចិន្ត្រៃយ៍បក្ស គឺជាអ្នកផ្តល់ការពិភាក្សាលើបញ្ហាធ្វើការនៅតាមការដ្ឋាន ការសួរចម្លើយ និងការចាប់ខ្លួន ព្រមទាំងពិនិត្យមើលល័ក្ខខ័ណ្ឌរស់នៅទូទាំងប្រទេស និងមានសិទ្ធិអំណាចដើម្បីបញ្ជាឲ្យសម្លាប់មនុស្សបានភ្លាមៗ។[339]

## គ. ស្ថាប័នដទៃទៀត

១១៨. រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យត្រូវបានអនុម័តនាសម័យប្រជុំមហាសន្និបាតជាតិលើកទី ៣ នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៧៥ និងប្រកាសជាផ្លូវការ នាថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦។[340] ជាការកត់សម្គាល់ រដ្ឋធម្មនុញ្ញនេះមានធ្វើការបែងចែកអំណាចជា ៣ (បី) ដែរ ត្បិតយ៉ាងដូចជា អំណាចតុលាការក៏ត្រូវបានចែងអំពីបញ្ហាតុលាការដោយត្រូវបានគេហៅឈ្មោះថា "គណៈកម្មាធិការតុលាការ" ដែលត្រូវបានជ្រើសតាំងដោយសភាតំណាងប្រជាជនកម្ពុជា។[341] គណៈកម្មាធិការនេះគឺជាអង្គការតុលាការរបស់ប្រជាជនដែលតំណាងឲ្យយុត្តិធម៌របស់ប្រជាជន ការពារយុត្តិធម៌របស់ប្រជាជន ការពារសិទ្ធិសេរីភាពប្រជាធិបតេយ្យរបស់ប្រជាជន ហើយផ្តន្ទាទោសដល់គ្រប់សកម្មភាពដែលប្រឆាំងនឹងរដ្ឋរបស់ប្រជាជន ឬដែលល្មើសនឹងច្បាប់រដ្ឋរបស់ប្រជាជន កម្មករ កសិករ និងកងទ័ព[illegible]

កម្ពុជា[342] ក៏ប៉ុន្តែ ជាក់ស្តែង គេសង្កេតឃើញថា ស្ថាប័នមួយនេះពុំត្រូវបានដាក់ឱ្យដំណើរការទេក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។[343]

១១៩. រីឯ អំណាច ២ (ពីរ) ផ្សេងទៀតរួមមាន អំណាចនីតិបញ្ញត្តិដែលត្រូវគេស្គាល់ថាជា "**សភាតំណាងប្រជាជនកម្ពុជា**" និង អំណាចនីតិប្រតិបត្តិដែលត្រូវបានគេស្គាល់ថាជា "**រដ្ឋាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ**"។[344] ក្នុងរបបនោះ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យត្រូវបានគេចាត់ទុកជាអង្គការអនុវត្តច្បាប់ និងមាគ៌ានយោបាយរបស់សភាតំណាងប្រជាជនកម្ពុជា ហើយទទួលខុសត្រូវចំពោះសភាតំណាងប្រជាជនកម្ពុជា ក្រោមហេតុផលថារដ្ឋាភិបាលត្រូវបានជ្រើសតាំងឡើងដោយសភាតំណាងប្រជាជន។[345] ចំពោះអំណាចនីតិបញ្ញត្តិដែលត្រូវបានរបបនោះកំណត់យកឈ្មោះថា "**សភាតំណាងប្រជាជនកម្ពុជា**" ដែលមានអ្នកតំណាងរាស្ត្រសរុបចំនួន ២៥០ (ពីររយហាសិប) រូប ខណៈដែលសមាជិកអ្នកតំណាងរាស្ត្រទាំងនោះត្រូវបានជ្រើសតាំងឡើងដោយប្រជាជនកម្ពុជា និងកងទ័ពបដិវត្តន៍កម្ពុជា តាមរយៈការបោះឆ្នោតដោយផ្ទាល់ និងសម្ងាត់ដោយមានអាណត្តិ ៥ (ប្រាំ) ឆ្នាំ។[346] ក្នុងចំណោមអ្នកតំណាងរាស្ត្រទាំង ២៥០ (ពីររយហាសិប) រូប មានតំណាងមកពីកសិករចំនួន ១៥០ (មួយរយហាសិប) រូប តំណាងកម្មករចំនួន ៥០ (ហាសិប) រូប និងតំណាងកងទ័ពបដិវត្តន៍ចំនួន ៥០ (ហាសិប) រូប។[347]

១២០. ក្នុងអាណត្តិរបស់ខ្លួន សភាតំណាងប្រជាជនកម្ពុជាមានភារកិច្ចបង្កើតច្បាប់ អនុម័តច្បាប់ពិនិត្យនិងតាមដានការអនុវត្តន៍ច្បាប់ ដោយអនុលោមតាមមាគ៌ានយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ។[348] សភាតំណាងប្រជាជនកម្ពុជានេះមានគណៈកម្មាធិការអចិន្ត្រៃយ៍មួយ និងគណៈកម្មាធិការមួយចំនួនផ្សេងទៀតដូចជា គណៈកម្មាធិការសេដ្ឋកិច្ច គណៈកម្មាធិការការពារប្រទេស គណៈកម្មាធិការការបរទេស គណៈកម្មាធិការវប្បធម៌សង្គម និងសុខាភិបាល ជាដើម។[349]

១២១. ក្រមកំណត់របៀបរបបធ្វើការងាររបស់សភាតំណាងប្រជាជនកម្ពុជា ត្រង់មាត្រា ១ បានបញ្ញត្តិថា *"សមាជិករបស់សភាតំណាងប្រជាជនកម្ពុជាមួយរូបៗ ត្រូវស្ថិតនៅជិតស្និទ្ធក្នុងមូលដ្ឋានរបស់ខ្លួនតទៅទៀត ត្រូវរួមសុខរួមទុក្ខជាមួយប្រជាជន ស្គាល់ចិត្តស្គាល់ថ្លើមប្រជាជន ក្តាប់សំណូមពរប្រជាជន ពោលគឺនៅជាប់នឹងសហជីព និងរោងចក្រ នៅក្នុងអង្គភាព*



* E.C.C.C * C.E.T.C * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

*សហករណ៍ការដ្ឋានប្រព័ន្ធភ្លឺ និងប្រឡាយទឹកទៅជាប់នឹងអង្គភាពរបស់ខ្លួន រួមសកម្មភាពកសាងប្រទេស និងការពារប្រទេសជាមួយប្រជាជនកម្មករ និងកសិករពលករផ្សេងៗ យុទ្ធជនយុទ្ធនារី និងកម្មាភិបាលនៃកងទ័ពបដិវត្តកម្ពុជាតទៅទៀត ដើម្បីឲ្យសមស្របនឹងឋានៈរបស់ខ្លួនជាតំណាងពិតប្រាកដរបស់ប្រជាជនកម្ពុជានិងកសិករ ពលករផ្សេងៗ និងកងទ័ពបដិវត្តន៍កម្ពុជា*"។[350]

១២២. ពាក់ព័ន្ធនឹងសមាសភាពថ្នាក់ដឹកនាំរបស់សភាតំណាងប្រជាជនកម្ពុជា សម្រេចរបស់គណៈកម្មាធិការមជ្ឈិមបក្ស ចុះកាលបរិច្ឆេទនាថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ បានសម្រេចតែងតាំង នួន ជា ជាប្រធានគណៈអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន។[351] ជាការកត់សម្គាល់ នៅឆ្នាំ ១៩៧៦ ដដែលនេះ ក្រោយពីរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យត្រូវបានអនុម័តនិងប្រកាសជាផ្លូវរួចហើយនោះ គេសង្កេតឃើញថា សភាតំណាងប្រជាជនកម្ពុជាធ្លាប់បានបើកកិច្ចប្រជុំប្រកាសបង្កើតរដ្ឋសភាបានតែម្តងគត់ ហាក់ដូចជារបបកម្ពុជាប្រជាធិបតេយ្យបានប្រកាសប្រាប់ពិភពលោកថា ក្រោយក្រោមការដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ ប្រទេសកម្ពុជាក៏មានស្ថាប័នរដ្ឋសភាដែរ។[352]

១២៣. ផ្អែកតាមសក្ខីកម្មសាក្សីមួយរូប ដែលជាអតីតអ្នកតំណាងរាស្ត្របានលើកឡើងថា "*ក្នុងនាមខ្លួនជាតំណាងរាស្ត្រ តែខ្លួនមិនដឹងពីការងារនោះទេ ហើយខ្លួនមិនទាំងស្គាល់ប្រធានសភាជាអ្នកណាទេ ហើយថែមទាំងឆ្ងល់ថា សភាហ្នឹងធ្វើការអី?*"។[353] អតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្គេកអ៊ាវ ហៅ ឌុច បាននិយាយថា "*កម្ពុជាជាប្រទេសមួយដែលសភាតំណាងប្រជាជនមានត្រឹមតែជានិមិត្តរូប*"។[354]

១២៤. សភាតំណាងប្រជាជនកម្ពុជាហាក់ដូចជា សភាគ្មានសិទ្ធិអំណាចអ្វីទាំងអស់ ពីព្រោះថាអ្វីៗទាំងអស់ត្រូវស្ថិតនៅក្រោមអំណាចនៃការដឹកនាំរបស់បក្ស។[355] សភាតំណាងប្រជាជនកម្ពុជាបែរជាបានធ្វើការងារជាទៀងទាត់ក្នុងការផ្ញើរសារអបអរសាទរទៅកាន់ប្រទេសជាមិត្តដែលមានទំនាក់ទំនងការទូតជាមួយនឹងរបបកម្ពុជាប្រជាធិបតេយ្យ និងមានការងារមួយទៀតត្រឹមតែជាការទទួលគណៈប្រតិភូសភាបរទេសអញ្ជើញមកទស្សនកិច្ចនៅកម្ពុជា។[356]



* CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

១២៥. អ្វីដែលកាន់តែបង្ហាញនូវអវត្តមាននៃអំណាចរបស់សភាតំណាងប្រជាជននោះគឺ សភានេះមិនដែលបានធ្វើការងារដែលសំខាន់ៗ ទាក់ទិនការបង្កើតនូវសេចក្តីស្នើច្បាប់ ឬ ការពិភាក្សាលើការអនុម័តច្បាប់ណាមួយនោះឡើយ[357] បើទោះបីជារដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យបានចែងយ៉ាងច្បាស់លាស់ថា សភាតំណាងប្រជាជនកម្ពុជាមានភារកិច្ចធ្វើច្បាប់[358] អនុម័តច្បាប់[359] ពិនិត្យតាមដានការអនុវត្តច្បាប់ និងកំណត់មាគ៌ានយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ។[360]

## ឃ. ខ្សែបញ្ជា

១២៦. នៅពេលមានសេចក្តីសម្រេចពីគណៈកម្មាធិការមជ្ឈិមបក្ស ឬ គណៈកម្មាធិការអចិន្ត្រៃយ៍បក្ស យន្តការនៃការផ្សព្វផ្សាយត្រូវបានអនុវត្តដល់លេខាភូមិភាគ និងលេខាតំបន់ស្វយ័តដែលនឹងត្រូវមានកាតព្វកិច្ចធ្វើការ ផ្សព្វផ្សាយនូវគោលនយោបាយ និងសេចក្តីណែនាំជាបន្តទៅឱ្យលេខាតំបន់ និងលេខាស្រុក ដើម្បីអនុវត្តតាមគោលនយោបាយដែលអង្គការថ្នាក់លើដែលបានដាក់ចុះ។[361]

១២៧. ចំណែកឯ យន្តការនៃការរាយការណ៍ត្រឡប់មកវិញ ឃុំនានាត្រូវរាយការណ៍ត្រឡប់ទៅគណៈស្រុក គណៈស្រុកត្រូវរាយការណ៍ជាបន្តទៅគណៈតំបន់។ គណៈតំបន់មានកាតព្វកិច្ចត្រូវរាយការណ៍ជាបន្តទៅគណៈភូមិភាគ។ លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាក៏បានចែងដែរថា "*អង្គការដែលមានសិទ្ធិ និងអំណាចខ្ពស់ជាងគេបំផុត សម្រាប់ភូមិភាគនីមួយៗនោះ គឺគណៈកម្មាធិការភូមិភាគ*"។[362]

## ៣. គោលនយោបាយនៃការបោសសម្អាតនៅភូមិភាគពាយ័ព្យ

១២៨. គោលនយោបាយនៃការបោសសម្អាតការសម្រិតសម្រាំង[363] ឬ វិសុទ្ធកម្ម[364] របស់ ប.ក.ក ត្រូវបានបក្សអនុវត្តចាប់តាំងពីដើមឆ្នាំ ១៩៧៧[365] ខណៈកន្លែងខ្លះតាំងពីឆ្នាំ ១៩៧៥ នៅតាមបណ្តាភូមិភាគ និងតំបន់ស្វយ័ត[366] ពេញផ្ទៃប្រទេសទាំងមូល។[367] អតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុច បាននិយាយថា "*ផ្អែកលើសេចក្តីសម្រេចចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ស្តីពីសិទ្ធិសម្រេចកម្មេចក្នុងជួរនិងក្រៅជួរ*



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * ECCC * CETC

*ប្រគល់តួនាទីកម្ទេចឲ្យកម្មាភិបាល ពោលគឺជាឯកសារខាងចាត់តាំងដែលគេរក្សាជាសម្ងាត់ប្រហែលជាសម្រាប់តែអចិន្ត្រៃយ៍* "។[368] ឌុច បានអះអាងថា "*សេចក្តីសម្រេចរបស់មជ្ឈិមបក្ស ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ នេះ បានសម្រេចបោសសម្អាតទាំងក្នុង និងក្រៅជួរ គឺជាចំណុចគន្លឹះ ដើម្បីធ្វើឲ្យបក្ស កងទ័ព និងប្រជាជនស្អាតស្អំ ហើយការបោសសម្អាតផ្ទៃក្នុងគឺជាចំណុចគន្លឹះ* "។[369] ហើយ ឌុច បានបន្តរៀបរាប់ថា "*ឯកសារនេះមានលក្ខណៈជាប្រវត្តិសាស្ត្រវាបញ្ជាក់ពីរបត់មួយ ពីព្រោះវាបញ្ជាក់ពីការចាប់ផ្តើមនៃការសម្រិតសម្រាំងផ្ទៃក្នុង* "។[370] ដូចគ្នាដែរ សាក្សីម្នាក់ដែលធ្វើការនៅមន្ទីរភូមិភាគធ្លាប់បានអានឯកសារមួយសម្រាប់ចែកចាយទៅសមាជិកបក្សដែលមានសេចក្តីថា យើងត្រូវការបោសសម្អាតខ្មាំងដែលបង្កប់ខ្លួននៅក្នុងបដិវត្តន៍ និងបក្សកុំម្មុយនីស្តកម្ពុជានៅទូទាំងប្រទេស។[371] តាមពិតទៅការបោសសម្អាតខ្មាំងដែលបង្កប់ខ្លួននៅក្នុងបដិវត្តន៍ និងបក្សកុំម្មុយនីស្តកម្ពុជាគឺត្រូវបានលើកយកមកពិភាក្សាតាំងពីបង្កើតបដិវត្តន៍មកម្ល៉េះ។[372]

១២៩. គោលនយោបាយបោសសម្អាតរបស់បក្សកុំម្មុយនីស្តកម្ពុជា ត្រូវបានអនុវត្តចាប់ពីថ្នាក់លើរហូតដល់ក្រោម[373] ដោយអង្គការថ្នាក់លើថា "**ធ្វើម៉េចឲ្យតែបានស្អាត កុំឲ្យមានជនក្បត់នៅក្នុងជួរ**"។[374] សក្ខីកម្មសាក្សីឈ្មោះ ខៀវ អេន បានបង្ហាញថា "*បើអ្នកណាជាបក្ខជន ជាយុវកក បើមកតាមខ្សែមួយណា ហើយខ្សែនោះត្រូវបានចាប់ខ្លួន ពួកគេក៏ត្រូវបានចាប់ខ្លួនដែរ* "។[375] កន្លងមក អតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុច បានធ្វើការបកស្រាយពាក្យ "**សម្រិតសម្រាំង**" មានន័យថា "***ដកសមាសភាពខ្មាំងចេញ ពីក្នុងជួរ ពីក្នុងកងទ័ព ពីក្នុងប្រជាជន ដើម្បីឲ្យជួរឲ្យកងទ័ពឲ្យប្រជាជនស្អាត*** "។[376] ឌុច បានបញ្ជាក់បន្ថែមថា *ការងារសម្រិតសម្រាំងផ្ទៃក្នុងបក្ស និងផ្ទៃក្នុងប្រជាជន ដែលឥឡូវនេះយើងហៅថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ វាជាការងាររបស់ទាំងអស់គ្នា ដែលម្នាក់ៗត្រូវបំពេញទៅតាមតួនាទីរបស់ខ្លួនខានមិនបាន*។[377]

១៣០. ក្នុងបរិបទនេះ រលកនៃការចាប់ខ្លួនបានកើតឡើងស្របពេលគ្នានឹងការកើនឡើងនៃអ្នកឆ្វេងនិយមក្នុងជួរគណៈកម្មាធិការមជ្ឈិមបក្ស។ ជាក់ស្តែង "**វន វ៉េត**" ដែលមានតួនាទីជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច ត្រូវបានចាប់ខ្លួន។[378] អតីតប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន ហៅ ហែម បាននិយាយថា "*គាត់ (វន វ៉េត) ត្រូវគេចាប់ខ្លួន ព្រោះគាត់គឺជាស្ថាបនិករបស់ឃ្លូនបង្កប់នៅក្នុងបក្សកុំម្មុយនីស្តកម្ពុជា ។ ស្រដៀងគ្នានេះដែរ សោ ភឹម ត្រូវ*



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

*ចាប់ខ្លួនដោយសារមូលហេតុដូចគ្នានេះ* ”។[379] ការអនុវត្តនូវគោលនយោបាយនៃការបោសសម្អាតនេះ ប.ក.ក មានការរំពឹងទុកជាមុនខ្ពស់ និងមហិច្ឆតាប្រកបដោយភាពជឿជាក់ថា ការបោសសម្អាតសត្រូវផ្ទៃក្នុងមុខជានឹងជួយទប់ស្កាត់នូវការឈ្លានពានណាមួយពីសំណាក់បរទេសខាងក្រៅជាក់ជាពុំខាន។[380]

១៣១. ការបោសសម្អាតត្រូវបានអនុវត្ត គឺក្រោយពេល ប៉ុល ពត ធ្វើជាអធិបតីនៃកិច្ចប្រជុំដែលនិយាយអំពីការផ្លាស់ប្តូរកម្មាភិបាលចាស់ៗដែលត្រូវបានលែងទុកចិត្ត ហើយក្រោយពីកិច្ចប្រជុំមានកម្មាភិបាលមួយចំនួនបានបាត់ខ្លួន។[381] ម្យ៉ាងទៀត នៅពាក់កណ្តាលឆ្នាំ ១៩៧៧ ការបោសសម្អាត បានចាប់ផ្តើមធឡើងនៅតាមផ្នែកផ្សេងៗទៀត គឺដំបូងនៅខេត្តសៀមរាប បន្ទាប់មកខេត្តកំពង់ធំ និងជាបន្តបន្ទាប់នៅទូទាំងភូមិភាគកណ្តាល ជាដើម[382] ហើយបានកើនឡើងខ្លាំងនាឆ្នាំ ១៩៧៨។[383] យោងតាមចម្លើយរបស់ ឌុច និងសាក្សីផ្សេងទៀត ការបោសសម្អាតអនុវត្តបន្តបន្ទាប់គ្នាចាប់ពីភូមិភាគឧត្តរ បន្តទៅភូមិភាគបស្ចិម បន្ទាប់មកភូមិភាគពាយ័ព្យ និងភូមិភាគបូព៌ា ដោយត្រូវបានចោទថាជាពួកក្បត់។[384] ឌុច និយាយទៀតថា នៅខែ មេសា ឆ្នាំ ១៩៧៨ មានការចាប់ខ្លួនជាស៊េរី ដូចជា លេខាភូមិភាគបស្ចិមឈ្មោះ ជូ ជេត ហៅ ស៊ី បន្ទាប់មក រស់ ញឹម និង គង់ សុផល ហៅ កឹ លេខា និងអនុលេខានៃភូមិភាគពាយ័ព្យជាបន្តបន្ទាប់។[385]

១៣២. ក្នុងបរិបទនៃការបោសសម្អាតទាំងក្នុងជួរនិងក្រៅជួរនេះ ឌុច ឆ្លើយអះអាងថា តាម៉ុក ដែលជាលេខាទី៣ នៃបក្ស និងជាលេខាភូមិភាគនិរតីត្រូវបានតែងតាំងជាលេខាភូមិភាគបស្ចិម ភូមិភាគពាយ័ព្យ និងតំបន់ ៨០១។[386] ខ្លឹមសារនៃសេចក្តីសម្រេចចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ក៏បានចែងយ៉ាងច្បាស់ទាក់ទងការបោសសម្អាតនៅក្នុងភូមិភាគថា បើនៅក្នុងក្របខ័ណ្ឌមូលដ្ឋានត្រូវ “**អចិន្ត្រៃយ៍ភាគសម្រេច**”។[387]

១៣៣. ការបោសសម្អាតនៅភូមិភាគពាយ័ព្យទំនងជាអាចបានចាប់ផ្តើមតាំងពីឆ្នាំ១ ៩៧៦[388] ឬ ខែ មករា ឆ្នាំ១៩៧៧[389] ពោលតាំងតែជំនាន់កម្មាភិបាលពាយ័ព្យគ្រប់គ្រងភូមិភាគនេះ[390] ដែលក្នុងពេលនោះ រស់ ញឹម ជាលេខាភូមិភាគនៅឡើយ[391] និងបន្តរហូតដល់ពេលកម្មាភិបាលនិរតីគ្រប់គ្រងភូមិភាគនេះ។[392] ក្នុងពេលនោះ នៅភូមិភាគពាយ័ព្យមានរៀបចំអង្គប្រជុំលើបញ្ហានេះ ដើម្បីរៀបចំការបោសសម្អាតដោយមានការចូលរួមប្រជុំពីខាងគណៈភូមិភាគ



E.C.C.C * C.E.T.C * INVESTIGATING JUDGES · CO-JUGES D'INSTRUCTION

តំបន់ ស្រុក មេឃុំ ប្រធានសហករណ៍ និង មេកង។[393] សាក្សីម្នាក់ទៀតឆ្លើយថា ដើមឡើយ នៅពាក់កណ្ដាលឆ្នាំ ១៩៧៧ ពួកបស្ចិមបានមកជំនួស និងបោសសម្អាតពួកពាយ័ព្យដោយអន្លើៗ ហើយក្រោយមកទើបមានពួកនិរតីមកបោសសម្អាតពួកពាយ័ព្យកាន់តែខ្លាំងឡើងនៅពាក់កណ្ដាលឆ្នាំ ១៩៧៨។[394] សាក្សីយ៉ាងច្រើនបង្ហាញដូចៗគ្នាថា តាម៉ុក មកគ្រប់គ្រងពាយ័ព្យតាំងពីខែមករាឆ្នាំ ១៩៧៧[395] មុន រស់ ញឹម ត្រូវចាប់ខ្លួនរហូតដល់ពេលដួលរលំនៃរបបខ្មែរក្រហម។[396] នៅពាក់កណ្ដាលឆ្នាំ ១៩៧៨ ក្រោយពេលចាប់ខ្លួន រស់ ញឹម និងយកទៅឃុំខ្លួននៅក្នុងគុកទួលស្លែង និងដកកម្មាភិបាលជាន់ខ្ពស់ចេញពីតំណែង ហើយ តាម៉ុក ក៏ក្លាយជាលេខាភូមិភាគពាយ័ព្យជាផ្លូវការ។[397]

១៣៤. សាក្សីជាច្រើនដែលត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យបានចូលរួមប្រជុំនៅតាកែវ មុនពេលចេញដំណើរដែលនៅទីនោះ តាម៉ុក បានប្រកាសថា បាត់ដំបងជា “*តំបន់រំដោះថ្មី* ” សភាពការណ៍នៅទីនោះ “*មិនល្អ* ” ហើយភូមិភាគត្រូវការជំនួយ[398] ហើយ តាម៉ុក បានចោទមនុស្សទាំងអស់នៅភូមិភាគពាយ័ព្យទាំងអស់ថាជាជនក្បត់។[399] យោងតាមចម្លើយរបស់សាក្សីជាច្រើន ការបោសសម្អាតនៅភូមិភាគពាយ័ព្យត្រូវបានធ្វើឡើងប្រឆាំងនឹងកម្មាភិបាលភូមិភាគពាយ័ព្យ ដោយការចោទ “*ភូមិភាគពាយ័ព្យទាំងអស់ក្បត់* ”[400] ឬ យកលេសថាមករំដោះភូមិភាគពាយ័ព្យ[401] ឬ មានចលនាបះបោរផ្ដាច់ខ្លួន[402] ឬ ជាភ្នាក់ងារកាហ្សេបេ ឬ សេអ៊ីអា[403] ឬ ជាគិញវៀតណាម ឬ ក្បាលយួនខ្លួនខ្មែរ[404] ឬ ទប់ទល់ជាមួយវៀតណាម[405] ឬ បានប្រព្រឹត្តកំហុស និងមិនដើរតាមអង្គការ[406] ឬចោទថាពួកពាយ័ព្យនៅមានកម្មសិទ្ធិឯកជននិងសម្ភារៈនិយម ហើយពួកពាយ័ព្យនៅតែក្នុងការិយាល័យ មិនចុះទៅតាមការដ្ឋាន[407] ឬ ដោយសារពួកពាយ័ព្យកាលនោះមានពាក្យស្លោកថា ក្បាលមិនជាប់មេឃ ជើងមិនជាប់ដី[408] ឬ ដោយសារនៅភូមិភាគពាយ័ព្យមានខ្វះកម្មាភិបាល។[409]

១៣៥. ការបោសសម្អាតសំដៅផងដែរចំពោះអ្នកដែលត្រូវបានសង្ស័យថាជាប់ទាក់ទងជាមួយនឹងវៀតណាម ឬ គិញវៀតណាម ដូចជាខ្មែរក្រោម[410] និងទៅលើប្រជាជនធម្មតា[411] ព្រមទាំងទៅលើពួកនិរតីចាស់ដែលបានមកដល់ភូមិភាគពាយ័ព្យមុនដោយចោទថា ក្បត់និងមិនតឹងរ៉ឹងប្រាសចាកពីរបបផ្ដាច់ការ។[412]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

១៣៦. ដំបូងឡើយ រស់ ញឹម ដែលជាលេខាភូមិភាគពាយ័ព្យធ្លាប់បានចាប់ខ្លួន តា ហឿន ដែលជាលេខាស្រុកភ្នំសំពៅ ប្រហែលនៅដើមឆ្នាំ ១៩៧៨ ដោយចោទថាជាភ្នាក់ងារសេអ៊ីអា។[413]

១៣៧. ក្នុងពេលប្រជុំកងទ័ព តាហាប់ បានឡើងប្រកាសថា តាម៉ុក ដែលតឹងតែងនឹងប្រជាជន សម្លាប់ប្រជាជន និងទាហាន[414] គឺជាអ្នកសកម្ម និងចេញបញ្ជានានា ហើយតាម៉ុកគ្រប់គ្រង ៣ ភូមិភាគ។[415] សាក្សី ពេជ្រ ជឹម និយាយថា បន្ទាប់ពីបោសសម្អាតបួនភូមិភាគរួចមក វិទ្យុបានផ្សាយអំពី ប៉ុល ពត តែងតាំង តាម៉ុក ជាប្រធានអគ្គសេនាធិការដោយគ្រប់គ្រងលើ សុន សេន ដែលជាអគ្គសេនាធិការ។[416] ឌុច ឆ្លើយអះអាងស្រដៀងគ្នាដែរថា ប៉ុល ពត បានចេញបញ្ជាផ្ទាល់តែងតាំង តាម៉ុក ដែលជាលេខាទី៣ នៃបក្ស និងជាលេខាភូមិភាគនិរតី ឱ្យធ្វើជាលេខាភូមិភាគបស្ចិម ភូមិភាគពាយ័ព្យ និងតំបន់ ៨០១[417] និងត្រូវបានចាត់តាំងឱ្យមកបោសសម្អាតភូមិភាគពាយ័ព្យ និងប្រជាជនដែលចោទថាក្បត់។[418] នៅឆ្នាំ ១៩៧៧ ក្រោយពេល តាម៉ុក បានដឹកនាំអង្គប្រជុំនៅវាយបែកចាន ជិតព្រលានយន្តហោះខេត្តបាត់ដំបង ដោយមានការចូលរួមពីកម្មាភិបាលថ្នាក់នៃភូមិភាគពាយ័ព្យរួច តាម៉ុក បានដកតំណែង រស់ ញឹម និង តាកៅ។[419] សាក្សីម្នាក់បញ្ជាក់ថា ក្រោយការខ្លួនចាប់ខ្លួន តា រស់ ញឹម យកទៅឃុំនៅទួលស្ដេង ឈ្មោះ តាគី បានឡើងប្រកាសក្នុងអង្គប្រជុំថា **តាទិត្យ** បានឡើងជាលេខាតំបន់ និងក្រោយមកគ្រប់គ្រងភូមិភាគពាយ័ព្យផងដែរ។[420] ដោយឮឈ្មោះអ្នកធំតែ ២ (ពីរ) នាក់ តាម៉ុក និង **តាទិត្យ** សាក្សីម្នាក់ទៀតសន្និដ្ឋានថា **តាទិត្យ** ក៏ជាអនុភាគពាយ័ព្យដែរ។[421] សាក្សី លឹម ទឹម បានចូលរួមសន្និបាតមួយនៅសាលាសាកលបាត់ដំបងដែលមានតែកងការពារនិងយោធាចូលរួម ដោយសន្និបាតបានឧទ្ទេសនាម **តាទិត្យ** ជាប្រធានភូមិភាគ។[422]

១៣៨. ផ្ទុយទៅវិញ មានតែសាក្សីតែម្នាក់ដែលឆ្លើយយ៉ាងច្របូកច្របល់នៅចំពោះមុខការិយាល័យសហព្រះរាជអាជ្ញាប៉ុណ្ណោះដែលបានឆ្លើយថា **តាទិត្យ** បានមកជំនួសតាប៉ែតនៅថ្នាក់ភូមិភាគ ក្រោយពេលកម្មាភិបាលពាយ័ព្យថ្នាក់ភូមិភាគ និងតំបន់ត្រូវបានបោសសម្អាតអស់[423] និងថា **តាទិត្យ** បានប្រកាសខ្លួនគាត់ជាប្រធានភូមិភាគពាយ័ព្យថ្មី នៅក្នុងកិច្ចប្រជុំមួយចុងឆ្នាំ ១៩៧៨ ហើយ តាប៉ែត លែងជាប្រធានទៀតហើយ។[424]

១៣៩. ដើម្បីអនុវត្តគោលនយោបាយនៃការបោសសម្អាតទាំងក្នុងជួរ និងក្រៅជួរបក្សតាមសេចក្ដីសម្រេចរបស់គណៈមជ្ឈិមបក្ស និងបទបញ្ជារបស់ ប៉ុល ពត ឱ្យមានប្រសិទ្ធិភាព នៅដើម



E.C.C.C * C.E.T.C * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ឆ្នាំ ១៩៧៦ និងបន្តរហូតដល់ឆ្នាំ ១៩៧៨ តាម៉ុក ដែលជាលេខាភូមិភាគនិរតី[425] បានបញ្ជូនកម្មាភិបាលជាច្រើនក្រុមពីភូមិភាគនិរតីឱ្យទៅជំនួសកម្មាភិបាលមូលដ្ឋាននៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលនៃភូមិភាគពាយ័ព្យ។[426] ការប្រជុំបានធ្វើឡើងនៅឆ្នាំ ១៩៧៦[427] ឆ្នាំ ១៩៧៧[428] និងឆ្នាំ ១៩៧៨។[429] តាម៉ុក និងកម្មាភិបាលជាន់ខ្ពស់ផ្សេងទៀតបានចាត់តាំងកម្មាភិបាលពីភូមិភាគនិរតីឱ្យទៅកាន់តំណែងនិងទីកន្លែងផ្សេងៗនៅពេលពួកគេទៅដល់ភូមិភាគពាយ័ព្យ។[430]

១៤០. ទាក់ទងនឹងការរៀបចំបញ្ជូនប្រជាជននិងកម្មាភិបាលមកពាយ័ព្យ សាក្សីទាំងឡាយមិនបានបង្ហាញការចូលរួមរបស់ **តាទិត្យ** ទេ គឺមានតែ តាម៉ុក។[431] តាម៉ុក បានបញ្ជូនកម្មាភិបាលភូមិភាគនិរតីទៅភូមិភាគពាយ័ព្យ ៣ (បី) ដង។[432] លើកទីមួយធ្វើឡើងនៅឆ្នាំ ១៩៧៦ នៅពេលដែល កម្មាភិបាលភូមិភាគនិរតីមួយក្រុមតូចត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ ដើម្បីធ្វើការជាមួយកម្មាភិបាលភូមិភាគពាយ័ព្យ តែមិនបានទៅជំនួស ឬគ្រប់គ្រងពួកគេទេ។[433] លើកទីពីរធ្វើឡើងនៅឆ្នាំ ១៩៧៧ និងដើមឆ្នាំ ១៩៧៨ នៅពេល តាម៉ុក បញ្ជូនកម្មាភិបាលភូមិភាគនិរតី រួមជាមួយក្រុមគ្រួសារពួកគេ ដើម្បីទៅចាប់ខ្លួន និងជំនួសកម្មាភិបាលភូមិភាគពាយ័ព្យនៅថ្នាក់ឃុំ សហករណ៍ និងស្រុក។[434] ការបញ្ជូនកម្មាភិបាលលើកទីបីធ្វើឡើងនៅពាក់កណ្ដាលឆ្នាំ១៩៧៨។ នៅពេលនោះ កម្មាភិបាលភូមិភាគនិរតីបានទៅជំនួសកម្មាភិបាលភូមិភាគពាយ័ព្យថ្នាក់លើ ដោយបោសសម្អាតកម្មាភិបាលភូមិភាគពាយ័ព្យនៅថ្នាក់តំបន់ និងភូមិភាគ តែក៏បានទៅជំនួសកម្មាភិបាលថ្នាក់ក្រោមនៅថ្នាក់ស្រុក និងឃុំ ដែលធ្វើការក្រោមកម្មាភិបាលភូមិភាគ និងតំបន់ មុនពេលមានការបោសសម្អាតដែរ។[435] សក្ខីកម្មផ្សេងទៀតបង្ហាញថា តាម៉ុក ក៏បានបដិសេធសំណើសម្លាប់មនុស្ស ក្នុងព្រឹត្តិការណ៍នាថ្ងៃមួយចន្លោះពីម៉ោង ៧ (ប្រាំពីរ) ដល់ ១០ (ដប់) ព្រឹក ក្នុងឆ្នាំ១៩៧៨ ក្នុងភូមិទួសទូក ដែលក្នុងព្រឹត្តិការណ៍នោះតាឡឹក និងយាយចាន់ដែលជាមនុស្សកាចសាហាវ ដោយមានកងទ័ពឃាមប្រដាប់ដោយកាំភ្លើង និងគ្រាប់បែកចង់សម្លាប់មនុស្ស ១.៤០០ (មួយពាន់បួនរយ) នាក់ដែលប្រមូលផ្ដុំគ្នាដោយប្រើគ្រាប់បែក។[436] ក្នុងចំណោម ១.៤០០ (មួយពាន់បួនរយ) នាក់ តាម៉ុក បានសង្ស័យថា មានគិញវៀតណាម ឬ ក្បាលយួនខ្លួនខ្មែរ ប្រមាណតែ ៣០០ (បីរយ) នាក់។[437]

១៤១. បញ្ជានៃការបោសសម្អាត គឺចេញមកពីថ្នាក់ភូមិភាគទៅថ្នាក់តំបន់ ហើយថ្នាក់តំបន់បញ្ជាបន្តទៅថ្នាក់ស្រុក។[438] សាក្សី ហែម មឿន ដែលជាទាហាន និងជាសាច់ញាតិរបស់តាម៉ុក



* CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

ដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយ តាម៉ុក នៅភូមិភាគពាយ័ព្យ លើកឡើងថា មុនពេលកងពលនៃកងទ័ពរបស់គាត់ត្រូវបានបញ្ជូនទៅបាត់ដំបងនៅដើមឆ្នាំ ១៩៧៨ តាម៉ុក បានបញ្ជាឱ្យពួកគេ "*បោសសម្អាតពួកពាយ័ព្យ*"។[439] ក្នុងយុទ្ធនាការបោសសម្អាតនេះ កម្មាភិបាលស៊ីវិលគ្មានសិទ្ធិសម្លាប់មនុស្សទេ តែផ្ទុយទៅវិញ យោធាទើបមានសិទ្ធិសម្លាប់មនុស្ស។[440] សាក្សីម្នាក់ទៀតឆ្លើយថា ដើមឡើយ នៅពាក់កណ្ដាលឆ្នាំ ១៩៧៧ ពួកបស្ចិមបានមកជំនួស និងបោសសម្អាតពួកពាយ័ព្យដោយអន្លើៗ ហើយក្រោយមកទើបមានពួកនិរតីមកបោសសម្អាតពួកពាយ័ព្យកាន់តែខ្លាំងឡើងនៅពាក់កណ្ដាលឆ្នាំ ១៩៧៨។[441]

១៤២. ការបោសសម្អាតមិនត្រូវបានប្រកាសឱ្យដឹងទេ ព្រោះជារឿងសម្ងាត់[442] ជាក់ស្ដែង នៅដើមឆ្នាំ ១៩៧៨ សេក សំអាត ដែលត្រូវបានផ្ទេរទៅធ្វើជាសមាជិកគណៈស្រុកបាកានតាមបញ្ជាដ៏តឹងរ៉ឹងរបស់ឈ្មោះ រ៉ែន ក៏មិនបានដឹងអំពីផែនការបោសសម្អាតភូមិភាគពាយ័ព្យដែរ។[443] បន្ថែមលើនេះ សាក្សីបានឆ្លើយថា តាញ៉ាន មានបញ្ជីឈ្មោះមនុស្សដែលត្រូវចាប់ខ្លួន ដោយចោទថាប្រជាជននៅពាយ័ព្យ និងនៅបូព៌ាបានសហការជាមួយកងទ័ពវៀតណាម។[444]

១៤៣. នៅពេលដែលកម្មាភិបាលនិរតីមកដល់ ការចាប់ខ្លួននេះនៅកើតមានបន្ត និងមានសភាពកាន់តែធ្ងន់ធ្ងរ។ ការបោសសម្អាតធ្វើឡើងតាំងពីថ្នាក់ក្រោមដល់ថ្នាក់លើ ពោលគឺចាប់ពីថ្នាក់ភូមិ ថ្នាក់ឃុំ ឬ សហករណ៍ ស្រុក តំបន់ រហូតដល់ថ្នាក់ភូមិភាគ។[445]

១៤៤. ដោយមានក្រុមចាត់តាំងស្រេច និងមានយោធា ដែលអនុញ្ញាតអាចឱ្យមានការជំនួសភ្លាមៗតែម្ដង[446] ពួកនិរតីបានធ្វើការចាប់ខ្លួន កងទ័ព និងកម្មាភិបាលភូមិភាគពាយ័ព្យសូម្បីតែនៅកន្លែងប្រជុំ និងយកទៅឃុំឃាំងនៅតាមមន្ទីរសន្តិសុខនានាក្នុងភូមិភាគពាយ័ព្យ និងនៅមន្ទីរ ស-២១ នៅភ្នំពេញ ឬ ដកហូតតំណែង ឬ ចាត់តាំងឱ្យធ្វើការងារនៅតាមការដ្ឋាននានាក្នុងភូមិភាគពាយ័ព្យដើម្បី "កសាងខ្លួន" ឬ យកទៅសម្លាប់ ឬបាត់ខ្លួនបន្ទាប់ពីហៅទៅរៀនសូត្រ។[447] យោងតាមបញ្ជីអ្នកទោសនៅ ស-២១ កម្មាភិបាលនិងប្រជាជនភូមិភាគពាយ័ព្យសរុបចំនួន ៣៤៦ (បីរយសែសិបប្រាំមួយ) នាក់ ដែលក្នុងនោះមានយោធា ៧៥ (ចិតសិបប្រាំ) នាក់ កម្មាភិបាលស៊ីវិលថ្នាក់ភូមិភាគ ៨៦ (ប៉ែតសិបប្រាំមួយ) នាក់ ថ្នាក់តំបន់ ៧៦ (ចិតសិបប្រាំមួយ) នាក់ ថ្នាក់ស្រុក ៣៦ (សាមសិបប្រាំមួយ) នាក់ និងប្រជាជនចាស់ថ្មី



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

៧៣ (ចិតសិបបី) នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន សួរចម្លើយ និងសម្លាប់ចោលនៅ ស-២១។[448]

១៤៥. តាម៉ុក បានធ្វើការដកហូតអាវុធពីយោធាស្រុកនិងតំបន់អស់ ដោយសារពួកគេចង់បះបោរ។[449] សាក្សីដែលរស់នៅជិតផ្ទះរបស់កម្មាភិបាលថ្នាក់តំបន់ផ្តល់សក្ខីកម្មថា ក្រោយពីតាម៉ុកបានមកដល់ភូមិភាគពាយ័ព្យ កម្មាភិបាល និងយោធាពាយ័ព្យជាច្រើនត្រូវបានចាប់ខ្លួន ឃុំខ្លួន និងសម្លាប់ចោល និងខ្លះត្រូវបញ្ជូនតាមរថយន្តទៅគុកទួលស្លែង។[450] ដោយឡែកកម្មាភិបាលជាន់ខ្ពស់ថ្នាក់ភូមិភាគ និងតំបន់មិនត្រូវបានចាប់ខ្លួន ប៉ុន្តែត្រូវបានគេហៅទៅដោយប្រាប់ថា ទៅរៀនសូត្រ។[451]

១៤៦. ជាក់ស្តែង នៅថ្នាក់ភូមិភាគ ក្នុងខែកក្កដាឆ្នាំ១៩៧៨ រស់ ញឹម ជាលេខាភូមិភាគ[452] រហូតដល់ពេលត្រូវចាប់ខ្លួនយកទៅគុកទួលស្លែងនៅពាក់កណ្តាលឆ្នាំ ១៩៧៨ ហើយ តាម៉ុក ក៏ក្លាយជាលេខាភូមិភាគពាយ័ព្យជាផ្លូវការ។[453] តាគី ជាអនុលេខាភូមិភាគទី២ តាប៉ែត ជាអនុលេខាភូមិភាគទី៣ ក្រោយចាប់ខ្លួនតាគី នៅឆ្នាំ១៩៧៧ ទើប តាប៉ែត ឡើងជាអនុលេខាភូមិភាគទី២ រហូតដល់ចុងឆ្នាំ ១៩៧៧។[454] តាសាយ គណៈមន្ទីរភាគនិងលេខាតំបន់១ ពីដំបូងដល់ចុងឆ្នាំ១៩៧៥ ត្រូវបានចោទថាក្បត់និងចាប់ខ្លួន។[455] កម្មាភិបាលថ្នាក់ភូមិភាគឈ្មោះតាហ៊ឹម ក៏ត្រូវបានបោសសម្អាត។[456] តាមបញ្ជីអ្នកទោស ស-២១ ខែកញ្ញា ឆ្នាំ១៩៧៧ កម្មាភិបាលនៅមន្ទីរ ក្រសួងក្នុងភូមិភាគពាយ័ព្យត្រូវបានចាប់យកមកឃុំខ្លួននៅ ស-២១ រួមមានជាអាទិ៍៖ ស៊ុន ទឹម វរៈសេនាធំកងចល័តភាគ, ប៊ូ រ៉ិម សមាជិកវរៈសេនាតូច ៥៤, កងសមាសភាព កែវ កាន់ ហៅ ខឿន ប្រធានទូរគមនាគមន៍ភាគ, ណុប សឿន ប្រធានម៉ាស៊ីនកិនស្រូវពាណិជ្ជកម្មភាគ, ឃួន កែង ប្រធានឃ្លាំងប្រេងភាគ, ផាច ផ្លូយ ហៅ ប៉ូច ប្រធានម៉ាស៊ីនស្រូវរបស់ភាគនៅមង្គលបូរី, ហួយ ទូច ហៅ ថា ពិនិត្យអង្ករភាគ, ពៅ នេត យុទ្ធជនពេទ្យសត្វភាគ, កែប សុផុន យុទ្ធជនសិល្បៈភាគ អែម ម៉ន ប្រធានពាណិជ្ជកម្មភាគ[457], ហាម ឈិ ហៅ ហឿម ប្រធានកងចល័តរបស់ភាគ[458], ញ៉ិម សេត ប្រធានកសិកម្មភាគ, តន់ យេង ប្រធានក្រុមដឹកជញ្ជូនពាណិជ្ជកម្មភាគ និង ឈឹន ស៊ើន ប្រធានក្រុមជាងដែកភាគ។[459] អំឡុងឆ្នាំ ១៩៧៨ ការចាប់ខ្លួនកម្មាភិបាលមកពីតំបន់ ៤ មកសួរឃុំឃាំង សួរចម្លើយ នៅ ស-២១ នៅបន្តកើតមានក្នុងនោះរួមមាន៖ អ៊ុន សំអាង ប្រ[illegible] ម៉ាស៊ីនកិនស្រូវភូមិភាគ, លាយ ខួង អនុប្រធានពាណិជ្ជកម្មភូមិភាគ, លឹម ណា[illegible]

ប្រធានពាណិជ្ជកម្មភូមិភាគ, អួច រស់ ប្រធានគមនាគមន៍ភូមិភាគ, វ៉ែន វ៉ាន ប្រធានបច្ចេកទេសពេទ្យ ព៣ ភូមិភាគ,ឃី ខន អនុប្រធានសន្តិសុខរបស់ភូមិភាគ, អឿន ឆួម ប្រធានកងការពារមន្ទីរភាគ ម៣២, ម៉ា អ៊ុមស្រី លេខា វរៈសេនាតូច ៤៥៤ របស់ភូមិភាគ ឈឹម សៀប អនុលេខាវរៈសេនាតូច ៤៥៤ របស់ភូមិភាគ, អ៊ាម វ៉ាន គណៈកម្មាធិការពេទ្យ ព១ ភាគ, មួង ខឿ ហៅ លឹម ប្រធានរោងចក្រក្រឡឹងមង្គលបូរីភាគ[460], ពួក អេង ហៅ ផាន់ ជាសមាជិក វរៈសេនាតូច ៨៦ កាំភ្លើងធំរបស់ភូមិភាគ[461], យន់ ប៉េងសេង ហៅ សារ៉ា អនុប្រធានផលិតថ្នាំភូមិភាគ[462], គង់ សន សមាជិកពាណិជ្ជកម្មភូមិភាគ[463] ម៉ុម សាន ហៅ ចុង ប្រធានពេទ្យរបស់ភូមិភាគ[464], អ៊ុក ឆាត់ ហៅ វី ប្រធានពេទ្យ ព២ ភូមិភាគ[465], ជា កៀវ ហៅ កយ អនុប្រធានសន្តិសុខភូមិភាគ[466], និង ឈីន ខន អនុសន្តិសុខភូមិភាគ ជាដើម។[467]

១៤៧. ចំណែកឯ កម្មាភិបាលជាន់ខ្ពស់ទាំងផ្នែកស៊ីវិល និងយោធា ថ្នាក់តំបន់ ថ្នាក់ស្រុក ជាច្រើនក៏ត្រូវបានបោសសម្អាតផងដែរ។ នៅក្នុងតំបន់ ១ តាសាយ គណៈមន្ទីរភូមិភាគនិងលេខាតំបន់ ១ ពីដំបូងដល់ចុងឆ្នាំ ១៩៧៥ ត្រូវបានចោទថាក្បត់និងចាប់ខ្លួន។[468] ជា ហួន ហៅ តាវ៉ាញ លេខាតំបន់១ ជាមេបញ្ជាការយោធាតំបន់ និងជាអ្នកគ្រប់គ្រងទំនប់កង្គួតបន្តពី តាសាយ ឆ្នាំ នៅខែ កញ្ញា ឆ្នាំ ១៩៧៧ ត្រូវបានបោសសម្អាត និងយកទៅឃុំខ្លួននៅ ស-២១ ក្រោមបញ្ជារបស់មជ្ឈិមបក្ស ដោយសារថា តាវ៉ាញ បានប្រមូលអាវុធយកទៅលាក់ទុកនៅខាងកើតភ្នំធិបតី ដើម្បីបះបោរ បន្ទាប់ពីមានការប្រកាសថា ប៉ុល ពត ជាលេខាបក្ស។[469] តា ហេង ទាវ ហៅតាប៉ែត ក៏កាន់តួនាទីជាលេខាតំបន់១ ជំនួស តាវ៉ាញ។[470] បន្ទាប់មក ដោយសារខែសីហា ឆ្នាំ១៩៧៨ ហេង ទាវ ហៅ តាប៉ែត និងប្រពន្ធរបស់គាត់ត្រូវបានចាប់ខ្លួនដោយពួកនិរតី រួចបញ្ជូនទៅវាយថ្ម កាប់ឫស្សីនៅខេត្តកំពង់ស្ពឺតាមបញ្ជារបស់តាម៉ុក[471] តាទិត្យ បានឡើងជំនួសតាប៉ែតក្នុងតួនាទីជាគណៈតំបន់១ និងជំនួយការភូមិភាគ[472] ក្រោយរៀតណាមចូលមកដល់៣ថ្ងៃ។[473] ក្នុងស្រុកគាស់ក្រឡ កម្មាភិបាលថ្នាក់ខ្ពស់ និងថ្នាក់ទាបជាច្រើនត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខគាស់ក្រឡ ហើយកម្មាភិបាលថ្នាក់ទាបខ្លះនៅរស់រានមានជីវិត។[474] ពួកនិរតីធ្វើការបោសសម្អាតដោយត្រូវចាប់ខ្លួនទាំងគ្រួសារ និងសម្លាប់ប្រជាជនមូលដ្ឋាននិងកម្មាភិបាលពាយ័ព្យក្នុងតំបន់ ១ ទាំងគ្រួសារតែម្តងជាពិសេស កម្មាភិបាលថ្នាក់ឃុំ និងស្រុក។[475] ដោយឡែក មានកម្មាភិបាលតំបន់១ ជាច្រើន ត្រូវបានចាប់ខ្លួនយកមកឃុំខ្លួននៅ ស-២១ ក្នុងឆ្នាំ១៩៧៧ រួមមានជាអាទិ៍ អ៊ុយ អុល ហៅ ធឿម ជាប្រធានមន្ទីរភូមិ

កុយ សំ ប្រធានពាណិជ្ជកម្មតំបន់, រស់ ខ្លូង ហៅ វ៉ាន់ ជំនួយការចំការកប្បាសស្រុកសង្កែ, សូ យួម ហៅ វ័ន្ត យុទ្ធជនពេទ្យកសិដ្ឋានចំការកប្បាសតំបន់[476] និង អឿន ឡេង អនុលេខាស្រុកគាស់ក្រឡ ជាដើម។[477]

១៤៨. ចំពោះតំបន់ ២ មេបញ្ជាការតំបន់ ២ ឈ្មោះ តានៅ ត្រូវបានបោសសម្អាតនៅឆ្នាំ ១៩៧៧ ហើយជំនួសដោយឈ្មោះ កាន ដែលមកពីនិរតី។[478] មុនពេល សេក សំអាត ទៅដល់ស្រុកបាកាន វ៉ែន គឺជាលេខាស្រុកបាកាន ហើយយ៉ាន់ គឺជាអនុលេខាស្រុក ហើយក្រោយមកវ៉ែន ត្រូវបានជំនួសដោយឈ្មោះ ប៉េង។[479] ចន្លោះឆ្នាំ១៩៧៧ ដល់ ឆ្នាំ១៩៧៨ កម្មាភិបាលជាច្រើនត្រូវបានចាប់ខ្លួនយកទៅឃុំខ្លួន សួរចម្លើយ នៅ ស-២១ រួមមានជាអាទិ៍៖ ស្រី សំអឿន ឬ ស្រី អឿម ជាលេខាតំបន់២[480], អ៊ឹម ឆាវ ជាលេខាវរៈសេនាតូច ៣៥០ ប្រចាំតំបន់[481], នារី ឡាវ គាវ ហៅ ឃីម ជាប្រធានពេទ្យក្រុងពោធិសាត់ និងប្រពន្ធរបស់វ៉ាញ លេខាតំបន់ ១[482], អ៊ួង ជិន ហៅ ជល់ ឬផល ជំនួយការស្រុកក្តាត[483], ហុង អ៊ី ហៅ អ៊ឹម ឬ អ៉ឹម ជំនួយមន្ទីរស្រុកក្រគរ[484], ជា អឿន អនុលេខាស្រុកក្រគរ[485], និងអ៊ូច ផុន លេខាស្រុកមោងឬស្សី ជាដើម។[486]

១៤៩. ក្នុងតំបន់៣ តានាំ បានមកជំនួសតាហឿន ហើយតាឆេង និងតាម៉ុន ក្លាយជាគណៈស្រុកភ្នំសំពៅ[487] បន្ទាប់មកតា ឆាំ ដែលជាគណៈភ្នំសំពៅបានបាត់ខ្លួន ហើយត្រូវបានជំនួសដោយតា ម៉ៅ ដែលជាកម្មាភិបាលនិរតី។[488] កម្មាភិបាលតំបន់៣ ជាច្រើន ត្រូវបានចាប់ខ្លួនយកទៅ ស-២១ នៅចន្លោះឆ្នាំ ១៩៧៧ ដល់ ឆ្នាំ ១៩៧៨ រួមមានជាអាទិ៍៖ រ៉ន ជេត ហៅ គូ អនុលេខាតំបន់[489], ឆេង ឆន លេខាស្រុកបវិល[490], រិត នាល់ លេខាស្រុកអំពិល[491], វ៉ែន ម៉ើក លេខាវរៈសេនាធំតំបន់៣[492], ហាន ជន ហៅ យន់ ប្រធានពេទ្យតំបន់ ៣[493], ស្វាយ អឿត លេខាស្រុកប៉ោយប៉ែត[494], ផៃ ឡុប អនុប្រធានពាណិជ្ជកម្ម និង ស្វាយ អឿត លេខាស្រុកប៉ោយប៉ែត ជាដើម។[495]

១៥០. ចំណែកឯក្នុងតំបន់៤ វិញ កម្មាភិបាលថ្នាក់តំបន់ និងស្រុកជាច្រើនរូប ត្រូវបានចាប់យកមកឃុំខ្លួននៅ ស-២១ ក្នុងអំឡុងឆ្នាំ ១៩៧៧ ដល់ ឆ្នាំ ១៩៧៨ រួមមានជាអាទិ៍៖ មិញ ធៀម ឬ មិញ ធើម ហៅ ប៉ាង ជាលេខាតំបន់[496] ខែក ប៊ុន ហៅ តាស៊ូ ជាលេខាតំបន់, ស៊ុន ... ហៅ ស៊ុយ ជាអនុលេខាតំបន់, តូច មួច ជាសមាជិកតំបន់, សេង ស៊ី មឿន ហៅ...



ECCC * C.E.T.C * JUGES D'INSTRUCTION

សមាជិកមន្ទីរតំបន់, ស៊ុយខឿន ទទួលបន្ទុករោងជាក្រឡឹងស្រុកដូនទាវ, យ៉ូវ អុំ កាន់ស្ថិតិស្រុកដូនទ្រី ជុង ផារប់ ធ្វើស្ថិតិស្រុកដូន ទាវ, ថង វ៉ាត់ ធ្វើស្ថិតិស្រុកដូនទាវ, លាត លានហួស្ថិតិប្រព័ន្ធភ្លើស្រុកដូនទាវ, ឈួន ញ៉ូយ នីរសារតំបន់ ឯម សិម អនុលេខាស្រុកដូនទាវ[497], ម៉ក់ វ៉ៃ អនុលេខាស្រុកដូចទ្រី, ជឹម ចន អនុលេខាស្រុកដូចទាវ, ស្រី ឆាំ លេខាវរៈសេនាតូចយោធាតំបន់[498], ខុង អិន ប្រធានមន្ទីរតំបន់[499] និង វៅ ហាន សមាជិកពាណិជ្ជកម្មតំបន់ ៤ ជាដើម។[500]

១៥១. ដោយឡែក ចំពោះតំបន់៥ កម្មាភិបាលភូមិភាគនិរតីដែលស្និទ្ធនឹងតាម៉ុកមកជំនួសភូមិភាគពាយ័ព្យដែលត្រូវបានចោទថាក្បត់ហើយត្រូវបានចាប់ខ្លួននិងសម្លាប់ចោល។ ហឿង លេខាតំបន់ ៥ តាជាល គណៈស្រុកព្រះនេត្រព្រះ ឈ្មោះ អន ម៉ោង និង សំអាត និងគណៈឃុំ និងគណៈស្រុកត្រូវបានចាប់ខ្លួន (តំបន់៥)។[501] មានកម្មាភិបាលតំបន់ ៥ និងថ្នាក់ស្រុកជាច្រើនត្រូវបានចាប់យកទៅឃុំខ្លួននៅ ស-២១ នៅចន្លោះឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៨ រួមមានជាអាទិ៍៖ ណែន ទុយ ហៅភី លេខា វរៈសេនាតូច ៥១៣ របស់តំបន់, សឿ សាញ៉ុញ លេខាអនុសានាធំរបស់តំបន់, ម៉ែន ជុន ហៅ ហិង លេខាតំបន់៥, ឃីម ហួត លេខាស្រុកថ្មពួក, សួន សន លេខាស្រុកសិរីសោភ័ណ, វ៉ែន វ៉ុត សមាជិកស្រុកស្វាយស៊ីសុផុន, ស្មុត ស្មន់ប្រធានពាណិជ្ជកម្មស្រុកភ្នំស្រុក, គុយ គឿន ប្រធានពេទ្យតំបន់, ឡឹម លាំ ប្រធានកសិកម្មតំបន់, ស្វាយ សៀន ហៅ ហុង ប្រធានសិល្បៈតំបន់, ម៉ក់ ឡឹង ហៅ ងាត ប្រធានកងចល័តស្រុកព្រះនេត្រព្រះ, ឡោក ឆ្វត ជំនួយការពាណិជ្ជកម្មតំបន់, យ៉ាវ យ៉ឹយ ជំនួយការកងចល័តស្រុកសិរីសោភ័ណ, ម៉ែន ជូ ជំនួយការចំការកប្បាសតំបន់, វឿត អ៊ិត់ អនុប្រធានសេដ្ឋកិច្ចតំបន់[502], ហែម មឿន អ្នកកាន់បញ្ជីដីស្រែតំបន់[503], សាវ៉ាន់ ពាណិជ្ជកម្មតំបន់, ឆាំ ឆាត អនុលេខាស្រុកពួក, សាន់ ឡេង ប្រធានចំការកប្បាស, ចយ ឃាម សមាជិកពាណិជ្ជកម្មតំបន់[504], ហេង រិន ហៅ ម៉ី លេខាតំបន់៥ និងប្រពន្ធគាត់ឈ្មោះ ស្វ រ៉ង[505], ឈឿន វ៉ាត់ សមាជិកការដ្ឋានតំបន់[506], ង៉ាន យ៉ែម ហៅ ហាត់ លេខាស្រុកភ្នំស្រុក[507], ឌឹម សារឿន ហៅ ម៉ែន អនុពេទ្យតំបន់[508] និង សាប់ ធិ ហៅ ថោង សមាជិកស្រុកភ្នំស្រុក ជាដើម។[509]

១៥២. ក្នុងតំបន់៧ កែ គឹមហ៊ួត ហៅ សុត ជាលេខាតំបន់ និង អ៊ុំ តួយ ជាអនុលេខាត្រូវបានចាប់ខ្លួន ឃុំឃាំង សួរចម្លើយនៅ ស-២១។[510] បន្ទាប់មកឈ្មោះ តាទ្រី ឡើងជំនួស តាសុត រហូតដល់ពេលរំដោះក្នុងឆ្នាំ ១៩៧៩។[511]

១៥៣. ដោយឡែក ចំពោះ **តាទិត្យ** វិញ មានសក្ខីកម្មបង្ហាញថា **តាទិត្យ** ធ្លាប់ទៅទំបន់កង្អត ហើយធ្វើជាអធិបតីបើកកិច្ចប្រជុំ ដោយមានទាហានការពារច្រើន ដើម្បីស្រាវជ្រាវរកខ្មាំងយួន ឬ អ្នកដែលចូលដៃចូលជើងជាមួយនឹងវៀតណាម ដើម្បីបង្ការកុំឲ្យមានការវាយប្រហារលើគាត់ ដោយបានប្រកាសថា បងប្អូនកុំឲ្យចូលដៃចូលជើងជាមួយយួន ហើយរួបរួមជាមួយនឹងនិរតីហ្នឹងទៅ។[512] ជាលទ្ធផល អ្នកដែលនិយាយភាសាវៀតណាម ឬ មានជាប់ខ្សែស្រឡាយវៀតណាមនឹងត្រូវសម្លាប់ចោល។[513]

១៥៤. គួរបញ្ជាក់ថា ចលនាបះបោរផ្តាច់ខ្លួន និងការទប់ទល់ជាមួយវៀតណាមកាន់តែខ្លាំងឡើងក្នុងរយៈពេលពីត្រីមាសទី២ រហូតដល់ចុងរបបនៅឆ្នាំ ១៩៧៨ ខណៈដែល **តាទិត្យ** នៅទីនោះ។[514] សាក្សីម្នាក់ឈ្មោះ វី ផាន់ បានបំភ្លឺថា នៅក្នុងអង្គប្រជុំមួយដែលមានវត្តមានរបស់តាប៉ែតដែរនោះ **តាទិត្យ** បាននិយាយលើកទឹកចិត្តវាយខ្មាំងវៀតណាម ចលនាខ្មែរសេរី ខ្មាំងស៊ីរូងផ្ទៃក្នុង។[515]

១៥៥. ដូចនេះ នៅពេល **តាទិត្យ** ទៅដល់ភូមិភាគពាយ័ព្យ គោលការណ៍បោសសម្អាតបាននឹងកំពុងដំណើរការយូរមកហើយ ហើយមានវត្តមាននៃទីតាំងឧក្រិដ្ឋកម្មរួចទៅហើយ។ តួនាទី និងអំណាចផ្លូវការ និងជាក់ស្តែងរបស់ **តាទិត្យ** នៅពាយ័ព្យ ត្រូវមើលក្នុងបរិបទនៃកាលៈទេសៈយ៉ាងហោចណាស់ក៏តាមរយៈសេដ្ឋកិច្ចសង្គម និងការបោសសម្អាតដែល ប.ក.ក បានអនុវត្តដើម្បីកសាង និងការពារបដិវត្តសង្គមនិយម ជាពិសេសពាក់ព័ន្ធនឹងការជម្លៀសប្រជាជនទូទាំងប្រទេស សេដ្ឋកិច្ច នៅពាយ័ព្យ និងការជម្លៀសមកពាយ័ព្យ (ក្នុងនោះនិរតីមកពាយ័ព្យដែរ) និងការបោសសម្អាតដែលបានកើតឡើងមុន **តាទិត្យ** ទៅដល់។

១៥៦. ផលវិបាកជាច្រើនកើតចេញពី គោលនយោបាយបោសសម្អាត។ សាក្សី ឈូក រីន ជាអតីតកម្មាភិបាលបាននិយាយថា "រឿងដែលបែកបាក់គ្នាដោយសារនយោបាយរបស់ ប៉ុល ពត ដោយសារតែគោលការណ៍បក្សកុំម្មុយនីស្តកម្ពុជាហ្នឹង វាមហាហោតផ្លោះពេក ដែលធ្វើឲ្យ



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

មានការបែកបាក់គ្នា"។[516] ការបោសសម្អាតបានបណ្តាលឱ្យមានការបែកបាក់ផ្ទៃក្នុងរបស់ ប.ក.ក ដោយអតីតកម្មាភិបាលខ្មែរក្រហមខ្លះបានរត់ទៅវៀតណាម ហើយអ្នកខ្លះទៀតបានរត់ចូលព្រៃ។[517] ប្រឈមមុខនឹងផលវិបាកជាច្រើនដែលកើតចេញពីនយោបាយនៃការបោសសម្អាតនេះ កម្មាភិបាលខ្មែរក្រហមបានដាក់កំហុសលើ ប៉ុល ពត។[518]

១៥៧. ក្នុងអំឡុងពេល និងបន្ទាប់ពីការបោសសម្អាត តាម៉ុក និងកម្មាភិបាលជាន់ខ្ពស់ផ្សេងទៀតបានចាត់តាំងកម្មាភិបាលពីភូមិភាគនិរតីឱ្យទៅកាន់តំណែង និងទីកន្លែងផ្សេងៗ នៅពេលពួកគេទៅដល់ភូមិភាគពាយ័ព្យ។[519] សាក្សីជាច្រើនលើកឡើងថា តាម៉ុក បានជ្រើសរើសមនុស្សស្និទ្ធរបស់គាត់ឱ្យដឹកនាំកម្មាភិបាលភូមិភាគនិរតីទៅភូមិភាគពាយ័ព្យ។[520] កម្មាភិបាលពាយ័ព្យមានការភ័យបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួន។[521]

## ៤. រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋាន និងភូមិភាគ

១៥៨. ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានភូមិភាគចំនួន ៦ (ប្រាំមួយ) រួមមាន[522] ភូមិភាគនិរតី[523] ភូមិភាគបស្ចិម[524] ភូមិភាគពាយ័ព្យ[525] ភូមិភាគកណ្តាល[526] (អតីតភូមិភាគឧត្តរ)[527] ភូមិភាគឦសាន[528] និង ភូមិភាគបូព៌ា។[529] ក្រៅពីនេះក៏មានតំបន់ស្វយ័តមួយចំនួន[530]មាន៖ កំពង់សោម[531] មណ្ឌលគីរី (តំបន់១០៥)[532] ព្រះវិហារ (តំបន់១០៣)[533] ក្រចេះ (តំបន់៥០៥)[534] ជាអាទិ៍។ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល មានតាមឋានានុក្រមពីលើទៅក្រោមដូចជា៖[535] ភូមិភាគ[536] តំបន់[537] ស្រុក[538] ឃុំ[539] ភូមិ[540] ក្រុម[541] និងកង។[542]

១៥៩. នៅថ្នាក់ភូមិភាគ សន្និបាតភូមិភាគជាអង្គការដែលមានឋានានុក្រមខ្ពស់បំផុត។[543] ភូមិភាគនីមួយៗត្រូវបានដឹកនាំដោយ លេខាភូមិភាគមួយរូប[544] អនុលេខាភូមិភាគមួយរូប[545] ព្រមទាំងសមាជិកគណៈភូមិភាគ[546]។ ដូចគ្នាដែរចំពោះការដឹកនាំរបស់តំបន់ស្វយ័ត។[547] ចាប់ពីលេខាភូមិភាគឡើងទៅភាគច្រើន ជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស[548] ហើយមានតែសមាជិកលេខាភូមិភាគមួយចំនួនតូចប៉ុណ្ណោះ អាចជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស។[549]

១៦០. ភូមិភាគមានឋានានុក្រមរដ្ឋបាលត្រួតលើតំបន់ ស្រុក ឃុំ ភូមិ និងសហករណ៍។[550] ហេតុនេះបណ្ដាភូមិភាគក៏ត្រូវបានបែងចែកជាតំបន់ ខណៈតំបន់ត្រូវបានបែងចែកការគ្រប់គ្រងបន្តទៅថ្នាក់ស្រុក រីឯ ស្រុកក៏ត្រូវគ្រប់គ្រងបន្តលើភូមិ សហករណ៍ជាបន្តនៅតាមមូលដ្ឋានផ្ទាល់។[551] កងចល័តតាមស្រុកនីមួយៗមានសមាជិកប្រហែល ៣.០០០ (បីពាន់) នាក់។[552]

## ៤.១. ភូមិភាគពាយ័ព្យ

១៦១. ភូមិភាគពាយ័ព្យគឺជាភូមិភាគមួយក្នុងចំណោមភូមិភាគទាំង ៦ (ប្រាំមួយ) នៃរបបកម្ពុជាប្រជាធិបតេយ្យក្រោយពីខែ មេសា ឆ្នាំ ១៩៧៦។[553] ភូមិភាគនេះក្ដោបភូមិសាស្ត្រខេត្តបាត់ដំបង និងពោធិ៍សាត់ (១៧៧) និងត្រូវបានបែងចែកជាតំបន់ ១, ២, ៣, ៤, ៥, ៦ និងតំបន់ ៧។[554] គណៈដឹកនាំនៃភូមិភាគនេះមាន មូល សម្បត្តិ ហៅ រស់ ញឹម ជាលេខា។ ក្រោយមក ក្នុងអំឡុងពាក់កណ្ដាលឆ្នាំ ១៩៧៨ គាត់ត្រូវបានជំនួសដោយ តាម៉ុក ដែលជាលេខាភូមិភាគនិរតី។[555] អនុលេខា មានឈ្មោះ គង់ សុផល។ បន្ថែមពីលើនេះ **តាទិត្យ** ត្រូវបានអះអាងថា ជាគណៈភូមិភាគពាយ័ព្យក្នុងពាក់កណ្ដាលឆ្នាំ ១៩៧៨។[556] មេបញ្ជាការយោធានៃភូមិភាគពាយ័ព្យគឺ តាឃ្លាំង។[557] តំបន់ ១ លេខាដំបូងគឺ តា កុក ដែលមាន តា ស៊ូ និង តាសាយ ជាសមាជិក ក្រោយមក តាវ៉ាញ និងមាន តាណុប ជាសមាជិក ហើយដែលចុងក្រោយ **តាទិត្យ** បានមកជំនួស។[558] សារុន ជាលេខាតំបន់ ២។[559] លេខាតំបន់ ៣ មាន តា ប៉ា[560] តាប៉ែត និងតាទុំ[561] និង តា ឆាំ[562] តាគុំ។[563] លេខាតំបន់ ៤ រួមមានឈ្មោះ ខែក ប៊ុន ហៅ តាស៊ូ ដែលត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៧[564] មិញ ធឿម ឬ មិញ ធើម ហៅ ប៉ាង ដែលត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៨[565] ព្រមទាំងមាន តាវ៉ាន់ និង តាវ៉ៃ ជាគណៈតំបន់[566] ស៊ុន គុន ហៅ ស៊ុយ ជាអនុលេខាតំបន់, តូច មួច ជាសមាជិកតំបន់ និង សេង ស៊ីមឿន ហៅ ថុល ជាសមាជិកមន្ទីរតំបន់។[567] តាជាល ជាលេខាតំបន់ ៥[568] និងបន្ទាប់មកជំនួសដោយ ម៉ែន ជុន ហៅ តាហិង។[569] តំបន់ ៦ មានតាផូ តាស៊ុយ ជាលេខា[570] តា កុក តា ឡឹក តា ផេង និងតារឿង ជាអនុ។[571] តំបន់៧ នៃភូមិភាគពាយ័ព្យ គ្រប់ដណ្ដប់ស្រុកបាកាន ខេត្តពោធិ៍សាត់។ លេខាតំបន់ ៧ មាន វចនាសម្ព័ន្ធដឹកនាំ តាសុត (កែ គឹមហ៊្វួត) ជាលេខា និង តាតួយ ជាអនុលេខា។[572] សាក្សីបានអះអាងថា តាសុត និង ផែង ជាគណៈតំបន់ ៧ ផងដែរ។[573] បន្ទាប់មកឈ្មោះ តាទ្រី បានឡើងជំនួស តាសុត រហូតដល់ពេលវៀតណាមចូលមករំដោះក្នុងឆ្នាំ១៩៧៩។[574]



CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION" E.C.C.C * C.E.T.C

## ៤.១.១. រចនាសម្ព័ន្ធអំណាចតំបន់១ អំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ

១៦២. តំបន់១ ចែកចេញជាស្រុកចំនួន ៥ រួមមាន ស្រុកគាស់ក្រឡ ស្រុកមោងឫស្សី ស្រុកសង្កែ[575] ស្រុករតនមណ្ឌល[576] និងស្រុកសំឡូត។[577]

១៦៣. តំបន់១ ត្រូវបានគ្រប់គ្រងដោយកម្មាភិបាលពាយ័ព្យ ហើយដែលក្រោយមកពួកគេត្រូវបានចាប់ខ្លួនដោយពួកនិរតី។[578] មានតែមនុស្សបីនាក់ប៉ុណ្ណោះដែលជាប្រធាននៃតំបន់នេះ។[579] អ្នកគ្រប់គ្រងតំបន់១ ចន្លោះឆ្នាំ១៩៧៥ ដំបូងគេគឺ តាកុក ដែលជាជនជាតិពណ៌។[580] បន្ទាប់មកមាន តាពាង ហៅ តាសាយ គណៈមន្ទីរភូមិភាគ និងលេខាតំបន់១ ពីដំបូងដល់ចុងឆ្នាំ ១៩៧៥ ដែលក្រោយមក ត្រូវបានចោទថាក្បត់និងចាប់ខ្លួន។[581] តាសាយមានអនុប្រធាន ៣ (បី) នាក់ គឺ តាណុប តាកុប និង តាស៊ូ, ហើយ ស៊ានក៏ជាសមាជិកនៃគណៈតំបន់ដែរ។[582] តាវេង គឺជាអនុលេខាតំបន់១[583] តានឹមជាសមាជិកតំបន់១[584] តែមិនដឹងកាលបរិច្ឆេទនៃការកាន់អំណាចរបស់ពួកគេទេ។

១៦៤. តាវ៉ាញ លេខាតំបន់១ ជាមេបញ្ជាការយោធាតំបន់ និងជាអ្នកគ្រប់គ្រងទំនប់កង្ហត បន្តពីតាសាយ ហើយប្រហែលចុងឆ្នាំ ១៩៧៥ ដល់ចុងឆ្នាំ ១៩៧៦ ត្រូវបានបោសសម្អាត មុនពួកនិរតីមកដល់ ៤ (បួន) ទៅ ៥ (ប្រាំ) ខែ ដោយសារថាតាវ៉ាញបានប្រមូលអាវុធយកទៅលាក់ទុកនៅខាងកើតភ្នំធិបតី[585] និងមានបញ្ជាពីគណៈកម្មាធិការមជ្ឈិមបក្ស។[586] តា ហេង ទាវ ហៅតាប៉ែត ដែលជាអនុលេខាភូមិភាគពាយ័ព្យ ឡើងកាន់នាទីជាលេខាតំបន់១ ជំនួសតាវ៉ាញ។[587] បន្ទាប់មក ដោយសារខែ សីហា ឬវិច្ឆិកា ឆ្នាំ១៩៧៨ ហេង ទាវ ហៅ តាប៉ែត និងប្រពន្ធរបស់គាត់ ត្រូវបានចាប់ខ្លួនដោយពួកនិរតី រួចបញ្ជូនទៅវាយថ្ម កាប់ឫស្សីនៅខេត្តកំពង់ស្ពឺតាមបញ្ជារបស់តាម៉ុក[588] **តាទិត្យ** បានឡើងជំនួសតាប៉ែតក្នុងនាទីជាគណៈតំបន់១ រហូតដល់ចប់របបខ្មែរក្រហម។[589]

១៦៥. នៅស្រុកសង្កែ តាវ៉ី គឺជាលេខាស្រុក[590] ដែលមានតាយានជាអនុលេខា។[591] បន្ទាប់មក ស៊ុន គុណ បានឡើងជាលេខាស្រុក។ គាត់ត្រូវបានសម្លាប់ដោយពួកនិរតីនៅចុងឆ្នាំ ១៩៧៧។[592] នៅពេលមកដល់តំបន់១ ពួកនិរតីបានហៅបាណន់ថា ស្រុកសង្កែ[593] ...



E.C.C.C. * C.E.T.C. * JUGES D'INSTRUCTION

01619085


រ៉ែន ជាកម្មាភិបាលមកពីភូមិភាគនិរតី គឺជាលេខាស្រុក។[594] ស្រុកម៉ោងឫស្សីមាន តាយឿន ជាលេខាស្រុក និង តាលេង ជាអនុលេខា។[595] យឹន ជាលេខាស្រុកគាស់ក្រឡ។[596] តាណោន និង តាថុន ដែលជាគណៈស្រុក។[597] យាយឡេង ជាលេខាស្រុកសំឡូត។[598] គន ជាគណៈស្រុករតនមណ្ឌល។[599]

## ៤.២. ភូមិភាគនិរតី

១៦៦. ភូមិភាគនិរតីត្រូវបានបែងចែកជា ៤ (បួន) តំបន់ រួមមាន៖ តំបន់ ៣៥[600] (ខេត្តកំពត)[601] តំបន់ ១៣[602] (ខេត្តតាកែវ)[603] តំបន់ ៣៣ (ស្រុកសំរោងទង និងស្រុកគងពិសីនៃខេត្តកំពង់ស្ពឺ)[604] និង តំបន់ ២៥ (មួយផ្នែកនៃខេត្តកណ្តាល)។[605] នៅភូមិភាគនិរតី ឈ្មោះ អ៊ុង ជឿន ឬ ឈិត ជឿន ហៅ តា ម៉ុក ត្រូវបានតែងតាំងជាលេខាភូមិភាគនេះចាប់តាំងពីកកើតរហូតដល់ការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ។[606]

១៦៧. ភូមិសាស្ត្រភូមិភាគនិរតី ស្ថិតនៅផ្នែកខាងជើងផ្លូវជាតិលេខ៤ ដែលរួមមាន ៤ (បួន) តំបន់ គឺ តំបន់ ១៣ (ខេត្តតាកែវ) តំបន់ ២៥ (មួយផ្នែកនៃខេត្តកណ្តាល) តំបន់ ៣៣ (ខេត្តកំពង់ស្ពឺ) និងតំបន់ ៣៥ (ខេត្តកំពត)។[607] តំបន់១៣ មានទីតាំងនៅក្នុងខេត្តតាកែវ ចែកចេញជា ៨ (ប្រាំបី) ស្រុក៖ ស្រុកត្រាំកក់ (ស្រុក ១០៥), ស្រុកគិរីវង់ (ស្រុក ១០៩), ស្រុកកោះអណ្តែត (ស្រុក ១០៨), ស្រុកព្រៃកប្បាស, ស្រុកសំរោងទង, ស្រុកទ្រាំង (ស្រុក ១០៧), ស្រុកអង្គរជ័យ (ស្រុក ១០៦) និងស្រុកតានី។[608] តំបន់ ២៥ ស្ថិតនៅមួយផ្នែកនៃខេត្តកណ្តាលត្រូវបានបែងចែកជា ៤ (បួន) ស្រុក រួមមាន ស្រុកស្អាង ស្រុកកោះធំ ស្រុកលើកដែក និងស្រុកកៀនស្វាយ។[609] តំបន់ ៣៣ ស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ មាន ៦ (ប្រាំមួយ) ស្រុកដូចជា ស្រុកស្រាង ឬស្រុកបរសេដ្ឋ (ស្រុក ៥១) ស្រុកបូរីជលសារ ព្រៃកប្បាស (ស្រុក ៥៥) ស្រុកសំរោង (ស្រុក ៥៤) ស្រុកបាទី (ស្រុក ៥៦) និងស្រុកគងពិសី (ស្រុក ៥២)។[610] តំបន់ ៣៥ ស្ថិតនៅក្នុងខេត្តកំពតរួមមាន ៥ (ប្រាំ) ស្រុកគឺ ស្រុកកោះស្លា ស្រុកកំពត ស្រុកទូកមាស ស្រុកកំពង់ត្រាច និងស្រុកឈូក។[611]

១៦៨. បន្ទាប់ពីលោក ម៉ា មេង ជាអតីតលេខាភូមិភាគនិរតី បានស្លាប់កាលពីឆ្នាំ១៩៦៨ អ៊ុង ជឿន ឬឈិត ជឿន ហៅ តាម៉ុក ឬតា១៥ បានឡើងជាលេខាភូមិភាគនិរតី។[612] កង ចាប់ ...



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

សែ និង ជូ ជេត ហៅ ស៊ី ជាអនុលេខាភូមិភាគ។[613] នៅឆ្នាំ១៩៧៨ បន្ទាប់ពី រស់ ញឹម ហៅ តាញឹម លេខាភូមិភាគពាយ័ព្យត្រូវបានចាប់ខ្លួន។ តា ម៉ុក ត្រូវបានតែងតាំងជាលេខាភូមិភាគពាយ័ព្យ ក្នុងពេលដែលគាត់កំពុងកាន់តំណែងជាលេខាភូមិភាគនិរតី។[614] បន្ទាប់ពីចាប់ខ្លួន សែ នៅក្រោយថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៧៨ តាម៉ុក បានក្លាយជាលេខាបួនភូមិភាគគឺ និរតី បស្ចិម ពាយ័ព្យ និងឧត្តរថ្មី។[615]

## ៤.២.១. លេខាភូមិភាគនិរតី

១៦៩. ភូមិសាស្ត្រតំបន់ ១៣ ត្រូវបានបែងចែកជា ៥ (ប្រាំ) ស្រុករួមមាន ស្រុកត្រាំកក់ (ស្រុក ១០៥) ស្រុកអង្គរជ័យ (ស្រុក ១០៦) ស្រុកទ្រាំង (ស្រុក ១០៧) ស្រុកកោះអណ្តែត (ស្រុក ១០៨) និងស្រុកគិរីវង់ (ស្រុក ១០៩)[616] ស្ថិតនៅក្នុងភូមិភាគនិរតី។[617]

១៧០. បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ ១៩៧៥ លេខាតំបន់១៣ គឺ តាសោម ហៅ ថន។[618] ប្រហែលជានៅឆ្នាំ ១៩៧៦ តាសោម ត្រូវបានគេជំនួសនៅពេលដែលគាត់ធ្វើការលែងកើត។[619] លេខាតំបន់ ១៣ ត្រូវបានផ្លាស់ប្តូរជាញឹកញាប់ ជាក់ស្តែង តាសោម ហៅ ថន ជាលេខាតំបន់១៣ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៦ ក្រោមមកជំនួសដោយ តាប្រាក់ នៅចន្លោះឆ្នាំ ១៩៧៦ និង ១៩៧៧។[620] តាផែន ជាអនុលេខា និង មាស មុត ហៅ តាមុត ជាសមាជិក។[621]

១៧១. សាក្សីដែលធ្លាប់ធ្វើជាយោធាក្នុងតំបន់១៣ បានអះអាងថា តាសោម និងតាផែន ធ្វើជាគណៈតំបន់ ១៣ ក្នុងអំឡុងខែ តុលា ឬខែ វិច្ឆិកា ឆ្នាំ ១៩៧៧។[622] សាក្សីម្នាក់ទៀតឈ្មោះ ពេជ្រ ជឹម បានបញ្ជាក់ថា ក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៧ តាសោម នៅធ្វើជាគណៈតំបន់ ១៣ នៅឡើយ នៅពេលគាត់បានចាកចេញពីភូមិភាគនិរតីនៅពេលនោះ។[623] សាក្សីផ្សេងទៀតបានអះអាងប្រហាក់ប្រហែលគ្នានេះដែរថា តាសោម នៅជាប្រធានគណៈតំបន់១៣ រហូតដល់ខែ កញ្ញា ឆ្នាំ ១៩៧៨។[624] មានសាក្សីម្នាក់ឈ្មោះ ម៉ៅ ឆោម បានអះអាងថា តាមុត ជាលេខាតំបន់ ១៣ ហើយគណៈតំបន់មានឈ្មោះ តាមុត តាសោម និង តាភា។[625]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

១៧២. បើតាមសម្តីរបស់សាក្សីឈ្មោះ ទឹម ភួន ដែលត្រូវជាក្មួយរបស់ **តាទិត្យ** បានអះអាងថា **យឹម ទិត្យ** បានក្លាយជាលេខាតំបន់ ១៣ នៅដើមឆ្នាំ ១៩៧៨ ហើយគាត់ធ្វើជាលេខាតំបន់ ១៣ នេះ បានរយៈពេលប្រហែល ៦ (ប្រាំមួយ) ខែ។[626] ប៉ុន្តែសាក្សីឈ្មោះ ទឹម ភួន ត្រូវបានសម្ភាសន៍លើកក្រោយបានអះអាងថា មិនដឹងពីតួនាទីរបស់ **តាទិត្យ** នៅតំបន់ ១៣ នោះទេ គ្រាន់តែដឹងថា នៅពេលវៀតណាមវាយចូលស្រុកគិរីវង់ ប្រហែលជាចុងឆ្នាំ ១៩៧៧ ឬដើមឆ្នាំ ១៩៧៨ **តាទិត្យ** ត្រូវគេផ្ទេរពីស្រុកគិរីវង់មកខេត្តតាកែវ។[627] សាក្សីឈ្មោះ ទឹម ភួន បានបន្តអះអាងថា **តាទិត្យ** បានបន្តនៅខេត្តតាកែវប្រហែលបាន ៦ (ប្រាំមួយ) ខែ បន្ទាប់មកគាត់ត្រូវបានផ្លាស់ទៅក្រចេះមួយរយៈពេលខ្លី ហើយចេញពីក្រចេះទៅនៅបាត់ដំបងរហូតដល់ឆ្នាំ ១៩៧៩ ពេលវៀតណាមចូលមក។[628]

១៧៣. សាក្សីម្នាក់ទៀតឈ្មោះ ម៉ុង វេត បានអះអាងថា នៅក្នុងឆ្នាំ១៩៧៨ **តាទិត្យ** ក្លាយជាលេខាតំបន់ ១៣ បានមួយរយៈមុនពេលវៀតណាមមកដល់។[629] សាក្សីម្នាក់ទៀតឈ្មោះ នុត នៅ ដែលជាអតីតប្រធានសហករណ៍ភូមិភាគនិរតី បានអះអាងប្រហាក់ប្រហែលគ្នានឹងសាក្សីខាងលើថា **តាទិត្យ** ត្រូវបានគេប្រកាសជាលេខាតំបន់ ១៣ ថ្មី ប្រហែល ៧ (ប្រាំពីរ) ទៅ ៨ (ប្រាំបី) ខែមុនវៀតណាមចូលឆ្នាំ ១៩៧៩។[630] សាក្សីឈ្មោះ ហែម ឈួន ជាប្រជាជន ១៧ មេសា ឬ ប្រជាជនថ្មី ត្រូវបានគេបញ្ជូនឲ្យទៅធ្វើស្រែនៅស្រុកត្រាំកក់បានអះអាងថា ក្រោយឆ្នាំ ១៩៧៧ **តាទិត្យ** ត្រូវបានគេដំឡើងឋានៈធំជាមុន។[631] សាក្សី ២ (ពីរ) នាក់ទៀត ឈ្មោះ អ៊ុល ហឿន និងឈ្មោះ ដុក ចាន់ បានលើកឡើងប្រហាក់ប្រហែលគ្នាថា នៅដើមឆ្នាំ ១៩៧៦ **តាទិត្យ** ត្រូវបានផ្លាស់ទៅតំបន់។[632]

១៧៤. សាក្សីបានអះអាងថាបានជួប **តាទិត្យ** នៅពេលមកចូលរួមប្រជុំនៅភ្នំពេញប្រហែលក្នុងឆ្នាំ ១៩៧៦, ឆ្នាំ១៩៧៧ ឬ ក៏ឆ្នាំ១៩៧៨ ដែលធម្មតាការប្រជុំនេះសម្រាប់តែថ្នាក់តំបន់ឡើងទៅតែប៉ុណ្ណោះ។[633] សាក្សីឈ្មោះ ខៀវ នៅ បានលើកឡើងថា **តាទិត្យ** គឺជាលេខាស្រុកគិរីវង់ ហើយក្រោយមកត្រូវបានផ្លាស់ទៅធ្វើការជាមួយតាម៉ុកនៅមន្ទីរភូមិភាគនិរតី។[634] សាក្សីផ្សេងទៀតដែលកំពុងធ្វើស្រែប្រាំងនៅក្នុងស្រុកទ្រាំង នៃតំបន់ ១៣ ប្រហែលនៅឆ្នាំ ១៩៧៧ ឬ ឆ្នាំ ១៩៧៨ បានឃើញបុរសត្រពែកម្នាក់នៅក្នុងឡាន ហើយគេប្រាប់គាត់ថាបុរសនោះឈ្មោះ **យឹម ទិត្យ** ហើយឮគេនិយាយថាគាត់ជាលេខាតំបន់។[635]



CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION* E.C.C.C *C.E.T.C*

១៧៥. សាក្សីឈ្មោះ ពេជ្រ ជឹម បានអះអាងថាក្នុងចុងឆ្នាំ ១៩៧៨ បានឮវិទ្យុផ្សាយថា យឹម ទិត្យ គឺជាស្ដីទីតំបន់ ១៣ ហើយនៅទទួលភ្ញៀវនៅមន្ទីរតំបន់១៣ ដែលមានទីតាំងនៅក្នុងផ្ទះរបស់ តាម៉ុក នៅខេត្តតាកែវ ហើយសាក្សីបានបន្ថែមថា មានតែលេខា ឬ ក៏អនុលេខា ទើបអាចទទួលភ្ញៀវបាន។[636] សាក្សីផ្សេងទៀតក៏បានអះអាងប្រហាក់ប្រហែលគ្នានេះដែរថា យឹម ទិត្យ ជាអនុលេខាតំបន់១៣ ដោយសាក្សីតែងតែសង្កេតពិនិត្យនៅពេលដែលគណៈតំបន់ប្រជុំ ឬ ធ្វើសន្និបាតម្ដងៗ ថ្នាក់ដឹកនាំអង្គុយលើវេទិកា។ ជាទូទៅ អនុអង្គុយខាងស្ដាំដៃប្រធាន ហើយសមាជិកអង្គុយខាងឆ្វេងដៃ។ តាមការសង្កេតរបស់សាក្សីនៅពេលប្រជុំ និងសន្និបាត តាទិត្យ តែងតែអង្គុយនៅខាងស្ដាំដៃរបស់ តាសោម ដែលជាលេខាតំបន់១៣។[637]

១៧៦. ប៉ុន្តែទោះជាមានការអះអាងខាងលើក៏ដោយ ក៏សាក្សីឈ្មោះ ចាន់ វិចិត្រ បានអះអាង ផ្ទុយពីនេះថា តាទិត្យ គ្មានតួនាទីច្បាស់លាស់ទេ គ្រាន់តែធ្វើការងារតំណាងឱ្យភារកិច្ចរបស់ តាម៉ុក ម្ដងម្កាល ឬ មួយភ្លែតៗប៉ុណ្ណោះ "ធ្វើ ឬមិនធ្វើក៏រលាយរលត់អស់ដែរ"។[638]

## ៤.២.២. រចនាសម្ព័ន្ធអំណាចតំបន់១៣ អំឡុងពេល របបកម្ពុជាប្រជាធិបតេយ្យ

១៧៧. តំបន់ ១៣ មានទីតាំងស្ថិតនៅក្នុងខេត្តតាកែវ[639] ភូមិភាគនិរតីដែលមាន តាម៉ុក ជាលេខាភូមិភាគ។[640] តំបន់នេះស្ថិតនៅខាងលិចផ្លូវជាតិលេខ ៣។ ការិយាល័យតំបន់ ១៣ ស្ថិតនៅជិតវត្តអង្គតាសោម និង ខាងជើងផ្សារអង្គតាសោមប្រមាណ ៣០០ (បីរយ) ទៅ ៤០០ (បួនរយ) ម៉ែត្រ។[641]

១៧៨. សក្ខីកម្មជាច្រើនបានបង្ហាញភាពមិនស៊ីសង្វាក់គ្នាថាតើអ្នកណាគឺជាលេខាតំបន់ និងក្នុងពេលណាដែលពួកគេកាន់កាប់តួនាទីនេះ។ សាក្សីជាច្រើនឆ្លើយថា តាសោម និង តាម៉ុក គឺជាគណៈតំបន់ ១៣ ដំបូងគេ។[642] បន្ថែមលើនេះ សាក្សីម្នាក់ទៀតឆ្លើយថា តាមុត ក៏កាន់តួនាទីជាលេខាតំបន់ ១៣ ដែរ។[643] ចំណែកឯសាក្សីច្រើនផ្សេងទៀតផ្ដល់សក្ខីកម្មថា តាសោម កាន់ តួនាទីជាលេខាតំបន់ ១៣ នេះតាំងពីមុនឆ្នាំ ១៩៧៥ រហូតដល់ប្រហែលឆ្នាំ ១៩៧៦ ឬ ដល់ខែ តុលា ឬ ខែ វិច្ឆិកា ឆ្នាំ១ ៩៧៧[644] ហើយត្រូវបានប្ដូរដោយសារគាត់មានជំងឺ។[645] តាប្រាក់ មកពីតំបន់ ២៥ បានមកជំនួសតាសោម ក្នុងតួនាទីជាលេខាតំបន់ចន្លោះឆ្នាំ១៩៧៧



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

និងឆ្នាំ ១៩៧៧ រហូតដល់តាប្រាក់ត្រូវបោសសម្អាតជាមួយនឹងគណៈឃុំ ២ (ពីរ) ឬ ៣ (បី) នាក់ផ្សេងទៀត។[646]

១៧៩. ផ្ទុយទៅវិញ សាក្សីម្នាក់ទៀតផ្តល់ចម្លើយផ្ទុយថា គឺ តាទិត្យ ទេដែលបានទៅជំនួសតាសោម ក្នុងនាមជាលេខាតំបន់[647] ដែលចម្លើយនេះស៊ីសង្វាក់នឹងចម្លើយរបស់សាក្សីម្នាក់ទៀតដែលថា ប្រមាណ ៧ (ប្រាំពីរ) ទៅ ៨ (ប្រាំបី) ខែ មុនពេលវៀតណាមមកដល់ឆ្នាំ ១៩៧៩ តាទិត្យ បានឡើងកាន់កាប់តំណែងជាលេខាតំបន់ ១៣ ជំនួស តាវ៉ាន ដែលជួបគ្រោះថ្នាក់ចរាចរណ៍។[648] មានតែសាក្សី ២ (ពីរ) នាក់ ដែលអះអាងផ្ទុយពីគេថា **តាទិត្យ** គឺជាគណៈតំបន់ ១៣ នៅឆ្នាំ ១៩៧៥ និងកាន់តួនាទីនេះបានតែ ១ (មួយ) ឆ្នាំ ប៉ុណ្ណោះ[649] រួចក៏ត្រូវបានផ្ទេរទៅភូមិភាគពាយ័ព្យជាមួយ យាយថែម នៅឆ្នាំ ១៩៧៧។[650] បន្ទាប់ពី តាទិត្យ ត្រូវបានផ្ទេរទៅពាយ័ព្យ តាគិត ត្រូវបានជ្រើសរើសជាលេខាតំបន់ ១៣ បានតែ១ ឆ្នាំ ប៉ុណ្ណោះ ។[651] តាផែន គឺជាអនុលេខា ឬ គណៈតំបន់ ១៣ រហូតដល់ខែតុលា ឬ វិច្ឆិកា ឆ្នាំ ១៩៧៧[652] ដែលក្រោយមកត្រូវបានបញ្ជូនទៅកាន់តំបន់ ៣៥[653] និង ស៊ាង[654], មាស មុត (ជាមនុស្សទី២)[655], តាគីរ (ជាមនុស្សទី៣)[656], អ៊ឹម ថែម (ប្រហែលពេញឆ្នាំ១៩៧៥)[657], យាយចេន[658], សំ បិត (ត្រឹមមួយរយៈ)[659] ដែលត្រូវបានជំនួសដោយ តាវ៉ាន[660] ជាសមាជិកតំបន់ ១៣។ តាង៉ូយ និង តាឃឹម ជាជំនួយការរបស់តាគីរ ត្រូវបានចោទថាជាកាហ្សេបេ និងត្រូវបានចាប់ខ្លួន។[661] ប្រហែលឆ្នាំ ១៩៧៦ យាយថែម បានឡើងជំនួស តាគីរ បន្ទាប់ពី តាគីរ ត្រូវបានដកទៅធ្វើការនៅកន្លែងយកថ្មនៅភ្នំជ្រៃអូរស្មៅ។[662] នារីឈ្មោះ ជាតិ គឺជាស្ត្រីទទួលបន្ទុកគ្រប់គ្រងស្ត្រីនៅក្នុងតំបន់ ១៣ [663] ខណៈដែល យាយថែម គ្រប់គ្រងផ្នែកកុមារ ស្ត្រី និងបុរសនៅក្នុងតំបន់នេះ។[664]

១៨០. សាន ជាលេខាស្រុកត្រាំកក់[665] បន្ទាប់មកមាន ខុម ជាលេខាស្រុកត្រាំកក់។[666] តាគីរ, ពេជ្រ ជឹម, ញៀវ, យាយបឿន (ពីឆ្នាំ១៩៧៨) ជាសមាជិកស្រុក ឬ ជាអនុលេខាស្រុក។[667] ភី, តាគិត, ជឿន និង ចាយ ជាគណៈស្រុកត្រាំកក់។[668] ក៏ប៉ុន្តែ សាក្សីមិនច្បាស់ថា ចាយ កាប់កាប់តួនាទីអ្វីឱ្យប្រាកដឡើយ ដែលក្រោយមកត្រូវបានផ្ទេរទៅបាត់ដំបង ភូមិភាគពាយ័ព្យជាមួយនឹង យាយថែម ប្រហែលនៅពាក់កណ្តាលឆ្នាំ ១៩៧៦។[669]



* សហចៅក្រមស៊ើបអង្កេត * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

១៨១. ក្នុងស្រុកកោះអណ្តែត តាស៊ាង ជាលេខាស្រុក។[670] សាក្សីម្នាក់អះអាងថាតាសាន គឺជាគណៈស្រុក[671] នៅឆ្នាំ១៩៧៥។[672]

១៨២. ញ៉ែន គឺជាលេខាស្រុកអង្គរជ័យនៅចន្លោះឆ្នាំ ១៩៧៦ និង ឆ្នាំ១៩៧៧ ដែលមាន ជឿន និង ចែម(ប្រពន្ធតាញ៉ែន) ជាអនុលេខា។[673] យាយចែម និង យាយភន ជាអ្នកគ្រប់គ្រងស្ត្រីនៅក្នុងស្រុក។[674] មុន, ប៉ែន យន (ត្រូវបានអង្គការយកទៅរៀនសូត្រ), យាយរ៉ាន (ពីឆ្នាំ ១៩៧៨) គឺជាគណៈស្រុកអង្គរជ័យ។[675]

១៨៣. សក្ខីកម្មផ្សេងទៀតបង្ហាញថា ស្រុកតានីហៅស្រុក ១០៦ មានតាញ៉ែនជាប្រធាន[676] និង យាយចែម ជាលេខា។[677]

១៨៤. ស្រុកទ្រាំងមាន ឃឹម ជាលេខាស្រុក[678] តាសាន ជាលេខាស្រុក[679] ហើយតាមសាក្សីឈ្មោះ ពេជ្រ ជឹម និយាយថា ស៊ឹម អាចជាអនុលេខាស្រុកទ្រាំង។[680]

### ៤.២.៣. រចនាសម្ព័ន្ធអំណាចស្រុកគិរីវង់ (តំបន់១៣)

១៨៥. ស្រុកគិរីវង់ ឬ ហៅថាស្រុក ១០៩[681] មានការិយាល័យនៅទន្លាប់។[682] មានឃុំដូចជា ឃុំរាមអណ្តើក[683] ឃុំចារអ្វ[684] ឃុំព្រៃរំដេង[685] ឃុំកំពែង[686] ឃុំសោម[687] ឃុំត្នោតចាង។[688] តាខៀវ ជាលេខាស្រុកគិរីវង់ អំឡុងឆ្នាំ១៩៧៥ ប៉ុន្តែត្រូវបានចាប់ខ្លួនដោយសារចោទថាមិនស្មោះត្រង់ ហើយដែលមាន **តាទិត្យ** ជាអនុលេខា[689] បន្ទាប់មកមាន តាសៀង ជាលេខាបន្ត ដែលមាន **តាទិត្យ** ជាអនុលេខាដដែល។[690] **តាទិត្យ** ជាលេខាស្រុកនៅឆ្នាំ១៩៧៦[691] គង់ ណាម នៅឆ្នាំ ១៩៧៧[692] តាតឹន ហៅ តាតុំ ដែលត្រូវបានចាប់ដោយចោទថាបានចូលរួមជាមួយពួកកាហ្សេបេ[693] តាសៀង[694] យាយប៊ូ[695] ជាគណៈស្រុកនៅពេលជិតចប់របប។[696] សាក្សីម្នាក់ទៀតនិយាយថា តាសឿន ឬ យាយឃឿន អាចជាគណៈស្រុកគិរីវង់រហូតដល់ពេលវៀតណាមចូលមកដល់។[697]



* CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

### ៤.២.៤. លេខាស្រុកគិរីវង់ (ស្រុក ១០៩)

១៨៦. មន្ទីរស្រុកគិរីវង់មានទីតាំងនៅក្នុងភូមិត្រពាំងរុន ឃុំរាមអណ្ដើក ស្រុកគិរីវង់។[698] ស្រុកគិរីវង់ ហៅ ស្រុក ១០៩ ស្ថិតក្នុងខេត្តតាកែវ ជាផ្នែកមួយនៃតំបន់១៣ ក្នុងភូមិភាគនិរតី។[699] មន្ទីរស្រុកគិរីវង់មានពីរកន្លែង គឺនៅផ្ទះរបស់ **តាទិត្យ** ស្ថិតនៅភូមិត្រពាំងរុន និងមួយកន្លែងទៀតគឺនៅផ្ទះរបស់ តាគុំ ដែលជាអគារមួយនៅទល់មុខវត្តសុបិន្ត ស្ថិតក្នុងភូមិចិន ឃុំរាមអណ្ដើក។[700] ប៉ុន្តែសាក្សីផ្សេងទៀតបានអះអាងថា មន្ទីរស្រុកគិរីវង់ស្ថិតនៅចន្លោះពីវត្តសុបិន និងវត្តព្រះធាតុ ដែលជាផ្ទះថ្មរបស់កុង ធីក ស្ថិតនៅក្នុងភូមិក្បាលដំរី។[701] រីឯសាក្សីឈ្មោះ ហេង ប្រិល បានលើកឡើងផ្សេងពីសាក្សីខាងលើទៀតថា មន្ទីរស្រុកគិរីវង់របស់ **តាទិត្យ** និងតាគុំ នៅវត្តឬស្សី ស្ថិតក្នុងភូមិឬស្សី ឃុំព្រៃរំដេង ស្រុកគិរីវង់ទៅវិញ។[702]

១៨៧. លេខាស្រុកគិរីវង់មានដូចជា៖ តានឹម, តាគឹន ហៅ តាគុំ, យាយបូ និង**តាទិត្យ**។[703] តាគុំត្រូវបានចាប់ខ្លួនដោយសារត្រូវបានចោទថាជាកាហ្សែបេ ។[704] **តាទិត្យ** ជាលេខាស្រុកគិរីវង់នៅចន្លោះឆ្នាំ ១៩៧៦ និង ១៩៧៧ ដែលក្រោយមកគាត់ត្រូវបានបញ្ជូនទៅបាត់ដំបងប្រហែលពាក់កណ្ដាលឆ្នាំ ១៩៧៧[705] ហើយបន្ទាប់មក យាយឃឿន ដែលជាគណៈស្រុកបានមកជំនួស**តាទិត្យ**[706] និងមាន តាគុំ ជាអនុលេខាស្រុក។[707] សាក្សីម្នាក់ទៀតបាននិយាយថាឈ្មោះ **ទិត្យ** គឺជាលេខាស្រុកគិរីវង់ ដែលគាត់ត្រូវបានចាប់ និងឃុំខ្លួននៅមន្ទីរសន្តិសុខភ្នំសន្លុង។[708]

## ជំពូក៤. តួនាទី និងអំណាចរបស់ជនត្រូវចោទ

### ១. សាវតារជនត្រូវចោទ

១៨៨. **យឹម ទិត្យ** ហៅ **តាទិត្យ** ឬ **តា១៧**[709] ភេទប្រុស កើតនៅថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៣៦ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មុខរបរ ជាមន្ត្រីចូលនិវត្តន៍[710] មានទីកន្លែងកំណើតនៅភូមិត្រពាំងគល់ ឬ ត្រពាំងធំ ឃុំត្រពាំងធំ (ត្បូង) ស្រុកត្រាំកក់ (អតីតស្រុក ១០៥) ខេត្តតាកែវ[711] ដែលជាផ្នែកមួយនៃតំបន់១៣ ក្នុងភូមិភាគនិរតី។[712] គាត់មានកម្ពស់ ១,៧០ (មួយកៀត ចិតសិប) ម៉ែត្រ មានមាឌក្រអាញ សម្បុរស្រអែម និងក្បាលឆកបន្តិច។[713]

CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

១៨៩. សាក្សីជាច្រើនបានអះអាងថា តាទិត្យ ធ្លាប់ធ្វើជាព្រះសង្ឃគង់នៅវត្តត្រាំធំនៅដើមទសវត្សរ៍ឆ្នាំ១៩៥០ មុនពេលដែលគាត់ទៅសិក្សានៅវត្តមហាមន្ត្រីក្នុងក្រុងភ្នំពេញ។[714] សាក្សីម្នាក់បានបញ្ជាក់ថា តាទិត្យ គឺជាមនុស្សខ្លាំងបំផុតម្នាក់[715] ប៉ុន្តែមានសាក្សីផ្សេងទៀតបានបញ្ជាក់ថា តាទិត្យ ជាមនុស្សមានចរិកស្លូតបូត ជាមនុស្សល្អត្រឹមត្រូវ និងស្មោះត្រង់។[716]

## ២. ការចូលរួមទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្ម

### ក. អង្គហេតុដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ

#### ១. មន្ទីរសន្តិសុខវត្តប្រធាតុ

១៩០. មន្ទីរសន្តិសុខវត្តប្រធាតុមានទីតាំងស្ថិតនៅក្នុងភូមិក្បាលដំរី ឃុំគោកព្រេច ស្រុកគិរីវង់ (ស្រុក១០៩)[717] ខេត្តតាកែវ តំបន់ ១៣ ភូមិភាគនិរតី។[718] មន្ទីរសន្តិសុខវត្តប្រធាតុត្រូវបានបង្កើតឡើងនៅអំឡុងខែ កក្កដា ឆ្នាំ ១៩៧៥ និងបានដំណើរការរហូតដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យ។[719] ខណៈដែលសាក្សីមួយចំនួនបានលើកឡើងថា មន្ទីរសន្តិសុខនេះត្រូវបានបង្កើតឡើងតាំងពីមុនឆ្នាំ ១៩៧៥។[720] មន្ទីរសន្តិសុខវត្តប្រធាតុជាមន្ទីរសន្តិសុខថ្នាក់ស្រុក ឬ គេហៅថា "មន្ទីរនគរបាលស្រុកគិរីវង់"។[721]

១៩១. មន្ទីរសន្តិសុខវត្តប្រធាតុ មានទីតាំងស្ថិតនៅក្បែរវត្តប្រធាតុ។[722] មន្ទីរសន្តិសុខនេះមានទំហំដីប្រមាណជា ១ (មួយ) ហិកតា ដែលហ៊ុំមព័ទ្ធទៅដើមត្នោត និងដើមឈើផ្សេងព័ទ្ធជុំវិញ។[723] ក្នុងបរិវេណមន្ទីរសន្តិសុខវត្តប្រធាតុមាន អគារប្រមាណចំនួន ៣ (បី) ក្នុងនោះមាន ទីមួយជាអគារវែងមួយជាគុកដែលមានបណ្តោយប្រវែងប្រហែលជា ៤០ (សែសិប) ម៉ែត្រ[724] ទីពីរជារោងឃុំឃាំងអ្នកជាប់ឃុំ ដែលមានទទឹងទំហំប្រហែល ៨ (ប្រាំបី) ម៉ែត្រ និងបណ្តោយប្រហែល ១២ (ដប់ពីរ) ម៉ែត្រ និងទីបីជាអគាររោងបាយ ដោយមានទាំងកន្លែងចិញ្ចឹមមាន់ ឃ្លាំងអង្ករ និងកន្លែងស្នាក់នៅរបស់អ្នកធ្វើការនៅមន្ទីរសន្តិសុខ។[725]

១៩២. ចំពោះរចនាសម្ព័ន្ធគ្រប់គ្រងមន្ទីរសន្តិសុខនេះ ប្រធានមន្ទីរសន្តិសុខដំបូងគេឈ្មោះ ចាន់។[726] ... រីឯ ឈ្មោះ ឈឹម និងឈ្មោះ ព្រីង ជាអនុប្រធានមន្ទីរ។[727] ក្រោយមកឈ្មោះ ព្រីង បាន...



CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION* E.C.C.C *C.E.T.C*

ជាប្រធានមន្ទីរសន្តិសុខ ហើយគាត់បានកាន់តំណែងនេះរហូតដល់កម្ពុជាប្រជាធិបតេយ្យដួលរលំ។[728] ទន្ទឹមនឹងពេលដែលឈ្មោះ ព្រីង ជាប្រធានគុក[729] ឈ្មោះ ឈឹម និងឈ្មោះ បេន ជាអនុប្រធានមន្ទីរសន្តិសុខ។[730] សក្ខីកម្មសាក្សីខ្លះថា ចំពោះការអនុវត្តជាក់ស្តែងឃើញមានឈ្មោះ ព្រីង ចាន់ និង ឈឹម ជារឿយៗតែងធ្វើការរួមគ្នាដូចប្រធាន។[731] សក្ខីកម្មសាក្សីបង្ហាញថា មុននឹងបញ្ជាឱ្យចាប់ខ្លួន និងបញ្ជូនទៅមន្ទីរសន្តិសុខវត្តប្រធាតុ គេត្រូវរាយការណ៍ទៅឱ្យប្រធានសន្តិសុខស្រុកជាមុនសិន។[732] ចំពោះការរាយការណ៍ទៅថ្នាក់លើមានតែប្រធានមន្ទីរសន្តិសុខវត្តប្រធាតុឈ្មោះ ព្រីង ទេ ដែលជាអ្នកមានសិទ្ធិរាយការណ៍ឱ្យគណៈស្រុកគិរីវង់។[733]

១៩៣. នៅមន្ទីរសន្តិសុខនេះ មានមនុស្សសំខាន់ម្នាក់ទៀតដែលមានឈ្មោះ ប៊ិន ដែលជាយោធាស្រុក ហើយក្រោយមក ប៊ិន បានក្លាយជាយោធាតំបន់ នៅក្នុងខែ មេសា ឆ្នាំ ១៩៧៥ ។[734] សក្ខីកម្មសាក្សីមួយរូបអះអាងថា ប៊ិន និង ចាន់ ជាមេឃ្លាំបស្រុក និងទទួលខុសត្រូវសន្តិសុខស្រុកគិរីវង់ទាំងមូល។[735] សាក្សីមួយចំនួនលើកឡើងថា គេមិនដែលឃើញឈ្មោះ ប៊ិន ចេញចូលមន្ទីរសន្តិសុខវត្តប្រធាតុទេ។[736] ផ្ទុយទៅវិញ សាក្សីមួយរូបថា ប៊ិន ជាមនុស្សកាចសាហាវហើយតែងតែចេញបញ្ជាឱ្យគេចាប់មនុស្សយកមកមន្ទីរសន្តិសុខវត្តប្រធាតុ។[737] ជាមួយនឹងសិទ្ធិអំណាចទាំងនេះហើយបានធ្វើឱ្យសាក្សីខ្លះយល់ច្រឡំថា ប៊ិន នេះហើយដែលជាប្រធានមន្ទីរសន្តិសុខវត្តប្រធាតុ។[738]

១៩៤. មន្ទីរសន្តិសុខវត្តប្រធាតុជាកន្លែងឃុំខ្លួនប្រជាជន និងប្រជាជនខ្មែរក្រោម ដែលចាប់បានមកពីតាមបណ្តា ភូមិ ឃុំ និងសហករណ៍ទាំងឡាយ ក្នុងស្រុកគិរីវង់ ខេត្តតាកែវ តំបន់ ១៣ ភូមិភាគនិរតី។[739] នៅពេលខ្លះក្នុងករណីត្រូវចាប់ខ្លួនមនុស្សម្តងៗគឺខាងថ្នាក់ស្រុកជាអ្នកបញ្ជូនបញ្ជីឈ្មោះមនុស្សដែលត្រូវចាប់ខ្លួនទៅឱ្យថ្នាក់ឃុំ ដើម្បីអនុវត្តបទបញ្ជា។[740]

១៩៥. អ្នកទោសនៅមន្ទីរសន្តិសុខវត្តប្រធាតុ មាន ២ (ពីរ) ប្រភេទ៖ អ្នកទោសធ្ងន់ និង អ្នកទោសស្រាល។[741] អ្នកទោសធ្ងន់ គេសំដៅទៅលើអ្នកដែលជាប់និន្នាការពីរបបមុនៗ រីឯអ្នកទោសស្រាលសំដៅដល់អ្នកដែលមានរឿងតូចតាច។[742] ចំពោះបញ្ហាតូចតាចដែលឈានទៅមានការចាប់ខ្លួនប្រជាជនមកឃុំនោះ ដោយសារអ្នកទាំងអស់នោះភាគច្រើនបានប្រព្រឹត្តអំពើមួយចំនួនដូចជា ធ្វើឱ្យបែកចាន, លួចរបស់ហូប, លួចដកដំឡូង, លួចអង្ករ, និងលួចយក



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ជាអាទិ៍។[743] ម្យ៉ាងវិញទៀត បើតាមសាក្សីម្នាក់រូបថា អ្នកទោសនៅមន្ទីរសន្តិសុខនេះ មិនត្រូវបានបែងចែកផ្សេងគ្នាទៅតាមប្រភេទអ្នកទោសឡើយ។[744]

១៩៦. អ្នកទោសត្រូវបានដាក់ខ្នោះជើងភ្ជាប់ទៅនឹងរបាដែក ១ (មួយ) វែង រីឯដៃម្ខាងរបស់គាត់ត្រូវបានដាក់ខ្នោះជាប់នឹងអ្នកទោសផ្សេងទៀត។[745] អ្នកទោសដែលជាប់ខ្នោះទាំងនោះ ត្រូវគេដាក់ឱ្យដេកជាពីរជួរ ដោយដាក់ជើងទល់គ្នា។ ក្នុងរោងអគារសម្រាប់ឃុំឃាំងមនុស្សមានខ្នោះ ពី ២ (ពីរ) ទៅ ៣ (បី) ជួរ ដោយក្នុងមួយជួរៗ គេដាក់អ្នកទោសបានប្រមាណជា ៥០ (ហាសិប) នាក់ ហើយក្រោយពីគេយកទៅសម្លាប់ខ្លះ ទើបគេត្រូវចាប់មនុស្សយកមកដាក់បន្ថែមទៀត។[746]

១៩៧. សាក្សីម្នាក់ដែលបានជាប់នៅក្នុងគុកនៅមន្ទីរសន្តិសុខវត្តព្រះធាតុអស់ ១២ (ដប់ពីរ) ខែ ក្នុងឆ្នាំ ១៩៧៧ បានផ្តល់សក្ខីកម្មថា នៅអំឡុងពេលជាប់គុកនោះ គាត់ត្រូវគេឃុំឃាំងក្នុងគុករយៈពេល ៣ (បី) ខែ ហើយក្រោយមកទើបបញ្ជូនគាត់ទៅកន្លែងអប់រំ ៤ (ប្រាំបួន) ខែ ដោយតម្រូវឱ្យគាត់ដើររកអុស និង ឡើងត្នោត ជាដើម។[747] អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខវត្តប្រធាតុមួយចំនួនក៏ត្រូវបានគេដោះលែងក៏មាន។[748] អ្នកទោសនៅមន្ទីរសន្តិសុខវត្តប្រធាតុត្រូវគេធ្វើទារុណកម្មយ៉ាងទារុណរួមមាន យកថង់ផ្លាស្ទិកគ្របក្បាល ត្រដរខ្សែ វាយនឹងថ្មោង និងចាប់បញ្ច្រកអំបិល ជាអាទិ៍។[749] អ្នកកត់ត្រាយកចម្លើយមានឈ្មោះ ឌុច ចាន់។[750] អ្នកជាប់ឃុំត្រូវបានគេសួរចម្លើយដោយការធ្វើទារុណកម្ម រួចហើយទើបគេចាប់យកទៅសម្លាប់ចោល ខណៈដែលអ្នកទោសខ្លះ ត្រូវគេយកទៅសម្លាប់តែម្តង។[751] អ្នកទោសត្រូវបានគេយកទៅសម្លាប់នៅវាលស្រែខាងត្បូងវត្តប្រធាតុ នាពេលស្ងាត់ៗអាចជាពេលថ្ងៃត្រង់ ឬ ពេលរសៀលព្រះអាទិត្យជិតលិច។[752]

១៩៨. ម្យ៉ាងវិញទៀត ក៏នៅមានការលេចឮថា នារីដែលស្អាតៗត្រូវបានគេបង្ខំឱ្យរួមភេទ ហើយប្រសិនបើគេដឹងថាស្ត្រីនោះមានផ្ទៃពោះ គេនឹងចាប់នារីយកទៅសម្លាប់ចោល។[753] អ្នកទោសនៅវត្តប្រធាតុនេះ ខ្លះបានស្លាប់ដោយសារការធ្វើទារុណកម្ម ឬអត់អាហារ ឬជំងឺជាដើម[754] និងអ្នកខ្លះទៀតត្រូវបានគេនាំចេញពីគុក ហើយវាយសម្លាប់ទម្លាក់ដាក់ចូលក្នុងរណ្តៅដែលមានចម្ងាយប្រមាណជា ១០០ (មួយរយ) ម៉ែត្រ ពីវត្តប្រធាតុ។[755] សាក្សីបាន បន្ថែមថា ករណីដែលមានការសម្លាប់មនុស្សក្នុងចំនួនច្រើននាក់ នោះគេនឹងត្រូវធ្វើវា



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ជំនួយពីថ្នាក់ស្រុកមកជួយ។[756] សាក្សីមួយរូបបានផ្តល់សក្ខីកម្មថា ធ្លាប់ឃើញអ្នកនៅគ្រប់គ្រងគុកនោះ កាត់ក្បាលមនុស្សសម្លាប់ទៀតផង។[757] ជាចុងក្រោយ មានតែអ្នកទោស ៤ (បួន) នាក់ ប៉ុណ្ណោះដែលបានរួចផុតពីការសម្លាប់ នៅមន្ទីរសន្តិសុខវត្តប្រធាតុ។[758]

១៩៩. បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម គេឃើញនៅមានសេសសល់នូវគំនរឆ្អឹងមនុស្សយ៉ាងខ្ពស់ និងរណ្តៅសាកសព។[759] មន្ទីរសន្តិសុខវត្តប្រធាតុនេះ ត្រូវបានគេចាត់ទុកថា ជាកន្លែងឃុំឃាំង និងសម្លាប់មនុស្សដ៏ធំជាងគេមួយនៅស្រុកគិរីវង់។[760] សាក្សីមួយចំនួនបានធ្វើការប្រមាណថា អាចមានជនរងគ្រោះពី ៥.០០០ (ប្រាំពាន់) ទៅ ៦.០០០ (ប្រាំមួយពាន់) នាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តប្រធាតុនេះ។[761] រីឯ សាក្សីផ្សេងបែរជាលើកឡើងថា ចំនួនមនុស្សដែលត្រូវបានគេសម្លាប់នៅមន្ទីរសន្តិសុខវត្តប្រធាតុ មានច្រើនរហូតដល់ ១៦.០០០ (មួយម៉ឺនប្រាំមួយពាន់)[762] នាក់ ខណៈដែលមួយចំនួនក្នុងចំណោមនោះត្រូវបានសម្លាប់តាំងពីនៅក្នុងរបប លន់ នល់ មកម្ល៉េះ។[763] ជាក់ស្តែង នៅបរិវេណនៃមន្ទីរសន្តិសុខវត្តប្រធាតុនេះ បន្ទាប់ពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ គេឃើញមានរណ្តៅសាកសពចំនួន ២០០ (ពីររយ) ទៅ ៣០០ (បីរយ) រណ្តៅ ហើយមានគំនរឆ្អឹងមនុស្សយ៉ាងខ្ពស់ និងរប៉ាត់រប៉ាយទៅដោយលលាដ៍ក្បាលមនុស្សត្រូវបានរកឃើញ។[764]

២០០. សាក្សីខ្លះថា ប្រហែលជានៅចុងឆ្នាំ ១៩៧៥ ឬ ដើមឆ្នាំ ១៩៧៦ បានឃើញ **តា ទិត្យ** ចុះមកមើលអ្នកទោសនៅមន្ទីរសន្តិសុខវត្តប្រធាតុ។[765] សាក្សីជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តប្រធាតុពីរនាក់ បានបញ្ជាក់ថា **តា ទិត្យ** ធ្លាប់មកពិនិត្យមន្ទីរសន្តិសុខវត្តប្រធាតុ យ៉ាងតិច ២ (ពីរ) ដង។[766] ផ្ទុយទៅវិញ តាមសក្ខីកម្មសាក្សីជាច្រើននាក់ផ្សេងទៀត បានអះអាងប្រហាក់ប្រហែលគ្នាថា ពុំដែលបានឃើញ **តាទិត្យ** ចុះមកពិនិត្យមន្ទីរសន្តិសុខវត្តប្រធាតុនោះទេ។[767]

២០១. មានការលើកឡើងដែរថា **តាទិត្យ** បានដឹងពីចាប់ខ្លួន និងសម្លាប់មនុស្ស នៅមន្ទីរសន្តិសុខវត្តប្រធាតុនេះ។[768] ទន្ទឹមនឹងនោះ មានសក្ខីកម្មសាក្សីផ្សេងទៀតបានអះអាងដែរថា **តាទិត្យ** បានចេញបញ្ជាឲ្យគេដោះលែងអ្នកទោស បន្ទាប់ពីគាត់បានចុះមកមើលមន្ទីរសន្តិសុខនេះ។[769] សាក្សីមួយរូបថា នៅពេលគាត់បានកំពុងដើរតម្រង់ទៅវត្តប្រធាតុ គាត់បានឃើញ **តាទិត្យ** ធ្វើដំណើរតាមម៉ូតូ ដើម្បីមកត្រួតពិនិត្យនៅតាមឃុំ។[770]



E.C.C.C * C.E.T.C. INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

## ២. មន្ទីរសន្តិសុខក្រាំងតាចាន់

២០២. មន្ទីរសន្តិសុខក្រាំងតាចាន់ ត្រូវបានគេស្គាល់ថាជាមន្ទីរអប់រំស្រុក ១០៥[771] ឬជាមន្ទីរសន្តិសុខស្រុក។[772] មន្ទីរសន្តិសុខនេះមានទីតាំងស្ថិតនៅក្នុងភូមិត្រពាំងលាន ឃុំគុស ស្រុកត្រាំកក់ (ស្រុក ១០៥)[773] ខេត្តតាកែវ។[774]

២០៣. មន្ទីរសន្តិសុខក្រាំងតាចាន់ មានរាងជាចតុកោណកែង ហើយនៅក្នុងបរិវេណគុកនោះ មានអគារសម្រាប់ប្រធាន និងអនុប្រធានគុក[775] ដោយនៅចំកណ្តាលមានរណ្តៅធំមួយ។ មានរណ្តៅបីផ្សេងទៀតដែលស្ថិតនៅតាមទិសនីមួយៗនៅ ខាងជើងឆៀងខាងលិច និងខាងកើតនៅខាងត្បូងឆៀងខាងកើត និងនៅប៉ែកខាងលិច។[776] មន្ទីរសន្តិសុខក្រាំងតាចាន់ ក៏មានគុកងងឹតក្រោមដីផងដែរ។[777]

២០៤. ទាក់ទិននឹងការបង្កើតមន្ទីរសន្តិសុខក្រាំងតាចាន់ សាក្សីមួយចំនួនអះអាងថាដំបូងឡើយមន្ទីរនេះត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៧២ ឬ ឆ្នាំ ១៩៧៣ ជាកន្លែងទុកសម្រាប់ប្រជុំ ហើយនៅពាក់កណ្តាលឆ្នាំ ១៩៧៣ ក្រាំងតាចាន់បានផ្លាស់ប្តូរទៅជាមន្ទីរឃុំឃាំងក្រោមការគ្រប់គ្រងរបស់គណៈស្រុក ១០៥។[778] ប៉ុន្តែមានសាក្សីខ្លះអះអាងថា មន្ទីរសន្តិសុខក្រាំងតាចាន់បង្កើតឡើងនៅដើមឆ្នាំ ១៩៧៥ ឬ ក្នុងឆ្នាំ ១៩៧៥ ដែលមានទីតាំងស្ថិតនៅក្នុងព្រៃ[779] ឬស្ថិតនៅក្បែរវត្តអង្គពណ្ណរាយ។[780] ចំណែកសាក្សីឈ្មោះ អ៊ុក ហ៊ីម បានលើកឡើងថានៅមុនឆ្នាំ ១៩៧៦ មន្ទីរសន្តិសុខក្រាំងតាចាន់មិនមែនជាគុកពិតប្រាកដទេ តែជាមន្ទីរអប់រំដែលគេបញ្ជូនមនុស្សទៅរៀនសូត្រ និងជាកន្លែងវាយសម្លាប់មនុស្ស រហូតដល់ឆ្នាំ ១៩៧៦ ទើបគេចាប់ផ្តើមសាងសង់រោងដើម្បីធ្វើជាគុក។[781] សាក្សីផ្សេងទៀតក៏បានអះអាងថាមន្ទីរសន្តិសុខក្រាំងតាចាន់បង្កើតឡើងក្នុងគោលបំណងដើម្បីធ្វើការអប់រំរៀនសូត្រផង និងសម្រាប់សួរចម្លើយផង។[782] មន្ទីរសន្តិសុខក្រាំងតាចាន់បានដំណើរការរហូតដល់ថ្ងៃដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។[783]

២០៥. សាក្សីមួយចំនួនបានអះអាងថាដូចៗគ្នាថាដំបូងឡើយ ផាន់ ឆេន ហៅ តា ឆេន ជាប្រធានគ្រប់គ្រងរបស់មន្ទីរអប់រំក្រាំងតាចាន់ចាប់តាំងពីមុនឆ្នាំ ១៩៧៣។[784] នាពេលក្រោយ[illegible] តា ឆេន ត្រូវបានគេផ្លាស់ចេញពីមន្ទីរ ហើយអនុប្រធានរបស់គាត់ឈ្មោះ ឡេង អា[illegible]

តា អាន់ បានក្លាយជាប្រធានមន្ទីរ[785], តា ឃន ជាអនុប្រធានរបស់ តា អាន់ ក្រោយមក ឌុច ធំ អតីតអ្នកយាមគុកក្រាំងតាចាន់បានឡើងជាអនុប្រធាន និងនាពេលក្រោយមក តា ពេញ ក្លាយជាអនុប្រធានជំនួស ឌុច ធំ។[786] តាចេង ជាសមាជិកម្នាក់ និងមានអ្នកយាមមួយចំនួនទៀត។[787] មន្ទីរសន្តិសុខនេះមានបុគ្គលិកចំនួនសរុបប្រហែល ១២ (ដប់ពីរ) ឬ ១៣ (ដប់បី) នាក់[788] ក្នុងនោះមានបុគ្គលិកធ្វើការនៅមន្ទីរ និងបុគ្គលិកយ៉ាងហោចណាស់ ៦ (ប្រាំមួយ) នាក់ ជាទាហានកងការពារ។[789]

២០៦. ប្រជាជនដែលត្រូវបានជម្លៀសមកពីភ្នំពេញ ត្រូវបានគេបញ្ជូនទៅដាក់នៅមន្ទីរសន្តិសុខក្រាំងតាចាន់។[790] ចំណែកអ្នកទោសផ្សេងៗទៀតមកពីគ្រប់ឃុំក្នុងស្រុកទូទាំងខេត្តតាកែវ និងអ្នកទោសមកពីខេត្តដទៃទៀត[791] អ្នកតាំងទីលំនៅថ្មីដែលមកពីស្រុកគិរីវង់[792] អតីតអ្នករដ្ឋការរបបចាស់[793] ត្រូវបានគេបញ្ជូនទៅដាក់នៅមន្ទីរសន្តិសុខក្រាំងតាចាន់ទាំងអស់គ្នា។[794]

២០៧. សាក្សីបានលើកឡើងថា ខ្មែរក្រោមត្រូវបានគេបញ្ជូនទៅក្រាំងតាចាន់តាំងពីឆ្នាំ ១៩៧៥ បន្តបន្ទាប់រហូតដល់ឆ្នាំ ១៩៧៨។ ខ្មែរក្រោមត្រូវបានគេបញ្ជូនគុកក្រាំងតាចាន់ច្រើនជាងគេនៅឆ្នាំ ១៩៧៧ ពីព្រោះជាឆ្នាំដែលវៀតណាមវាយចូលមកខ្លាំង ហើយពេលនោះគេចោទប្រជាជនកម្ពុជាក្រោមថាជាយួន។[795] ជាក់ស្តែងមានរបាយការណ៍នានារវាងមន្ទីរឃុំ មន្ទីរស្រុក និងមន្ទីរសន្តិសុខក្រាំងតាចាន់ បាននិយាយពីរឿងចាប់ខ្លួនពួកខ្មែរក្រោមចាប់ពីឆ្នាំ ១៩៧៥ រហូតដល់ឆ្នាំ ១៩៧៨។[796] សាក្សីបានអះអាងថា ក្រោយខ្មែរក្រហមរំដោះទីក្រុងភ្នំពេញ មានជនជាតិភាគតិចខ្មែរក្រោមបីគ្រួសារត្រូវបានគេបញ្ជូនឱ្យទៅរស់នៅក្នុងភូមិរបស់គាត់ ហើយក្រោយមកត្រូវបានគេបញ្ជូនទៅក្រាំងតាចាន់។[797] ជនរងគ្រោះឈ្មោះ យ៉ាន់ ប៉ែត ក៏ធ្លាប់ត្រូវបានគេចាប់បញ្ជូនទៅក្រាំងតាចាន់ដែរ។[798]

២០៨. មន្ទីរសន្តិសុខក្រាំងតាចាន់ ក៏ជាកន្លែងសម្លាប់មនុស្សផងដែរ។[799] សាក្សីឈ្មោះ រៀល សន បានអះអាងថា ខ្លួនបានចូលរួមប្រជុំចំនួនពីរដងគឺនៅពាក់កណ្តាល និងចុងរបបខ្មែរក្រហម ហើយបានឮគណៈស្រុកត្រាំកក់ ប្រកាសប្រាប់អ្នកចូលរួមអំពីប្រភេទមនុស្សដែលត្រូវបោសសម្អាតមនុស្សពាក់ព័ន្ធនឹងរបប លន់ នល់ ដែលនឹងត្រូវសម្លាប់ទាំងអស់ដូចជា អ្នករាជការនគរបាល និងទាហានមានឋានៈចាប់ពីអាស់សឺដង់ (នាយចំណង់)។[800] សក្ខីកម្មរបស់សាក្សីផ្សេងៗទៀតក៏បានបង្ហាញឱ្យឃើញថាមានប្រជាជន ១៧ មេសា អ្នកជម្លៀសពីភ្នំពេញ និង



INVESTIGATING JUDGES *E.C.C.C*C.E.T.C.* JUGES D'INSTRUCTION

អ្នកធ្លាប់បម្រើការងារក្នុងរបប លន់ នល់ ជាច្រើននាក់ត្រូវបានគេសម្រិតសម្រាំង និងបញ្ជូនទៅមន្ទីរសន្តិសុខក្រាំងតាចាន់។[801]

២០៩. មនុស្សត្រូវបានចាប់ខ្លួនដោយ មេភូមិ[802] ឈ្លប[803] និងនិរសារ។[804] ជាទូទៅមានការចាប់បញ្ជូនអ្នកទោសមានទាំងកុមារ និងស្ត្រី ក្មេង ចាស់[805] ទៅដាក់គុកក្រាំងតាចាន់ជារៀងរាល់ថ្ងៃ ឬ ៣ (បី) ទៅ ៥ (ប្រាំ) ថ្ងៃម្តង។[806] ចំនួនអ្នកទោសបញ្ជូនមកមន្ទីរសន្តិសុខក្រាំងតាចាន់មិនទៀងទាត់ទេ[807] មានពេលខ្លះការចាប់បញ្ជូនអ្នកទោសទៅដាក់គុកក្រាំងតាចាន់ម្តងៗមានពី ២០ (ម្ភៃ) ទៅ ៣០ (សាមសិប) នាក់។[808] សាក្សីបានឃើញគេចងពួកជនជាតិជា ៦ ខ្សែ ហើយបណ្តើរទៅក្រាំង តាចាន់ ហើយពួកគាត់ទាំងអស់នោះមានទាំងកូនក្មេងផងដែរ។[809] សាក្សីបានបន្ថែមថា ពេលនោះគាត់បានឃើញមនុស្សប្រហែល ៥៩ ទៅ ៦៨ នាក់មិនរាប់កុមារទេ។[810] មានការអះអាងខុសៗគ្នាពីចំនួនអ្នកជាប់ឃុំឃាំងនៅក្រាំងតាចាន់ ដោយខ្លះថាច្រើនជាង ២០០ (ពីររយ) នាក់[811] ខ្លះថាមានយ៉ាងច្រើន ៣០ នាក់ប៉ុណ្ណោះ តែបើមានច្រើនជាងនេះគឺអាចមាននៅក្នុងសម័យតាផេន មុនក្នុងឆ្នាំ១៩៧៥។[812] សាក្សីបានអះអាងថា ហេតុផលដែលគេចាប់មនុស្សបញ្ជូនទៅគុកក្រាំងតាចាន់ គឺដោយសារសុំបាយគេហូប[813] ប្រជាជនដែលប្រឆាំងនឹងបដិវត្តន៍[814] និងប្រកែក ឬបដិសេធដាច់អហង្ការមិនព្រមរៀបការ។[815]

២១០. អ្នកទោសនៅទីនោះត្រូវបានគេសួរចម្លើយ ធ្វើទារុណកម្ម[816] និងវាយនៅពេលដែលសួរចម្លើយ[817] ហើយត្រូវបានគេស្តីបន្ទោសមើលងាយ និងត្រូវបានគេដាក់ខ្នោះជើងទៀតផង។[818] ជាក់ស្តែងសាក្សីម្នាក់បានឮសំឡេងរញ៉េរញ៉ៃ ហើយបានមើលតាមរបងគុកឃើញគេវាយអ្នកទោស និងហែកមាត់អ្នកទោសណាដែលមិនព្រមនិយាយ(ឆ្លើយ)។ អ្នកសួរចម្លើយនោះគឺជាអនុប្រធានមន្ទីរក្រាំងតាចាន់។[819]

២១១. សាក្សីម្នាក់ដែលធ្លាប់ជាប់ទោសនៅមន្ទីរក្រាំងតាចាន់បានលើកឡើងថា ខ្លួនធ្លាប់ឃើញមានលិខិតស្ទើរតែរាល់ថ្ងៃគឺសរសេរប៊ិចពណ៌ក្រហមពីអង្គការថ្នាក់លើ ដោយដាក់ឈ្មោះអ្នកដែលត្រូវកម្ទេច បន្ទាប់មកអ្នកដែលមានឈ្មោះក្នុងលិខិតនោះ ត្រូវបានគេហៅណែនាំថា "គោរពផែនការនិងអង្គការ កុំក្បត់នឹងអង្គការ យើងបានរួចទៅតាមសហការណ៍វិញ ត្រូវគោរពតាមផែនការ"។ តាមពិតអ្នកទោសទាំងនោះត្រូវបានគេយកទៅសម្លាប់ចោល។[820]



C.E.T.C * C.E.T.C * INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

សាក្សីម្នាក់ឈ្មោះ សែត យ៉ែម ដែលជាអ្នកទោសម្នាក់នៅក្រាំងតាចាន់បានអះអាងថា កូនរបស់គាត់ឈ្មោះ សែត ខែម ដែលនៅជាប់គុកជាមួយគាត់ ត្រូវបានគេសម្លាប់ និងហាមមិនឱ្យពួកគាត់យំទៀត។[821]

២១២. នៅមន្ទីរសន្តិសុខក្រាំងតាចាន់មានអ្នកទោសជាជនជាតិខ្មែរក្រោមប្រមាណ ១២៧ នាក់ ដោយមិនរាប់បញ្ចូលកូនក្មេងផង ដែលត្រូវបានបញ្ជូនមកកាន់មន្ទីរសន្តិសុខក្រាំងតាចាន់ ដើម្បីរៀនសូត្រ តែតាមពិតពួកគេត្រូវបានគេយកទៅសម្លាប់ទាំងអស់ ដោយដំបូងគេវាយសម្លាប់ឪពុកម្តាយជាមុនសិន រួចរុញទម្លាក់ចូលក្នុងរណ្តៅ ទាំងអ្នកខ្លះមិនទាន់ទាំងស្លាប់ផង បន្ទាប់មកគេវាយសម្លាប់កូនទៀត។[822] សាក្សីផ្សេងទៀតដែលបានឃើញដោយផ្ទាល់ភ្នែកម្តងឬពីរដង[823] បានអះអាងថា ខ្មែរក្រោមមិនត្រូវបានជាប់គុកយូរនោះទេ គឺតែ ១ (មួយ) ឬ ២ (ពីរ) ថ្ងៃ ត្រូវគេយកទៅសម្លាប់ហើយ ជួនកាលម្តង ៣ (បី), ៤ (បួន) ឬក៏ ៥ (ប្រាំ) នាក់។ សាក្សីខ្លះទៀតថា គេសម្លាប់អ្នកទោសម្តងៗពី ៥០ (ហាសិប) ទៅ ៦០ (ហុកសិប) នាក់ ឬ ១០០ (មួយរយ) នាក់។[824] សាក្សីបានអះអាងថា អ្នកយកមនុស្សទៅសម្លាប់ដោយផ្ទាល់គឺ តា អាន់ ប្រធានមន្ទីរសន្តិសុខក្រាំងតាចាន់ ប៉ុន្តែសាក្សីមិនបានឃើញការសម្លាប់មនុស្សដោយរបៀបណានោះទេ គ្រាន់តែឃើញមានមនុស្សស្លាប់គរលើគ្នា។[825]

២១៣. សាក្សីមួយចំនួនអះអាងថា ថ្នាក់ដឹកនាំនៃមន្ទីរសន្តិសុខក្រាំងតាចាន់ គ្មានសិទ្ធិសម្រេចចាប់ខ្លួនដោយគ្មានបញ្ជាពីថ្នាក់លើនោះទេ[826] ហើយថ្នាក់ក្រោមត្រូវតែធ្វើតាមការណែនាំរបស់ថ្នាក់លើ។[827] ជាទូទៅថ្នាក់ស្រុក ជាអ្នកទទួលរបាយការណ៍នានាដែលបញ្ជូនមកពីថ្នាក់ឃុំនានា ហើយរបាយការណ៍ទាំងនោះភាគច្រើនរាយការណ៍ជូនថ្នាក់លើពាក់ព័ន្ធនឹងសមាសភាពសង្ស័យ សកម្មភាពក្បត់របស់ខ្មាំង សភាពការណ៍នៅក្នុងមូលដ្ឋានរបស់ខ្លួន ការចាប់បានខ្មាំង ឬការសុំមតិណែនាំ សុំការសម្រេចពីអង្គការថ្នាក់លើជាអាទិ៍។[828] ចំពោះអ្នកដែលត្រូវថ្នាក់ឃុំចាប់ ត្រូវបញ្ជូនទៅថ្នាក់ស្រុក និងត្រូវបញ្ជូនបន្តទៅមន្ទីរសន្តិសុខក្រាំងតាចាន់ព្រមជាមួយរបាយការណ៍។[829] ទន្ទឹមជាមួយគ្នានេះស្រុកក៏ធ្វើរបាយការណ៍បញ្ជូនទៅថ្នាក់តំបន់ផងដែរ[830] ចំណែកសេចក្តីសម្រេចរបស់ថ្នាក់លើដែលបញ្ជូនមកវិញនោះគឺតាអាន់ ប្រធានមន្ទីរសន្តិសុខក្រាំងតាចាន់ជាអ្នកអនុវត្ត។[831] តាអាន់ រាយការណ៍ទៅថ្នាក់លើរបស់គាត់អំពីចម្លើយសារភាពរបស់អ្នកទោសទាំងនោះ ហើយសេចក្តីសម្រេចទាំងឡាយ



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

រួមមានការបន្តតាមចាប់ខ្លួនខ្សែខ្មាំង ការតាមដានអ្នកទោសបន្តទៀត ឬការកម្ទេចអ្នកទោសសុទ្ធតែមានបញ្ជាមកពីថ្នាក់លើ។[832]

២១៤. សាក្សីធ្លាប់ឮគេនិយាយប្រាប់ថា ប្រធាន អនុប្រធាន និងពួកឈ្លបទាំងអស់នៅមន្ទីរក្រាំងតាចាន់ បានយកអ្នកទោសស្រីទៅសម្លាប់ទាំងអស់ ក្រោយពួកចាប់រំលោភរួច។[833] ជាក់ស្តែងមានសាក្សីម្នាក់បានអះអាងថា អ្នកវាយអង្គុលីលេខនៅមន្ទីរក្រាំងតាចាន់[834] បានសម្លាប់នារីកងចល័តជាច្រើននាក់ យ៉ាងសាហាវ ដោយបានយកចុងគ្រាប់ M-79 យកទៅញាត់ក្នុងកេរ្តិ៍ខ្មាសរបស់នារីនោះ បន្ទាប់ពីបានចាប់រំលោភរួច។[835] ប៉ុន្តែសាក្សីមួយចំនួនបានអះអាងថា ពិតជាមានការសម្លាប់មនុស្សនៅមន្ទីរក្រាំងតាចាន់មែន តែមិនមានករណីរំលោភស្ត្រីនៅក្នុងគុកនោះទេ។[836] បើសិនជាមានករណីបែបនេះជនរងគ្រោះ និងអ្នកប្រព្រឹត្តនឹងត្រូវបានសម្លាប់ដោយសារប្រព្រឹត្តខុសសីលធម៌។[837]

២១៥. សាក្សីឈ្មោះ យិន តេង បានអះអាងថា ប្រធានមន្ទីរសន្តិសុខក្រាំងតាចាន់បានទាក់ទងជាមួយ តាម៉ុក តាមរយៈសំបុត្រឆ្លងឆ្លើយ ដោយមាននិរសាម្នាក់ឈ្មោះ មឿន (ក្មេង)។[838] សាក្សីមួយចំនួនបានអះអាងថាធ្លាប់ឃើញ តាម៉ុក មកបរិវេណក្រាំងតាចាន់ ៣ ទៅ ៤ ថ្ងៃម្តង ឬ១ អាទិត្យម្តង។[839] ក្រៅពីនេះមានសាក្សីផ្សេងៗទៀតដែលធ្លាប់ធ្វើជាអ្នកយាមគុក និងអ្នកជាប់គុកនៅក្រាំងតាចាន់បានអះអាងដូចៗគ្នាថា ពួកគេមិនធ្លាប់ឮ និងមិនធ្លាប់ស្គាល់ឈ្មោះ **យឹម ទិត្យ** ឬ **តាទិត្យ** ឡើយ។[840]

## ៣. ទីតាំងសម្លាប់មនុស្សភូមិព្រៃល

២១៦. ទីតាំងសម្លាប់មនុស្សភូមិព្រៃលស្ថិតនៅក្នុងឃុំសោម ស្រុកគិរីវង់ ខេត្តតាកែវ[841] ជិតព្រំដែនជាមួយប្រទេសវៀតណាម។[842] មិនមានភាពជាក់លាក់ថា កន្លែងសម្លាប់មនុស្សនេះ កើតឡើង និងបញ្ចប់ទៅវិញនៅពេលណាទេ។ ក៏ប៉ុន្តែ សាក្សីភាគច្រើនអះអាងថា ទីតាំងនេះចាប់ដំណើរការក្នុងអំឡុងចុងឆ្នាំ ១៩៧៨។ ក្នុងភូមិព្រៃល មានវត្តដែលត្រូវបានព័ទ្ធជុំវិញដោយព្រៃឫស្សី។[843]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

២១៧. តាប្រាជ្ញា ជាអ្នកគ្រប់គ្រងទ័ពនៅទីនោះ។[844] សាក្សីខ្លះ បានអះអាងថា ឈ្មោះ ហេង ជាអ្នកគ្រប់គ្រងលើខ្មែរក្រោម នៅក្នុងវត្តព្រៃល។[845]

២១៨. ខ្មែរក្រហមបានលួងលោមខ្មែរកម្ពុជាក្រោមឲ្យចូលមកក្នុងវត្តព្រៃល។[846] ខ្មែរក្រហមបានគម្រាមបាញ់សម្លាប់ ក្នុងករណីដែលមានអ្នកណាជំទាស់។[847] ខ្មែរក្រោមចំនួន ៣០ (សាមសិប) នាក់បានរត់គេចចេញនាពេលស្នើឲ្យចាកចេញមករស់នៅក្នុងភូមិព្រៃល។[848] សាក្សីជាច្រើនបានអះអាងស្រដៀងគ្នាថា នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រោម ដែលមកពីប្រទេសវៀតណាមត្រូវបានប្រមូលមកដាក់ក្នុងវត្តភូមិព្រៃល[849] ក្នុងនោះមានកុមារនិងស្ត្រីផងដែរ។[850] ក្នុងចំណោមនោះ ពួកគេត្រូវបានកេណ្ឌឲ្យចូលធ្វើជាទាហាន[851] ដើម្បីវាយប្រឆាំងតបនឹងវៀតណាម។[852] ក្រៅពីខ្មែរកម្ពុជាក្រោម ព្រះសង្ឃក៏ត្រូវបានគេជម្លៀសពីវត្តផ្សេងទៀតមកកាន់វត្តព្រៃល រួចត្រូវបានគេផ្សឹកនៅទីនោះតែម្តង។[853] ព្រះសង្ឃក្មេងៗត្រូវបានគេឲ្យទៅធ្វើទ័ពខ្មែរក្រហម ហើយចំណែកចៅអធិការត្រូវបានគេបញ្ជូនទៅកំពែងគោកព្រិច។[854]

២១៩. ខ្មែរក្រោមទាំងនោះ មិនត្រូវបានអនុញ្ញាតឲ្យចាកចេញពីវត្តព្រៃលទេ។[855] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា ខ្មែរក្រោមណាដែលបានចេញពីវត្តព្រៃលដោយគ្មានការអនុញ្ញាតពីខ្មែរក្រហមនឹងត្រូវបាត់ខ្លួន ហើយជាក់ស្តែងក៏ធ្លាប់មានទាហានខ្មែរក្រោមបានបាត់ខ្លួននៅពេលយប់ផងដែរ។[856] នៅចុងឆ្នាំ ១៩៧៨ ខ្មែរក្រហមបានសម្លាប់ខ្មែរក្រោម ដោយសារពួកគេលួចរត់ទៅវៀតណាមវិញ។[857] បន្ថែមពីលើនេះ ប្រជាជនមានស្ត្រីនិងកុមារត្រូវបានសម្លាប់[858] ដោយសារពួកគេនិយាយប៉ៃឡាំៗ[859] ឬ ប្រជាពលរដ្ឋដែលមានប្តី ឬ ប្រពន្ធជាប់ខ្សែវៀតណាម។[860] ជាក់ស្តែងសាក្សីបានឃើញដោយផ្ទាល់បានអះអាងថាមានគ្រួសារមួយប្រពន្ធជាជនជាតិយួន ហើយកូនប្អូននាក់ និយាយភាសាខ្មែររដឹន ត្រូវបានគេយកទៅសម្លាប់ទាំងអស់។[861] ទោះបីជាយ៉ាងនេះក្តី សាក្សីខ្លះបានអះអាង ថាមិនបានដឹងអំពីការសម្លាប់ទេ។[862] សាក្សីខ្លះគ្រាន់តែបានកត់សម្គាល់ថា មានការបាត់ខ្លួនប្រជាជននៅទីនោះ។[863]

២២០. សាក្សីអះអាងថា ធ្លាប់ប្រទះឃើញរណ្តៅសពរួមនានាដែលខ្មែរក្រោមត្រូវបានយក[illegible] សម្លាប់នៅភូមិព្រៃល ឃុំសោម ដែរ។[864] ខ្មែរក្រោមត្រូវបានគេវាយចោល និងញាត់[illegible]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

ល្អាងនៅលើភ្នំប្រហែលជាង ១.០០០ (មួយពាន់) នាក់។[865] សាក្សីឈ្មោះ សាន ទូច ដែលសព្វថ្ងៃរស់ក្នុងភូមិនោះ មានអះអាងថា នៅក្នុងភូមិព្រៃល មានរណ្តៅសម្លាប់មនុស្សតែមួយប៉ុណ្ណោះ គឺជារូង ឬ ជាល្អាងនៅលើភ្នំ ដែលមានចម្ងាយប្រហែល ១,៥ (មួយក្បៀសប្រាំ) គីឡូម៉ែត្រ ពីភូមិព្រៃល។[866]

២២១. ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ខ្មែរក្រោមត្រូវបានគេសម្លាប់ តាមគោលនយោបាយរបស់ ប៉ុល ពត ហើយពួកគាត់បានបញ្ជាក់បន្ថែមថា ពួកគេមិនដែលស្គាល់ និងមិនដែលឮឈ្មោះ តាទិត្យ នោះទេ។[867]

## ៤. ទីតាំងសម្លាប់មនុស្សវត្តអង្គុណា

២២២. ទីតាំងសម្លាប់មនុស្សវត្តអង្គុណា មានទីតាំងស្ថិតនៅក្នុងភូមិប្រាសាទ ឃុំកំពែង ស្រុកគិរីវង់ (ស្រុក ១០៩)[868] ខេត្តតាកែវ តំបន់ ១៣ ភូមិភាគនិរតី ។[869] ទីតាំងសម្លាប់មនុស្សវត្តអង្គុញ ត្រូវបានបង្កើតឡើងនៅក្រោយឆ្នាំ ១៩៧៥។[870]

២២៣. វត្តអង្គុញ គឺជាវត្តមួយតូចដែលហ៊ុមព័ទ្ធជុំវិញដោយវាលស្រែធំល្វឹងល្វើយ។[871] វត្តអង្គុណា មិនមែនជាទីកន្លែងឃុំឃាំង និងសម្លាប់មនុស្ស ប៉ុន្តែវាកន្លែងស្នាក់នៅរបស់កងយុវជន កងយុវនារី និងកងកុមារ ជាអាទិ៍។[872] រីឯ ទីតាំងសម្លាប់មនុស្សវត្តអង្គុណាវិញ ស្ថិតនៅខាងក្រៅបរិវេណវត្តអង្គុណាដែលនៅតាមបណ្តាទួល និងដំបូកទាំងឡាយដែលនៅក្រៅវត្តអង្គុណា។[873] ទីទួលដំបូកដែលនៅម៉្តុំវត្តអង្គុណាមានច្រើនកន្លែង ខ្លះមានចម្ងាយប្រហែល ៥០ (ហាសិប) ម៉ែត្រ, ១០០ (មួយរយ) ម៉ែត្រ និង ២០០ (ពីររយ) ម៉ែត្រពីវត្តអង្គុណា។[874]

២២៤. តាប៉ុស ជាប្រធានសហករណ៍ក្នុងឃុំកំពែង ស្រុកគិរីវង់ និងឈ្មោះ ឆេង ជាអនុប្រធាន។[875]

២២៥. សាក្សីមួយរូប បានឃើញសាកសពមនុស្សជាច្រើននាក់ ដែលបានស្លាប់នៅតាមដំបូកក្បែរវត្តអង្គុណា។[876] ខណៈដែលសាក្សីរូបនេះនៅបានបន្ថែមទៀតថា "មិនមានការដ្ឋាន ឬ



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

សមរភូមិនៅក្បែរវត្តអង្គុណទេ"។[877] ផ្ទុយទៅវិញ មានសាក្សីខ្លះបានអះអាងថា មានការសម្លាប់ខ្លះដែរនៅវត្តអង្គុណ ហើយខ្លះទៀតនៅនឹងកន្លែងការដ្ឋានតែម្តង។[878]

២២៦. អ្នកទោសដែលត្រូវបានគេចាប់បញ្ជូនមកវត្តអង្គុណនេះរួមមាន អ្នកចេះដឹង អ្នកជាប់និន្នាការរដ្ឋការ អតីតកងទ័ព និងខ្មែរក្រោម ជាអាទិ៍។[879] មានសាក្សីជាច្រើននាក់ត្រូវបានគេចាប់បញ្ជូនមកវត្តអង្គុណបានរួចរស់ជីវិតត្រឡប់មកវិញ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ។[880] អ្នកទោសមួយចំនួនត្រូវបានគេឃុំឃាំងកន្លែងផ្សេងៗ ប៉ុន្តែនៅពេលសម្លាប់ត្រូវគេចាប់យកទៅសម្លាប់នៅទីតាំងសម្លាប់មនុស្សវត្តអង្គុណ។[881]

២២៧. អ្នកស្នាក់នៅក្នុងវត្តអង្គុណ ត្រូវគេតម្រូវឱ្យធ្វើការជីកប្រឡាយ ហើយនៅពេលសម្រាកគេឱ្យច្រៀងចម្រៀងបដិវត្តន៍ដើម្បីកំដរបរិយាកាស។ ជាក់ស្តែងមានអ្នកច្រៀងម្នាក់បែរជាច្រៀងច្រឡំបទបរទេសទាំងភ្លេចខ្លួនត្រូវគេចាប់អូសយកទៅវាយចោលនៅចំពោះមុខមនុស្សគ្រប់គ្នាស្តែងៗតែម្តង។[882]

២២៨. គេឃើញមានរណ្តៅ ដោយរណ្តៅនីមួយៗភាគច្រើនមានទំហំប្រមាណជា ទទឹងប្រហែល ២ (ពីរ) ម៉ែត្រ បណ្តោយប្រហែល៤ (បួន) ម៉ែត្រ ស្ថិតនៅខាងក្រៅបរិវេណវត្តអង្គុណ។[883] សាក្សីអះអាងថា ធ្លាប់ប្រទះឃើញរណ្តៅសពរួមជាច្រើនកន្លែងដែលប្រជាជនខ្មែរក្រោមត្រូវបានយកទៅសម្លាប់នៅវត្តអង្គុណ។[884]

២២៩. ប្រជាជនខ្មែរក្រោមដែលត្រូវបានគេប្រមូលមកដាក់នៅវត្តអង្គុណ ត្រូវបានគេចាប់យកទៅសម្លាប់ប្រមាណជា ២ (ពីរ) ឬ ៣(បី) នាក់ ក្នុង ១ (មួយ) សប្តាហ៍ នៅតាមទួលដំបូក និងគុម្ពោតព្រៃរបោះដែលនៅក្រៅបរិវេណវត្តអង្គុណ។[885]

## ៥. ទីតាំងសម្លាប់មនុស្សព្រៃភូមិស្លែង

២៣០. ភូមិស្លែងស្ថិតនៅក្នុងឃុំគោកព្រេច ស្រុកគិរីវង់ ខេត្តតាកែវ។[886] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានអះអាងថា ភូមិស្លែង មានវត្តមួយឈ្មោះថា វត្តស្លែង[88...]



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានអះអាងថា នៅក្បែរៗភូមិស្ពៃង មានភ្នំព្រៃ និងព្រៃគុម្ពោតច្រើន[888] ហើយជាកន្លែងសម្លាប់មនុស្សផងដែរ។[889] ប៉ុន្តែ សាក្សីម្នាក់បានអះអាងថា មិនមានព្រៃទេនៅក្នុងភូមិស្ពៃង មានតែវាលស្រែប៉ុណ្ណោះ។[890] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានបញ្ជាក់ថា នៅចុងឆ្នាំ ១៩៧៨ ភូមិស្ពៃងជាទីតាំងប្រជុំរបស់ពួកខ្មែរក្រហម។[891]

២៣១. សាក្សីឈ្មោះ ហុក ចន បាននិយាយថា នៅក្នុងឆ្នាំ ១៩៧៥ ភូមិស្ពៃងមានមន្ទីរឃុំឃាំងក្រោមដីនៅក្នុងវត្តស្ពៃង ប៉ុន្តែក្រោយមកនៅឆ្នាំ ១៩៧៦ មន្ទីរឃុំឃាំងនោះត្រូវបានគេប្តូរទៅកន្លែងផ្សេងវិញ។[892] ក៏ប៉ុន្តែអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតដែលធ្លាប់ត្រូវបានគេបញ្ជូនឱ្យទៅរស់នៅភូមិស្ពៃង បានអះអាងថា នៅភូមិស្ពៃងពុំបានឃើញមានវត្ត ឬ មន្ទីរឃុំឃាំងអ្វីទេ សូម្បីតែរោងបាយរួមក៏ពុំមានដែរ មានតែអគារសាលារៀនប៉ុណ្ណោះ។[893]

២៣២. សាក្សីដែលធ្លាប់ធ្វើដំណើរទៅភូមិស្ពៃងក្នុងអំឡុងពេល ១០ (ដប់) ថ្ងៃម្តង ដើម្បីចូលរួមប្រជុំបានអះអាងថា តាសុខ តារូ និងតាប៉ោះ អ្នកគ្រប់គ្រងនៅវត្តស្ពៃង។[894] តាប៉ោះ ជាមេភូមិស្ពៃង ហើយគាត់មានតួនាទីដើរមើលចុងអៅដាំស្ល មើលប្រជាជនធ្វើការ ដូចជាភ្ជួររាស់ដកស្ទូងនៅតាមវាលស្រែជាដើម។[895] ពួកគាត់ទាំងបីនាក់ជាអ្នកមើលការគ្រប់គ្រង់ ដើរប្រមូលមនុស្សមកប្រជុំ និងបែងចែកការងារឱ្យធ្វើ។[896] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតបានអះអាងថា សែម ឃុំ មកពីវៀតណាម ជាប្រធាន និងអ្នកទទួលខុសត្រូវនៅវត្តស្ពៃង។[897]

២៣៣. សាក្សីបានរៀបរាប់ថា នៅឆ្នាំ ១៩៧៨ ប្រជាជនកម្ពុជាក្រោម ត្រូវបានគេលួងលោមឱ្យមករស់នៅស្រុកខ្មែរ[898] ហើយឱ្យមករស់នៅក្នុងទីធ្លាវត្តស្ពៃង ចំណែកប្រជាជនមូលដ្ឋានរស់នៅក្នុងភូមិស្ពៃង។[899] បើតាមសាក្សីរូបនេះ ប្រជាជនដែលរស់នៅភូមិស្ពៃងគឺសុទ្ធតែខ្មែរកម្ពុជាក្រោមទាំងអស់ ក្រៅពីនោះមិនមាននរណាទេ នៅពេលដែលគាត់មកដល់នៅឆ្នាំ ១៩៧៨។[900] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ប្រជាជនខ្មែរកម្ពុជាក្រោមត្រូវបានពួកខ្មែរក្រហមបង្ខំឱ្យផ្លាស់ប្តូរទីកន្លែងស្នាក់នៅពីភូមិព្រៃលទៅភូមិស្ពៃង ដោយគេប្រាប់ថាខ្លាចខ្មាំងវៀតណាមចូលឈ្លានពាន។[901] អ្នកដាក់ពាក្យសុំតាំងខ្លួន...



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ដើមបណ្ដឹងរដ្ឋប្បវេណីពីរនាក់ក៏បានអះអាងថា ប្រជាជនខ្លះត្រូវបានគេផ្លាស់ពីវត្ត ឬទីតាំងផ្សេងៗ ទៅនៅក្នុងភូមិស្ដែងផងដែរ។[902] ការបំលាស់ទីនោះគឺធ្វើដំណើរដោយថ្មើរជើង[903] ដោយស្ងៀមស្ងាត់យឺតៗនិងមិនបានឈប់សម្រាកអ្វីទាំងអស់[904] ដោយចំណាយរយៈពេលរហូតដល់ ៣ (បី) ថ្ងៃក៏មាន។[905] សាក្សីផ្សេងទៀតបានអះអាងថា រូបគាត់រួមមានបងប្រុសម្នាក់ និងកូន ២ (ពីរ) នាក់ ក៏ត្រូវបានគេបញ្ជូនមកភូមិស្ដែងដែរ បន្ទាប់ពីបានរស់នៅក្នុងភូមិកំពែងបានប្រហែល ២ (ពីរ) ឬ ៣ (បី) ខែ។[906]

២៣៤. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់បានលើកឡើងថា គាត់រួមទាំងមនុស្សប្រហែលពី ២០ (ម្ភៃ) ទៅ ៣០ (សាមសិប) នាក់ផង ដែលនៅក្នុងកងជាមួយគ្នាត្រូវគេឲ្យទៅស្នាក់នៅក្នុងវត្តស្ដែង ពេលនោះកងចាស់ដែលនៅទីនោះត្រូវបានគេយកចេញទៅបាត់អស់ហើយ ដោយមិនដឹងពីមូលហេតុទេ គ្រាន់តែគេប្រាប់ថាត្រូវប្ដូរកន្លែង។[907] សាក្សីបានបញ្ជាក់ថា មានខ្មែរក្រោមរស់នៅក្នុងភូមិស្ដែងនៅចុងឆ្នាំ ១៩៧៧ ហើយបានបាត់ ខ្លួនម្ដងមួយៗ និងមិនដែលឃើញត្រឡប់មកវិញទេ។[908] ជាក់ស្ដែងមានសាក្សីម្នាក់ដែលត្រូវបានគេបញ្ជូនពីកំពែងមកភូមិស្ដែងបានអះអាងថា មានកូនរបស់គាត់ ២ (ពីរ) នាក់ និងបងប្រុសម្នាក់ បន្ទាប់ពីត្រូវបានមកភូមិស្ដែងបានប្រហែល ១ (មួយ) ខែ ត្រូវបានពួកខ្មែរបញ្ជូនទៅធ្វើការកន្លែងផ្សេង ហើយក៏បាត់ខ្លួនរហូត។[909]

២៣៥. ក្នុងឆ្នាំ ១៩៧៨ ពេលប្រជុំនៅវត្តស្ដែង ពួកខ្មែរក្រហមបាននិយាយពេលប្រជុំផ្សព្វផ្សាយដល់ប្រជាជនពីហេតុការណ៍ដែលខ្មែរក្រោមខ្លះបានរត់ទៅវៀតណាម ហើយពួកខ្មែរក្រហមបានចោទពួកខ្មែរក្រោមទាំងនោះថាគឺជា “**ក្បាលយួនខ្លួនខ្មែរ**” និងត្រូវតែសម្លាប់ចោល ដើម្បីកុំឲ្យពួកគេបានរត់ទៅវៀតណាមទៀត។[910] សាក្សីម្នាក់ឈ្មោះ សាន់ តូច បានអះអាងថា បានឃើញពួកខ្មែរក្រហមដឹកប្រជាជនខ្មែរក្រោមជាច្រើនរទេះសេះ ចេញពីភូមិផ្សេងៗដូចជាភូមិអង្គខ្នុរ ភូមិកំពែង ភូមិអង្គុណា ភូមិគោកព្រិច និងភូមិស្ដែង នៅក្នុងឃុំកំពែងយកទៅសម្លាប់ក្នុងព្រៃក្នុងភូមិស្ដែង នៅពេលដែលគាត់កំពង់សាងសង់ស្ពាន។[911]

២៣៦. ប្រសិនបើមាននរណាធ្វើខុស ពួកខ្មែរក្រហមនឹងយកមនុស្សទៅសម្លាប់ចោលនៅក្នុងរណ្ដៅដែលមានស្រាប់នៅក្នុងភូមិស្ដែង។[912] ពួកខ្មែរក្រោមត្រូវបានគេយកទៅសម្លាប់ ហើយ... នៅទីកន្លែងសម្លាប់នានាក្នុងស្រុកគិរីវង់ រួមមានព្រៃភូមិស្ដែង។[913] តាមចម្លើយសាក្សី...

លើកឡើងថា មានខ្មែរក្រោម ៣ (បី) នាក់ជាអ្នកឃ្វាលគោត្រូវបានពួកខ្មែរក្រហមចាប់យកទៅដាក់នៅវត្តស្ពែងដោយសារពួកគេលួចចាប់គោដើម្បីកាប់យកសាច់ហូប។[914]

២៣៧. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានអះអាងថា ធ្លាប់បានឃើញការស្លាប់មនុស្សនៅវត្តស្ពែង និងអ្នកខ្លះទៀតស្លាប់ដោយសារការបង្អត់បាយ។[915] ក៏ប៉ុន្តែ មានសាក្សី អះអាងថា នៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ មិនបានឃើញការកាប់សម្លាប់នៅភូមិស្ពែងទេ តែឃើញមានសាកសព។[916] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ក៏បានថ្លែងស្រដៀងគ្នានេះផងដែរ។[917]

២៣៨. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះបានបន្ថែមទៀតថា បានឃើញមានគំនរឆ្អឹងខ្មោចជាច្រើននៅក្រោយវត្តស្ពែង។[918] មានលលាដ៍ក្បាលមនុស្សនៅពេញត្រពាំងនៅខាងលិចក្បែរវត្តស្ពែង។[919] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតបានថ្លែងពីការប្រទះឃើញលលាដ៍ក្បាលដែលនៅស្រស់ៗ និងខ្លះទៀតស្ងួត" ខណៈគាត់ដើររកគោ។[920]

## ៦. ទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមុនី

២៣៩. វត្តអង្គសិរីមុនី ឬ វត្តសំភ្លី ឬ វត្តថ្មី[921] មានទីតាំងស្ថិតនៅក្នុងភូមិសំភ្លី ឃុំព្រៃខ្ពា ស្រុកកោះអណ្តែត (ស្រុក ១០៨) ក្នុងតំបន់ ១៣ នៃភូមិភាគនិរតី។[922] វត្តអង្គសិរីមុនីនេះស្ថិតនៅខាងស្តាំដៃនៃផ្លូវលំទៅកាន់ទិសខាងជើង ចេញពីភូមិសំភ្លី ឃុំព្រៃខ្ពា ឆ្ពោះទៅកាន់ភូមិស៊ីស្លា ឃុំផ្កាប្រជុំ។[923] ក្នុងសម័យខ្មែរក្រហម នៅក្នុងបរិវេណវត្តអង្គសិរីមុនីមានតែព្រះវិហារ និងអគារសាលារៀនធ្វើពីឈើ ហើយមិនមានរបងព័ន្ធជុំវិញវត្តនេះទេ។[924] សាក្សីបានបញ្ជាក់ថាអគារទាំងពីរនេះគឺសម្រាប់ឃុំឃាំងមនុស្ស។[925] ប្រហែលជាក្នុងឆ្នាំ ១៩៧៦ នៅបរិវេណវត្តអង្គសិរីមុនី មានកន្លែងឃុំឃាំងអ្នកទោសនៅជិតទីតាំងរបស់ពួកយោធាខ្មែរក្រហម ដែលមន្ទីរឃុំឃាំងនោះមានទំហំបណ្តោយ ៩ (ប្រាំបួន) ម៉ែត្រ ទទឹង ៧ (ប្រាំពីរ) ម៉ែត្រ។[926]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D' INSTRUCTION

២៤០. រីឯ ទីតាំងសម្លាប់មនុស្សព្រៃសុខុនស្ថិតនៅខាងជើងវត្តអង្គសិរីមុនី នៅចន្លោះភូមិសំភ្លី និងភូមិស៊ីស្លា ដែលមានចម្ងាយពីភូមិទាំងពីរប្រហែល ២,៥ (ពីរក្បៀសប្រាំ) គីឡូម៉ែត្រ។[927] នៅក្នុងរបបខ្មែរក្រហមប្រជាជនត្រូវបានគេហាមមិនឱ្យចូលទៅក្នុងព្រៃសុខុនទេ។[928]

២៤១. វត្តអង្គសិរីមុនី និងទីតាំងសម្លាប់មនុស្សព្រៃសុខុនបានចាប់ផ្តើមដំណើរការតាំងពីថ្ងៃ ១៧ ខែមេសា ឆ្នាំ១ ៩៧៥ រហូតដល់ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ ពេលដែលវៀតណាមចូលមកដល់ទីនោះ។[929] វត្តអង្គសិរីមុនីត្រូវបានប្រើប្រាស់ជាកន្លែងសម្រាប់ឃុំឃាំងមនុស្ស។[930] ចំណែកព្រៃសុខុនជាកន្លែងដែលគេបញ្ជូនមនុស្សទៅសម្លាប់ចោល។[931] សាក្សីមួយចំនួនបានអះអាងថា ព្រៃសុខុនគឺជាទីតាំងសម្លាប់ដ៏ធំមួយ និងមានរណ្តៅធំៗជាច្រើនសម្រាប់កប់មនុស្ស។[932]

២៤២. ចាប់តាំងពីឆ្នាំ ១៩៧៥ រហូតដល់ការរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ វត្តអង្គសិរីមុនីបានដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់យោធាស្រុកកោះអណ្តែត។[933] យោធាស្រុកបានយកទីតាំងវត្តនេះធ្វើជាទីតាំងមូលដ្ឋានរបស់អង្គភាពខ្លួន។[934]

២៤៣. សាក្សីឈ្មោះ វង ណុប ដែលបានរស់នៅភូមិសំភ្លីពេញមួយរបបកម្ពុជាប្រជាធិបតេយ្យបានអះអាងថា ឈ្មោះ ម៉ោង ប្រធានសន្តិបាល ជាអ្នកសម្រេចបញ្ជូនមនុស្សចេញពីអគារសាលារៀនស្ថិតនៅក្នុងបរិវេណវត្តយកទៅកន្លែងសម្លាប់។[935] សាក្សីដដែលនេះក៏បានលើកឡើងថាឈ្មោះ ម៉ោង មានតួនាទីជាប្រធាននគរបាលតំបន់ ១០៨។[936]

២៤៤. អង្គភាពយោធាស្រុកកោះអណ្តែត មានមេបញ្ជាការយោធាស្រុកឈ្មោះ សឿន ជាអ្នកគ្រប់គ្រងទីតាំងមូលដ្ឋានរបស់យោធានៅក្នុងវត្តអង្គសិរីមុនី[937] ប៉ុន្តែមានភ័ស្តុតាងបង្ហាញថាឈ្មោះ តាអ៊ូច ហៅ សាន[938] បានធ្វើជាគណៈស្រុកកោះអណ្តែតទី១ បានរយៈពេល ២ (ពីរ)ឆ្នាំ ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។[939] ក្រោយមក ឈ្មោះ សឿន ហៅ ឪអាឈ្លូស[940] ឡើងធ្វើជាគណៈស្រុកជំនួសរហូតពេលដែលវៀតណាមចូលមកដល់ក្នុងខែវិច្ឆិកាឆ្នាំ១៩៧៨។[941] សាក្សីបានបន្ថែមថា គណៈស្រុកដែលឡើងថ្មីត្រូវបានខ្មែរក្រហមប្រកាសប្រាប់ឱ្យប្រជាជនដឹងតាមរយៈប្រធានភូមិ និងឃុំ។[942] ប៉ុន្តែសាក្សីផ្សេងទៀតដែលត្រូវបានគេជម្លៀសមកនៅទួលគោកស្រុកជិតភូមិស៊ីស្លាបានលើកឡើងថា មិនដែលមានកម្មាភិបាលខ្មែរក្រហមមកដើម្បីប្រជុំនិយាយ ឬ ប្រកាសអ្វីទេ គឺមានតែយោធាខ្មែរក្រហមប៉ុណ្ណោះ។[943]



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

២៤៥. មានការអះអាងផ្សេងពីនេះរបស់សាក្សីផ្សេងទៀតថា អ្នកគ្រប់គ្រងយោធាស្រុកគឺ អ៊ឹម ចែម[944] រីឯ ឈ្មោះ សឿន ជាប្រធានកងពល ដែលក្ដាប់លើ អ៊ឹម ចែម។[945] សាក្សីបាន បន្ថែមថា អ៊ឹម ចែម ធ្វើជាអ្នកគ្រប់គ្រងយោធាស្រុកកោះអណ្ដែតតាំងពីឆ្នាំ ១៩៧២ ឬ ឆ្នាំ ១៩៧៣។[946] សាក្សីផ្សេងទៀតបានអះអាងថា ឈ្មោះ សុវណ្ណ ជាប្រធានកងចល័តផង ប្រធានយុវជនផង គ្រប់គ្រងស្រុកកោះអណ្ដែតទាំងមូល។[947] ប៉ុន្តែសាក្សីផ្សេងទៀតលើក ឡើងថា តាម៉ុន ជាប្រធានកងទ័ពដែលគ្រប់គ្រងលើប្រជាជន ១៧ មេសា។[948]

២៤៦. ប្រជាជនត្រូវបានគេជម្លៀសពីភ្នំពេញមកភូមិស៊ីស្លាប្រើរយៈពេលប្រហែល ៥ (ប្រាំ) ថ្ងៃ[949] ដោយធ្វើដំណើរថ្មើរជើង។[950] មានភ័ស្តុតាងបញ្ជាក់ថា ការជម្លៀសប្រជាជនទៅកាន់ភូមិស៊ី ស្លា និងភូមិសំភ្លី ត្រូវបានប្រមូលមកពីកន្លែងផ្សេងៗគ្នានៃស្រុកកោះអណ្ដែតដូចជា ខ្មែរ ក្រោមត្រូវបានផ្លាស់មកពីភូមិត្រពាំងកក់ក្នុងឃុំផ្កាប្រជុំ មករស់នៅក្នុងភូមិស៊ីស្លា ក្នុងខណៈ ពេលដែលប្រជាជនភូមិស៊ីស្លាផ្លាស់ទៅនៅភូមិត្រពាំងកក់វិញ។[951]

២៤៧. សាក្សីបានបញ្ជាក់ថា ប្រជាជនដែលត្រូវបានជម្លៀស ពេលមកដល់ត្រូវបានទាហានខ្មែរ ក្រហមឱ្យសង់រោងស្នាក់នៅដោយខ្លួនឯង ហើយបែងចែកជាក្រុមដែលក្នុងមួយក្រុមមាន ១៥ (ដប់ប្រាំ) គ្រួសារ។[952] ពួកគាត់ត្រូវបានគេប្រគល់ភារកិច្ចដោយ អ្នកដែលពេញកម្លាំង ឱ្យលើកភ្លឺស្រែ ហើយអ្នកដែលមានកូនតូចៗទៅកាប់ដីដំបូក រំលាយភ្លឺស្រែនៅជិតភូមិ។ ចំណែកឯចាស់ៗគេឱ្យដើរកាប់ចិញ្ច្រាំទន្ត្រានខេត្តធ្វើជី កូនតូចៗគឺមានអ្នកនៅមើល។[953] នៅ ពេលនោះប្រជាជនត្រូវបានប្រាប់ឱ្យប្រឹងប្រែងធ្វើការប្រឆាំងជាមួយនឹងនាយទុនសក្តិភូមិ ប្ដេជ្ញាធ្វើស្រែឱ្យបានមួយហិកតាពីបីទៅប្រាំតោន។[954]

២៤៨. ប្រជាជនត្រូវបានគេឱ្យធ្វើការមិនមានសម្រាកនោះទេ ធ្វើការទាំងយប់ទាំងថ្ងៃ គឺចាប់ពីម៉ោង ៤ (បួន) ព្រឹករហូតដល់ម៉ោង ៧ (ប្រាំពីរ) យប់ ដោយឱ្យសម្រាកនៅម៉ោង ១២ (ដប់ពីរ) ថ្ងៃត្រង់ ១ (មួយ) ម៉ោង និងម៉ោង ៥ (ប្រាំ) ល្ងាច ១ (មួយ) ម៉ោង។[955] ចំពោះរបប អាហារ មនុស្សម្នាក់ត្រូវបានគេអនុញ្ញាតឱ្យតែកន្លះកំប៉ុងបាយក្នុង ១ (មួយ) ថ្ងៃ ឬ បបរ ១ (មួយ) កំប៉ុងក្នុង ១ (មួយ) ថ្ងៃ។[956]

សហចៅក្រមស៊ើបអង្កេត
ECCC * CETC
CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

២៤៩. ប្រជាជនដែលជម្លៀសមកពីទីក្រុងភ្នំពេញ និងខេត្តតាកែវត្រូវបានគេយកទៅដាក់នៅក្នុងបរិវេណវត្តអង្គសិរីមុនី យ៉ាងហោចណាស់ក៏មានប្រជាជនចំនួន ១.០០០ (មួយពាន់) គ្រួសារ ដែលមួយគ្រួសារមានសមាជិកជាមធ្យមចាប់ពី ៤ (បួន) នាក់ត្រូវបានគេឃុំឃាំងនៅក្នុងសាលារៀនមួយ និងមន្ទីរឃុំឃាំងមួយស្ថិតនៅក្នុងបរិវេណវត្តអង្គសិរីមុនី។[957] មានប្រជាជនរាប់រយគ្រួសារជម្លៀសមកពីខេត្តតាកែវ និងពីភ្នំពេញ[958] មានចម្រុះពូជសាសន៍ដូចជា សាសន៍ខ្មែរ ខ្មែរកាត់ចិន និងខ្មែរកម្ពុជាក្រោម ដែលប្រជាជនទាំងនោះជាប្រជាជនធម្មតា ជាអ្នករកស៊ី អ្នកធ្វើការក្នុងរដ្ឋការ និងទាហាន លន់ នល់។[959]

២៥០. សាក្សីបានលើកឡើងថា មានខ្មែរក្រោមប្រហែល ៤០០ (បួនរយ) គ្រួសារមកពីភ្នំពេញ និងតាកែវ ដែលក្នុងមួយគ្រួសារមានសមាជិកពី ៣ (បី) ទៅ ៦ (ប្រាំមួយ) នាក់[960] និងមានប្រជាជនប្រហែល ៤០០ (បួនរយ) គ្រួសារផ្សេងទៀតក្រៅពីខ្មែរក្រោម ត្រូវបានបញ្ជូនមកដាក់នៅវត្តអង្គសិរីមុនី។[961] សាក្សីផ្សេងទៀតក៏អះអាងដែរថា ប្រជាជនជាច្រើនដែលមកពីភូមិផ្សេងៗក្នុងស្រុកកោះអណ្តែតត្រូវបានគេឃុំឃាំងនៅក្នុងវត្តអង្គសិរីមុនីដែរ។[962] ប៉ុន្តែភស្តុតាងផ្សេងទៀតបានបង្ហាញថា ខ្មែរក្រោមមានចំនួនពី ១០ (ដប់) ទៅ ២០ (ម្ភៃ) គ្រួសារត្រូវបានខ្មែរក្រហមយកមកឃុំឃាំងជាបណ្តោះអាសន្ននៅក្នុងវត្តអង្គសិរីមុនី។[963]

២៥១. សាក្សីម្នាក់បានរៀបរាប់ថា ប្រជាជនដែលត្រូវបានគេយកមកឃុំឃាំងនៅវត្តអង្គសិរីមុនីមិនត្រូវបានដាក់ខ្នោះនោះទេ ប៉ុន្តែគេមិនអនុញ្ញាតឱ្យចេញដើររហេតរហូតទេ។[964] សាក្សីបានបន្ថែមថា ការឃុំឃាំង និងស្ថានភាពជាប់ឃុំឃាំងរបស់ប្រជាជននៅក្នុងវត្តអង្គសិរីមុនីគឺអាស្រ័យលើប្រធានសន្តិសុខឈ្មោះ ម៉ោង ជាអ្នកសម្រេច។[965]

២៥២. សាក្សីជាច្រើនបានអះអាងថា ខ្មែរក្រោម និងប្រជាជន ១៧ មេសា មកពីខេត្តតាកែវ និងភ្នំពេញ ដែលជាប់ឃុំឃាំងនៅវត្តអង្គសិរីមុនី ត្រូវបានគេយកទៅសម្លាប់នៅព្រៃសុខុន ដោយចោទប្រកាន់ថាជាខ្មាំង។[966] ចំពោះគ្រួសារខ្មែរក្រោមទាំងអស់ដែលត្រូវបានឃុំឃាំងនៅវត្តអង្គសិរីមុនី ត្រូវបានយកទៅសម្លាប់នៅព្រៃសុខុនជាក្រុមៗរហូតដល់អស់[967] ក្រោយពីមកដល់បានរយៈពេល ១០ (ដប់) ថ្ងៃ ឬ តិចជាងនេះ។[968] ប្រជាជនជម្លៀសដទៃទៀត ត្រូវបានគេបញ្ជូនឱ្យទៅរស់នៅតាមភូមិផ្សេងៗ ឬក៏ត្រូវបានចោទប្រកាន់ថាជាខ្មាំង និងស[illegible]ចោលដូចខ្មែរក្រោមដែរ។[969] សាក្សី វង ណុប អះអាងថា បានឃើញពួកយោ[illegible]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ទោសយ៉ាងហោចណាស់ ១០ (ដប់) នាក់ ជារៀងរាល់ថ្ងៃ កាត់តាមមុខផ្ទះរបស់ខ្លួនឆ្ពោះទៅព្រៃសុខុនក្នុងអំឡុងពេល ២ (ពីរ) ទៅ ៣ (បី) ខែ ចាប់ពីខែ ឧសភា ឬ ខែ មិថុនា ឆ្នាំ ១៩៧៥។[970] អ្នកទោសជាច្រើននាក់ដែលគេបណ្តើរសំដៅទៅព្រៃសុខុននោះ មិនដែលឃើញត្រឡប់មកវិញទេ។[971] មានសាក្សីម្នាក់បានបញ្ជាក់ថា ប្រហែលជា ៤ (បួន) ខែមុនពេលដែលវៀតណាមចូលមកដល់ គាត់បានឃើញគេសម្លាប់មនុស្សជាច្រើនសុទ្ធតែមនុស្សប្រុស ដោយប្រើដើមសង្កែ និងស្តៅសម្រាប់វាយ រួចទម្លាក់ចូលក្នុងអន្លង់នៅព្រៃសុខុន។[972]

២៥៣. សាក្សី ៣ (បី) នាក់ បានឃើញរណ្តៅសាកសពនៅព្រៃសុខុន ក្រោយរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ។[973] សាក្សីបានបញ្ជាក់ដោយបានប៉ាន់ស្មានថាមានប្រជាជនប្រហែល ៤.០០០ (បួនពាន់) នាក់ ត្រូវបានគេសម្លាប់នៅព្រៃសុខុន។[974] ខណៈសាក្សីម្នាក់ទៀតបានអះអាងថា ប្រជាជនប្រហែល ១.០០០ (មួយពាន់) គ្រួសារដែលរស់នៅទួលគោកស្រុក និងទួលភូមិ នៅសល់តែ ៣០០ (បីរយ) គ្រួសារ ប៉ុណ្ណោះនៅពេលដែលកងទ័ពវៀតណាមមកដល់នៅចុងឆ្នាំ ១៩៧៨។[975]

## ៧. មន្ទីរសន្តិសុខវត្តគាស់ក្រឡ

២៥៤. មន្ទីរសន្តិសុខគាស់ក្រឡ ស្ថិតនៅក្នុងភូមិគាស់ក្រឡ ឃុំគាស់ក្រឡ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ក្នុងតំបន់ ១ ភូមិភាគពាយ័ព្យ។[976] មន្ទីរសន្តិសុខនេះ ស្ថិតនៅក្នុងបរិវេណវត្តគាស់ក្រឡ[977] ហើយរួមមានរោងបាយ ដែលត្រូវបានគេយកទៅធ្វើជាឃ្លាំងស្រូវ និងជាមន្ទីរឃុំឃាំង[978] កន្លែងស្នាក់នៅរបស់កម្មាភិបាលខ្មែរក្រហម កន្លែងសម្រាប់សិក្សា និងអគារសម្រាប់ឃុំឃាំងចំនួនពីរ។[979] នៅមន្ទីរសន្តិសុខគាស់ក្រឡ មានសាលាឆាន់មួយដែលគេយកធ្វើជារោងម៉ាស៊ីនកិនស្រូវ សាលាបាលីត្រូវបានប្រើប្រាស់ជាកន្លែងសម្រាប់ឃុំឃាំងអ្នកទោស និងផ្ទះរបស់យោធាខ្មែរក្រហម។[980]

២៥៥. នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ វត្តគាស់ក្រឡត្រូវបានអតីតកងទ័ព លន់ នល់ ប្រើប្រាស់ធ្វើជាទីតាំងមូលដ្ឋានរបស់ខ្លួន[981] ហើយទីតាំងនេះត្រូវបានឡោមព័ទ្ធដោយខ្មែរក្រហមនាអំឡុងពេលប្រយុទ្ធគ្នា។[982] វត្តគាស់ក្រឡត្រូវបានប្រើប្រាស់ជាមន្ទីរសន្តិសុខនៅពេលដែលពួកនិរតីបានមកដល់។[983] មន្ទីរនេះត្រូវបានដំណើរការដោយកម្មាភិបាលនិរតីម្នាក់ឈ្មោះ



ការិយាល័យសហចៅក្រមស៊ើបអង្កេត E.C.C.C *C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION*

១៩៧៨ នៅមុនពេលដែលកងទ័ពវៀតណាមចូលមកដល់។[984] សាក្សីជាច្រើននាក់បានបំភ្លឺថាមន្ទីរសន្តិសុខនេះកើតឡើងនៅពេលនិរតីមកដល់[985] គឺប្រហែលពី ៤ (បួន) ទៅ ៦ (ប្រាំមួយ) ខែ មុនវៀតណាមរំដោះ។[986] សាក្សីម្នាក់ទៀតបានអះអាងថា មន្ទីរសន្តិសុខគាស់ក្រឡនេះ ត្រូវបានគេប្រើដល់ចុងឆ្នាំ ១៩៧៨។[987] សាក្សីម្នាក់ទៀតដែលត្រូវបានគេចាប់ខ្លួនទៅដាក់នៅវត្តគាស់ក្រឡ ឈ្មោះ ប៊ុ ពឿត បានអះអាងថាមន្ទីរសន្តិសុខគាស់ក្រឡត្រូវបានរំលាយនៅចុងបញ្ចប់នៃរបបខ្មែរក្រហមដែរ។[988]

២៥៦. មន្ទីរសន្តិសុខគាស់ក្រឡជាមន្ទីរសន្តិសុខគ្រប់គ្រងដោយថ្នាក់ស្រុក។[989] សាក្សីដែលជាអតីតយោធាខ្មែរក្រហមនៅស្រុកគាស់ក្រឡឈ្មោះ សៅ ជាប់ បានបំភ្លឺថាមន្ទីរសន្តិសុខគាស់ក្រឡស្ថិតក្រោមការទទួលខុសត្រូវរបស់ឈ្មោះ ភេន ដែលត្រូវបានចាត់តាំងដោយខាងទ័ព ហើយស្ថិតក្រោមការបញ្ជារបស់ស្រុក។[990] សាក្សីឈ្មោះ ឆន ឡូញ ធ្លាប់ឮគេនិយាយថា តាយ៉ានជាប្រធានសហករណ៍គាស់ក្រឡបានប្រហែលជា ០១ ឆ្នាំ មុននឹងត្រូវបានគេចាប់យកទៅសម្លាប់ចោលក្នុងអំឡុងឆ្នាំ ១៩៧៦ ឬ ១៩៧៧។[991] សាក្សីឈ្មោះ សៅ ជាប់ បានបញ្ជាក់ថា តាយឹន ជាអ្នកទទួលខុសត្រូវសហករណ៍នៅស្រុកគាស់ក្រឡ រហូតដល់ឆ្នាំ ១៩៧៨[992] បន្ទាប់មក តាគីម ដែលជាកម្មាភិបាលនិរតី បានក្លាយជាប្រធានសហករណ៍ភូមិគាស់ក្រឡជំនួសតាយឹន។[993] ឈ្មោះ គីម និង ប៉ោង ជាអ្នកបញ្ជាឲ្យពួកយោធាចាប់មនុស្សទៅដាក់នៅវត្តគាស់ក្រឡ។[994]

២៥៧. សាក្សីឈ្មោះ សៅ ជាប់ បានបំភ្លឺថាមន្ទីរសន្តិសុខគាស់ក្រឡត្រូវបានបង្កើតឡើងសម្រាប់ដាក់កម្មាភិបាលពាយ័ព្យដែលប្រព្រឹត្តកំហុស។[995] សាក្សីម្នាក់ទៀតបានអះអាងថា សម្រាប់អ្នកទោសធ្ងន់ គេដាក់អ្នកទោសនោះទៅដាក់នៅមន្ទីរសន្តិសុខវត្តគាស់ក្រឡ។[996] អ្នកទោសត្រូវបានចាប់ខ្លួន ដោយសារត្រូវបានគេចោទថា "ជាអ្នកក្បត់ ដែលមានក្បាលយួនខ្លួនខ្មែរ"[997] ជាអតីតទាហាន លន់ នល់ ឬជាគ្រូបង្រៀន និងគ្រួសាររបស់ពួកគេ[998] ព្រមទាំងអតីតកម្មាភិបាលពាយ័ព្យ អ្នកដែលជាប់ពាក់ព័ន្ធ និងសាច់ញាតិ ជាអាទិ៍។[999] សាក្សីម្នាក់ទៀតឈ្មោះ ប៊ុ ពឿត បានអះអាងថា ឪពុករបស់គាត់ត្រូវបានគេចាប់ខ្លួនទៅដាក់នៅមន្ទីរសន្តិសុខគាស់ក្រឡ បន្ទាប់ពីគេបានប្រកាសថា "គេធ្វើការចម្រាញ់យកតែគ្រាប់ស្រូវគ្រាប់អង្ករដែលល្អៗ ហើយដកគ្រាប់អាក្រក់ចេញ"។[1000]



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

២៥៨. ជាក់ស្តែងមានកម្មាភិបាលពាយ័ព្យដូចជា តា យ៉ាន ដែលជាប្រធានសហករណ៍គាស់ក្រឡ ត្រូវបានគេចាប់ប្រហែលជាក្នុងឆ្នាំ ១៩៧៦ ឬ ឆ្នាំ ១៩៧៧[1001] បន្ទាប់ពីកម្មាភិបាលនិរតីបានមកដល់។[1002] សាក្សីឈ្មោះ ទុំ ភើយ បានឃើញកម្មាភិបាលនិរតីចាប់ និងបានដឹកគ្រួសារប្រធានរោងបាយភូមិពន្លៃដែលជាកម្មាភិបាលពាយ័ព្យ និងចាប់ចងមនុស្សមួយចំនួនផ្សេងទៀតជាជួរៗ យកទៅដាក់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខវត្តគាស់ក្រឡ។[1003] សាក្សីដទៃទៀតបានអះអាងស្របគ្នាថា ធ្លាប់ឃើញគេចាប់ចងពួកកម្មាភិបាលពាយ័ព្យហើយបណ្តើរទៅទាំងខ្សែៗ[1004] និងមានមនុស្ស ១ (មួយ) ខ្សែមានគ្នាប្រហែល ១០ (ដប់) នាក់ ត្រូវឈ្លបក្នុងកាំភ្លើងបណ្តើរទៅវត្តគាស់ក្រឡ។[1005]

២៥៩. ប្រជាជនដែលត្រូវបានចាប់ខ្លួន ភាគច្រើនត្រូវបានដឹកតាមរទេះយកទៅឃុំឃាំងនៅមន្ទីរសន្តិសុខវត្តគាស់ក្រឡ។[1006] សាក្សីម្នាក់ធ្លាប់ធ្វើការនៅកងចល័តបានរៀបរាប់ថា នៅមុនពេលវៀតណាមមកដល់បន្តិច បានឃើញប្តីប្រពន្ធដែលនិយាយប៉ៃឡាំសម្បុរសទំនងជាវៀតណាមត្រូវបានគេដឹកតាមរទេះយកទៅដាក់នៅមន្ទីរសន្តិសុខវត្តគាស់ក្រឡ។[1007] សាក្សីម្នាក់ដែលជាធ្លាប់ធ្វើជាអ្នកបររទេះបានអះអាងថា ប្រហែលខែ មិថុនា ឬ ខែ កក្កដា ឆ្នាំ ១៩៧៨ គាត់ត្រូវបានកម្មាភិបាលនិរតីចាត់ឱ្យដឹកមនុស្សបួននាក់ ដែលក្នុងនោះរួមមានយាយ សឿម និងកូន ២ (ពីរ) នាក់ និងលើកក្រោយមកទៀតចាត់ឱ្យដឹក អ៊ំ យ៉ាត យកទៅវត្តគាស់ក្រឡ ប៉ុន្តែនៅពេលទៅដល់វត្តដូនបា ត្រូវបានយោធាឃាត់ឱ្យឈប់ ហើយពួកគេបានឡើងបររទេះគោដឹកបន្តវិញ។[1008] សាក្សីម្នាក់ទៀតឈ្មោះ ទុំ ភើយ បំភ្លឺថា នៅចុងឆ្នាំ ១៩៧៨ អនុភូមិឈ្មោះ អំ បានបញ្ជាឱ្យគាត់យករទេះទៅដឹកគ្រួសាររបស់ តា ហួល និងគ្រួសាររបស់ តាហ៊ី សរុបប្រហែលចំនួន ១២ (ដប់ពីរ) នាក់យកទៅដាក់នៅវត្តគាស់ក្រឡដែរ។[1009]

២៦០. សាក្សី ប៊ី ពឿត ដែលធ្លាប់ជាប់ឃុំនៅមន្ទីរសន្តិសុខគាស់ក្រឡប៉ាន់ស្មានថាយ៉ាងហោចណាស់មានអ្នកទោស ២០០ (ពីររយ) ទៅ ៣០០ (បីរយ) នាក់ ត្រូវបានឃុំឃាំងក្នុងមន្ទីរសន្តិសុខ។[1010] នៅពេលគេសម្លាប់អ្នកទោសម្តងៗ ពួកអ្នកទោសត្រូវបានយោធាចងជាខ្សែៗដោយមួយខ្សែៗមានអ្នកទោស ១០ (ដប់) នាក់ បណ្តើរយកចេញទៅសម្លាប់។[1011] ពួកយោធាជាអ្នកចូលមកយកអ្នកទោសពីអគារឃុំឃាំងនៃមន្ទីរសន្តិសុខគាស់ក្រឡចេញទៅក្រៅ ហើយត្រឡប់មកវិញដោយមានបាតដៃប្រលាក់ឈាម។[1012] មនុស្សដែលគេ...



E.C.C.C * C.E.T.C * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

មន្ទីរសន្តិសុខគាស់ក្រឡ មិនមានវាសនារួចខ្លួនមកវិញទេ ដោយពួកយោធាខ្មែរក្រហមធ្វើការចាប់ខ្លួនទាំងគ្រួសាររួមទាំងកុមារផង ហើយពួកគេត្រូវបានគេសម្លាប់ចោល។[1013] សាក្សីនេះបន្ថែមថា អ្នកទោសដែលត្រូវបានគេនាំយកទៅសម្លាប់ ពីមន្ទីរសន្តិសុខគាស់ក្រឡប្រហែល ១០០ (មួយរយ) នាក់ ក្នុងនោះមានបងប្អូនសាច់ញាតិរបស់គាត់ប្រហែលជិតពាក់កណ្តាល[1014] ដោយពួកកម្មាភិបាលនិរតីចាត់ទុកគ្រួសាររបស់គាត់ជាពួកក្បត់។[1015]

២៦១. មានសាក្សីជាច្រើននាក់បានលើកឡើងថា នៅក្រោយបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ គេបានប្រទះ ឃើញមានសាកសពហើមរលួយ ឆ្អឹង និងខោអាវសាកសពទាំងនោះ នៅពេលដែលប្រជាជនជីកកាយរណ្តៅសាកសពដើម្បីរកមាស[1016] និងមានរណ្តៅសាកសពជាច្រើននៅក្នុងបរិវេណវត្តគាស់ក្រឡ។[1017] សាក្សីអះអាងថាមានរណ្តៅសាកសពប្រហែលជា ១០ (ដប់) រណ្តៅ ដែលរណ្តៅនីមួយៗមានកប់សាកសពប្រហែលជា ២០ (ម្ភៃ) ទៅ ៣០ (សាមសិប) នាក់។[1018] សាក្សីបានប៉ាន់ស្មានថា មានសាកសពរាប់រយនាក់ត្រូវបានរកឃើញនៅទីនោះ។[1019]

២៦២. ភ័ស្តុតាងក៏បង្ហាញថា មានរណ្តៅសពនៅក្រៅបរិវេណវត្ត។[1020] រណ្តៅនីមួយៗមានទទឹងប្រហែល ៥ (ប្រាំ) ម៉ែត្រ និង បណ្តោយប្រហែល ៦ (ប្រាំមួយ) ម៉ែត្រ[1021] ប៉ុន្តែសាក្សីផ្សេងទៀតបានអះអាងថា រណ្តៅនីមួយៗមានទទឹងប្រហែល ៣ (បី) ម៉ែត្រ និងបណ្តោយ ៤ (បួន) ម៉ែត្រ និងជម្រៅប្រហែល ១ (មួយ) ម៉ែត្រ។[1022] ក្នុងនោះមានរណ្តៅសាកសពជាច្រើនដូចជា រណ្តៅសាកសពតូចៗ រណ្តៅសាកសពរួមជាច្រើន និងរណ្តៅគ្រាប់បែកដែលគេប្រើសម្រាប់កប់សាកសពនៅបរិវេណខាងក្រៅវត្តគាស់ក្រឡ។[1023] នៅក្នុងរណ្តៅនោះមានឃើញឆ្អឹង និងលលាដ៍ក្បាលចម្រុះគ្នា មានទាំងមនុស្សចាស់ និងកូនក្មេង។[1024]

២៦៣. មិនមានសាក្សីណាបំភ្លឺថា មានវត្តមានរបាយការណ៍ ការបញ្ជា ឬថាមានស្គាល់ តាទិត្យ ឡើយ បើទោះបីក្រោយពេល ក.ស.ច.ស លើកសួរចំណោទះក៏ដោយ។[1025]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

## ៨. សហករណ៍ធិបតី (រួមមាន មន្ទីរសន្តិសុខវត្តធិបតី)

២៦៤. មន្ទីរសន្តិសុខមានទីតាំងនៅក្នុងវត្តធិបតីស្ថិតនៅលើកំពូលភ្នំ ក្នុងភូមិដំណាក់អន្ទែង ឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ស្ថិតក្នុងតំបន់ ១ នៃភូមិភាគពាយ័ព្យរបស់រដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ។[1026] មន្ទីរសន្តិសុខនេះ ត្រូវបានបង្កើតឡើងដោយកម្មាភិបាលពាយ័ព្យ[1027] ផ្ទុយទៅវិញ មន្ទីរឃុំឃាំងត្រូវបានបង្កើតនៅក្រោយការមកដល់របស់កម្មាភិបាលនិរតីនៅចុងឆ្នាំ ១៩៧៧ នៅវត្តភ្នំធិបតី[1028] និងមានដំណើរការរហូតដល់វៀតណាមចូលមកដល់។[1029] ក៏ប៉ុន្តែសាក្សីម្នាក់រស់នៅក្នុងព្រៃក្បែរភ្នំធិបតីជឿជាក់ថា ភ្នំធិបតីគឺជាភូមិមិនមែនជាមន្ទីរសន្តិសុខទេ។[1030] សាក្សីម្នាក់ទៀតធ្លាប់ស្នាក់នៅសាលាឆាន់នៅភ្នំធិបតី ប៉ុន្តែបែរជាមិនដឹងថា ភ្នំធិបតីជាមន្ទីរសន្តិសុខនោះទេ។[1031]

២៦៥. សហករណ៍ភ្នំធិបតីមានទំហំរាប់រយហិកតា[1032] ដោយមានព្រំប្រទល់ខាងកើតជាប់នឹងសហករណ៍ចកកកោះ ខាងត្បូងជាប់នឹងគាស់ក្រឡ ខាងជើងជាប់នឹងសហករណ៍គី ហើយខាងលិចនៅចំកន្លែងទួលម្ទេស។[1033] សហករណ៍ភ្នំធិបតីរួមមានស្រែនៅស្វាយស ជើងទិញ តាផុក ភ្នំធិបតី និងទួលម្ទេស។[1034] សហករណ៍ភ្នំធិបតី ស្ថិតក្រោមការគ្រប់គ្រងរបស់ស្រុកគាស់ក្រឡ។[1035]

២៦៦. សាក្សី ៣ (បី) នាក់បានបញ្ជាក់ថា កម្មាភិបាលនិរតីដំបូងធ្វើការជាមួយពាយ័ព្យដូចធម្មតាដោយមិនមានការប្រកាសផ្លាស់ប្តូរទេ តែក្រោយមកស្រាប់តែបាត់កម្មាភិបាលពាយ័ព្យ[1036] ហើយដាក់ជំនួសមកវិញដោយពួកនិរតី។[1037] សាក្សីម្នាក់រស់នៅឃុំធិបតី បានបំភ្លឺថាពួកនិរតីមកដល់ដើមឆ្នាំ ១៩៧៧។[1038]

២៦៧. នៅក្នុងឆ្នាំ ១៩៧៧ ប្រហែលក្នុងខែ កុម្ភៈ លេខ ភីវ ត្រូវបាន តាប៉ែត ចាត់តាំងជាប្រធានសហករណ៍ធិបតី[1039] ដែលនៅពេលនោះ យឹន ជាលេខាស្រុកគាស់ក្រឡ។[1040] ប៉ុន្តែបន្ទាប់ពីពួកនិរតីមកដល់ តាសុន បានឡើងមកជំនួស តាមបញ្ជារបស់ តាណោន និង តាផុន ដែលជាគណៈស្រុក។[1041] តាខ្លឹប តាឃឿន តាផន ជាគណៈឃុំ តាយ៉ាន់ ជាយោធាឃុំ តាឡុង ជាគណៈស្រុក តាប៉ក់ ប្រធានយោធាស្រុក ហើយតា វ៉ាញ លេខាតំបន់១។[1042]

២៦៨. ប្រធានសហករណ៍ធិបតីប្រហែលជាក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៧ បានអះអាងថា នៅខណៈនោះសហករណ៍នេះ មានប្រជាជនប្រហែលជាង ៣០.០០០ (បីម៉ឺន) នាក់ រួមមានអ្នកជម្លៀសមកពីភ្នំពេញ ចាម ចិន វៀតណាម និងប្រជាជនដទៃទៀត។[1043] សាក្សីបានបន្ថែមថា ប្រជាជនទទួលបានរបបអាហារ ៣ (បី) កំប៉ុងសម្រាប់ ១០ (ដប់) នាក់ ក្នុងមួយពេល។[1044] មានអាហារមិនគ្រប់គ្រាន់ចំពោះតែអ្នកភូមិទេ ចំណែកចំពោះអ្នកធ្វើការមានគ្រប់គ្រាន់។[1045]

២៦៩. សាក្សីដែលត្រូវបានគេបញ្ជូនទៅរស់នៅភ្នំធិបតីបានរៀបរាប់ថា ស្ថានភាពរស់នៅរបស់ប្រជាជននៅទីនោះ មានការលំបាក ហើយត្រូវបានបែងចែកការងារដូចជា ច្រូតស្រូវ ធ្វើស្រែ ដកស្ទូង និងលើកទំនប់ជាដើម គ្មានពេលសម្រាកឡើយ[1046] គ្មានអាហារគ្រប់គ្រាន់[1047] គ្មានថ្នាំព្យាបាល។[1048] សាក្សីបានអះអាងថា ស្ថានភាពបែបនេះបន្តរហូតដល់វៀតណាមមកដល់។[1049]

២៧០. ការបាត់ខ្លួនបានកើតឡើងជាធម្មតានៅសហករណ៍ធិបតីក្នុងរបបខ្មែរក្រហម។ ជាក់ស្តែងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានអះអាងថា ប្រហែលនៅពាក់កណ្តាលឆ្នាំ ១៩៧៨ នៅក្នុងរដូវភ្ជួរស្រែ ធ្លាប់ឃើញបុរសជំទង់ម្នាក់ដែលធ្វើការនៅក្នុងកងភ្ជួរ ត្រូវបានខ្មែរក្រហមហៅទៅភ្ជួរកន្លែងផ្សេង រួចក៏បាត់ខ្លួនរហូត។[1050] សាក្សីម្នាក់បានលើកឡើងថា ក្រោយពួកនិរតីមកដល់ មានស្ត្រី ៣ (បី) នាក់ត្រូវបានគេនាំយកទៅបោកស្រូវនៅក្នុងភូមិក្បែរភ្នំធិបតី ដោយមិនដែលឃើញស្ត្រីទាំង ៣ (បី) នាក់នោះត្រឡប់មកវិញទេ។ បើតាមការសន្និដ្ឋានរបស់សាក្សីនោះ ស្ត្រីទាំងអស់នោះត្រូវបានគេនាំយកទៅសម្លាប់បាត់អស់ហើយ។[1051]

២៧១. សាក្សីម្នាក់បានអះអាងថា នៅចុងឆ្នាំ ១៩៧៨ ខ្លួនគាត់ និងប្រជាជនប្រហែលពី ៣០ (សាមសិប) ទៅ ៤០ (សែសិប) នាក់ ត្រូវបានគេបញ្ជូនពីតំបន់ព្រៃលិចទឹកទៅធ្វើការនៅភ្នំធិបតី ដើម្បីធ្វើជីធម្មជាតិដោយយកលាមកមនុស្សលាយជាមួយដីដំបូក និងដើមទន្ទ្រានខែត្រ។[1052] សាក្សីបានបន្ថែមថា នៅពេលដែលគាត់ធ្វើជីធម្មជាតិនៅភ្នំធិបតី គាត់ត្រូវបានគេចាប់ដាក់ឃុំនៅភ្នំធិបតីដែលមានចម្ងាយពីរោងបាយប្រហែល ៣០ (សាមសិប) ទៅ ៤០ (សែសិប) ម៉ែត្រ។[1053] គាត់មិនបានដឹងថា មានមនុស្សប៉ុន្មាននាក់ដែលជាប់ឃុំនៅទីនោះទេ



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ដោយសារតែអ្នកជាប់ឃុំត្រូវបានគេដាក់ដោយឡែកៗពីគ្នា។[1054] សាក្សីត្រូវបានដោះលែងដោយឈ្មោះ យ៉ង់ ជាប្រធានកង ហើយឈ្មោះ យ៉ង់ បានប្រាប់ថាអ្នកជាប់ឃុំនៅទី នោះនឹងត្រូវបានគេយកទៅសម្លាប់ចោលទាំងអស់។[1055] សាក្សីផ្សេងទៀត បានអះអាងថា នៅចុងឆ្នាំ ១៩៧៨ គាត់ត្រូវបានពួកកងឈ្លបនិរតីចាប់យកទៅឃុំឃាំងនៅក្នុងវត្តភ្នំធិបតី ដោយចោទថាជាខ្មាំង។[1056]

២៧២. សាក្សីអតីតកងចល័តជិតវត្តធិបតី បំភ្លឺថាកម្មាភិបាលពាយ័ព្យឱ្យប្រជាជនធ្វើការធ្ងន់ហើយធ្វើបាបប្រជាជន[1057] ព្រមទាំងបានឃើញការចាប់ចងប្រជាជន និងយកថ្លើមមនុស្សញ្ជូរ។[1058] សាក្សីម្នាក់បានឃើញអ្នកទោសត្រូវច្រកថង់ផ្លាស្ទិករុំក្បាល ដាក់ខ្នោះជើង និងយកទៅបាត់ពេលយប់រហូតដល់ចំនួនថយចុះ។[1059] ចំណែកអ្នកទោសនៅសល់ត្រូវពួកពាយ័ព្យបញ្ចេញអស់ពីមន្ទីរនេះមុនពេលនិរតីទៅដល់។[1060] ជនរងគ្រោះត្រូវបានពួកពាយ័ព្យចាប់ដាក់ឃុំ ប៉ុន្តែ ១០ (ដប់) ថ្ងៃក្រោយមកនិរតីក៏ដោះលែងគាត់។[1061] សាក្សីបានបញ្ជាក់ទៀតថា មានអ្នកទោសទាំងប្រុស ទាំងស្រីប្រហែល ១០០ (មួយរយ) នាក់ ត្រូវបានគេឃុំនៅអគារឃុំឃាំងដែលមានទីតាំងស្ថិតនៅជើងភ្នំធិបតី។[1062]

២៧៣. អ្នកទោសនៅក្នុងមន្ទីរសន្តិសុខធិបតី ត្រូវបានបាត់ខ្លួន ឬ ត្រូវបានគេសម្លាប់ ជារឿយៗ។ ជាក់ស្តែងសាក្សីឈ្មោះ ឃិន ឃៀន បានអះអាងថា នៅចុងឆ្នាំ ១៩៧៨ អ្នកទោសនៅទីនោះដែលធ្លាក់ខ្លួនឈឺ ភាគច្រើនគឺស្លាប់[1063] ហើយមានតិចណាស់ដែលនៅរស់។ អ្នកទោសផ្សេងទៀតដែលត្រូវគេសម្លាប់ម្តង ២ (ពីរ) ទៅ ៣ (បី) នាក់ និង ត្រូវបានគេយកអ្នកថ្មីមកដាក់ជំនួសវិញមានចំនួនដូចគ្នា។[1064] សាក្សីបានបន្ថែមថា ខ្មែរក្រហមសម្លាប់អ្នកទោសទាំងនោះ ដោយវាយនឹងដំបងទៅលើអ្នកទោសទម្លាក់ទៅក្នុងរណ្តៅដែលជីករណ្តៅដោយពួកគេមានចម្ងាយប្រហែល ៥០០ (ប្រាំរយ) ម៉ែត្រ ពីឃ្លាំងនោះ។[1065] សាក្សីដែលបានកត់សម្គាល់ឃើញថា មានអ្នកទោសសរុបប្រហែល ១០០ (មួយរយ) នាក់ ត្រូវបានគេសម្លាប់ក្នុងរយៈពេល ៤ (បួន) ខែ។[1066]

២៧៤. សាក្សីម្នាក់ឈ្មោះ អ៊ុយ ចិន្តា បានអះអាងថា ជាទម្លាប់នៅក្នុងរបបខ្មែរ អ្នកដែលគេចាប់ខ្លួនយកទៅដាក់នៅមន្ទីរសន្តិសុខភ្នំធិបតី គឺត្រូវគេសម្លាប់ហើយ។មានសាកសពជាច្រើន ត្រូវបានគេកប់នៅក្នុងរណ្តៅធំ ១ (មួយ) នៅក្បែរភ្នំធិបតី។[1067] សាក្សីនេះបានបន្ថែមថា ម្នាក់



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ការសម្លាប់ច្រើនជាងមុនទៀត នៅពេលពួកនិរតីមកដល់។[1068] គាត់បានឃើញរណ្តៅកប់សាកសពនៅជាប់ជើងភ្នំក្រោយភូមិថ្មី ប៉ុន្តែមិនបានឃើញសាកសពដោយផ្ទាល់ភ្នែកទេ បានឃើញតែរណ្តៅនោះមានស្នាមដីកប់ថ្មី ហើយនិងមានក្លិនស្អុយពីសាកសពទាំងនោះ។[1069] សាក្សីដដែលបានបញ្ជាក់បន្ថែមថា អ្នកទោសទាំងអស់ត្រូវបានគេយកទៅសម្លាប់នៅក្រោយភូមិថ្មី ហើយអ្នកភូមិនៅម្តុំនោះដឹងរឿងនេះទាំងអស់គ្នា។[1070] សាក្សីបានលើកឡើងថា ប្រជាជនដែលនៅភូមិថ្មីនោះភាគច្រើនគឺជាកម្ពុជាក្រោម ហើយពួកខ្មែរក្រហមបានប្រព្រឹត្តចំពោះពួកកម្ពុជាក្រោមដូចគ្នានឹងប្រជាជនធម្មតាដែរ។[1071]

២៧៥. សាក្សីភាគច្រើន រាប់បញ្ចូលឈ្មោះ យាន ដែលបានធ្វើស្រែនៅកងចល័តជិតភ្នំធិបតី អះអាងថា ធ្លាប់ឮឈ្មោះតែមិនដឹងតួនាទីរបស់ **តាទិត្យ**។[1072] សាក្សីម្នាក់បំភ្លឺថា មិនដែលឃើញកម្មាភិបាលនិរតីណាមកទស្សនៈកិច្ចនៅកន្លែងគាត់ធ្វើការទេ។[1073]

## ៩. ការដ្ឋានទំនប់កង្ហត

២៧៦. ការដ្ឋានទំនប់កង្ហត ឬ កាហាត[1074] មានទីតាំងស្ថិតក្នុងភូមិកង្ហត ឃុំកង្ហត (បច្ចុប្បន្នឃុំកន្ទឺ១) ស្រុកសង្កែ ខេត្តបាត់ដំបង តំបន់ ១ ភូមិភាគពាយ័ព្យ។[1075] ការដ្ឋានទំនប់កង្ហតនេះ ត្រូវបានអ្នកខ្លះហៅថា "ទ្វារទឹកកង្ហត"។[1076] ការដ្ឋានទំនប់កង្ហតត្រូវបានបង្កើតឡើងប្រហែលជានៅពាក់កណ្តាលឆ្នាំ១៩៧៦[1077] ហើយបានដំណើរការរហូតដល់ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។[1078] ការដ្ឋានទំនប់កង្ហតស្ថិតក្រោមការគ្រប់គ្រងរបស់តំបន់ ១។[1079]

២៧៧. ដំបូងមាន តា សាយ ជាលេខាតំបន់ ១ និងជាអ្នកទទួលខុសត្រូវទំនប់កង្ហតមុនដំបូងគេ។[1080] បន្ទាប់មកទើបមាន៖ តា វ៉ាញ, តា សាម៉ន, តា ប៉ែត, និង **តាទិត្យ**។[1081] នៅពេលដែលតាវ៉ាញ គ្រប់គ្រង គាត់បានស្នាក់នៅ និង ធ្វើការនៅផ្ទះសសរ៤០ នាប៉ែកខាងកើតការដ្ឋានកង្ហតប្រហែល ១៥០ (មួយរយហាសិប) ម៉ែត្រ។[1082] សម្រាប់នាពេលក្រោយមក តា វ៉ាញ ត្រូវបានចោទបះបោរនិងបាត់ខ្លួន ចំណែកឯ តា ប៉ែត ហៅ ហេង ទាវ ក៏កាន់បន្តនៅទីនេះបានប្រហែល ១ (មួយ) ឆ្នាំមុន **តាទិត្យ** មកដល់។[1083] មានការលើកឡើងថា នៅក្រោមការគ្រប់គ្រងរបស់ តា ប៉ែត ប្រជាជនមានបាយហូប និងមិនមានការធ្វើបាបប្រជាជនទេ។[1084]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

តាទិត្យ ស្លាក់នៅទំនប់កង្ហតកាន់តំបន់ ១ តែម្តង។[1085] បន្ទាប់ពី តាទិត្យ មកដល់មិនមានការផ្លាស់ប្តូរកម្មាភិបាលទេ។[1086]

២៧៨. ទំនប់កង្ហតត្រូវបានគេប្រើប្រាស់ ដើម្បីធ្វើការចែកចាយទឹកស្ទើរតែគ្រប់កន្លែងសំខាន់ៗ នៅក្នុងតំបន់ ១ ដូចជា៖ ទួលអណ្តែត ស្តង់ កោះសារ៉ាត កង្ហត ជាអាទិ៍។[1087] ផ្អែកតាមបរិវេណទីតាំងភូមិសាស្ត្រនៃទំនប់កង្ហត បានបង្ហាញថា នាភាគខាងកើតទំនប់នេះ មានប្រឡាយមួយយ៉ាងវែងដែលមានប្រវែងប្រមាណជា ២ (ពីរ) គីឡូម៉ែត្រ ដែលលាតសន្ធឹងដល់ទៅក្រឡឹងដុំ[1088] ហើយបន្តទៅភ្ជាប់ដល់ទួលម្ទេស[1089] ខណៈដែលប្រឡាយមួយខ្សែទៀតត្រូវបានលាតសន្ធឹងទៅដល់ជើងទីញ។[1090]

២៧៩. ដំបូងឡើយ ទំនប់កង្ហតស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីកម្មាភិបាលខាងភូមិភាគពាយ័ព្យ។[1091] ប៉ុន្តែ ក្រោយមកត្រូវបានជំនួសដោយខាងកម្មាភិបាល ដែលត្រូវបានបញ្ជូនពីភូមិភាគនិរតីនាចុងឆ្នាំ ១៩៧៨។[1092] ពេលក្រុមនិរតីបានមកដល់ កម្មាភិបាលនៅភូមិភាគពាយ័ព្យមួយចំនួនធំ ក៏ត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ ដោយរាប់ចាប់ពីថ្នាក់មេកងរហូតដល់ថ្នាក់តំបន់ ហើយជាញឹកញ៉ាប់ ការចាប់ខ្លួននោះត្រូវបានគេធ្វើឡើងស្ទើរតែរៀងរាល់យប់។[1093]

២៨០. ទំនប់កង្ហតជាទំនប់មួយដែលកាត់ស្ទឹងសង្កែ ដោយមានកម្ពស់ប្រមាណជា ២០ (ម្ភៃ) ម៉ែត្រ ទទឹង ៧០ (ចិតសិប) ម៉ែត្រ និងបណ្តោយ ១០០ (មួយរយ) ម៉ែត្រ។[1094] សាក្សីមួយចំនួនថា ទួលអណ្តែតក៏ជាផ្នែកមួយនៃការដ្ឋានទំនប់កង្ហតដែរ។[1095] ទួលអណ្តែតនេះ ត្រូវបានគេប្រើជាកន្លែងសម្រាប់អ្នកធ្វើការងារនៅទំនប់កង្ហតទៅសម្រាក[1096] និង ប្រើប្រាស់ជាកន្លែងសម្រាប់រក្សាទុកសម្ភារៈ និងជួសជុលគ្រឿងចក្រដែលបានខូចនៅទំនប់កង្ហត។[1097] នៅអំឡុងខែ ឧសភា ឆ្នាំ១ ៩៧៧ ខ្នងខាងលើនៃទំនប់កង្ហតដែលទើបតែសង់រួចបានប្រហែលជាប្រវែង ១០ (ដប់) ម៉ែត្រ[1098] ក៏ត្រូវបានដួលរលំបាក់ ខណៈពេលដែលមានមនុស្សកំពុងធ្វើការនៅខាងក្រោមក្បែរទំនប់នោះ។[1099] តាមសក្ខីកម្មឈ្មោះ វ៉ាន់ ជា អតីតកងចល័តបាននិយាយថា *"អ្នកធ្វើការប្រហែលជា ១០ (ដប់) ទៅ ២០ (ម្ភៃ) នាក់ ស្លាប់នៅពេលនោះ ...ខ្ញុំបានឃើញខ្សែទឹកយ៉ាងខ្លាំងហូរកាត់ត្រង់ចំណុចដែលបាក់នោះ។ ទំនប់នោះបាក់នៅពេល*



* ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

*ប្រហែលជាម៉ោងបួន ឬម៉ោងប្រាំរសៀល* "។ [1100] ទន្ទឹមនឹងនោះដែរ មានសាក្សីមួយរូបទៀតលើកឡើងថា "ការបាក់ទំនប់ (កង្គួត) បានកើតឡើងចំនួនពីរលើក"។[1101]

២៨១. នៅការដ្ឋានទំនប់កង្គួត កងចល័តខ្លះគ្មានអគារសម្រាប់ស្នាក់នៅនោះទេ មានតែការប្រក់តង់កៅស៊ូធ្វើជាដំបូលដើម្បីបានកន្លែងស្នាក់នៅ ហើយអ្នកខ្លះដេកក្នុងអង្រឹង ទន្ទឹងនឹងនោះ ក៏មានកងចល័តខ្លះបានស្នាក់នៅក្នុងរោងធ្វើពីឈើប្រក់ស័ង្កសីដែរ។[1102] ទីកន្លែងស្នាក់នៅរបស់បុរស និងនារីត្រូវនៅផ្សេងពីគ្នាជៀសវាងការខុសសីលធម៌។ ទន្ទឹមនឹងនោះ ក៏មានកងចល័តខ្លះបានស្នាក់នៅប្រហែលពី ៤០ (សែសិប) ម៉ែត្រ ប៉ុណ្ណោះពីទ្វារទឹកកង្គួត។[1103]

២៨២. ការធ្វើការនៅទំនប់កង្គួតប្រព្រឹត្តទៅទាំងថ្ងៃទាំងយប់។[1104] ពេលព្រឹកចាប់ពីម៉ោង ៧ (ប្រាំពីរ) ព្រឹកដល់ ម៉ោង ១១ (ដប់មួយ) ថ្ងៃត្រង់ ទើបដល់ពេលហូបបាយ រួចនាពេលរសៀលត្រូវធ្វើការចាប់ពីម៉ោង ១ (មួយ) រហូតដល់ម៉ោង ៥ (ប្រាំ) រសៀល ទើបបានបាយហូប រីឯពេលយប់ត្រូវធ្វើការចាប់ពីម៉ោង ៧ (ប្រាំពីរ) និង៣០ (សាមសិប) នាទីរហូតដល់ម៉ោង ១១ (ដប់មួយ) យប់។[1105] ចំពោះរបបអាហារនៅការដ្ឋានទំនប់កង្គួតទទួលបានក្នុង ១ (មួយ) ថ្ងៃ ២ (ពីរ) ពេល ដោយ ១ (មួយ) ពេល បបរខាប់ និង ១ (មួយ) ពេលទៀតបបររាវៗ។[1106] ជាក់ស្តែង ការហូបចុកនៅទីនេះឃើញថា មិនបានគ្រប់គ្រាន់នោះទេ រហូតដល់មានអ្នកធ្វើការនៅការដ្ឋាននេះបានស្លាប់ជាច្រើននាក់ ដោយការបរិភោគមិនបានគ្រប់គ្រាន់។[1107] បើទោះបីជាយ៉ាងណាក៏ដោយ ក៏អ្នកធ្វើការនៅការដ្ឋានកង្គួត មិនដែលឮមាត់ត្អូញត្អែរពីការលំបាកនោះទេ ហើយបើអ្នកណាហ៊ាន ប្រាកដជាត្រូវគេចាប់បញ្ជូនទៅមន្ទីរឃុំឃាំងបាណន់។[1108] អ្នកដែលធ្លាប់ត្រូវបានគេចាប់បញ្ជូនទៅឃុំឃាំងនៅគុកបាណន់ភាគច្រើនត្រូវស្លាប់ ចំណែកឯអ្នកខ្លះមួយចំនួនតូចក៏ត្រូវបានគេដោះលែងឱ្យមកវិញដែរ។[1109]

២៨៣. បើតាមសក្ខីកម្មសាក្សីជាច្រើនរូបបានលើកឡើងថា មានមនុស្សជាច្រើននាក់ត្រូវបានគេចាប់បញ្ជូនឱ្យទៅធ្វើការនៅការដ្ឋានទំនប់កង្គួត។[1110] នៅពេលធ្វើការនៅការដ្ឋាន មានក្រុមយោធាដែលប្រដាប់ដោយកាំភ្លើងឈរយាមនៅកន្លែងការដ្ឋាន។[1111] ស្ថានភាពធ្វើការនៅការដ្ឋានមិនសូវមានលក្ខណៈខុសគ្នានោះទេ ទាំងមុននិងក្រោយពេលក្រុមនិរតីមកដល់។[1112] ជាក់ស្តែង នាដើមដំបូងពេលក្រុមនិរតីមកដល់គឺ ទាំងក្រុមនិរតីនិងពាយ័ព្យធ្វើការរួមគ្នា



CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION* E.C.C.C * C.E.T.C.

គ្នា ប៉ុន្តែ អំណោះក្រោយមកខាងក្រុមនិរតីជាអ្នកនាំមុខខាងពាយ័ព្យវិញម្តង[1113] ដោយហេតុថា ពេលកម្មាភិបាលនិរតីបានមកដល់ ខាងកម្មាភិបាលពាយ័ព្យចាប់ពីថ្នាក់កងវរហូតដល់ថ្នាក់តំបន់ ត្រូវបានគេចាប់យកទៅរៀនសូត្រជាបន្តបន្ទាប់ ហើយក៏បាត់ខ្លួនរហូត លើកលែងតែអ្នកណាទាំងឡាយណាដែលគេគិតថា នៅមានប្រយោជន៍ប្រើទើបគេឲ្យនៅរស់។[1114] បើទោះបីជាមានការបាត់ខ្លួនអ្នកធ្វើការនៅការដ្ឋានទំនប់កង្កួតក៏ពិតមែន ប៉ុន្តែពុំមានសាក្សីរូបណាបានធ្លាប់ឃើញការសម្លាប់នោះដោយផ្ទាល់ភ្នែកនោះដែរ។[1115] ខាងក្រុមអ្នកពាយ័ព្យមិនចូលចិត្តក្រុមអ្នកមកនិរតី ហើយបើតាមសាក្សីមួយរូបបាននិយាយថា *"ក្នុងរយៈពេលនោះកម្មាភិបាលពួកនិរតីក៏បានបាត់បង់ច្រើនដែរ ដោយសារពួកពាយ័ព្យគេមិនចូលចិត្ត"*។[1116]

២៨៤. ក្រោយពេលកម្មាភិបាលនិរតីមកដល់ គេឃើញមានកម្មាភិបាលនៅខាងភូមិភាគពាយ័ព្យតែងបាត់ខ្លួនជាបណ្តើរៗ ជាពិសេស ចាប់យកទៅទាំងខ្សែៗនាពេលយប់។[1117] ទន្ទឹមនឹង ក៏មានសាក្សីបានលើកឡើងដែរថា អ្នកដែលគេចាប់បណ្តើរទាំងនោះ ប្រហែលជាត្រូវគេសម្លាប់អស់ហើយ ដោយសារគាត់បានឃើញសាកសពនៅក្នុងព្រៃក្បែរដំបូក នៅពេលគាត់បានទៅរកអុស ដោយសាកសពទាំងនោះមាន ទាំងប្រុសស្រី និងកុមារ ខណៈអ្នកខ្លះ ស្លាប់ទាំងដៃជាប់ចំណង។[1118]

២៨៥. ករណីមានមនុស្សខ្ជិលច្រអូស គេត្រូវធ្វើការរាយការណ៍ទៅឲ្យកងហាដើម្បីរាយការណ៍បន្តទៅកងវរ នឹងបន្តទៅថ្នាក់លើមួយថ្នាក់ទៀត ទើបទទួលបានបញ្ញាណែនាំត្រឡប់មកវិញដើម្បីយកបទបញ្ញានោះមកអនុវត្តតាម។[1119] សក្ខីកម្មសាក្សីម្នាក់បានបង្ហាញនូវបញ្ញាដែលណែនាំអ្នកដែលកំហុសនោះថា *"បើឈឺត្រូវប្រាប់ថា ឈឺ ហើយបើចង់ទៅលេងផ្ទះត្រូវសុំការអនុញ្ញាតពីប្រធានជាមុន"*។[1120] ប្រសិនបើអ្នកណាហ៊ានលួចទៅផ្ទះ ហើយត្រូវអង្គការចាប់បាន គេនឹងយកអ្នកនោះទៅសម្លាប់ចោលតែម្តង។[1121] សាក្សីម្នាក់ទៀតជាអតីតប្រធានកងនៅទំនប់កង្កួតបានលើកឡើងថា *"ពេលខ្លះពួកកងចល័តត្រូវការអង្ករ ឬបាយយកទៅឲ្យឪពុកម្តាយរបស់គេហូប ហើយគេបានសុំយើង យើងក៏ឲ្យគេទៅតាមសំណើ"*។[1122] ករណីដែលមានអ្នកណាម្នាក់ឈឺញឹកញាប់នឹងត្រូវបានគេចាត់ទុកជាខ្មាំង ប៉ុន្តែ អ្នកទាំងនោះមិនត្រូវបានគេចាប់ខ្លួនទេ ដោយគ្រាន់តែព្យាយាមណែនាំ អប់រំ អ្នកទាំងនោះឲ្យកែខ្លួន និងខិតខំប្រឹងធ្វើការឲ្យខ្លាំងក្លាឲ្យអង្គការតែប៉ុណ្ណោះ។[1123]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

២៨៦. ចំពោះចំនួនអ្នកដែលមកលើកទំនប់កង្កួតមិនមានទិន្ន័យឲ្យបានជាក់លាក់នោះទេ ខណៈសាក្សីខ្លះថា មានមនុស្សរាប់ពាន់នាក់ធ្វើការនៅទំនប់កង្កួត[1124] រីឯ អ្នកខ្លះថា មានដល់ទៅរាប់ម៉ឺននាក់។[1125] អ្នកដែលបានចូលរួមលើកទំនប់កង្កួតរួមមាន កងមនុស្សចាស់ កងយុវជន កងយុវនារី និងកងកុមារ ជាអាទិ៍។[1126] ក្រៅពីនេះ នៅមានកងដាច់ខាតក៏បានចូលរួមធ្វើការនៅការដ្ឋានទំនប់ផង ដោយកងដាច់ខាតខុសពីកងចល័តទូទៅនៅត្រង់ថា *"កងដាច់ខាតនេះគឺត្រូវតែធ្វើឲ្យហើយនូវអ្វីៗដែលចាត់តាំងឲ្យធ្វើ"*។[1127] លើសពីនេះ កងដាច់ខាតមានអំណាចចាប់ចងទៅលើបណ្តាមនុស្សទាំងឡាយណាដែលបានធ្វើការនៅតាមកងចល័ត ហើយដែលបានប្រព្រឹត្តកំហុស។[1128]

២៨៧. នៅចន្លោះពីឆ្នាំ ១៩៧៧ ទៅ ឆ្នាំ ១៩៧៨ នៅការដ្ឋានទំនប់កង្កួតក៏គេឃើញមានការសម្លាប់ខ្មែរក្រោមដែរ។ តាមការប៉ាន់ប្រមាណរបស់សាក្សី មានខ្មែរក្រោមប្រមាណជា ២ (ពីរ) ទៅ បី (បី) នាក់ ត្រូវបានគេយកទៅសម្លាប់ស្ទើរតែរៀងរាល់ថ្ងៃ។[1129] នៅចុងឆ្នាំ ១៩៧៨ ប្រហែលជា ៣ (បី) ខែ មុនពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំមានការចាប់ប្រជាជនឃុំឃាំងនៅក្នុងផ្ទះសសរ៤០ ដែលនៅជិតទំនប់កង្កួត និងនៅតែបន្តកើតមានយ៉ាងពេញបន្ទុក។[1130] ពេលខ្លះ គ្រាន់តែខាងយុវជននិយាយគ្នាលេងជាមួយខាងយុវនារី ក៏បានក្លាយទៅជាមូលហេតុក្នុងការឈានទៅចាប់ខ្លួនយកទៅសម្លាប់បានដែរ ក្រោមហេតុផលថាខុសសីលធម៌។[1131]

២៨៨. ចំពោះយុវជនភាគច្រើនដែលធ្វើការងារនៅទំនប់កង្កួតពេលយប់ បើត្រូវគេស្នើឲ្យទៅប្រជុំ ឬទៅរៀនសូត្រ ហើយមិនដែលឃើញពួកគេត្រឡប់មកវិញទេ។[1132] បើទោះបីជារបបកម្ពុជាប្រជាធិបតេយ្យជិតមានការដួលរលំក៏ដោយ ក៏ការសម្លាប់នៅបន្តកើតមានដដែលនៅការដ្ឋានទំនប់កង្កួតនេះ។[1133] រហូតដល់ពេលខ្លះ បើគេចាប់បានអ្នកណាដែលបានលួចរបស់របរហូបទោះយ៉ាងដូចជា ផ្លែក្រូច ជាអាទិ៍ ក៏គេបញ្ជូនឲ្យទៅជីករណ្តៅប្រមាណជា ៣០ (សាមសិប) រណ្តៅ ទើបគេព្រមដោះលែងឲ្យត្រឡប់មកវិញ។[1134]

២៨៩. ក្រោយពេលដែល **តាទិត្យ** បានដល់ការដ្ឋានទំនប់កង្កួតមិនបានប៉ុន្មានផង ស្រាប់តែ តាព្រំ ក៏ត្រូវបានគេចាប់ខ្លួនតែម្តង។ សាក្សីឈ្មោះ ឈឿន ប៊ាន បានលើកឡើងថា "ក្រោយពេលដែល **តាទិត្យ** បានកាន់អំណាចរយៈពេល ២ (ពីរ) សប្តាហ៍ទើប តា ព្រំ ត្រូវបានចាប់



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ខ្លួន"។[1135] ក្រោយមកនៅក្នុងខែ សីហា ឬខែ កញ្ញា ឆ្នាំ ១៩៧៧ តាមរយៈកិច្ចប្រជុំមួយ **តាទិត្យ** បានណែនាំខ្លួនថា គាត់ជាគណៈតំបន់១។[1136] នាពេលមួយមានការប្រជុំដែលមានការចូលរួមពីប្រជាជន ប្រធានភូមិ ឃុំ និងស្រុក សរុបប្រមាណជា ៨០០ (ប្រាំបីរយ) នាក់ នៅការដ្ឋានទំនប់កង្កួត ហើយក៏មានការប្រកាសពីវត្តមាន **តាទិត្យ** និងតួនាទីរបស់គាត់មកជួយដឹកនាំតំបន់ ១។[1137] រីឯ **តាទិត្យ** ក៏បានឡើងនិយាយ ពីការលើកទឹកចិត្តដល់ប្រជាជន និងការវាយប្រហារពីសំណាក់ខ្មាំងដែលស៊ីរូងផ្ទៃក្នុង។[1138]

២៩០. តាមសាក្សីថា **តាទិត្យ** បានមកធ្វើការគ្រប់គ្រងការដ្ឋានទំនប់កង្កួត នៅក្នុងខែ វិច្ឆិកា ឬ ខែ ធ្នូ ឆ្នាំ ១៩៧៧ ។[1139] តាមសាក្សីមួយចំនួនបានបញ្ជាក់ថា **តាទិត្យ** ធ្លាប់បានមកពិនិត្យការដ្ឋានទំនប់កង្កួត។[1140] នៅពេលស្ថិតក្រោមការគ្រប់គ្រងដោយ **តាទិត្យ** មានសាក្សីម្នាក់បានធ្វើការប៉ាន់ប្រមាណថា មានប្រជាជនប្រមាណ ៧០ (ចិតសិប) ភាគរយ នៃចំនួនប្រជាជនសរុបនៅក្នុងភូមិដែលបានស្លាប់ដោយសារអត់អាហារ និងធ្លាក់ខ្លួនឈឺ។[1141] ផ្ទុយទៅវិញបែរជាមានសាក្សីជាអតីតអ្នកលើកទំនប់កង្កួតថា "យើងមានអាហារហូបចុកគ្រប់គ្រាន់ ហើយគេក៏មានបំប៉នយើងបានល្អផងដែរ"។[1142]

២៩១. សាក្សីជាច្រើនជាអ្នកធ្វើការនៅទំនប់កង្កួតបាននិយាយថា មិនដែលឃើញ និងបានស្គាល់ **តាទិត្យ** នោះទេ។[1143] ខណៈសាក្សីខ្លះទៀតក៏បានអះអាងថា **តាទិត្យ** គាត់ជាមនុស្សមានអាកប្បកិរិយាស្លូតបូត។[1144] នៅពេលដែល **តាទិត្យ** ទៅទីនោះក៏មិនដែលឃើញបានការចាប់ខ្លួនមនុស្សដែរ។[1145] ខណៈពេលដែលជៀកនឹងការដួលរលំរបបទៅហើយ **តាទិត្យ** នៅបន្តដាស់តឿនប្រជាជនឱ្យចូលរួមប្រឹងប្រែងកសាងទំនប់និងធ្វើស្រែឱ្យប្រទេសរីកចម្រើន "**កុំឱ្យខ្មាំងវាយ ឬ បង្អត់បាយយើង**"។[1146]

២៩២. សាក្សីឈ្មោះ ឈឿន ប៉ាន បាននិយាយថា "*ខ្ញុំឃើញ **តាទិត្យ** ដើរមើលការងារ (ការដ្ឋានទំនប់កង្កួត) នៅពេលនោះ ហើយជួនកាល គាត់ដើរត្រួតពិនិត្យការងារជាមួយ តា ម៉ុក ដោយ តាម៉ុក គ្រាន់តែមកត្រួតពិនិត្យម្តងម្កាលប៉ុណ្ណោះ*"។[1147] ចំពោះវត្តមាន **តា ទិត្យ** នៅការដ្ឋានទំនប់កង្កួតត្រូវបានសាក្សីឈ្មោះ ឈឿន ប៉ាន បានបន្ថែមទៀតថា "*បើនិយាយអំពីចំនួនដង គឺរាប់មិនអស់នោះទេ ព្រោះគាត់ចុះមើលការងារនៅឯការដ្ឋានទំនប់កង្កួតរៀងរាល់ថ្ងៃ*"។[1148]

01619123



## ១០. មន្ទីរសន្តិសុខបាណន់

២៩៣. មន្ទីរសន្តិសុខបាណន់មានទីតាំងស្ថិតក្នុងភូមិឆាយរំពាត់ ឃុំកន្ទឺ២ ស្រុកសង្កែ ខេត្តបាត់ដំបង តំបន់ ១ ភូមិភាគពាយ័ព្យ។[1149] មន្ទីរសន្តិសុខបាណន់ព័ទ្ធជុំវិញទៅដោយបន្ទាល្ងួសដែលស្ថិតនៅប៉ែកខាងក្រៅវត្តបាណន់ក្រោមនៅខាងមុខផ្លូវចុះពីប្រាសាទបាណន់តែម្តង។[1150] ដើមឡើយ ទីកន្លែងមន្ទីរសន្តិសុខបាណន់ ជាទីស្នាក់ការប៉ុស្តិ៍នគរបាលរបស់របបសាធារណរដ្ឋខ្មែរ។[1151] មន្ទីរសន្តិសុខបាណន់ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៧៥ ហើយបានដំណើរការរហូតដល់ពាក់កណ្តាលឆ្នាំ ១៩៧៨។[1152] វាជាមន្ទីរសន្តិសុខថ្នាក់ស្រុក។[1153]

២៩៤. តាមសក្ខីកម្មថា មន្ទីរសន្តិសុខបាណន់ដំបូងឡើយ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់យោធាស្រុក[1154] ប៉ុន្តែ នៅឆ្នាំ ១៩៧៨ មន្ទីរសន្តិសុខនេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងដោយតំបន់វិញ។[1155] សាក្សីឈ្មោះ ឈាង ប៉ា អតីតជាកងការពាររបស់ តា ប៉ែត បាននិយាយឲ្យដឹងថា គាត់ធ្លាប់ឮមន្ទីរសន្តិសុខស្រុកបាណន់ ត្រូវបានប្តូរទៅជាមន្ទីរសន្តិសុខតំបន់វិញ នៅក្រោយពេលខាងក្រុមនិរតីបានមកដល់។[1156]

២៩៥. នៅក្នុងបរិវេណមន្ទីរសន្តិសុខបាណន់ មានអគារចំនួន ៤ (បួន) រួមមាន៖ ៣ (បី) អគារសម្រាប់ធ្វើការឃុំខ្លួនអ្នកទោស និង ១ (មួយ) អគារទៀតសម្រាប់ធ្វើជាកន្លែងសួរចម្លើយអ្នកទោស។[1157] អ្នកទោសនៅមន្ទីរសន្តិសុខបាណន់ ត្រូវបានគេធ្វើការបែងចែក ២ (ពីរ) ប្រភេទ៖ អ្នកទោសស្រាល និង អ្នកទោសធ្ងន់។[1158] ចំពោះអ្នកទោសស្រាល ត្រូវបានគេឃុំឃាំងក្នុងរោងវែងមួយដោយប្រក់ដំបូលស័ង្កសី ដែលមានទទឹងប្រមាណជា ៥ (ប្រាំ) ម៉ែត្រ និងបណ្តោយប្រមាណជា ១០ (ដប់) ម៉ែត្រ។ រីឯ អ្នកទោសធ្ងន់ខ្លះត្រូវបានគេឃុំឃាំងក្នុងគុកងងឹតក្រោមដី ដែលមានទំហំប្រមាណជា ៣ (បី) ម៉ែត្រ គុណ ៤ (បួន) ម៉ែត្រ ហើយអ្នកទោសទាំងនោះមិនអាចមើលឃើញពន្លឺថ្ងៃនោះទេ។[1159] រោងដែលប្រើសម្រាប់ការសួរចម្លើយវិញត្រូវបានបិទបាំង ជិតទាំងដំបូងនិងជញ្ជាំងដោយស័ង្កសី ដែលមានទំហំប្រមាណជា ៣ (បី) ម៉ែត្រ គុណ ៦ (ប្រាំមួយ) ម៉ែត្រ ដែលមានចម្ងាយប្រហែលជា ៣០ (សាមសិប) ម៉ែត្រ ពីរោងសម្រាប់ឃុំឃាំងអ្នកទោស។[1160] នៅក្បែរបរិវេណកន្លែងមន្ទីរសន្តិសុខបាណន់ ជើងភ្នំបាណន់ដែលស្ថិតនៅចម្ងាយប្រហែលមួយគីឡូម៉ែត្រក៏ជាទីតាំងសម្លាប់មនុស្សមួយដែរ។[1161]

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
* CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

២៩៦. អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខបាណន់រស់នៅក្នុងភាពគ្មានអនាម័យទេ បើសូម្បីតែបង្គន់ក៏គ្មានដែរ។[1162] ពេលណាអ្នកទោសត្រូវការបត់ជើងធំត្រូវគេឱ្យជុះដាក់ឡាំង ឬ ប៉ោត រួចយកទៅចាក់នៅកន្លែងជិតនោះ ដែលមានក្លិនស្អុយយ៉ាងអសោចមែនទែន។[1163]

២៩៧. អ្នកទោសនៅមន្ទីរសន្តិសុខវត្តបាណន់រួមមានទាំង អតីតរដ្ឋការ កងទ័ព កម្មាភិបាលភូមិភាគពាយ័ព្យ និងប្រជាជនដែលធ្វើការនៅតាមការដ្ឋាននានាក្នុងស្រុកសង្កែ ជាអាទិ៍។[1164] សាក្សីឈ្មោះ វ័រ រួម ជាអតីតអ្នកយាមនៅមន្ទីរសន្តិសុខបាណន់ បានអះអាងថា មន្ទីរសន្តិសុខនេះមានអ្នកទោសបួនប្រភេទរួមមាន ទី១ អ្នករត់ពីខេត្តនានា ទី២ អ្នកទោសដែលខុសសីលធម៌ ទី៣ អ្នកទោសលួចដំឡូង វាយមាន់វាយទាហូប និង ទី៤ អ្នកទោសធ្ងន់ដែលជាប់និន្នាការនឹងទាហាន លន់ នល់។[1165]

២៩៨. អ្នកទោសនៅមន្ទីរសន្តិសុខនេះមានទាំង បុរស និងនារី ប៉ុន្តែត្រូវបានគេដាក់កន្លែងឃុំឃាំងឱ្យនៅដាច់ពីគ្នា។[1166] អ្នកដែលធ្វើការនៅទំនប់កង្គួតដែលបានប្រព្រឹត្តកំហុស ក៏ត្រូវបានគេចាប់បញ្ជូនមកឃុំឃាំងនៅមន្ទីរសន្តិសុខបាណន់ដែរ។[1167] ចំពោះការសម្លាប់មនុស្សនៅបាណន់នេះ បើសូម្បីតែនៅកសិណទឹកភ្នំបាណន់ ក៏មានការសម្លាប់មនុស្សច្រើនដែរ។[1168] អ្នកទោសមានចន្លោះពី ៥០ (ហាសិប) នាក់ ទៅ ៣៥០ (បីរយហាសិប) នាក់។[1169] អ្នកទោសនៅមន្ទីរសន្តិសុខបាណន់ភាគច្រើនជាមនុស្សពេញវ័យ ដែលត្រូវបានគេចាប់មកដាក់នៅមន្ទីរសន្តិសុខបាណន់។[1170] អ្នកទោសឃុំនៅបាណន់នេះ ត្រូវបានគេចាប់នាំមកមន្ទីរសន្តិសុខនេះស្ទើរតែជារៀងរាល់ថ្ងៃ។[1171]

២៩៩. ការហូបចុករបស់អ្នកជាប់ឃុំ មានការខ្វះខាតមែនទែន មានតែបបររាវៗបាន ២ (ពីរ) ដងក្នុងមួយថ្ងៃ ដោយឱ្យតែពេលព្រឹក និងល្ងាច រីឯយប់គេមិនឱ្យនោះទេ។[1172] អ្នកទោសនៅមន្ទីរសន្តិសុខបាណន់ត្រូវបានគេធ្វើបាប និងធ្វើទារុណកម្ម ដោយមិនឱ្យអ្វីហូបឡើយក្រៅតែពីឱ្យទងដំឡូងផ្កាហូបជាអាហារ។[1173] ជារួម របបអាហារសម្រាប់អ្នកទោសដែលបានជាប់ឃុំឃាំងនៅបាណន់នេះ មានត្រឹមតែជាអង្ករលាយជាមួយទឹកឆៅ និងបន្លែរលួយៗ និងបបររាវៗជាមួយទងដំឡូង ជាដើម។[1174] លើសពីនេះ ពេលខ្លះគេឱ្យតែបបររាវៗ ប៉ុន្តែថែមទាំងលាយជាមួយនឹងបន្លែរលួយៗ និងមានដង្កូវថែមទៀត។[1175]



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

៣០០. អ្នកទោសត្រូវគេដាក់ខ្នោះជើងឱ្យនឹងកន្លែង។[1176] អ្នកទោសត្រូវគេធ្វើទារុណកម្មទោះយ៉ាងដូចជា វាយនឹងដំបង រុំកំណាត់កៅស៊ូឱ្យថប់ខ្យល់ រួចទើបគេសួរយកចម្លើយ។[1177] អ្នកទោសនៅមន្ទីរសន្តិសុខនេះមាន តាមការប៉ានប្រមាណមានចំនួន រាប់រយនាក់ត្រូវបានគេដាក់ខ្នោះជើង។[1178]

៣០១. នៅពេលដែលមានថ្នាក់លើចុះមកមើលមន្ទីរសន្តិសុខនេះ គេប្រាប់ទៅអ្នកទោសឱ្យដេក កុំឱ្យងើបអង្គុយ ឬ ជជែកគ្នា ហើយបើមិនធ្វើតាមការណែនាំទេ គេនឹងធ្វើទារុណកម្មដោយវាយនឹងដំបង ឬ សោរកង់។[1179] អ្នកទោសនៅបាណន់ ត្រូវបានគេសួរចម្លើយ ១ (មួយ) អាទិត្យម្តង។[1180] អ្នកទោសខ្លះក៏បានត្រូវគេដោះលែងឱ្យរួចជីវិតដែរ ប៉ុន្តែត្រូវគោរពតាមលក្ខខណ្ឌដោយតម្រូវឱ្យស្បថក្នុងខ្លឹមសារថា មិនត្រូវចង់គំនុំ ឬ សងសឹងនឹងពួកគេវិញទេ។[1181]

៣០២. មានប្រជាជនជាច្រើននាក់ ដែលត្រូវបានចោទថាជាអ្នកទោសហើយត្រូវបានគេឃុំឃាំង និងសម្លាប់ចោលនៅមន្ទីរសន្តិសុខបាណន់នេះ។[1182] ភាគច្រើនការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខបាណន់ត្រូវបានគេធ្វើនាពេលយប់ដោយដឹកតាមរទេះសេះ តាមឡានទាំងដៃជាប់ខ្នោះ ជាអាទិ៍។[1183] នៅពេលសម្លាប់មនុស្សភាគច្រើនគេប្រើ ពូថៅ (សម្រាប់អារក) ចំពុះទង់ កាំភ្លើង ត្បូងចប ជាដើម។[1184] ទន្ទឹមនឹងក៏មានអ្នកជាប់ឃុំនៅបាណន់នេះ បានស្លាប់អស់ជាច្រើននាក់ដែរ ដោយសារឥតមានអ្វីហូប។[1185] សក្ខីកម្មបង្ហាញថា នៅក្រោមការគ្រប់គ្រងរបស់ខាងក្រុមពាយ័ព្យ អ្នកទោសជានារីជាច្រើននាក់ត្រូវគេរំលោភបូករួចទើបគេយកទៅសម្លាប់ចោល ប៉ុន្តែក្រោយពេលខាងក្រុមនិរតីមកដល់ វិន័យកាន់តែតឹងរ៉ឹង បើដឹងច្បាស់ថានរណា ឬ ក្រុមណាប្រព្រឹត្ត នោះច្បាស់ជាត្រូវគេយកសម្លាប់ចោលគ្មានសល់ទេ។[1186]

៣០៣. អ្នកទោសដែលត្រូវចាប់យកមកមន្ទីរសន្តិសុខបាណន់ នៅពេលដែលគេត្រូវយកទៅសម្លាប់ គេចងទាំងខ្សែៗនាំចេញពីមន្ទីរសន្តិសុខបាណន់ហើយក៏បាត់ខ្លួនរហូត។[1187] ជារឿយៗ ពេលខ្លះ អ្នកទោសត្រូវបានគេចាប់យកទៅសម្លាប់ស្ទើរតែជារៀងរាល់ថ្ងៃ។[1188] ផ្ទុយទៅវិញ មានតែសាក្សីឈ្មោះ វ៉ែ រួម ដែលបានអះអាងឱ្យដឹងថា នៅគុកបាណន់មិនមានការកាប់សម្លាប់ទេ តែមានអ្នកទោសស្លាប់ដោយអត់បាយ។[1189] ជាក់ស្តែង គេឃើញមានសា[illegible] ជាច្រើនស្ថិតនៅប៉ែកខាងជើងភ្នំបាណន់ ដោយគេដាក់សាកសពចោលលើដីពាស[illegible]

កាលដោយមិនបានកប់ឡើយ។[1190] ដោយឃើញស្ថានភាពបែបនេះ អ្នកទោសមួយចំនួននៅមន្ទីរសន្តិសុខវត្តវត្តបាណន់ត្រូវបានគេតម្រូវឲ្យធ្វើការទាំងជាប់ខ្នោះ និងចូលរួមសែងសាកសពដែលគេសម្លាប់រួចហើយយកទៅកប់ឲ្យបានស្រួលបួលឡើងវិញ។[1191] ចំពោះការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខបាណន់ គេឃើញថាក្រោយការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ មានឆ្អឹង និងលលាដ៍ក្បាលមនុស្សជាច្រើននៅពាសវាលពាសកាលជុំវិញវត្តបាណន់។[1192]

៣០៤. នៅដើមឆ្នាំ ១៩៧៧ មានព្រឹត្តិហេតុអ្នកទោសចូនប្រមាណជា ១២ (ដប់ពីរ) នាក់ បានរត់ចេញពីមន្ទីរសន្តិសុខ ប៉ុន្តែត្រូវបានគេចាប់បានមកវិញបានតែ ២ (ពីរ) នាក់ និងត្រូវគេយកទៅសម្លាប់។[1193] ក្រោយមកនៅពាក់កណ្តាលឆ្នាំ១៩៧៨ គេឃើញមានការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខបាណន់មានការកើនឡើងជាខ្លាំង។[1194]

## ១១. មន្ទីរសន្តិសុខខ្នងគួ

៣០៥. មន្ទីរសន្តិសុខខ្នងគួ ឬ គុកខ្នងគួ មានទីតាំងស្ថិតនៅក្នុងភូមិបាណន់ ឃុំកន្ទឺ២ ស្រុកសង្កែ ខេត្តបាត់ដំបង។[1195] មន្ទីរសន្តិសុខនេះស្ថិតនៅភាគខាងកើតស្ទឹងសង្កែ ហើយវាស្ថិតនៅម្ខាងទៀតនៃស្ទឹងទល់មុខមន្ទីរសន្តិសុខបាណន់។[1196] មន្ទីរសន្តិសុខខ្នងគួមានចម្ងាយប្រហែលជា ៤០ (សែសិប) ទៅ ៥០ (ហាសិប) ម៉ែត្រ ពីស្ពានឆ្លងស្ទឹង។[1197] មន្ទីរសន្តិសុខនេះមានចម្ងាយប្រហែល ៣០ (សាមសិប) គីឡូម៉ែត្រ ភាគខាងត្បូងក្រុងបាត់ដំបង។[1198]

៣០៦. មន្ទីរសន្តិសុខខ្នងគួ មានទំហំបណ្តោយ ១០០ (មួយរយ) ម៉ែត្រ ពីកើតទៅលិច និងទទឹង ៦០ (ហុកសិប) ទៅ ៧០ (ចិតសិប) ម៉ែត្រពីជើងទៅត្បូង ហើយមានរបងឫស្សីព័ទ្ធជុំវិញបរិវេណមន្ទីរសន្តិសុខ។[1199] គេអាចចេញចូលបានតាមរបងនោះ ប៉ុន្តែពុំមាននរណាហ៊ានទៅជិតកន្លែងនោះទេ ហើយរបងឫស្សីនោះមានកម្ពស់ប្រហែល ១,៥ (មួយក្បៀសប្រាំ) ម៉ែត្រ។[1200] នៅក្នុងបរិវេណមន្ទីរនេះមានអគារឃុំឃាំងសម្រាប់ដាក់អ្នកទោសដែលមានបណ្តោយប្រហែលពី ៣០ (សាមសិប) ទៅ ៥០ (ហាសិប) ម៉ែត្រ ពីកើតទៅលិច និងទទឹងប្រហែល ១៥ (ដប់ប្រាំ) ទៅ ២០ (ម្ភៃ) ម៉ែត្រ ពីជើងទៅត្បូង។[1201] អគារឃុំឃាំងនេះធ្វើពីឈើ និងប្រក់ស័ង្កសី មានកម្រាល និងមានទ្វារនៅចុងខាងកើត និងខាងលិចអគារ។



ECCC * CETC * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ក្រៅពីនេះមានរោងបាយ[1203] មានឃ្លាំងដាក់អង្ករ[1204] ផ្ទះសម្រាប់ធ្វើការ[1205] រោងសម្រាប់អ្នកយាមស្នាក់នៅ និងរោងសម្រាប់សួរចម្លើយ។[1206] មានភស្តុតាងបង្ហាញថា នៅក្រៅបរិវេណមន្ទីរសន្តិសុខខ្នងគូមានទីតាំងសម្លាប់មួយឈ្មោះ គូរកណ្តាល ដែលរួមមានកន្លែងសម្លាប់មនុស្សចំនួនពីរកន្លែង[1207] និងមានទីតាំងសម្លាប់ពីរកន្លែងទៀតនៅខាងលិចគុកខ្នងគូ។[1208]

៣០៧. មន្ទីរសន្តិសុខខ្នងគូត្រូវបានបង្កើតឡើងដំបូងប្រហែលនៅពាក់កណ្តាលឆ្នាំ១៩៧៦[1209] ឬ នៅឆ្នាំ១៩៧៧។[1210] មូលហេតុនៃការបង្កើតមន្ទីរសន្តិសុខនេះ ដោយសារគុកបាណន់ត្រូវបានគេផ្លាស់ប្តូរមកដាក់នៅទីនេះតាំងពីជំនាន់កម្មាភិបាលពាយ័ព្យគ្រប់គ្រងម្ល៉េះ។[1211] ទោះបីជាយ៉ាងនេះក្តី សាក្សីខ្លះទៀតបានអះអាងថា មន្ទីរសន្តិសុខខ្នងគូបង្កើតឡើងបន្ទាប់ពីកម្មាភិបាលនិរតីមកដល់នៅចុងឆ្នាំ ១៩៧៧[1212] ឬ នៅពាក់កណ្តាលឆ្នាំ ១៩៧៨ ក្នុងអំឡុងពេលដែលអ្នកទោសនៅក្នុងមន្ទីរសន្តិសុខបាណន់ត្រូវបានគេបញ្ជូនឆ្លងទៅដាក់នៅខ្នងគូដែលស្ថិតនៅខាងកើតនៃស្ទឹងសង្កែ។[1213] មន្ទីរសន្តិសុខនេះបានដំណើរការរហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ។[1214]

៣០៨. មន្ទីរសន្តិសុខខ្នងគូ ស្ថិតក្រោមការគ្រប់គ្រងរបស់ស្រុក[1215] ក្រោយមកមន្ទីរសន្តិសុខនេះត្រូវបានផ្ទេរឱ្យនៅក្រោមការគ្រប់គ្រងដោយតំបន់វិញ។[1216] មានហេតុផលផ្សេងគ្នាដែលអះអាងថាគុកនេះជាមន្ទីរសន្តិសុខថ្នាក់តំបន់ដូចជា កម្មាភិបាលថ្នាក់តំបន់មកគ្រប់គ្រងហើយគេដកយោធាស្រុកចេញ[1217] ឬ មានមនុស្សច្រើនជាប់ឃុំនៅទីនេះ[1218] ឬ មានអ្នកទោសមកពីកន្លែងផ្សេងៗគ្នាក្នុងតំបន់។[1219] សាក្សីម្នាក់ឈ្មោះ ភឿក ឡាម ជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខខ្នងគូ បានអះអាងថាឈ្មោះ សួម ជាប្រធានមន្ទីរសន្តិសុខខ្នងគូ។[1220] ខណៈសាក្សីម្នាក់ទៀតឈ្មោះ ឈឿង ប៊ាន ដែលធ្លាប់ធ្វើជាទាហានជាមួយឈ្មោះ សួម បានអះអាងថា សួម មានតួនាទីជាអនុប្រធានមន្ទីរសន្តិសុខខ្នងគូ ប៉ុន្តែសាក្សីពុំបានចាំឈ្មោះប្រធានមន្ទីរសន្តិសុខខ្នងគូទេ បើទោះបី សួម ធ្លាប់ប្រាប់សាក្សីអំពីប្រធានរបស់គាត់ក៏ដោយ។[1221] អ្នកសួរចម្លើយនៅមន្ទីរសន្តិសុខនេះ មានឈ្មោះ សឿន[1222] ហើយការចាប់ខ្លួនភាគច្រើនធ្វើឡើងដោយពួកឈ្លបស្រុក។[1223]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

01619128



៣០៩. សាក្សីឈ្មោះ វ៉ វ រួម បានបំភ្លឺថា មន្ទីរសន្តិសុខខ្នងគូមានទំហំធំជាងគុកបាណន់ ហើយនៅទីនោះមានទាំងអ្នកធ្វើស្រែ អ្នកជាប់ទោស និងក្មេងតូចៗចាប់ពីមួយខែរហូតដល់ ១០ (ដប់) ឆ្នាំដែ លមកតាមឪពុកម្តាយរបស់ពួកគេ។[1224] អ្នកទោសមាន ៤ (បួន) ប្រភេទ គឺអ្នកទោសរត់មកពីខេត្តនានា អ្នកទោសដែលខុសសីលធម៌ អ្នកទោសលួចអាហាររហូប និងអ្នកទោសជាអតីតទាហានក្នុងរបប លន់ នល់។[1225]

៣១០. មន្ទីរសន្តិសុខខ្នងគូអាចផ្ទុកអ្នកទោសចន្លោះប្រហែល ១០០ (មួយរយ) ទៅ ២០០ (ពីររយ) នាក់[1226] ដែលអ្នកទោសទាំងអស់នោះរួមមានកម្មាភិបាលពាយ័ព្យ[1227] ប្រជាជនមូលដ្ឋានមកពីសហករណ៍ទួលម្ទេសក្នុងតំបន់ ១[1228] កសិករមកពីសហករណ៍ក្តោងក្នុងតំបន់ ៣[1229] ព្រមទាំងមានជនជាតិវៀតណាមមកពីស្រុកបាណន់[1230] ជាអាទិ៍។ ជាក់ស្តែងសាក្សីឈ្មោះ អៀក ឡាម អតីតអ្នកទោសនៅមន្ទីរសន្តិសុខនេះបានរៀបរាប់ថា ចាប់ពីពាក់កណ្តាលរហូតដល់ចុងឆ្នាំ ១៩៧៨ ឈ្លបមកពីស្រុកបាណន់បានប្រមូលចាប់ពួកគ្រួសារវៀតណាម ដែលនៅក្នុងភូមិទាំងអស់ក្នុងឃុំឈើទាល ស្រុកបាណន់។[1231] សាក្សីម្នាក់ទៀតបានអះអាងដែរថា ធ្លាប់ឃើញគេបញ្ជូនអ្នកទោសចេញពីគុកភ្នំបាណន់ ឆ្លងស្ទឹងទៅដាក់នៅក្នុងខ្នងគូ។[1232]

៣១១. អ្នកទោសនៅមន្ទីរសន្តិសុខនេះ ត្រូវបានគេដាក់ខ្នោះជើង[1233] ហើយអ្នកទោសស្រី និងអ្នកទោសប្រុសត្រូវបានឃាំងដាច់ពីគ្នាដោយជញ្ជាំងជាក្រណាត់បាវ។[1234] អ្នកទោសត្រូវបានគេធ្វើទារុណកម្មជារៀងរាល់ថ្ងៃ[1235] ដោយវាយដំបង្ខំឱ្យធ្វើការ[1236] ឬវាយបង្ខំសួរចម្លើយ និងឱ្យសារភាពពីអំពើរបស់ខ្លួន ចំណែកអ្នកទោសខ្លះទៀតត្រូវគេវាយរហូតទាល់តែស្លាប់។[1237] សាក្សីឈ្មោះ គឹម ចាត ជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខខ្នងគូ បានអះអាងថាអ្នកទោសត្រូវបានគេធ្វើទារុណកម្ម ដោយយកថង់ផ្លាស្ទីកគ្របពីលើក្បាល និងមុខអ្នកទោស រួចវាយរហូតដល់សន្លប់ ហើយគេយកអ្នកទោសទាំងនោះទៅសួរចម្លើយនៅពេលពួកគេដឹងខ្លួនឡើងវិញ។[1238]

៣១២. អ្នកទោសត្រូវបានគេបង្ខំឱ្យធ្វើការចាប់តាំងពីម៉ោង ៨ (ប្រាំបី) ព្រឹក ដោយឈប់សម្រាកបាយត្រង់ និងចាប់ផ្តើមបន្តការងារពីម៉ោង ១ (មួយ) ថ្ងៃត្រង់រហូតដល់ម៉ោង ៥ (ប្រាំ) ល្ងាច។[1239] ប៉ុន្តែរបបអាហារសម្រាប់អ្នកទោសវិញ មិនមានគ្រប់គ្រាន់ឡើយ ដោយមានតែបបររាវៗលាយជាមួយអំបិល ចំណែកអាហារសម្រាប់អ្នកយាមនៅមន្ទីរឃុំឃាំងនោះវិញ



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION
E.C.C.C * C.E.T.C

មានបាយ និងសាច់គោ ឬ សាច់ជ្រូក។[1240] អ្នកទោសខ្លះឃ្លានខ្លាំងពេកក៏បានរើសសំបកដំឡូងមីដែលគេចាក់ចោលយកមកហូប។[1241] អ្នកទោសដែលមានជំងឺពុំទទួលបានថ្នាំសម្រាប់ព្យាបាលឡើយ។[1242] ការណ៍នេះបណ្តាលឲ្យអ្នកទោសជាច្រើនស្លាប់នៅក្នុងមន្ទីរឃុំឃាំង។[1243] សាក្សីឈ្មោះ ភឿក ឡាម បញ្ជាក់បន្ថែមថា គាត់ត្រូវបានគេចាប់ដាក់ឃុំឃាំងក្នុងមន្ទីរសន្តិសុខខ្នងគូ នោះតាំងពីពេលមានផ្ទៃពោះ ២ (ពីរ) ខែ រហូតដល់ថ្ងៃសម្រាលកូន។[1244]

៣១៣. មានភស្តុតាងបង្ហាញឲ្យឃើញថា គេយកអ្នកទោសទៅសម្លាប់ចោលក្នុងអំឡុងពី ២ (ពីរ) ទៅ ៣ (បី) ថ្ងៃម្តង បន្ទាប់មកអ្នកទោសថ្មីត្រូវបានគេនាំយកមកដាក់នៅមន្ទីរសន្តិសុខនេះ។[1245] សាក្សីម្នាក់បានអះអាងថាធ្លាប់ឮថា មានការចាប់មនុស្សបញ្ជូនទៅទីនោះ តែមិនដែលឃើញមានត្រឡប់មកវិញទេ។[1246]

៣១៤. សាក្សីបានលើកឡើងថា ប្រហែលជាមុនពួកវៀតណាមចូលមកដល់ គាត់បានឃើញអ្នកទោសប្រហែលជាជាង ៣០ (សាមសិប) នាក់ ត្រូវបានគេបណ្តើរចេញពីមន្ទីរសន្តិសុខខ្នងគូយកទៅសម្លាប់នៅវាលស្រែនៅជិតមន្ទីរសន្តិសុខនេះ។[1247] គាត់បានបន្ថែមថា ២ (ពីរ) ថ្ងៃក្រោយមកបានឃើញសាកសពអ្នកទោសទាំងនោះ ដាក់តម្រៀបគ្នាជារង្វង់មូលនៅវាលស្រែដែលជាកន្លែងគេយកអ្នកទោសទៅសម្លាប់។[1248]

៣១៥. សាក្សីឈ្មោះ វី ផាន់ បានបញ្ជាក់ថា មួយរយៈពេលខ្លីមុនពេលដែលកងទ័ពវៀតណាមចូលមកដល់ អ្នកទោសនៅមន្ទីរសន្តិសុខខ្នងគូប្រហែល ៦០ (ហុកសិប) នាក់ត្រូវបានខ្មែរក្រហមយកចេញទៅសម្លាប់នៅក្នុងត្រពាំងមួយក្បែរនោះ។[1249] សាក្សីបានបន្ថែមថា ក្នុងចំណោមអ្នកទោសទាំងនោះ មានបុរសម្នាក់នៅរស់ ក្រៅពីនេះសាកសពទាំងអស់ត្រូវបានប្រជាជនដុតអស់ហើយ។[1250] សាក្សីបានដឹងអំពីការសម្លាប់អ្នកទោសទាំងនោះ ដោយសារការបញ្ជាពីឈ្មោះ ផាន ជាគណៈឃុំកន្ទឺ ២ ទៅអ្នកធ្វើការនៅមន្ទីរឃុំឃាំងខ្នងគូឲ្យនាំយកអ្នកទោសទាំងអស់ទៅសម្លាប់។[1251]

៣១៦. សាក្សី ៣ (បី) នាក់ បានអះអាងស្របគ្នាថា នៅពេលដែលវៀតណាមចូលមកដល់ខេត្តបាត់ដំបង អ្នកទោសនៅជាច្រើននាក់នៅមន្ទីរសន្តិសុខខ្នងគូត្រូវបានគេយកទៅសម្លាប់

គូរកណ្តាល។[1252] សាក្សីបានបន្ថែមថា មាន ៤ (បួន) កន្លែងដែលគេយកអ្នកទោសទៅសម្លាប់ ដែលមាន ៣ (បី) កន្លែងនៅគូរកណ្តាល ដែលមានទីតាំងនៅខាងកើតគុកខ្នងគូ ប្រហែល ៦០០ (ប្រាំមួយរយ) ម៉ែត្រ និង ២ (ពីរ) កន្លែងទៀតនៅខាងលិច។[1253]

៣១៧. មានសាក្សីម្នាក់ដែលធ្លាប់រស់នៅក្បែរខ្នងគូប្រហែលនៅក្នុងឆ្នាំ ១៩៧៦ ឬ ឆ្នាំ ១៩៧៧ បានអះអាងថាធ្លាប់ឮថា មានការចាប់មនុស្សបញ្ជូនទៅទីនោះ តែមិនដែលឃើញមានត្រឡប់មកវិញទេ គឺមានន័យថាត្រូវបានគេសម្លាប់ ហើយមិនដឹងថាអ្នកទាំងអស់ត្រូវបានសម្លាប់ដោយវិធីណានោះទេ ព្រោះគាត់មិនដែលឮស្នូរកាំភ្លើងទេ ប្រហែលសម្លាប់ដោយប្រើត្បូងចប។[1254] សាក្សីបានអះអាងថា អ្នកទោសខ្លះបានស្លាប់ដោយសារមិនមានអាហារគ្រប់គ្រាន់ ឈឺ ដោយសារនៅក្នុងមន្ទីរឃុំឃាំងមានអាកាសធាតុក្តៅខ្លាំង។[1255]

៣១៨. សាក្សីបានអះអាងថាមានរណ្តៅកប់ខ្មោចជាច្រើនក្បែរបរិវេណគុក ដោយរណ្តៅនីមួយៗមានសាកសពពី ៣ (បី) ទៅ ៥ (ប្រាំ) នាក់។[1256] មិនតែប៉ុណ្ណោះសាក្សីមួយចំនួនក៏បានឃើញគំនរសាកសពជាច្រើននៅគរលើគ្នានៅក្រៅបរិវេណមន្ទីរសន្តិសុខ ដែលមានចម្ងាយប្រហែល ២០០ (ពីររយ) ម៉ែត្រ ទៅ ៦០០ (ប្រាំមួយរយ) ម៉ែត្រ។[1257] គំនរសាកសពខ្លះមានរាប់រយនាក់ដែលគរលើគ្នាជាពំនូកដ៏ធំ គំនរខ្លះទៀតមានសាកសព ៤ (បួន) ទៅ ៥ (ប្រាំ) នាក់ និងខ្លះទៀតមាន ១០ (ដប់) នាក់ គរលើគ្នា[1258] សាក្សីឈ្មោះ ស៊ុំ រឿត បានបន្ថែមថាសាកសពភាគច្រើនគឺជាមនុស្សពេញវ័យដែលមានទាំងប្រុសនិងស្រី ហើយកូនក្មេងមានចំនួនតិចតួចប៉ុណ្ណោះ។[1259] សាក្សីឈ្មោះ ហ៊ឹម ឆុងលី បានជឿថាសាកសពទាំងនោះ គឺសុទ្ធតែយកចេញពីមន្ទីរសន្តិសុខខ្នងគូទាំងអស់ ហើយគាត់សង្កេតឃើញថាសាកសពទាំងនោះមិនត្រូវបានសម្លាប់ដោយកាំភ្លើងទេ។[1260] សាក្សីបានសង្កេតឃើញថា សាកសពខ្លះត្រូវបានគេសម្លាប់ដោយអារក និងខ្លះទៀតត្រូវបានគេវាយក្បាលពីក្រោយ។[1261]

៣១៩. សាក្សីបានសន្និដ្ឋានថា មានសាកសពប្រហែល ២០០ (ពីររយ) នាក់ ត្រូវបានគេប្រទះឃើញនៅទាំងបួនទីតាំងសម្លាប់នោះ ហើយសាកសពទាំងនោះត្រូវបានគេទុកគរចោលនៅទីនោះ។[1262] សាក្សីបានបន្ថែមថា គាត់មិនបានឃើញគេសម្លាប់អ្នកទោសទាំងនោះទេ គាត់ដឹងរឿងនេះដោយសារគាត់ត្រូវបានគេប្រើឲ្យទៅដុតខោអាវរបស់អ្នកស្លាប់ទាំងនោះ និងបានដឹងពីអ្នករស់នៅក្បែរទីកន្លែងសម្លាប់នោះប្រាប់។[1263]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

៣២០. សាក្សីឈ្មោះភឿក ឡាម បានអះអាងថា មិនមានការរំលោភបំពានផ្លូវភេទទៅលើអ្នកទោសស្រីនៅទីនោះទេ។[1264] សាក្សីម្នាក់បានអះអាងថា មិនដែលបានដឹង ឬបានឃើញអ្វីកើតឡើងនៅមន្ទីរសន្តិសុខខ្នងគូទេ។[1265] សាក្សីម្នាក់ទៀតដែលជាអតីតអ្នកបើកបររថយន្តដឹកឈើបានអះអាងថា ធ្លាប់ដឹកមនុស្សពិការជើងម្នាក់ដែលធ្វើការមិនកើតពីគុកបាណន់ តែមិនធ្លាប់ដឹងអំពីមន្ទីរសន្តិសុខខ្នងគូនៅទីណាដែរ។[1266] សាក្សីឈ្មោះ ព្រិន អន ធ្លាប់ឮគេនិយាយប្រាប់ថាខ្នងគូ គឺជាគុក ប៉ុន្តែគាត់ខ្លួនឯងមិនដែលបានឃើញមនុស្សត្រូវបានគេបញ្ជូនទៅគុកខ្នងគូឡើយ។[1267]

## ១២. ការដ្ឋានរោងចក្រស្ករសកំពង់គុល

៣២១. រោងចក្រស្ករសកំពង់គុលមានទីតាំងនៅក្នុងភូមិតាម្បៀក ឃុំកំពង់គុល (បច្ចុប្បន្នឃុំថែងមានជ័យ) ស្រុកបាណន់ (បច្ចុប្បន្នស្រុកសង្កែ) ខេត្តបាត់ដំបង ក្នុងតំបន់ ១ នៃរបបកម្ពុជាប្រជាធិបតេយ្យ[1268] រោងចក្រនេះគឺជាទីតាំងផលិតស្ករស និងត្រូវបានបង្កើតឡើងដោយពួកពាយ័ព្យ និងដំណើរការរហូតដល់ដួលរលំនៃរបបក្នុងឆ្នាំ ១៩៧៩។[1269]

៣២២. ស្ថិតក្នុងទីធ្លាទំហំប្រមាណ ១ (មួយ) គីឡូម៉ែត្រ ៤ (បួន) ជ្រុង[1270] អគារនៃរោងចក្រនេះមានប្រវែងប្រហែលពី ១០០ (មួយរយ) ម៉ែត្រ ទៅ ១៥០ (មួយរយហាសិប) ម៉ែត្រ[1271] ឬ ២០០ (ពីររយ) ម៉ែត្រ[1272] ដែលរួមមានដូចជា ផ្ទះអ្នកយាម អគាររដ្ឋបាលទំហំ ១៥ (ដប់ប្រាំ) ម៉ែត្រ គុណនឹង ២០ (ម្ភៃ) ម៉ែត្រ អគារដាក់ម៉ាស៊ីនភ្លើងដែលមានម៉ាស៊ីនភ្លើង ២ (ពីរ) គ្រឿងទំហំ ១៥ (ដប់ប្រាំ) ម៉ែត្រ គុណនឹង ៣០ (សាមសិប) ម៉ែត្រ អគារដាក់ម៉ាស៊ីនកិនទឹកអំពៅដែលមានរោងសម្រាប់ដាក់ឡានទំហំ ៥០ (ហាសិប) ម៉ែត្រការ៉េ រោងជាងម៉ាស៊ីនក្រឡឹងទំហំ ១៥ (ដប់ប្រាំ) ម៉ែត្រ គុណនឹង ២០ (ម្ភៃ) ម៉ែត្រ រោងចក្រស្ករសទំហំ ១៥ (ដប់ប្រាំ) ម៉ែត្រ គុណនឹង ២០ (ម្ភៃ) ម៉ែត្រ ឃ្លាំងស្តុកស្ករស ៤០ (សែសិប) ម៉ែត្រ គុណនឹង ២០ (ម្ភៃ) ម៉ែត្រ ឃ្លាំងស្តុកម៉ាស៊ីន ៤០ (សែសិប) ម៉ែត្រ គុណនឹង ២០ (ម្ភៃ) ម៉ែត្រ ជញ្ជីងថ្លឹងរថយន្ត ខ្ទម អាងស្តុកទឹក និងប៉មស្តុកទឹក[1273] និងមានផ្ទះ ៤ (បួន) ខ្នង សម្រាប់កម្មករ និងទីប្រឹក្សាបច្ចេកទេសចិនស្នាក់នៅដែលផ្ទះនីមួយៗមានទំហំ ១៥ (ដប់ប្រាំ) ម៉ែត្រ គុណនឹង ២០ (ម្ភៃ) ម៉ែត្រ។[1274]



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

៣២៣. សាក្សី លឹម ទឹម អតីតអ្នកការពារក្នុងរោងចក្រស្តុរសកំពង់គុសបានអះអាងថា រោងចក្រស្តុរសកំពង់គុលដំបូងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកពាយ័ព្យ ដែលមានគណៈកម្មការគ្រប់គ្រងរោងចក្រដូចជា តាម៉ែត ជាប្រធានរោងចក្រ តាណុប ជាអនុប្រធាន និងតាបាវ ជាសមាជិក។[1275] តាម៉ែត តាណុប និង តាបាវ ត្រូវបានចាប់ និងបាត់ខ្លួនក្នុងអំឡុងពាក់កណ្តាលឆ្នាំ ១៩៧៨ ដោយក្រុមរបស់តាម៉ុក។[1276] តាយ៉ាន បានក្លាយជាប្រធានរោងចក្រ ហើយ យាយ សារី ដែលជាកម្មាភិបាលនីរតីផងដែរនោះ បានក្លាយជាអនុប្រធាន។[1277] សាក្សីបានបន្ថែមថា ពីរបីថ្ងៃក្រោយមក តាយ៉ាន ក៏ត្រូវបានចាប់ខ្លួនដោយចោទថាក្បត់[1278] ហើយយាយសារី នៅកាន់តួនាទីជាអនុប្រធានរោងចក្រដដែល។[1279] អ៊ើង និង ភិន កាន់តួនាទីជំនួស តាយ៉ាន បានតែប៉ុន្មានខែប៉ុណ្ណោះក៏វៀតណាមចូលមកដល់។[1280]

៣២៤. អតីតអ្នកការពារនៅក្នុងរោងចក្របានអះអាងថា រោងចក្រស្តុរសកំពង់គុលប្រហែលជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់មជ្ឈិមបក្ស មិនមែនក្រោមការគ្រប់គ្រងរបស់តំបន់ទេ។[1281] នេះដោយសារថា នៅពេលមានការប្រជុំម្តងៗ មានតាម៉ុក មកពីខាងមជ្ឈិមមក ហើយ តាសៀន ដែលមកពីខាងភូមិភាគក៏បានចូលរួមប្រជុំដែរ។[1282] គាត់បានបញ្ជាក់ទៀតថា មិនដែលឃើញមានអ្នកមកពីខាងតំបន់មកប្រជុំទេ។[1283] ក្រៅពី តាម៉ុក និង តាសៀន មានឈ្មោះ អ៊ើង និង ភិន ដែលមកជាមួយ តាម៉ុក បានចូលរួមប្រជុំដែរ ប៉ុន្តែមិនដឹងថាពួកគាត់មានតួនាទីអីទេ។[1284] សាក្សីបានបញ្ជាក់ថា នៅពេលតាម៉ុកមិនបានមកពិនិត្យមើលរោងចក្រ អ៊ើង មកមើលរោងចក្រជំនួសតាម៉ុក។[1285] គាត់បានបន្ថែមថា នៅពេលដែលអ៊ើងមកពិនិត្យម្តងៗ ជួនកាលគាត់មកដេកនៅទីនោះ ២ (ពីរ) ឬ ៣ (បី) យប់ ទើបត្រឡប់ទៅបាត់ដំបងវិញ។[1286] សាក្សីបានអះអាងថា ធ្លាប់បានឮឈ្មោះ **តាទិត្យ** នៅពេលប្រជុំនៅបាត់ដំបង តែមិនដែលបានឃើញ **តាទិត្យ** ទៀតទេ បន្ទាប់ពី តាម៉ុក មកដល់រោងចក្រ។[1287]

៣២៥. រោងចក្រនេះមានកម្មករប្រហែល ១០០ (មួយរយ) នាក់ ដែលបែងចែកជា ៤ (បួន) ទៅ ៥ (ប្រាំ) ក្រុមធ្វើការ។[1288] សាក្សីដែលធ្លាប់ជាកម្មករនៅរោងចក្រកំពង់គល់ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ ១៩៧៩ បំភ្លឺថា រោងចក្រដំណើរការ ២៤ (ម្ភៃបួន) ម៉ោង។ ករណីមានការងារប្រញាប់ កម្មករត្រូវធ្វើការពេញមួយយប់រហូតដល់ព្រឹក។[1289] កម្មកររោងចក្រម្នាក់ទៀតថ្លែងថា ការងារនៅរោងចក្រគឺធ្វើពីម៉ោង ៥ (ប្រាំ) ទៅ ៨ (ប្រាំបី) យប់ ធ្វើការបណ្តើរហូបបាយបណ្តើរ គ្មានពេលសម្រាកទេ ព្រោះអង្គការបង្ខំធ្វើការឲ្យគ្រប់ផែនការស្តុរសពី ៣ (បី)



CO-INVESTIGATING JUDGES * "CO-JUGES D'INSTRUCTION" * E.C.C.C * C.E.T.C

៥ (ប្រាំ) តោន។[1290] សាក្សីដដែលអះអាងថា បើកម្មករធ្វើខុសពេលថ្ងៃ ពេលយប់ត្រូវយកទៅហើយ។[1291] សាក្សីជាកម្មករនៅរោងចក្រតាំងពីឆ្នាំ ១៩៧៦ សង្កេតឃើញថាមនុស្សជាច្រើនបាត់ខ្លួនពីរោងចក្រ។[1292]

៣២៦. សាក្សីឈ្មោះ ខយ ឆួយ ដែលជាកម្មករនៅក្នុងរោងចក្រប្រហែលនៅចុងឆ្នាំ១៩៧៦ បានអះអាងថា នៅមុនឆ្នាំ ១៩៧៨ មានការចាប់ចងមនុស្សយូរៗម្តង ប៉ុន្តែក្រោយពីឆ្នាំ ១៩៧៨ ការចាប់ខ្លួនមានសន្ទុះញឹកញាប់មែនទែន។[1293] សាក្សីបានបញ្ជាក់បន្ថែមថា នៅក្រោយឆ្នាំ ១៩៧៨ ២ (ពីរ) ឬ ៣ (បី) ថ្ងៃមានការចាប់មនុស្សម្តងៗ ហើយមានពេលមួយនោះគេចាប់មនុស្សយកទៅដាក់នៅអគាររដ្ឋបាល[1294] គាត់ត្រូវបានគេចាត់តាំងឱ្យទៅយាមអ្នកទាំងនោះ។[1295]

៣២៧. សាក្សីជាកម្មករនៅក្នុងរោងចក្រស្ករសកំពង់គុលប្រហែលនៅចុងឆ្នាំ ១៩៧៦ បានអះអាងថា មានតាគួន និងគ្រួសាររបស់គាត់ដែលជាខ្មែរក្រោម ត្រូវបានកម្មាភិបាលនិរតីដឹកនាំដោយយាយសារី នាំចេញទៅហើយបាត់ខ្លួនរហូត។[1296] សាក្សីបានបន្ថែមថា មានកម្មករប្រុសៗជាច្រើនត្រូវបានគេចាប់យកទៅបាត់ ហើយប្រពន្ធរបស់ពួកគេនៅកន្លែងធ្វើការ[1297] ក្រោយមកគេប្រមូលប្រពន្ធអ្នកទាំងនោះយកទៅដាក់នៅភូមិមួយហៅថា "ភូមិមេម៉ាយ"។[1298]

៣២៨. សាក្សីបានអះអាងថា នៅប្រហែល ៣ (បី) ខែមុនពេលវៀតណាមចូលមកដល់ពួកខ្មែរក្រោម និងជនជាតិវៀតណាមមានចំនួនប្រហែល ៣០ (សាមសិប) នាក់ ត្រូវបានគេប្រមូលមកដាក់នៅក្នុងរោងទំហំ ៨ (ប្រាំបី) គុណនឹង ៣០ (សាមសិប) ម៉ែត្រ ដែលមានទីតាំងនៅជាប់នឹងផ្ទះដែលគាត់ការពារបានប្រហែល ១ (មួយ) ឬ ២ (ពីរ) យប់។[1299] សាក្សីបានបន្ថែមថា មូលហេតុដែលគេចាប់ពួកខ្មែរក្រោម និងជនជាតិវៀតណាមទាំងនោះដោយសារគេចោទថា ពួកទាំងនោះ "ជាប់ខ្សែយួន"[1300] ដែលត្រូវបានគេស្គាល់ដោយសារពួកនោះមានស្បែកស និងនិយាយភាសាខ្មែររដឹនៗ។[1301] ហេតុការណ៍នៃការចាប់ខ្លួននោះកើតឡើងបន្ទាប់ពីសាក្សីបានទៅចូលរួមប្រជុំនៅបាត់ដំបងប្រហែលក្នុងខែមីនា ឆ្នាំ១៩៧៨ គឺក្នុងពេលដែល **តាទិត្យ** ត្រូវបានគេប្រកាសជាលេខាតំបន់ពាយ័ព្យ[1302] ហើយក្រោយមកប្រហែលនៅពាក់កណ្តាលឆ្នាំ១ ៩៧៨ តាម៉ុក បានមកពិនិត្យមើលរោងចក្រស្ករសកំពង់គុល។[1303]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C.

៣២៩. ពួកខ្មែរក្រោម និងជនជាតិវៀតណាម ទាំងនោះត្រូវបានគេយកឡានមកដឹកចេញទៅ ហើយពេលឡានត្រឡប់មកវិញ ឃើញមានតែខោអាវមកជាមួយ។[1304] សាក្សីបានសន្និដ្ឋានថា ពួកខ្មែរក្រោម និងជនជាតិវៀតណាមទាំងនោះត្រូវបានចាប់យកទៅធ្វើស្រែនៅបឹងត្រាវ ប៉ុន្តែគាត់ឮពួកយោធានិយាយថាអ្នកទាំងនោះត្រូវបានគេដឹកយកទៅសម្លាប់អស់ហើយ។[1305]

៣៣០. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សំ ឡេង បានបំភ្លឺថា ធ្លាប់បានឃើញសាកសព និងខោអាវនៅចម្ងាយប្រហែល ៥០០ (ប្រាំរយ) ម៉ែត្រពីរោងចក្រ។[1306] គាត់បានបន្ថែមថា សាកសពទាំងនោះមានខ្លះថ្មី និងចាស់នៅគរលើគ្នា ហើយមានសភាពបែកខ្ទេចខ្ទី និងមានក្លិនអាក្រក់ណាស់។[1307] សាក្សីបានបញ្ជាក់ថា សាកសពមានចំនួនប្រហែលពី ២០ (ម្ភៃ) ទៅ ៣០ (សាមសិប) នាក់ក្នុងមួយកន្លែងៗ ហើយសាកសពនោះមានទាំងក្មេងទាំងចាស់។[1308] កម្មករបានថ្លែងថា ពេលគាត់រត់ចេញពីរោងចក្រក្នុងខែ មករា ឬ កុម្ភៈ ឆ្នាំ ១៩៧៨ បានឃើញសាកសពគលើគ្នានៅវាលស្រែ ២០ (ម្ភៃ) ទៅ ៣០ (សាមសិប) នាក់ ឆ្ងាយពីរោងចក្រ ៥០០ (ប្រាំរយ) ម៉ែត្រ។[1309]

៣៣១. កម្មករទាំង ២ (ពីរ) នាក់ ខាងលើបានបំភ្លឺប្រហាក់ប្រហែលគ្នាថា ដោយកម្មករម្នាក់ធ្លាប់ឃើញការរៀបការដោយបង្ខំម្តង ១០ (ដប់) គូនៅរោងចក្រនេះ នាពេលនោះ ឈ្មោះ យ៉ាន ជាអ្នកប្រកាស និងមានការនាំទៅបន្ទប់រៀងខ្លួន ដែលមានឈ្លបយាមពេលយប់នៃថ្ងៃរៀបការផង។កម្មករម្នាក់ទៀតថា ការរៀបការដោយបង្ខំយ៉ាងតិច ១០ (ដប់) គូ ដោយប្រធានរោងចក្រជាអធិបតី ផ្តើមពីឆ្នាំ ១៩៧៦ រហូតដល់ដួលរលំរបបខ្មែរក្រហម។[1310]

៣៣២. សាក្សីម្នាក់ដែលធ្លាប់ធ្វើការនៅអង្គភាពនេសាទរបស់យោធាភូមិភាគក្នុងជំនាន់ពាយ័ព្យធ្លាប់ឮតាមរយៈយោធាភូមិភាគថា តាទិត្យ នាំកងកម្លាំងដោយផ្ទាល់មកមើលស្ថានភាពនៅរោងចក្រកំពង់គុល ព្រមទាំងចាត់តាំង ឈ្មោះ យ៉ាន ឲ្យគ្រប់គ្រងរោងចក្រ។[1311] សាក្សីម្នាក់ទៀតដែលធ្លាប់ជាកម្មកររោងចក្រប្រាប់ថា ធ្លាប់ឮឈ្មោះតាទិត្យ តែមិនដែលឃើញ និងមិនដឹងមុខតំណែងគាត់ឡើយ។[1312] សាក្សីឈ្មោះ លឹម ទឹម អតីតអ្នកការពារចិននៅក្នុងរោងចក្រនោះ បានបំភ្លឺថា មុនពេលចាប់ តាយ៉ាន ក្នុងឆ្នាំ ១៩៧៨ នៅសន្និបាតនៅសាកលវិទ្យាល័យបាត់ដំបង ដែលមានអ្នកចូលរួមសុទ្ធតែកងការពារ និងយោធាប្រហែល២០០នាក់ តាទិត្យត្រូវបានគេឧទ្ទេសនាមជាគណៈភូមិភាគពាយ័ព្យ។[1313] នៅពេលនោះតាទិត្យ បាននិយាយថា

01619135



និរតីមកជួយការពាររោងចក្រខ្លាចយួនចូលដុតរោងចក្រ។[1314] សាក្សីបានបន្ថែមថា តាទិត្យមិនដែលមករោងចក្រកំពង់គុលឡើយ គឺមានតែតាម៉ុកទេដែលចេញចូលរោងចក្រ។[1315]

## ១៣. ការរៀបការដោយបង្ខំនៅស្រុកសំឡូត

៣៣៣. ស្រុកសំឡូត មានទីតាំងស្ថិតនៅក្នុងតំបន់១ នៃភូមិភាគពាយ័ព្យ។[1316] យោងតាមសក្ខីកម្មរបស់សាក្សី ២ (ពីរ) នាក់ ការរៀបការដោយបង្ខំបានកើតមាននៅក្នុងស្រុកសំឡូត។[1317]

៣៣៤. សាក្សីម្នាក់ដែលជាយោធាពិការដែលបានផ្លាស់ពីតាកែវ បានរៀបការនៅក្នុងពិធីនៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៧៨ នោះដែរ។[1318] សាក្សីនារីម្នាក់ទៀតបានអះអាងថា នៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៧៨ ដូចគ្នា គាត់ក៏ត្រូវបានគេបង្ខំឲ្យរៀបការជាមួយយោធាពិការម្នាក់ដែរ។[1319] សាក្សីក៏បានអះអាងផងដែរថា និយាយរួមគឺនៅចុងរបបខ្មែរក្រហមមានការរៀបការច្រើន។[1320]

៣៣៥. គោលបំណងមួយនៃការរៀបការគឺ ដើម្បីលើកទឹកចិត្តដល់កម្មាភិបាលពិការមកពី ខាងកើត ខេត្តកំពង់ឆ្នាំង ពួកនិរតី ឬ តាកែវ។[1321] អ្នករៀបការមិនបានដឹងពីពិធីរៀបការជាមុននោះទេ[1322] សូម្បីតែយាយឡេងដែលជាលេខាស្រុកសំឡូត[1323] ក៏មិនបានដឹងជាមុនថាគាត់ត្រូវរៀបការនៅពេលនោះដែរ។[1324] នារីខ្លះមិនស្រលាញ់អនាគតប្ដីនោះទេ។[1325]

៣៣៦. តាម៉ុក ជាអ្នកហៅកម្មាភិបាលទៅប្រជុំហើយប្រាប់ថា ពួកឯងមិនត្រូវទៅណាទេថ្ងៃនេះ ត្រូវមុជទឹកឲ្យស្អាត រសៀលនេះ អញការប្រពន្ធឲ្យ។[1326] ជាក់ស្ដែង សាក្សីម្នាក់ទៀតនិយាយថា តាម៉ុក គាត់មករៀបការឲ្យអ្នកពិការ អ្នកពិការស្រលាញ់អ្នកណាចង្អុលទៅ[1327] ដោយតាម៉ុក ប្រើដំបងដើម្បីចង្អុលថាអ្នកណាត្រូវរៀបការជាមួយអ្នកណា។[1328]

៣៣៧. ការរៀបការត្រូវបានប្រារព្ធធ្វើឡើងនៅក្នុងមន្ទីរស្រុកសំឡូតចាស់ នៅវេលាម៉ោង ២ (ពីរ) រសៀល[1329] សម្រាប់យុទ្ធជនចំនួន ៤០ (សែសិប) គូ ប៉ុន្តែមានយុទ្ធជនតែ ៣៨ (សាមសិបប្រាំបី) រូប ប៉ុណ្ណោះ ដែលបានរៀបការ ព្រោះនៅពេលនោះមានស្ត្រី ២ (ពីរ) នាក់បានរត់



E.C.C.C * C.E.T.C * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ចេញពីពិធី។[1330] សាក្សីបានបន្ថែមថា ស្ត្រីទាំងពីរនាក់នោះមិនត្រូវបានចាប់ខ្លួន ឬ ធ្វើបាបនោះទេ ព្រោះតាម៉ុក បាននិយាយថា កុំធ្វើអីពួកគេ ព្រោះពួកគេនៅក្មេងពេក។[1331]

៣៣៨. នៅមុនពេលចាប់ផ្តើមពិធីរៀបការ សាក្សីបានឃើញ **តាទិត្យ** បានមកជួបនិយាយជាមួយតាម៉ុក ប៉ុន្តែមិនបានដឹងពួកគេនិយាយគ្នាពីរឿងអ្វីទេ។[1332] តាម៉ុក បានចូលរួមកម្មវិធីរៀបការ នៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៧៨។[1333] តាម៉ុក បានបញ្ជា **តាទិត្យ** ឲ្យដឹកជញ្ជូនគ្រែ មុង អង្រឹងមកចែកអ្នកពិការដែលទើបរៀបការ ហើយបីថ្ងៃក្រោយ **តាទិត្យ** ធ្វើតាមបញ្ជារបស់តាម៉ុកមែន ដោយក្នុងសំបុត្រដែលរៀបរាប់ពីរបស់របរទាំងនេះ មានសរសេរថា ពីគណៈតំបន់ ១ ទិត្យ និងហត្ថលេខារបស់គាត់។[1334]

៣៣៩. កម្មវិធីរៀបការត្រូវចែងជា ៦ (ប្រាំមួយ) វគ្គ គឺ ទី១ អ្នកចូលរួមត្រូវឈរគោរពទង់បក្សរយៈពេល ៣ នាទី មានលើកស្លាកសញ្ញាជាអក្សរធំៗថា ពិធីរៀបអាពាហ៍ពិពាហ៍។[1335] ទី ២ អ្នករៀបចំកម្មវិធីឡើងប្រកាសហេតុ ពីការរៀបអាពាហ៍ពិពាហ៍ ដោយនិយាយថា ពួកយើងដល់វ័យត្រូវមានគូស្រករ ហើយអ្នករៀបចំកម្មវិធីនោះគឺឈ្មោះ យាយឡេង ជាលេខាស្រុកសំឡូត។[1336] ទី៣ ការប្រកាសឈ្មោះគូស្រករដែលត្រូវរៀបការ ដោយតាម៉ុក ហៅម្តងមួយគូៗ។[1337] ទី ៤ **តាទិត្យ** ដែលជាតំណាងតំបន់១ ឡើងផ្តល់មតិណែនាំដល់គូស្រករដែលរៀបការថ្មី[1338] ហើយ **តាទិត្យ** បានមានប្រសាសន៍ថា ពួកយើងដែលទើបរៀបការថ្មីៗត្រូវចេះស្រលាញ់គ្នា ត្រូវមានសាមគ្គីភាព និងខិតខំបង្កបង្កើនផល។[1339] ទី៥ គូស្រករដែលរៀបការថ្មីឡើងប្តេជ្ញាចិត្ត និងទី ៦ ការប្រកាសបិទកម្មវិធីដែលធ្វើឡើងដោយ យាយឡេង ដោយមានការឈរស្ងើងស្នាធគោរពទង់បក្សរយៈពេល ៣ (បី) នាទី ជាកិច្ចបញ្ចប់[1340] និងពុំមានពិធីជប់លៀង សម្រាប់កម្មវិធីមង្គលការនោះទេ។[1341] នៅចុងកម្មវិធី តាម៉ុក បាននិយាយថា មិត្ត **ទិត្យ** ជាប្រធានតំបន់ សូមអញ្ជើញមានប្រសាសន៍ទៅកាន់គូស្រករទើបរៀបការថ្មីៗ។[1342]

៣៤០. សាក្សីមិនបានដឹងអំពីថាតើមានការតាមស៊ើបការណ៍ចំពោះអ្នករៀបការថ្មីៗ នោះទេ។[1343] សាក្សីម្នាក់ទៀតលើកឡើងច្បាស់ថា មិនមានអ្នកណាគេមកតានដានពួកយើងទេ។[1344]



C.C * C.E.T.C. CO-INVESTIGATING JUDGES D'INSTRUCTION

## ១៤. មន្ទីរសន្តិសុខភូមិវាល

៣៤១. មន្ទីរសន្តិសុខភូមិវាល មានទីតាំងស្ថិតនៅក្នុងឃុំតាឡូ (ឬតាលោ) ស្រុកបាកាន ខេត្តពោធិ៍សាត់។[1345] នៅភូមិវាលមានរណ្តៅកប់សាកសពដែលត្រូវបានបង្កើតឡើងនៅវាលនៅចំកណ្តាលវាលស្រែ។[1346]

៣៤២. មានខ្មែរក្រោមជាច្រើនត្រូវបានទទួលរងនូវការចាប់ខ្លួន ការឃុំខ្លួន ការធ្វើទារុណកម្ម និងការសួរចម្លើយ ដើម្បីឲ្យដឹងថា តើពួកគេជាគីញវៀតណាមមែន ឬ មិនមែន។[1347] ជាក់ស្តែងសាក្សីម្នាក់ដែលធ្លាប់ត្រូវបានគេចាប់ដាក់គុកនៅទីនោះ បានអះអាងថា គាត់ត្រូវបានពួកខ្មែរក្រហមចាប់ឃុំខ្លួន ដោយមិនដឹងពីមូលហេតុអ្វីផងដែរ ហើយ តាវ៉ាញ ខ្មែរក្រោម និងប្រជាជនវៀតណាមត្រូវបានគេចាប់ទាំងអស់ដាក់ក្នុងគុកភូមិវាល ដោយខ្មែរក្រោមត្រូវបានគេចចោទថា "មានក្បាលយួនខ្លួនខ្មែរ"។[1348] មន្ទីរសន្តិសុខភូមិវាលត្រូវបានយាមកាមដោយយោធា។[1349]

៣៤៣. សាក្សីបានអះអាងថា អ្នកទោសខ្មែរក្រោមទាំងឡាយត្រូវបានសម្លាប់ជាពិសេសនៅពេលយប់ និងទម្លាក់ចូលទៅក្នុងរណ្តៅកប់សាកសព។[1350] ប៉ុន្តែសាក្សីមិនបានឃើញការសម្លាប់ទាំងនោះទេ តែធ្លាប់បានឃើញទឹកឡើងពណ៌ក្រហម និងឃើញសាកសព។[1351]

៣៤៤. មានសាក្សីជាច្រើនបានលើកឡើងពាក់ព័ន្ធជាមួយតាម៉ុក ប៉ុន្តែមិនមានសាក្សីណាម្នាក់បាននិយាយពីការចូលរួមរបស់ **តាទិត្យ** ទេ។ មានកំណត់ហេតុជាច្រើនដែលជាឯកសារពាក់ព័ន្ធទៅនឹងទីតាំងមន្ទីរសន្តិសុខភូមិវាលដែរ ប៉ុន្តែក្នុងចំណោមសាក្សីដែលត្រូវបានសម្ភាសន៍ មិនមានចម្លើយណាមួយ ដែលទាក់ទងដល់ការចូលរួមរបស់ **តាទិត្យ** ឡើយ។[1352]

## ១៥. មន្ទីរសន្តិសុខស្វាយជ្រុំ

៣៤៥. គុកស្វាយជ្រុំ ស្ថិតនៅក្នុង ភូមិស្វាយជ្រុំ ឃុំបឹងបាតកណ្តាល ស្រុកក្តាត (ស្រុកបាកាន) នៃតំបន់ ២ ភូមិភាគពាយ័ព្យ។[1353] សាក្សីម្នាក់អះអាងថា ពីមុន គុកនេះមានឈ្មោះថាត្រពាំងជង។[1354] អ្នកផ្សេងថាជាមន្ទីរសន្តិសុខថ្នល[1355] ឬ មន្ទីរតាឃិន។[1356]

៣៤៦. សាក្សីក៏បានបង្ហាញទីតាំងសម្លាប់មនុស្សព្រៃភាគដែលស្ថិតនៅប្រមាណរយម៉ែត្រខាងលិចគុកស្វាយជ្រុំ និងនៅក្នុងទីតាំងនៃភូមិស្វាយជ្រុំ។[1357] រណ្តៅសាកសពទំហំ ១០ (ដប់) ម៉ែត្រ គុណនឹង ១០ (ដប់) ម៉ែត្រ ត្រូវបានរកឃើញនៅក្នុងតំបន់នេះ។[1358] យោងតាមសាក្សី លឹម សាត មន្ទីរថ្កូលមានរណ្តៅសាកសព ១០ (ដប់) ដែលរណ្តៅនីមួយៗមានទំហំ ១០ (ដប់) ម៉ែត្រ គុណនឹង ១០ (ដប់) ម៉ែត្រ។[1359] រណ្តៅដែលធំមានឆ្អឹងមនុស្សត្រូវបានរកឃើញនៅក្នុងមន្ទីរថ្កូលក្រោយឆ្នាំ១៩៧៩។[1360] គុកត្រូវបានចែកជាផ្នែកខាងកើត និងខាងលិច ដែលខណ្ឌដោយអូរមួយ[1361] និងមន្ទីរផ្នែកខាងជើង[1362] អគារឥតបង្អួចខាងត្បូង។[1363] ផ្នែកខាងកើត មានរោងឈើទំហំ ៦ (ប្រាំមួយ) គុណនឹង ៣០ (សាមសិប) ម៉ែត្រ។[1364] ផ្នែកខាងលិចមានផ្ទះឈើទំហំ ៥ (ប្រាំ) ម៉ែត្រ គុណនឹង ៣០ (សាមសិប) ឬ ៤០ (សែសិប) ម៉ែត្រ។[1365]

៣៤៧. មន្ទីរសន្តិសុខនេះដំណើរការចាប់ពី ខែ មិថុនា ឬ ខែ កក្កដា ឆ្នាំ ១៩៧៦ ដល់រដូវវស្សាចុងឆ្នាំ ១៩៧៨។[1366] ក្រោយពីគុកថ្កូលត្រូវបានរំសាយ អ្នកទោសក្នុងគុកត្រូវបានផ្ទេរទៅគុកបឹងគល់នៅក្នុងភូមិបឹងខ្នារ ស្រុកបាកាន[1367] និងមន្ទីរសន្តិសុខត្រាចក្រោល។[1368]

៣៤៨. សាក្សី ២ (ពីរ) រូបដែលធ្លាប់ជាប់ឃុំនៅក្នុងគុកស្វាយជ្រុំ រវាងឆ្នាំ ១៩៧៦ ដល់ ១៩៧៨ និយាយថា តាឃិន ជាប្រធានគុក និងក្រោយមកបានបាត់ខ្លួននៅពេលកម្មាភិបាលនិរតីមកដល់។[1369] តាគឹម ជាអនុរបស់តាឃិន។[1370] ម៉ី គឺជាប្រធានយោធា និងទទួលបន្ទុកខាងសម្លាប់មនុស្សនៅក្នុងមន្ទីរសន្តិសុខ។[1371] សមមិត្តនារី សាម គឺជាមេកងស្រួច[1372] ហើយ ហៀង គឺជាអ្នកយាមគុក។[1373]

៣៤៩. មិនមានភ័ស្តុតាងច្បាស់លាស់ថាមានខ្មែរក្រោមនៅត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខស្វាយជ្រុំដែរឬអត់។ នៅពេលដែល ឡាយ បូរី បានយល់ស្របអំពីវត្តមានរបស់ខ្មែរក្រោម[1374] លឹម សាត វិញបានលើកឡើងថា មិនមានខ្មែរក្រោមត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខស្វាយជ្រុំ[1375] ហើយថែមទាំងនិយាយថា ខ្មែរក្រោមត្រូវបានបញ្ជូនទៅស្រុកកំណើតរបស់ពួកគេវិញនៅឆ្នាំ ១៩៧៦។[1376] សាក្សី មូល វណ្ណ បាននិយាយថា ពលរដ្ឋមកពីខេត្តស្វាយរៀងត្រូវបានឃុំខ្លួននៅក្នុងគុកជាមួយនឹងយោធា ប្រជាជន ១៧ មេសា ចាម និងប្រជាជនមកពីខេត្តកំពង់... ហើយភាគច្រើនគឺជាប្រជាជនមកពីភ្នំពេញ។[1377]



* C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01619139


៣៥០. អ្នកជាប់ទោសខ្លះត្រូវបានយកទៅឃុំខ្លួនដោយដឹកតាមរទេះគោ[1378] ឬ រថយន្តយោធា។[1379] នៅពេលអ្នកទោសទៅដល់គុកចូលដំបូង ឥវ៉ាន់ និងខោអាវត្រូវបានដកហូត លើកលែងតែខោអាវមួយសម្រាប់។[1380] អគារត្រូវបានចាក់សោរ និងយាមកាមដោយកងល្បាតនៅពេលយប់ ហើយអ្នកទោសត្រូវបានដាក់ឱ្យដេកជា ២០ (ម្ភៃ) ជួរ។[1381] បន្ទប់មានសភាពអាក្រក់វេទនានិងមានមនុស្សពេញប្រៀប ព្រមទាំងមានលាមក និងទឹកនោម ធ្វើឱ្យគ្មានកន្លែងអាចសម្រាកបាន។[1382] ផ្នែកខាងកើតអាចដាក់អ្នកទោសស្រាលពី ៣០ (សាមសិប) ទៅ ៤០ (សែសិប) នាក់ ក្នុងពេលតែមួយ។[1383] ផ្នែកខាងលិចដាក់អ្នកទោសប្រព្រឹត្តបទល្មើសធ្ងន់ពី ៥០ (ហាសិប) ទៅ ៦០ (ហុកសិប) នាក់ ក្នុងពេលតែមួយ។[1384] អ្នកទោសត្រូវបានដាក់ខ្នោះ។[1385] អ្នកទោសធ្ងន់ធ្ងរ ឬ អ្នកទោសនយោបាយ ឬ អ្នកទោសឆ្កួត ត្រូវឃុំខ្លួននៅក្នុងអគារឥតបង្អួចខាងត្បូង[1386] ដោយមានចាក់សោរ និងយាមកាម។[1387] ចំណែកអ្នកទោសស្រាល ត្រូវបានឃុំខ្លួននៅក្នុងមន្ទីរផ្នែកខាងជើង។[1388] អ្នកទោសទាំងស្រាល និងទាំងធ្ងន់ធ្ងរត្រូវបានដាក់ច្រវ៉ាក់។[1389] អ្នកទោសស្រាលត្រូវតែធ្វើការដើម្បីលុតដំខ្លួនឯង បើបានធ្វើអ្វីខុសនោះពួកគេនឹងក្លាយជាអ្នកទោសធ្ងន់ធ្ងរ។[1390] សាក្សីម្នាក់ថា មានអ្នកទោសប្រមាណជិត ២.០០០ (ពីរពាន់) នាក់ ត្រូវបានឃុំខ្លួននៅក្នុងមន្ទីរខាងជើង រួមបញ្ចូលទាំងអគារ និងបន្ទប់អត់ចាក់សោរសម្រាប់គ្រួសារចំនួន ៥ (ប្រាំ)។[1391] បុរស និងស្ត្រីត្រូវបានដាក់ផ្សេងគ្នា ហើយប្តីប្រពន្ធត្រូវបានឃុំនៅក្នុងរោងផ្សេង។[1392] ដោយឡែក លឹម សាត ប៉ាន់ប្រមាណថា អ្នកទោសប្រហែល ៤០០ (បួនរយ) ទៅ ៥០០ (ប្រាំរយ) នាក់ នៅជាប់ឃុំឃាំងក្នុងគុកនៅឆ្នាំ ១៩៧៨។[1393] អ្នកដែលត្រូវបានឃុំខ្លួននៅក្នុងគុកងងឹត គឺស្ថិតនៅក្នុងគុករហូត ទាំងពេលហូបចុក និងបន្ទោរបង់។[1394]

៣៥១. អ្នកទោសដែលមិនធ្វើការទទួលបានតែបបររាវសម្រាប់ហូបតែ ២ (ពីរ) ដងក្នុងមួយថ្ងៃ។[1395] អ្នកទោសដែលធ្វើការខ្លះទទួលបានតែបបរ ដែល ១ (មួយ) ឆ្នាំង ដាំ ៤ (បួន) កំប៉ុងសម្រាប់មនុស្ស ៣០ (សាមសិប) នាក់ ឬក៏ស៊ុបបន្លែ។[1396] អ្នកខ្លះទទួលបាន ១ (មួយ) កំប៉ុងសម្រាប់គ្នា ៤ (បួន) នាក់។[1397] អ្នកទោសធ្ងន់ធ្ងរត្រូវបានដាក់ច្រវ៉ាក់ ឬបង្ខំឱ្យជីកស្រះទឹកជិតមន្ទីរ។[1398] អ្នកទោសស្រាលជីកប្រឡាយ និងលើកភ្លឺស្រែ។[1399] ពួកគេធ្វើការតាំងពីម៉ោង ៧ (ប្រាំពីរ) ព្រឹករហូតដល់ម៉ោង ៥ (ប្រាំ) ល្ងាច ដោយសម្រាកបាយថ្ងៃត្រង់ ២ (ពីរ) ម៉ោង និងសម្រាក ១៥ (ដប់ប្រាំ) នាទី នៅពេលព្រឹក។[1400] មានតែថ្នាំបុរាណខ្មែរសម្រាប់ព្យាបាលជំងឺ។[1401]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

៣៥២. អ្នកទោសត្រូវបានគេវាយធ្វើបាបនៅពេលសួរចម្លើយ[1402] និងថា អ្នកទោសស្រីក្នុងបន្ទប់របស់គាត់ត្រូវបានគេដកក្រចក និងជ្រមុជក្បាលចូលក្នុងទឹក។[1403] យោងតាមសំដីរបស់ លឹម សាត នៅពេលទៅដល់គុក អ្នកទោសត្រូវបានសួរចម្លើយដោយ ឃិន គីម និង ឆោក តែមិនត្រូវបានធ្វើទារុណកម្មនោះទេ។[1404] អ្នកដាក់ពាក្យសុំម្នាក់ឈ្មោះ ខេក ចាន់ ដែលជាសមាជិកនៃកងចល័តនៅក្នុងតំបន់៧ ឆ្លើយថា អ្នកទោសដែលរស់នៅក្នុងភូមិក្តីឆ្នូល ត្រូវបានចោទប្រកាន់ថាជាយួន និងបានរងទារុណកម្ម។[1405] ក្បាលរបស់គាត់ត្រូវបានដាក់ក្នុងថង់ផ្លាស្ទិក ហើយចាក់ទឹកចូលដើម្បីធ្វើឲ្យថប់ដង្ហើម។[1406]

៣៥៣. មានភស្តុតាងតិចតួចដែលទាក់ទងនឹងការសម្លាប់អ្នកទោសខ្មែរក្រោមនៅគុកស្វាយជ្រុំ។ ក៏ប៉ុន្តែ ឡាយ បូនី អះអាងថា អ្នកណាដែលនិយាយសម្លេងរបៀបខ្មែរក្រោម នឹងត្រូវយកទៅសម្លាប់[1407] ហើយខ្មែរក្រោមនៅក្នុងក្រុមរបស់គាត់បានបាត់ខ្លួនទាំងអស់។[1408] នាងលើកឡើងថា មនុស្សប្រហែល ១០០.០០០ (មួយសែន) នាក់ត្រូវបានសម្លាប់នៅស្វាយជ្រុំ និងបញ្ជាក់ថា នាងដឹងព័ត៌មានដោយសារទាហានខ្មែរក្រហមម្នាក់ដែលត្រូវបានឃុំខ្លួនជាមួយនាង។[1409] គាត់គឺជាសាក្សីតែម្នាក់គត់ដែលផ្តល់ព័ត៌មានអំពីចំនួននេះ។ គាត់បានអះអាងទៀតថា នៅចុងឆ្នាំ ១៩៧៦ រាល់ ៣ (បី) ថ្ងៃ មនុស្សប្រហែល ២០០ (ពីររយ) នាក់ មានមនុស្សធំ និងកូនក្មេងត្រូវបាននាំទៅភូមិភាគនៅពេលបាយថ្ងៃត្រង់ និងមិនដែលឃើញត្រឡប់មកវិញនោះទេ។ ក្រោយមក ទើបដឹងថាអ្នកទាំងនោះត្រូវបានយកទៅសម្លាប់នៅភូមិភាគ។[1410]

៣៥៤. សាក្សីឈ្មោះ សាត លឹម ផ្តល់ចម្លើយថា អ្នកជាប់ឃុំត្រូវបាននាំទៅព្រៃ ក្នុងបរិវេណឃុំ និងត្រូវបានគេវាយរហូតដល់ស្លាប់ក្រោយពីទៅដល់គុកប្រមាណកន្លះខែ។ អ្នកទោសខ្លះត្រូវបានបង្ខំឲ្យជីករណ្តៅដោយខ្លួនឯងមុននឹងត្រូវបានសម្លាប់។[1411] ខេក ចាន់ បានដឹងអំពីពូរបស់គាត់ និងអតីតទាហាន លន់ ណាល់ ពីរនាក់ ត្រូវបានកងឈ្លបវាយរហូតដល់ស្លាប់ដោយប្រើចប។[1412] អតីតអ្នកទោសម្នាក់ទៀតឈ្មោះ ទាំ ជះ អះអាងថា មនុស្សភាគច្រើនដែលត្រូវនាំទៅមន្ទីរសន្តិសុខខាងត្បូង ត្រូវបានសម្លាប់។[1413] មានតែសាក្សីម្នាក់គត់ដែលបានអះអាងអំពីឧប្បត្តិហេតុមួយដែលអ្នកជាប់ឃុំឃាំងម្នាក់ត្រូវបានបាញ់សម្លាប់បន្ទាប់ពីចប់ការប្រជុំស្វ័យតិទៀន។[1414] សាក្សីមិនដែលដឹងឮអំពីអំពើហិង្សាផ្លូវភេទនៅគុកស្វាយជ្រុំឡើយ។[1415]



CO-INVESTIGATING JUDGES CO-JUGES D'INSTRUCTION E.C.C.C * C.E.T.C

៣៥៥. សាក្សីបានឆ្លើយមិនស៊ីសង្វាក់គ្នានិងច្បាស់លាស់អំពីចំនួនអ្នកទោស។ យោងតាមសាក្សី ៣ រូប នៅចន្លោះខែ មិថុនា ឬ កក្កដា ឆ្នាំ ១៩៧៦ ដល់ ឆ្នាំ១៩៧៧ មានមនុស្សយ៉ាងតិច ២.០០០ (ពីរពាន់) នាក់ ទៅ ៣.០០០ (បីពាន់) នាក់ ត្រូវបានចាប់ខ្លួន នាំទៅមន្ទីរសន្តិសុខស្វាយជ្រុំ។[1416] មិនមានភ័ស្តុតាងបញ្ជាក់ជនជាប់ចោទធ្លាប់បានទៅគុកស្វាយជ្រុំនោះទេ។

## ១៦. ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ

៣៥៦. ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវមានរណ្តៅប្រមាណជិត ១០ (ដប់)[1417] ស្ថិតនៅភូមិបាក់មែក ឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់។[1418] តាមសក្ខីកម្មរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវដំណើរការចាប់ពីឆ្នាំ១៩៧៧[1419] រហូតដល់ឆ្នាំ ១៩៧៨។[1420]

៣៥៧. ប្រធានគុកឈ្មោះ ណោម។[1421] យាន ផាន និយាយថា ម៉ី, ស៊ុន, ប៉ុច, សាយ សម្បត្តិ គឺជាអ្នកសម្លាប់មនុស្ស[1422] ហើយតាប៉ិចគឺជាប្រធានឈ្លបនៅខ្នារទទឹង។[1423] គង់ សំអឿន គឺជាគណៈស្រុកបាកាន។[1424]

៣៥៨. ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់និយាយថា មានខ្មែរក្រោមច្រើនជាង ២០០ (ពីររយ) គ្រួសារ ឬ ១.០០០ (មួយពាន់) នាក់ ត្រូវបានបញ្ជូនទៅទួលសេះញ៉ូវ។[1425] សាក្សីម្នាក់បានបញ្ជាក់ថា នៅឆ្នាំ១៩៧៧ ខ្មែរក្រោម[1426] ប្រជាជនដែលសង្ស័យថាជាខ្មែរក្រោម[1427] ឬ អ្នកដែលត្រូវបានសង្ស័យថាទាក់ទងនឹងវៀតណាមជាច្រើន[1428] ឬ ច្រឡំថាជាប្រជាជនជម្លៀសមកពីបូព៌ាដោយសារគាត់បង់កក្រមាពណ៌ខៀវ[1429] ត្រូវបានបញ្ជូនទៅទួលសេះញ៉ូវមុនពេលសម្លាប់។[1430]

៣៥៩. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់និយាយថា គាត់ត្រូវបានឃុំខ្លួន ១០ (ដប់) ថ្ងៃ។[1431] អ្នកជាប់ឃុំទទួលទារុណកម្មដោយបង្អត់អាហារ ប៉ុន្តែពុំមានវាយដំទេ។[1432] ខ្មែរក្រហមចាប់ផ្តើមសម្លាប់ពួកមូលធនក្នុងចំណោមខ្មែរក្រោម បន្ទាប់មកសម្លាប់ពួកអនុធន ហើយនៅដើមឆ្នាំ ១៩៧៨ ខ្មែរក្រោមទាំងអស់ត្រូវបានសម្លាប់។[1433] សក្ខីកម្មអំពីការសម្លាប់ខ្មែរក្រោមនៅទួលសេះញ៉ូវបានផ្អែកទៅលើខោអាវ នាឡិកា និងរបស់របរផ្ទាល់ខ្លួន...

ទៀតរបស់ខ្មែរក្រោម ដែលកម្មាភិបាលខ្មែរក្រហមប្រមូលត្រឡប់មកវិញ។[1434] ខ្មែរក្រោមត្រូវបានបែងចែកជា ២ (បី) ក្រុម ក្រុមទី១ គឺក្រុមដែលមានកម្លាំងខ្លាំង ក្រុមទី២ គឺស្ត្រី និងកុមារ ត្រូវបានបញ្ជូនទៅព្រៃក្របៅដើម្បីសម្លាប់ ក្រុមទី៣ គឺមានកុមារ មនុស្សឈឺ និងអ្នកដែលរៀបការជាមួយខ្មែរក្រោមត្រូវបានយកទៅសម្លាប់នៅទួលសេះញ៉ូវ។[1435] ដើមបណ្ដឹងផ្សេងទៀតបានអះអាងថា ក្រុមទី៣ គឺ មនុស្សចាស់ បុរសខ្មែរក្រោមដែលភាគច្រើនបញ្ជូនទៅសម្លាប់នៅទួលសេះញ៉ូវ។[1436] សាក្សីម្នាក់បានឃើញខ្មែរក្រោមចំនួន ១០០ (មួយរយ) នាក់ មកពីរូងតាកុក ភូមិរំលេច ភូមិបាក់មែក ភូមិខ្នារទទឹង ត្រូវយកទៅសម្លាប់នៅទួលសេះញ៉ូវ។[1437] សាក្សីម្នាក់ទៀតបានប្រាប់ថា សាច់ញាតិរបស់គាត់ម្នាក់ត្រូវចោទថាជាខ្មែរក្រោម ហើយសម្លាប់នៅទួលសេះញ៉ូវជាមួយគ្រួសាររបស់គាត់។[1438] សាក្សីម្នាក់ផ្សេងទៀតបានអះអាងថា បន្ទាប់ពីការសម្លាប់ខ្មែរក្រោម ប្រជាជនមកពីស្វាយរៀងជាច្រើនពាន់នាក់ត្រូវបានសម្លាប់នៅទួលសេះញ៉ូវ និងនៅព្រៃក្របៅ។[1439] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់និយាយថា ខ្មែរក្រហមបានប្រជុំរើសខ្មែរក្រោមដើម្បីទៅកាច់ពោត ហើយខ្មែរក្រោមទាំងនោះត្រូវបានសម្លាប់ ដែលម្ដងៗមានប្រហែល ២០ (ម្ភៃ) នាក់។[1440] អ្នកដែលមកពីបូព៌ាត្រូវបានគេចង[1441] បណ្ដើរយកទៅវាលស្រែដើម្បីសម្លាប់ដោយវាយនឹងដំបង[1442] ប្រើកាំបិតចាក់ក្រោមក្លៀក និងវាយពីក្រោយត្រង់កញ្ចឹងក[1443] ឬ ដោយប្រើកាំភ្លើង។[1444]

៣៦០. សាក្សីជាច្រើនបានផ្ដល់តួលេខខុសគ្នា និងមិនច្បាស់លាស់ អំពីចំនួនជនរងគ្រោះដែលត្រូវបានសម្លាប់ដោយខ្លះថា ១០០ (មួយរយ) នាក់[1445] ម្នាក់ទៀតបាននិយាយថា មានសាកសពប្រមាណពី ៦.០០០ (ប្រាំមួយពាន់) ទៅ ៧.០០០ (ប្រាំពីរពាន់) នៅក្នុងរណ្ដៅដែលភាគច្រើនជាខ្មែរក្រោមដែលជម្លៀសមកពីបូព៌ា។[1446] នៅពេលប្រជុំមួយ គេបានប្រកាសថាខ្មាំងវៀតណាម ៣.០០០ (បីពាន់) នាក់ ត្រូវបានកម្ទេច។[1447] មានតែសាក្សីម្នាក់ដែលត្រូវបានសង្គ្រោះដោយ តាសួន ដែលប្រាប់ខ្មែរក្រហមថាគាត់មិនមែនជាអ្នកស្វាយរៀង។[1448]

៣៦១. ប្រហែលឆ្នាំ ១៩៨៣ ឬ ឆ្នាំ ១៩៨៤ ប្រធានឃុំរំលេច លោក មាស ចាន់ថន បានប្រមូលឆ្អឹងនៅក្នុងរណ្ដៅយកទៅដាក់ក្នុងវត្តរំលេច។[1449] សាក្សីម្នាក់ទៀតបានប្រាប់ថាគាត់ឃើញតែរណ្ដៅដែលមានទឹកនៅពេញរណ្ដៅ ប៉ុន្តែមិនអាចមើលឃើញសាកសព ឬ ឆ្អឹងនោះទេ។[1450]

៣៦២. ទាក់ទងនឹងអំពើហិង្សាផ្លូវភេទវិញ នារីត្រូវបានកងឈ្លបចាប់រំលោភមុននឹងសម្លាប់។[1451] មានសាក្សីម្នាក់ដែលមានប្ដីជាខ្មែរក្រោមត្រូវបានខ្មែរក្រហមបង្ខំឱ្យរៀបការលើកទី២ជាមួយ មនុស្ស ៥ (ប្រាំ) គូរផ្សេងទៀត។[1452] គាត់ត្រូវបានគំរាមដោយឈ្លបឈ្មោះ ស៊ុន ដោយកាន់ កាំបិត ហើយនិយាយថា បើលោកស្រីមិនព្រមរៀបការ អង្គការចែកដី ២,៥ (ពីរក្បៀស ប្រាំ) ម៉ែត្រ ឱ្យ ដូច្នេះហើយទើបលោកស្រីព្រមរៀបការ។[1453] អ្នកដែលរៀបការថ្មីៗត្រូវ បានពួកឈ្លបតាមដានដើម្បីឱ្យប្រាកដថាប្ដីប្រពន្ធព្រមរស់នៅជាមួយគ្នាឬទេ។[1454]

៣៦៣. ក្នុងចំណោមសក្ខីកម្មទាំងអស់ មិនមានភ័ស្តុតាងបង្ហាញថាជនត្រូវចោទបានទៅទួលសេះញ៉ូវ នោះទេ។ ក្នុងចំណោមការស្ដាប់ចម្លើយសាក្សីជាច្រើន មិនបានបង្ហាញពីព័ត៌មានដែល ទាក់ទងទៅនឹងការគ្រប់គ្រង ឬការបញ្ជាទៅលើទីតាំងខាងលើនោះទេ។[1455]

## ១៧. ទីតាំងសម្លាប់មនុស្សព្រៃក្របៅ

៣៦៤. ទីតាំងសម្លាប់មនុស្សព្រៃក្របៅ ស្ថិតនៅវាលស្រែ នៃភូមិព្រៃក្របៅ ឃុំខ្នារទទឹង ស្រុក បាកាន ខេត្តពោធិ៍សាត់[1456] ដែលមានរណ្ដៅទំហំ បណ្ដោយ ១០ (ដប់) ម៉ែត្រ ទទឹង ១០ (ដប់) ម៉ែត្រ ជម្រៅ ១ (មួយ) ម៉ែត្រ។[1457]

៣៦៥. តាមចម្លើយរបស់សាក្សីម្នាក់ ទីតាំងសម្លាប់មនុស្សព្រៃក្របៅ ដំណើរការតាំងពីចុងឆ្នាំ ១៩៧៥ ឬ ដើមឆ្នាំ ១៩៧៦[1458] រហូតដល់ឆ្នាំ ១៩៧៨។[1459] លេខាស្រុកបាកានឈ្មោះ យាយ រឹម គឺជាអ្នកបញ្ជាឱ្យយកមនុស្សទៅសម្លាប់នៅព្រៃក្របៅ។[1460] ស៊ុន, សែ, រឹម, ហួត និង សុក ជាអ្នកនាំមនុស្សទៅសម្លាប់។[1461]

៣៦៦. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ២ (ពីរ) នាក់ អះអាងថា ខ្មែរក្រោមត្រូវ បានបញ្ជូនទៅព្រៃក្របៅដើម្បីប្រមូលផលដំឡូង និងពោត។[1462] ម្យ៉ាងទៀត មានសាក្សីបាន ឃើញដោយផ្ទាល់ភ្នែកអំពីការបញ្ជូនខ្មែរក្រោមទៅទីតាំងសម្លាប់មនុស្ស[1463] និងមាន ភ័ស្តុតាងបង្ហាញថាអ្នកទោសខ្មែរក្រោមនៅគុកភូមិវាលក៏ត្រូវបានបញ្ជូនមកទៅនេះដែរ។[1464] អ្នកដាក់ពាក្យសុំម្នាក់ឆ្លើយថា គាត់ឃើញខ្មែរក្រហមដឹកជញ្ជូនខ្មែរក្រោមទៅទីតាំងខា[illegible] នៅតែមួយព្រឹក ដោយត្រឡប់មកវិញឃើញតែសម្ភារៈរបស់ពួកគេមួយរទេះ ដែល[illegible]

ថាពួកគេត្រូវបានសម្លាប់។[1465] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ផ្តល់ចម្លើយថា ខ្មែរក្រោមចំនួន ១០ (ដប់) គ្រួសារ មានគ្នា ៦០ (ហុកសិប) នាក់ ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខភូមិវាលនិងត្រូវបានសម្លាប់។[1466]

៣៦៧. ការសម្លាប់ខ្មែរក្រោមទ្រង់ទ្រាយធំបានកើតឡើងនៅក្នុងឃុំរំលេច និងខ្នារទទឹង ហើយជនរងគ្រោះត្រូវបានសម្លាប់ និងកប់នៅទីតាំងរណ្តៅសពសេះញ៉ូវ និងព្រៃក្របៅ។[1467] ភស្តុតាងបង្ហាញថា នៅឆ្នាំ១៩៧៨ ខ្មែរកម្ពុជាក្រោមជាច្រើនត្រូវបានសម្លាប់នៅព្រៃក្របៅ ឃុំតាលោ។[1468] សហចៅក្រមស៊ើបអង្កេតមានសក្ខីកម្មមួយចំនួន ដែលមិនបានឃើញការសម្លាប់ តែបានឃើញសាកសពនៅក្នុងទីតាំងសម្លាប់។[1469] សាកសពប្រហែលពី ២០០ (ពីររយ) ទៅ ៣០០ (បីរយ) ត្រូវបានរកឃើញនៅទីតាំងនេះ ក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។[1470] សាក្សីម្នាក់ផ្តល់សក្ខីកម្មថា មានខ្មែរក្រោមជាង ៣០០ (បីរយ) គ្រួសារ ត្រូវបានដាក់នៅក្រោលគោនៅព្រៃក្របៅ ហើយគេសម្លាប់ចោលទាំងអស់នៅព្រៃក្របៅដោយកប់ក្នុងរណ្តៅរួម។[1471] សាកសពរបស់ពួកគេមិនត្រូវបានកប់ជិតទេ។[1472]

៣៦៨. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ឆ្លើយថា បានឃើញ និងឮ យាយរឹម លេខាស្រុកបាកាន បានបញ្ជាទៅ អ៊ុន អួន ឱ្យយកប្រជាជនមកពីភូមិវាលទៅសម្លាប់នៅព្រៃក្របៅ។[1473] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតបញ្ជាក់ថា គ្រួសារផ្សេងដែលមានកូនទៅរស់នៅខាងក្រៅ គឺកូនចៅទាំងអស់នោះអាចរស់នៅបាន តែក្រុមគ្រួសាររបស់ពួកគេត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោល។[1474] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជឿថា គាត់បាននៅរស់ដោយសារបានជ្រើសរើសរស់នៅជាមួយនឹងម្តាយរបស់លោកស្រី ដែលជាអ្នកមកពីកំពតទើបគាត់នៅរស់ដល់បច្ចុប្បន្ន ហើយឪពុកគាត់ដែលជាខ្មែរក្រោមត្រូវបានសម្លាប់នៅព្រៃក្របៅ។[1475]

៣៦៩. ដោយឡែក សាក្សី ២ (ពីរ) នាក់បានលើកជាសក្ខីកម្មថា ពួកគេបានឃើញសាកសពអ្នកដែលត្រូវបានជម្លៀសមកពីបូព៌ា ដោយសារពួកគេស្គាល់ក្រមាពណ៌ខៀវនៅទីតាំងសម្លាប់ដែលអង្គការបានឱ្យទៅអ្នកទាំងនោះ។[1476] បន្ថែមលើនេះ សាក្សីម្នាក់បញ្ជាក់ថា ខ្មែរក្រោមរាប់ពាន់នាក់និងអ្នកមកពីខេត្តស្វាយរៀងត្រូវបានគេសម្លាប់នៅទួលសេះញ៉ូវ និងព្រៃ



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ក្របៅ។[1477] ក្រៅពីនេះ សាក្សីម្នាក់បានបន្ថែមថា សាច់ញាតិរបស់គាត់ខ្លះដែលជាទាហាន លន់ នល់ ត្រូវបានសម្លាប់នៅព្រៃក្របៅក្នុងឆ្នាំ ១៩៧៦។[1478]

៣៧០. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានឆ្លើយថា ប្រហែលជា ១ (មួយ) ខែក្រោយការសម្លាប់ខ្មែរក្រោមលើកទី៣ គេបានបង្ខំឱ្យបុរសពោះម៉ាយ និងមេម៉ាយដែលធ្លាប់មានប្រពន្ធ ឬក៏ប្តីជាខ្មែរក្រោមទាំងអស់ឱ្យរៀបការ រួមទាំងម្តាយរបស់ខ្ញុំផងដែរ។[1479] ចម្លើយនេះស៊ីសង្វាក់ទៅនឹងចម្លើយសាក្សីម្នាក់ដែលថា ប្តីរបស់គាត់ត្រូវបានសម្លាប់នៅទួលសេះញ៉ូវ ហើយគាត់ត្រូវបានបង្ខំឱ្យរៀបការក្រោយហេតុការណ៍នោះភ្លាម។[1480]

៣៧១. សាក្សីជាច្រើនមិនបានបង្ហាញពីព័ត៌មានដែលទាក់ទងទៅនឹងការគ្រប់គ្រង ឬការបញ្ជារបស់ **តាទិត្យ** ទៅលើទីតាំងខាងលើនោះទេ។[1481]

## ១៨. ទីតាំងសម្លាប់មនុស្សវត្តចន្ទរង្សី

៣៧២. វត្តចន្ទរង្សី ហៅវត្តរំលេច[1482] មានទីតាំងស្ថិតក្នុង ភូមិប្រឡាយរំដេង[1483] (ចន្លោះកណ្តាលភូមិរំលេច និងភូមិប្រឡាយរំដេង)[1484] ឃុំរំលេច ស្រុកបាកាន[1485] ស្ថិតក្នុងតំបន់ ២ ភូមិភាគពាយ័ព្យ។[1486] សាក្សីម្នាក់បានឆ្លើយថា វត្តរំលេច មិនមែនជាគុកទេ។[1487] ផ្ទុយទៅវិញវត្តចន្ទរង្សីគ្រាន់តែជាកន្លែងសម្លាប់មនុស្សតែមួយពេលប៉ុណ្ណោះ។[1488]

៣៧៣. សាក្សី អ៊ុក សឿម ដែលជាអតីតប្រធានសហករណ៍រំលេច បាននិយាយថា ប្រជាជនបូព៌ាដែលនៅក្នុងតំបន់ ៧ នៃស្រុកកណ្តៀង ចំនួនប្រហែល ៣០០ (បីរយ) នាក់ ត្រូវបានយោធាខ្មែរក្រហមយកមកដាក់នៅតាមផ្លូវខាងមុខវត្តរំលេច។[1489] តែក្រោយមក សាក្សីដដែលនិយាយថា ពួកគេទាំង ៣០០ (បីរយ) នាក់ ត្រូវយកមកទុកនៅវត្តរំលេច។[1490] ការចាប់ខ្លួននេះ ដោយសារនៅពេលដែលខ្មែរក្រហមកំពុងប្រយុទ្ធជាមួយវៀតណាមនៅពោធិ៍សាត់ ជនស៊ីវិលមកពីបូព៌ាទាំងនេះបានទៅរកវៀតណាម ហើយក៏ត្រូវទាហានខ្មែរក្រហមចាប់បានតាមផ្លូវ។[1491]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES / CO-JUGES D'INSTRUCTION

៣៧៤. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងម្នាក់បានអះអាងប្រហែលគ្នាថា នៅឆ្នាំ ១៩៧៩ វៀតណាមបានចូលមកដល់ក្រុងពោធិ៍សាត់ហើយ។[1492] នៅពេលនោះក៏មានការបះបោរពីអ្នកមកពីបូព៌ានៅតាមសហករណ៍ ដើម្បីត្រឡប់ទៅស្រុករបស់ពួកគេវិញ។[1493] ទាហានខ្មែរក្រហមបានមកឃាត់ចាប់អ្នកទាំងអស់នោះ ប៉ុន្តែមិនអនុញ្ញាតឲ្យមានការបាញ់សម្លាប់នោះទេ។[1494]

៣៧៥. ប្រជាជនបូព៌ាទាំងនោះបានឡើងស្រែកជយឃោសម្តងម្នាក់ៗថា *"ជយោ! បក្សកុំម្មុយនីស្តបដិវត្តន៍កម្ពុជាដ៏ភ្លឺស្វាង សូមមើលខ្ញុំឲ្យច្បាស់ តើខ្ញុំខ្មែរ ឬជាយួន បើខ្ញុំមានឈាមយួន ក្បាលយួន សូមឲ្យបក្សមើលឲ្យច្បាស់ បើខ្ញុំខ្មែរ សូមឲ្យបក្សវិនិច្ឆ័យ។ បើខ្ញុំយួន សូមឲ្យសម្លាប់ចោលចុះ"*។[1495] នៅពេលនោះក៏មានអ្នកបូព៌ាម្នាក់បានចោលពូថៅត្រូវចំក្បាលទាហានខ្មែរក្រហម ជាហេតុនាំឲ្យមានការបាញ់រះទៅលើអ្នកបូព៌ាទាំងអស់នោះ។[1496] អ្នកបូព៌ាមកពីស្រុកកណ្តៀងនៃតំបន់ ៧ ប្រមាណ ៣០០ (បីរយ) នាក់ ត្រូវបានសម្លាប់នៅមុខវត្តរំលេច ផ្លូវចូលភូមិរំលេចទៅដល់ស្ពានដំណាក់ត្រាចនៅជិតវត្តរំលេច។[1497] សាក្សីដែលនៅកំពុងរែកទឹកនៅផ្លូវជាប់វត្តរំលេចបានឆ្លើយថា អ្នកបះបោរដែលត្រូវបានខ្មែរក្រហមបាញ់សម្លាប់នៅជិតវត្តរំលេច ដោយសារពួកគេបានរត់ចូលទៅខាងកងទ័ពរបស់ ហេង សំរិន។[1498] សាក្សីម្នាក់គ្រាន់តែឮគេនិយាយថា ប្រជាជនបូព៌ាត្រូវសម្លាប់នៅរំលេច[1499] ដោយកងទ័ពដែលត្រូវបានគេរៀបចំរួចជាស្រេច។[1500]

៣៧៦. បន្ទាប់មក នៅយប់ដដែលនោះ សាកសពទាំងនោះអ្នកភូមិដឹកតាមរទេះគោយកទៅទម្លាក់ក្នុងរណ្តៅរួម និងកប់នៅភូមិកូនត្នោត ឃុំរំលេច រហូតដល់ព្រឹកឡើងទើបអស់។[1501]

៣៧៧. សាក្សីជាច្រើនមិនបានបង្ហាញពីព័ត៌មានដែលទាក់ទងទៅនឹងការគ្រប់គ្រង ឬការបញ្ជារបស់ **តាទិត្យ** ទៅលើទីតាំងខាងលើនោះទេ។[1502]

## ១៩. មន្ទីរសន្តិសុខវត្តគិរីរម្យ

៣៧៨. បើយោងតាមផែនទីរដ្ឋបាលរបស់ខ្មែរក្រហម មន្ទីរសន្តិសុខវត្តគិរីរម្យស្ថិតនៅលើភ្នំសំពៅ ក្នុងឃុំភ្នំសំពៅ ស្រុកភ្នំសំពៅ ខេត្តបាត់ដំបង តំបន់៣ ភាគពាយ័ព្យ។[1503] សាក្សីដែល

មកដល់ភូមិភ្នំសំពៅកើតវិញប្រហែលខែ ៥ ឆ្នាំ ១៩៧៩ អះអាងថា នៅចម្ងាយប្រហែលជា ម្ភៃម៉ែត្រ ខាងជើង ឆៀងខាងកើតវិហារ មានរោងបាយ ហើយមានកុដិមួយនៅក្បែរនោះ ដែរ និងថា នៅល្អាងតែងខ្លួន ដែលស្ថិតនៅវិហារខាងជើងវត្តគិរីរម្យ ហើយនៅខាងលិចផ្លូវ ទៅល្អាងតែងខ្លួនបន្តិច ក៏មានផ្លូវមួយទៅល្អាងល្ខោន ហើយមុនដល់ល្អាងល្ខោនមានល្អាង មួយនៅខាងឆ្វេងដៃ ហៅថាល្អាងកង្កែប។[1504]

៣៧៩. មន្ទីរសន្តិសុខវត្តគិរីរម្យដំណើរការមុនពួកនិរតីមកដល់ និងបន្តរហូតដល់ក្រោមការគ្រប់គ្រង នៃពួកនិរតី។[1505] ចន្លោះពីដើមឆ្នាំ១៩៧៦ ដល់ចុងរបបខ្មែរក្រហម សាក្សី ៨ (ប្រាំបី) នាក់ បានឃើញទាហានខ្មែរក្រហមបណ្តើរអ្នកទោសឡើងជណ្តើរមកវត្ត។[1506] ផ្ទុយទៅវិញ សាក្សីម្នាក់ឆ្លើយថា ក្នុងខែច្រូត (ខែ មករា ឬ ខែ កុម្ភៈ) ឆ្នាំ ១៩៧៨ ពេលដែលពួកនិរតីចូល មកទើបគេយកអ្នកទោសទៅសម្លាប់នៅលើវត្តគិរីរម្យ។[1507] ចំណែកសាក្សីម្នាក់ផ្សេងទៀត ថា នៅពេលដែលពួកនិរតីមកដល់ គេយកល្អាងល្ខោនលើកំពូលភ្នំសំពៅ គឺជាកន្លែង សម្លាប់។[1508] សាក្សីម្នាក់និយាយថា ល្អាងល្ខោនត្រូវបានកម្មាភិបាលនិរតីយកមនុស្សទៅ សម្លាប់នៅទីនោះ ក្នុងអំឡុងរយៈពេល ២ (ពីរ) ឬ ៣ (បី) ខែ មុនរបបខ្មែរក្រហមត្រូវបាន ផ្តួលរលំប៉ុណ្ណោះ ពីព្រោះនៅពេលដែលខ្ញុំធ្វើការនៅក្នុងអង្គភាពតម្បាញនៅភ្នំសំពៅនោះ ទីនោះមិនមានកន្លែងសម្លាប់មនុស្សទេ។[1509]

៣៨០. ប្រធាននគរបាលឈ្មោះ អេង ជាអ្នកសម្លាប់មនុស្សនៅលើភ្នំសំពៅ។[1510] ឈ្លបពួកទាហាន ពួកមេៗ ដែលក្តោបប្រជាជននេះឯង ជាអ្នកចាប់មនុស្សយកទៅភ្នំសំពៅ។[1511] សាក្សីម្នាក់ បានឆ្លើយដោយមិនច្បាស់ថា គឺពួកឈ្លប ឬក៏ខាងសន្តិសុខ ប្រហែលមកពីខាងតំបន់ជាអ្នក មកយកមនុស្សទៅ[1512] បាត់ស្ងាត់ឈឹង ដោយមិនដឹងយកទៅណា។[1513] តាមចម្លើយរបស់ សាក្សីម្នាក់ទៀត ពួកនិរតី និងអ្នកដែលនៅក្នុងភូមិនោះដែលចង់ធ្វើមេ និងអ្នកខ្លាចងាប់ ជា អ្នកចាប់ខ្លួនមនុស្ស។[1514]មនុស្សទាំងអស់នោះត្រូវបានគេឃុំនៅផ្ទះក្បែរកន្លែងដែលសាក្សី រស់នៅ ដែលជាអតីតផ្សារភ្នំសំពៅ។[1515] ពាក់កណ្តាលឆ្នាំ១ ៩៧៨ កម្មាភិបាលពាយ័ព្យត្រូវ ចោទថាក្បត់ និងត្រូវចាប់ខ្លួន។[1516] កម្មាភិបាលនិរតីប្រកាសថាពាយ័ព្យក្បត់[1517] ហើយកាន់ តួនាទីជំនួស។[1518] កម្មាភិបាលពាយ័ព្យត្រូវដកតួនាទី ចាប់ខ្លួន ឬបាត់ខ្លួន[1519] ហើយច្រើន នាក់ត្រូវបានដាក់នៅមន្ទីរសន្តិសុខវត្តគិរីរម្យ។[1520] មនុស្សត្រូវបានឃុំនៅក្នុងរូងភ្នំ[1521] រយៈពេល ២ (ពីរ) ទៅ ៣ (បី) ថ្ងៃ ហើយខ្លះត្រូវបានគ្រួសារយកមាសមកលោះអ្នកទោស



E.C.C.C * C.E.T.C * INVESTIGATING JUDGES "CO-JUGES D'IN...

ទៅវិញ ចំណែកអ្នកមិនមានប្រាក់ត្រូវបានសម្លាប់ចោល។[1522] អ្នកទោសមកពីភូមិសំពៅ និងភូមិគោកអំពិល[1523] និងមកពីស្រុកបាណន់[1524] ត្រូវបានចាប់ខ្លួនដោយសារថាឈឺមិនអាចធ្វើការបាន។[1525] តាវ៉ាក់ ជាអ្នកស្រាវជ្រាវក្នុងចំណោមអ្នកមូលដ្ឋាន ហើយចាប់បាន ១០ (ដប់) នាក់ចោទថាមានផែនការចង់ផ្តួលរំលំអង្គការ ដោយសាក្សីបានឃើញតែម្តងគត់ នៅឆ្នាំ ១៩៧៦។[1526]

៣៨១. ព្រះសង្ឃ ១ (មួយ) អង្គមានសង្ឃដីកាថា ពេលដែលអាត្មាបានទៅដល់ព្រះវិហារ អាត្មាឃើញនៅមានបន្ទប់ឃុំឃាំងតូចៗ ហើយមានស្នាមឈាមជាច្រើននៅកន្លែងនោះ។[1527] សាក្សីដែលនៅភ្នំសំពៅនៅខែ ឧសភា ឆ្នាំ ១៩៧៩ ថា នៅលើមាត់រូងនោះមាន ស្នុត បំពង់ទឹក និងដំបងឈើ។[1528]

៣៨២. សាក្សីម្នាក់អះអាងថា មុន និងក្រោយពួកនិរតីមកដល់ មានការសម្លាប់មនុស្សនៅលើភ្នំសំពៅ។[1529] មនុស្សជាច្រើនត្រូវបានសម្លាប់ និងទម្លាក់ចូលល្អាងនៅវត្តគិរីរម្យ។[1530] អ្នកដែលត្រូវបានសម្លាប់ មិនដឹងថាយកមកពីណាខ្លះទេ។[1531] អ្នកដែលត្រូវសម្លាប់ជាទាហាន និងកម្មាភិបាលដែលជំហានទី១ មានបញ្ជីឈ្មោះ ក៏ប៉ុន្តែបន្ទាប់មកអ្នកដែលប្រព្រឹត្តខុសជាទូទៅ នឹងត្រូវបានសម្លាប់។[1532] សាក្សីជាព្រះសង្ឃបានមានសង្ឃដីកាថា អាត្មាឮពីអ្នកភូមិនៅជិតៗនោះប្រាប់អាត្មាថា គេអារកអ្នកទោស ហើយគេយកសាកសពទៅបោះចោលនៅល្អាងចម្ងាយ ២០ (ម្ភៃ) ទៅ ៣០ (សាមសិប) ម៉ែត្រ ពីព្រះវិហារនោះ។[1533] សាក្សីម្នាក់មានឱកាសមើលឃើញខ្មែរក្រហមវះពោះរៀនយកថ្លើម[1534] ដោយបរិយាយថា នៅវិហារគិរីរម្យហ្នឹង កន្លែងឧក្រិដ្ឋកម្មនៅវិហារគិរីរម្យហ្នឹង គេព្យួរក ដាក់ខ្នោះ វះយកថ្លើម ក៏នៅកន្លែងហ្នឹង គឺកន្លែងតែមួយ[1535] ហើយមានទរមួយសម្រាប់ត្រងបង្ហូរឈាមទៅក្នុងបាសាំងធំមួយ។[1536] សាក្សីចុងក្រោយនេះបន្តថា មនុស្សរស់ គេចងខ្សែរពួរ ប៉ុនៗកដៃ ហើយគេព្យួរកផុតជើងពីដីប្រហែលមួយចំអាម មួយខ្សែរបស់គេមានមនុស្ស ៨ (ប្រាំបី) នាក់ ទាំងអស់មាន ៤ (បួន) ខ្សែ។[1537] មនុស្សដែលត្រូវបានគេព្យួរក គឺជាមនុស្សប្រុសទាំងអស់ នៅសល់តែខោខ្លីទេ សម្លៀកបំពាក់ខោអាវវែងគ្មានទេ នៅខាងក្រោមមានជាប់ខ្នោះប្រហែល ៣០ (សាមសិប) ទៅ៤០ (សែសិប) នាក់ទៀត មានស្រី មានប្រុស មានក្មេង មានចាស់ ខាងក្រោមមានគេជាប់ខ្នោះ ៤ (បួន) ជួរ ទល់ខ្នងគ្នា និងទល់ជើងគ្នា ហើយគេដាក់ខ្នោះជើង និងដៃចងស្លាប់សេកទៅក្រោយ។[1538]

៣៨៣. សាក្សីម្នាក់អះអាងដោយផ្អែកលើផ្លឹងនៅក្នុងល្អាងភ្នំគិរីរម្យថា ជនរងគ្រោះមានប្រមាណត្រឹមរាប់រយនាក់។[1539] ក្រោយឆ្នាំ១៩៧៩ មេឃុំគេឱ្យអាត្មាទៅប្រមូលក្បាលខ្មោចនៅវត្តគិរីរម្យយកមកទុកនៅភ្នំសំពៅ នៅល្អាងមួយកន្លែង អាត្មារាប់ឃើញថា មានចំនួនពី ២០ (ម្ភៃ) ទៅ ៣០ (សាមសិប) លលាដ៍ក្បាល តែមានសាកសពនៅតាមល្អាងផ្សេងទៀត។[1540] សាក្សីដែលបានទៅដល់ទីតាំងវត្តគិរីរម្យនៅប្រហែលខែ ឧសភា ឆ្នាំ ១៩៧៩ ឆ្លើយថា នៅល្អាងតែងខ្លួន មានឃើញសពស្លាប់នៅទីនោះ នៅខាងលិចផ្លូវទៅល្អាងតែងខ្លួនបន្តិច បានឃើញសពពីរនាក់ទំនងជាទាហានខ្មែរក្រហម ដោយមានពាក់អាវខ្មៅ និងមួកកាតិប នៅល្អាងកង្កែបមានសពក្មេងចាស់។ នៅល្អាងល្ពៅមានសាកសពដែលត្រូវបានវាយទម្លាក់មក ដោយឃើញសពសុទ្ធតែផ្កាប់មុខ ហើយមានស្នាមបែកក្បាលពីក្រោយ និងទៅក្នុងល្អាងរាងជ្រៅបន្តិចឃើញមានសពច្រើនដែរ។[1541]

៣៨៤. តាមការស៊ើបសួរ ទំនងជាគ្មានអ្នកទោសដែលជាប់ឃុំនៅវត្តនេះនៅរស់នោះទេ។[1542] លើសពីនេះទៀត មិនមានសាក្សីជាកម្មាភិបាលផ្ទាល់ឬផ្ទៃក្នុង។ មានតែសាក្សីតែ ៣ (បី) នាក់តែប៉ុណ្ណោះ ឃើញ (តែប៉ុន្មានដង) ពីចម្ងាយអ្នកយាមមន្ទីរសន្តិសុខបណ្តើរអ្នកទោស[1543] ឬបានឮតៗគ្នាអំពី **តាទិត្យ**។

## ២០. មន្ទីរសន្តិសុខវត្តសម្តេច

៣៨៥. វត្តសម្តេច ស្ថិតក្នុងភូមិសម្តេច[1544] ស្រុកសង្កែ[1545] តំបន់ ៣ នៃរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ។[1546] ផ្ទុយទៅវិញ មានតែសាក្សីម្នាក់ប៉ុណ្ណោះដែលបានឆ្លើយថា វត្តសម្តេច ស្ថិតក្នុងស្រុកសង្កែ តំបន់ ៤។[1547]

៣៨៦. ស្ថិតក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគពាយ័ព្យ វត្តសម្តេចជាមន្ទីរពេទ្យ[1548] ហើយនិរតីនៅតែបន្តយកធ្វើជាមន្ទីរពេទ្យ។[1549] នៅអំឡុងខែវស្សាប្រហែលជាខែ តុលា ឆ្នាំ ១៩៧៧ សាក្សីម្នាក់ធ្លាប់ឈឺ និងបានស្នាក់នៅក្នុងមន្ទីរពេទ្យវត្តសម្តេច។[1550] វត្តសម្តេច ជាមន្ទីរពេទ្យស្រុក។[1551] ប្រហែលខែ មិថុនា ខែ កក្កដា ឆ្នាំ ១៩៧៨ កម្មាភិបាលនិរតីបានប្រើប្រាស់វត្តសម្តេចធ្វើជាកន្លែងឃុំខ្លួន និងសម្លាប់មនុស្ស។[1552] ផ្ទុយទៅវិញ តាមសក្ខីកម្ម



* C.E.T.C * E.C.C.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION *

របស់សាក្សីម្នាក់បានឲ្យដឹងថា ក្នុងខែ តុលា ឆ្នាំ ១៩៧៧ វត្តសម្តេចមានមុខងារជាកន្លែងឃុំឃាំងមនុស្សដែលត្រូវចាប់ ៤០០ (បួនរយ) ទៅ ៥០០ (ប្រាំរយ) នាក់។[1553]

៣៨៧. សាក្សីម្នាក់ទៀតជានិយាយថា អ្នកកាន់កាប់នៅវត្តសម្តេចឈ្មោះ តាងួន។[1554] ចំណែកសាក្សីម្នាក់ទៀតឆ្លើយថា មេកងធំឈ្មោះ សៀ ជាអ្នកគ្រប់គ្រងវត្តសម្តេច។[1555] ហុង ដែលជាប្រពន្ធរបស់ សៀ សុទ្ធតែមកពីភូមិភាគនិរតី ក៏ធ្វើការនៅក្នុងភូមិសម្តេចដែរ។[1556] អ្នកសម្លាប់មនុស្សចំនួន ៥ (ប្រាំ) នាក់ធ្វើការងារពេញម៉ោងនៅទីនោះ[1557] ម្នាក់ក្នុងចំណោមនោះមានឈ្មោះ យ៉ុង។[1558]

៣៨៨. ក្រោមការគ្រប់គ្រងរបស់កម្មាភិបាលនិរតី មនុស្សជាច្រើនមកពីតាមភូមិ និងសហករណ៍ត្រូវបានចាប់ខ្លួនទាំងខ្សែៗ និងបាត់ខ្លួន។[1559] មនុស្សត្រូវយកទៅដាក់ឃុំក្នុងព្រះវិហាររបស់វត្តពេញៗ[1560] ទុករយៈពេល ២ (ពីរ) ទៅ ៣ (បី) ថ្ងៃ មុននឹងត្រូវសម្លាប់។[1561] តាមសក្ខីកម្មរបស់សាក្សីម្នាក់បានឲ្យដឹងថា ក្នុងខែតុលា ឆ្នាំ១៩៧៧ មនុស្សប្រហែលជា ៤០០ (បួនរយ) ទៅ ៥០០ (ប្រាំរយ) នាក់ ជាអតីតមន្ត្រីរដ្ឋសម័យមុន អ្នកដែលលួចរបស់ហូបចុកត្រូវបានចាប់យកទៅវត្តសម្តេច។[1562]

៣៨៩. ២ (ពីរ) ខែ ក្រោយពេលកម្មាភិបាលនិរតីមកដល់ ពួកពាយ័ព្យទាំងអស់ត្រូវបានចាប់ចងយកទៅសម្លាប់ចោល[1563] ក្នុងវត្តសម្តេច[1564] រហូតដល់ឆ្នាំ១៩៧៨។[1565] សាក្សីម្នាក់បានឮកម្មាភិបាលនិរតីនិយាយគ្នាថា មានជនរងគ្រោះប្រហែល ១០០ (មួយរយ) នាក់ ត្រូវបានសម្លាប់ក្នុងនោះមានកុមារផងដែរ[1566] ដោយកូនតូចៗអាយុប្រហែលជា ១២ (ដប់ពីរ) ឬ ១៣ (ដប់បី) ឆ្នាំ ត្រូវមនុស្សធំសម្លាប់។[1567] សាក្សីត្រូវបានប្រពន្ធរបស់ប្រធានសហករណ៍ជួយសង្គ្រោះជីវិត ដោយលុបឈ្មោះចេញពីបញ្ជីអ្នកដែលគេត្រូវយកទៅសម្លាប់។[1568] ក្មេងអាយុប្រហែល ២ (ពីរ) ទៅ ៣ (បី) ឆ្នាំ ត្រូវបានបោះឡើងទៅលើ ហើយយកដាវចាក់ទ្រពីក្រោម[1569] ឬ ត្រូវបោកសម្លាប់។[1570] មនុស្សចាស់ត្រូវបានគេចងទាំងខ្សែៗ យកទៅវាយសម្លាប់ម្តងមួយៗ ដោយវាយនឹងត្បូងចប[1571] ឬ ដោយវាយនឹងភ្លៅរទេះ។[1572] អ្នកខ្លះមិនទាន់ស្លាប់នៅឡើយត្រូវបានគេកប់ទាំងរស់។[1573]

៣៩០. ការសម្លាប់មនុស្សប្រព្រឹត្តទៅ ១ (មួយ) យប់ ២ (ពីរ) ថ្ងៃ[1574] ឬ ១ (មួយ) ថ្ងៃ[1575] ដោយមានរៀបចំដាក់ប៉ុស្តិ៍ត្រួតពិនិត្យបិទទីតាំង[1576] មិនឱ្យនរណាទៅជិតបាន។[1577] ក្រោយសម្លាប់មនុស្សរួច ប៉ុស្តិ៍ត្រួតពិនិត្យត្រូវបានរើចេញ។[1578] រណ្តៅត្រូវបានជីករួចស្រេចមុនពេលសម្លាប់ ហើយខ្មែរក្រហមយកអំបិលទៅចាក់លើសាកសពក្នុងរណ្តៅ[1579] កាលនោះសាក្សីបានធ្លាក់ចូលក្នុងរណ្តៅសាកសពមួយនៅក្នុងវត្តសម្តេច។[1580] ប្រជាជនដែលរស់នៅម្ខាងស្ទឹងអាចស្តាប់ឮសំឡេងស្រែកយ៉ាងច្បាស់នៅពេលដែលគេសម្លាប់មនុស្ស។[1581] សាក្សីម្នាក់ទៀតនិយាយថា មានរណ្តៅ ៣ (បី) ដោយ រណ្តៅនីមួយៗ មានទំហំប្រហែល ជា ៥ (ប្រាំ) ម៉ែត្រ ៤ (បួន) ជ្រុង។[1582]

៣៩១. ផ្ទុយទៅវិញ កាលជំនាន់ពាយ័ព្យ មិនធ្លាប់ឃុំខ្លួនមនុស្ស ឬ សម្លាប់មនុស្សនៅវត្តសម្តេចទេ។[1583] ជំនាន់ពាយ័ព្យ មនុស្ស ៥ (ប្រាំ) ទៅ ១០ (ដប់) នាក់[1584] គ្រូបង្រៀន គ្រូពេទ្យ អ្នកមាន ទាហាន[1585] ត្រូវបានចាប់ចងយកទៅសម្លាប់ជាខ្សែ។[1586] សាក្សីម្នាក់និយាយថា មនុស្សត្រូវបានឃុំខ្លួន និងសម្លាប់ក្នុងខែ តុលា ឆ្នាំ ១៩៧៧[1587] តែមិនដឹងកន្លែងសម្លាប់[1588] ព្រោះកន្លែងសម្លាប់ផ្សេងទៀតមានដូចជា វត្តសំរោង ឬ នៅរកា[1589] ឬ ទីតាំងដទៃនៅក្នុងភូមិសម្តេច។[1590]

៣៩២. ការជម្លៀសក្នុងភូមិសាស្រ្តវត្តសម្តេចកើតឡើងនៅខែ ធ្នូ ឆ្នាំ ១៩៧៨។[1591] ស្ថានភាពរស់នៅជំនាន់ពាយ័ព្យមិនទាន់វេទនាដូចនិរតីមកទេ ព្រោះនៅបបរខាប់នៅឡើយ ពេលនិរតីមកដល់បានវេទនាខ្លាំង។[1592]

## ២១. ឃុំកំពង់ព្រៀង (រួមមាន ភូមិកាច់រទេះ ភូមិថ្មី ភូមិសាលាត្រាវ និងមន្ទីរសន្តិសុខវត្តពោធិ៍លង្កា)

៣៩៣. មន្ទីរសន្តិសុខវត្តពោធិ៍លង្កា ហៅ វត្តកាច់រទេះ[1593] ឬ វត្តដំណាក់រទេះ[1594] មានទីតាំងនៅតាមបណ្តោយផ្លូវជាតិលេខ ៥[1595] ក្នុងបរិវេណនៃភូមិទាំងមូល[1596] នៃភូមិកាច់រទេះ[1597] (អតីតភូមិដំណាក់រទេះ)[1598] ឃុំកំពង់ព្រៀង ស្រុកសង្កែ (ស្រុក៤១)[1599] ខេត្តបាត់ដំបង[1600] ជិតសាលាត្រាវ[1601]។ សាលាត្រាវក៏ជាកន្លែងឃុំឃាំងមនុស្សផងដែរ។[1602] គុកវត្តពោធិ៍លង្កា ឬ គុកវត្តកាច់រទេះ[1603] គឺជាមន្ទីរសន្តិសុខយោធាតំបន់ ៤[1604] សម្រាប់ឃុំឃាំង...



E.C.C.C * C.E.T.C * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

សម្លាប់មនុស្ស។[1605] នៅពេលពួកពាយ័ព្យកាន់កាប់ គុកលាតសន្ធឹងប្រហែល ១ (មួយ) គីឡូម៉ែត្រ ៤ (បួន) ជ្រុង កន្លែងខ្លះមិនមានបាំងជញ្ជាំង[1606] ហើយពេលនិរតីកាន់កាប់ដែល បង្រួមមកនៅក្នុងវត្ត។[1607] មន្ទីរសន្តិសុខវត្តពោធិ៍លង្កា ត្រូវបានបង្កើតឡើងចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ ១៩៧៦ នៅពេលពួកពាយ័ព្យកាន់កាប់ និងបន្តរហូតដល់ពេលនិរតីកាន់កាប់។[1608] ផ្ទុយទៅវិញ សាក្សីពីរនាក់បាននិយាយថា គុកវត្តកាច់រទេះត្រូវបានប្រើប្រាស់ចាប់តាំងពី អំឡុងខែ សីហា ឬ ខែ កញ្ញា ឬ ខែ តុលា ឆ្នាំ ១៩៧៨ រហូតដល់ចុងបញ្ចប់របបខ្មែរ ក្រហម។[1609]

៣៩៤. ផ្ទះដែលស្ថិតនៅជុំវិញវត្ត[1610] ព្រមទាំងព្រះវិហារត្រូវបានប្រើប្រាស់សម្រាប់ឃុំឃាំង មនុស្ស។[1611] កុដិចំនួនប្រហែល ៤ (បួន) ទៅ ៥ (ប្រាំ) ជាកន្លែងសម្រាប់រក្សាទុកថ្នាំរបស់ មន្ទីរសង្គមកិច្ច។[1612] ផ្ទះមួយនៅខាងត្បូងព្រះវិហារ ចម្ងាយប្រហែល ៥០០ (ប្រាំរយ) ម៉ែត្រ ទៅ ១ (មួយ) គីឡូម៉ែត្រគឺជាគុកយោធា ឬ មន្ទីរយោធា តាំងពីសម័យពួកពាយ័ព្យ រហូតដល់ពួកនិរតី។[1613] ទីតាំងសម្លាប់មនុស្សដ៏ធំមួយស្ថិតនៅចំពីក្រោយវត្តនេះ។[1614] រណ្តៅសាកសពស្ថិតនៅខាងត្បូងវត្តក្នុងភូមិកាច់រទេះ។[1615]

៣៩៥. វត្តពោធិ៍លង្កាទំនងជាគ្រប់គ្រងដោយយោធា។[1616] តាឡឹក និងយាយចាន់ គឺជាអ្នកគ្រប់គ្រង ស្រុក ៤១ និងស្រុក ៤២។[1617] ម៉ៅ ជាប្រធានប្រចាំការគុកកាច់រទេះ។[1618] អ្នកទទួលខុស ត្រូវធំជាងគេនៅវត្តកាច់រទេះ និងសាលាត្រាវ ឈ្មោះតាវ៉ន។[1619] តឹក ស៊ឹម ជាអតីតយោធា យាមនៅវត្តពោធិ៍លង្កា។[1620] សាក្សីមិនដែលចូលភូមិកាច់រទេះ ទាំងក្នុងនិងក្រោយរបបខ្មែរ ក្រហម តែបានឮថា ទីនោះជាកន្លែងយោធា និងមន្ទីរសន្តិសុខ។[1621] យោធាជាអ្នកដើរចល័ត មើលប្រជាជនធ្វើការនៅក្នុងភូមិ។[1622] ឆ្នាំ ១៩៧៧ តាយិន ជាកម្មាភិបាលពាយ័ព្យដែលមាន ចរិកសាហាវនៅមន្ទីរសន្តិសុខកាច់រទេះ ត្រូវបានសម្លាប់ដោយពួកនិរតី។[1623]

៣៩៦. ការចាប់មនុស្សយកមកឃុំឃាំងនៅក្នុងវត្តពោធិ៍លង្កា មានតាំងតែពីចុងឆ្នាំ ១៩៧៥ រហូត ដល់ឆ្នាំ១៩៧៩។[1624] សាក្សី ២ (ពីរ) នាក់បានលើកឡើងអំពីការចាប់មនុស្សយកទៅ សាលាត្រាវ។[1625] ក្នុងពេល មិត្តយិន ធ្វើជាមេសន្តិសុខនៅទីនេះ មនុស្សជាច្រើននាក់ដែល គេចាប់មកពីភូមិផ្សេងៗយកទៅសម្លាប់នៅវត្តកាច់រទេះ។[1626] អ្នកភូមិសាលាត្រាវប្រមាណ ៣០ (សាមសិប) នាក់[1627] មានបុរស ស្ត្រី កុមារ និងទាហាន[1628] ត្រូវបានចាប់ខ្លួនយកទៅ



E.C.C.C. CO-INVESTIGATING JUDGES CO-JUGES D'INSTRUCTION

វត្តកាច់រទេះ ដោយសារមូលហេតុ បានប្រព្រឹត្តខុសសីលធម៌[1629] ប្រព្រឹត្តកំហុសតិចតួច[1630] កាច់ស្លាបព្រាអស់មួយ[1631] លួចរបស់ហូប[1632] និងបាត់នង្គ័ល។[1633] អ្នកទោសត្រូវបានដឹកតាមឡានទាំងពេលព្រឹក និងពេលរសៀល។[1634]

៣៩៧. អ្នកទោសត្រូវឃុំខ្លួនប្រហែល ៣ (បី) ទៅ ៥ (ប្រាំ) ខែ។[1635] ពួកគេត្រូវបានវាយធ្វើបាបដោយដំបង ឬ ដែក[1636] ហើយអ្នកទោសធ្ងន់ធ្ងរត្រូវបានដាក់ខ្នោះជើង។[1637] អ្នកជាប់ឃុំឃាំង ២ (ពីរ) នាក់បានស្លាប់នៅក្នុងវត្តពោធិ៍លង្កា។[1638] មានអ្នកទោសម្នាក់រត់ចេញមិនរួច។[1639] ហើយ ១ (មួយ) សប្តាហ៍មុនពេលវៀតណាមចូលដល់មន្ទីរនោះ ខណៈអ្នកទោស ១៥ (ដប់ប្រាំ) នាក់ បានរត់គេចខ្លួនរួច។[1640]

៣៩៨. ពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៧ ប្រជាជនត្រូវបង្ខំឱ្យធ្វើការ។[1641] ឆ្នាំ ១៩៧៧ មនុស្សច្រើនស្លាប់ដោយអត់អាហារនិងខ្វះថ្នាំ។[1642] នៅពេលនិរតីមកដល់ មានប្រជាជនស្លាប់ដោយខ្វះអាហារ ចំណែកនៅមន្ទីរសន្តិសុខ មានសួរចម្លើយនិងដោះលែងអ្នកគ្មានទោស ដែលមិនមានទេក្នុងជំនាន់ពាយ័ព្យ។[1643] ពួកនិរតីចាប់តាយិនដាក់មន្ទីរសន្តិសុខកាច់រទេះ និងសម្លាប់ចោល។[1644]

៣៩៩. មនុស្សត្រូវបានសម្លាប់នៅវត្តពោធិ៍លង្កា។[1645] សាក្សីម្នាក់អះអាងថា ភូមិសាលាត្រាវ ឃុំកំពង់ពៀង ស្រុកសង្កែ ជាកន្លែងដែលសម្លាប់ច្រើនជាងគេ។[1646] អតីតទាហានកងចល័តម្នាក់បានឃើញផ្ទាល់ភ្នែកនូវជនរងគ្រោះពេញៗ ឡានត្រូវបានដឹកពីខាងភូមិភាគបូព៌ាទៅកាន់ទីតាំងនេះរាល់ថ្ងៃ ដែលគ្មាននរណាម្នាក់អាចរស់ជីវិតឡើយ។[1647] ឆ្នាំ ១៩៧៦ សាក្សីបានឃើញមនុស្ស ៣០ (សាមសិប) ទៅ ៤០ (សែសិប) នាក់ ត្រូវសម្លាប់នៅ កាច់រទេះរាល់ថ្ងៃ។[1648] សាក្សីបានឮថា ក្នុងឆ្នាំ ១៩៧៧ ពួកពាយ័ព្យបានរំលោភនារីឈ្មោះ វណ្ណា ហើយសម្លាប់ចោលនៅវត្តកាច់រទេះ។[1649] នៅចន្លោះឆ្នាំ ១៩៧៧ ទៅ ឆ្នាំ ១៩៧៨ សាច់ញាតិសាក្សីត្រូវសម្លាប់នៅកាច់រទេះ។[1650] នារដូវក្តៅក្នុងឆ្នាំ១ ៩៧៨ អ្នករស់រានមានជីវិតម្នាក់ពីគុកនេះបានឃើញផ្ទាល់ភ្នែកនូវការសម្លាប់មនុស្សចំនួន ១៤ (ដប់បួន) ទៅ ១៥ (ដប់ប្រាំ) នាក់ ដែលត្រូវបានវាយចំក្បាលផ្នែកខាងក្រោយដោយប្រើព្រនង់ឈើ។[1651] ចុងឆ្នាំ ១៩៧៨ យោធាពាយ័ព្យ ២ (ពីរ) នាក់ត្រូវបានសម្លាប់[1652] នៅខាងក្រោយវត្តកាច់រទេះ ដោយយោធា ៣ (បី) នាក់ ដែលមានអាវុធ និងចប ដោយវាយលើអ្នកទោសចំកញ្ចឹងក។


* ECCC * CETC * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ក្បាលប្រហែល ២០ (ម្ភៃ) ទៅ ៣០ (សាមសិប) ដង។[1653] សាក្សីនៅក្បែរនោះតែប្រមាណពី ៥០ (ហាសិប) ទៅ ១០០ (មួយរយ) ម៉ែត្រ។[1654] ចុងឆ្នាំ ១៩៧៨ ឬ ដើមឆ្នាំ១៩៧៩ និរតីបានចាប់ពួកពាយ័ព្យ ដោយមូលហេតុពាយ័ព្យធ្វើបាបប្រជាជនខ្លាំងពេក និងមិនឱ្យប្រជាជនហូបគ្រប់គ្រាន់[1655] ហើយពួកនិរតីបានឱ្យប្រជាជនហូបបបរខាប់ជាងពេលពួកពាយ័ព្យគ្រប់គ្រង។[1656] ហេតុដូចនេះហើយ បានជាពួកពាយ័ព្យខ្លះបានរត់រប៉ាត់រប៉ាយ[1657] ខ្លះទៀតត្រូវបានសម្លាប់នៅកាច់រទេះ។[1658] កម្មាភិបាលពាយ័ព្យទាំងគ្រួសារបានបាត់ខ្លួន។[1659] ការសម្លាប់ "បានកើនឡើងយ៉ាងខ្លាំង ចាប់ពីឆ្នាំ ១៩៧៧ រហូតដល់ ឆ្នាំ ១៩៧៩"។[1660] អ្នកទោសត្រូវបញ្ជូនយកទៅសម្លាប់នៅពេលយប់។[1661] មានសាក្សីម្នាក់មិនធ្លាប់ឃើញគេយកអ្នកទោសទៅសម្លាប់ទេ។[1662] សាក្សីត្រូវបានរៀបចំឱ្យរៀបការនៅក្នុងរោងបាយរួមក្នុងភូមិកាច់រទេះ។[1663]

៤០០. សាក្សីដែលចូលទៅវត្តពោធិ៍លង្កាក្រោយរំដោះឆ្នាំ ១៩៧៩ បានឃើញស្នាមឈាមនៅលើជញ្ជាំង។[1664] សាក្សីបានឃើញ រណ្ដៅសម្លាប់មនុស្ស និងការសម្លាប់មនុស្ស ១៤ (ដប់បួន) ទៅ ១៥ (ដប់ប្រាំ) នាក់ ព្រមទាំងសរុបថាអ្នកទោស នៅមន្ទីរនេះមានសរុបចំនួនប្រហែល ៦០នាក់។ ឡុង ហ៊ិន បានជីករណ្ដៅ ឆ្នាំ ១៩៨០ ដល់ឆ្នាំ ១៩៨១ បានប៉ាន់ស្មានថា មានសពប្រហែល ៥.០០០ (ប្រាំពាន់) ទៅ ៧.០០០ (ប្រាំពីរពាន់) នាក់។[1665] តាមការប៉ាន់ស្មានផ្សេងទៀត មានប្រជាជនប្រមាណពី ៥.០០០ (ប្រាំពាន់) នាក់ ទៅ ៧.៥០០ (ប្រាំពីរពាន់ប្រាំរយ) នាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខនេះ។[1666]

៤០១. សាក្សីទាំងអស់មិនបានដឹងឮអំពីវត្តមាន និងបំភ្លឺពាក់ព័ន្ធនឹងឈ្មោះ **តាទិត្យ** ឡើយ។ នៅពេលដែលអ្នកស៊ើបអង្កេតសួរថា តើសាក្សីស្គាល់ឬអត់ សាក្សីបំភ្លឺថា មិនដែលស្គាល់ **តាទិត្យ** នោះទេ។[1667] ក្នុងអំឡុងពួកនិរតីកាន់កាប់ សាក្សីមិនធ្លាប់ឃើញនរណាម្នាក់ត្រូវបាននាំទៅមន្ទីរសន្តិសុខវត្តកាច់រទេះទេ។[1668]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

## ២២. ឃុំវាំងកេសី (រួមមាន វត្តកេសី និងភូមិវាំងកេសី)

៤០២. វត្តវាំងកេសី ស្ថិតនៅភូមិវាំងក្រោល ឃុំវាំងកេសី ស្រុកសង្កែ នៅក្នុងតំបន់ ៤។[1669] ទីតាំងនេះកើតឡើងដោយពួកពាយ័ព្យ ហើយដំណើរការរហូតដល់វៀតណាមចូលដល់។[1670] សហករណ៍វាំងកេសីរួមមាន ទឹកដីឃុំវាំងកេសី និងស្រះកែវ។[1671]

៤០៣. សាក្សីម្នាក់ធ្លាប់ធ្វើការនៅជិតភ្នំធិបតីតំបន់ ១ ជិត ១ (មួយ) ឆ្នាំ ក្រោយខែមេសា ឆ្នាំ ១៩៧៥ ហើយក្រោយមកគាត់បានរស់នៅនិងច្រូតស្រូវនៅការដ្ឋានឡូងតង ការដ្ឋានតាចយ ក្នុងតំបន់ ៤។[1672] គាត់សង្កេតឃើញថា អ្នកធ្វើការជាមួយគ្នាស្លាប់ដោយខ្វះអាហារ ខ្វះថ្នាំ គ្រុន រាកមួល ហើមខ្លួន ទាំងមុន និងក្រោយនិរតីមកដល់។[1673] យោងសាក្សី ២ (ពីរ) នាក់ ការមកដល់របស់និរតីនោះគឺចុងឆ្នាំ ១៩៧៨ ប៉ុន្មានខែមុនរំដោះ ហើយលក្ខខណ្ឌការរស់នៅ និងការងារមិនមានការផ្លាស់ប្តូរ។[1674]

៤០៤. នៅក្នុងជំនាន់ពាយ័ព្យគណៈតំបន់ ៤ ឈ្មោះ តាវ៉ាន់ និង តារ៉ៃ ចំណែកឯ ប្រធានសហករណ៍នៅវាំងកេសីឈ្មោះ ភន់ ។[1675] ប្រធានសហករណ៍ជំនាន់និរតីឆ្នាំ ១៩៧៨ ឈ្មោះរិន។[1676] សាក្សីដែលច្រូតស្រូវនៅការដ្ឋានឡូងតង ការដ្ឋានតាចយ ក្នុងតំបន់៤ សង្កេតឃើញថា កម្មាភិបាលចាស់ឈ្មោះ តយ បានបាត់ខ្លួន ឈ្មោះមឿនរត់គេចខ្លួន ហើយមានឈ្មោះ យឿម ចងកសម្លាប់ខ្លួន។ កម្មាភិបាលនិរតីដែលមកជំនួសជាប្រធានសហករណ៍វាំងក្រោល ឈ្មោះ តាឡឹក យាយចាន់។[1677]

៤០៥. សាក្សីដែលធ្វើគ្រូបង្រៀននៅវាំងកេសីបំភ្លឺថា ពួកពាយ័ព្យសម្លាប់ទាហាន លន់ នល់ នៅដើមឆ្នាំ ១៩៧៧ ។[1678] សាក្សីម្នាក់ដែលច្រូតស្រូវនៅការដ្ឋានក្នុងតំបន់ ៤ បានឮពីកម្មាភិបាលពាយ័ព្យតំបន់ ៤ ប្រាប់ថា កម្មាភិបាលនោះបានចូលរួមប្រជុំកម្មាភិបាលដែលមានការលើកឡើងនូវគោលការណ៍ បើមានខ្មែរក្រោមនឹងយកទៅសម្លាប់ចោល។[1679] សាក្សីនេះក៏បានឮតាមអ្នកដឹកជញ្ជូនខ្មែរក្រោមថា ខ្មែរក្រោមត្រូវយកទៅសម្លាប់នៅភូមិកាច់រទេះ ឃុំកំពង់ព្រៀង។[1680] សាក្សីដដែលបំភ្លឺថា ពេលនិរតីមកដល់មិនមានការសម្លាប់ខ្មែរក្រោមទៀតនោះទេ។[1681] សាក្សីដែលធ្វើគ្រូបង្រៀននៅវាំងកេសីបន្ថែមថា ខ្មែរក្រោមទាំងនោះត្រូវចោទថា



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

យួន ដោយសារមានសម្បុរស ហើយត្រូវបានហៅឡើងឡានទៅសមរភូមិ ដើម្បីបានអាហារ ២ (ពីរ)ពេលតែតាមពិតត្រូវយកទៅសម្លាប់ចោល។[1682]

៤០៦. សាក្សីម្នាក់ដែលធ្វើការនៅការដ្ឋានក្នុងតំបន់ ៤ បំភ្លឺថា មុននិរតីមកដល់ មេក្រុមរបស់គាត់បានហៅគាត់ទៅចូលរួមក្នុងពិធីរៀបការម្តង ២០ (ម្ភៃ) គូ ឃុំវាំងកេសីស្រុកសង្កែតំបន់ ៤។[1683] គាត់មិនបានដឹងថាបុរសស្ត្រីរៀបការនោះពេញចិត្តនឹងគ្នាឬយ៉ាងណានោះទេ តែគាត់ធ្លាប់ឮថា មានការរៀបការដោយបង្ខំ ការបង្ខំឱ្យរស់នៅជាមួយគ្នា និងមានការលែងលះក្រោយមក។[1684]

៤០៧. សាក្សីម្នាក់ដែលបានធ្វើការក្នុងឃុំស្រះកែវនៃសហករណ៍មួយដែលក្តាប់លើឃុំវាំងកេសីផងដែរនោះ បំភ្លឺថា ឆ្នាំ ១៩៧៨ គាត់ផ្ទាល់និងអ្នកដទៃ ពី ៧០ (ចិតសិប) ទៅ ៨០ (ប៉ែត) គូទៀត ត្រូវបានបង្ខំឱ្យរៀបការនៅវត្តវាំងកេសី។[1685] ការរៀបការដោយបង្ខំនេះមានគណៈសហករណ៍នារី និងបុរសជាអ្នកផ្សំផ្គុំ។[1686] យោងតាមសាក្សីម្នាក់ទៀតដែលធ្វើជាគ្រូបង្រៀននៅឃុំវាំងកេសី ស្រុកសង្កែតំបន់ ៤ ប្រធានសហករណ៍ឈ្មោះរិន បានបង្ខំឱ្យរៀបការដូចគ្នាដែរគឺជាមួយបុរសឈ្មោះកាន់ ស៊ើន ក្នុងពិធីដែលមានសរុប ៨៣ (ប៉ែតសិបបី) គូ។[1687] មានការប្រកាសថា សាក្សីនិងអ្នកត្រូវរៀបការ "ត្រូវដើរតាមមាគ៌ារបស់បក្សមិនមានអ្នកណាអាចប្រកែកបានទេ" ហើយមានយោធាដើរស៊ើបការណ៍។[1688]

៤០៨. សាក្សីម្នាក់ដែលធ្លាប់ធ្វើការជាកងចល័តនៅស្រះកែវបានឃើញ តាឡឹកយាយចាន់ ក្នុងសភាពដូចជារត់គេចពីវៀតណាមបានកៀរប្រជាជន ៣០០ (បីរយ) ទៅ ៤០០ (បួនរយ) នាក់ឱ្យទៅប្រជុំហូបនំបញ្ចុកនៅវត្តវាំងកេសី និងបានបាញ់រះប្រជាជន ដែលរត់មិនព្រមទៅប្រជុំមុនពេលវៀតណាមចូលរំដោះ។[1689] ក្នុងនោះ កាន់ ស៊ើន ដែលបានរៀបការជាមួយសាក្សីជាគ្រូបង្រៀននៅវាំងកេសីបានរត់ ហើយត្រូវបាញ់បាក់ភ្លៅហើយអូសយកទៅសម្លាប់ព្រមទាំងមានអ្នកត្រូវរបួសជាច្រើន។ ខ្មែរក្រោមនៅវាំងកេសីត្រូវបានដឹកទាំងឡានៗទៅសម្លាប់ពេលវៀតណាមជិតចូលរំដោះ ប៉ុន្តែមិនដឹងសម្លាប់នៅទីណា យោងតាមបំភ្លឺរបស់សាក្សី។[1690]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * C.C.E.T.C.

៤០៩. សាក្សី ២ (ពីរ) នាក់មិនបានបំភ្លឺពីការពាក់ព័ន្ធរបស់ តាទិត្យ ឡើយ។ នៅពេលអ្នកស៊ើបសួរថា តើធ្លាប់ឮឈ្មោះ តាទិត្យ ទេ សាក្សីឆ្លើយថា មិនធ្លាប់ឮទេ។[1691] សាក្សីម្នាក់ដែលធ្វើជាកងចល័តនៅស្រះកែវធ្លាប់ឮគេៗគ្នាពីមេកងតូចតាចនិយាយក្នុងកងចល័តថា តាទិត្យ ជាកម្មាភិបាលមកពីខេត្តពោធិ៍សាត់ និងកំពង់ឆ្នាំង និងមានយោធា ៣ (បី) នាក់ ដើរតាមរហូត ហើយពេលគាត់ទៅដល់កន្លែងណា គឺតែងតែមានការនាំមនុស្សចេញនិងបាត់ខ្លួន។[1692]

## ២៣. មន្ទីរសន្តិសុខ គុកលេខ ០៨

៤១០. ទីតាំងមន្ទីរសន្តិសុខគុកលេខ ០៨ ឬ មន្ទីរសន្តិសុខក្បាលឈើពុក[1693] (នៅខាងចុងភូមិប៉ែកព្លិសាន)[1694] ត្រូវបានបំភ្លឺដោយសាក្សីមួយចំនួនរបស់ ក.ស.ច.ស ថាស្ថិតនៅភូមិក្បាលឈើពុក[1695] ឃុំស្យា[1696] ស្រុកកណ្ដៀង[1697] ខេត្តពោធិ៍សាត់[1698] ត្រូវជាស្រុកបាកាន (ស្រុក ២២)[1699] តំបន់ ៧[1700] នៃរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ។ សាក្សីម្នាក់អះអាងថា មន្ទីរសន្តិសុខគុក០៨ ស្ថិតនៅក្នុងវត្តបន្ទាយយួន។[1701] គុកលេខ ០៨ ជាអតីតបន្ទាយទាហាន លន់ នល់[1702] និងហ៊ុមព័ទ្ធដោយរបងឫស្សី។[1703] គុកនេះមានអគារធំៗចំនួន ៥ (ប្រាំ) សម្រាប់ដាក់អ្នកទោស ដោយអគារ ១ (មួយ) សម្រាប់កុមារ អគារ ១ (មួយ) សម្រាប់ស្ត្រី អគារ ២ (ពីរ) ទៀតសម្រាប់បុរស និងគុកពិសេស ១ (មួយ) និងមានរោងបាយរួម ១ (មួយ) ព្រមទាំងមានផ្ទះ ១ (មួយ) ខ្នងសម្រាប់កម្មាភិបាលនិងឈ្លប។[1704] មន្ទីរសន្តិសុខគុកលេខ ០៨ ដំណើរការតាំងពីឆ្នាំ ១៩៧៥។[1705] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់អះអាងថា គុកលេខ ០៨ បានដំណើរការពេញមួយរបបខ្មែរក្រហម។[1706]

៤១១. សាក្សីម្នាក់ទៀតបាននិយាយថាឈ្មោះ អាប៉ោង ជាមេគុក០៨[1707] ខណៈដែលសាក្សីម្នាក់ផ្សេងទៀតថា ឈាង ធ្វើការនៅគុកលេខ ០៨។[1708] ដើមបណ្ដឹងម្នាក់ឆ្លើយថា មេគុក ០៨ មុន ឈ្មោះ ហេង និងបន្ទាប់មកឈ្មោះ ជាង។[1709] សាក្សីម្នាក់ឆ្លើយថា មេគុកលេខ ០៨ ជាមនុស្សម្នាក់ដែលសម្លាប់មនុស្ស។[1710]

៤១២. សាក្សី ៣ (បី) នាក់ បានឆ្លើយថា អ្នកទោសជាច្រើនត្រូវបានចាប់យកមកឃុំខ្លួននៅគុកលេខ ០៨។[1711] សាក្សីម្នាក់ដែលរស់នៅម្ខាងស្ទឹងពីមន្ទីរ ០៨ ប្រមាណ ១.០០០ (មួយពាន់) ម៉ែត្រ ឆ្លើយថាមានមនុស្សប្រហែល ២០០ (ពីររយ) នាក់ដែលជាប់ឃុំនៅក្នុងមន្ទីរ ០៨។[1712]

ចំណែកឯសាក្សីម្នាក់មិនដឹងអំពីចំនួនអ្នកជាប់ទោសនៅគុកលេខ ០៨ ទេ។[1713] នៅឆ្នាំ ១៩៧៨ ប្រជាជនស្វាយរៀង ៥០០ (ប្រាំរយ) នាក់ មនុស្សចាស់ កូនក្មេង មនុស្សស្រី និង មនុស្សប្រុសទាំងអស់ដែលត្រូវបានចាប់យកពីស្រុកកណ្ដៀងជាច្រើនដងត្រូវគេចងដៃទៅ ខាងក្រោយខ្នង និងយកទៅដាក់នៅមន្ទីរសន្តិសុខលេខ ០៨។[1714] អ្នកទោសដែលត្រូវជាប់ឃុំ មានដូចជា អ្នកទោសមកពីតំបន់ ៧[1715] អតីតមន្ត្រីសម័យ លន់ នល់[1716] ស្ត្រីដែលជាប្រពន្ធ និងកូនរបស់អតីតទាហាន លន់ នល់[1717] ក្មេងតូចៗ[1718] ស្ត្រីដែលប្ដីរត់គេចខ្លួន[1719] អ្នកលួច ឆក់ប្លន់[1720] ខ្ជិលច្រអូស[1721] អ្នកខុសសីលធម៌[1722] និងអ្នកបះបោរខ្លាំងនៅស្វាយរៀង។[1723]

៤១៣. អ្នកទោសត្រូវដាក់ខ្នោះនៅពេលយប់ ហើយតម្រូវឱ្យធ្វើការរយៈពេល ១១ម៉ោងនៅពេល ថ្ងៃ។[1724] សាក្សីបានអះអាងថា អ្នកទោសត្រូវបានគេបញ្ចេញមកធ្វើការងារនៅខាងក្រៅ ជាមួយពួកគាត់[1725] ដូចជានៅកន្លែងលើកទំនប់[1726] លើកប្រឡាយគ្មានពេលសម្រាក។[1727] អ្នកទោសដែលចេញមកធ្វើការនៅខាងក្រៅគុករងទុក្ខវេទនាណាស់ សូម្បីតែស្បែកកណ្ដុរ នៅក៏ពួកគេហូបដែរ។[1728] អ្នកទោសត្រូវបានអនុញ្ញាតឱ្យដងត្រី តែបើស៊ីនៅកន្លែងងូតទឹក នោះនឹងមិនត្រូវអនុញ្ញាតឱ្យយកទៅហូបនៅកន្លែងគុកលេខ ០៨ ឡើយ។[1729]សាក្សីពីរនាក់ មិនធ្លាប់ឮការរំលោភមនុស្សស្រីនៅគុកលេខ ០៨ នោះទេ។[1730] យោងសក្ខីកម្មរបស់សាក្សី ៤ (បួន) នាក់ បានឱ្យដឹងថា អ្នកទោសស្ត្រីដែលជាប់ឃុំត្រូវបានគេរំលោភសេពសន្ថវៈ។[1731] ការរំលោភ ការកាត់អវៈយវៈ និងយកថ្លើមមនុស្ស ត្រូវបានអ្នកទោសម្នាក់រស់ជីវិតមើល ឃើញផ្ទាល់ភ្នែកទាំងអស់។[1732] សាក្សីម្នាក់ផ្សេងទៀតបានឃើញគេធ្វើបាបមនុស្សនៅក្នុង មន្ទីរ០៨ ដោយកូនឈ្លបអាយុប្រហែល១០ (ដប់) ឆ្នាំ ម្នាក់ យកកញ្ចូថៅ (ផ្លែទំហំប្រហែល ពីរធ្នាប់ម្រាមដៃ) វាយក្បាល អ្នកទោសប្រហែល ២០ (ម្ភៃ) នាក់ ដែលត្រូវឱ្យអង្គុយជាជួរ នោះគ្រប់គ្នា វាយម្នាក់មួយពូថៅ។[1733]

៤១៤. ចំពោះការសម្លាប់វិញ អ្នកស្វាយរៀងត្រូវបានសម្លាប់ចាប់ពីឆ្នាំ ១៩៧៧ ដល់ចប់របប ប៉ុល ពត។[1734] សាក្សីម្នាក់និយាយថា នៅឆ្នាំ១៩៧៨ គឺមានអ្នកមកពីស្វាយរៀងត្រូវបានគេ សម្លាប់នៅក្នុងមន្ទីរសន្តិសុខ ០៨ ដោយពេលខ្លះមានអ្នកទោស ២ (ពីរ) ទៅ ៣ (បី) នាក់ នៅក្នុងក្រុមរបស់ខ្ញុំដែលមកពីស្វាយរៀងត្រូវបានខ្មែរក្រហមហៅចុះពីលើផ្ទះ ហើយបណ្ដើរ យកទៅសម្លាប់នៅក្នុងស្រះជិតនោះ[1735] ដូចជាស្រះត្រឡាច។[1736] អ្នកស្វាយរៀងត្រូវ សម្លាប់អស់ក្រោយឃុំខ្លួនបាន ៣ (បី) យប់[1737] ហើយមានយប់មួយ មនុស្សមួយមន្ទីរត្រូវ



C.O INVESTIGATING JUDGES * E.C.C.C * C.E.T.C * JUGES D'INSTRUCTION

បានសម្លាប់ចោលទាំងអស់។[1738] ប្អូនថ្លៃស្រីរបស់សាក្សីម្នាក់ក៏ត្រូវបានទៅសម្លាប់នៅគុក ០៨។[1739] សមាជិកគ្រួសារចំនួន ៥ (ប្រាំ) នាក់ របស់សាក្សីម្នាក់ទៀតត្រូវបានសម្លាប់នៅគុក០៨។[1740] សាក្សីម្នាក់និយាយថា ជិតដល់ឆ្នាំ១៩៧៩ អ្នកទោសត្រូវបានសម្លាប់ ក្រោយពីត្រូវបានយោធារំលោភនៅក្រោមដើមឈើ។[1741] អ្នកទោសត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខលេខ០៨ ដោយសារហូបមិនឆ្អែតនិងបានលួចបេះ ស្រូវហូប[1742] ក្មេងប្រុសស្រី[1743] អ្នកស្តាប់វិទ្យុប៉ុស្តិ៍អាមេរិកាំង[1744] ឬ ជាសេ.អ៊ី.អា[1745] ហើយក្មេងតូចៗខ្លះក៏បានស្លាប់ដោយសារតែការអត់បាយនៅក្នុងគុក ០៨។[1746] មុនពេលកងទ័ពវៀតណាមចូលមកដល់ប្រហែលជា ១០ (ដប់) ថ្ងៃ ឬ កន្លះខែ អ្នកទោសនៅគុកលេខ ០៨ ប្រហែលជា ៣០០ (បីរយ) នាក់ ទៀតត្រូវបានសម្លាប់។[1747] ពាក់ព័ន្ធនឹងមន្ទីរនេះ សាក្សីបំភ្លឺដូចៗគ្នា អំពីការសម្លាប់ភាគច្រើន ទៅលើប្រជាជនដែលជម្លៀសមកពីបូព៌ា ចន្លោះចុង១៩៧៧ និងឆ្នាំ១៩៧៨ ដោយមិនដឹងពីមូលហេតុនិងការសម្រេច។[1748] សាកសពត្រូវកប់នៅតាមភ្លឺស្រែ។[1749]

៤១៥. សាក្សីម្នាក់គ្រាន់តែបានអះអាងថា មានអ្នករួចរស់ជីវិតពីគុក០៨។[1750] សាក្សីម្នាក់ទៀតមិនដែលបានទៅគុកលេខ០៨ ម្នាក់គ្រាន់តែឮថា គ្មានអ្នកទោសណារួចជីវិតនៅគុកលេខ ០៨ ទេ។[1751] យោងតាម លោក ហង់រី ឡូកា អ្នកទោសដែលនៅសេសសល់ត្រូវបានសម្លាប់ចោល នៅពេលយប់មុនពេលវៀតណាមចូលមកដល់នៅក្នុងខែ មករា ឆ្នាំ ១៩៧៩។[1752]

៤១៦. សាក្សីម្នាក់និយាយថា គាត់មិនអាចស្មានត្រូវអំពីចំនួនអ្នកស្លាប់បានទេ គ្រាន់តែដឹងថាស្លាប់ច្រើន។[1753] មានរណ្តៅនៅកូនភ្នំតូចមួយ នៅមានចម្ងាយប្រហែលជា ៥០០ (ប្រាំរយ) ទៅ ៦០០ (ប្រាំមួយរយ) ម៉ែត្រ ទៅគុកលេខ ០៨ ហើយរណ្តៅធំមួយទៀត គឺមានសាកសពប្រហែល ៣០០ សាកសព នៅខាងជើងគុកលេខ ០៨ ដែលមានចម្ងាយប្រហែលជា ៤០០ (បួនរយ) ម៉ែត្រ ពីគុក។[1754] សាកសពដែលនៅក្នុងរណ្តៅសាកសពដំបូងដែលសាក្សីបាននិយាយនោះជាសាកសពដែលស្លាប់ដោយជំងឺ ឯសាកសពដែលនៅក្នុងរណ្តៅធំនោះ ស្លាប់ដោយសារត្រូវបានគេសម្លាប់។[1755] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ឆ្លើយថា បានឃើញរណ្តៅស្រះត្រឡាចមានសាកសពចំនួនជាង ៧០០ (ប្រាំពីរ)។[1756] សាក្សីម្នាក់ទៀតបានប៉ាន់ស្មានថា មនុស្សរាប់ពាន់នាក់ត្រូវសម្លាប់នៅគុកលេខ ០៨។[1757] ចំណែក ឯសាក្សីម្នាក់ដែលបានរួចជីវិតពីការសម្លាប់នៅគុកលេខ ០៨ បានបំភ្លឺថា មនុស្សប្រមាណខ្ទង់ ២.០០០ (ពីរពាន់) នាក់ ត្រូវបានយកទៅសម្លាប់នៅមន្ទីរសន្តិសុខគុកលេខ ០៨។



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ឬ ក្បាលឈើពុក។[1758] តាមការប៉ាន់ស្មានរបស់លោក ឡង់រី ឡូកា មានប្រជាជនចំនួនពី ៤.០០០ (បួនពាន់) ទៅ ១០.០០០ (មួយម៉ឺន) នាក់ ត្រូវបានសម្លាប់នៅក្នុងមន្ទីរសន្តិសុខនេះ។[1759]

៤១៧. ពាក់ព័ន្ធនឹងមន្ទីរនេះ សាក្សីទាំងអស់មិនបានបំភ្លឺដល់ឈ្មោះ **តាទិត្យ** ទេ។ ក្រោយពេល ក.ស.ច.ស សួរលើកចំឈ្មោះ **តាទិត្យ** សាក្សីទាំងអស់បំភ្លឺថា មិនបានដឹងឮ ឃើញ ឬ ស្គាល់ទេ។

## ២៤. ទីតាំងសម្លាប់មនុស្ស វាលបាក់ជញ្ជើង

៤១៨. វាលបាក់ជញ្ជើង ស្ថិតនៅក្នុង ឃុំស្រែស្តុក[1760] ស្រុកកណ្តៀង[1761] ខេត្តពោធិ៍សាត់[1762] តំបន់ ៧ ភូមិភាគពាយ័ព្យ។[1763] ទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជើងស្ថិតនៅចម្ងាយ ១០ (ដប់) គីឡូម៉ែត្រ ភាគខាងលិចទួលពោធិ៍ជ្រៃ។[1764] វាលបាក់ជញ្ជើងជាវាលដែលមិនមានផ្ទះនោះទេ តែមានបឹងឈូកមួយ[1765] មានទំហំ៨ហិចតា[1766] សម្រាប់នេសាទត្រី។[1767] វាលបាក់ជញ្ជើងនេះនៅជិតទន្លេ ហើយកន្លែងនេះមានរណ្តៅ ១ (មួយ) ដែលមានទំហំប្រហែលជា ៥០ (ហាសិប) ម៉ែត្រ ៤ (បួន) ជ្រុង។[1768]

៤១៩. សាក្សីដែលដឹងតាមរយៈអ្នកជិតខាងបាននិយាយថា ការកាប់សម្លាប់ប្រជាជនភូមិភាគបូព៌ានៅវាលបឹងបាក់ជញ្ជើងចាប់ផ្តើមនៅដើមឆ្នាំ ១៩៧៨ បន្តរហូតមកដល់ឆ្នាំ ១៩៧៩។[1769] មិត្តណុម ជាអ្នកកោះប្រជុំដើម្បីបញ្ជូនមនុស្សទៅវាលបាក់ជញ្ជើង។[1770] ខ្មែរក្រហមប្រើរទេះដើម្បីដឹកមនុស្សយកទៅសម្លាប់។[1771] សាក្សីម្នាក់មិនដឹងថាអ្នកណាជាអ្នកបញ្ជាឱ្យដឹកប្រជាជនបូព៌ាទៅវាលបាក់ជញ្ជើង។[1772]

៤២០. ដំបូងឡើយ ពួកខ្មែរក្រហមដឹកអ្នកស្វាយរៀងទាំងឡានៗ ពីស្វាយរៀងមកដាក់នៅក្រុងពោធិ៍សាត់។[1773] ពួកខ្មែរក្រហមបានកុហកប្រាប់ពួកបូព៌ា ឬអ្នកស្វាយរៀងថា ពួកគេត្រូវទៅធ្វើស្រែ ច្រូតស្រូវ និងធ្វើចម្ការនៅបាក់ជញ្ជើង។[1774] សាក្សីបន្ថែមថា នៅពេលដែលពួកបូព៌ាមកដល់ដំបូង មានអ្នកខ្លះបានធ្វើបាតុកម្មប្រឆាំង ដោយមិនព្រមរស់នៅទីនេះ ហើយពួកគេចង់ត្រឡប់ទៅស្រុកកំណើតរបស់ពួកគេវិញ។[1775] ពួកគេបានដើរពីសហករណ៍[illegible]



INVESTIGATING JUDGES *CO-JUGES D'INSTRUCTION* E.C.C.C * C.E.T.C

ទីរួមខេត្តពោធិ៍សាត់ ប៉ុន្តែ ត្រូវពួកខ្មែរក្រហមចាប់យកទៅបាត់ដោយមិនដឹងយកទៅទីណាទេ។[1776]

៤២១. អ្នកស្វាយរៀងមានទាំងក្មេង ទាំងចាស់ ទាំងប្រុស ទាំងស្រី[1777] ត្រូវបានសម្លាប់នៅវាលបាក់ជញ្ជីង។[1778] ប្រហែលជានៅចុងឆ្នាំ ១៩៧៨ នៅពេលដែលវៀតណាមជិតចូលមកដល់ប្រទេសកម្ពុជា សាក្សីម្នាក់បានឮពួកកងរទេះដែលជាអ្នកដឹកមនុស្សនិយាយគ្នាថា យប់មិញពួកគេដឹកពួកបូព៌ាទៅសម្លាប់នៅវាលបាក់ជញ្ជីង។[1779] សាក្សីពីរនាក់បាននិយាយថា ខ្មែរក្រហមបានប្រើរទេះគោប្រហែលជា ៣០ (សាមសិប) គ្រឿង ដើម្បីដឹកប្រជាជនមកពីតាមសហករណ៍រាប់ពាន់យកទៅសម្លាប់នៅវាលបាក់ជញ្ជីង។[1780] សាក្សីដែលបានចូលរួមដឹកប្រជាជនទាំងនោះ ឆ្លើយថា ការដឹកប្រជាជននោះមានចំនួនបីទៅបួនថ្ងៃទើបអស់។[1781] រទេះគោត្រូវចេញដំណើរចាប់ពីម៉ោងបួនទៀបភ្លឺ រហូតដល់ម៉ោង ១១ (ដប់មួយ) ថ្ងៃត្រង់ទើបទៅដល់វាលបាក់ជញ្ជីង។[1782] សាក្សីបន្តទៀតថា ទាំងគាត់ និងប្រជាជនមិនបានដឹងថាគេដឹកយកទៅសម្លាប់ទេ ព្រោះប្រជាជនមានទឹកមុខ និងនិយាយគ្នាលេងធម្មតានៅលើរទេះ។[1783] ពេលដឹកនោះ មិនមានឈ្លប ឬ យោធាខ្មែរក្រហមអមរទេះទេ ប៉ុន្តែពេលទៅដល់វាលបាក់ជញ្ជីង ទើបមានយោធាខ្មែរក្រហមពួនជាស្រេចនៅក្នុងព្រៃត្បែងក្បែរនោះ។[1784] កងរទេះក៏ឱ្យប្រជាជនចុះដាក់ឥវ៉ាន់ក្បែរនោះ ហើយទាហានខ្មែរក្រហមឱ្យកងរទេះថយក្រោយប្រហែលជា៣០ម៉ែត្រពីកន្លែងប្រជាជនចុះ រួចហើយពួកយោធាខ្មែរក្រហមបណ្តើរប្រជាជនទៅបាញ់សម្លាប់ចម្ងាយប្រហែល ១០០ (មួយរយ) ម៉ែត្រ ពីកន្លែងដែលរទេះឈប់។[1785] សាក្សីបានឃើញពួកខ្មែរក្រហមបាញ់ដោយផ្ទាល់ ខ្លះស្លាប់នៅក្នុងបឹង និងវាលបាក់ជញ្ជីងនោះ។[1786] សាក្សីម្នាក់ទៀតដឹងតាមរយៈអ្នកជិតខាងថា ពួកខ្មែរក្រហមទៅពួនស្ទាក់ដើម្បីបាញ់សម្លាប់ប្រជាជនទាំងនោះនៅវាលបឹងបាក់ជញ្ជីង នៅឆ្នាំ ១៩៧៩។[1787] សាកសពខ្លះមានក្រមាពណ៌ខៀវ[1788] និងមានជាប់ចំណង[1789] ខ្លះត្រូវបានដាក់ក្នុងចូលក្នុងរណ្តៅ ហើយត្រាក់ទំរកាយដីកប់ពីលើ។[1790]

៤២២. ក្រោយរំដោះខេត្តពោធិ៍សាត់បានទាំងស្រុង ប្រហែលនៅខែមីនា ឬខែមេសា សាក្សីម្នាក់បានទៅវាលបាក់ជញ្ជីង ដើម្បីដើររកស្រូវ ហើយបានឃើញសាកសពរលួយជាច្រើននៅទីនោះ។[1791] សាក្សីម្នាក់បានប៉ាន់ប្រមាណចំនួនសាកសពប្រហែលនៅចន្លោះខ្ទង់រយទៅដល់ខ្ទង់មួយពាន់សាកសព។[1792]



* ការិយាល័យសហចៅក្រមស៊ើបអង្កេត * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

៤២៣. មិនមានឯកសារដែលនិយាយពីព័ត៌មានរបស់ តាទិត្យ ទាក់ទងទៅនឹងការគ្រប់គ្រង ឬ បញ្ជា លើ ទីតាំងឧក្រិដ្ឋកម្មនេះទេ។

## ខ. អង្គហេតុមិនដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ

### ១. មន្ទីរសន្តិសុខវត្តសុបិន

៤២៤. វត្តសុបិនមានទីតាំងស្ថិតនៅក្នុងភូមិក្បាលដំរី ឃុំគោកព្រេច ស្រុកគិរីវង់ ខេត្តតាកែវ។[1793] ក្នុងបរិវេណវត្តមានព្រះវិហារ និង សាលាឆាន់ ដែលក្រោយមកត្រូវបានកម្ពុភិបាលកម្ពុជាប្រជាធិបតេយ្យយកធ្វើជាកន្លែងស្តុរអំបែងដបធ្វើអំពូលថ្នាំពេទ្យ និងកន្លែងបោកស្រូវ។[1794] សាក្សីមួយចំនួនអះអាងថាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មន្ទីរសន្តិសុខវត្តសុបិនមិនមែនជាគុកទេ តែជាកន្លែងសម្រាប់ប្រមូលផ្តុំទទួលអ្នកទោសយកមកអប់រំរយៈពេលខ្លី ខណៈដែលអ្នកទោសទាំងអស់នោះត្រូវបានយកទៅសម្លាប់ចោលនៅកន្លែងផ្សេងទៀត។[1795] សាក្សីខ្លះអះអាងវត្តសុបិនជាកន្លែងសម្រាប់ធ្វើការដែរដោយក្នុងនោះមានកន្លែងជួលជុលគ្រឿងយន្តផ្សេងៗ កន្លែងធ្វើស្រែ កន្លែងផលិតចាន ឆ្នាំង ខ្ទះ ផាល ជាដើម។[1796]

៤២៥. សាក្សីម្នាក់បានអះអាងថា គាត់ត្រូវបានគេបញ្ជូនឲ្យទៅធ្វើអំពូលថ្នាំពេទ្យនៅខាងក្នុងវត្តសុបិន ប្រហែលក្នុងឆ្នាំ ១៩៧៦ ឬ ឆ្នាំ ១៩៧៧ ប៉ុន្តែខ្លួនមិនដែលឃើញកន្លែងឃុំឃាំង ហើយក៏មិនធ្លាប់បានដឹងថាមានមនុស្សត្រូវគេឃុំ ឬ បាត់ខ្លួននៅទីនោះដែរ។[1797] វាជាកន្លែងផលិតអំពូលថ្នាំ និងជាកន្លែងធ្វើស្រែប៉ុណ្ណោះ។[1798] អ្នកទោសភាគច្រើនជាអតីតទាហានមេ ១០ ខ្ទង មេ ៥០ ខ្ទង នៅក្នុងរបប លន់ នល់ ត្រូវបានគេចាប់បញ្ជូនទៅវត្តសុបិន។[1799]

៤២៦. ក្នុងអំឡុងចុងឆ្នាំ ១៩៧៥ មានអង្គប្រជុំមួយនៅវត្តសុបិន ដែលមាន យាយបូ ជាគណៈស្រុកគិរីវង់ និងលេខាស្រុកម្នាក់ទៀតបានប្រកាសអំពីចំនួនអ្នកត្រូវចាប់បញ្ជូនមកវត្តសុបិន ប៉ុន្តែ តាទិត្យ ពុំមានវត្តមានក្នុងអង្គប្រជុំនោះទេ។[1800] សាក្សីមួយចំនួនអះអាងថាខ្លួនបានដឹងឮតៗគ្នា ថាតាមរយៈការកោះប្រជុំនៅវត្តសុបិននេះ អតីតទាហាននៃរបប លន់ នល់ត្រូវបានឃុំឃាំងក្នុងព្រះវិហារ មុននឹងយកទៅសម្លាប់ចោលនៅក្នុងព្រៃនៅតាមផ្លូវពីវត្តសុបិនទៅវត្តព្រះធាតុ។[1801] អ្នកទោសត្រូវបានចាប់ចងដៃទៅក្រោយខ្នង និងមានដាក់ស៊ីក...



INVESTIGATING JUDGES "CO-JUGES D'INSTRUCTION" E.C.C.C * C.E.T.C

ប្រឡោះភ្លៀក ដោយក្នុងមួយខ្សែមានប្រហែល ១០ (ដប់) នាក់។[1802] ជាក់ស្តែងមានសាក្សីដែលធ្លាប់ជាអតីតទាហាន លន់ នល់ ហើយដែលនៅមានជីវិតពីព្រឹត្តការណ៍សម្លាប់នោះ បានអះអាងថា ទាហានខ្មែរក្រហមបណ្តើរអ្នកទោសម្តងៗ ១០ (ដប់) នាក់ យកទៅបាញ់សម្លាប់ក្នុងព្រៃហើយគាត់ក៏បានឃើញសាកសពមនុស្សផ្សេងទៀតដែលគេបញ្ជូនមកជាមួយគាត់។[1803] សាកសពទាំងនោះត្រូវបានទម្លាក់ចោលក្នុងអាងនិងត្រូវបានអ្នកភូមិកប់។[1804]

៤២៧. ប៉ុន្តែ មានសាក្សីផ្សេងទៀតដែលបានស្ថិតនៅវត្តសុបិនក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ បញ្ជាក់អះអាងថា នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ មិនមានការកាប់សម្លាប់នៅក្នុងវត្តសុបិនឡើយ។[1805]

៤២៨. មានសាក្សីម្នាក់គត់ដែលត្រូវបានគេបញ្ជូនឲ្យទៅធ្វើអំពូលថ្នាំនៅវត្តសុបិនបានអះអាងថា ធ្លាប់ឃើញ **តា ទិត្យ** ទៅវត្តសុបិនម្តងម្កាលដែរ តែមិនញឹកញាប់ទេ។[1806]

## ២. ទីតាំងសម្លាប់មនុស្សភូមិសោម

៤២៩. ទីតាំងសម្លាប់មនុស្សភូមិសោម ស្ថិតក្នុងឃុំសោម ស្រុកគិរីវង់ ខេត្តតាកែវ។[1807]

៤៣០. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានបញ្ជាក់ថា គាត់បានដឹងឮតៗគ្នាពីព្រឹត្តិការណ៍សម្លាប់ខ្មែរក្រោមប្រមាណ ៦០ (ហុកសិប) នាក់ ដែលបានមកសុំចុះចូលជាមួយពួកខ្មែរក្រហមនៅក្នុងភូមិសោម ប្រហែលអំឡុងឆ្នាំ១៩៧៧ ឬ ឆ្នាំ ១៩៧៨ តែត្រូវបានពួកខ្មែរក្រហមដឹកយកទៅសម្លាប់ទាំងអស់ បន្ទាប់ពីពិធីជប់លៀងស្វាគមន៍ពួកគេរួច។[1808]

៤៣១. នៅក្នុងភូមិសោមមានរណ្តៅបេធំៗចំនួន ៣ (បី) រណ្តៅ មានរាងជារង្វង់ដែលមានអង្កត់ផ្ចិតប្រហែល ៥ (ប្រាំ) ម៉ែត្រ និងជម្រៅ ១,៧ (មួយក្បៀសប្រាំពីរ) ម៉ែត្រ ហើយរណ្តៅទាំងនេះគឺជារណ្តៅកប់សាកសព។[1809] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ខ្លួនបានឮពីប្រជាជនមូលដ្ឋាន ថាខ្មែរក្រោមត្រូវបានសម្លាប់នៅភូមិសោម។[1810]

ក្រោយរបបដួលរលំគាត់បានទៅមើលដាក់ក្នុងរណ្តៅគ្រាប់ទាំង ៣ (បី) ហើយបានអះអាងថាឃើញសាកសពពេញរណ្តៅ។[1811] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដដែលនេះ បានឃើញសាកសព និងក្រណាត់អាវជាច្រើនត្រូវបានគេឃើញនៅពេញក្នុងរណ្តៅទាំងនោះប៉ុន្តែមិនអាចប៉ាន់ស្មានចំនួនសាកសពឡើយ។[1812]

៤៣២. សាក្សីម្នាក់ទៀតឈ្មោះ ម៉ឹង វេត បញ្ជាក់ថា នៅភូមិសោមមិនមានការចាប់ឃុំខ្លួន ធ្វើទារុណកម្ម និងសម្លាប់មនុស្សទេ ដោយសារតែភូមិនេះមានតែកងទ័ពរស់នៅគ្មានប្រជាជនរស់នៅទេ។[1813]

៤៣៣. ក្នុងចំណោមអ្នកដែលផ្តល់ព័ត៌មានទាក់ទងទីតាំងសម្លាប់មនុស្សភូមិសោម មិនមានអ្នកណាម្នាក់ធ្លាប់បានឮ ឬធ្លាប់ស្គាល់ពីឈ្មោះ **យឹម ទិត្យ** ឡើយ។[1814]

## ៣. ការដ្ឋានអន្លង់វល្លិប្រេង និង ទីតាំងសម្លាប់មនុស្សឆ្នាល់មាន់

៤៣៤. ការដ្ឋានអន្លង់វល្លិប្រេង ស្ថិតនៅក្នុងភូមិឫស្សីព្រះ ឃុំឆ្នាល់មាន់ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង តំបន់១ ភូមិភាគពាយ័ព្យ។[1815] បើទោះបីជាមានការលើកឡើងខ្លះហៅថា អន្លង់វល្លិប្រេង និងខ្លះទៀតថា អន្លង់វិលប្រែង ក៏ដោយ ប៉ុន្តែ តាមសក្ខីកម្មសាក្សីថា "*មិនមានទេ អន្លង់វិលប្រែងទេ គឺអន្លង់វល្លិប្រេង*" ទើបជាការត្រឹមត្រូវ។[1816] ជាក់ស្តែង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានការដ្ឋានមួយមានឈ្មោះថា "ការដ្ឋានអន្លង់វល្លិ៍ប្រេង" ស្ថិតនៅក្នុងស្រុកគាស់ក្រឡ។[1817] លើសពីនេះទៀត ទីតាំងអន្លង់វល្លិប្រេងនេះស្ថិតនៅត្រង់ព្រំប្រទល់ធម្មជាតិដែលមានប្រឡាយទឹកមួយនៅ កណ្តាលវាល។[1818] បច្ចុប្បន្ន អតីតការដ្ឋានអន្លង់វល្លិប្រេងត្រូវបានប្រែក្លាយទៅជាវាលស្រែធំល្វឹងល្វើយ។[1819] ការដ្ឋានអន្លង់វល្លិប្រេងនេះ ត្រូវបានដាក់ឱ្យដំណើរការរហូតដល់ពេលដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ។[1820]

៤៣៥. មេភូមិឫស្សីព្រះរួមមានឈ្មោះ ណោម[1821], ប៉ុស[1822], និង ខឹម[1823], រីឯ គណៈសហករណ៍អន្លង់វល្លិប្រេងឈ្មោះ ប៉ោះ។[1824] ក្រុមកម្មាភិបាលនិរតីបានមកដល់ភូមិឫស្សីព្រះនៅពាក់កណ្តាលឆ្នាំ១៩៧៨។[1825]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

៤៣៦. អ្នករស់នៅក្នុងភូមិនានានៅជុំវិញការដ្ឋានអន្លង់វល្លិប្រេង ត្រូវបានគេបង្ខំឱ្យធ្វើការ និងបោះជំរុំស្នាក់នៅកណ្ដាលវាល ដើម្បីធ្វើការប្រមូលផលស្រូវ បោកបែន ច្រកដាក់ការ៉ុង និងធ្វើការចែកចាយស្រូវទៅកាន់ទីតាំងផ្សេងៗ។[1826] នៅការដ្ឋានមានអ្នកធ្វើការងារជាច្រើនដូចជា កងយុវជន កងយុវនារី កងកុមារ និងកងមនុស្សចាស់។[1827] ចំពោះកងយុវជននិងយុវនារីថ្នាក់លើបានដាក់បញ្ជាមកឱ្យធ្វើការតាមកងចល័ត រីឯ កងកុមារត្រូវគេតម្រូវឱ្យដើររើសអាចម៍គោដើម្បីធ្វើជីដាក់ស្រែ ចំណែក ឯចាស់ៗគេឱ្យមើលកូនក្មេងតូចៗ ដែលឪពុកម្ដាយរបស់ពួកគេត្រូវធ្វើការនៅតាមការដ្ឋាន។[1828]

៤៣៧. អន្លង់វល្លិប្រេង ក៏ជាទីតាំងការដ្ឋានធ្វើការងារ ហើយទីកន្លែងនេះពុំត្រូវបានគេប្រើប្រាស់ជាមន្ទីរសន្តិសុខសម្រាប់ធ្វើការឃុំឃាំងខ្លួនមនុស្សនោះទេ។[1829] នៅការដ្ឋាននេះ ពុំឃើញមានការសម្លាប់មនុស្ស។[1830]

៤៣៨. នៅការដ្ឋានអន្លង់វល្លិប្រេង គេតម្រូវឱ្យធ្វើការចាប់ពីម៉ោង ៥ (ប្រាំ) ព្រឹក ដល់ម៉ោង ១១ (ដប់មួយ) ថ្ងៃត្រង់ ទើបបានសម្រាកហូបបាយសម្រាប់ពេលរសៀលត្រូវបន្តពីម៉ោង ១ (មួយ) ដល់ម៉ោង ៥ (ប្រាំ) រសៀល។[1831] ប្រជាជនប្រមាណជា ២០០ (ពីររយ) គ្រួសារត្រូវបានគេចាត់បញ្ជូនឱ្យទៅធ្វើការនៅការដ្ឋានអន្លង់វល្លិប្រេង ដោយមានការរស់នៅលំបាកមែនទែន ព្រោះត្រូវដេកផ្ទាល់ដីតែម្ដង ឬខ្លះក្នុងកូនខ្ទមតូចៗ។[1832] កងកុមារក៏ត្រូវបានគេចាប់បញ្ជូនមកធ្វើការនៅការដ្ឋានអន្លង់វល្លិប្រេងដែរ។[1833] ចំពោះរបបអាហារអ្នកធ្វើការនៅការដ្ឋានអន្លង់វល្លិប្រេង គេចែកបបរឱ្យម្នាក់បាន ២ (ពីរ) ឬ ៣ (បី) វែកប៉ុណ្ណោះ។[1834]

៤៣៩. ការដ្ឋានអន្លង់វល្លិប្រេងត្រូវបានយាមកាមដោយទាហានភូមិភាគនិរតីប្រមាណជា ២០ (ម្ភៃ) នាក់។[1835] គេឃើញមានប្រជាជនដែលធ្វើការនៅការដ្ឋាន មួយចំនួនក៏ត្រូវបានគេចាប់បញ្ជូនយកទៅសម្លាប់នៅកន្លែងសម្លាប់មនុស្សឆ្ពាល់មាន់ ឬពេលខ្លះ បញ្ជូនទៅសម្លាប់នៅមន្ទីរសន្តិសុខគាស់ក្រឡ។[1836] អ្នកដែលធ្វើការនៅការដ្ឋានអន្លង់វល្លិប្រេង ត្រូវតម្រូវឱ្យធ្វើការស្ទើរតែរហូតដល់ការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ ហើយអ្នកទាំងនោះបានឈប់ធ្វើការនៅពេលឮដំណឹងតាមវិទ្យុផ្សាយថា នៅភ្នំពេញត្រូវបានរំដោះ។[1837]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

៤៤០. ទីតាំងសម្លាប់មនុស្សឆ្នាល់មាន់ មានទីតាំងស្ថិតក្នុងបរិវេណសាលារៀនក្នុងឃុំឆ្នាល់មាន់ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង តំបន់ ១ ភូមិភាគពាយ័ព្យ។[1838] អ្នកដែលត្រូវគេយកមកសម្លាប់នៅឆ្នាល់មាន់នេះមានដូចជា ប្រធានកង ថ្នាក់ភូមិ ថ្នាក់ឃុំ និងក្រុមគ្រួសាររបស់អ្នកទាំងនោះជាដើម។[1839] ទីតាំងឈ្មោះថា ឆ្នាល់មាន់ នេះ ពីមុនត្រូវបានប្រជាជនគេហៅថា "ស្នាយមាន់"។[1840]

៤៤១. ប្រជាជនជាច្រើននាក់ ត្រូវបានគេបញ្ជូនយកទៅសម្លាប់ នៅទីតាំងសម្លាប់មនុស្សឆ្នាល់មាន់។[1841] ការចាប់ខ្លួនមនុស្សយកទៅសម្លាប់ឆ្នាល់មាន់មានការកើនឡើងខ្លាំង ក្រោយការមកដល់របស់ក្រុមនិរតី។[1842] ទីកន្លែងសម្លាប់មនុស្សឆ្នាល់មាន់ ត្រូវគេប្រើសម្រាប់តែធ្វើការសម្លាប់មនុស្សភ្លាមៗតែប៉ុណ្ណោះ ហើយមិនមានលក្ខណៈជាមន្ទីរសន្តិសុខ ដើម្បីឃុំឃាំងមនុស្សជាបណ្តោះអាសន្ននៅទីនោះ។[1843] ការសម្លាប់មនុស្សនៅឆ្នាល់មាន់ គេប្រើឧបករណ៍សំខាន់ៗរួមមាន ដំបងដែក ដើម្បីវាយសម្លាប់មនុស្សជាអាទិ៍។[1844] ពេលខ្លះត្រូវគេវាយទម្លាក់រណ្តៅដែលគេជីករួចជាស្រេចក៏មានដែរ។[1845] សាកសពទាំងអស់ដែលមាននៅឆ្នាល់មាន់នេះ មិនសុទ្ធតែត្រូវគេសម្លាប់នៅទីតាំងឆ្នាល់មាន់នេះទេ ប៉ុន្តែ អ្នកទាំងខ្លះបានស្លាប់ដោយអត់អាហារ និងមួយចំនួនទៀតត្រូវស្លាប់ដោយជំងឺ ក៏ត្រូវបានគេយកមកកប់នៅទីតាំងនេះដែរ។[1846] ចំពោះចំនួនអ្នកស្លាប់ ពុំមានប្រភពណាមួយអាចបញ្ជាក់បានឱ្យបានជាក់ច្បាស់លើបញ្ហានេះទេ។

៤៤២. ភស្តុតាងបង្ហាញថា មានរណ្តៅសាកសពជិតស្រែក្បែរបរិវេណសាលារៀន។[1847] សាក្សីម្នាក់បំភ្លឺថា មានរណ្តៅសាកសពច្រើននៅទីតាំងនេះ។[1848] តាមសក្ខីកម្ម សាក្សីឃើញរណ្តៅ ១ (មួយ) ដែលមានសាកសពប្រហែលជា ២០ (ម្ភៃ) នាក់ ក្នុងនោះមានបងស្រីរបស់សាក្សីផងដែរ។[1849] បន្ទាប់ពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ គេឃើញមានរណ្តៅសាកសពច្រើននៅទីកន្លែងសម្លាប់មនុស្សឆ្នាល់មាន់។[1850]

៤៤៣. មានសាក្សីជាច្រើនរូបដែលជាអ្នករស់នៅទាំងការដ្ឋានអន្លង់វល្លិប្រេង ប៉ុន្តែពួកគេមិនបានឮឈ្មោះ **តា ទិត្យ** នោះទេ។[1851]



ECCC CETC CO-INVESTIGATING JUDGES CO-JUGES D'INSTRUCTION

## ៤. មន្ទីរសន្តិសុខបន្ទាយត្រែង

៤៤៤. មន្ទីរសន្តិសុខបន្ទាយត្រែង ស្ថិតនៅក្នុងភូមិគីឡូ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង និងជាផ្នែកមួយរបស់តំបន់១នៃភូមិភាគពាយ័ព្យ។[1852] តាមការប៉ាន់ស្មានមានប្រជាជនចំនួន ៨០០ (ប្រាំបីរយ) នាក់ ទៅ ១.០០០ (មួយពាន់) នាក់ ត្រូវបានសម្លាប់នៅក្នុងទីតាំងនេះ។[1853] ការសម្លាប់ដ៏ខ្លាំងក្លាបំផុតបានកើតឡើង នៅចន្លោះឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៨ ខណៈពេលដែលប្រជាជនមួយចំនួនធំត្រូវបាន "សម្លាប់ដោយ មិនរើសមុខ"។[1854] ទំហំដីនៃវាលពិឃាតនោះមានចំនួន ១០ (ដប់) ហិកតា និងគ្របដណ្តប់ទៅដោយព្រៃឫស្សី ទាំងអស់ដែលត្រូវបានហៅថា ព្រៃឫស្សីសង្កាដែក។[1855] ជនដែលដល់ម្នាក់ដែលនៅរស់រានមានជីវិត នៅឡើយត្រូវបានគេរកឃើញ។[1856]

៤៤៥. សាក្សី នួន មួន បានបញ្ជាក់ថា មន្ទីរនេះដំណើរការ "ប្រហែលនៅដើមឆ្នាំ ១៩៧៧ និយាយរួមបន្ទាយត្រែងជាមន្ទីរសន្តិសុខពេលដែលពួកនិរតីចូលមកដល់"[1857] ពោលគឺមុនពេលជនត្រូវចោទទៅដល់។ សាក្សី ពៅ គឿន អះអាងថា បន្ទាយនេះដំណើរច្រើនឆ្នាំមកហើយរហូតដល់ឆ្នាំ ១៩៧៧ ទើប មេកងពលឈ្មោះ មាស រ៉ែន បានប្រចាំការនៅបន្ទាយត្រែង ត្រូវបានចាប់ខ្លួនយកទៅទួលស្លែង តាមលិខិតរបស់ ប៉ុល ពត ដែលហៅមេកងពល មេកងវរៈសេនាទៅរៀនសូត្រ។[1858] សាក្សី ពៅ គឿន បន្តថា នេះជាផ្នែកមួយនៃការអនុវត្តផែនការបោសសម្អាត។[1859] ដូចនេះហើយបានជាពេល **តាទិត្យ** មកដល់ បានប្រាប់អ្នកចិញ្ចឹមគោ អ្នកធ្វើកប្បាស ឲ្យយកចិត្តទុកដាក់ ព្រោះមេៗទៅរៀតសូត្រអស់ហើយ។[1860] សាក្សីអះអាងថា **តាទិត្យ** និយាយនេះ ក្នុងមុខតំណែងជាគណៈតំបន់ គ្រប់គ្រងភូមិភាគ ក្នុងនោះមានខេត្តបាត់ដំបងផងដែរ។[1861] យើងមិនមានសាក្សីណាបញ្ជាក់បានច្បាស់អំពីការសម្លាប់ និងបាត់ខ្លួនរបស់អ្នកទោស។ ចំណែក សាក្សី នួន មួន ពេលជីករកមាសក្រោយរបបខ្មែរក្រហមបានឃើញសាកសពថ្មីៗ ហើយសន្និដ្ឋានថាមានការសម្លាប់ចុងឆ្នាំ ១៩៧៨។ សាក្សីដដែលនេះ អះអាងថា មានការរើសាកសពទាំងនោះ ហើយប៉ាន់ប្រមាណថា មានសម្លាប់មនុស្ស ៦០០ (ប្រាំមួយរយ) នាក់ មានទាំងក្មេង ហើយមនុស្ស ទាំងនោះប្រហែលត្រូវចងមុនយកទៅសម្លាប់។[1862] តាមភ័ស្តុតាងនិងអង្គហេតុដែលបានស៊ើបក្នុងសំណុំរឿង ០០២ មានតែមន្ត្រីនៃគណៈកម្មាធិការស្រាវជ្រាវអំពើប្រល័យពូជសាសន៍ ឬ មន្ទីរវប្បធម៌ទសវត្សរ៍ ឆ្នាំ ១៩៨០ ទើបអាចបំពេញកិច្ចការរើសនិងប្រមូលសាកសពនេះបាន។[1863] យើងមិនដឹង

សាក្សី នួន មួន នេះ ធ្លាប់មាននាទីនេះប្រយ៉ាងណា។ យើងមិនមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីវិភាគនិងកំណត់រកធាតុអង្គហេតុដែលច្បាប់តម្រូវឱ្យមាននោះបាននៅឡើយ។ ក្នុងនោះផងដែរ ក.ស.ច.ស បានស៊ើបសួរនិងរកមិនឃើញឈ្មោះ ចិន កន្តាល ដែលរបាយការណ៍ឆ្នាំ ១៩៩៨ របស់មជ្ឈមណ្ឌលឯកសារថា ជាអ្នកសម្លាប់នៅបន្ទាយត្រែង។[1864] មិនមានភ័ស្តុតាង ឬ សាក្សីណាបញ្ជាក់ពីការពាក់ព័ន្ធរបស់ជនត្រូវចោទទៅនឹងមន្ទីរសន្តិសុខនេះឡើយ។ សាក្សី នួន មួន បានឃើញជនត្រូវចោទជាលើកដំបូង ក្នុងឋានៈជាលេខាតំបន់១ នៅពេលដែលគាត់ត្រូវបានគេហៅទៅបំពាក់អាវុធនៅក្នុងវត្តត្រែង ដើម្បីទៅវាយវៀតណាម នៅចុងឆ្នាំ ១៩៧៨។[1865]

## ៥. ការដ្ឋានទំនប់ភ្នំត្រជាក់ចិត្ត

៤៤៦. ការដ្ឋានទំនប់ភ្នំត្រជាក់ចិត្តមានទីតាំងស្ថិតនៅភូមិរូង ឃុំព្រៃត្រឡាច ស្រុករុក្ខគិរី ខេត្តបាត់ដំបង។[1866] ការដ្ឋានទំនប់នេះមានទីតាំងនៅក្បែរភ្នំត្រជាក់ចិត្ត[1867] និងមានអូរធំមួយហៅថា អូរត្រជាក់ចិត្ត។[1868] ទីតាំងភ្នំត្រជាក់ចិត្តត្រូវបានហ៊ុមព័ទ្ធដោយព្រៃយ៉ាងក្រាស់ ប្រសិនបើមើលពីចម្ងាយគេឃើញមានដំបូលរោងសង្ក័សីនៅលើភ្នំនោះ[1869] ហើយរោងមួយនេះទុកសម្រាប់ឱ្យអ្នកធ្វើការសម្រាកនៅក្នុងនោះ។[1870] ការដ្ឋានសាងសង់អាងទំនប់ភ្នំត្រជាក់ចិត្តនោះមានទំហំទទឹង ២៥ (ម្ភៃប្រាំ) ម៉ែត្រ បាតទំនប់ ៥០ (ហាសិប) ម៉ែត្រ កម្ពស់ ៥០ (ហាសិប) ម៉ែត្រ និងប្រវែងប្រហែល ៣ (បី) គីឡូម៉ែត្រ។[1871] ទីតាំងនេះមានដំណើរការរហូតដល់ពេលដែលវៀតណាមមកដល់។[1872]

៤៤៧. សាក្សីឈ្មោះ ក្រិប រ៉ុន ធ្លាប់រស់នៅក្នុងកងកុមារត្រៀមធ្វើជាយោធាស្រុកមោង ត្រូវបានពួកកម្មាភិបាលនិរតីកៀរទៅនៅភ្នំត្រជាក់ចិត្ត ក្នុងអំឡុងពេល ៧ (ប្រាំពីរ) ថ្ងៃ មុនពេលដែលវៀតណាមមកដល់នៅដើមឆ្នាំ ១៩៧៩ បានបំភ្លឺថា អ្នកគ្រប់គ្រងនៅភ្នំត្រជាក់ចិត្តឈ្មោះ ហៀង និង ឈ្មោះ ម៉េច ប៉ុន្តែ សាក្សីមិនបានដឹងច្បាស់ថាពួកគេជាអ្នកគ្រប់គ្រងធំជាងគេឬយ៉ាងណា។[1873]

៤៤៨. ការដ្ឋានទំនប់ភ្នំត្រជាក់ចិត្តជាទីតាំងការដ្ឋានការងារដោយបង្ខំ។ នៅភ្នំត្រជាក់ចិត្តការលើក ទំនប់រៀបចំជាអាង ១ (មួយ)។[1874] ប្រជាជនត្រូវបានគេបង្ខំឱ្យចូលរួមក្នុងការងារ...



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

សង់ទំនប់ និងការងារផ្សេងៗទៀត។[1875] អ្នកធ្វើការនៅទីនោះពុំមានសិទ្ធិដើរហើរដោយសេរីទេ ដោយមានកម្មាភិបាលនៅចាំឃ្លាំមើលសកម្មភាព និងគ្រប់គ្រងការងារនៅការដ្ឋានទាំងមូល។[1876]

៤៤៩. គេបែងចែកអ្នកធ្វើការជាកងយុវជនមានទាំងស្ត្រី និងបុរសទទួលបន្ទុកការងារធ្ងន់ៗ និងកងកុមារ[1877] សម្រាប់ធ្វើការងារក្នុងមួយថ្ងៃ ១០ (ដប់) ម៉ោង ដោយបែងចែកជា ៣ (បី) ពេល និងមានទិសដៅការងារ លើកដីឱ្យបាន ៣ ម៉ែត្រគូបក្នុងមួយពេល។[1878] របបអាហារមាន ២ (ពីរ) ដង ក្នុង ១ (មួយ) ថ្ងៃ ប៉ុន្តែមិនមានអាហារហូបគ្រប់គ្រាន់ទេ ដែលការណ៍នេះបណ្តាលឱ្យមានប្រជាជនធ្លាក់ខ្លួនឈឺដោយសារកង្វះអាហារ។[1879] សាក្សីបានធ្វើការប៉ាន់ស្មានថាមានមនុស្សច្រើនជាង ១០០ (មួយរយ) នាក់ បានធ្វើការងារនៅការដ្ឋាននេះ។[1880] ការដ្ឋានទំនប់មិនទាន់បានសាងសង់រួចរាល់ ហើយត្រូវបានបោះបង់ចោលនៅពេលពួកវៀតណាមចូលមកដល់។[1881]

៤៥០. សាក្សីម្នាក់ដែលពួកនិរតីកៀរទៅនៅភ្នំត្រជាក់ចិត្តបាន ៧ (ប្រាំពីរ) ថ្ងៃ មុនពេលវៀតណាមមកដល់ សង្កេតឃើញថាមិនមានការរៀបចំធ្វើការទៀតទេ ដោយសារប្រជាជនរួមទាំងសាក្សីផងនាំគ្នារត់។[1882] ខ្លះរត់ចូលទៅខាងវៀតណាម ខ្លះត្រូវខ្មែរក្រហមឱ្យជញ្ជូនគ្រាប់រត់ឡើងភ្នំ។[1883]

៤៥១. ការបំភ្លឺរបស់សាក្សីជាច្រើនបានឱ្យដឹងថា ពួកកម្មាភិបាលនិរតីបានកៀរប្រជាជនរាប់រយនាក់ពីភ្នំធិបតី និងពីតំបន់ផ្សេងៗទៀត ហើយបញ្ជូនទៅការដ្ឋានទំនប់ភ្នំត្រជាក់ចិត្ត នៅចុងឆ្នាំ ១៩៧៨ មុនពេលវៀតណាមចូលមកដល់។[1884] ប្រជាជនមកពីភូមិកាច់រទេះចំនួនប្រហែល ៧០០ (ប្រាំពីររយ) ទៅ ៨០០ (ប្រាំបីរយ) នាក់ត្រូវបានជម្លៀសមកភ្នំត្រជាក់ចិត្ត ដោយពួកកម្មាភិបាលខ្មែរក្រហមមានគម្រោងរៀបចំសម្លាប់ចោលទាំងអស់ ប៉ុន្តែមានអ្នកខ្លះបានរត់គេចខ្លួនរួច និងមានទាហានវៀតណាមចូលមករំដោះ។[1885] ចំណែកសាក្សីឈ្មោះ ផាន់ យឹម បានបញ្ជាក់ថា ប្រជាជនក្នុងភូមិរបស់ខ្លួនទាំងអស់ត្រូវបានបញ្ជូនទៅភ្នំត្រជាក់ចិត្ត ដោយធ្វើដំណើរថ្មើរជើងរយៈពេលកន្លះខែ។[1886]

៤៥២. សាក្សីឈ្មោះ ផាន់ យឹម ដែលដឹងឮតាមរយៈបុរសម្នាក់ដែលរត់គេចខ្លួនពីភ្នំត្រជាក់ចិត្ត អះអាងបន្ថែមថា មានការរៀបចំគម្រោងរបស់កម្មាភិបាលនិរតីយកប្រជាជនដាក់ក្នុងអាងទំនប់ភ្នំត្រជាក់ចិត្តដើម្បីបំផ្ទុះមីនសម្លាប់ចោល។[1887]

៤៥៣. សាក្សីអះអាងថា ខ្លួនបានឮពីប្រជាជនដែលនៅរស់រានមានជីវិតពីការកាប់សម្លាប់នៅភ្នំត្រជាក់ចិត្តរៀបរាប់ពីវិធីសម្លាប់មនុស្ស។[1888] ដោយកម្មាភិបាលនិរតីប្រាប់ប្រជាជនកៀរមកពីតំបន់ផ្សេងៗឱ្យចូលរួមប្រជុំទទួលផែនការពីអង្គការ ហើយបោះគ្រាប់បែកចូលក្នុងហ្វូងមនុស្សក្នុងពេលប្រជុំ។[1889]

៤៥៤. ក្រៅពីនេះ មានអ្នកធ្វើការនៅការដ្ឋានទំនប់ត្រូវបានគេយកទៅសម្លាប់នៅកន្លែងផ្សេងៗនៅជិតកន្លែងការងារនោះ។[1890] អ្នកទាំងនោះត្រូវបានគេយកទៅសម្លាប់ម្តងៗមានចំនួន ៣ (បី) នាក់ ក្រោមរូបភាពហៅទៅចូលរួមប្រជុំ។[1891] តាមការប៉ាន់ស្មាន មនុស្សប្រហែល ១០០ (មួយរយ) នាក់ត្រូវបានកម្មាភិបាលនិរតីសម្លាប់នៅការដ្ឋានទំនប់ភ្នំត្រជាក់ចិត្តនេះ។[1892] សាក្សីឈ្មោះ ក្រិប រ៉ុន អះអាងថា នៅភ្នំត្រជាក់ចិត្តគាត់ធ្លាប់បានឃើញសាកសពមនុស្សចំនួន ២ (ពីរ) នាក់ នៅក្បែរអាង ប៉ុន្តែសាក្សីមិនធ្លាប់ឃើញការចាប់ខ្លួនឬសម្លាប់មនុស្សដោយផ្ទាល់ឡើយ។[1893] ចំណែកសាក្សីឈ្មោះ មាស ព្រឿង វិញបញ្ជាក់ថា ខ្លួនធ្លាប់ឃើញដោយផ្ទាល់ភ្នែកការសម្លាប់មនុស្សចំនួន ៣ (បី) ដង ដោយពួកឈ្លបក្មេងៗ ហើយមនុស្សភាគច្រើនត្រូវបានសម្លាប់ដោយសារលួចអាហារ ជាអតីតអ្នកធ្វើការ និងទាហានក្នុងរបបចាស់ ជាអាទិ៍។[1894]

៤៥៥. ក្រោយរបបដួលរលំនៅឆ្នាំ ១៩៧៩ មានការប្រទះឃើញសាកសពមនុស្សជាច្រើនតាមផ្លូវទៅភ្នំត្រជាក់ចិត្ត ដោយសាកសពទាំងនោះមិនត្រូវបានគេកប់ទេ[1895] និងមានរណ្តៅសាកសពជាច្រើនទៀត ដែលមានសាកសពប្រហែល ៣០ (សាមសិប) ទៅ ៤០ (សែសិប) នាក់ នៅតំបន់ភ្នំត្រជាក់ចិត្ត។[1896]

៤៥៦. សាក្សីទាំងអស់ដែលបានបំភ្លឺអំពីការដ្ឋានភ្នំត្រជាក់ចិត្តខាងលើ មិនបានលើកឡើងពីឈ្មោះ **តាទិត្យ** ឡើយ។ នៅពេលអ្នកស៊ើបសួរសួរថាស្គាល់ **តាទិត្យ** ឬទេ សាក្សីភាគច្រើនឆ្លើយថា មិនធ្លាប់ឮឈ្មោះនេះទេ។[1897]



ECCC * C.E.T.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

## ៦. ទីតាំងសម្លាប់មនុស្សបន្ទាយអូរតាក្រែ

៤៥៧. ទីតាំងសម្លាប់បន្ទាយអូរតាក្រែ មានទីតាំងស្ថិតនៅភូមិភ្នាវ ឃុំស្ពៅ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង តំបន់ ១ ភូមិភាគពាយ័ព្យ។[1898] ទីតាំងនេះស្ថិតនៅលើទំហំដីប្រមាណជា ២ (ពីរ) ហិចតា នៅតាមមាត់អូរដែលពោរពេញដោយព្រៃឫស្សី។[1899] មុនឆ្នាំ ១៩៧៥ អូរតាក្រែត្រូវបានប្រជាជនយកធ្វើជាកន្លែងបូជាសព ដោយសារទីនោះគឺជាទីទួល។[1900] បន្ទាយអូរតាក្រែបានក្លាយជាទីតាំងសម្លាប់មនុស្ស និងបានដំណើរការរហូតដល់ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។[1901]

៤៥៨. នៅឆ្នាំ១៩៧៧ នៅពេលកងទ័ពបានដឹកមនុស្សទាំងឡានៗមកឈប់តម្រៀបគ្នា ដើម្បីសម្លាប់មនុស្សនៅអូរតាក្រែ សាក្សីឈ្មោះ ពៅ គឿន ដែលលួចឃើញហេតុការណ៍នោះដោយផ្ទាល់ភ្នែកបាននិយាយប្រាប់ថា *"ខ្ញុំបានឃើញគេសម្លាប់មនុស្ស ហើយខ្ញុំស្ទើរតែត្រូវគេសម្លាប់ផងដែរ។ ខ្ញុំឮសំឡេងគេវាយសម្លាប់មនុស្សផូសៗតែម្តង"*។[1902] សាក្សីមួយរូបទៀតក៏បានលួចមើលឃើញដោយផ្ទាល់ភ្នែកដែរថា *"ខ្ញុំឃើញគេយកអ្នកទោសចុះពីលើឡាន ហើយអូសនៅនឹងថ្នល់យកទៅ ខ្ញុំឈប់ឡាន ហើយគេឃើញខ្ញុំ គេបក់ដៃឱ្យខ្ញុំទៅឱ្យផុតទៅ"*។[1903] អ្នកទោសត្រូវបានដឹកតាមឡានយកមកសម្លាប់ទាំងដៃនៅជាប់ចំណង។[1904] អូរតាក្រែជាកន្លែងដែលគេយកមនុស្សមកសម្លាប់តែម្តង ហើយពុំមានទីកន្លែងធ្វើការឬស្នាក់នៅនោះទេ។[1905] អ្នកដែលសម្លាប់មនុស្សនៅអូរតាក្រែមានឈ្មោះ គុយ,ឈ្មោះ អ៊ីត និងអ្នកផ្សេងទៀតមកពីនិរតី។[1906]

៤៥៩. មនុស្សដែលសម្លាប់នៅអូរតាក្រែ ត្រូវបានគេដឹកយកមកពីមន្ទីរសន្តិសុខបន្ទាយត្រែង ដែលមានចម្ងាយពីគ្នាប្រមាណជា ៥ (ប្រាំ) គីឡូម៉ែត្រ។[1907] ម្យ៉ាងទៀត នៅមានការនាំមនុស្សមកពីមន្ទីរកសាងកកោះនៅស្រុកមោងឫស្សី ប៉ៃលិន និងទីកន្លែងផ្សេងៗទៀត យកមកសម្លាប់នៅអូរតាក្រែនេះដែរ។[1908] ការសម្លាប់មនុស្សនៅអូរតាក្រែ ពេលខ្លះគេប្រើគល់ឫស្សីដើម្បីសម្លាប់មនុស្ស។[1909] ជនរងគ្រោះនៅទីតាំងនេះ ភាគច្រើនជាមនុស្សពេញវ័យ នេះបើតាមការប្រមូលឆ្អឹងបានក្រោយការដួលរលំរបប។[1910] មិនតែប៉ុណ្ណោះ ពុំមាននរណាម្នាក់បានរួចជីវិតពីបន្ទាយអូរតាក្រែនេះទេ ដោយហេតុថាគេបានសម្លាប់បង្ហើយតែម្តងនៅមុនពេលរំដោះ។[1911]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

៤៦០. នៅទីតាំងសម្លាប់មនុស្សបន្ទាយអូរតាក្រែ មានរណ្តៅសាកសពប្រមាណជា ៨ (ប្រាំបី) កន្លែង ដោយរណ្តៅនីមួយៗ មានប្រវែងប្រហែលជា ៣ (បី) ម៉ែត្រ គុណ ៤ (បួន) ម៉ែត្រ ដែលអាចដាក់សាកសពបានប្រហែលពី ៤០ (សែសិប) ទៅ ៥០ (ហាសិប) នាក់ ហើយជាក់ស្តែងក្នុងរណ្តៅនីមួយៗពោរពេញទៅដោយឆ្អឹងសាកសព និងសម្លៀកបំពាក់ចាស់ៗ ដែលចម្រុះមានបុរស នារី និងកុមារនៅក្នុងនោះ។[1912]

៤៦១. បន្ទាប់ពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ គេសង្កេតឃើញមានសេសសល់នូវឆ្អឹងសាកសពជាច្រើន នៅទីតាំងសម្លាប់បន្ទាយអូរតាក្រែ។[1913] លើសពីនេះទៀត ក៏មានសេសសល់ដែរនូវរណ្តៅសាកសពចន្លោះពី ១០ (ដប់) ទៅ ៣៥ (សាមសិបប្រាំ) រណ្តៅ នៅបន្ទាយអូរតាក្រែ។[1914] ម្យ៉ាងវិញទៀត សាក្សីសន្និដ្ឋានថាមានសាកសពពី ៤០ (សែសិប) ទៅ ៥០ (ហាសិប) នាក់ នៅក្នុងរណ្តៅ និងនៅខាងក្រៅសរុបគឺមិនតិចជាង ១.៥០០ (មួយពាន់ប្រាំរយ) នាក់ ឡើយ។[1915]

## ៧. ការដ្ឋាន និងមន្ទីរសន្តិសុខទួលម្ទេស

៤៦២. ការដ្ឋាន និងមន្ទីរសន្តិសុខទួលម្ទេស ស្ថិតនៅចម្ងាយ ៣០០ (បីរយ) ម៉ែត្រ ពីប្រឡាយទួលម្ទេស[1916]។ ទួលម្ទេស ឬ សហករណ៍ទួលម្ទេស[1917] មានទីតាំងស្ថិតនៅចន្លោះភ្នំធិបតី និងភូមិកង្ហត[1918] ដោយមានចម្ងាយប្រហែល ១០ (ដប់) គីឡូម៉ែត្រ ខាងលិចភ្នំធិបតី[1919] និងប្រហែល ៤ (បួន) គីឡូម៉ែត្រ ពីភូមិកង្ហត។[1920]

៤៦៣. សហករណ៍ទួលម្ទេសត្រូវបានប្រើប្រាស់ជាការដ្ឋានការងារ និងមន្ទីរសន្តិសុខផងដែរ។[1921] នៅទីនោះមានរោងវែងៗសម្រាប់ពួកកម្មាភិបាលស្នាក់នៅ និងរោងអ្នកទោសធ្វើពីឈើមានជញ្ជាំងធ្វើពីក្តារប្រក់សង្ក័សី ហើយវាត្រូវបានគេចាក់សោរដូចឃ្លាំង មិនមានខ្នោះដាក់អ្នកទោសទេ និងមានឈ្លបយាមនៅខាងក្រៅជាង ២០ (ម្ភៃ) នាក់។[1922] ក្នុងមួយកងមានអ្នកយាមពី ៧ (ប្រាំពីរ) ទៅ ៨ (ប្រាំបី) នាក់ ព្រមទាំងមានរោងបាយវែងៗ រោងវែងគ្មានជញ្ជាំងប្រក់ស្បូវ ឬ ប្រក់ស្លឹកឈើនៅតាមមាត់ប្រឡាយសម្រាប់កងចល័តដែលមកជួយធ្វើការនៅការដ្ឋាន។[1923] ក្រៅពីនេះនៅមានរោងធំមួយសម្រាប់ដាក់ម៉ាស៊ីនជាច្រើន និង[illegible]ប្រេងផងដែរ។[1924] មានទំនប់មួយនៅភ្នំឆាយបល្ល័ង្ក ឬ ភ្នំគយជាផ្នែកមួយរបស់[illegible]



INVESTIGATING JUDGES *CO-JUGES D'INSTRUCTION* E.C.C.C * C.E.T.C

ម្ទេស។[1925] ការដ្ឋានទួលម្ទេសត្រូវបានដាក់ឱ្យដំណើរការរហូតដល់ចុងឆ្នាំ ១៩៧៨ ឬ ដើមឆ្នាំ ១៩៧៩។[1926]

៤៦៤. ការដ្ឋានទួលម្ទេសស្ថិតនៅក្រោមការគ្រប់គ្រងរបស់តំបន់ ១ ហើយសហករណ៍ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឃុំ ស្រុក។[1927] សាក្សីឈ្មោះ រឿង សុភាព ដែលធ្លាប់រស់នៅទួលម្ទេសតាំងពីឆ្នាំ ១៩៧៦ រហូតដល់ចប់របបខ្មែរក្រហម និងសាក្សីផ្សេងៗទៀតដែលធ្លាប់ធ្វើការនៅទួលម្ទេសបានអះអាងថា ថ្នាក់ដឹកនាំនៅទួលម្ទេសមានឈ្មោះ វន ឬ វុន, វ៉ុន និង តាស្រី បន្ទាប់មកឈ្មោះ វ៉ុន ត្រូវបានគេចាប់ខ្លួនក្នុងអំឡុងឆ្នាំ ១៩៧៧ ដោយត្រូវបានគេចោទថាក្បត់ ហើយត្រូវបានជំនួសដោយឈ្មោះ រិន ដែលជាកម្មាភិបាលពាយ័ព្យរហូតដល់ការដួលរលំនៃរបបខ្មែរក្រហម។[1928] សាក្សីផ្សេងទៀតដែលធ្លាប់ធ្វើការនៅការដ្ឋានទួលម្ទេសដែរបានបំភ្លឺថា ឈ្មោះ វន ជាប្រធានគ្រប់គ្រងម្នាក់[1929] និងប្រធានសហករណ៍ទួលម្ទេសម្នាក់ឈ្មោះ យ៉ាន់។[1930]

៤៦៥. សាក្សីឈ្មោះ ទេព សារុន អះអាងថា តាវ៉ាញ ជាលេខាតំបន់ ១ ឧស្សាហ៍មកមើលការដ្ឋានទួលម្ទេសនេះ។[1931] ខណៈសាក្សីផ្សេងទៀតអះអាងថាមិនដែលឃើញកម្មាភិបាលថ្នាក់តំបន់ ឬ ថ្នាក់ស្រុកចុះមកការដ្ឋានទួលម្ទេសម្តងណាឡើយ មានតែកម្មាភិបាលថ្នាក់ស្រុកប៉ុណ្ណោះចុះមកក្នុងភូមិដាក់ផែនការឱ្យកម្មាភិបាលមូលដ្ឋានសម្រុកការងារ។[1932]

៤៦៦. សាក្សីម្នាក់រៀបរាប់ពីការចាប់ខ្លួនមនុស្សមកមន្ទីរសន្តិសុខទួលម្ទេសថា មានការចាប់មនុស្សប្រហែល ៧ (ប្រាំពីរ) ទៅ ៨ (ប្រាំបី) ក្រុម មុនពេលចាប់ក្រុមរបស់គាត់ដែលក្នុងម្តងៗគេចាប់មនុស្សពី ៧ (ប្រាំពីរ) រហូតដល់ ១៥ (ដប់ប្រាំ), ២០ (ម្ភៃ), ឬ ៣០ (សាមសិប) នាក់។[1933] សាក្សីបានបន្ថែមថា ក្រុមគាត់ជាក្រុមទី៨ ឬ ទី៩ ដែលមានមនុស្សប្រហែល ៤៥ (សែសិបប្រាំ) នាក់ រួមទាំងគាត់ផងដែរក៏ត្រូវបានគេចាប់ខ្លួនដែរ។[1934]

៤៦៧. សាក្សីម្នាក់ទៀតបានអះអាងថា គាត់ត្រូវគេចាប់យកទៅឃុំឃាំងនៅទួលម្ទេសអស់រយៈពេល ៣ (បី) ខែ ក្រោយពេលដែលពួកនិរតីបានមកដល់នៅដើមឆ្នាំ ១៩៧៧។[1935] កម្មាភិបាលពាយ័ព្យទាំងអស់ត្រូវបានចាប់ខ្លួនយកទៅដាក់នៅមន្ទីរសន្តិសុខទួលម្ទេស ដោយចោទប្រកាន់ថាជាកាហ្សែបេ ឬ ខ្មែរយួន។[1936] អ្នកទោសទាំងនោះមានទាំងប្រជាជនម្ល...



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

និងភាគច្រើនអ្នកទោសជាកម្មាភិបាលពាយ័ព្យទាំងគ្រួសារ ចាប់តាំងពីថ្នាក់សហករណ៍រហូតដល់ថ្នាក់ស្រុក។[1937]

៤៦៨. សាក្សីឈ្មោះ សុខ ជាតិ ដែលត្រូវបានគេបញ្ជូនទៅទួលម្ទេសនៅក្នុងខែ សីហា ឆ្នាំ ១៩៧៧ រហូតដល់ដើមឆ្នាំ ១៩៧៨ បានលើកឡើងថា នៅទួលម្ទេសមិនមានឃើញមន្ទីរឃុំឃាំង ឬគុកសម្រាប់ដាក់មនុស្សអ្វីទាំងអស់។[1938] ប៉ុន្តែ មនុស្សយ៉ាងតិចពី ៣០ (សាមសិប) ទៅ ៤០ (សែសិប) នាក់ ត្រូវបានឈ្លបបញ្ជូនឱ្យទៅរៀនសូត្រ ដោយមូលហេតុអ្នកទាំងនោះធ្លាប់ធ្វើបាក់ដងរែក រហែកបង្គី បាក់ដងចប និងអ្នកដែលធ្លាប់និយាយតវ៉ា ជាអាទិ៍។[1939]

៤៦៩. នៅការដ្ឋានទួលម្ទេស មានមនុស្សរាប់រយរហូតដល់ខ្ទង់ពាន់នាក់ធ្វើការនៅទីនោះ ហើយជាទូទៅអ្នកទាំងនោះត្រូវបានគេយកមកពីគ្រប់សហករណ៍តំបន់១ និងភាគច្រើនជាកម្មាភិបាលពាយ័ព្យ ដែលនិរតីចាប់បាន។[1940] គេបែងចែងអ្នកធ្វើការជា ២ (ពីរ) ទៅ ៣ (បី) កង ដោយក្នុងមួយកងមាន ១០ (ដប់) ក្រុម ហើយមួយកងមានចំនួនមនុស្សប្រហែលជាង ៣០ (សាមសិប) នាក់ មានទាំងបុរស ស្ត្រី និងកុមារ។[1941]

៤៧០. សាក្សីមួយចំនួនដែលជាប់ឃុំនៅទួលម្ទេស បានអះអាងថាពួកគាត់ត្រូវបានគេចាប់យកបញ្ជូនទៅទួលម្ទេស ហើយបង្ខំឱ្យធ្វើការជាទម្ងន់ដូចជា រំលំដើមឈើ លើកទំនប់ ជីកប្រឡាយ លើកភ្លឺស្រែ ដកសំណាប និងស្ទូងស្រូវ ដោយមានអ្នកយាមនៅជាប់ជានិច្ច ហើយគេឱ្យសម្រាកតែ ២ (ពីរ) ម៉ោងប៉ុណ្ណោះក្នុង ១ (មួយ) ថ្ងៃ។[1942] មិនតែប៉ុណ្ណោះមានការកំណត់ទិសដៅការងារយ៉ាងលំបាក បើធ្វើពុំបានតាមផែនការនឹងត្រូវប្រឈមមុខនឹងការប្រជុំទិតៀន។[1943] ជាក់ស្តែងគេឱ្យអ្នកធ្វើការនៅទីនោះលើកភ្លឺស្រែឱ្យបានកម្ពស់ ១ (មួយ) ម៉ែត្រ ខ្នងភ្លឺស្រែ ១ (មួយ) ម៉ែត្រ និងបាត ១,៥ (មួយក្បៀសប្រាំ) ម៉ែត្រ ដោយក្នុងម្នាក់ៗត្រូវធ្វើឱ្យបានប្រវែង ១០ (ដប់) ម៉ែត្រក្នុងមួយថ្ងៃ[1944] ឬ ត្រូវរំលំ ដើមឈើ ១០ (ដប់) ដើមក្នុង ១ (មួយ) ថ្ងៃ។[1945]

៤៧១. ការងារចាប់ផ្តើមនៅពេលព្រឹកព្រលឹម សម្រាកនៅម៉ោង ១១ (ដប់មួយ) ថ្ងៃត្រង់ និងចាប់ផ្តើមការងារវិញនៅម៉ោង ១ (មួយ) រសៀលរហូតដល់ពេលល្ងាច ព្រមទាំងមានការបោកស្រូវរហូតដល់ម៉ោង ១ (មួយ) យប់ផងដែរ។[1946] របបអាហារមិនមានគ្រប់គ្រាន់

ឡើយ ហើយត្រូវផ្ដល់ឲ្យ ២ (ពីរ) ពេលក្នុង ១ (មួយ) ថ្ងៃ ជាបបរជាមួយសម្លត្រកួន ឬ ស្លឹកឈើស្ងួជាមួយអំបិលតែប៉ុណ្ណោះ ដែលបណ្ដាលឲ្យមានអ្នកឈឺ និងស្លាប់ជាច្រើន។[1947]

៤៧២. សាក្សីម្នាក់ដែលធ្វើការជីកសំណាបពីទួលម្ទេសដាក់តាមស្រែបានបំភ្លឺថា ការងារមិនសូវលំបាក តែមានយោធាមកពិនិត្យ ហើយប្រើដំបង ឬ រំពាត់វាយអ្នកធ្វើការយឺតយ៉ាវ។[1948] សាក្សីម្នាក់ដែលធ្លាប់ធ្វើការនៅទួលម្ទេស ក្នុងរដូវវស្សា ឆ្នាំ ១៩៧៧ បានបំភ្លឺថា អ្នកធ្វើការនៅទីនោះពុំមានបាត់ខ្លួនទេ តែគាត់បានឃើញពីរដង គេយកមនុស្សប្លែកៗ ហើយគេឲ្យកិនស្រូវដោយមានការយាមផង ក្នុងម្ដងៗមានមនុស្ស ៤ (បួន) ឬ ១០ (ដប់) នាក់។[1949] ក្រោយមកទៀត គាត់បានឃើញរណ្ដៅថ្មីដែលគេកប់នៅជិតការដ្ឋាននោះ។[1950] សាក្សីម្នាក់ទៀតដែលធ្លាប់ជាប់ឃុំនៅទួលម្ទេស អះអាងថាកម្មាភិបាលពាយ័ព្យដែលជាប់ឃុំឃាំងជាមួយខ្លួន បាត់ខ្លួនពីរឬបីនាក់ជារៀងរាល់ថ្ងៃ តាំងពីចំនួនមនុស្សជាង ១០០ (មួយរយ) នាក់ មកនៅត្រឹមចំនួនមនុស្ស ៣០ (សាមសិប) នាក់។[1951]

៤៧៣. ចំពោះប្រជាជន អតីតកម្មាភិបាលថ្នាក់សហករណ៍ ថ្នាក់ស្រុក និងយោធាភូមិភាគពាយ័ព្យដែលត្រូវបានគេចាប់ខ្លួន ត្រូវបានគេហៅមករោងបាយឲ្យហូបបបរ ដោយមានពួកឈ្លប ៥ (ប្រាំ) ទៅ ៦ (ប្រាំមួយ) នាក់ ពន្យល់ប្រាប់ឲ្យទៅធ្វើការកន្លែងការដ្ឋានការងារផ្សេងៗ[1952] ដូចជាទៅកាប់អំពៅនៅដូនត្រីក ក្បាលស្ទឹងសង្កែ ក្បែរព្រំដែនខ្មែរថៃ នៅកោះ ជាដើម ហើយក៏បាត់ខ្លួនរហូតជួនកាល ៤ (បួន) ទៅ ៥ (ប្រាំ) ថ្ងៃ បន្ទាប់មក មានសាកសពមនុស្ស ៩ (ប្រាំបួន) ទៅ ១០ (ដប់) នាក់ ត្រូវបានគេឃើញទៅតាមព្រៃ និងត្រពាំង។[1953]

៤៧៤. ភស្តុតាងបានបង្ហាញថា នៅក្នុងអំឡុងឆ្នាំ ១៩៧៨ ក្រោយពេលពួកកម្មាភិបាលនិរតីចូលមកគ្រប់គ្រងបាន ១ (មួយ) ឆ្នាំ មានការកាប់សម្លាប់ខ្លាំងលើពួកយោធាពាយ័ព្យច្រើនជាងប្រជាជនធម្មតា ដោយពួកនិរតីចាត់ទុកកម្មាភិបាលចាស់ទាំងអស់នោះជាខ្មាំងរបស់អង្គការ។[1954] សាក្សីម្នាក់បានអះអាងថា គាត់ និងមិត្តភក្តិផ្សេងទៀតបានចូលរួមប្រជុំនៅទីនោះដែលការប្រជុំនោះគេមានគម្រោងសម្លាប់អ្នកដែលទៅចូលរួម។[1955] សាក្សីបានរៀបរាប់ថា នៅពេលនោះ គេជីករណ្ដៅរួចហើយ រួចគេឲ្យអ្នកចូលរួមហូបនំបញ្ចុកក្នុងរណ្ដៅនោះ។ ដល់យប់ឡើង ពួកគាត់បាននាំគ្នារត់មកខ្ទង់គូ តែត្រូវពួកយោធាឃើញ ហើយដេញបាញ់សម្លាប់ប្រុសៗអស់ ៤ (បួន) នាក់។[1956] សាក្សីផ្សេងទៀតអះអាងថាគាត់បាន



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ឃើញដោយផ្ទាល់ភ្នែកចំពោះការចាប់ខ្លួនកម្មាភិបាលពាយ័ព្យ ហើយគាត់សន្និដ្ឋានថាពួកគេត្រូវបានសម្លាប់ ដោយសារគាត់មិនដែលឃើញពួកគេទាំងនោះបានត្រឡប់មកវិញទេ។[1957]

៤៧៥. សាក្សីឈ្មោះ យ៉េត យឿន ជាមេកងអនុសេនាតូចក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៦ ហើយក្រោយមកនៅឆ្នាំ ១៩៧៨[1958] ត្រូវបានគេជ្រើសរើសឱ្យធ្វើជាមេកងអនុសេនាតូចនៅទួលម្ទេសម្តងទៀត បានអះអាងថា បានឃើញសាកសពប្រហែល ១០ (ដប់) នាក់ ដែលជាមនុស្សប្រុសពេញវ័យរៀបការ និងជាខ្មែរសុទ្ធ និងខ្មែរកាត់ចិន នារដូវប្រាំងប្រហែលជាក្នុងអំឡុងខែ មេសា ឬ ខែ ឧសភា ឆ្នាំ ១៩៧៧ ដោយកាលនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្មាភិបាលពាយ័ព្យនៅឡើយ។[1959] សាកសពទាំងនោះពុំមានជាប់ចំណងទេ ប៉ុន្តែគាត់សន្និដ្ឋានថា មនុស្សទាំងនោះប្រាកដជាត្រូវបានចង មុនពេលពួកគេត្រូវបានសម្លាប់។[1960]

៤៧៦. សាក្សីម្នាក់ទៀតបានសន្និដ្ឋានថា មានមនុស្សនៅទួលម្ទេសប្រហែល ៨០០ (ប្រាំបីរយ) នាក់ បានបាត់ខ្លួននៅការដ្ឋាននិងមន្ទីរសន្តិសុខទួលម្ទេសក្នុងអំឡុងពេលរបបខ្មែរក្រហម។[1961]

៤៧៧. សាក្សីឈ្មោះ សៅ ជាប់ បានអះអាងថា នៅក្នុងឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៧ **យឹម ទិត្យ** បានចុះមកមើលការដ្ឋានទួលម្ទេស។[1962] គាត់បានបន្ថែមថា **យឹម ទិត្យ** មកពិនិត្យមើលគេធ្វើការដ្ឋាន ធ្វើស្រែចម្ការ និងលើកទំនប់។[1963] សាក្សីម្នាក់ទៀតដែលត្រូវបានបញ្ជូនទៅធ្វើការនៅទួលម្ទេសនៅឆ្នាំ ១៩៧៨ បានអះអាងថា ធ្លាប់បានជួបជាមួយ **យឹម ទិត្យ** នៅពេលគាត់ចូលរួមកិច្ចប្រជុំមួយមុនពេលវៀតណាមមកដល់[1964] នៅពេលប្រជុំនោះ **យឹម ទិត្យ** និយាយប្រាប់ប្រជាជនត្រូវខំធ្វើស្រែឱ្យបានផល ដើម្បីឱ្យខាងយោធាបានហូប ហើយប្រាប់ប្រជាជនឱ្យប្រយ័ត្នជាមួយខ្មាំងយួន។[1965]

៤៧៨. សាក្សីម្នាក់ដែលត្រូវបានបញ្ជូនទៅការដ្ឋានទួលម្ទេសនៅក្នុងអំឡុងខែ សីហា ឆ្នាំ ១៩៧៧ រហូតដល់ដើមឆ្នាំ ១៩៧៨ បានបំភ្លឺថា **តាទិត្យ** ចូលទៅគ្រប់គ្រងនៅទីនោះក្នុងឆ្នាំ១៩៧៧[1966] ហើយខ្លួនគាត់ក៏ធ្លាប់បានជួប **យឹម ទិត្យ** នៅក្នុងកិច្ចប្រជុំមួយនៅបាណន់នៅចុងឆ្នាំ ១៩៧៧។[1967] ក្រោយមកនៅទួលម្ទេសមានការយកមនុស្សប្រមាណ ១០ (ដប់) នាក់ ទៅរៀនសូត្ររាល់ ២ (ពីរ) ឬ ៣ (បី) ថ្ងៃ ម្តង ហើយក៏បាត់ខ្លួនទៅ។[1968]



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

៤៧៩. ទោះជាយ៉ាងនេះក៏ដោយ មានភ័ស្តុតាងផ្សេងៗទៀតបង្ហាញថា **យឹម ទិត្យ** មិនមានវត្តមាននៅទួលម្ទេសទេ។ ជាក់ស្តែងសាក្សីជាច្រើននាក់ដែលបានរស់នៅ និងធ្វើការនៅសហករណ៍ទួលម្ទេសរហូតដល់ចប់របបខ្មែរក្រហមក៏អះអាងថាមិនដែលឃើញ មិនដែលស្គាល់ ឬ ឮពី **តាទិត្យ** ទៅពិនិត្យនៅទួលម្ទេសទេ។[1969] សាក្សីម្នាក់ដែលបានគេបញ្ជូនទៅធ្វើស្រែនៅចម្ងាយ ២ (ពីរ) គីឡូម៉ែត្រ ពីទួលម្ទេស ប្រហែលពីខែ ឧសភា ឬ ខែ មិថុនា ឆ្នាំ ១៩៧៧ រហូតដល់ឆ្នាំ ១៩៧៩[1970] ក៏បានបញ្ជាក់ថា មិនស្គាល់ **តាទិត្យ** ដែរ។[1971] ចំណែកសាក្សីឈ្មោះ នួន មួន បានកាន់តួនាទីជំនួយការតំបន់ ១ ជំនាន់កម្មាភិបាលពាយ័ព្យគ្រប់គ្រងហើយត្រូវបានយកមកដាក់នៅទួលម្ទេសពេលនិរតីមកដល់បានបំភ្លឺថា មិនដែលឮឈ្មោះ **តាទិត្យ** នៅទួលម្ទេសឡើយ។[1972] សាក្សីម្នាក់ដែលបានធ្វើការដឹកសំណាបពីទួលម្ទេសដាក់តាមស្រែបានបំភ្លឺថាធ្លាប់ឮឈ្មោះ **តាទិត្យ** តែមិនដែលឃើញមុខឡើយ។[1973]

## ៨. ទួលអណ្តែត

៤៨០. វត្តទួលអណ្តែត មានទីតាំងស្ថិតនៅក្នុងភូមិដូង ឃុំចែងមានជ័យ ស្រុកបាណន់ ខេត្តបាត់ដំបង។[1974] សាក្សីបានបំភ្លឺថា វត្តទួលអណ្តែតនេះមានចម្ងាយប្រហែល ៣០០ (បីរយ) ទៅ ៤០០ (បួនរយ) ម៉ែត្រពីការដ្ឋានទំនប់កង្ហត។[1975] វត្តទួលអណ្តែតជាទីតាំងសម្រាប់ឃុំឃាំងនិងជាទីតាំងសម្លាប់មនុស្ស។[1976] ប៉ុន្តែមានសាក្សីអះអាងថាវត្តទួលអណ្តែតមិនមែនជាមន្ទីរសន្តិសុខ ឬ គុក ឬ មន្ទីរឃុំឃាំងទេ។[1977] វាជាកន្លែងសម្រាប់ទុកដាក់ឡាន និងគ្រឿងចក្រផ្សេងៗ ដែលខូចនៅទំនប់កង្ហតសម្រាប់ជួសជុល ហើយពេលខ្លះវាជាកន្លែងដាក់មនុស្សបណ្តោះអាសន្នផងដែរ។[1978]

៤៨១. បរិវេណវត្តទួលអណ្តែតមានទីធ្លាទំហំប្រហែល ១ (មួយ) ហិចតា មានអគារ ១ (មួយ) សម្រាប់ដាក់គ្រឿងម៉ាស៊ីន ហើយនៅចម្ងាយប្រហែល ២០ (ម្ភៃ) ម៉ែត្រពីអគារនោះ មានអគារឈើប្រក់ដំបូលស័ង្កសីគ្មានបង្អួច ទំហំ ៦ (ប្រាំមួយ) ម៉ែត្រ គុណនឹង ៨ (ប្រាំបី) ម៉ែត្រសម្រាប់ឃុំឃាំងអ្នកទោសធ្ងន់។[1979] នៅចម្ងាយប្រហែល ៣០ (សាមសិប) ម៉ែត្រពីអគារឈើនេះ មានអគារគ្មានជញ្ជាំង ១ (មួយ) ប៉ុន្តែមានអ្នកយាមកាមសម្រាប់ឃុំឃាំងអ្នកទោសស្រាល។[1980] ទីតាំងវត្តទួលអណ្តែតនេះបានដំណើរការរហូតដល់ពេលកងទ័ពវៀតណាមមកដល់។[1981]



C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៤៨២. សាក្សីឈ្មោះ ឆាំ លុយ ដែលធ្លាប់ជាប់ឃុំនៅវត្តទួលអណ្តែតអះអាងថា អ្នកគ្រប់គ្រងវត្តទួលណ្តែតមានឈ្មោះ តានីម និងមានយោធាប្រដាប់ដោយកាំភ្លើងអាកា និងបេ៤០ នៅយាមកាមជុំវិញទីនោះ។[1982] សាក្សីម្នាក់ទៀតឈ្មោះ កៅ ពន អះអាងថា បានជួប តានីម ម្តងនៅទួលអណ្តែត ហើយតា នីម ជាអ្នកបញ្ជាឱ្យសាក្សីកាន់កាំភ្លើង។[1983]

៤៨៣. ប្រជាជនជាច្រើនបានបាត់ខ្លួនពីក្នុងភូមិ ដោយសារគេចាប់បញ្ជូនអ្នកទាំងនោះយកទៅឃុំឃាំងនៅវត្តទួលអណ្តែត ក្រោមការចោទប្រកាន់ថាជាពួកក្បត់ ឬ ជាខ្មែរយួន។[1984] យោធាធ្វើការចាប់ខ្លួនមនុស្សទាំងគ្រួសារៗ ហើយដឹកអ្នកទោសតាមឡានទ្រុង ដោយម្តងៗមានចំនួនមនុស្សពី ២០ (ម្ភៃ) ទៅ ៤០ (សែសិប) នាក់។[1985] សាក្សីឈ្មោះ ឆាំ លុយ ដែលត្រូវបានគេចាប់ខ្លួននៅពេលនោះ បានអះអាងថាពេលទៅដល់មន្ទីរសន្តិសុខនោះគេបែងចែកអ្នកទោសជាពីរក្រុម ដោយធ្វើការជ្រើសរើសអ្នកទោសមួយចំនួនដែលត្រូវយកទៅបាញ់សម្លាប់ចោលភ្លាមៗ ដោយសារមនុស្សទាំងនោះមានព័ត៌មានច្បាស់លាស់ទាក់ទងនឹងខ្មែរយួន រីឯអ្នកទោសដែលគេពុំទាន់យកទៅសម្លាប់ភ្លាម គេឃុំនៅកន្លែងផ្សេងមួយទៀតដែលមានចម្ងាយប្រហែល ៣០ (សាមសិប) ម៉ែត្រពីអគារនោះ ដើម្បីទុកប្រមូលព័ត៌មានច្បាស់លាស់សិន។[1986] សាក្សីឈ្មោះ ឈន ប៊ា អះអាងថា បងប្អូនជីដូនមួយរបស់គាត់ព្រមទាំងប្រពន្ធ និងម្តាយត្រូវបានគេចាប់យកទៅឃុំឃាំងនៅវត្តទួលអណ្តែត។[1987]

៤៨៤. សាក្សីមិនបានឃើញការសម្លាប់ដោយផ្ទាល់ភ្នែក តែបានឃើញយោធាបណ្តើរអ្នកទោសទៅសម្លាប់នៅពេលព្រលប់[1988] និងបានឮសម្លេងរបស់ជនរងគ្រោះដែលគេជ្រើសរើសយកទៅសម្លាប់ចំនួនប្រហែលជាង ២០ (ម្ភៃ) នាក់ រួមទាំងកូនក្មេងផង ចំណែកអ្នកទោសនៅសល់ខ្លះត្រូវបញ្ជូនទៅកាន់ភ្នំធិបតី និងខ្លះទៀតត្រូវគេបាញ់សម្លាប់ចោល។[1989]

៤៨៥. សាក្សីឈ្មោះ ឈន ប៊ា ប៉ាន់ស្មានថាមានចំនួនមនុស្សដែលត្រូវបានគេសម្លាប់នៅវត្តទួលអណ្តែតចំនួនលើសពី ១០០ (មួយរយ) នាក់ ។[1990] ចំណែកសាក្សីឈ្មោះ ឆាំ លុយ អះអាងថាក្រោមការគ្រប់គ្រងរបស់ តា នីម នៅវត្តទួលអណ្តែត បងប្អូនរបស់សាក្សី និងប្រជាជនជាច្រើននាក់នៅក្នុងតំបន់ត្រូវបានយកទៅសម្លាប់។[1991]



C.C.C * C.E.T.C * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៤៨៦. សាក្សីសន្និដ្ឋានថា ដោយសារ តាទិត្យ ជាលេខាតំបន់ ១ គាត់ជាអ្នកបញ្ជាឱ្យសម្លាប់មនុស្ស ហើយ តានីម ដែលអ្នកនិរតី និងជាកូនចៅរបស់ តាទិត្យ ក៏បានសម្លាប់មនុស្សនៅតំបន់ ១ ច្រើនដែរ ដោយចោទថាទាក់ទងនឹងវៀតណាម។[1992] សាក្សីក៏ជឿជាក់ថា តាទិត្យ បានធ្វើដំណើរឡើងចុះទៅកាន់មន្ទីររបស់ តានីម នៅវត្តទួលអណ្តែត ប៉ុន្តែសាក្សីមិនដែលបានឃើញការធ្វើដំណើរមកវត្តទួលអណ្តែតរបស់ តាទិត្យ ដោយផ្ទាល់ភ្នែក ហើយក៏មិនដែលជួបនឹង តាទិត្យ ឡើយ។[1993]

## ៩. ក្រឡឹងដុំ

៤៨៧. ក្រឡឹងដុំ ជាទីតាំងការដ្ឋានស្ថិតនៅក្នុងភូមិសាស្ត្រតំបន់ ១ នៃរបបកម្ពុជាប្រជាធិបតេយ្យ។ ការដ្ឋានក្រឡឹងដុំនេះស្ថិតនៅតំបន់វាលស្រែ មានចម្ងាយប្រហែល ២ (ពីរ) ទៅ ៤ (បួន) គីឡូម៉ែត្រខាងកើតទំនប់កង្កួត[1994] និងស្ថិតនៅជាប់នឹងការដ្ឋានទួលម្ទេស។[1995] មាប្រឡាយ ១ (មួយ) លាតសន្ធឹងពីកង្កួត ហើយឆ្លងកាត់ក្រឡឹងដុំ។[1996] ការដ្ឋាននេះបានចាប់ផ្តើម និងបន្តដំណើរការរហូតដល់ពេលកងទ័ពវៀតណាមចូលមកដល់។[1997]

៤៨៨. ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធនៃការគ្រប់គ្រងការដ្ឋាន ពុំមានសាក្សីណាម្នាក់អាចផ្តល់ព័ត៌មានពីរចនាសម្ព័ន្ធនៃការគ្រប់គ្រងនៅការដ្ឋានក្រឡឹងដុំបានច្បាស់លាស់ឡើយ[1998] ខណៈមានសាក្សីឈ្មោះ ជួន ថន តែម្នាក់គត់ដែលអះអាងថា ខ្លួនជាកម្មាភិបាលទទួលខុសត្រូវនៅការដ្ឋានក្រឡឹងដុំ ហើយរាយការណ៍ទៅប្រធានសហករណ៍ត្រែងឈ្មោះ ឈាន។ [1999]

៤៨៩. នៅការដ្ឋានក្រឡឹងដុំមានអ្នកធ្វើការនៅទីនោះជាក្រុមកងចល័តយុវជន យុវនារី និងមានប្រជាជនធម្មតាផងដែរ។[2000] ជាក់ស្តែង សាក្សីឈ្មោះ ជួន ថន ដែលជាប្រធានកងចល័តអះអាងថា នៅដើមឆ្នាំ១៩៧៨ ខ្លួនបានគ្រប់គ្រងកងចល័តដែលមានសមាជិកចំនួនប្រហែល ៥០ (ហាសិប) នាក់ និងត្រូវបានប្រធានសហករណ៍របស់ខ្លួនបញ្ជូនឱ្យទៅធ្វើស្រែនៅក្រឡឹងដុំ។[2001] ហើយថ្នាក់លើបានប្រគល់ផែនការឱ្យធ្វើស្រែលើដីចំនួន ១០០ (មួយរយ) ហិចតា និងទទួលខុសត្រូវគោ ៥ (ប្រាំ) នឹម។[2002]

៤៩០. ស្ថានភាពការងារនៅក្រឡឹងដុំមានការលំបាកជាខ្លាំង ដោយអ្នកធ្វើការត្រូវបានគេបង្ខំឲ្យធ្វើការពុំមានពេលសម្រាកឡើយ។[2003] មិនតែប៉ុណ្ណោះនៅការដ្ឋានក្រឡឹងដុំពុំមានរបបអាហារគ្រប់គ្រាន់សម្រាប់ផ្ដល់ឲ្យអ្នកធ្វើការទេ។[2004] សាក្សីម្នាក់អះអាងថាខ្លួនបានរត់ចេញពីក្រឡឹងដុំ ដោយសារកង្វះអាហារ ហើយត្រូវបានគេដេញតាមចាប់ខ្លួន។[2005]

៤៩១. សាក្សីឈ្មោះ ជួន ថន អះអាងថាពុំមានការធ្វើបាប ឬកាប់សម្លាប់អ្នកធ្វើការងារនៅការដ្ឋានក្រឡឹងដុំទេ។[2006] សក្ខីកម្មរបស់សាក្សីទាំងអស់បង្ហាញថា មិនមានសាក្សីណាម្នាក់ធ្លាប់ឃើញ **តាទិត្យ** មកពិនិត្យនៅការដ្ឋានក្រឡឹងដុំទេ។[2007]

## ១០. គុកត្រាចក្រោល ហៅ គុកបឹងបាតកណ្ដាល

៤៩២. មន្ទីរសន្ដិសុខត្រាចក្រោល ឬគុកបឹងបាតកណ្ដាល ស្ថិតនៅក្នុងភូមិត្រាចក្រោល ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់។[2008] បរិវេណមន្ទីរសន្ដិសុខនេះត្រូវបានរុំព័ទ្ធដោយរបងឈើព័ទ្ធដោយបន្លាលួសនៅជុំវិញ[2009] មានអគារឃុំឃាំង ២ (ពីរ) ជារោងវែងៗ មានទទឹងប្រហែលជា ៣ (បី) ម៉ែត្រ ហើយបណ្ដោយប្រហែលជា ៥ (ប្រាំ) ម៉ែត្រ។[2010] អគារឃុំឃាំង ១ (មួយ) សម្រាប់អ្នកទោសប្រុស និង ១ (មួយ) ទៀតសម្រាប់ឃុំឃាំងអ្នកទោសស្រី ដោយគេធ្វើជាខ្ទមសម្រាប់អ្នកទោសបីឬបួននាក់ស្នាក់នៅក្នុងមួយខ្ទម។[2011] ក្រៅពីនេះក្នុងបរិវេណគុកត្រាចក្រោល មានអគារ ១ (មួយ) ជាកន្លែងស្ដុកថ្នាំខ្មែរ ឬ ជាកន្លែងសង្គមកិច្ចដែលគ្រប់គ្រងដោយតាឈឿន កន្លែងដាំដំឡូងមី សម្រាប់ឲ្យអ្នកទោសធ្វើការ និងឃ្លាំងផ្ទុកស្ដុក។[2012]

៤៩៣. ក្នុងឆ្នាំ ១៩៧៦ មន្ទីរសន្ដិសុខនេះបានបើកដំណើរការដំបូងនៅភូមិថ្លូល ឃុំបត់កណ្ដាល ស្រុកបាកាន ខេត្តពោធិ៍សាត់ ដោយមាន តាឃិន ជាអ្នកគ្រប់គ្រង ហើយអំឡុង ឆ្នាំ ១៩៧៧ មន្ទីរសន្ដិសុខបានផ្លាស់ប្ដូរទីតាំងមកវត្តបឹងគល់វិញ។[2013] បន្ទាប់មកទៀតមន្ទីរសន្ដិសុខត្រូវបានប្ដូរទីតាំងទៅនៅភូមិត្រាចក្រោលដោយមានឈ្មោះថា មន្ទីរសន្ដិសុខត្រាចក្រោល ជាទីតាំងចុងក្រោយបង្អស់[2014] មានចម្ងាយប្រហែល ១ (មួយ) គីឡូម៉ែត្រពីវត្តបឹងគល់។[2015] មន្ទីរសន្ដិសុខនេះដំណើរការរហូតដល់ពេលវៀតណាមចូលមកដល់។[2016]



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៤៩៤. មន្ទីរសន្តិសុខត្រាចក្រោល ត្រូវបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្រុកក្លាត (បច្ចុប្បន្ន ស្រុកបាកាន) ដោយសារមនុស្សមកពីគ្រប់ភូមិឃុំត្រូវបញ្ជូនទៅមន្ទីរនេះ។[2017] មានការអះអាងផ្សេងៗគ្នាទាក់ទិននឹងឈ្មោះប្រធានមន្ទីរសន្តិសុខត្រាចក្រោល ដោយសារមានការផ្លាស់ប្តូរសមាសភាពអ្នកគ្រប់គ្រងពីពេលមួយទៅពេលមួយ។ ឈ្មោះដែលសាក្សីចង្អុលបង្ហាញអាចជាអ្នកគ្រប់គ្រងនៅមន្ទីរសន្តិសុខនេះក្នុងអំឡុងពេលផ្សេងៗគ្នា។ សាក្សីឈ្មោះ អ៊ុម ពុំ ដែលធ្លាប់ជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខត្រាលក្រោលជាង ១ (មួយ) ឆ្នាំ បានអះអាងថាប្រធានមន្ទីរសន្តិសុខត្រាចក្រោលមានឈ្មោះថា ខុន ហើយឈ្មោះ ប៊ី អាចជាប្រធាន ឬ អនុប្រធាននៅត្រាចក្រោលដែរ ដោយសារអ្នកទាំងពីរធ្វើការជាមួយគ្នា។[2018] ខណៈសាក្សីម្នាក់ទៀតឈ្មោះ សឹម វឿន ជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខនេះ រយៈពេល ៦ (ប្រាំមួយ) ខែ មុនវៀតណាមចូលមកដល់ អះអាងថាឈ្មោះ ឌី ជាប្រធានមន្ទីរសន្តិសុខនេះ។[2019]

៤៩៥. សាក្សីឈ្មោះអម សុខុន ហៅ ខុន ជាអតីតប្រធានមន្ទីរសន្តិសុខត្រាចក្រោលក្នុងអំឡុងពេលមួយបានបំភ្លឺថា អ្នកគ្រប់គ្រងមន្ទីរសន្តិសុខត្រាចក្រោលនាពេលដំណើរការដំបូងមានឈ្មោះតាឃិន។[2020] ក្រោយពីប្តូរទីតាំងមកនៅវត្តបឹងគល់ ឈ្មោះ នៅ និង យ៉ាន់ ក្លាយជាអ្នកគ្រប់គ្រង មិនយូរប៉ុន្មានត្រូវគេយកទៅសម្លាប់ចោលនៅអំឡុងឆ្នាំ ១៩៧៧។[2021] បន្ទាប់មកសាក្សីត្រូវបានគេតែងតាំងឲ្យគ្រប់គ្រងមន្ទីរសន្តិសុខ ដែលខណៈនោះមានទីតាំងនៅវត្តបឹងគល់នៅឡើយ រហូតដល់ពេលគេដកដំណែងនៅឆ្នាំ ១៩៧៨ ទើបឈ្មោះ ពឹម មកគ្រប់គ្រងមន្ទីរសន្តិសុខនេះបន្ត។[2022] សាក្សីបន្ថែមថាឈ្មោះ ឌី ក៏ជាប្រធានមន្ទីរសន្តិសុខត្រាចក្រោលដែរ។[2023] ក្រៅពីនេះមានកម្មាភិបាល និងយោធាខ្មែរក្រហមប្រហែលជា ៥០ (ហាសិប) ទៅ ៦០ (ហុកសិប) នាក់ ផ្លាស់វេនគ្នាយាមកាម និងប្រចាំការ។[2024]

៤៩៦. តាមការប៉ាន់ស្មានរបស់សាក្សី មន្ទីរសន្តិសុខនេះអាចផ្ទុកអ្នកទោសចំនួនប្រហែល ២០០ (ពីររយ) ទៅ ៤០០ (បួនរយ) នាក់។[2025] អ្នកទោសទាំងនោះរួមមាន ប្រជាជន ១៧ មេសា និងកម្មាភិបាលខ្មែរក្រហម មានទាំងបុរស ស្ត្រី និងកុមារ ដែលពួកគេចោទប្រកាន់ថាជាខ្មាំងនាយទុនសក្តិភូមិ ជនខុសសីលធម៌ អ្នករឹងទទឹងមិនគោរពបទបញ្ជា ឬតវ៉ានឹងការរៀបការដោយបង្ខំ ត្រូវបានចាប់ខ្លួនបញ្ជូនទៅទីនោះ។[2026] អ្នកទោសបុរស និងស្ត្រីត្រូវដាក់ឃុំឃាំងផ្សេងពីគ្នា។[2027] អ្នកទោសមិនត្រូវបានអនុញ្ញាតឲ្យដើរហើរឡើយ។[2028] ពួកគេត្រូវបានគេ


ការិយាល័យសហចៅក្រមស៊ើបអង្កេត * E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ឃុំខ្លួនក្នុងអគារឃុំឃាំងនីមួយៗ មានចំនួនចន្លោះពី ៥០ (ហាសិប) ទៅ ៦០ (ហុកសិប) នាក់[2029] ដោយមានដាក់ខ្នោះនៅនឹងដៃ ជើង និង ក។[2030] ករណីអ្នកទោសលួចរត់គេចខ្លួន ប្រសិនបើចាប់បានអ្នកទោសនឹងត្រូវគេធ្វើទារុណកម្មរហូតដល់ស្លាប់។[2031] ជាក់ស្តែង អ្នកទោសលួចរត់ចំនួន ៣ (បី) នាក់ត្រូវបានវះពោះនៅពេលចាប់បាន[2032] និងអ្នកទោសម្នាក់ត្រូវកាប់កនឹងកាំបិត។[2033]

៤៩៧. អ្នកទោសចាស់ត្រូវបានគេនាំចេញទៅសម្លាប់ចោល មុននឹងនាំអ្នកទោសថ្មីមកដាក់ឃុំឃាំងបន្ត។[2034] ជាក់ស្តែង សាក្សីធ្លាប់បានឃើញយោធា និងអ្នកយាមគុកបណ្តើរអ្នកទោសទៅសម្លាប់ក្នុងព្រៃ ហើយស្ពាយសម្ភារៈអ្នកទោសត្រឡប់មកវិញ។[2035] សាក្សីម្នាក់ធ្លាប់បានឃើញដោយផ្ទាល់ភ្នែកនូវសកម្មភាពដែលយោធាខ្មែរក្រហមបណ្តើរអ្នកទោសប្រហែល ១៥ (ដប់ប្រាំ) នាក់ យកទៅបាញ់សម្លាប់ចោលនៅក្នុងព្រៃ ប្រមាណ ៥០០ (ប្រាំរយ) ម៉ែត្រ ពីគុកត្រាចក្រោល។[2036] សាក្សីម្នាក់ទៀតអះអាងថា នៅពេលខ្លួនចេញទៅធ្វើការនៅក្រៅគុក បានឃើញសាកសពរាប់រយនាក់ដែលត្រូវគេសម្លាប់ចោលនៅរាយប៉ាយនៅវាលខាងក្រោយគុក។[2037]

៤៩៨. សាក្សីម្នាក់អះអាងថានៅក្នុងឆ្នាំ ១៩៧៧ និង ឆ្នាំ១៩៧៨ ការសម្លាប់មនុស្សនៅក្នុងមន្ទីរសន្តិសុខត្រាចក្រោលកើនឡើងខ្លាំង។[2038] ជាក់ស្តែងសាក្សីផ្ទាល់បានឃើញឈ្លបយកមនុស្សដែលមានសម្បុរសដូចចិន និងយួន ឬ កូនក្មេង ធ្វើទារុណកម្ម ឬ យកចេញទៅសម្លាប់ជារៀងរាល់យប់ នៅក្បែរមន្ទីរសន្តិសុខត្រាចក្រោល។[2039] ជនរងគ្រោះមួយចំនួនដូចជា តាណែម ដែលជាគណៈតំបន់ ៧ ក៏ត្រូវយកទៅសម្លាប់ចោលដែល ព្រោះគាត់និយាយប៉ៃឡាំដូចយួន។[2040] ឆៅ និង យ៉ាន ជាអ្នកគ្រប់គ្រងនៅមន្ទីរសន្តិសុខត្រាចក្រោល ប៉ុន្តែគ្រប់គ្រងមិនបានប៉ុន្មានផងត្រូវបានយកទៅសម្លាប់ចោលដោយមិនមានមូលហេតុច្បាស់លាស់។[2041]

៤៩៩. សាក្សីភាគច្រើនដែលបានបំភ្លឺទាក់ទងមន្ទីរសន្តិសុខត្រាចក្រោល បានអះអាងស្របគ្នាថាមិនស្គាល់ ឬឮឈ្មោះ **យឹម ទិត្យ ឬ តាទិត្យ** ឡើយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។[2042]

# ១១. អំពើហិង្សាផ្លូវភេទលើខ្មែរក្រោម និងអ្នកបូព៌ានៅស្រុកបាកាន

៥០០. យោងតាមសក្ខីកម្មរបស់សាក្សី ៤ (បួន) នាក់ ដែលបានឃើញដោយផ្ទាល់ភ្នែកបានបញ្ជាក់ថា ការរំលោភលើនារីក្នុងស្រុកបាកាន កើតមាននៅអណ្ដូងចារ នៅតាំងក្រសាំង នៅទួលពង្រ និងនៅក្រោមផ្ទះឃុំឃាំងភូមិវាលផិតកន្លែងសម្លាប់។[2043] ដោយឡែក មានសាក្សីតែម្នាក់គត់ដែលបានដឹងឮតាមរយៈគេបានអះអាងថា ការរំលោភលើនារីបានកើតឡើងនៅទួលប្រហូត។[2044] ការរំលោភលើនារីនៅក្នុងស្រុកបាកាន មានតាំងពីឆ្នាំ១៩៧៥ និងបន្តរហូតដល់ជិតចុងរបបខ្មែរក្រហម។[2045] មានសក្ខីកម្មបញ្ជាក់ថា ឈ្មោះ ឈុង និងព្រលឹត គឺជាអ្នកប្រគល់នារីក្មេងស្អាតម្នាក់ទៅឱ្យឈ្មោះ គង់ ដើម្បីរំលោភ។[2046] សាក្សីម្នាក់ទៀតនិយាយថា កងទ័ព កងឈ្លប និងពេជ្ឈឃាតគឺជាអ្នកចាប់រំលោភមនុស្សស្រី រួចទើបសម្លាប់ចោលតាមក្រោយ។[2047] សាក្សីម្នាក់បំភ្លឺថា ឈ្មោះ គង់ បានចាប់រំលោភលើនារីម្នាក់។[2048] មុនពេលរំលោភ និងសម្លាប់នារី ពួកពេជ្ឈឃាតតែងតែផឹកជាមុនសិន។[2049] សាក្សីម្នាក់មិនដឹងអំពីចំនួនអ្នកចាប់រំលោភទេ។[2050] នារី និងក្មេងស្រីស្អាតៗ គឺជាមុខសញ្ញានៃការចាប់រំលោភ រួចសម្លាប់។[2051] នារីរងគ្រោះភាគច្រើន គឺជាជនជាតិខ្មែរក្រោម និងជនជាតិខ្មែរ[2052] នារីបូព៌ាម្នាក់។[2053] សាក្សីម្នាក់ដែលឃើញផ្ទាល់ភ្នែកម្នាក់ចម្ងាយប្រមាណ ៣០ (សាមសិប) ម៉ែត្រពីទីតាំងរំលោភ អះអាងថា នារីរងគ្រោះមាន ៣ (បី) ទៅ ៤ (បួន) នាក់។[2054] នារីជនរងគ្រោះទាំងនោះគឺមានអាយុប្រហែល ១៦ (ដប់ប្រាំមួយ) ឆ្នាំ[2055] ហើយខ្លះមានអាយុប្រហែល ៣០ (សាមសិប) ឆ្នាំ។[2056]

៥០១. ពួកឈ្លបបានអូសនារីរងគ្រោះទៅគៀនហើយស្រាតខោអាវ ជាន់ពីលើ រួចរំលោភ។[2057] ក្នុងនោះមាននារីម្នាក់ត្រូវបានអ្នកចាប់រំលោភយកឫស្សីរុកប្រដាប់ភេទ។[2058] សាក្សីម្នាក់ឆ្លើយថា ការរំលោភបានផ្ដើមឡើងនៅម៉ោង ប្រមាណ ៧ (ប្រាំពីរ) ទៅ ៨ (ប្រាំបី) រហូតដល់អស់ចិត្ត ដោយមិនមានបញ្ជាក់ថ្ងៃ ឬ យប់នោះទេ។[2059] សាក្សីធ្លាប់បានឃើញ នារី ២ (ពីរ) នាក់ត្រូវបានរំលោភនៅពេលយប់។[2060] ខណៈសាក្សីម្នាក់ទៀតអះអាង ថាការរំលោភក៏កើតមានផងដែរនៅពេលទៀបភ្លឺ។[2061]

៥០២. ផ្អែកលើសក្ខីកម្មរបស់សាក្សីជាច្រើននាក់ ជាទូទៅ នារីៗត្រូវបានគេរំលោភ រួចយកទៅសម្លាប់[2062] ហើយនារីខ្លះត្រូវបានសម្លាប់ដោយអារក។[2063] កងទ័ពដែលបានរំលោភ ...



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

សម្លាប់នារីទាំងនោះមិនមានទោសឡើយ។[2064] ប៉ុន្តែ សាក្សីម្នាក់បានអះអាងថា អ្នកដែលបានរំលោភ និងសម្លាប់មនុស្សនារីទាំងនោះ ក្រោយមកត្រូវបានគេចាប់យកទៅសម្លាប់ចោលវិញ ដែលអាចជាបញ្ជារបស់គណៈស្រុកដែលឲ្យកងទ័ពស្រុកទៅចាប់អ្នករំលោភគេនោះ។[2065]

## ១២. ទីតាំងសម្លាប់មនុស្សដំណាក់រាំង

៥០៣. ដំណាក់រាំង ជាទីតាំងសម្លាប់មនុស្សស្ថិតនៅជិតប៉ៃលិន។[2066] ដំបូងឡើយ ប្រជាជនត្រូវបានចាប់ខ្លួន ដោយសារបានរត់ចូលព្រៃ ព្រោះមានការភ័យខ្លាចពីការសម្លាប់របស់ពួកខ្មែរក្រហម ប៉ុន្តែក្រោយមកបន្តិចត្រូវបានដោះលែងវិញតាមបញ្ជារបស់ នួន ជា។[2067] ក្រោយពីដោះលែងបានប្រមាណ ៣ (បី) ថ្ងៃ ប្រជាជនប្រមាណ ៤០ (សែសិប) នាក់ ត្រូវបានចាប់ខ្លួនវិញដោយកងទ័ពក្រោមការដឹកនាំផ្ទាល់ដោយ **យឹម ទិត្យ** ជាលេខាតំបន់ ហើយយកមកឃុំខ្លួននៅបាណន់។[2068] ការចាប់ខ្លួនប្រជាជនទាំងនេះ ធ្វើឡើងតាមបញ្ជារបស់ តាម៉ុក ក្នុងគោលដៅបោសសម្អាត។[2069]

៥០៤. សាក្សីលើកឡើងថា អ្នកទោសត្រូវបានគេដឹកតាមឡានយកទៅសម្លាប់នៅដំណាក់រាំង។[2070] សាក្សីបានបន្ថែមថា ប្រជាជនដែលត្រូវបានគេសម្លាប់ត្រូវបានគេយកទៅកប់នៅក្រោមដី។[2071] ប៉ុន្តែ ក៏មានអ្នកខ្លះទៀតគ្រាន់តែរងរបួសបាក់ដៃបាក់ជើង ហើយបានរត់រួចខ្លួនពីការសម្លាប់នោះដែរ។[2072]

## ១៣. មន្ទីរសន្តិសុខវត្តកណ្តាល

៥០៥. មន្ទីរសន្តិសុខវត្តកណ្តាលមានទីតាំងនៅត្រើយខាងកើតនៃស្ទឹងសង្កែ ដែលស្ថិតនៅចំកណ្តាលទីក្រុងបាត់ដំបង ហើយក៏ជាគុកធំបំផុតនៅក្នុងភូមិភាគពាយ័ព្យ។[2073] សាក្សីឈ្មោះ ទាត់ ធឿន បានរៀបរាប់ថា មន្ទីរសន្តិសុខវត្តកណ្តាលជាមន្ទីរសន្តិសុខមជ្ឈិម ដោយសារគាត់ (សាក្សី)បានដឹងពីនិរសា តាញឹម ឈ្មោះ ណាម និង ខួង។[2074] សាក្សីដដែលថ្លែងថាមន្ទីរនេះស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់មជ្ឈិម មិនមែនភូមិភាគនោះទេ។[2075] សាក្សីរបស់



C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ស.ច.ស ឈ្មោះ លឹម ទឹម និង សុខ ឯម បញ្ជាក់ថា ប្រធានមន្ទីរសន្តិសុខវត្តកណ្តាល ឈ្មោះ កយ។[2076]

៥០៦. នៅចុងឆ្នាំ ១៩៧៨ សាក្សីម្នាក់ទៀតឈ្មោះ ឈន វន ជាអតីតកងការពារតាញឹម អះអាងថា គាត់បានឃើញយោធា ២ (ពីរ) ឡានឆែកឆេរផ្ទះតាញឹម ខណៈដែលសាក្សីកំពុងដឹកប្រពន្ធតាញឹមទៅភូមិផ្សេង។[2077] លុះសាក្សីត្រឡប់មកវិញដល់ក្រុងបាត់ដំបង គាត់ត្រូវបានចាប់ខ្លួនដាក់វត្តកណ្តាលដែលគ្រប់គ្រងដោយយោធាមកពីនិរតី។[2078] នៅក្នុងខែ មីនា ឆ្នាំ ១៩៧៧ សាក្សី លឹម ទឹម ត្រូវបានចាប់ឃុំឃាំងនៅវត្តកណ្តាលនេះមួយរយៈ និងត្រូវបានដោះលែងវិញដោយសារ គាត់នៅក្នុងឡាន ប៉ុន្តែមិនមែនជាអ្នកបើកឡានដែលបានបើកឡានប៉ះទង្គិចរោងចក្រក្រឡឹងនៅភ្នំសំពៅ។[2079]

៥០៧. អគារឃុំឃាំងរបស់មន្ទីរ សន្តិសុខនេះមានកម្ពស់ ៣ (បី) ជាន់ និងមាន "បន្ទប់ជាច្រើនសម្រាប់ ដាក់អ្នកទោស"។[2080] វត្តកណ្តាលជាគុកមានការរៀបចំយ៉ាងប្រុងប្រយ័ត្នដែលបញ្ជីអ្នកទោសត្រូវរក្សាទុក[2081] អ្នកទោសត្រូវថតរូប ហើយសំណុំឯកសារជាលាយលក្ខណ៍អក្សរជាមួយនឹងប្រវត្តិរូបត្រូវបានរៀបចំទុក។[2082] នៅក្នុងឆ្នាំ ១៩៧៨ អ្នកទោសត្រូវបានសួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់នៅក្នុងវត្ត ឬ នៅក្នុងផ្ទះនានាដែលស្ថិតនៅស្ថិតនៅក្បែរៗវត្តនោះ។[2083] សាក្សីឈ្មោះ វ៉ាន់ ណាត ដែលបានជាប់ឃុំឃាំងនៅវត្តកណ្តាលចាប់ពីថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ រហូតដល់ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៧៨[2084] ត្រូវបាននាំយកទៅព្រៃខាងក្រោយគុកដាក់ទៅក្នុង "ផ្ទះថ្មតូចមួយ" ជាកន្លែងដែលគាត់បានឃើញ "រនុកដែកយ៉ាងវែង ដំបង ស្បោងផ្លាស្ទិក និងរំពាត់" ព្យួរនៅលើជញ្ជាំង និង "ស្នាមប្រឡាក់ឈាមស្រស់ៗ" នៅខាងក្រោមកៅអីរបស់គាត់ទៀតផង។[2085]

៥០៨. ការឆក់ខ្សែភ្លើងក៏ត្រូវបានគេប្រើប្រាស់ជាមធ្យោបាយ ដើម្បីធ្វើទារុណកម្មអ្នកទោស និងដើម្បីយកចម្លើយ។[2086] បរិយាកាសនៃការភ័យខ្លាចកើតមាននៅវត្តកណ្តាល ខណៈដែលអ្នកទោសបានដឹងថា អ្នកទោសផ្សេងៗទៀតត្រូវបានធ្វើទារុណកម្ម[2087] ហើយភ័យខ្លាចថាអ្នកទោសនឹងប្រឈមមុខនឹងជោគវាសនាដូចៗគ្នា។[2088]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៥០៩. ស្ថានភាពរស់នៅគុក គឺមានលក្ខណៈអមនុស្សធម៌ណាស់។ វ៉ាន់ណាត បានទទួលបបរ ១ (មួយ) ចានចែកជាមួយអ្នកទោស ៦ (ប្រាំមួយ) នាក់ផ្សេងទៀត[2089] ហើយមិនអនុញ្ញាតឲ្យផឹកទឹកទេ។[2090] អ្នកទោសត្រូវបានដាក់ខ្នោះជើងជាប់[2091] ឬ ចាក់សោរទុកនៅក្នុងឃ្លាំងធ្វើពីឈើ។[2092] អ្នកទោសភាគច្រើនដែលត្រូវនាំទៅកាន់មន្ទីរសន្តិសុខវត្តកណ្តាល មិនដែលបានឃើញត្រឡប់មកវិញទេ។ [2093]

៥១០. នាពេលបច្ចុប្បន្ននេះ មិនមានការប៉ាន់ស្មានណាមួយស្តីពីចំនួនប្រជាជនដែលត្រូវបានសម្លាប់នៅទីតាំងមន្ទីរសន្តិសុខនេះទេ ខណៈមានអ្នកនៅរស់ជីវិតម្នាក់អះអាងថា អ្នកទោសត្រូវបានសម្លាប់ចោលស្ទើររាល់ថ្ងៃ។[2094] ខ្មោចត្រូវបានអូសយកចេញ "ដូចសត្វជ្រូកដោយដៃ និងជើងចងភ្ជាប់ទៅនឹងព្រនង់ឫស្សីមួយ"។[2095]

## ១៤. មន្ទីរសន្តិសុខវត្តបន្ទាយនាង

៥១១. មន្ទីរសន្តិសុខវត្តបន្ទាយនាង មានទីតាំងនៅក្នុងភូមិភ្នំលិច ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ។[2096] មន្ទីរសន្តិសុខវត្តបន្ទាយនាង ឬហៅថាមន្ទីរសន្តិសុខ ២៣០[2097] ស្ថិតនៅក្នុងបរិវេណវត្តបន្ទាយនាងដែលមានទំហំប្រហែល ១ (មួយ) គីឡូម៉ែត្រ ៤ (បួន) ជ្រុង និងមានទាហានយាមការពារជុំវិញបរិវេណវត្ត។[2098] ក្នុងបរិវេណវត្តនោះរួមមានព្រះវិហារ កុដិ អគារឈើនៅខាងត្បូង និងនៅខាងលិច សុទ្ធសឹងតែជាកន្លែងសម្រាប់ដាក់អ្នកទោសធ្ងន់ និងអ្នកទោសស្រាល[2099] រោងឈើគ្មានជញ្ជាំងសម្រាប់សួរចម្លើយអ្នកទោស[2100] ផ្ទះឈើសម្រាប់ពួកកម្មាភិបាលធ្វើការ។[2101] ភស្តុតាងបានបង្ហាញថាទីតាំងខាងក្នុងវត្ត និងខាងក្រៅបរិវេណវត្តបន្ទាយនាងត្រូវបានគេប្រើដើម្បីសម្លាប់មនុស្ស។[2102] មន្ទីរសន្តិសុខនេះត្រូវបានបង្កើតឡើងដោយកម្មាភិបាលពាយ័ព្យ និងបានចាប់ផ្តើមដំណើរការនៅក្នុងឆ្នាំ ១៩៧៦[2103] ហើយនៅពេលដែលកម្មាភិបាលនិរតីបានមកដល់មន្ទីរសន្តិសុខនេះបានបន្តប្រតិបត្តិការរដែលរហូតដល់ពេលវៀតណាមចូលមកដល់ក្នុងឆ្នាំ ១៩៧៩។[2104]

៥១២. សាក្សីមួយចំនួនអះអាងថា មន្ទីរសន្តិសុខវត្តបន្ទាយនាងជាមន្ទីរសន្តិសុខស្ថិតនៅក្រោមការគ្រប់គ្រងដោយយោធា ដោយសារតែអ្នកធ្វើការ និងអ្នកយាមនៅទីនោះសុទ្ធតែជាយោធា។[2105] មន្ទីរសន្តិសុខនេះបង្កើតដំបូងដោយភូមិភាគពាយ័ព្យ និងគ្រប់គ្រងដោយ



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ប្រធានឈ្មោះ សុខ។[2106] នៅពេលដែលពួកកម្មាភិបាលនិរតីចូលមកគ្រប់គ្រងឈ្មោះ សុខ នៅតែធ្វើការជាប្រធានមន្ទិរសន្តិសុខផ្នែកសួរចម្លើយដដែល រហូតដល់គាត់ត្រូវបានគេយកទៅសម្លាប់ បន្ទាប់ពីវៀតណាមបានចូលមកដល់។[2107] សាក្សីឈ្មោះ ម៉ាន់ ជួន ដែលធ្លាប់ជាប់ឃុំរយៈពេលមួយសប្តាហ៍នៅមន្ទីរសន្តិសុខវត្តបន្ទាយនាង អះអាងថាខ្លួនស្គាល់គ្នាជាមួយនឹងឈ្មោះ ម៉ៅ ដែលជាប្រធានកងការពារគុក ប៉ុន្តែសាក្សីមិនស្គាល់ប្រធានគុកវត្តបន្ទាយនាងទេ។[2108]

៥១៣. សាក្សីឈ្មោះ ម៉ាន់ ជួន បន្ថែមថាខ្លួនធ្លាប់ជាប់ឃុំនៅទីនោះនាអំឡុងដើមឆ្នាំ ១៩៧៦ ហើយខ្លួនបានឃើញមានអ្នកយាមចំនួន ១២ (ដប់ពីរ) នាក់[2109] ខណៈសាក្សីដែលរស់នៅជិតមន្ទីរសន្តិសុខតាំងពីដើមឆ្នាំ ១៩៧៧ រហូតដល់របបដួលរលំ បញ្ជាក់ថាខ្លួនបានឃើញអ្នកយាមដើរល្បាតជុំវិញមន្ទីរសន្តិសុខចំនួនប្រហែល ២០ (ម្ភៃ) ទៅ ៣០ (សាមសិប) នាក់។[2110]

៥១៤. ដើមឆ្នាំ១៩៧៧ នៅក្រោមការគ្រប់គ្រងរបស់កម្មាភិបាលពាយ័ព្យ និងមុនពេលកម្មាភិបាលនិរតីមកដល់ ការចាប់ខ្លួនប្រជាជនបានកើនឡើង ដោយជនរងគ្រោះភាគច្រើនជាអតីតទាហាន អ្នករដ្ឋការនៃរបប លន់ នល់ និងប្រជាជនដែលប្រព្រឹត្តខុសសីលធម៌។[2111] ប៉ុន្តែនៅពេលកម្មាភិបាលនិរតីមកដល់ ពួកគេចាប់ផ្តើមធ្វើការចាប់ខ្លួនកម្មាភិបាលពាយ័ព្យជាបន្តបន្ទាប់[2112] ចាប់ពីថ្នាក់ភូមិ ថ្នាក់ឃុំ[2113] រហូតដល់ថ្នាក់ភូមិភាគ[2114] ហើយការចាប់ខ្លួនបែបនេះកាន់តែខ្លាំងនៅក្នុងអំឡុងខែ តុលា ឬ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨[2115] ។ សាក្សីម្នាក់បានបំភ្លឺថាពេលកម្មាភិបាលនិរតីមកដល់ កម្មាភិបាលពាយ័ព្យជាច្រើននាក់ត្រូវបានគេដកចេញ ខណៈអ្នកយាម និងយោធាពាយ័ព្យមួយចំនួនបន្តធ្វើការនៅមន្ទីរសន្តិសុខដដែលក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលនិរតី។[2116]

៥១៥. តាមការប៉ាន់ស្មានរបស់សាក្សីមួយចំនួន មន្ទីរសន្តិសុខវត្តបន្ទាយនាងអាចផ្ទុកអ្នកទោសច្រើនដល់ទៅរាប់រយនាក់។[2117] អ្នកជាប់ឃុំមានទាំងបុរស ស្ត្រី និងកុមារ ឃុំឃាំងជាមួយគ្នាដោយពុំមានការបែងចែកឡើយ។[2118] អ្នកទោសភាគច្រើនជាបុរស មានសមាសភាពចម្រុះដូចជាប្រជាជនថ្មី និងអតីតទាហាន លន់ នល់[2119] និងកម្មាភិបាលពាយ័ព្យជាដើម។[2120] ពេលខ្លះអ្នកទោសទាំងនោះត្រូវបញ្ជូនមកពីមន្ទីរសន្តិសុខផ្សេងទៀត រួមមានមន្ទីរសន្តិសុខ សិរីសោភ័ណ[2121] និងចំការខ្នុរ។[2122] សាក្សីម្នាក់ដែលមានផ្ទះស្ថិតនៅក្បែរមន្ទីរសន្តិសុខ

អះអាងថាខ្លួនបានឃើញអ្នកទោសនាំចូលមកម្តងៗ ចំនួន ១០ (ដប់) នាក់ ឬច្រើនជាងនេះ តាមឡានហ្ស៊ីបទាហានជារៀងរាល់ថ្ងៃ។[2123]

៥១៦. នៅក្នុងកន្លែងឃុំឃាំងអ្នកទោសទាំងអស់ត្រូវបានដាក់ឱ្យដេកផ្ងារដោយជើងម្ខាងជាប់ខ្នោះធ្វើអំពីឈើជាជួរៗ។[2124] ខ្នោះឈើមានចំនួន ១២០ (មួយរយម្ភៃ) ទៅ ១៣០ (មួយរយសាមសិប) ខ្នោះ សម្រាប់ដាក់អ្នកទោសពី ៥ (ប្រាំ) ទៅ ៨ (ប្រាំបី) នាក់ ក្នុង ១ (មួយ) ខ្នោះ។[2125] អ្នកទោសរងទារុណកម្មពីសំណាក់ពួកអ្នកយាម និងអ្នកសួរចម្លើយ ដោយពួកគេវាយដំទាត់ធាក់ ហើយពេលខ្លះប្រើដំបងដើម្បីវាយអ្នកទោស។[2126] ក្រៅពីនេះអ្នកទោសខ្លះត្រូវបានវាយនឹងបំពង់ទីប ព្យួរក ធ្វើឱ្យថប់ដង្ហើមដោយប្រើស្បោង ផ្លាស្ទិក និងធ្វើទារុណកម្មដោយឆក់ខ្សែភ្លើងដែលតចរន្តចេញពីម៉ាស៊ីនភ្លើងតូចមួយ។

៥១៧. អ្នកទោសត្រូវបានឃោធាប្រដាប់ដោយកាំភ្លើងចាប់ចងជាខ្សែៗ បណ្តើរយកទៅកន្លែងសម្លាប់ចាប់ពី ៨ (ប្រាំបី) ទៅ ១០ (ដប់) នាក់ ស្ទើរតែរៀងរាល់ថ្ងៃ ដោយការសម្លាប់ភាគច្រើនធ្វើឡើងនៅពេលព្រលប់។[2127] ពួកគេត្រូវគេយកចេញទៅសម្លាប់ដោយវាយ ឬបាញ់សម្លាប់ ជួនកាលអ្នកទាំងនោះត្រូវគេច្របាច់ក ឬ វះពោះ។[2128] សាក្សីម្នាក់អះអាងថាបានឃើញគេនាំអ្នកទោសចេញទៅសម្លាប់នៅខាងក្រៅមានចម្ងាយប្រហែល ២០០ (ពីររយ) ម៉ែត្រ ពីកន្លែងឃុំឃាំងខាងលិចវត្តបន្ទាយនាង ហើយក្រោយមកសាក្សីបានឃើញខោអាវ និងស្បែកជើងជនរងគ្រោះដែលត្រូវបានគេសម្លាប់។[2129] សាក្សីម្នាក់ទៀតបំភ្លឺថា ខ្លួនបានដឹងឮពីព្រឹត្តិការណ៍សម្លាប់អ្នកទោស ៥០ (ហាសិប) ទៅ ៦០ (ហុកសិប) នាក់ ដោយយកអ្នកទោសពីមន្ទីរឃុំឃាំងឱ្យទៅជីកប្រឡាយមួយចម្ងាយ ១,៥ (មួយក្បៀសប្រាំ) គីឡូម៉ែត្រពីវត្ត ហើយអ្នកទោសទាំងអស់ត្រូវបានសម្លាប់ និងកប់នៅប្រឡាយនោះតែម្តង។[2130]

៥១៨. សាក្សីឈ្មោះ សំ សុខន ដែលរស់នៅជិតមន្ទីរសន្តិសុខវត្តបន្ទាយនាងរហូតដល់ពាក់កណ្តាលឆ្នាំ ១៩៧៧ អះអាងថា គាត់បានឃើញរណ្តៅនៅក្នុង និងខាងក្រៅបរិវេណវត្តបន្ទាយនាង ដែលរណ្តៅនីមួយៗមានសាកសពពី ៨ (ប្រាំបី) ទៅ ១០ (ដប់) នាក់ និងរណ្តៅខ្លះទៀតនៅខាងក្រៅវត្តមានសាកសពពី ១៥ (ដប់ប្រាំ) ទៅ ២០ (ម្ភៃ) នាក់ ។[2131] សាក្សីនេះបន្ថែមថាក្រោយរបបខ្មែរក្រហមដួលរលំខ្លួនធ្លាប់ចាប់បានឈ្មោះ សុខ ជាប្រធានមន្ទីរសន្តិសុខវត្តបន្ទាយនាង ដែលបានបញ្ជាក់ប្រាប់សាក្សីថា មានមនុស្សប្រហែលជា ៩.០០០ (ប្រាំបួន



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ពាន់) នាក់ ត្រូវបានសម្លាប់នៅក្នុងនិងខាងក្រៅបរិវេណវត្ត។[2132] ក្នុងឆ្នាំ១៩៧៦ នាជំនាន់កម្មាភិបាលពាយ័ព្យកាន់កាប់ មានសាក្សីបានឃើញរណ្តៅសពថ្មីជារៀងរាល់ ៤ (បួន) ថ្ងៃម្តង និងបានឮសម្លេងអ្នកទោសស្រែកនៅពេលធ្វើទារុណកម្ម រាល់ពេលឮសម្លេងម៉ាស៊ីនភ្លើង។[2133]

៥១៩. តាមការប៉ាន់ស្មានរបស់សាក្សីដទៃទៀតបង្ហាញថា ក្រោយឆ្នាំ ១៩៧៩ មានចំនួនរណ្តៅសាកសពចន្លោះពី ១០០ (មួយរយ) ទៅ ២០០ (ពីររយ) រណ្តៅ ដែលរណ្តៅនីមួយៗមានផ្ទុកសាកសពចាប់ពី ១០ (ដប់) រហូតដល់ទៅ ២៥ (ម្ភៃប្រាំ) នាក់ នៅក្នុងទីតាំងសម្លាប់ទំហំ ១ (មួយ) ហិចតាចំពីខាងមុខវត្តបន្ទាយនាង។[2134] ចំនួនជនរងគ្រោះអាចមានចំនួនពី ៣.៥០០ (បីពាន់ប្រាំរយ) ដល់ ៥.០០០ (ប្រាំពាន់) នាក់ ត្រូវបានសម្លាប់ចោលនៅទីនោះ។[2135]

៥២០. សាក្សីទាំងអស់ដែលបានបំភ្លឺអំពីវត្តបន្ទាយនាង មិនដឹងឬស្គាល់ឬមិនបាននិយាយដល់ ឈ្មោះ **តាទិត្យ** ដែលជាជនត្រូវចោទពាក់ព័ន្ធនឹងមន្ទីរសន្តិសុខវត្តបន្ទាយនាងនេះទេ។ មានសាក្សីម្នាក់បានរៀបរាប់ឈ្មោះកម្មាភិបាលនិរតីថ្នាក់មូលដ្ឋាន ប៉ុន្តែមិនបានស្គាល់កម្មាភិបាលថ្នាក់តំបន់ ឬ ថ្នាក់ភូមិភាគឡើយ។[2136] ខណៈសាក្សីម្នាក់ទៀតដែលរស់នៅជិតវត្តបន្ទាយនាងជឿជាក់ថាមន្ទីរនេះមិនមានដំណើរការបន្តទៅនៅពេលពួកនិរតីមកដល់ ដោយសារតែក្រោយពេលកម្មាភិបាលពាយ័ព្យបោះបង់ចោលមន្ទីរនេះ គាត់មិនឃើញមានអ្នកទោសនៅក្នុងបរិវេណមន្ទីរសន្តិសុខនេះ ហើយក៏ពុំមានការហាមប្រាមប្រជាជនមិនឱ្យធ្វើដំណើរឆ្លងកាត់វត្តទៀតទេ។[2137]

## ១៥. មន្ទីរសន្តិសុខវត្តធម្មយុត្តិ

៥២១. វត្តធម្មយុត្តិ (បច្ចុប្បន្នមានឈ្មោះ វត្តបូជាវត្តី) មានទីតាំងស្ថិតនៅក្នុងភូមិវាមគន់ ឃុំគារ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ដែលស្ថិតនៅចម្ងាយប្រហែល ៥០ (ហាសិប) គីឡូម៉ែត្រខាងត្បូង ទីរួមខេត្តបាត់ដំបងនិងមានចម្ងាយ ១ (មួយ) គីឡូម៉ែត្រ ពីសាលាស្រុកមោងឫស្សី។[2138] នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្រុកមោងឫស្សី ត្រូវបានបែងចែកជាពិសេសរវាងតំបន់ ១ និងតំបន់ ៤ នៃភូមិភាគពាយ័ព្យ។[2139] មន្ទីរសន្តិសុខមានទីតាំងស្ថិត



ECCC * CETC * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

នៅក្នុងបរិវេណវត្តធម្មយុត្តិ[2140] និងមានព្រះវិហារស្ថិតនៅចម្ងាយប្រហែល ៥០ (ហាសិប) ម៉ែត្រពីច្រកចូលដែលត្រូវបានកម្មាភិបាលខ្មែរក្រហមប្រើប្រាស់ជាកន្លែងសម្រាប់សួរចម្លើយអ្នកទោស។[2141]

៥២២. មន្ទីរសន្តិសុខវត្តធម្មយុត្តិជាទីតាំងឃុំឃាំងអ្នកទោស និងជាទីតាំងសម្លាប់មនុស្សផងដែរ។ នៅផ្នែកខាងកើតនៃបរិវេណមន្ទីរសន្តិសុខ ខាងក្រោយព្រះវិហារ មានទីតាំងសម្លាប់មនុស្សចំនួនពីរកន្លែង ដែលនៅទីនោះអ្នកទោសត្រូវបានគេសម្លាប់ និងបោះសាកសពចោល។[2142] វត្តធម្មយុត្តិត្រូវបានដាក់ឱ្យដំណើរការជាមន្ទីរសន្តិសុខ នៅក្នុងឆ្នាំ១៩៧៦។[2143] មន្ទីរសន្តិសុខនេះមានដំណើរការរហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ ១៩៧៩។[2144]

៥២៣. មន្ទីរសន្តិសុខវត្តធម្មយុត្តិជាមន្ទីរសន្តិសុខគ្រប់គ្រងដោយថ្នាក់ស្រុក និងជាកន្លែងសម្រាប់ឃុំឃាំងអ្នកទោសធ្ងន់នៅក្នុងស្រុក។[2145] សាក្សីឈ្មោះ ហ៊ុយ គ្រឹម ដែលជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តធម្មយុត្តិ បានអះអាងថា ឈ្មោះ សុខ មានតួនាទីជាប្រធានមន្ទីរសន្តិសុខវត្តធម្មយុត្តិ រហូតដល់ចប់របបកម្ពុជាប្រជាធិបតេយ្យ។[2146]

៥២៤. ពួកឈ្លបជាអ្នកដើរយកការណ៍តាមភូមិ ហើយរាយការណ៍មកឈ្មោះ សុខ ដែលជាប្រធានមន្ទីរសន្តិសុខវត្តធម្មយុត្តិ ដើម្បីចាប់ខ្លួនមនុស្សទាំងនោះ។[2147] អ្នកទោសទាំងអស់នៅទីនោះត្រូវបានគេដាក់ខ្នោះជើង ហើយអ្នកទោសជាបុរសគេឱ្យស្លៀកតែខោខ្លី ចំណែកអ្នកទោសជាស្ត្រីត្រូវបានគេឃុំឃាំងដោយឡែកពីអ្នកទោសបុរស។[2148] ការសួរចម្លើយធ្វើឡើងនៅក្នុងព្រះវិហារ។[2149] អ្នកសួរចម្លើយធ្វើទារុណកម្មទៅលើអ្នកទោស ដោយវាយដំ ឬ យកថង់ប្លាស្ទិចមកច្រកក្បាលអ្នកទោសរហូតដល់ប្រកាច់ ហើយក្នុង ១ (មួយ) ថ្ងៃគេធ្វើបែបនេះលើអ្នកទោស ៣ (បី) ឬ ៤ (បួន) នាក់។[2150] អ្នកទោសត្រូវបានគេនាំចេញពីកន្លែងឃុំឃាំង រួចយកមកសួរចម្លើយនៅក្នុងព្រះវិហារ មុននឹងយកទៅកន្លែងសម្លាប់។[2151]

៥២៥. សាក្សីម្នាក់អះអាងថាខ្លួនធ្លាប់ឃើញការសម្លាប់អ្នកទោសប្រហែល ២០ (ម្ភៃ) ទៅ ៣០ (សាមសិប) នាក់ មានបុរស ស្ត្រី និងកុមារ នៅកន្លែងមួយមានចម្ងាយប្រហែល ១០០ (មួយរយ) ម៉ែត្រ ខាងត្បូងវត្តធម្មយុត្តិ។ សាក្សីបន្ថែមថា អ្នកទោសត្រូវគេដឹកតាមឡាន



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ហើយទាហានខ្មែរក្រហមយកអ្នកទោសម្តងមួយៗ មកវាយសម្លាប់នឹងដំបង ឬបំពង់ទីប រួចទម្លាក់ទៅក្នុងរណ្តៅ។[2152]

៥២៦. សមាជិកក្នុងកងចល័តដែលធ្វើការនៅក្បែរមន្ទីរសន្តិសុខវត្តធម្មយុត្តិ ក៏ត្រូវបានយកមកសម្លាប់នៅមន្ទីរសន្តិសុខវត្តធម្មយុត្តិដែរ។ សមាជិកកងចល័តត្រូវបានគេចាប់ខ្លួននៅពេលយប់ រួចយកទៅសម្លាប់កន្លែងមួយក្បែរវត្តធម្មយុត្តិ ដោយមានឮសម្លេងស្រែកចេញពីទីនោះ ។[2153]

៥២៧. យោងតាមរបាយការណ៍របស់ ហង់រី ឡូកា បញ្ជាក់ថា វត្តមានរបស់ពួកកម្មាភិបាលនិរតីនៅទីតាំងនេះគឺ ក្នុងខែ សីហា ឆ្នាំ ១៩៧៧។[2154] ក្នុងពេលនោះកម្មាភិបាលពាយ័ព្យត្រូវបានផ្លាស់ប្តូរ ៣ (បី) ដងរួចទៅហើយ ហើយនៅពេលមានការផ្លាស់ប្តូរម្តងៗ កម្មាភិបាលចាស់ៗត្រូវបានគេយកទៅសម្លាប់ចោល[2155] ហើយនាពេលក្រោយមកទើបកម្មាភិបាលនិរតីចាប់ផ្តើមសម្លាប់ប្រជាជន។[2156]

៥២៨. របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការប៉ាន់ស្មាន តួលេខជនរងគ្រោះចំនួនប្រហែល ១.០០០ (មួយពាន់) នាក់ ត្រូវបានសម្លាប់នៅក្នុងមន្ទីរសន្តិសុខនេះ ហើយចំនួននៃការសម្លាប់កាន់តែមានសភាព "ធ្ងន់ធ្ងរខ្លាំង" នៅក្នុងខែ វិច្ឆិកា និងខែ ធ្នូ ឆ្នាំ ១៩៧៨ នៅពេលដែលអ្នកភូមិទាំងអស់ត្រូវបានសម្លាប់ដោយកម្មាភិបាលភូមិភាគនិរតី និង "អ្នកគាំទ្រតាម៉ុក"។[2157]

## ១៦. មន្ទីរសន្តិសុខ និងការដ្ឋានភ្នំទ្រយោង

៥២៩. មន្ទីរសន្តិសុខ និងការដ្ឋានភ្នំទ្រយោង ត្រូវបានបង្កើតឡើងប្រហែលជាខែ មិថុនា ឬខែ កក្កដា ឆ្នាំ១ ៩៧៧។[2158] មន្ទីរសន្តិសុខ និងការដ្ឋាននេះ ត្រូវបានបង្កើតឡើង មុនការមកដល់របស់ក្រុមកម្មាភិបាលនិរតី។[2159] ចំពោះមន្ទីរសន្តិសុខភ្នំទ្រយោង ត្រូវបានគេចាត់ទុកថាជាគុកដ៏ធំនៅតំបន់ ៥ ហើយមន្ទីរសន្តិសុខនេះ ស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីលេខាតំបន់៥។[2160] សឿន ជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោងដោយផ្ទាល់[2161] ហើយក្នុងនាមជាប្រធាន សឿន ត្រូវរាយការណ៍ទៅគណៈតំបន់៥ ឈ្មោះ តារីន។[2162]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៥៣០. មន្ទីរសន្តិសុខ និងការដ្ឋានភ្នំទ្រយោងនេះរួមមានទាំង កន្លែងហាត់ពត់លត់ដំ កន្លែងគាស់ថ្មនិង វាយថ្ម កន្លែងឃុំឃាំង និងកន្លែងសម្លាប់មនុស្ស ជាអាទិ៍។[2163] ចំពោះអ្នកដែលត្រូវធ្វើការនៅការដ្ឋានភ្នំទ្រយោង បើជាអ្នកដែលគេទុកចិត្តគេឱ្យធ្វើការនៅឆ្ងាយៗ ផ្ទុយទៅវិញបើមិនទុកចិត្តគេតម្រូវឱ្យធ្វើការនៅកន្លែងជិតៗ ដោយហេតុថា ពេលខ្លះភាគច្រើនអ្នកដែលធ្វើការឆ្ងាយៗច្រើនតែលួចរត់។[2164] របបហូបចុកនៅការដ្ឋានភ្នំទ្រយោងត្រូវគេចែកឱ្យអង្ករ ១,៥ (មួយកៀសប្រាំ) កំប៉ុង សម្រាប់មនុស្សម្នាក់ក្នុង ១ (មួយ) ថ្ងៃ ហើយក្រោយមកថយមកត្រឹមតែមួយកំប៉ុង។[2165]

៥៣១. ម៉ោងពេលធ្វើការនៅការដ្ឋានភ្នំទ្រយោង ត្រូវចាប់ផ្តើមពីម៉ោង ៧ (ប្រាំពីរ) ព្រឹក ដល់ម៉ោង ១១ (ដប់មួយ) ថ្ងៃត្រង់ រីឯ រសៀលចាប់ពីម៉ោង ១ (មួយ) រហូតដល់ម៉ោង ៤ (បួន) ល្ងាច។[2166]

៥៣២. ការដ្ឋានភ្នំត្រយោងនេះ មានមនុស្សប្រហែលជា ៦០០ (ប្រាំមួយរយ) នាក់។[2167] ប្រជាជនមិនត្រូវបានគេអនុញ្ញាតឱ្យដើរមកជិតមន្ទីរសន្តិសុខភ្នំត្រយោងនោះទេ។[2168] ប្រជាជនទាំងឡាយណាដែលមានប្រវត្តិរូបមិនល្អ ឬ ធ្វើខុសនៅតាមសហករណ៍ ឬ ឃុំ ជាអាទិ៍ ត្រូវគេចាប់បញ្ជូនមកមន្ទីរសន្តិសុខភ្នំត្រយោង ហើយភាគច្រើនត្រូវស្លាប់។[2169] ចំពោះអ្នកទោសនៅមន្ទីរសន្តិសុខ និងការដ្ឋានភ្នំទ្រយោង ភាគច្រើនជាប្រជាជនថ្មី ឬ ជាប្រជាជន ១៧ មេសា។[2170] អ្នកទោសនៅមន្ទីរសន្តិសុខនេះ ត្រូវបានចាប់បញ្ជូនមកតាមរយៈរទេះសេះតាមឡាន ពេលខ្លះ ១ (មួយ) នាក់ ឬ ២ (ពីរ) នាក់ ឬ ១ (មួយ) គ្រួសារ។[2171]

៥៣៣. ចំពោះរោងសម្រាប់ឃុំឃាំងមនុស្សនីមួយៗ គេអាចដាក់មនុស្សបានប្រហែលជា ៥០ (ហាសិប) នាក់ ដោយគេដាក់ខ្នោះវែងជាជួរតែម្តង។[2172] អ្នកទោសធ្ងន់ត្រូវគេដាក់ខ្នោះ នៅក្នុងរោងមួយដែលស្ថិតនៅខាងជើងភ្នំទ្រយោង ប៉ុន្តែ បើពេលដែលត្រូវគេយកទៅសម្លាប់គេចាប់យកចេញទៅតែម្តង។[2173] អ្នកទោសនៅមន្ទីរសន្តិសុខភ្នំទ្រយោង ជារឿយៗតែងត្រូវគេនាំយកទៅសម្លាប់នាពេលយប់។[2174]

៥៣៤. នៅដើមឆ្នាំ ១៩៧៨ មានប្រជាជនវៀតណាមប្រមាណជា ១.០០០ (មួយពាន់) គ្រួសារ ត្រូវបានគេបញ្ជូនមកសម្លាប់នៅមន្ទីរសន្តិសុខភ្នំទ្រយោង។[2175] ពេលជិតដួលរលំរបបខ្មែរ



ECCC * C.E.T.C * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ប្រជាធិបតេយ្យ អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខភ្នំត្រយោងត្រូវគេបញ្ចេញយកទៅសម្លាប់ទាំងអស់ ក្រោមការចេញពីបញ្ជាដោយផ្ទាល់ពី តាសឿន ដោយមានយោធាប្រមាណជា ៣០ (សាមសិប) នាក់ ជាអ្នកសម្លាប់អ្នកទោសទាំងនោះ។[2176] នៅពេលសម្លាប់ អ្នកទោសត្រូវគេឱ្យលុតជង្គង់នៅមាត់រណ្តៅ ហើយត្រូវគេវាយនឹងដំបង ឬ ត្បូងចបកាប់ទាំងដៃនៅជាប់ចំណងគួរឱ្យសង្វេគ។[2177] សាក្សីមួយរូបលើកឡើងថា "អ្នកទោសមានប្រុសមានស្រី ហើយអ្នកទោសប្រុសមានសម្លៀកបំពាក់ជាប់ខ្លួន ចំណែកអ្នកទោសស្រីគ្មានសម្លៀកបំពាក់នោះទេ"។[2178]

៥៣៥. អ្នកដែលត្រូវបានគេចាប់បញ្ជូនមក មន្ទីរសន្តិសុខភ្នំទ្រយោងមានរាប់ទាំង មនុស្សដែលលួចរបស់របរគេ។[2179] ចំពោះមនុស្សទាំងឡាយណា ដែលចាប់បានមកពីតាមកងចល័តនៅក្នុងស្រុកព្រះនេត្រព្រះ ក៏ត្រូវបានគេបញ្ជូនមកមន្ទីរសន្តិសុខភ្នំត្រយោង។[2180] អ្នកទោសនៅមន្ទីរសន្តិសុខភ្នំត្រយោងមានពីរប្រភេទគឺ អ្នកទោសស្រាល និងអ្នកទោសធ្ងន់។[2181] ចំពោះអ្នកទោសស្រាល ត្រូវគេចាប់មកឃុំដោយសារមានកំហុសបន្តិចបន្តួច ហើយក៏ដោះលែងទៅវិញ រីឯ អ្នកទោសធ្ងន់នឹងត្រូវគេយកទៅសម្លាប់។[2182] អ្នកទោសជាច្រើននាក់ ត្រូវបានគេយកទៅសម្លាប់នៅជើងភ្នំទ្រយោង។[2183] តាមការប៉ាន់ប្រមាណរបស់សាក្សីថា មានជនរងគ្រោះជាច្រើននាក់ត្រូវបានគេយកមកសម្លាប់នៅមន្ទីរសន្តិសុខភ្នំត្រយោង ប៉ុន្តែពុំអាចកំណត់នូវចំនួនជាក់លាក់បានឡើយ។[2184]

## ១៧. ការដ្ឋានស្ពានស្រែង និងព្រៃរនាម

៥៣៦. ការដ្ឋានស្ពានស្រែង និងព្រៃរនាម មានទីតាំងស្ថិតនៅក្នុងស្រុកព្រះនេត្រព្រះ តំបន់ ៥ ភូមិភាគពាយ័ព្យ ។ ការកសាងទំនប់ស្ពានស្រែងមានប្រវែង ៨ (ប្រាំបី) គីឡូម៉ែត្រ។[2185]

៥៣៧. មានមនុស្ស ១.៣០០ (មួយពាន់បីរយ) នាក់ ត្រូវបានដាក់ពង្រាយនៅតាមការដ្ឋាន។ នៅក្នុងការដ្ឋាននេះ មានការធ្វើការងារដោយបង្ខំ កង្វះអាហារ និងសម្លៀកបំពាក់ ក៏ដូចជាការគំរាមសម្លាប់ និងការសម្លាប់ចំពោះកំហុសតូចតាច។[2186]



C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៥៣៨. មានសាក្សីជាច្រើនដែលស្ថិតនៅទីតាំងខាងលើបានរៀបរាប់ថាគេមិនធ្លាប់ឮ ឬ ធ្លាប់ស្គាល់ **តាទិត្យ** ទេ។ សាក្សីខ្លះថា ធ្លាប់ឮឈ្មោះ **តាទិត្យ** តែមិនបានដឹងពីតួនាទីរបស់គាត់ទេ។

៥៣៩. ជាក់ស្តែង សាក្សី ឈិត យឿក ដែលធ្លាប់ជាឈ្លប និងបន្ទាប់មកធ្វើការផ្នែករដ្ឋបាល ក្នុងស្រុកព្រះនេត្រព្រះ[2187] ពីឆ្នាំ១៩៧៥ ថា "ខ្ញុំធ្លាប់ឮឈ្មោះ **តាទិត្យ** ប៉ុន្តែមិនដែលស្គាល់ទេ"។[2188] សាក្សីម្នាក់ទៀតឈ្មោះ ទុំ សឿន ដែលត្រូវបានផ្លាស់ពីត្រាំកក់ទៅភូមិភាគពាយ័ព្យក្នុងខែ មីនា ១៩៧៧[2189] ឱ្យធ្វើជាប្រធានកងចល័តតំបន់ ៥[2190] ភូមិភាគពាយ័ព្យ បានឆ្លើយថា **តា ទិត្យ** ត្រូវជាកូនប្រសារតាម៉ុក តែមិនដឹងពីតួនាទីទេ ព្រោះ **តាទិត្យ** ត្រូវបានបញ្ជូនទៅតំបន់៣ នៅបាត់ដំបង។ រីឯសាក្សី ប៊ូ ម៉ៅ ធ្វើការក្នុងកងចល័តតំបន់ ៥[2191] និយាយថា មិនដែលឮឈ្មោះ **តាទិត្យ**។[2192] សាក្សី និត ស៊ីត់ វិញក៏បានអះអាងស្របគ្នាថា មិនដែលឮឈ្មោះ **តាទិត្យ** ឡើយ។[2193]

## ១៨. ការរំលោភផ្លូវភេទនៅស្រុកព្រះនេត្រព្រះ

៥៤០. យោងតាមសក្ខីកម្មរបស់សាក្សីឈ្មោះ ភាច រស់ បានឱ្យដឹងថា តាមបញ្ជារបស់ពួកនិរតី[2194] ក្នុងឆ្នាំ១៩៧៧[2195] នៅកូនដំរីក្នុងស្រុកព្រះនេត្រព្រះ នារីជនជាតិវៀតណាមជាបងប្អូនបង្កើត ២ (ពីរ) នាក់ដែលរស់នៅស្រុកខ្មែរជាយូរមកហើយឈ្មោះ សាន់ និងឈ្មោះ នួន ត្រូវបានប្រធានកងលេខ ៣០ របស់ស្រុកព្រះនេត្រព្រះកោះហៅ។[2196] កងចល័តនៃកងលេខ ៣០ ចំនួន ១៥ (ដប់ប្រាំ) នាក់ បានរំលោភផ្លូវភេទលើពួកនាងទាំង ២ (ពីរ) នាក់។[2197] ក្រោយមក ពួកកងចល័តបានយក ដងចបជីកបុកប្រដាប់ភេទពួកនាងបណ្តាលឱ្យរងរបួសហូរឈាម។[2198] នារីទាំង ២ (ពីរ) នាក់នេះត្រូវបានសម្លាប់នៅវាលដង្កៀបក្តាម[2199] ដោយថ្លើមរបស់ពួកនាងត្រូវបានរះយកទៅឆាស៊ី។[2200]

៥៤១. សក្ខីកម្មរបស់ឈ្មោះ ភាច រស់ នេះមិនស៊ីសង្វាក់ទាល់តែសោះជាមួយនឹងសក្ខីកម្មរបស់ឈ្មោះ លីន ញ៉ក់ ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនោះទេ។[2201] តាមពិតទៅ សក្ខីកម្មរបស់ឈ្មោះ លីន ញ៉ក់ នេះ បានលើកឡើងអំពីការសម្លាប់បងស្រីធំរបស់គាត់តែម្នាក់គត់ឈ្មោះថា លីន ផល្លី ដែលត្រូវបានគេចោទថាជាជនជាតិវៀតណាមដោយសារតែស្បែកពណ៌ស និងត្រូវបានរំលោភ



ECCC * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ធ្វើទារុណកម្ម ហើយសម្លាប់ចោលនៅក្នុងស្រុកមោងឫស្សី ខេត្តបាត់ដំបង ក្នុងឆ្នាំ១៩៧៨ ទៅវិញ។[2202]

៥៤២. មិនមានសាក្សីណាម្នាក់បាននិយាយអំពីការចូលរួមរបស់ **តាទិត្យ** ទៅលើទីតាំងនេះទេ។

## ១៩. វត្តព្រះនេត្រព្រះ ទីតាំងឃុំខ្លួន និងទីតាំងសម្លាប់មនុស្ស ពាក់ព័ន្ធនានា (ចំការដូង ចំការយាយនឹង ចំការតាលីង)

៥៤៣. វត្តព្រះនេត្រព្រះ មានទីតាំងស្ថិតនៅក្នុងឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ នៅក្នុងវត្តនេះ មានមន្ទីរពេទ្យមួយ។[2203] មន្ទីរពេទ្យមិនត្រូវបានគេធ្វើជាគុកទេ។[2204] មានកន្លែងសម្លាប់មនុស្សមួយចំនួន ដែលនៅក្បែរបរិវេណវត្តព្រះនេត្រព្រះរួមមាន ចំការយាយនឹង ចំការដូង និងចំការតាលីង។ ចំការដូងស្ថិតនៅជិត និងទល់មុខគ្នានឹងចំការយាយនឹង មានចម្ងាយពី ១.០០០ (មួយពាន់) ទៅ ១.៥០០ (មួយពាន់) ម៉ែត្រ ប៉ែកពាយ័ព្យនៃផ្ទះតាក្រក។[2205] បន្ថែមពីលើនេះ មានផ្ទះរបស់តាក្រកដែលជាសមាជិកឃុំព្រះនេត្រព្រះ ស្ថិតនៅខាងជើង និងចំងាយ ៨០០ (ប្រាំបី) ម៉ែត្រ ពីវត្តព្រះនេត្រព្រះ។[2206]

៥៤៤. សាក្សីបានអះអាងថា អ៊ឹម ចែម ដែលជាលេខាស្រុកព្រះនេត្រព្រះ ធ្លាប់រៀបចំប្រជុំជាច្រើននៅក្នុងវត្តព្រះនេត្រព្រះ និងមានមនុស្សចូលរួមធំមួយ[2207] ហើយបាននិយាយពីសាមគ្គីភាពរួមរស់ជាមួយគ្នា។[2208]

៥៤៥. មនុស្សត្រូវបានចាប់ខ្លួនដោយ កម្មាភិបាលស្រ្តីមកពីភូមិភាគនិរតី ហើយយកទៅឃុំនៅផ្ទះតាក្រក[2209] មុនពេលដែលពួកគេត្រូវបានសម្លាប់នៅក្នុងចំការក្បែរនោះនាពេលយប់។[2210] ជាក់ស្តែង សាក្សីបានអះអាងថា មានការសម្លាប់នៅក្នុងចំការតាលីង។[2211] ទោះបីជាយ៉ាងនេះក្តី សាក្សីខ្លះ អះអាងថា មិនមានការសម្លាប់ក្នុងទីតាំងនេះទេ។ សាក្សីផ្សេងទៀតបានអះអាងថា ការសម្លាប់បានធ្វើឡើងជាទ្រង់ទ្រាយធំនៅខាងក្រោយផ្ទះរបស់តាក្រក មុនពេលដែលកងទ័ពវៀតណាមបានចូលមកដល់។[2212]



C.E.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៩៤៦. បន្ថែមលើការសម្លាប់ មានមនុស្សដែលស្លាប់ក្នុងមន្ទីរពេទ្យដោយសារជំងឺ ខ្វះការព្យាបាល និងថ្នាំត្រឹមត្រូវ។ សាកសពត្រូវបានដុត[2213] ឬ ត្រូវបានកប់ជុំវិញបរិវេណវត្ត[2214] ឬ នៅចំការដូង ចំការឃាយនឹង[2215] ឬ ចំការតាលីង។[2216] ជនរងគ្រោះភាគច្រើនជាបុរស ហើយត្រូវបានប៉ាន់ប្រមាណថា មានចំនួន ៦៦០ (ប្រាំមួយរយហុកសិប) ទៅ ៧២០ (ប្រាំពីររយម្ភៃ) នៅក្នុងចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៦។[2217]

៩៤៧. មិនមានសាក្សីណាម្នាក់បាននិយាយអំពីការចូលរួមរបស់ **តាទិត្យ** ទៅលើទីតាំងនេះទេ។

## ២០. ទីតាំងសម្លាប់មនុស្ស ភូមិចក្រី

៩៤៨. ទីតាំងសម្លាប់មនុស្សភូមិចក្រីស្ថិតនៅប៉ែកខាងលិចនៃមន្ទីរស្រុកព្រះនេត្រព្រះ[2218] ក្នុងភូមិចក្រី ឃុំជប់ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។[2219]

៩៤៩. ភ័ស្តុតាងទំនងជាបង្ហាញថា ប្រជាជនត្រូវបានគេឃុំមួយរយៈពេលខ្លីនៅមន្ទីរសន្តិសុខភូមិចក្រីនៅមុនពេលគេសម្លាប់ចោល ហើយយ៉ាងហោចណាស់មានអ្នកជាប់ឃុំឃាំងនៅទីតាំងផ្សេងមួយទៀត ត្រូវបានគេយកទៅទីតាំងនោះដើម្បីសម្លាប់ចោល។[2220] ជនរងគ្រោះនៃការកាប់សម្លាប់នៅទីតាំងភូមិចក្រី មានទាំងប្រជាជន "ចាស់" និង "ប្រជាជនថ្មី" ដែលត្រូវបានគេចោទថាមានកំហុសសីលធម៌ ឬ ជាទាហាន លន់ នល់។[2221]

៩៥០. គេបានរកឃើញ រណ្តៅ និងឆ្អឹង នៅទីតាំងនោះក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។[2222] យោងតាមការប៉ាន់ស្មាន ចំនួនមនុស្សដែលត្រូវគេសម្លាប់មានចន្លោះពី ១.៨២៥ (មួយពាន់ប្រាំបីរយម្ភៃប្រាំ) នាក់ ទៅ ៧.៣០០ (ប្រាំពីរពាន់បីរយ) នាក់។ ទោះបីជាយ៉ាងនេះក្តី សាក្សីម្នាក់ទៀតបញ្ជាក់ថា មនុស្សប្រហែល ២០០ (ពីររយ) នាក់ត្រូវបានគេសម្លាប់នៅភូមិចក្រី។ សាក្សីនេះបន្ថែមថា មនុស្សប្រាំទៅដប់នាក់នៅពេលនោះត្រូវបានគេដឹកយកទៅសម្លាប់ចោលម្តងមួយៗ។[2223]

៩៥១. មិនមានសាក្សីណាម្នាក់បាននិយាយអំពីការចូលរួមរបស់ តាទិត្យ ទៅលើទីតាំងនេះទេ។



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

## ២១. ទីតាំងសម្លាប់មនុស្ស ព្រៃតារ៉ុត

៥៥២. ភស្តុតាងបង្ហាញថា ព្រៃតារ៉ុតគឺជាវាលពិឃាត មានទីតាំងស្ថិតនៅភូមិក្រសាំងថ្មី ឃុំជប់[2224] ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ តំបន់ ៥ ភូមិភាគពាយ័ព្យ ភាគឦសាន នៃភូមិចក្រី និង មន្ទីរស្រុក។[2225] ទីតាំងសម្លាប់មនុស្សនេះត្រូវបានប្រើប្រាស់ដំបូង ក្រោយពេលកម្មាភិបាល ភូមិភាគនិរតីបានមកដល់នៅចុងឆ្នាំ ១៩៧៨ ឬ ដើមឆ្នាំ ១៩៧៨។[2226]

៥៥៣. សាក្សីម្នាក់រម្លឹកថា កងទ័ពដែលដឹកមនុស្សទៅវាលពិឃាតព្រៃតារ៉ុត អាចទំនងជាកងឈ្លប មកពីថ្នាក់ស្រុក ឬ សហករណ៍។[2227]

៥៥៤. ក្រោមការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំភូមិភាគនិរតី បុរស ស្ត្រី ក្មេងៗ ទារក និងមនុស្ស ចាស់[2228] ត្រូវបានគេដឹកតាមឡានជាប្រចាំទៅព្រៃតារ៉ុត និងក្រោយមកត្រូវបានគេសម្លាប់ ចោលជាញឹកញាប់នៅពេលល្ងាច។[2229] សាក្សីពិពណ៌នាថា ឡានពុំសូវមកញឹកញាប់នោះទេ នៅដើមឆ្នាំ ១៩៧៨ ប៉ុន្តែ ឡានទាំងនេះមកកាន់តែច្រើនឡើងនៅចាប់ពីខែមិថុនា ឬ ខែកក្កដា ឆ្នាំ ១៩៧៨ រហូតដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យ។[2230] សាក្សីក៏បានផ្តល់ភស្តុតាងអំពី ការកាប់សម្លាប់[2231] ការឮសម្លេងស្រែក និងសម្រែកនៅក្នុងអំឡុងពេលកាប់សម្លាប់[2232] ហើយបានឃើញសាកសពនៅទីតាំងនោះនៅមុនពេលរបបកម្ពុជាប្រជាធិបតេយ្យបានដួល រលំ។[2233]

៥៥៥. ការប៉ាន់ស្មានផ្តល់ជូនដោយសាក្សីរបស់ ក.ស.ច.ស ដែលបានឃើញរណ្តៅនោះ មានចំនួន ជនរងគ្រោះខុសៗគ្នាពីចំនួនតិចជាង ១០០ (មួយរយ) នៅក្នុង ៣ (បី) រណ្តៅ ទៅរាប់រយ នាក់នៅក្នុង ២ (ពីរ) រណ្តៅ។[2234] បើយកចំនួនប៉ាន់ស្មានទាបបំផុតសម្រាប់រណ្តៅចំនួន ៥ (ប្រាំ) វាផ្តល់ភស្តុតាងគ្រប់គ្រាន់អាចឲ្យយើងជឿជាក់ថា បើគិតរណ្តៅរួមគ្នា ជនរងគ្រោះ មានចំនួនយ៉ាងហោចណាស់ ១០០ (មួយរយ) នាក់។

៥៥៦. មិនមានសាក្សីណាម្នាក់បាននិយាយអំពីការចូលរួមរបស់ តាទិត្យ ទៅលើទីតាំងនេះទេ។



CO-INVESTIGATING JUDGES · CO-JUGES D'INSTRUCTION · E.C.C.C · C.E.T.C

# ២២. ទីតាំងសម្លាប់ ល្អាងគួយយំ

៥៥៧. ល្អាងគួយយំជាល្អាងតូចមួយ[2235] មានទីតាំងនៅខាងក្រោយវិទ្យាល័យអូរប្រាសាទ ស្ថិតនៅភូមិភ្នំធំ ឃុំអូរប្រាសាទ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ក្នុងតំបន់ ៣ នៃភូមិភាគពាយ័ព្យ។[2236] នៅចន្លោះពីឆ្នាំ១៩៧៨ ដល់ ដើមឆ្នាំ ១៩៧៩ ល្អាងនេះជាទីតាំងសម្លាប់របស់ពួកនិរតី គឺមានប្រជាជន ៥០០ (ប្រាំរយ) នាក់ ត្រូវបានសម្លាប់នៅទីនេះ។[2237]

៥៥៨. សាក្សីដែលធ្វើការវាយថ្មនៅភ្នំធំក្នុងតំបន់ ៣ បានឃើញ កម្មាភិបាលនិរតីមកដល់ការដ្ឋានវាយថ្មភ្នំធំ នៅខែ តុលា ឆ្នាំ ១៩៧៨ និងបានចាប់កម្មាភិបាលពាយ័ព្យទាំងអស់ ទាំងថ្នាក់ដឹកនាំតូចធំយកទៅបាត់ ហើយពួកនិរតីទទួលតំណែងជំនួសវិញ។[2238] សាក្សីបំភ្លឺថា ពួកនិរតីឱ្យប្រជាជនរួមទាំងសាក្សីធ្វើការឥតឈប់ គឺធ្វើ ២៤ (ម្ភៃបួន) ម៉ោងក្នុង ១ (មួយ) ថ្ងៃ និងឱ្យបបររាវ២ពេលក្នុងមួយថ្ងៃ។ បើនរណាមិនអាចធ្វើបាន គឺគេយកទៅសម្លាប់ ឬ ចាប់ដាក់គុក។ ខណៈនោះដោយសារទ្រាំទ្រនឹងការងារធ្ងន់មិនបាន សាក្សីក៏ត្រូវជាប់គុកនៅមន្ទីរសន្តិសុខភ្នំធំ ១៨ (ដប់ប្រាំបី) ថ្ងៃ រហូតដល់វៀតណាមចូលរំដោះ។[2239] គាត់អះអាងថា ពួកនិរតីធ្វើទារុណកម្មគាត់ដោយចងដៃទៅក្រោយយ៉ាងតឹង ស្ទើរដកដង្ហើមមិនរួច និងវាយនឹងខ្សែពួរ ហើយអ្នកទោស ២០០ (ពីររយ) ទៅ ៣០០ (បីរយ) នាក់ត្រូវដាក់ខ្នោះជើងឈើជាច្រើនជួរ មានប្រវែង ១,៨ (មួយក្បៀសប្រាំបី) ទៅ ២ (ពីរ) ម៉ែត្រ ដែលដាក់មនុស្សបាន ៥ (ប្រាំ) នាក់ និងឃុំនៅរោងវែងៗ។[2240] សាក្សីដដែលគិតថា មុនវៀតណាមចូល ១ (មួយ) ខែ ប្រជាជនដែលត្រេកអរនឹងការចូលមកដល់របស់វៀតណាម ត្រូវបានកម្មាភិបាលនិរតីយកទៅសម្លាប់នៅល្អាងគួយយំ។[2241] សាក្សីបន្តថា ២ (ពីរ) ឬ ៣ (បី) ខែ ក្រោយវៀតណាមចូល សាក្សី និងប្អូនថ្លៃស្រីបានទៅប្រមូលអាចម៍ប្រចៀវនៅល្អាងគួយយំ ហើយបានឃើញឈាមពាសពេញលើថ្មជុំវិញមាត់ល្អាង និងមានសាកសពប្រហែល ១០ (ដប់) នាក់ ដៃត្រូវចងជាមួយខ្សែនីឡុង ហើយគាត់គិតថាជាសាកសពប្រជាជនដែលត្រេកអរ ១ (មួយ) ខែ មុនវៀតណាមចូលមកដល់។[2242]

៥៥៩. សាក្សីមិនបានបំភ្លឺពីតួនាទី និងសកម្មភាពចូលរួមរបស់ **តាទិត្យ** នៅទីតាំងសម្លាប់ល្អាងគួយយំ ក្នុងតំបន់៣ ឡើយ។ សាក្សីក៏មិនបាននិយាយពីវត្តមានរបស់ **តាទិត្យ** ហើយអ្នកស៊ើបសួរក៏មិនបានសួរពីរចនាសម្ព័ន្ធដែលពាក់ព័ន្ធនឹង **តាទិត្យ** ឡើយ។[2243]



CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION* E.C.C.C * C.E.T.C

## ២៣. ទីតាំងសម្លាប់មនុស្ស វត្តចំការខ្នុរ

៥៦០. ទីតាំងសម្លាប់មនុស្សវត្តចំការខ្នុររួមមានមន្ទីរសន្តិសុខមួយ និងទីតាំងកាប់សម្លាប់មួយដែលដំណើរការនៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ[2244] យ៉ាងហោចណាស់ពីឆ្នាំ១៩៧៦[2245] រហូតដល់យូរបំផុតចុងខែ វិច្ឆិកា ឆ្នាំ ១៩៧៨។[2246] វត្តចំការខ្នុរ ឬ វត្តជុំគិរី[2247] ស្ថិតនៅក្នុងភូមិអូរអំបិល ឃុំអូរអំបិល ស្រុកស៊ីសុផុន[2248] តំបន់ ៥[2249] ភូមិភាគពាយ័ព្យ។[2250]

៥៦១. ភ័ស្តុតាងពុំបានបង្ហាញថា នរណាជាអ្នកទទួលខុសត្រូវ ឬ គ្រប់គ្រងវត្តចំការខ្នុរ នាពេលស្ថិតក្រោមការគ្រប់គ្រងរបស់ភូមិភាគនិរតីទេ។ ទោះបីជាយ៉ាងនេះក្តី ក្រោយការដឹកនាំរបស់ភូមិភាគពាយ័ព្យ និងភូមិភាគនិរតី ប្រជាជនត្រូវបានគេឃុំឃាំង និងកាប់សម្លាប់នៅទីតាំងនោះ។ ភ័ស្តុតាងជាច្រើនបានបង្ហាញថា ការកាប់សម្លាប់កើតឡើងនៅក្នុងបរិវេណវត្ត[2251] និងទីតាំងជុំវិញ[2252]។ សាក្សីម្នាក់បានឃើញ *"សាកសពជាច្រើននៅរាយប៉ាយតាមជញ្ជាំង [វត្ត]"* ព្រមទាំងបន្ទប់មានស្នាមប្រឡាក់ឈាម និងសាកសពមនុស្សជាប់ខ្នោះដៃ និងខ្នោះជើងដែលត្រូវបានគេសម្លាប់ចោលនៅក្នុងបរិវេណវត្ត[2253] ក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៨[2254]។ សាកសពមានស្នាមជាំ និងរបួសមុខកាំបិត ហើយសាក្សីបានសន្និដ្ឋានថា ពួកគេត្រូវបានធ្វើទារុណកម្មនៅមុនពេលសម្លាប់ចោល។[2255] ចាប់តាំងពីពេលនោះមក ផ្នូរសាកសពមួយចំនួនត្រូវបានរកឃើញនៅទីតាំងនោះ។[2256]

៥៦២. ភ័ស្តុតាងអំពីចំនួនអ្នកជាប់ឃុំ និងជនរងគ្រោះនៃការកាប់សម្លាប់មានភាពខុសៗគ្នា។ ទោះបីជាយ៉ាងនេះក្តី យើងពុំឃើញមានភ័ស្តុតាងបង្ហាញច្បាស់ថាតើជនរងគ្រោះចំនួនប៉ុន្មាននាក់ត្រូវបានសម្លាប់ដោយកម្មាភិបាលភូមិភាគនិរតី។ នៅក្នុងអំឡុងពេលចុះពិនិត្យមើលទីតាំងនោះ មនុស្សពីរនាក់បានបង្ហាញអ្នកស៊ើបអង្កេតនូវរណ្តៅកប់សាកសពចំនួនប្រាំដែលរណ្តៅទាំងអស់ត្រូវបានកកាយរួចហើយ។[2257] ចំនួនមនុស្សស្លាប់មានការប៉ាន់ស្មានខុសៗគ្នា ប៉ុន្តែ តួលេខប៉ាន់ស្មានទាំងនេះពុំបានបញ្ជាក់ថាជនរងគ្រោះត្រូវបានគេសម្លាប់នៅពេលណានោះឡើយ។ សាក្សីដែលបានចូលរួមនៅក្នុងកំណាយទីតាំងនោះនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០[2258] បានរាប់សាកសពនៅក្នុងរណ្តៅចំនួន ៥ (ប្រាំ) ដោយរកឃើញចំនួន ១០ (ដប់), ១៦ (ដប់ប្រាំមួយ), ២០ (ម្ភៃ), ៤៣ (សែសិបបី) និងរាប់រយ[2259] ហើយបានឃើញរណ្តៅមួយទៀតមានសាកសពរាយប៉ាយពេញរណ្តៅ។[2260] សាក្សីម្នាក់ប៉ាន់ស្មានថា មនុស្សចំនួន

១.០០០ (មួយពាន់) នាក់បានស្លាប់[2261] ហើយសាក្សីម្នាក់ទៀតបានឃើញរណ្ដៅរួមចំនួនពីរ ដែលរណ្ដៅមួយមានសាកសពប្រហែល ១.០០០ (មួយពាន់) សាកសព។[2262]

៥៦៣. សាក្សីមិនបានបំភ្លឺពីតួនាទី និងសកម្មភាពចូលរួមរបស់ **តាទិត្យ** នៅទីតាំងនេះឡើយ។

## ២៤. ការដ្ឋានទំនប់ត្រពាំងថ្ម

៥៦៤. ការដ្ឋានទំនប់ត្រពាំងថ្ម មានទីតាំងស្ថិតនៅក្នុងភូមិត្រពាំងថ្ម ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) តំបន់ ៥ ភូមិភាគពាយ័ព្យ។[2263] ការដ្ឋានទំនប់ត្រពាំងថ្មមិនទាន់ត្រូវបានសាងសង់រួចរាល់ជាស្ថាពរទេ នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំនោះ។[2264] ជាក់ស្ដែង ការកសាងទំនប់ត្រពាំងថ្មនេះ ត្រូវបានចាប់ផ្ដើមធ្វើបន្តនៅឆ្នាំ១៩៧៦ ប៉ុន្តែ ការដ្ឋានទំនប់នេះត្រូវបានថ្នាក់លើបានចេញបញ្ជាឲ្យសម្រុកធ្វើមែនទែននៅចន្លោះឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧។[2265]

៥៦៥. ការដ្ឋានទំនប់ត្រពាំងថ្ម ត្រូវបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភូមិភាគ។[2266] តាវ៉ាល់ ជាអ្នកពាយ័ព្យ និងជាអ្នកគ្រប់គ្រងការដ្ឋានទំនប់ត្រពាំងថ្មដែរ។[2267] បន្ទាប់មក តាវ៉ាល់ ត្រូវបានគេសម្លាប់នៅចុងឆ្នាំ១៩៧៧។[2268] ក្រោយមក កម្មាភិបាលនិរតីឈ្មោះ យន (ឬ យន់) និង ទាវ បានមកជំនួសដោយបានគ្រប់គ្រងរហូតដល់ឆ្នាំ១៩៧៩។[2269]

៥៦៦. ការដ្ឋានទំនប់ត្រពាំងថ្ម គឺជាការកសាងនូវទំនប់ដ៏ធំ និងមានប្រវែងយ៉ាងវែងដោយមានបណ្ដោយប្រវែងប្រមាណជា ៨ (ប្រាំបី) គីឡូម៉ែត្រ ដោយបាតក្រោមប្រហែល ៦០ (ហុកសិប) ម៉ែត្រ ជម្រៅប្រហែលជា ៨ (ប្រាំបី) ម៉ែត្រ និងខ្នងលើប្រវែងប្រហែល ២០ (ម្ភៃ) ម៉ែត្រ។[2270] ការដ្ឋានទំនប់ត្រពាំងថ្ម មានមនុស្សប្រមាណជា ១០.០០០ (មួយម៉ឺន) នាក់ដែលធ្វើការនៅទីនោះ។[2271] សាក្សីមួយរូបបានប្រាប់ថា "*មនុស្សចូលរួមលើកទំនប់ (ទំនប់ត្រពាំងថ្ម) មានចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) នាក់ ព្រោះមានការប្រជុំសន្និបាត ដោយប្រកាសប្រាប់ថា កម្លាំងសរុបលើកទំនប់នេះមានចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) នាក់*"។[2272] ប៉ុន្តែ បើតាមឯកសារជាសារទូរលេខ ដែលកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

បានឆ្លើយប្រាប់អ្នកកាសែតយូហ្គោស្លាវីថា ការដ្ឋានទំនប់ត្រពាំងថ្មមានមនុស្សធ្វើការចំនួន ២០.០០០ (ពីរម៉ឺន) នាក់។[2273]

៥៦៧. ការលើកទំនប់គេបែងចែកជា ក្រុមមានគ្នា ១០ (ដប់) នាក់ កងតូចមានគ្នា ៣០ (សាមសិប) នាក់ កងធំមានគ្នា ១៥០ (មួយរយហាសិប) នាក់ (បីកងតូចស្មើមួយកងធំ)។[2274] អ្នកដែលចូលរួមលើកទំនប់ត្រពាំងថ្ម ភាគច្រើនជា កម្លាំងយុវជន យុវនារី កុមារ និងអ្នកមានវ័យកណ្តាលដែលនៅតាមកងចល័ត។[2275] ជាក់ស្តែង មានសាក្សីជាច្រើននាក់ធ្លាប់ត្រូវបានគេបង្ខំឱ្យមកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម។[2276]

៥៦៨. ការធ្វើការងារនៅការដ្ឋានទំនប់ត្រពាំងថ្ម មានស្ថានភាពលំបាកមែនទែន ដោយក្នុងមួយថ្ងៃតម្រូវឱ្យលើទំនប់ឱ្យបានចន្លោះប្រមាណជា ២ (ពីរ) ទៅ ៣ (បី) ម៉ែត្រគូប ក្នុងមនុស្សម្នាក់។[2277] ប្រសិនអ្នកណាមួយធ្វើការមិនគ្រប់តាមផែនការមានន័យថា បើមិនហើយទេ គេមិនឱ្យហូបបាយទេ ។[2278] ចំពោះកុមារគេក៏តម្រូវឱ្យចូលរួមជួយលើកទំនប់ដែរ ប៉ុន្តែគេមិនបានបែងចែងជាម៉ែត្រគូបដូចមនុស្សពេញវ័យទេ តែគេឱ្យកាប់ដី រែកដីចាក់លើទំនប់ទៅតាមផែនការដែលគេដាក់ឱ្យធ្វើ ។[2279]

៥៦៩. អ្នកលើកទំនប់នៅការដ្ឋានទំនប់ត្រពាំងថ្ម ត្រូវចាប់ផ្តើមធ្វើការងារតាំងពីម៉ោង ៤ (បួន) ព្រឹករហូតដល់ម៉ោង ១១ (ដប់មួយ) ថ្ងៃត្រង់ទើបបានបាយហូប និងត្រូវបន្តពីម៉ោង ១ (មួយ) រសៀលដល់ម៉ោង ៥ (ប្រាំ) ល្ងាច ទើបដល់ពេលហូបបាយល្ងាច បន្ទាប់មកត្រូវធ្វើបន្តបន្ថែមទៀតចាប់ពីម៉ោង ៦ (ប្រាំមួយ) ល្ងាចរហូតដល់ម៉ោង ៩ (ប្រាំបួន) យប់។[2280] ជាក់ស្តែង អ្នកដែលមកលើកទំនប់នៅការដ្ឋានត្រពាំងថ្មនេះ មានការហូបចុកមិនបានគ្រប់គ្រាន់ទេ រហូតដល់ពេលខ្លះត្រូវហូបស្លឹកឈើបន្ថែម ដើម្បីបានឆ្អែតពោះ។[2281]

៥៧០. ពេលធ្វើការលើកទំនប់នោះ គេតម្រូវអ្នកធ្វើការបន្តធ្វើរហូតដោយគេមិនឱ្យអង្គុយ ឬ ឈប់សម្រាកទេ លើកលែងតែ ពេលផឹកទឹកបានឈប់ប្រហែលជា ៥ (ប្រាំ) នាទីប៉ុណ្ណោះ។[2282] លើសពីនេះទៀត ពេលម៉ោងធ្វើការគេមិនអនុញ្ញាតឱ្យនិយាយគ្នាទេ ដោយម្នាក់ៗត្រូវខិតខំធ្វើការ លើកលែងតែពេលសម្រាកអាចនិយាយគ្នាបានខ្លះ ហើយចំពោះបុរសនិងស្ត្រី បើ ប៊ានតែនិយាយលេងច្រើនជាមួយគ្នាគេនឹងចោទថា "ខុសសីលធម៌"។[2283]



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

៩៧១. ចំពោះប្រព័ន្ធរាយការណ៍នៅការដ្ឋានទំនប់ត្រពាំងថ្ម ប្រធានក្រុមកងចល័តត្រូវរាយការណ៍ទៅប្រធានកងធំ រួចប្រធានកងធំត្រូវធ្វើការរាយការណ៍ជាបន្តទៅឱ្យ តាវ៉ាល់ ដែលជាអ្នកគ្រប់គ្រងរួមលើការដ្ឋានទំនប់នេះ។[2284] នៅពេលមានការរាយការណ៍ពីកងចល័តណាមួយថា សមាជិកក្នុងកងចល័តនោះមានសុខភាពល្អ ហើយខិតខំធ្វើការងារឱ្យតាមផែនការ នោះក្រុមកងចល័តនោះនឹងទទួលបានរបបហូបចុកគ្រប់គ្រាន់។[2285] ចំពោះការហូបចុកនេះ ក្រុមមេកងបានហូបបានឆ្អែត ដោយហូបបាយបានទាំងបីពេលក្នុងមួយថ្ងៃ រីឯម្ហូបវិញសម្បូរមែនទែនហើយសុទ្ធតែឆ្ងាញ់ៗរួមមាន ត្រី និងបង្កង ជាអាទិ៍។[2286]

៩៧២. អ្នកធ្វើការតាមកងចល័តនៅការដ្ឋានទំនប់ត្រពាំងថ្ម បើប្រព្រឹត្តកំហុសនឹងត្រូវគេបញ្ជូនទៅផ្នែករែកដីលេខមួយវិញ។[2287]ម្យ៉ាងវិញទៀត ក្នុងករណីដែលថ្នាក់លើបែងចែកឱ្យធ្វើប្រសិនបើប្រជាជនរូបណាធ្វើការមិនគ្រប់តាមផែនការ គេនឹងចោទថា "ជាជនក្បត់" ហើយត្រូវគេបញ្ជូនទៅដាក់ក្នុង "កងករណី" ដែលមានន័យថា "កងអ្នកមានទោស"។[2288] ចំពោះការដាក់ទណ្ឌកម្មគេឱ្យរែកដីឱ្យបាន ៣ (បី) ម៉ែត្រគូប ទៅ ៣,៥ (បីក្បៀសប្រាំ) ម៉ែត្រគូប។ នៅពេលដែលអ្នកនោះមិនធ្វើបានគ្រប់ផែនការទេ អ្នកនោះត្រូវគេយកទៅសម្លាប់។[2289] ចំពោះការស្លាប់នៅការដ្ឋានទំនប់ត្រពាំងថ្ម រាប់បញ្ចូលទាំងការស្លាប់ដោយការហូបចុកមិនបានគ្រប់គ្រាន់ និងការស្លាប់ដោយសារជំងឺជាច្រើនប្រភេទទោះយ៉ាងដូចជាជំងឺរាករូស ជំងឺអាសន្នរោគ និងជំងឺគ្រុនចាញ់ជាអាទិ៍។[2290]

៩៧៣. សាក្សីមួយរូបដែលជាអ្នកបានចូលរួមលើកទំនប់ត្រពាំងថ្ម បានលើកឡើងពីរឿងបញ្ហាអនាម័យនៃការរស់នៅ និងហូបចុកថា "*គ្មានអនាម័យទេ ស៊ីអង្ករសម្រូប អាចម៍ដូចអាចម៍ឆ្កែ។ បត់ជើងធំពាសវាលពាសកាស មានរុយច្រើនណាស់ ហើយរោមពេញក្បាល ពេលចូលក្នុងរោងហូបបាយពេលថ្ងៃ*"។[2291] លើសពីនេះ សាក្សីមួយរូបទៀតបានលើកឡើងដែរថា "*ពេលហូបបាយម្តងៗ ទាល់តែចងមុង ព្រោះមានរុយច្រើន*"។[2292] ជាក់ស្តែង ចំពោះបញ្ហាសុខមាលភាពអ្នកលើកទំនប់វិញមិនត្រូវបានគិតគូរឡើយ ដោយហេតុថាគ្មានទេមន្ទីរពេទ្យ ឬ មណ្ឌលសុខភាព ខណៈមានអ្នកឈឺ គេនឹងប្រើវិធីព្យាបាលតាមបែបបុរាណដែលមិនមានលក្ខណៈឆ្លើយតបទៅនឹងការព្យាបាលតាមវិធីត្រឹមត្រូវនោះទេ ដោយគេប្រើតែថ្នាំស្ងួនមូលៗដូចអាចម៍ទន្សាយឱ្យអ្នកជំងឺហូប ហើយភាគច្រើនមិនបានជាសះស្បើយទេ។[2293]



ECCC * C.E.T.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៥៧៤. ដោយសារតែ ការងារនៅការដ្ឋានទំនប់ត្រពាំងថ្ម មានការលំបាកពេក ក៏មានអ្នករត់ចេញពីការដ្ឋានមកផ្ទះ ហើយក្រោយមកត្រូវចាប់យកទៅសម្លាប់ទាំងអស់។[2294] ការសម្លាប់មនុស្សនៅការដ្ឋានទំនប់ត្រពាំងថ្ម ជារឿយៗតែងត្រូវធ្វើឡើងនាពេលយប់។[2295] សាក្សីមួយរូបបានលើកឡើងថា *"មានការសម្លាប់មនុស្សដោយយកទៅកប់នៅត្រចៀកស្ពានទី ១ នៃទំនប់ត្រពាំងថ្ម ហើយអ្នកទាំងនោះគឺជាអ្នកមានផ្ទៃពោះពីប្រាំខែឡើង ឬជិតគ្រប់ខែ។ ដោយគេនិយាយថា ដើម្បីធ្វើស្ពានជាប់ លុះត្រាតែយកស្ត្រីមានផ្ទៃពោះយកទៅសម្លាប់ដាក់ត្រចៀកស្ពានទើបស្ពាននោះជាប់"*។[2296]

៥៧៥. នៅឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ គណៈភូមិភាគពាយ័ព្យបានចុះមកពិនិត្យការដ្ឋានទំនប់ត្រពាំងថ្ម។[2297] រីឯគណៈកម្មាធិការមជ្ឈិមបក្សនៃបក្សកុំម្មុយនីស្តកម្ពុជា មិនដែលបានមកចុះពិនិត្យមើលការដ្ឋានទំនប់ត្រពាំងថ្មដោយផ្ទាល់នោះទេ។[2298] ទាក់ទិននឹងវត្តមានរបស់ជនត្រូវចោទ មានសាក្សីមួយរូបឈ្មោះ ជឹម ចាន់ធឿន ក៏បានលើកឡើងថា *"ខ្ញុំឮពីឈ្មោះគាត់ (តាទិត្យ) ពេលខ្ញុំទៅលើកទំនប់ត្រពាំងថ្ម ក្នុងឆ្នាំ១៩៧៨ គាត់(តាទិត្យ)ជាអ្នកក្ដាប់ តែខ្ញុំមិនដឹងថាគាត់ (តាទិត្យ)មានតួនាទីអ្វីទេ។ ខ្ញុំឮពីឈ្មោះ **តាទិត្យ** ពេលដែលខ្ញុំយកត្រី កំពឹស ទៅឱ្យមន្ទីរចាត់ការរបស់ទំនប់ ខ្ញុំក៏ឮគេនិយាយថា **តាទិត្យ** និងថ្នាក់ដឹកនាំភូមិភាគ និងតំបន់ នឹងមកត្រួតពិនិត្យទំនប់ត្រពាំងថ្ម ដូច្នេះ អ្នកគ្រប់គ្រងកន្លែងលើកទំនប់ត្រូវប្រយ័ត្នឱ្យមែនទែន"*។[2299] ផ្ទុយទៅវិញបែរជាមានសាក្សីជាច្រើននាក់ ដែលរស់នៅក្នុងស្រុកព្រះនេត្រព្រះបែរជាឆ្លើយប្រហាក់ប្រហែលគ្នាថា មិនដែលស្គាល់ **តាទិត្យ** ទាល់តែសោះ។[2300]

## ២៥. ទីតាំងសម្លាប់ ទួលពោធិ៍ជ្រៃ

៥៧៦. ទួលពោធិ៍ជ្រៃ ឬ ទួលព្រះជ្រៃ មានទីតាំងស្ថិតនៅក្នុងភូមិព្រីងខ្ពស់ ឃុំស្រែស្តុក ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់។[2301] ទួលពោធិ៍ជ្រៃ គឺជាកន្លែងសម្លាប់មនុស្ស ឬវាលពិឃាតផង និងជាកន្លែងកប់សាកសពដ៏ធំមួយផងនៅក្បែរមូលដ្ឋានទាហានសាធារណៈរដ្ឋខ្មែរ។[2302]

៥៧៧. ទួលពោធិ៍ជ្រៃមិនមែនជាមន្ទីរឃុំឃាំងទេ ប៉ុន្តែគឺជាកន្លែងសម្លាប់មនុស្សតែម្តង។ អ្នកទោសដែលជាអតីត ទាហាន លន់ នល់ និងមន្ត្រីផ្សេងៗទៀតត្រូវបានគេឃុំឃាំងនៅបន្ទាយភូមិពោធិ៍ មុនយកទៅសម្លាប់នៅទួលពោធិ៍ជ្រៃ។[2303] ប៉ុន្តែយោងតាមរបាយការណ៍ស៊ើបអង្កេត



E.C.C.C * C.E.T.C * INVESTIGATING JUDGES * JUGES D'INSTRUCTION

កំណត់អត្តសញ្ញាណទីកន្លែងខេត្តពោធិ៍សាត់ បង្ហាញថាទួលពោធិ៍ជ្រៃក៏ជាមន្ទីរសន្តិសុខទូទៅមួយដែលជាទីកន្លែងសម្រាប់ឃុំខ្លួន និងសម្លាប់ថ្នាក់ឃុំ ថ្នាក់ស្រុក និងថ្នាក់ភូមិភាគដែលត្រូវបានប្រើប្រាស់នៅក្នុងតំបន់ខេត្តពោធិ៍សាត់ ។[2304]

៥៧៨. សាក្សីបានលើកឡើងថាប្រហែលជាខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីទទួលជ័យជម្នះខ្មែរក្រហមបានប្រមូល ទាហាន នគរបាល ដែលមានបណ្តាស័ក្តិទាំងតូចទាំងធំដែលមាននិន្នាការសម័យ លន់ នល់ យកទៅឃុំខ្លួននៅបន្ទាយពោធិ៍ជ្រៃ មុនពេលយកទៅសម្លាប់ចោលនៅទួលពោធិ៍ជ្រៃ។[2305] តាមចម្លើយសាក្សី អ្នកមកពីបូព៌ាដែលនៅសហករណ៍ផ្សេងៗ និងអ្នកដែលជាប់ឃុំឃាំងនៅតាមមន្ទីរសន្តិសុខ ក៏ត្រូវបានគេយកទៅសម្លាប់នៅវាលស្រែជិតទួលពោធិ៍ជ្រៃ។[2306] ប្រជាពលរដ្ឋត្រូវបានដឹកតាមឡានដឹកទំនិញធំៗទៅកាន់វាលពិឃាត ហើយត្រូវគេប្រហារជីវិតភ្លាមៗតែម្តង។[2307] បន្ទាប់ពីការរំដោះទីរួមខេត្តពោធិ៍សាត់ ការសម្លាប់អតីតទាហាន លន់ នល់ ដែលមានឋានៈខ្ពស់ ព្រមទាំងទាហាន លន់ នល់ និងមន្ត្រីផ្សេងៗទៀត ពីរាប់រយនាក់ ( អប្បរមា ២០០នាក់) ដល់ទៅ ១.០០០ (មួយពាន់) នាក់ ឬច្រើនជាងនេះ នៅក្នុងដំណាក់កាលបន្ទាប់ពីការរំដោះ ក្រោយថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ភ្លាម ដោយបានប្រាប់ថា ពួកគេត្រូវតែឆ្លងកាត់ការរៀនសូត្រ និងទៅជួបសម្តេចឪ ហើយពួកគេនឹងទទួលបានឋានន្តរសក្តិរបស់ពួកគេមកវិញ។[2308] សាក្សីផ្សេងទៀតបានអះអាងថា សាកសពប្រហែលជាង ៣.០០០ (បីពាន់) នាក់ ត្រូវបានពួកខ្មែរក្រហមដឹកទៅដាក់នៅទួលពោធិ៍ជ្រៃ ហើយបានឈូសសាកសពប្រមូលផ្តុំគរលើគ្នា នៅក្នុងឆ្នាំ១៩៧៥។[2309]

៥៧៩. ទួលពោធិ៍ជ្រៃអាចត្រូវបានគេប្រើប្រាស់ ជាកន្លែងសម្រាប់យកសាកសពទៅបោះចោល ដោយមិនរើសមុខអស់រយៈពេលជាច្រើនឆ្នាំ បន្ទាប់ពីមានការសម្លាប់ទាហាន លន់ នល់ ដ៏ច្រើនលើសលុបរួចមក។ ប៉ុន្តែក្រោយពីមានការសម្លាប់នៅឆ្នាំ១៩៧៥រួចមក មិនឃើញមានភ័ស្តុតាងណាមួយដែលបង្ហាញថា មានព្រឹត្តិការណ៍ក្នុងលក្ខណៈប្រហាក់ប្រហែលគ្នាណាមួយបានកើតឡើងនៅទីតាំងទួលពោធិ៍ជ្រៃនេះទេ។[2310]

៥៨០. សាក្សីបានអះអាងថា រចនាសម្ព័ន្ធគ្រប់គ្រងរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧៦ រួមមាន តាកន ជាគណៈភូមិភាគ បន្ទាប់ពីតាខ្លែងជាគណៈតំបន់៧ ត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៧ តា[illegible] ឡើងជាលេខាតំបន់៧ តាតូយ ជាអនុគណៈតំបន់៧ និងតាផែង ជាគណៈតំបន់៧ [illegible]

យក់ ហង្ស ជាអភិបាលខេត្តពោធិ៍សាត់ តាម៉ៅ ជាគណៈស្រុក២១ តាសាន ជាអនុគណៈស្រុក២១ (ស្រុកកណ្តៀង អតីតស្រុកបាកាន) តាសិត ជាគណៈស្រុក។[2311] តាសុត និងតាតួយ ជាគណៈតំបន់ដំបូងរហូតដល់១៩៧៨ បន្ទាប់មកឈ្មោះ តាទ្រី ឡើងជំនួសតាសុតរហូតដល់ពេលវៀតណាមរំដោះចូលមកក្នុងឆ្នាំ១៩៧៩។[2312] មានសាក្សីបានលើកឡើងថា គណៈស្រុកឈ្មោះ សិត បានមកបញ្ជាដោយផ្ទាល់ឱ្យប្រជាជននៅក្នុងឃុំស្យា ស្រុកកណ្តៀង ដែលមាន ៥ (ប្រាំ) សហករណ៍ ឱ្យជីកប្រឡាយ និងលើកភ្លឺស្រែ។[2313]

៥៨១. សាក្សីឈ្មោះ ស៊ុយ សេងឈុន ដែលធ្លាប់ធ្វើការនៅក្នុងកងនេសាទសហករណ៍រហូតដល់ឆ្នាំ ១៩៧៩ បានអះអាងថាធ្លាប់បានទៅពិនិត្យមើលនៅទួលពោធិ៍ជ្រៃ ឃើញមានពំនូករណ្តៅធំៗ ៤ (បួន) ទៅ ៥ (ប្រាំ) កន្លែង ដែលរណ្តៅនីមួយៗមានទំហំប្រហែលជា ១០ (ដប់) ម៉ែត្របួនជ្រុង។[2314]

៥៨២. មិនមានសាក្សីណា ឬ ភ័ស្តុតាងណាដែលអះអាង ឬ បង្ហាញអំពីការចូលរួមផ្ទាល់ ឬ ដោយប្រយោលរបស់ **តាទិត្យ** នៅក្នុងទីតាំងឧក្រិដ្ឋកម្មនេះទេ។

## ២៦. ការរៀបការដោយបង្ខំនៅស្រុកសង្កែ

៥៨៣. ស្រុកសង្កែ ឬ ស្រុក ៤២ មានទីតាំងស្ថិតក្នុងតំបន់ ៤។[2315] តាសាយ ហៅ តាវ៉ៃ ដែលជាកម្មាភិបាលពាយ័ព្យ គឺជាមេស្រុកសង្កែស្ទើរពេញមួយរបប ហើយបានរត់គេចខ្លួនមុនការដួលរលំនៃរបបខ្មែរក្រហម ៣ (បី) ខែ។[2316] ប្តីប្រពន្ធឈ្មោះ តាឡឹក និងយាយចាន់ គឺជាអ្នកគ្រប់គ្រង ហើយយាយចាន់ជាមនុស្សកាច និងជាមេលើប្តី។[2317] យាយចាន់ គ្រប់គ្រងប្រមាណ ៤ (បួន) ឃុំ ស្មើនឹងពាក់កណ្តាលស្រុកសង្កែ។[2318]

៥៨៤. ការរៀបការនៅស្រុកសង្កែ កើតមាននៅសម័យក្រោមការគ្រប់គ្រងរបស់ពាយ័ព្យ និងនិរតី។[2319] ការរៀបការរបស់អ្នកភូមិសន្ទុក ភូមិបឹងឈ្លូក ភូមិក្បាលថ្នល់ ភូមិដំណាក់ដង្កោ ភូមិវាំងកេសី និងភូមិវាំងក្រោល ប្រារព្ធធ្វើនៅវត្តវាំងកេសី ខ្លះទៀតធ្វើនៅអូរស្រឡៅ បាយដំរាំ ភូមិកំពង់គោ ឃុំកំពង់ព្រៀង នៃស្រុកសង្កែ ឬ ស្រុក ៤២។[2320]



* ECCC * CETC * CO-INVESTIGATING JUDGES · CO-JUGES D'INSTRUCTION

៥៨៥. សាក្សីម្នាក់អះអាងថា ការរៀបការគឺដើម្បីកុំឱ្យមានករណីរំលោភតាមដុបតាមព្រៃ ឬ ខុសសីលធម៌។[2321]

៥៨៦. សាក្សីបាននិយាយថា មិនមានការរៀបការដោយបង្ខំនោះទេ[2322] ដោយបុរសជាអ្នកស្នើជ្រើសរើសប្រពន្ធទៅអង្គការ[2323] ឬ ជួនពេលខ្លះកម្មាភិបាលជាអ្នកស្នើរៀបចំឱ្យ។[2324] ការរៀបការត្រូវបានរៀបចំឡើងទាំងសម្រាប់កម្មាភិបាលធំ និងប្រជាជន។[2325] សាក្សីផ្តល់សក្ខីកម្មបន្ថែមទៀតថា មិនឃើញគេធ្វើអ្វីគាត់នោះទេ នៅពេលនារីប្រកែកមិនព្រមរៀបការ។[2326] ក៏ប៉ុន្តែសាក្សីម្នាក់ថា អ្នកដែលត្រូវរៀបការនោះមិនហ៊ានប្រកែកនោះទេដោយសារខ្លាច។[2327] ដោយឡែក សាក្សីម្នាក់ទៀតអះអាងថា នៅសម័យនោះ ការរៀបការនៅស្រុកសង្កែមាន ៣ (បី) ប្រភេទគឺ ទី១ ការបង្ខំឱ្យរៀបការ ទី២ ការរៀបការដោយស្ម័គ្រចិត្ត និងទី៣ ការរៀបការ ដើម្បីបាននៅសមរភូមិក្រោយ និងហូបចុកគ្រប់គ្រាន់។[2328]

៥៨៧. តាមការប្រកាសរបស់តាឡឹក និងយាយចាន់ ៣ (បី) ឬ ៤ (បួន) ខែ មុនវៀតណាមចូលមកដល់ ការរៀបការត្រូវធ្វើឡើងច្រើនគូ ដើម្បីជៀសវាងខាតពេលវេលាធ្វើការងារដូចជាការដកស្ទូង វែកដី ជាដើម។[2329] ការរៀបការម្តងៗមានប្រមាណ ១០ (ដប់), ១៥ (ដប់ប្រាំ), ២០ (ម្ភៃ), ៣០ (សាមសិប), ៧៥ (ចិតសិបប្រាំ) ទៅ ៨០ (ប៉ែតសិប) គូ[2330] ដោយកម្មាភិបាលដែលរៀបការអង្គុយលើកៅអី ហើយប្រជាជនអង្គុយលើជុំឥដ្ឋ។[2331] គ្មានពិធីសាសនា ឬ ប្រពៃណីត្រូវបានធ្វើឡើងនោះទេ។[2332] កម្មាភិបាល គឺជាអធិបតីនៃការរៀបការ[2333] ហើយពេលខ្លះ តាប៉ែត ជាអធិបតីហើយឡើងប្រកាសណែនាំកុំឱ្យឈ្លោះប្រកែកគ្នា។[2334] ពិធីប្រារព្ធនៅម៉ោង ៦ (ប្រាំមួយ) ល្ងាច និងបំភ្លឺពិធីដោយការដុតចង្កៀងដូង។[2335] អ្នករៀបចំបានឡើងប្រកាសអំពីការក្លាយទៅជាប្តីប្រពន្ធ ដោយប្តីប្រពន្ធថ្មីត្រូវចាប់ដៃគ្នាឡើងប្តេជ្ញា រួចហើយចែកបបរាវឱ្យម្នាក់ ១ (មួយ) វែកត្រឡប់ទៅផ្ទះវិញ។[2336] សាច់ញាតិខ្លះក៏បានមានវត្តមានក្នុងពិធីរៀបការញាតិរបស់គេដែរ។[2337]

៥៨៨. សាក្សីនិយាយថា ក្រោយរៀបការរួច មិនមានអ្នកណាតាមឈ្លបយកការណ៍នោះទេ។[2338] ខណៈសាក្សីម្នាក់ទៀតអះអាងថា មានឈ្លបដើរតាមដានអ្នកដែលរៀបការដែលមិនត្រូវរ៉ូវគ្នា រួចរាយការណ៍ទៅថ្នាក់លើ។[2339] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

ម្នាក់បានឆ្លើយថា ប្ដីប្រពន្ធជាគូឃរបស់គាត់ដែលប្រកែកមិនព្រមរួមដំណេកជាមួយគ្នា ត្រូវបានរៀបការជាមួយអ្នកផ្សេងរៀងៗខ្លួនក្នុងពេលជាមួយគ្នាម្ដងទៀត។[2340]

## គ. ចំនួនជនរងគ្រោះ

៩៨៩. អង្គហេតុចំនួន ៥០ (ហាសិប) មានមន្ទីរសន្ដិសុខ ទីតាំងសម្លាប់មនុស្ស និង ការដ្ឋានការងារដោយបង្ខំ ត្រូវបានចោទក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ អង្គហេតុនៃទីតាំងឧក្រិដ្ឋកម្ម ចំនួន ២៤ (ម្ភៃបួន) ត្រូវបានដាក់ក្រោមការពិនិត្យ (ការស៊ើបសួរ) របស់សហចៅក្រមស៊ើបអង្កេត ក្រៅពីនេះមិនត្រូវបានដាក់ក្រោមការពិនិត្យទេ ដោយសារមិនមានភ័ស្តុតាងច្រើនពាក់ព័ន្ធនឹងជនត្រូវចោទ។ សហចៅក្រមស៊ើបអង្កេតជាតិបានពិចារណាភ័ស្តុតាង ពាក់ព័ន្ធនឹងចំនួននៃជនរងគ្រោះ។ សាក្សីបានអះអាងពីចំនួនជនរងគ្រោះស្លាប់ ឬ ត្រូវបានសម្លាប់។ ក៏ប៉ុន្តែ ទីតាំងចំនួន ១ (ស្រុកសំឡូត) មិនមានព័ត៌មានអំពីជនរងគ្រោះ និងមិនមានការបញ្ជាក់ថាមានចំនួនប៉ុន្មានទេ សម្រាប់ទីតាំងឧក្រិដ្ឋកម្ម (ទីតាំងសម្លាប់មនុស្សវត្តអង្គុណ, ព្រៃភូមិស្លែង និងមន្ទីរសន្តិសុខភូមិវាល)។ តាមការបូកសរុប មានជនរងគ្រោះចំនួនប្រហែល ៥៣០៥០ (ប្រាំម៉ឺនបីពាន់ហាសិប) នាក់ បានស្លាប់ ឬ ត្រូវបានសម្លាប់។

៩៩០. ភ័ស្តុតាងបានបង្ហាញថា **យឹម ទិត្យ** មានជាប់ពាក់ព័ន្ធនឹងទីតាំងមួយចំនួនដូចជា មន្ទីរសន្តិសុខវត្តប្រធាតុ, ការដ្ឋានទំនប់កង្កួត, រោងចក្រស្ករសកំពង់គុល និង ស្រុកសំឡូត តាមរយៈការទៅពិនិត្យ ឬការដឹកនាំប្រជុំនៅទីតាំង។ ទោះបីជាយ៉ាងនេះ ភ័ស្តុតាងមិនបានបង្ហាញថាចំនួនមនុស្សស្លាប់ ឬសម្លាប់ ភ្ជាប់នឹងទង្វើរបស់ យឹម ទិត្យទេ។ ជាចុងក្រោយ វាមានភាពមិនច្បាស់លាស់អំពីចំនួនប៉ុន្មានត្រូវបានសម្លាប់ និងប៉ុន្មានស្លាប់ ដូចជាដោយសារជំងឺ ឬដោយសារអត់អាហារ និងស្លាប់ ឬសម្លាប់មុនពេល **យឹម ទិត្យ** ទៅដល់ភូមិភាគពាយ័ព្យ។

## ជំពូក៥. ការពិចារណាលើភស្តុតាង

### ក. ការធ្វើសម្ភាសន៍ដែលមិនមែនជាកំណត់ហេតុស្តាប់ចម្លើយ ដែលបង្កើតឡើងដោយសហចៅក្រមស៊ើបអង្កេត

៥៩១. ភាគច្រើនលើសលុប ចំពោះភស្តុតាងត្រូវបានពឹងផ្អែកក្នុងសំណុំរឿងលេខ០០៤ រួមមាន៖ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែលត្រូវបង្កើតឡើងដោយ ក.ស.ច.ស ក្នុងពេលស៊ើបសួរដែលត្រូវបានរៀបចំក្រោមការត្រួតពិនិត្យពីតុលាការ និង ជាកម្មវត្ថុនៃការធានាយ៉ាងជាក់លាក់ ដោយអនុលោមតាមនីតិវិធីត្រឹមត្រូវ។ ហេតុដូច្នេះ ប្រភេទនៃភស្តុតាងបែបនេះត្រូវទទួលបាននូវសច្ចធារណ៍នៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន។[2341] យើងពិចារណាថា ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការមកពីសំណុំរឿងផ្សេងទៀតនៅ អ.វ.ត.ក ហើយដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងលេខ០០៤ ដោយសារតែភាពពាក់ព័ន្ធរបស់ប្រតិចារឹកទាំងនោះជាមួយការចោទប្រកាន់នានា ត្រូវទទួលបាននូវសច្ចធារណ៍ដូចគ្នា។

៥៩២. ការធ្វើសម្ភាសន៍ ឬ ភស្តុតាងដទៃទៀត ដែលត្រូវបានប្រមូលដោយមិនមានការត្រួតពិនិត្យមើលតាមផ្លូវតុលាការ ដោយស្ថាប័នណាមួយដែលមិនស្ថិតក្នុង អ.វ.ត.ក នោះមិនត្រូវទទួលបាននូវសច្ចធារណ៍បែបនេះឡើយ។[2342]ករណីលើកលែង សម្រាប់វិធាននេះត្រូវបានតំណាងដោយការស្តាប់ចម្លើយដែលរៀបចំឡើងដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ត្រូវទទួលបាននូវសច្ចធារណ៍អាចបដិសេធបាននៃភាពពាក់ព័ន្ធ និង ភាពអាចជឿជាក់បានបឋម។[2343] ទោះជាយ៉ាងនេះក្តី ការស្តាប់ចម្លើយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានបង្កើតឡើងដោយមិនមានការធានាតាមផ្លូវតុលាការ និងមិនមានភាពផ្លូវការដែលកំណត់លក្ខណៈនៃកំណត់ហេតុនោះឡើយ។

៥៩៣. ជុំវិញការស្តាប់ចម្លើយដែលធ្វើឡើងដោយ សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងអំឡុងពេលស៊ើបអង្កេតបឋម បើទោះបីជាត្រូវបានរៀបចំដាច់ដោយឡែក សម្រាប់កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌក៏ដោយ ក៏ការស្តាប់ចម្លើយនេះមិនត្រូវបានធ្វើឡើងដោយមានការស្បថ និង ហត្ថលេខា ឬ ស្នាមមេដៃពីអ្នកផ្តល់ចម្លើយនោះទេ។ ខណៈការយកចម្លើយនោះ...

បានរៀបចំឡើងដោយតែ សាមីសហព្រះរាជអាជ្ញាអន្តរជាតិដែលជាភាគី ក្នុងគោលបំណង រំលេចឱ្យឃើញនូវផលប្រយោជន៍ជាក់ស្តែង ដូចមានលទ្ធផលក្នុងសំណុំរឿងស្រាប់។ ទោះជាយ៉ាងនេះក្តី ការស្តាប់ចម្លើយបែបនេះត្រូវបានប្រមូលឡើង សម្រាប់គោលបំណងនៃសវនាការព្រហ្មទណ្ឌ ។ ដូច្នេះ ជាគោលការណ៍ត្រូវទទួលបាននូវតម្លៃជាភ័ស្តុតាងខ្ពស់ជាងភ័ស្តុតាងដែលមិនត្រូវបានប្រមូលសម្រាប់គោលបំណងនេះ រួមទាំងភ័ស្តុតាងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។[2344]

៩៩៤. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពុំអាចទទួលបាននូវសច្ចធារណ៍នៃភាពអាចជឿជាក់បាន ហើយត្រូវទទួលបាននូវតម្លៃជាភ័ស្តុតាងទាបប៉ុណ្ណោះ ប្រសិនបើកាលៈទេសៈនៃការកត់ត្រាពាក្យសុំតាំងខ្លួននោះមិនមានភាពច្បាស់លាស់។[2345] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងរបស់ជនរងគ្រោះបានផ្តល់នូវការសន្និដ្ឋានទូទៅប៉ុណ្ណោះ។ ហេតុដូច្នេះ តំណាង "ការរៀបរាប់ទូទៅ" ដែលខុសពីបទពិសោធន៍ផ្ទាល់ខ្លួន ហើយជាលទ្ធផលត្រូវចាត់ទុកថា មិនគ្រប់គ្រាន់សម្រាប់កំណត់ពីអង្គហេតុពាក់ព័ន្ធ។[2346] ខណៈដែលការស្តាប់ចម្លើយពីដើមបណ្តឹងរដ្ឋប្បវេណី ក្រៅពីតុលាការត្រូវទទួលបាននូវតម្លៃជាភ័ស្តុតាងទាប។[2347]

៩៩៥. ជាការសន្និដ្ឋាន និងថ្លឹងថ្លែង លើការពិចារណាទាំងអស់នេះ ចំពោះកំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ដែលបង្កើតឡើងដោយ ក.ស.ច.ស និងប្រតិចារឹកនាពេលសវនាការត្រូវទទួលបាននូវសច្ចធារណ៍នៃភាពអាចជឿជាក់បានខ្ពស់ ហើយត្រូវទទួលបាននូវតម្លៃជាភ័ស្តុតាងខ្ពស់ជាងការស្តាប់ចម្លើយដែលបានរៀបចំឡើងដោយស្ថាប័នដទៃផ្សេងទៀត។ ចំពោះការស្តាប់ចម្លើយដែលរៀបចំឡើងដោយស្ថាប័នផ្សេងទៀតនោះ គួរត្រូវអនុម័តយកវិធីសាស្ត្រប្រុងប្រយ័ត្នខ្លាំងជាង ក្នុងការវាយតម្លៃទៅលើឯកសារទាំងនោះហើយព័ត៌មានដែលមាននៅក្នុងនោះ គួរត្រូវបានពឹងផ្អែកតែក្នុងករណីដែលទទួលបានការគាំទ្រដោយប្រភពផ្សេងទៀតប៉ុណ្ណោះ។

## ខ. ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម

៥៩៦. អនុលោមតាមមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម គឺមានការហាមឃាត់ដាច់ខាតមិនឱ្យពឹងផ្អែកទៅលើព័ត៌មានដែលមានក្នុងឯកសារ ដែលទទួលបានដោយការធ្វើទារុណកម្ម[2348] និងមិនឱ្យប្រើប្រាស់ចម្លើយបែបនេះ ជាមូលដ្ឋានក្នុងការសួរដេញដោលសាក្សីឡើយ។[2349] ដោយហេតុថា ចម្លើយសារភាពរបស់អ្នកទោសដែលត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខ ស-២១ ត្រូវបានសន្មតថា ជាប្រភេទចម្លើយដែលទទួលបានដោយការធ្វើទារុណកម្ម។ នេះគឺជាសច្ចធារណ៍អាចបដិសេធបាន។[2350]

៥៩៧. ព័ត៌មានដែលមាននៅក្នុងចម្លើយសារភាពពីមន្ទីរសន្តិសុខ ស-២១ ដែលផ្តល់ឱ្យដោយបុគ្គលដែលមិនមែនជាជនរងគ្រោះនៃការធ្វើទារុណកម្ម ជាឧទាហរណ៍ទាក់ទិន ចំណារដោយអ្នកធ្វើទារុណកម្ម មិនស្ថិតក្រោមការហាមឃាត់នេះឡើយ[2351] ពីព្រោះថា មាត្រា ១៥ ដដែលខាងលើនេះ ក៏មិនបានហាមឃាត់ការប្រើប្រាស់ព័ត៌មាន ដែលមានក្នុងចម្លើយដែលធ្វើឡើងដោយទារុណកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីស្វែងរកសាក្សី និងអាចឈានទៅស្តាប់ចម្លើយពួកគាត់ដែរ។[2352] ហេតុដូច្នេះ មិនមានការហាមឃាត់មិនឱ្យប្រើប្រាស់ភស្តុតាងរបស់សាក្សី ដែលត្រូវបានកំណត់នៅក្នុងចម្លើយ ដែលទទួលបានដោយការធ្វើទារុណកម្មដូចជា ចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ និងការស្តាប់ចម្លើយនាពេលបន្ទាប់ដោយ ក.ស.ច.ស នោះទេ។[2353]

## ជំពូក៦. ច្បាប់ជាធរមាន ពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលនៅ អ.វ.ត.ក

### ១. យុត្តាធិការបុគ្គលនៅ អ.វ.ត.ក

៥៩៨. តាមមាត្រា ១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះហត្ថលេខានៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក") ចែងថា៖



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

*"គោលបំណងរបស់កិច្ចព្រមព្រៀងនេះ គឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ ១៧ មេសា ១៩៧៥ ដល់ ថ្ងៃ ០៦ មករា ១៩៧៩"*។

៥៩៩. មាត្រា ១ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ ប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ អ.វ.ត.ក") ដោយផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀង អ.វ.ត.ក[2354] ចែងថា៖

*"ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩"*។

៦០០. មាត្រា ២ នៃច្បាប់ អ.វ.ត.ក រំឭកឡើងវិញជាថ្មីថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបង្កើតឡើងដើម្បីជំនុំជម្រះ *"មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម [...] ដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ ១៧ មេសា ១៩៧៥ រហូតដល់ថ្ងៃ០៦ មករា ១៩៧៩"*។

៦០១. អ.ជ.ត.ក បានបកស្រាយពាក្យថា *"មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"* សំដៅលើជនពីរប្រភេទ គឺ មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ដែលស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត និងជនដែលមិនមែនជាមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ប៉ុន្តែក៏ជាជនស្ថិតនៅក្នុងចំណោមជនទាំងឡាយដែល

ទទួលខុសត្រូវខ្ពស់បំផុត។ ជនទាំងពីរប្រភេទនេះ ត្រូវតែជាមន្ត្រីខ្មែរក្រហម និងស្ថិតនៅក្នុងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតដើម្បីឱ្យតុលាការអនុវត្តយុត្តាធិការបុគ្គលឱ្យបានត្រឹមត្រូវ ហេតុនេះ លក្ខណៈវិនិច្ឆ័យទាំងនេះមានលក្ខណៈត្រួតលើគ្នា មិនមែនដាច់ដោយឡែកពីគ្នាទេ។[2355]

៦០២. អ.ជ.ត.ក បានប្រកាសដោយខ្លួនឯងស្ដីពីលក្ខណៈយុត្តិសាស្ត្រនៃមាត្រា ១ នៃច្បាប់ អ.វ.ត.ក។ ទាក់ទិននឹងចំណុចនេះ អ.ជ.ត.ក បានសន្និដ្ឋានថា បញ្ហាថាតើជនជាប់ចោទជាកម្មាភិបាលខ្មែរក្រហម ឬ យ៉ាងណា *"ពាក់ព័ន្ធជាមួយនឹងបញ្ហាអង្គហេតុប្រវត្តិសាស្ត្រដែលមានលក្ខណៈងាយយល់ និងច្បាស់លាស់ ហើយផ្ដល់ឆន្ទានុសិទ្ធិតិចតួច ឬមិនបានផ្ដល់ឆន្ទានុសិទ្ធិទាល់តែសោះដល់អង្គជំនុំជម្រះសាលាដំបូង"* ហេតុនេះជាបញ្ហាដែលអាចវិនិច្ឆ័យបាន ដែលគ្របដណ្ដប់ដោយយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។[2356]

៦០៣. ផ្ទុយទៅវិញទាក់ទិននឹងពាក្យថា "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" អ.ជ.ត.ក បានសន្និដ្ឋានថា ប្រភេទទាំងពីរនេះពុំមែនជាលក្ខណៈវិនិច្ឆ័យផ្នែកយុត្តាធិការ *តាមន័យចង្អៀត* *(stricto sensu)* ទេ វាគ្រាន់តែពិពណ៌នាអំពីទម្រង់នៃគោលនយោបាយស្ដីពីការចោទប្រកាន់ដោយសហព្រះរាជអាជ្ញានិងការស៊ើបអង្កេតដោយឯករាជ្យពី ក.ស.ច.ស ប៉ុណ្ណោះ។ អង្គជំនុំជម្រះបានសន្និដ្ឋានថា ជាគោលការណ៍ ប្រភេទទាំងពីរនេះមិនត្រូវបានកំហិតដោយវិធាននៃការបកស្រាយបែបតឹងរ៉ឹងទេ ហើយជាខ្លឹមសារ វាពុំអាចធ្វើការវិនិច្ឆ័យបាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬ អ.ជ.ត.ក បានទេ ដោយសារពុំមានបង្ហាញអំពីការបំពានឆន្ទានុសិទ្ធិដោយពុំសុចរិត ឬការវិនិច្ឆ័យមិនត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈនោះឡើយ។[2357]

៦០៤. ទោះជាយ៉ាងនេះក្ដី នៅក្នុងបរិបទផ្នែកតុលាការ លក្ខណៈវិនិច្ឆ័យសំខាន់បែបនេះមិនអាចបកស្រាយដោយពុំបានពិចារណាទៅដល់ចំណុចជាមូលដ្ឋាននានាបានទេ ទោះបីវាមានលក្ខណៈផ្លូវច្បាប់ជាក់លាក់បែបណាក៏ដោយ។ តាមពិត ការយោងទៅការបំពានឆន្ទានុសិទ្ធិដោយផ្អែកលើភាពពុំសុចរិត ឬការវិនិច្ឆ័យមិនត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ ជាការសន្មតជាមុនថា មានរង្វាស់ដែលអាចវាស់វែង និងត្រូវតែវាស់វែងដល់ការអនុវត្តឆន្ទានុសិទ្ធិ ពោលគឺ ដែលបង្កើតជាព្រំដែននៃសុចរិតភាព និងការវិនិច្ឆ័យត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ ។ល។

សេចក្តីសម្រេចស្ថិតនៅក្នុងសភាពមិនត្រឹមត្រូវ។ ជាគោលការណ៍ យើងក៏មិនយល់ស្របផង ដែរ ទៅនឹងទឡ្ហីករណ៍ដែលថា ការប្រៀបធៀបទៅនឹងបុគ្គលផ្សេងទៀតជាការមិនសមរម្យ ឬសក្តិសមនោះ។[2358] ផ្ទុយពីសាវតារនេះ វាក្លាយជាបញ្ហាបន្ទាប់បន្សំនៃពាក្យពេចន៍ ថាតើគេហៅលក្ខណៈវិនិច្ឆ័យនោះថាជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការ ឬ ជាការណែនាំផ្នែកគោលនយោបាយ។ ជាខ្លឹមសារ វាមានសារៈសំខាន់ជាកម្រិតទូលំទូលាយ ប៉ុន្តែមិនមែនមិនអាចធ្វើការវិនិច្ឆ័យបានទាំងស្រុងនៃការទទួលយកសម្រាប់ ក.ស.ព និង ក.ស.ច.ស នោះទេ។

៦០៥. ទោះបីយើងបានប្រកាសនៅទីនេះ (ហើយ ស.ច.ស.អ បានប្រកាសដោយឡែកនៅកន្លែងផ្សេង)[2359] ថា យើងមិនយល់ស្របទៅនឹងការធ្វើចំណាត់ថ្នាក់របស់ អ.ជ.ត.ក អំពី "យុត្តាធិការបុគ្គល" ថា លក្ខណៈវិនិច្ឆ័យមិនមែនយុត្តាធិការក៏ដោយ តែយើងយល់ថា ដោយសារមូលហេតុនៃការគោរពតាមផ្លូវតុលាការចំពោះស្ថាប័នកំពូលដែលពិនិត្យមើលបណ្តឹងសាទុក្ខ យើងមានកាតព្វកិច្ចក្នុងការអនុវត្តតាមខ្លឹមសារនៃច្បាប់យុត្តិសាស្ត្ររបស់ អ.ជ.ត.ក លុះត្រាតែមានសំអាងហេតុពិសេសក្នុងការមិនយល់ស្រប និងប្រកាន់ជំហរជំទាស់ជាចំហ។ នេះជាការពិត ទោះបីថា អ.ប.ជ ជាស្ថាប័នតែមួយគត់ដែលទទួលពិនិត្យមើលបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស ហើយថា នៅក្នុងប្រព័ន្ធស៊ីវិលឡូដូចនៅកម្ពុជា ពុំមានទ្រឹស្តី*ប្រកាន់តាមអ្វីដែលបានសម្រេចមក (stare decisis)* ក៏ដោយ។ ទោះជាយ៉ាងណាក្តី ពាក់ព័ន្ធនឹងភាពច្បាស់លាស់ និងភាពដូចគ្នានៃច្បាប់ នៅក្នុងបរិយាកាសផ្លូវច្បាប់ដែលស្រដៀងនឹង អ.វ.ត.ក វាជាការមិនអាចទទួលយកបានទេ ដែលតម្រូវឱ្យចៅក្រមថ្នាក់ក្រោមនៅក្នុងឋានានុក្រមតុលាការបដិសេធច្បាប់យុត្តិសាស្ត្ររបស់ អ.ជ.ត.ក លុះត្រាតែមានសំអាងហេតុពិសេស។

## ២. អ.ជ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា៖ យុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និងយុត្តាធិការរឿងក្តីដោយឡែក

៦០៦. ទោះជាយ៉ាងណាក្តី លក្ខណៈវិនិច្ឆ័យនៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក អាចបណ្តាលឱ្យមានការព្រួយបារម្ភធ្ងន់ធ្ងរមួយទៀតផ្នែកគោលនយោបាយ ដែលតម្រូវឱ្យមានការឆ្លើយតប នៅក្នុងបរិបទនេះ ដើម្បីកំណត់អំពីផលវិបាកនៃការសន្និដ្ឋានថា ពុំមានយុត្តាធិការបុគ្គល និងផលប៉ះពាល់អ្វីខ្លះដែលអាចកើតមានចំពោះការអនុវត្តឆន្ទានុសិទ្ធិនៃគោលនយោបាយរបស់



C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ស.ច.ស នៅពេលសម្រេចលើកលែងការចោទប្រកាន់ក្នុងរឿងក្តីមួយ ដោយផ្អែកលើយុត្តាធិការបុគ្គលតែមួយ។

៦០៧. បញ្ហាដែលកំពុងពិភាក្សាគឺកង្វះយុត្តាធិការ ដែលតុលាការកម្ពុជាធម្មតាមានទៅលើឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តដោយមនុស្សដែលស្ថិតក្នុងប្រភេទ "មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត"។ បន្ទាប់ពីបានពិនិត្យយ៉ាងល្អិតល្អន់ទៅលើប្រវត្តិនៃការចចារមុនពេលបង្កើត អ.វ.ត.ក និងការវិវឌ្ឍចាប់តាំងពីពេលនោះមក ជាពិសេសដូចដែល អ.ជ.ត.ក បានលើកឡើង យើងយល់ឃើញថា នាពេលបច្ចុប្បន្ននេះ តុលាការកម្ពុជាផ្សេងទៀតពុំមានយុត្តាធិការបុគ្គល ឬព្រឹត្តិការណ៍នានាដែលស្ថិតនៅក្នុងយុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និងយុត្តាធិការរឿងក្តី របស់ អ.វ.ត.ក ទេ។ ហេតុនេះ អាចមានទឡ្ហីករណ៍ថា យើងគួរទប់ទល់ទៅនឹងឥទ្ធិពលជាក់ស្តែងនៃទិដ្ឋភាពនេះ និងអនុវត្តឆន្ទានុសិទ្ធិរបស់យើងឱ្យបានទូលំទូលាយតាមតែអាចធ្វើទៅបាន ដើម្បីជាប្រយោជន៍នៃការសន្និដ្ឋានអំពីយុត្តាធិការបុគ្គល ដើម្បីបញ្ចៀសនូវគម្លាតនៃនិទណ្ឌភាពដែលពុំសមរម្យ។ យើងពុំយល់ស្របទៅនឹងសំអាងហេតុនោះទេដោយសារមានសំអាងហេតុនានាដូចខាងក្រោម។

៦០៨. នៅពេលលើកឡើងអំពីគោលការណ៍នានាខាងលើ អ.ជ.ត.ក បានដឹងថា វាខុសពីយុត្តាធិការ (ដែលមានលក្ខណៈ) អន្តរជាតិនានា ដែលអង្គជំនុំជម្រះបានដកស្រង់នៅក្នុងទឡ្ហីករណ៍របស់ខ្លួនក្នុងអំឡុងប្រវត្តិនៃការចរចារវាង អ.ស.ប និង កម្ពុជា ទម្រង់នៃច្បាប់ស្តីពី អ.វ.ត.ក ត្រូវបានដោះស្រាយ ដោយបានដឹងថា ពុំមានការចរចាអំពីយុត្តាធិការដែល តុលាការកម្ពុជាធម្មតាមាន ឬពីប្រព័ន្ធដែលមានលក្ខណៈអន្តរជាតិដែលដំណើរការនៅតុលាការផ្សេងទៀត ឧទាហរណ៍ នៅ បូស្នៀ និង កូសូវ៉ូ ឬតុលាការយោធាក្រោយសង្គ្រាមលោកលើកទី ២ ចំពោះចារីនានាដែលនៅសេសសល់ ដែលស្ថិតនៅទាបជាងលក្ខខណ្ឌនៃការទទួលខុសត្រូវដែលបានកំណត់ដោយ អ.វ.ត.ក នោះឡើយ។

៦០៩. ជាការពិត អ.ជ.ត.ក បានទទួលស្គាល់យ៉ាងច្បាស់អំពីជំហរពិសេសរបស់ អ.វ.ត.ក ដោយប្រៀបធៀបទៅនឹងតុលាការផ្សេងទៀត ឧទាហរណ៍ តុលាការ ICTY ដោយលើកឡើងថា៖

"[...] អ.វ.ត.ក មានអត្ថិភាពនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាដែល អ.វ.ត.ក អនុវត្តនូវសមត្ថកិច្ចផ្តាច់មុខ និងពុំមានការបញ្ជូនរឿងក្តីណាមួយទៅតុលាការមួយផ្សេងទៀតឡើយ"។[2360]

៦១០. ស្រដៀងគ្នាដែរ នៅឆ្នាំ ២០១១ អ.ប.ជ បានសម្រេចរួចហើយថា រាជរដ្ឋាភិបាលកម្ពុជាអាចប្រើប្រាស់តុលាការធម្មតារបស់ខ្លួនក្នុងការជំនុំជម្រះពួកខ្មែរក្រហម តែផ្ទុយទៅវិញ រាជរដ្ឋាភិបាលបានជ្រើសរើសការបង្កើត អ.វ.ត.ក៖

"[...] រដ្ឋាភិបាលមាន [...] សេរីភាពក្នុងការចោទប្រកាន់បទល្មើសបែបនេះ [...] នៅក្នុងការអនុវត្តយុត្តាធិការមូលដ្ឋានរបស់ខ្លួន [...]។ ទោះបីជាយ៉ាងនេះក្តី *ជាជាងការប្រើប្រាស់រចនាសម្ព័ន្ធតុលាការរបស់ខ្លួនដែលមានស្រាប់* រដ្ឋាភិបាល [...] បានព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ បង្កើត អ.វ.ត.ក [...] ហើយ*បានផ្ទេរយុត្តាធិការទៅឱ្យ អ.វ.ត.ក* ធ្វើការជំនុំជម្រះលើរឿងក្តីទាំងនេះ" [គូសបញ្ជាក់បន្ថែម]។[2361]

៦១១. រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិមិនបានព្យាយាមកំណត់ឱ្យមានការស៊ើបអង្កេត និងការជំនុំជម្រះទៅលើបុគ្គលដែលមិនស្ថិតនៅក្នុងលក្ខខណ្ឌនៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ ដោយសារពួកគេមិនស្ថិតនៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត។ គេផ្តល់មូលហេតុ ដែលនាំឱ្យមានការធ្វើសមាហរណកម្មពួកខ្មែរក្រហមចូលមកក្នុងសង្គម គឺជាមូលហេតុសំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងថែរក្សាសន្តិភាព និងការផ្សះផ្សាជាតិ។[2362] "គម្លាតនៃនិទណ្ឌភាព" នេះ និងទំនាក់ទំនងរបស់វាទៅនឹងគោលនយោបាយនៃការធ្វើសមាហរណកម្ម ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ឧទាហរណ៍ នៅដើមឆ្នាំ ២០០៨ ដោយអតីតប្រធានអង្គភាពគាំពារការការពារក្តី Rupert Skilbeck ថាមានភាពខុសប្រក្រតី បើប្រៀបធៀបទៅនឹងតុលាការផ្សេងទៀត។[2363]

៦១២. ជាពិសេស ខុសពីតុលាការ ឬ សាលាក្តីផ្សេងទៀតដែលត្រូវបានបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិ ឬជាតុលាការ (ជាតិ) ចម្រុះ[2364] កិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក ពុំមានខចែងអំពីគោលការណ៍*គ្មានការកាត់ទោសពីរដងលើរឿងក្តីតែមួយ (ne bis in idem)* តាមខ្សែបណ្តោយ ឬប្រការឧត្តមានុភាព (primacy clause) ពោលគឺ បញ្ញត្តិមួយដែលគ្រប់គ្រងទំនាក់ទំនងរវាងការស៊ើបអង្កេត ការជំនុំជម្រះ និងសេចក្តីសម្រេចនៅថ្នាក់



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

ជាតិ ក្នុងតុលាការធម្មតា និងការស៊ើបអង្កេត ការជំនុំជម្រះ និងសេចក្តីសម្រេចនៅកម្រិតតុលាការពិសេស។ ហេតុនេះ ច្បាប់ជាធរមាននៅ អ.វ.ត.ក មិនបានប្រមើលមើលជាមុននូវស្ថានភាពមួយដែលអាចមានទំនាស់ផ្នែកយុត្តាធិការ ដែលតម្រូវឱ្យមានបញ្ញត្តិបែបនេះទេ។

៦១៣. ហេតុនេះ ឧទាហរណ៍ការប្រៀបធៀបដោយមិនត្រឹមត្រូវទៅនឹងច្បាប់យុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាផ្ទេរសមត្ថកិច្ច (referral bench) នៃតុលាការ ICTY អនុលោមតាមវិធាន ១១*ស្ទួន* នៃវិធានស្តីពីនីតិវិធី និងភស្តុតាង ដើម្បីវាស់ស្ទង់នូវកម្រិតធ្ងន់ធ្ងរ និងការទទួលខុសត្រូវ ពុំមានប្រយោជន៍ទេដោយសារ*បរិបទនៃការចរចា*នៅក្នុងករណី អ.វ.ត.ក មានភាពខុសគ្នាទាំងស្រុង៖ បណ្តាអ្នកតាក់តែងច្បាប់ចង់កំហិតយុត្តាធិការបុគ្គលចំពោះអ្នក ដែលមានការទទួលខុសត្រូវខ្ពស់ជាងគេបំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឧទាហរណ៍ ដែលបានដឹងយ៉ាងច្បាស់ពីចំនួនសរុបនៃការស្លាប់ដែលត្រូវបានប៉ាន់ស្មានក្នុងកម្រិតទាបចំនួនប្រមាណ ១.៧០០.០០០ (មួយលានប្រាំពីរសែន) នាក់[2365] នៅពេលនោះ ដែលមានចំនួនស្មើនឹងជម្លោះធំៗក្នុងសម័យទំនើបរួមគ្នា រួមទាំងស្ថានភាពទាំងអស់នៅចំពោះមុខតុលាការ ICC មកដល់សព្វថ្ងៃ។ ពួកគេក៏បានដឹងដែរថា មានបុគ្គលអាចជាចារីក្នុងចំនួនដ៏ច្រើន[2366] ដែលម្នាក់ៗអាចទទួលខុសត្រូវក្នុងការស្លាប់មនុស្សរាប់រយ ឬរាប់ពាន់នាក់ ជាសេណារីយ៉ូដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានច្រានចោលសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាផ្ទេរសមត្ថកិច្ច ដោយសារអង្គជំនុំជម្រះពិចារណា *នៅក្នុងចំណោមបញ្ហាផ្សេងទៀត* ថា ជនល្មើសអាចមានការទទួលខុសត្រូវចំពោះការស្លាប់ជនរងគ្រោះចំនួន ១៤០ (មួយរយសែសិប) នាក់។[2367]

៦១៤. វិសាលភាពដោយឡែកនៃការស្លាប់មនុស្សនៅក្នុងរបបខ្មែរក្រហម ប្រវត្តិនៃការចរចាដែលកំណត់ដោយ អ.ជ.ត.ក[2368] ព្រមទាំងភស្តុតាងដែលបានមកពីការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ តែមួយមិនអាចប្រកាន់យកវិធីសាស្ត្រស្រដៀងគ្នាបានទេ ដោយសារតែការវាស់វែងទៅតាមប្រភេទនៃចំនួនទាំងនេះនឹងធ្វើឱ្យទាហានធម្មតាជាច្រើននាក់ដែលបានសម្លាប់មនុស្សជាទ្រង់ទ្រាយធំជាប្រចាំក្នុងរយៈពេលជាយូរ ឬ ថ្នាក់លើផ្ទាល់របស់ពួកគេដែលបានបញ្ជាពួកគេ ក្លាយជាបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត ដែលអាចនាំឱ្យមានការស៊ើបអង្កេតថ្មីៗជាច្រើនទៀត ទៅតាមវិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង។ ប្រការនោះច្បាស់ជាពុំមែនជាអ្វីដែលអ្នកតាក់តែងច្បាប់គ្រប់គ្រង អ.វ.ត.ក បានប្រមើលមើលនោះទេ តែផ្ទុយទៅវិញ



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

បានដឹងថា នៅមានចារីប្រភេទនេះជាច្រើនសន្ធឹកសន្ធាប់ទៀត ហើយពួកគេនឹងមិនត្រូវបាននាំមកកាត់ទោសទេ។

៦១៥. ឧទាហរណ៍ការណ៍ដែលថា ក្រមព្រហ្មទណ្ឌឆ្នាំ២០១០ មានចែងអំពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងមាត្រា ១៨៣ ដល់ ១៩៨ និងបទប្បញ្ញត្តិទូទៅនៅក្នុងមាត្រា ៨ នៃក្រមព្រហ្មទណ្ឌ ប្រកាសថា ក្រមព្រហ្មទណ្ឌ

"ពុំអាចនាំឱ្យមានការបង្កើតនូវស្ថានភាពយុត្តិនិសេធ ចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរ *ដែលកំណត់ដោយច្បាប់ដោយឡែក* ទាក់ទងដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬអនុសញ្ញាអន្តរជាតិ ដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជាឡើយ" (គូសបញ្ជាក់បន្ថែម)។

មិនអនុញ្ញាតឱ្យមានការសន្និដ្ឋានដែលថា មានយុត្តាធិការសម្រាប់តុលាការធម្មតាទេ៖ ការយោងខាងលើ សំដៅដល់ច្បាប់ អ.វ.ត.ក ពុំសំដៅដល់ច្បាប់នានាដែលផ្តល់អំណាចបែបប្រតិសកម្មដល់តុលាការធម្មតាឡើយ។

៦១៦. មាត្រា៣ និង១០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០១០ រួមគ្នាមានចែងពី*គោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង* *(nullum crimen)* និងវិធាននៃច្បាប់ដាក់ទោសស្រាលជាងមុន *(lex mitior)* ពោលគឺថា ត្រូវយកច្បាប់ដែលមានលក្ខណៈបន្ធូរបន្ថយជាងគេមកអនុវត្ត ប្រសិនបើមានការកែប្រែច្បាប់នៅពេលប្រព្រឹត្តបទល្មើស និងពេលជំនុំជម្រះក្តី។ ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ពុំមានចែងបទប្បញ្ញត្តិស្តីអំពីឧក្រិដ្ឋកម្មនានាដែលបានលើកឡើងខាងលើទេ ដែលមានកំណត់ត្រឹមតែបទល្មើសថ្នាក់ជាតិ។

៦១៧. ពុំមានភាពច្បាស់លាស់ផងដែរថា តើច្បាប់រដ្ឋធម្មនុញ្ញកម្ពុជានឹងអនុញ្ញាតឱ្យមានការអនុវត្តដោយផ្ទាល់ចំពោះបទល្មើសនានាដែលត្រូវបានទទួលស្គាល់ ទៅតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមិនស្ថិតក្នុងការទទួលខុសត្រូវនៃកិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក ឬយ៉ាងណាទេ ដោយសារមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ត្រឹមតែយោងដល់បទដ្ឋាន*សិទ្ធិមនុស្ស*ដែលអាចអនុវត្តដោយផ្ទាល់តែប៉ុណ្ណោះ។ ដូចដែល ស.ច.ស.អ បាន



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ពន្យល់នៅក្នុងបរិបទផ្សេងថា ការរំលោភទៅលើបទដ្ឋានសិទ្ធិមនុស្សបែបនោះ ពុំចាំបាច់សុទ្ធតែបណ្តាលឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទេ។[2369]

៦១៨. សរុបមក យើងយល់ឃើញថាប្រសិទ្ធភាពនៃច្បាប់ អ.វ.ត.ក ទៅលើយុត្តាធិការបុគ្គលមានទិដ្ឋភាពពីរ៖ ក. វាកំហិតនូវយុត្តាធិការបុគ្គល*ផ្ទាល់* របស់ អ.វ.ត.ក ត្រឹមតែចំពោះអ្នកទទួលខុសត្រូវខ្ពស់បំផុត និង ខ. វាមិនរាប់បញ្ចូលយុត្តាធិការបុគ្គល ឬយុត្តាធិការលើរឿងក្តីរបស់តុលាការកម្ពុជា*ធម្មតា* ទៅលើព្រឹត្តិការណ៍នានាដែលស្ថិតក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ឡើយ។

៦១៩. សេចក្តីសន្និដ្ឋានបែបទ្រឹស្តីនេះក៏ត្រូវបានបញ្ជាក់ដោយអង្គហេតុជាក់ស្តែងដែលថា ពុំមានការស៊ើបអង្កេត ឬ ការជំនុំជម្រះទៅលើរឿងក្តីប្រភេទនេះចំពោះចារីថ្នាក់ក្រោមនៅចំពោះមុខតុលាការកម្ពុជាធម្មតា *ក្រោយពេល* បង្កើត អ.វ.ត.ក ទេ ទោះបីសម័យកម្ពុជាប្រជាធិបតេយ្យបានបន្សល់ទុកការប៉ះទង្គិចផ្លូវចិត្តនៅក្នុងសង្គមកម្ពុជា ហើយមានបុគ្គលរាប់ពាន់នាក់អាចជាចារី ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដោយផ្ទាល់ ឬក្នុងនាមជាថ្នាក់លើនៅរស់រានមានជីវិតក៏ដោយ។

៦២០. ហេតុនេះមានគម្លាតនិទណ្ឌភាពជាខ្លាំងសម្រាប់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ទោះជាយ៉ាងណាក្តី ការធ្វើសេចក្តីសន្និដ្ឋាននេះមិនត្រូវមានឥទ្ធិពលផ្នែកគោលនយោបាយមកលើការអនុវត្តធន្ទានុសិទ្ធិរបស់យើង ពាក់ព័ន្ធទៅនឹងយុត្តាធិការបុគ្គលទេ ដោយសារមានសំអាងហេតុនានាដែលនឹងរៀបរាប់នៅផ្នែកបន្ទាប់។

## ៣. គោលការណ៍ច្បាប់ព្រហ្មទណ្ឌ៖ ប្រសិទ្ធភាពនៃគោលការណ៍ "វិមតិសង្ស័យ បានប្រយោជន៍ដល់ជនជាប់ចោទ" ការបកស្រាយក្នុងន័យចង្អៀត យុត្តាធិការ បែបជ្រើសរើស និងការជំនុំជម្រះបែបជ្រើសរើស

៦២១. ក្នុងចំណោមកត្តានានាដែលត្រូវយកមកពិចារណា ដើម្បីអនុវត្តធន្ទានុសិទ្ធិមាន គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងការបកស្រាយក្នុងន័យចង្អៀតនៃផ្លូវ



* CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

ព្រហ្មទណ្ឌ។ ស្របទៅនឹងការបកស្រាយគោលការណ៍នេះដោយ អ.ជ.ត.ក យើងយល់ថា គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* មានតួនាទីមួយក្នុងការបកស្រាយបទប្បញ្ញត្តិច្បាប់ ហើយការអនុវត្តគោលការណ៍នេះកំហិតត្រឹមតែវិមតិសង្ស័យដែលនៅមានក្រោយពេលអនុវត្តវិធានបទដ្ឋាននៃការបកស្រាយ។[2370] នៅក្នុងយុត្តាធិការមួយចំនួន គេអាចសម្រេចបានប្រសិទ្ធភាពដូចគ្នា តាមរយៈការអនុវត្តនូវការបកស្រាយក្នុងន័យចង្អៀត ឧទាហរណ៍នៅក្នុងច្បាប់កម្ពុជា[2371] និងនៅតុលាការ ICC។[2372]

៦២២. ការអនុវត្តគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* ការបកស្រាយក្នុងន័យចង្អៀត មានសារៈសំខាន់ជាងគេនៅក្នុងប្រព័ន្ធដែលច្បាប់មិនបានចែងពេញលេញ ហើយដែលនៅតែកើតមាននៅក្នុងវិស័យច្បាប់ព្រហ្មទណ្ឌ (ដែលមានលក្ខណៈ) អន្តរជាតិ។ ជាពិសេស មិនត្រឹមតែ តាមការយល់ឃើញរបស់មេធាវីការពារក្ដីដែលថា បទចោទនានាដែលពួកគេត្រូវការពារ និងខ្លឹមសារផ្លូវច្បាប់នៃបទចោទទាំងនោះជាញឹកញយមានរូបភាព និង លក្ខណៈជាគោលដៅដែលប្រែប្រួលចុះឡើង៖ ករណីនានានៃការបកស្រាយផ្សេងៗគ្នាទៅលើទស្សនៈច្បាប់ដូចគ្នាបេះបិទនៅ អ.វ.ត.ក និង តុលាការផ្សេងៗទៀត ជាពិសេសទៅលើបញ្ហាយុត្តាធិការបុគ្គលតែម្តង[2373] ជាភ័ស្តុតាងយ៉ាងច្បាស់ដែលបញ្ជាក់ពីបញ្ហានេះ[2374]។ ករណីរបស់តុលាការពិសេសដែលមានយុត្តាធិការបុគ្គល យុត្តាធិការរឿងក្តី និងយុត្តាធិការពេលវេលាដែលចង្អៀត ដោយផ្អែកលើការចរចាយ៉ាងតឹងតែងរវាងរដ្ឋាភិបាលជាតិ និងសហគមន៍អន្តរជាតិ នៅក្នុងសេណារីយ៉ូអន្តរកាលក្រោយពេលមានជម្លោះ ដែលបានចាប់ផ្តើមដំណើរការជិត ៣០ឆ្នាំ ក្រោយពេលមានព្រឹត្តិការណ៍ដែលពិភាក្សានោះគឺជាឧទាហរណ៍ចម្បងមួយដែលចាំបាច់តម្រូវឲ្យមានការកំហិតចំពោះការបកស្រាយតាមផ្លូវតុលាការ។

៦២៣. នេះជាការពិត ជាពិសេស ដោយសារមានសម្ពាធពីការរំពឹងរបស់សាធារណជនពីសារព័ត៌មាន ដែលព្រួយបារម្ភជុំវិញទស្សនៈនិទណ្ឌភាពចំពោះអំពើឃោរឃៅជាទ្រង់ទ្រាយធំ របៀបវារៈនយោបាយ ព្រមទាំងការស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្រទៅលើព្រឹត្តិការណ៍ជាមូលដ្ឋានកន្លងមក។ និយាយម្យ៉ាងទៀត ជាញឹកញយ នៅក្នុងសេណារីយ៉ូរបៀបនេះ ពិរុទ្ធភាពរបស់ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទហាក់ដូចជាហួសពីការពិភាក្សាដេញដោល *តាំងពីដំបូង* *(ab initio)* ហើយកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ ពុំមែន



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

គ្រាន់តែជាការយល់ស្រប និងការបញ្ជាក់ជាផ្លូវការដែលមានបោះត្រា ចំពោះទស្សនៈទូទៅផ្នែកប្រវត្តិសាស្ត្រដែលមានស្រាប់ប៉ុណ្ណោះទេ។

៦២៤. ទោះបីជាយ៉ាងនេះក្តី វាជាការសមស្របដែលត្រូវរំឭកឡើងវិញនូវពាក្យពេចន៍របស់ **Robert H. Jackson** នៅសន្និសីទនៃសង្គមអាមេរិកកាំងនៃច្បាប់អន្តរជាតិកាលពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៤៥ ស្តីពីវិធីសាស្ត្រតុលាការដ៏ចម្រូងចម្រាស់ក្នុងការដាក់ទោសលើឧក្រិដ្ឋជនសង្គ្រាមនៃរបបណាហ្ស៊ីនៅមុនពេលចាប់ផ្តើមការជំនុំជម្រះនូរ៉ឹមប៊ឺក៖

*“ នោះគឺជាហានិយភ័យមួយក្នុងចំណោមហានិយភ័យនានាដែលត្រូវបានប្រថុយប្រថាន នៅពេលណាដែលការជំនុំជម្រះបានចាប់ផ្តើម។ គោលការណ៍ចុងក្រោយគឺ តុលាការមិនត្រូវយកបុគ្គលណាម្នាក់មកជំនុំជម្រះក្រោមទម្រង់នៃកិច្ចដំណើរការនីតិវិធីតុលាការ ប្រសិនបើតុលាការ មិនចង់មើលឃើញបុគ្គលរូបនោះមានសេរីភាព ក្នុងករណីរកមិនឃើញពិរុទ្ធភាព”*។[2375]

៦២៥. ការច្រានចោលការពិត ទោះវាមានន័យសាមញ្ញក៏ដោយ វាដូចនឹងការគាំទ្រលើសេចក្តីថ្លែងការណ៍ដ៏មិនសមរម្យរបស់ Benedict Carpzov តាំងពីឆ្នាំ១៦៥២ ថា៖ “គេដឹងឮទូទៅថា នៅក្នុងរឿងក្តីជំនុំជម្រះលើបទល្មើសធ្ងន់ធ្ងរបំផុត ព្រំដែននៃច្បាប់អាចត្រូវបានច្រានចោលដោយសារលក្ខណៈព្រៃផ្សៃនៃឧក្រិដ្ឋកម្ម”។[2376]

៦២៦. ច្បាស់ណាស់ថា អ.វ.ត.ក គឺជាតុលាការមួយដែលស្វែងរកយុត្តិធម៌តាមបែបជ្រើសរើស យោងតាមគោលបំណងនៃពាក្យពេចន៍ដែលបានចែង ពីព្រោះមានតែមនុស្សមួយក្រុមតូចតែប៉ុណ្ណោះដែលនឹងត្រូវយកមកចោទប្រកាន់នៅក្នុងតុលាការកម្ពុជា ចំពោះអំពើឃោរឃៅដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ពោលគឺអ្នកទាំងឡាយដែលស្ថិតនៅក្នុងរង្វង់យុត្តាធិការរបស់តុលាការ។

៦២៧. ការចុះកិច្ចព្រមព្រៀងដោយអវត្តមាននៃយុត្តាធិការដែលនៅសេសសល់ផ្សេងទៀតនៅក្នុងតុលាការជាតិកម្ពុជាគឺជាជម្រើសមនសិការនយោបាយនៅក្នុងអំឡុងពេលនៃការចរចារ



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

បានថ្លឹងថ្លែងលើការអំពាវនាវឱ្យមានការធ្វើសមាហរណកម្មខ្មែរក្រហមដែលនៅសេសសល់ចូលក្នុងសង្គមជាមួយនឹងគោលបំណងចង់បានការបញ្ចប់តាមផ្លូវតុលាការ សម្រាប់ការឈឺចាប់ខ្លោចផ្សារបស់ជនរងគ្រោះ ទោះបីជាពួកគេបានស្លាប់ ឬ នៅរស់រានមានជីវិតនៅឡើយ ព្រមទាំងសម្រាប់គ្រួសារ និងសង្គមរបស់ពួកគេទាំងមូល។

៦២៨. នៅក្នុងន័យនេះ ក.ស.ព ខ្លួនឯងកាលពីថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៩[2377] និងកាលពីថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤[2378] ជាថ្មីម្តងទៀត បានចង្អុលបញ្ជាក់ជាសាធារណៈរួចហើយថា សហព្រះរាជអាជ្ញាពុំចាំបាច់ផ្តួចផ្តើមឱ្យមានការស៊ើបអង្កេតបន្ថែមទៀត ក្រោយសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ នោះទេ។ អនុលោមតាមច្បាប់ ទោះបីជាគ្មានជនល្មើសណាម្នាក់អាចអះអាងថា ពួកគេទទួលរងនូវការប្រព្រឹត្តិដោយពុំយុត្តិធម៌ ពីព្រោះមានបុគ្គលជាច្រើនទៀតពុំត្រូវបានចោទប្រកាន់ ដែលបុគ្គលទាំងនេះអាចមានការទទួលខុសត្រូវដូចពួកគេក៏ដោយ ដរាបណាពួកគេទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ការចោទប្រកាន់តាមបែបជ្រើសរើសនៅក្នុងក្របខ័ណ្ឌយុត្តាធិការជ្រើសរើសបែបនេះអាចបង្ហាញនូវភាពយុត្តិធម៌តាមផ្លូវសីលធម៌។[2379] ចំណុចនេះជួយលើកតម្កើងភាពចាំបាច់ក្នុងការទទួលស្គាល់ថា ការវាយតម្លៃដ៏ហ្មត់ចត់ និងរឹងប៉ឹងមួយលើភ័ស្តុតាងប្រឆាំងនឹងបុគ្គលមួយចំនួនតូចនោះ ដែលកំពុងត្រូវបានស៊ើបអង្កេត គឺជាការចាំបាច់។

៦២៩. យោងតាមទស្សនៈនៃគោលនយោបាយព្រហ្មទណ្ឌទូទៅ វាពិបាកឱ្យសាធារណជន និងជនរងគ្រោះទទួលយកក្នុងន័យនៃពាក្យពេចន៍ទូលាយជាងនេះ ឧទាហរណ៍ សូម្បីទាហានដែលធ្លាប់បានសម្លាប់ក្មេងតូចៗដោយបោកនឹងគល់ឈើ[2380] ឬដែលបានប្រណាំងប្រជែងគ្នាថាតើនរណាអាចសម្លាប់មនុស្សបានច្រើនជាងគេ[2381] មិនគួរយកមកប្រឈមនឹងការកាត់ទោសនោះទេ។ ករណីនេះដូចគ្នានឹងបុគ្គលដែលបានប្រព្រឹត្តអំពើឃោរឃៅសាហាវយង់ឃ្នងជាច្រើនទៀត ឧទាហរណ៍ ដូចជា អំពើរំលោភជនរងគ្រោះ នៅមុនពេលសម្លាប់ពួកគេយកប្រមាត់ ឬថ្លើម និងនៅក្នុងករណីខ្លះយកគ្រឿងក្នុងមកចម្អិនសម្រាប់ហូបទៀតផង។[2382] នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាច្រើន ទង្វើបែបនេះនឹងនាំដល់ការដាក់ទោសអស់មួយជីវិតដោយពុំមានការលើកលែងទោស ហើយនៅក្នុងប្រទេសខ្លះ អាចមានទោសប្រហារជីវិតចំពោះអំពើនីមួយៗរបស់ជនល្មើសម្នាក់ៗ។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

៦៣០. ដើម្បីបញ្ជាក់ឡើងវិញនូវសម្តីដែលបានលើកឡើងខាងលើ គេបានដឹងអំពីចន្លោះប្រហោងនេះ នៅក្នុងអំឡុងពេលចរចារវាងភាគីជាតិ និងភាគីអន្តរជាតិ។ វាក៏ជាលក្ខណៈទូទៅនៃប្រព័ន្ធយុត្តាធិការ (ដែលមានលក្ខណៈ) អន្តរជាតិដែលបានបង្កើតឡើងដើម្បីបញ្ចប់ស៊ីណារីយ៉ូក្រោយជម្លោះតាមផ្លូវតុលាការ។ វិធីសាស្ត្របែបជ្រើសរើស សម្រាប់យុត្តាធិការលើនិទណ្ឌភាពតាមរយៈការចរចាជាក់ស្តែងចំពោះអតីតពួកខ្មែរក្រហមទាំងមូល នឹងទំនងជាពុំពេញចិត្ត និងអយុត្តិធម៌ចំពោះមនុស្សភាគច្រើន។ ទោះបី ជាយ៉ាងនេះក្តី ចៅក្រមនៃ អ.វ.ត.ក ត្រូវគោរពតាមសេចក្តីសម្រេចតាមផ្លូវនយោបាយរបស់អ្នកតាក់តែងច្បាប់ ក្រោយទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ ហើយម្យ៉ាងទៀត ការងារនេះមិនត្រូវ និងមិនអាចប្រដូចនឹងសច្ចធារណ៍និរទោស ឬ សច្ចធារណ៍ដោយស្វ័យប្រវត្តិនៃការទទួលខុសត្រូវខ្ពស់ចំពោះបុគ្គលដែល*ត្រូវបាន* នាំមកចំពោះមុខតុលាការដោយសារការចោទប្រកាន់របស់ ក.ស.ព នោះឡើយ។

៦៣១. សច្ចធារណ៍បែបនេះ ប្រសិនបើសន្មតមែននោះ ត្រូវធ្វើឡើងក្នុងលក្ខណៈផ្សេងពីនេះ។ ក្រោយរយៈពេលកន្លងហួសយូរមក ភ័ស្តុតាងសំខាន់ខ្លះតាមរយៈសាក្សី ឬប្រភពផ្សេងទៀតអាចធ្លាក់ដុនដាបដល់កម្រិតមួយដែលពិបាករកព័ត៌មានលម្អិតអាចទុកចិត្តបាន ហើយតាមពិតសាក្សីអាចពិបាកនឹងមកផ្តល់សក្ខីកម្ម។ ករណីនេះគឺពុំមែនការងារដែលត្រូវទម្លាក់ការទទួលខុសត្រូវឲ្យមេធាវីការពារក្តីនៅក្នុងការស៊ើបអង្កេតព្រហ្មទណ្ឌនោះទេ ឬនាំឲ្យក្លាយជាបទដ្ឋាននៃការបង្ហាញភ័ស្តុតាងក្នុងកម្រិតទាបសម្រាប់ការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ ឬការផ្តន្ទាទោសនោះឡើយ។ មេធាវីការពារក្តីមានសិទ្ធិទទួលបាននូវការវាយតម្លៃឲ្យបានសមហេតុផលលើភ័ស្តុតាង និងការបកស្រាយច្បាប់នៅក្នុងឋានានុក្រមតុលាការនៃ អ.វ.ត.ក គ្រប់ជាន់ថ្នាក់ ដោយគិតចាប់ផ្តើមពី ក.ស.ច.ស។

## ៤. យុត្តាធិការបុគ្គលតូចចង្អៀតត្រូវបានបង្ហាញក្នុង អំឡុងពេលនៃការចរចាបង្កើត អ.វ.ត.ក

៦៣២. ក្នុងការសម្រេចថាតើ **យឹម ទិត្យ** ជាមេដឹកនាំជាន់ខ្ពស់ ឬ ជាជនទទួលខុសត្រូវខ្ពស់បំផុតក្រៅពីពិនិត្យមើលសកម្មភាពចូលរួម វាចាំបាច់ផងដែរ ក្នុងការពិនិត្យមើលពីចេតនានៃអ្នករៀបចំសេចក្តីព្រាងច្បាប់ និង កិច្ចព្រមព្រៀង អ.វ.ត.ក ។ នេះមានភាពសមស្រប ក្នុង



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

ណៈដែលខ្លឹមសារច្បាប់និងកិច្ចព្រមព្រៀង មិនបានផ្តល់ន័យដល់ពាក្យ “មេដឹកនាំជាន់ខ្ពស់” ឬ “អ្នកទទួលខុសត្រូវខ្ពស់បំផុត”។

៦៣៣. មុននឹងបង្កើត អ.វ.ត.ក រដ្ឋាភិបាលក្នុងឆ្នាំ១៩៧៩ បានបង្កើតតុលាការជាតិ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមមាន ប៉ុល ពត និង អៀងសារី ចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ក្នុងបំណងស្វែងរកយុត្តិធម៌និងការពិត ។ បន្ទាប់ពី មានកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស ប្រទេសបារាំងនាឆ្នាំ១៩៩១ កម្ពុជាបានបោះឆ្នោតជាសកលនៅឆ្នាំ១៩៩៣ ជាមួយក្តីរំពឹងថាក្រុមមេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានចូលរួម និងនាំមកនូវសន្តិភាព តាមរយៈការបញ្ចប់នូវសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃជាង ១០ (ដប់) ឆ្នាំ គិតពីឆ្នាំ១៩៧៩ ។ ផ្ទុយទៅវិញ ក្រុមនេះមិនបានចូលរួមបោះឆ្នោតទេ និងបានបដិសេធលទ្ធផលបោះឆ្នោត និងបន្តការវាយប្រហារមកលើប្រជាជនកម្ពុជា ។ ដើម្បីសន្តិភាពកម្ពុជាបានរៀបចំ ច្បាប់ដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ក្នុងឆ្នាំ១៩៩៤ ។ ច្បាប់នេះបានទុករយៈពេល ៦ (ប្រាំមួយ) ខែដើម្បីឱ្យក្រុមប្រដាប់អាវុធ មានឋានៈទាបចុះចូល ប្រសិនបើមិនចង់ទទួលនូវការកាត់ទោសទេ ។ គោលបំណងចម្បងនៃច្បាប់នេះ ដើម្បីបញ្ចុះបញ្ចូលទាហានខ្មែរក្រហម ឱ្យមករួមរស់ក្នុងសន្តិភាព ក៏ប៉ុន្តែទន្ទឹមនឹងនេះ ក៏មិនភ្លេចទុកច្រកសម្រាប់កាត់ទោស មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះនៃអំពើឧក្រិដ្ឋប្រព្រឹត្ត ក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ផងដែរ។ នេះបានបង្ហាញតាមមាត្រា ៤០ ថ្មី នៃច្បាប់ ដែលមិនផ្តល់ការលើកលែងទោសដល់មេដឹកនាំទាំងនោះ ។

៦៣៤. ក្នុងឆ្នាំ២០០៣ តុលាការកម្ពុជាបានកាត់ទោសអតីតកម្មាភិបាលមានឋានៈទាបមាន ឈូក រិន និង នួន ប៉ែត ចំពោះការប្រព្រឹត្តិប្រឆាំងនឹងច្បាប់ជាតិកម្ពុជា។ ការណ៍នេះមិនមានន័យថា កម្ពុជាផ្តោតលើមុខសញ្ញាកម្មាភិបាលជាន់ទាបដែលប្រព្រឹត្តបទឧក្រិដ្ឋអន្តរជាតិនោះទេ។ ក្នុងគោលបំណងបញ្ចប់សង្គ្រាម និងការបង្រួបបង្រួមជាតិទាំងស្រុង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទ្រង់បានឡាយព្រះហស្តលេខាលើកលែងទោសដល់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ក្នុងឆ្នាំ១៩៩៦ ព្រមទាំងបានចាប់ខ្លួន តាម៉ុក ជាមេដឹកនាំជាន់ខ្ពស់មួយរូបដែរ និង ឌុច ដែលគេដឹងឮជាទូទៅថាជាប្រធានមន្ទីរសន្តិសុខ ស-២១ (គុកទួលស្លែង)។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C.

៦៣៥. ឆ្នាំ១៩៩៧ ខែមិថុនា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានសរសេរលិខិតទៅអង្គការសហប្រជាជាតិ ដើម្បីស្នើសុំជួយបង្កើត អ.វ.ត.ក។ រាជរដ្ឋាភិបាល បានដឹងច្បាស់អំពីការលើកលែងទោស ក៏ប៉ុន្តែ នៅតែមានបំណងបន្តស្វែងរកយុត្តិធម៌ទើបបានធ្វើសំណើនេះ។ ក្នុងនោះ ក៏បានផ្តោតតែលើ ឌុច និង តា ម៉ុក ដែលជាមេដឹកនាំដែលកំពុងតែជាប់ក្នុងមន្ទីរឃុំឃាំង។

៦៣៦. វត្តមាននៃការបង្កើត អ.វ.ត.ក ពុំមែនកើតឡើងដោយចៃដន្យនោះទេ ប៉ុន្តែ ជាលទ្ធផលដែលទទួលបានពីការចរចាជាច្រើនលើករវាង រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ អស់រយៈពេលជាង ១០ (ដប់) ឆ្នាំ ចាប់ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០៧។ អ្វីដែលជាគោលបំណងដ៏ពិតប្រាកដនៃការបង្កើត អ.វ.ត.ក នេះឡើង ដើម្បីលុបបំបាត់វប្បធម៌និទណ្ឌភាពបទឧក្រិដ្ឋអន្តរជាតិ។ ប៉ុន្តែ ដំណើរការនេះត្រូវធ្វើយ៉ាងណា មិនត្រូវឱ្យប៉ះពាល់ដល់សន្តិភាពទេ។ ជាក់ស្តែង មានការចរចាយ៉ាងស្រួចស្រាវលើបញ្ហាយុត្តាធិការបុគ្គល។ ចេតនារបស់រាជរដ្ឋាភិបាលផ្តោតសំខាន់លើមេដឹកនាំជាន់ខ្ពស់។ នេះបង្ហាញតាមរយៈការដាក់បន្ថែមនូវពាក្យ "**ជាន់ខ្ពស់**" ទៅលើពាក្យ "**មេដឹកនាំ**" ដែលអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានឯកភាព។ ពាក្យនេះគឺច្បាស់ណាស់សម្រាប់ តា ម៉ុក ដែលជាមេដឹកនាំកំពុងជាប់ក្នុងមន្ទីរឃុំឃាំង និង មេដឹកនាំមួយចំនួនទៀត ។ ពាក្យ "**ជនដែលទទួលខុសត្រូវខ្ពស់បំផុត**" ត្រូវបានដាក់បញ្ចូលនាពេលក្រោយទៅក្នុងបទប្បញ្ញត្តិយុត្តាធិការក្រោយពីដឹងថា ឌុច នៅរស់រានមានជីវិត។ កម្ពុជាបានឯកភាពសម្រាប់ករណី ឌុច ដោយសារគាត់ត្រូវបានចាប់ខ្លួន និងឃុំឃាំង។ ឯកសារចោទប្រកាន់ជនទាំងពីរនោះព្រមទាំងការឃុំខ្លួន អាចពន្យល់នូវចេតនាចង់បញ្ជូនឱ្យពួកគេ មកទទួលការកាត់សេចក្តីក្រោយពី អ.វ.ត.ក ត្រូវបានបង្កើត។[2383]

៦៣៧. នាអំឡុងពេលចរចា ភាគីទាំងពីរបានខ្វែងយោបល់លើចំនួនចៅក្រមនៃអង្គនីមួយៗ ព្រមទាំងយន្តការនៃការដោះស្រាយជម្លោះ ដែលត្រូវបានស្នើជាចម្បងដោយភាគីកម្ពុជាក្នុងការធានានូវអធិបតេយ្យភាព ហើយជាលទ្ធផល ការសម្របសម្រួលត្រូវបានប្រកាន់យក។ អង្គបុរេជំនុំជម្រះត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយជម្លោះខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេតជាដើម។ អង្គនីមួយៗត្រូវមានសមាសភាពចៅក្រមកម្ពុជាច្រើនជាង។ ឧទាហរណ៍ ក្នុងអង្គបុរេជំនុំជម្រះមានចៅក្រមកម្ពុជាចំនួន ៣ (បី) រូប



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

ចៅក្រមអន្តរជាតិចំនួន ២ (ពីរ) រូប។ រចនាសម្ព័ន្ធតុលាការពិសេស និងនីតិវិធីដែលចូលរួមដោយចៅក្រមជាតិ និងចៅក្រមអន្តរជាតិនេះឆ្លុះបញ្ចាំងឲ្យឃើញច្បាស់លាស់ពីយុត្តាធិការជ្រើសរើសយ៉ាងចង្អៀតបំផុតដែលមិនអាចប្រកែកបាន ដូច្នេះ ទោះបីជាមានអង្គហេតុជាក់ស្តែងពាក់ព័ន្ធនឹងជនត្រូវចោទក៏ដោយ ប៉ុន្តែ តាមការបកស្រាយតាមខ្លឹមសារច្បាប់គឺជនត្រូវចោទមិនដល់កម្រិតនៃប្រភេទយុត្តាធិការ "មេដឹកនាំជាន់ខ្ពស់ឬជនទទួលខុសត្រូវខ្ពស់បំផុត" នៃ អ.វ.ត.ក ដែរ។ ជាចុងក្រោយ ប្រសិនបើកម្ពុជាមិនមានចេតនាកាត់ទោសមេដឹកនាំខ្មែរក្រហមទេ កម្ពុជាទំនងជានឹងមិនសុំបង្កើត អ.វ.ត.ក ទេ ពីព្រោះកម្ពុជាដឹងយ៉ាងច្បាស់ថា អៀង សារី ត្រូវបានលើកលែងទោសរួចហើយ។ មាត្រា ៤០ ថ្មី នៃច្បាប់ស្តីពី អ.វ.ត.ក បានទុកអំណាចជូនតុលាការ ដើម្បីពិចារណាលើការលើកលែងទោស។ ជាចុងក្រោយ ក្នុងអំឡុងពេលនៃការពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតឲ្យមាន អ.វ.ត.ក តំណាងរាជរដ្ឋាភិបាលបាននិយាយយ៉ាងច្បាស់នៅក្នុងកិច្ចប្រជុំរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាថា មុខសញ្ញាសម្រាប់ការកាត់ទោសដោយ អ.វ.ត.ក <u>ត្រូវតែតិចតួច និងតួចចង្អៀត</u>។[2384]

៦៣៨. ជាសរុប សកម្មភាព និងចេតនារបស់ភាគីកម្ពុជាទាំងមុន និងអំឡុងពេលនៃការចរចា បង្កើតច្បាប់ អ.វ.ត.ក បង្ហាញពីយុត្តាធិការបុគ្គលដ៏តូចចង្អៀត ដើម្បីរកយុត្តិធម៌ និង រក្សាបានសន្តិភាព។ មុខសញ្ញាទាំងនោះគឺមេដឹកនាំជាន់ខ្ពស់ និង ឌុច ដែលជាបុគ្គលម្នាក់តែប៉ុណ្ណោះដែលជាជនទទួលខុសត្រូវខ្ពស់បំផុត។ ក្នុងដីកាដំណោះស្រាយ ០០៤/១ សហចៅក្រមស៊ើបអង្កេតអះអាងថា៖ ចៅក្រមនៅ អ.វ.ត.ក ត្រូវគោរពតាមសេចក្តីសម្រេចតាមផ្លូវនយោបាយរបស់អ្នកតាក់តែងច្បាប់។[2385]

## ៥. គោលនយោបាយ និងយន្តការនៃការធ្វើសេចក្តីសម្រេចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងឥទ្ធិពលលើងធ្វើនៃកម្មាភិបាល

៦៣៩. របបកម្ពុជាប្រជាធិបតេយ្យបានដឹកនាំប្រទេសចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[2386] ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ មានគោលដៅកសាងសង្គមកម្ពុជាទាំងមូលទៅជាប្រទេសដើរតាមមាគ៌ារបបសង្គមនិយមដ៏ច្បាស់លាស់មួយក្នុងលោក។[2387] ដើម្បីឈានទៅ សម្រេចបាននូវគោលដៅនេះ មានការកត់សម្គាល់ជាបឋម លើការអនុវត្តនូវនយោបាយនៃការជម្លៀស



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ប្រជាជនឱ្យចេញពីតាមបណ្ដាទីក្រុង និងប្រជុំជន ឱ្យទៅនៅតាមទីជនបទនានានៅទូទាំងប្រទេស[2388] ដើម្បីចូលរួមលើកកម្ពស់ វិស័យកសិកម្មជាអាទិភាព[2389] ក្នុងការជួយជម្រុញស្ថានភាពសេដ្ឋកិច្ចរបស់កម្ពុជា ឱ្យទទួលបាននូវការរីកចម្រើនជាអតិបរមាក្រោមការដឹកនាំពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងក្រោមការដាក់ចេញនូវគោលនយោបាយណែនាំពីបក្សកុម្មុយនីស្តកម្ពុជា[2390] ដោយប្រកាន់យកនូវភាពដាច់ខាតលើគោលជំហរ "**ឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន**"។[2391] លើសពីនេះទៀត របបនេះក៏នៅមានការដាក់ចេញនូវការលើកកម្ពស់វណ្ណៈជាន់ទាប តួយ៉ាងដូចជា វណ្ណៈកសិករ វណ្ណៈកម្មករដែលត្រូវបានគេចាត់ទុកជា វណ្ណៈក្រីក្រ ឱ្យមកធ្វើការត្រួតត្រា នៅរដ្ឋបាលថ្នាក់មូលដ្ឋានដោយរាប់ចាប់ពីថ្នាក់ភូមិឡើងមក។[2392]

៦៤០. ការដឹកនាំដំបូងឡើយ របបកម្ពុជាប្រជាធិបតេយ្យ បានយកតាមបែបសង្គមនិយម ប៉ុន្តែនាអំណើះក្រោយមក របបនេះបានប្រើទម្រង់នៃដឹកនាំប្រទេសឈានទៅតាមបែបកុម្មុយនីស្តផ្ដាច់ការ និងមានភាពដាច់ខាត ដោយបានយកបក្សជាអ្នកមានអំណាចខ្ពស់បំផុត តាមរយៈស្ថាប័នដ៏មានឥទ្ធិពលបំផុត ដែលត្រូវបានគេស្គាល់ឈ្មោះថា "**គណៈកម្មាធិការមជ្ឈិមបក្ស**"។ គណៈកម្មាធិការនេះមានសមាជិកប្រមាណ ៣០ (សាមសិប) រូប ត្រូវធ្វើការចូលរួម ដើម្បីចេញជាសេចក្ដីសម្រេចសំខាន់ៗមួយចំនួន ពាក់ព័ន្ធនឹងការដឹកនាំទាំងក្នុង និងក្រៅប្រទេស។[2393] បើទោះបីជា មានការលើកឡើងដោយ អតីតប្រធានគណៈប្រធានរដ្ឋ[2394] ខៀវ សំផន ហៅ ហែម ដែលបានលើកឡើងថា ជាគោលការណ៍អង្គការដែលសំខាន់ជាងគេគឺ "គណៈកម្មាធិការមជ្ឈិម" ប៉ុន្តែ ក្នុងការប្រតិបត្តិ **ជាក់ស្ដែង អំណាចលើការសម្រេចស្ថិតនៅលើគណៈកម្មាធិការអចិន្ត្រៃយ៍**។[2395] ចំពោះសមាសភាពរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជានាពេលនោះ មានសមាជិកចំនួន ៧ (ប្រាំពីរ) រូបមាន៖ ប៉ុល ពត, នួន ជា, សោ ភឹម, តា ម៉ុក, អៀង សារី, វន វ៉េត, និង សុន សេន។[2396]

៦៤១. រចនាសម្ព័ន្ធរដ្ឋបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យគ្រប់លំដាប់ថ្នាក់ ទាំងថ្នាក់លើ ថ្នាក់ក្រោម និង ថ្នាក់មូលដ្ឋាន ត្រូវបានបែងចែងយ៉ាងជាក់លាក់ លើការសម្រេចចាត់ចែង និងគ្រប់គ្រង ដោយឈរលើទម្រង់នៃការងារតាមបែបជា "**សមូហភាព**"។[2397] កសាងប្រទេសជាតិយើងបានឆាប់រហ័សនិងរឹងមាំបាន លុះត្រាណាតែ ការដឹកនាំប្រទេសនេះឈរលើការគ្រប់គ្រងនិងដឹកនាំតាមលក្ខណៈសមូហភាព។[2398] ម្យ៉ាងវិញទៀត គោលនយោបាយរបស់



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

រដ្ឋាភិបាលនាពេលនោះ ត្រូវបានប្រជុំផ្សព្វផ្សាយយ៉ាងទូលំទូលាយ តាមរយៈកិច្ចប្រជុំនូវគ្រប់កម្រិតរាប់ទាំង កម្រិតភូមិភាគ តំបន់ ស្រុក ឃុំ ភូមិ និងសហករណ៍ ជាអាទិ៍។[2399]

៦៤២. អង្គប្រជុំនាថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ នាពហុកីឡដ្ឋានជាតិអូឡាំពិក បានសម្រេចមិនឲ្យមានទីផ្សារ និងរូបិយវត្ថុជាតិទាំងស្រុងនៅកម្ពុជា។[2400] តាមសក្ខីកម្មអតីតកម្មាភិបាលដែលបានចូលរួមប្រជុំទាក់ទិនគោលនយោបាយបក្សដែលមាន ប៉ុល ពត និង នួន ជា ជាអ្នកឧទ្ទេសនាមបើកវគ្គបានអះអាងថា *"អ្នកទាំងពីរនេះនិយាយពីនយោបាយរៀបចំសហករណ៍ហាមមិនឲ្យចាយលុយ បិទទីផ្សារ និង វត្តអារាម ហើយថ្ងៃក្រោយអាចនឹងបើកឲ្យមានវិញ "*។[2401] មុនការដួលរំលំបន្តិច អង្គការមានសេចក្តីសម្រេចអនុញ្ញាតឲ្យមានចរាចររូបិយវត្ថុ និងអនុញ្ញាតឲ្យបើកមានទីផ្សារឡើងវិញ តែមិនទាំងទាន់ត្រូវបានអនុវត្តចេញជារូបរាងផង របបកម្ពុជាប្រជាធិបតេយ្យក៏បានដួលរលំ។[2402]

៦៤៣. ចំណែកឯង សេដ្ឋកិច្ចជាតិត្រូវប្រឈមមុខនឹងការដាំក្បាលចុះយ៉ាងគំហុក ដោយហេតុថាប្រទេសមួយនេះត្រូវបានដឹកនាំដោយរដ្ឋាភិបាល ដែលលុបបំបាត់ការចរាចររូបិយវត្ថុជាតិទាំងស្រុង[2403] ដោយផ្អែកលើហេតុផលថា ការចាយលុយនាំឲ្យមានអំពើពុករលួយ ការកេងប្រវ័ញ្ច និងការជិះជាន់ពីក្រុមវណ្ណៈសក្តិភូមិជាដើម លើសពីនេះ ការប្រើប្រាស់លុយក៏ជាប្រភពស្នូលបញ្ហាដ៏សំខាន់បំផុត ក្នុងការបង្កឲ្យរបបនេះអាចប្រឈមមុខនឹងអស្ថិរភាពក្នុងការដឹកនាំ និងគ្រប់គ្រងអំណាចរបស់ខ្លួន។[2404] ជាទូទៅ ការដាក់ឲ្យមានការចរាចរលុយនេះ ត្រូវបានអ្នកសេដ្ឋកិច្ចវិទូចាត់ទុកថា ជាមូលដ្ឋានគ្រឹះដ៏ចម្បងបំផុតមួយសម្រាប់ដំណើរការនិងជម្រុញកំណើនសេដ្ឋកិច្ចរបស់ប្រទេសជាតិមួយ។

៦៤៤. មិនតែប៉ុណ្ណោះ នាពេលក្រោយមកបក្សបានកំណត់ទិសដៅបង្កើនទិន្នផលស្រូវ[2405] ដោយបក្សជាអង្គការថ្នាក់លើបានបង្ខំឲ្យប្រជាជនធ្វើស្រូវឲ្យបាន **បីតោនក្នុងមួយហិចតា**[2406] លើដីស្រែទំហំ ១ (មួយ) លាន ៥ (ប្រាំ) សែនហិចតា អង្គការរំពឹងថានឹងទទួលបានស្រូវ រហូតដល់ ៤ (បួន) លាន ៥ (ប្រាំ) សែនតោន ដែលជាភារកិច្ចស្នូលមួយនៅឆ្នាំ១៩៧៦។[2407] សាក្សីជាអតីតអ្នកវាយអង្គលីលេខ បានអះអាងថា *"ឯកសារភាគច្រើននិយាយពីការធ្វើស្រែឲ្យបានបីតោនក្នុងមួយហិចតា"*។[2408] ចំពោះទិន្នផលដែលប្រមូលបានភាគច្រើនបំផុតត្រូវតែប្រគល់ជូនបក្សជាដាច់ខាត សម្រាប់ធ្វើការនាំចេញក្រៅប្រទេស។[2409] ដោយសារអ្នក



ECCC * C.E.T.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ផែនការមិនបានសម្រេចអាចក្លាយជាខ្មាំងនាំឲ្យស្លាប់ ដូច្នេះប្រធានសហករណ៍មួយចំនួនតាមមូលដ្ឋានបានបំប៉ោងតួលេខទិន្នផលដែលទទួលបាន ដើម្បីធ្វើឲ្យបក្សដែលជាអង្គការថ្នាក់លើមើលទៅថា ខិតខំប្រឹងប្រែងដើម្បីបក្សនិងជាមនុស្សស្មោះត្រង់នឹងបក្ស ដោយបានបញ្ជូនផលស្រូវឲ្យថ្នាក់លើយ៉ាងច្រើន ខណៈប្រជាជននៅមូលដ្ឋានខ្លួន ខ្វះខាតអង្ករទុកបរិភោគ។[2410]

៦៤៥. បណ្តាមូលដ្ឋានដែលរំដោះបានភ្លាមៗ មានការបែងចែក ឬ រួមបញ្ចូល ភូមិមួយចំនួនឲ្យទៅជា "សហករណ៍"[2411] ដែលមានលក្ខណៈជាសមូហភាពជាទូទៅ ជាពិសេសលើការរស់នៅនិងហូបចុក[2412] ក្រោមហេតុផលថា ភាពជាសមូហភាព ត្រូវបានគេឲ្យតម្លៃខ្ពស់ថាជាទស្សនៈទានមានលក្ខណៈមនុស្សធម៌ ដោយផ្តល់លទ្ធភាពដល់មនុស្សគ្រប់រូប គួរត្រូវតែទទួលបានបរិមាណម្ហូបអាហារដូចគ្នាៗ ជាអាទិ៍។[2413] បើនិយាយពីសហករណ៍ ត្រូវបានបក្សចាត់ទុកថា ជាមូលដ្ឋានបង្អែកបដិវត្តន៍ដ៏រឹងមាំ នៅក្នុងក្របខណ្ឌទូទាំងប្រទេស។[2414] ក្រោមការដឹកនាំរបស់បក្ស ប្រជាជនអាចទទួលបានអាហារដល់ទៅ ២ (ពីរ) ពេលក្នុង ១ (មួយ) ថ្ងៃ បបរ ១ (មួយ) ពេល និង បាយ ១ (មួយ) ពេល។[2415]

៦៤៦. ការគ្រប់គ្រងរបស់របបកម្ពុជាប្រជាធិបតេយ្យ មានទម្រង់ដឹកនាំខុសប្លែកពីរបបដទៃទៀតក្នុងសកលលោក។[2416] បើសូម្បីតែ អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសនិយាយដែរថា "**បដិវត្តន៍ខ្មែរ គ្មានប្រើគំរូណាមួយពីមុនឡើយ ហើយអ្វីដែលយើងកំពុងសម្រេចទាំងនេះ មិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រពីមុននៅឡើយទេ**"។[2417] បើនិយាយពីគោលជំហរគឺ កម្ពុជាប្រជាធិបតេយ្យមានលក្ខណៈដាច់ខាត[2418] ហើយប្រជាជនត្រូវបង្ខំឲ្យធ្វើការងារនៅតាមមូលដ្ឋាន ក្នុងស្ថានភាពលំបាកក្រៃលែង[2419] គ្មានទេពេលសម្រាកគ្រប់គ្រាន់។ មិនតែប៉ុណ្ណោះ ចំពោះប្រជាជន គ្មានទេសិទ្ធិសេរីភាព[2420]គ្មានសិទ្ធិទទួលបានព័ត៌មាន[2421]គ្មានសិទ្ធិធ្វើដំណើរ[2422] គ្មានទីផ្សារ[2423] គ្មានកម្មសិទ្ធិឯកជន[2424]គ្មានមន្ទីរពេទ្យ គ្មានមណ្ឌលសុខភាព និង គ្មានថ្នាំព្យាបាលជំងឺឲ្យបានគ្រប់គ្រាន់[2425] ជាអាទិ៍។

៦៤៧. ពាក់ព័ន្ធបញ្ហាជំនឿសាសនា បន្ទាប់ពីបានក្តោបក្តាប់អំណាចភ្លាម កម្ពុជាប្រជាធិបតេយ្យបានប្រើវិធានការគ្មានត្រាប្រណីទៅលើព្រះសង្ឃ ដោយចាប់បង្ខំឲ្យព្រះសង្ឃផ្សឹក[2426] ខណៈ ដែលព្រះសង្ឃណាបដិសេធ ត្រូវសម្លាប់ចោល។[2427] ចំណែកឯ វត្តអារាមដែលបានផ្ទើ

អប់រំនិងធ្វើការផ្សព្វផ្សាយសាសនា បែរជាត្រូវរងនូវការបំផ្លិចបំផ្លាញនៅទូទាំងប្រទេស[2428] យ៉ាងគំហុក។[2429] មិនតែប៉ុណ្ណោះ ប៉ុល ពត ដែលជានាយករដ្ឋមន្ត្រី និងជាលេខាបក្ស បាន អនុវត្តលទ្ធិម៉ាកដាច់ខាតទៅលើសាសនាទាំងអស់នៅកម្ពុជាដោយគ្មានការលើកលែង។[2430] សាក្សីជាច្រើនរូបអះអាងថា គ្រប់សាសនាទាំងអស់ត្រូវហាមឃាត់ ខណៈដែលវត្តអារាមក៏ត្រូវបានប្រែក្លាយជាកន្លែងរោងបាយ និងកន្លែងចិញ្ចឹមសត្វ។[2431] សាក្សីម្នាក់បាននិយាយថា *"ពេលនោះគ្រប់សាសនាទាំងអស់ត្រូវបាន បំបាត់ចោលគឺ មានតែបក្សកុំមុយនីស្តមួយទេ ដែលត្រូវគោរព។ បក្សកុំមុយនីស្តស្អប់ព្រះសង្ឃ...ជាងគេ"*។[2432]

៦៤៨. ដើម្បីសម្រេចតាមទិសដៅដែលបានដាក់ចេញ របបនេះបានសម្រុកការកសាងប្រទេស ដោយកំណត់យកកម្លាំងមនុស្សជាស្នូល ដើម្បីជំនួសគ្រឿងចក្រ ក្នុងការដឹកនាំតាមមាគ៌ាសង្គមនិយម ដែលនឹងធ្វើឲ្យកម្ពុជា ទៅជាប្រទេសសំបូរសប្បាយថ្កុំថ្កើងនិងរុងរឿងយ៉ាងឆាប់រហ័សបំផុត ក្រោមពាក្យស្លោកថា "**មហាលោតផ្លោះមហាអស្ចារ្យ**"[2433] ហេតុនេះទើបកម្ពុជាប្រជាធិបតេយ្យបានអនុវត្តមានលក្ខណៈដាច់ខាត និងប្រកាន់ខ្ជាប់នូវគោលនយោបាយចម្បងៗរួមមាន ការជម្លៀសប្រជាជន ការប្រព្រឹត្តលើក្រុមពិសេស ការដ្ឋានការងារដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការបោសសម្អាតផ្ទៃក្នុងនិងក្រៅបក្ស ជាអាទិ៍។ ទន្ទឹមនឹងនោះមានផលវិបាកជាច្រើនអនេកត្រូវបានកើតឡើង ជារួមទាក់ទិននឹងពាក្យថា "**ខ្មាំង**" ពេលខ្លះសំដៅតែលើអ្នកដែលគ្រាន់តែធ្វើឲ្យបាក់នង្គ័ល[2434] បាក់ចប បាក់ស្ពាបព្រា បែកចាន បែកឆ្នាំង[2435] ស្ទូងស្រូវច្រឡំពូជ[2436] លួចស្ករផែន[2437] លួចពោត ចេក និងដំឡូង ដែលដាំដោយខ្លួនឯង[2438] បើកឡានជាន់ហ្វ្រាំងអូសកង់រែង[2439] ទៅធ្វើការយឺតពេល[2440] រិះគន់អង្គការ[2441] ឬ ក្រោមហេតុផលថា អ្នកទាំងនោះជាអ្នកចង់បំផ្លិចបំផ្លាញអង្គការ។[2442]

៦៤៩. មុនឆ្នាំ១៩៧៥ បក្សក៏បានធ្វើការជម្លៀសប្រជាជនចេញពីតំបន់ដែលស្ថិតក្រោមការត្រួតត្រារបស់ខ្លួន។[2443] នៅខែកុម្ភៈ ឆ្នាំ១៩៧៥ គណៈកម្មាធិការមជ្ឈិមបក្ស បានប្រជុំសម្រេចផែនការជម្លៀសជាការត្រៀមទុកជាមុន ក្រោយពេលទទួលបានជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ។[2444] នាពេលនោះមេដឹកនាំជាន់ខ្ពស់មាន ប៉ុល ពត, នួន ជា, អៀង សារី, និង ខៀវសំផន ក៏បានចូលរួមកិច្ចប្រជុំ[2445] ដោយបានសម្រេចធ្វើការជម្លៀស ដែលក្រោយមកមាន ៣ (បី) ដំណាក់កាល។[2446] ផ្អែកតាម សក្ខីកម្មសាក្សីបានដកស្រង់សំដីរបស់កម្មាភិបាលជាន់ខ្ពស់ឈ្មោះ តា ម៉ុក ថា *"ប្រជាជនទាំងអស់ត្រូវតែជម្លៀសទៅកាន់ទីជនបទ*



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

*ដើម្បីកសាង សេដ្ឋកិច្ចជនបទ។ ... ការជម្លៀសប្រជាជនចេញពីទីក្រុងត្រូវបានធ្វើឡើងនៅទូទាំងប្រទេស ដោយការជម្លៀសត្រូវតែឱ្យហើយក្នុងរយៈពេល ០២ (ពីរ) ថ្ងៃ*។[2447] តាមការប៉ាន់ប្រមាណ ចំនួនប្រជាជនដែលត្រូវរងការជម្លៀសមានចំនួនសរុប ២.០០០.០០០ (ពីរលាន) នាក់។[2448] ទាក់ទងនឹងការជម្លៀសប្រជាជនក្នុងរវាងឆ្នាំ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ដែលមានជាបីដំណាក់កាល (សូមមើលកថាខណ្ឌ៨២ ដល់កថាខណ្ឌ ៨៧ ខាងលើនេះ)។

៦៥០. របបកម្ពុជាប្រជាធិបតេយ្យ បានធ្វើបំណែងចែកប្រជាជនតាមប្រវត្តិរូប[2449] រវាងអ្នករស់ក្នុងតំបន់រំដោះ និងអ្នកក្រោយឆ្នាំ១៩៧៥។ ភ្លាមៗក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គការបែងចែកប្រជាជនជាក្រុមជីវភាពជា អ្នកមាន អ្នកក្រីក្រ ឬ អ្នកចេះដឹង។ អ្នកណាមានឋានៈផ្ទាល់ ឬសាច់ញាតិ ជាអ្នករដ្ឋការរបបលន់នល់ របបសង្គមរាស្ត្រនិយមត្រូវបានចាត់ថាជាអ្នកជាប់និន្នាការមិនល្អ។[2450] ចំណែកឯ អ្នកដែលត្រូវជម្លៀសមកដល់កន្លែងថ្មីត្រូវបានអង្គការហៅថា ប្រជាជនថ្មី[2451] ឬប្រជាជន ១៧ មេសា។[2452] រីឯអ្នកនៅទីតាំងដដែលហៅថា ប្រជាជនចាស់[2453] ឬប្រជាជន ១៨ មេសា[2454] ជារួមសំដៅលើប្រជាជនអ្នកមូលដ្ឋាន។[2455] ប្រជាជនថ្មីត្រូវគេផ្តល់ឋានៈជា "ជនបញ្ញើ" ហើយមិនអាចកាន់តំណែងតួនាទីក្នុងរចនាសម្ព័ន្ធក្នុងកម្រិតណាមួយបានឡើយ។[2456] ផ្ទុយទៅវិញ ចំពោះប្រជាជនចាស់ ឬ អ្នកមូលដ្ឋាន អាចទទួលបានឋានៈជាប្រជាជនពេញសិទ្ធិតែម្តង ឬត្រៀម ប្រសិនមានសាច់ញាតិមានទំនាក់ទំនងជាមួយខ្មាំង។[2457]

៦៥១. ជាទូទៅ ប្រជាជនត្រូវបង្ខំឱ្យស្លៀកពាក់ដែលកំណត់ដោយអង្គការជាខោអាវពណ៌ខ្មៅដោយក្នុងមួយឆ្នាំប្រជាជនអាចទទួលបានពីរសម្រាប់យ៉ាងច្រើន គ្មានទេសេរីភាពក្នុងការស្លៀកសម្លៀកបំពាក់ គ្មានទេអនាម័យ គ្មានទេសុខមាលភាព។[2458] នៅតាមគ្រួសារនីមួយៗ គ្មានទេទ្រព្យសម្បត្តិកម្មសិទ្ធិឯកជន ផ្អែកលើគោលនយោបាយដែលត្រូវបានដាក់ឱ្យអនុវត្តចាប់តាំងពីមុនរំដោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មកម្ល៉េះ។[2459] ដោយមានហេតុផលថា របបកម្ពុជាប្រជាធិបតេយ្យយល់ថា ទ្រព្យសម្បត្តិឯកជន[2460] ជារបបនាយទុននិយមនាំឱ្យមានអំពើពុករលួយ[2461] ការកេងប្រវ័ញ្ចពីសំណាក់អ្នកមានទ្រព្យធនមកលើកម្មករ និងកសិករដែលជាវណ្ណៈជាន់ទាប។[2462]



E.C.C.C * C.E.T.C. CO-INVESTIGATING JUDGES * CO-JUGES

៦៥២. របបកម្ពុជាប្រជាធិបតេយ្យ បានដាក់កំហិតឲ្យមានការរៀបការដោយបង្ខំ បើទោះបីជាពុំអាចរកឃើញនូវឯកសារណាមួយមកបញ្ជាក់លើបញ្ហានេះ ប៉ុន្តែ ជាមួយនឹងការអនុវត្តដូចៗគ្នាពីតំបន់មួយទៅតំបន់មួយ និងពីភូមិភាគមួយទៅភូមិភាគមួយនៅទូទាំងប្រទេស ឃើញការអនុវត្តនូវគោលនយោបាយបាយចាប់បង្ខំឲ្យរៀបការនេះ ក្នុងទិសដៅដើម្បីសម្រេចដោយខានមិនបានលើការឈានទៅបង្កើនចំនួនប្រជាជន និងកម្លាំងអ្នកបន្តវេនក្នុងការការពារជំហរបដិវត្តន៍សង្គមនិយមដែលអង្គការបានដាក់ចេញ តាមរយៈយកអង្គការថ្នាក់លើរបស់ខ្លួនជាមេបាជំនួសឲ្យឪពុកម្តាយ។[2463] មិនតែប៉ុណ្ណោះ នេះដើម្បីចំណេញនយោបាយគ្រប់គ្រងលើបុគ្គល និងសេដ្ឋកិច្ច ដោយទុកឲ្យឪពុកម្តាយនៅធ្វើការតាមសហករណ៍ និងការដ្ឋានការងារ។[2464] សក្ខីកម្មសាក្សីបានបញ្ជាក់អំពីសារនយោបាយពីកម្មាភិបាលដែលស្ថិតក្នុងជួរថ្នាក់ដឹកនាំថា *"គេគ្រោងនឹងបង្កើនកម្លាំងថ្មី ឬក៏ប្រជាជនថ្មីឲ្យដល់ ១៥ ទៅ ២០ លាននាក់ នៅក្នុងរយៈពេលពី ១៥ ទៅ ២០ ឆ្នាំទៀត"*។[2465]

៦៥៣. ចំពោះការរៀបការអង្គការបានប្រមូលចងក្រង អ្នកដែលមានឋានៈនយោបាយដូចគ្នា ដោយផ្តល់ការលើកទឹកចិត្តដល់កងទ័ព។[2466] តាមការប្រកាសរបស់ ប៉ុល ពត ក្នុងសន្និសីទ ការបោះពុម្ពផ្សាយជាផ្លូវការ តាមសារទូរលេខ រួមផ្សំជាមួយនឹងការភ័យខ្លាចនូវអំពើហិង្សា ឬការស្លាប់។[2467] មានសាក្សីជាច្រើនផ្តល់សក្ខីកម្មថា អ្នកត្រូវគេបង្ខំឲ្យរៀបការមិនហ៊ានតវ៉ាឡើយ។[2468]

៦៥៤. ឈរលើគោលជំហរខ្វះការទុកចិត្ត និងព្យាយាមដាក់ការសង្ស័យរវាងគ្នានិងគ្នា បក្សបានដាក់ចេញនូវនយោបាយបោសសម្អាតក្នុងជួរនិងក្រៅជួរបក្ស ហើយដែលត្រូវបានបង្កើតតាំងតែពីមុនឆ្នាំ១៩៧៥ និងបន្តអនុវត្តកាន់តែមានទ្រង់ទ្រាយធំឡើងៗ ក្នុងគោលបំណងយ៉ាងណាដើម្បីបំផ្លាញឲ្យបានទាំងស្រុងនូវរចនាសម្ព័ន្ធ របបដឹកនាំមុនៗ នឹងឈានទៅលុបបំបាត់ឲ្យអស់នូវវណ្ណៈសក្តិភូមិ នាយទុន សាសនា ពូជសាសន៍ ជាដើម។[2469] គោលនយោបាយបោសសម្អាតត្រូវបានស្តែងឡើង តាមរយៈសេចក្តីសម្រេចគណៈមជ្ឈិមបក្សនាឆ្នាំ១៩៧៦ ដែលពាក់ព័ន្ធសិទ្ធិសម្រេចកម្ទេចក្នុងនិងក្រៅជួរបក្ស ដោយបានចែងយ៉ាងច្បាស់ថា *"បើនៅក្នុងក្របខណ្ឌមូលដ្ឋានត្រូវអចិន្ត្រៃយ៍ភាគសម្រេច ជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមន្ទីរមជ្ឈិមសម្រេច តំបន់ឯករាជ្យត្រូវអចិន្ត្រៃយ៍សម្រេច កងទ័ពមជ្ឈិមត្រូវសេនាធិការសម្រេច"*។[2470] ខណៈនោះដែរ សម្រាប់រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យត្រង់មាត្រា១០ បានចែងថា



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES

*"ចំពោះប្រភេទសកម្មភាពប្រឆាំង និងបំផ្លិចបំផ្លាញជាខ្សែសង្វាក់ ហើយគ្រោះថ្នាក់ដល់រដ្ឋរបស់ប្រជាជនត្រូវ ផ្តន្ទាទោសកម្រិតខ្ពស់បំផុត។ ចំពោះបទល្មើសក្រៅពីប្រភេទខាងលើត្រូវអប់រំកសាងក្នុងក្របខណ្ឌអង្គការរដ្ឋ ឬ ក្នុងក្របខណ្ឌអង្គការប្រជាជន"*។[2471] ទាំងនេះសបញ្ជាក់ពីការ គៀងគរគ្រប់យន្តការ ដើម្បីជម្រុញប្រសិទ្ធិភាពនៃការបោសសម្អាតដែលបក្សបានដាក់ចេញ ក្រោមការតាមដានជាប់ជាប្រចាំរបស់អង្គការ។

៦៥៥. បើពិនិត្យមើលទៅលើស្ថានការណ៍នៅក្រោយឆ្នាំ១៩៧៥ អ្វីៗក៏មានភាពស្មុគស្មាញពិបាកយល់នូវបញ្ហានៅគ្រប់ជាន់ថ្នាក់ រីឯ គោលនយោបាយទូទៅដឹកនាំប្រទេសដែលមានលក្ខណៈឆ្វេងនិយមជ្រុល តាមគន្លងមាគ៌ាឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ដែលត្រូវបានយកមកអនុវត្តជ្រុលនិយមហួសហេតុ ដែលប្លែកពីគេក្នុងលោក។[2472]

៦៥៦. នៅក្រោមការដឹកនាំរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដោយមានការចង្អុលបង្ហាញពីសំណាក់បក្សកុំម្មុយនីស្តកម្ពុជា របបនេះបានបង្កើតឱ្យមានមន្ទីរសន្តិសុខជាច្រើនកន្លែងសម្រាប់ប្រើប្រាស់ជាទីឃុំឃាំង អប់រំកែប្រែ ធ្វើទារុណកម្ម និងជាកន្លែងសម្លាប់មនុស្សដែលមានរហូតដល់ជាង ១៩៥ (មួយរយកៅសិបប្រាំ) មន្ទីរសន្តិសុខនៅទូទាំងប្រទេស។[2473] ជារួម កម្មាភិបាលគ្រប់ជាន់ថ្នាក់ត្រូវតែអនុវត្តតាមគោលមាគ៌ាដែលបក្សបានដាក់ចេញ ដោយត្រូវធ្វើការផ្សព្វផ្សាយបន្តនូវគោលនយោបាយបក្សដែលដាក់ចុះមក និងជាពិសេសអ្នកដែលពាក់ព័ន្ធត្រូវចូលរួមធ្វើការសម្របសម្រួលករណីអង្គការថ្នាក់លើសម្រេចឱ្យចាប់ខ្លួននរណាម្នាក់ដែលគេចាត់ទុកជាខ្មាំងរបស់អង្គការ"។[2474] នៅពេលមានការសម្រេចឱ្យចាប់ខ្លួនបុគ្គលណាមួយ គ្មានទេវប្បធម៌ជ្រៀតជ្រែកសេចក្តីសម្រេចឱ្យចាប់ខ្លួននោះពីព្រោះថា នាពេលនោះមានប្រយោគមួយឃ្លាដែលត្រូវបានគេប្រើប្រាស់ជាញឹកញាប់ថា **"កុំធ្វើអីដែលនាំឱ្យខ្មាស់នឹងអង្គការខ្មាស់នឹងកង់ប្រវត្តិសាស្ត្រ"**។[2475]

៦៥៧. នរណាៗក៏ដឹងដែរថា អ្វីៗទាំងអស់សុទ្ធតែជាបញ្ជាពី **"ថ្នាក់លើ"**[2476] ខណៈថ្នាក់ក្រោមខ្លះការយល់ដឹងឱ្យបានគ្រប់គ្រាន់លើខ្លឹមសារពីផែនការ ឬ កម្មវិធីនយោបាយដែលអង្គការបានដាក់ចុះ។[2477] ប៉ុន្តែ ប្រសិនបើមិនធ្វើតាមគោលនយោបាយថ្នាក់លើ បើទោះបីជាអ្នកមិនយល់ក៏ដោយ អ្នកនោះនឹងត្រូវចោទថាជាខ្មាំងរបស់អង្គការ[2478] ហើយនឹងត្រូវចាប់យកសម្លាប់ចោលភ្លាមៗក៏មាន។[2479] ក្នុងបរិបទកម្ពុជាប្រជាធិបតេយ្យបញ្ជាថ្នាក់លើជាដាច់



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

ត្រូវតែគោរពធ្វើតាមទាំងស្រុងដោយឥតងាករេ ហើយហ៊ានតែបដិសេធទោះតិចឬច្រើន អ្នកនោះនឹងត្រូវជាកម្មវត្ថុនៃការចាប់ខ្លួន និង សម្លាប់[2480] ខណៈដែលអ្នកដែលមានភាពក្លាហានក្នុងការរិះគន់នោះ ត្រូវបានអង្គការចាត់ទុកជា "ជនក្បត់ជាតិ"។[2481]

៦៥៨. ក្នុងរបបនោះមាន យន្តការដែលទទួលបានប្រជាប្រិយក្នុងការអនុវត្តនោះគឺ "**ការប្រជុំស្វ័យទិតៀន**" ដែលត្រូវបានគេអនុវត្តនូវគ្រប់ជាន់ថ្នាក់ ជាពិសេសនៅតាមសហករណ៍មូលដ្ឋាន ដែលការប្រជុំនេះតម្រូវឱ្យអ្នកដែលបានប្រព្រឹត្តខុស ត្រូវលាតត្រដាងពីកំហុសខ្លួនចេញមកក្រៅឱ្យអង្គប្រជុំបានដឹង ដើម្បីឱ្យអង្គប្រជុំជួយឱ្យយោបល់ ក្នុងគោលបំណងកុំឱ្យធ្វើកំហុសដដែលៗ។[2482] ម្យ៉ាងទៀត ប.ក.ក នៅបានកំណត់ឱ្យមានប្រជុំជីវភាពបក្សជាទៀងទាត់ ដោយលើកហេតុផលថា "បើប្រជុំទៀងទាត់ គឺចម្រើន ចម្រើនលឿន ចម្រើនយឺតគឺចម្រើន"។[2483] តាមរយៈការប្រជុំទាំងនោះ អង្គការបានឃោសនាពង្រឹងខឿនស្មារតីប្រជាជនឱ្យខិតខំធ្វើការ និងការលះបង់គ្រប់បែបយ៉ាងដើម្បីអង្គការ បើមិនដូច្នោះទេអ្នកនឹងត្រូវ "**ប្រវត្តិសាស្ត្រថ្កោលទោស**" ជាក់ជាពុំខាន។[2484] បើអង្គការសម្រេចកំណត់យកអ្នកណាទៅអប់រំរៀនសូត្រ ឬ កសាងមិនបាន អ្នកនោះនឹងត្រូវយកទៅសម្លាប់ចោលដោយបោះពាក្យថា "**ទុកក៏មិនចំណេញ ដកចេញក៏មិនខាត**"។[2485] លម្អាននេះត្រូវធ្លាក់លើ ហ៊ូ នឹម ត្រូវបានគេចាប់យកទៅសម្លាប់ នៅឆ្នាំ១៩៧៦ ដោយសារគាត់ហ៊ាន លើកស្នើឱ្យមានការចាយលុយ និងបើកឱ្យមានទីផ្សារឡើងវិញនៅប្រទេសកម្ពុជា ការណ៍នេះដែលផ្ទុយទៅនឹងការសម្រេចកន្លងមករបស់ ប៉ុល ពត, នួន ជា និង តាម៉ុក។[2486]

៦៥៩. ការអនុវត្តនូវគោលនយោបាយទាំងឡាយរបស់បក្សកុំម្មុយនីស្តកម្ពុជា ខាងលើបង្ហាញឱ្យឃើញថា ប្រជាជននៅទូទាំងប្រទេសត្រូវប្រឈមមុខនឹងផលវិបាកជាច្រើនឥតគណនា ក្រៅពីការត្រូវអង្គការយកទៅសម្លាប់ ក៏នៅមានដែរការស្លាប់នោះបណ្តាលពីភាពអត់ឃ្លានបណ្តាលខ្វះអាហារូបត្ថម្ភ និងការស្លាប់ដោយសារជំងឺរាករូស និងអាសន្នរោគ ជាដើម។[2487] នៅពេលប្រជាជនណាម្នាក់ឈឺ មិនមានទេការផ្តល់សេវាសុខាភិបាលដើម្បីព្យាបាលនោះទេ ពីព្រោះនាពេលគ្មានទេ មណ្ឌលសុខភាព មន្ទីរពេទ្យ និងថ្នាំព្យាបាលឱ្យបានគ្រប់គ្រាន់ ហើយពេលខ្លះក៏បណ្តាលឱ្យអ្នកជំងឺឈឺនិងស្លាប់នៅហ្នឹងកន្លែងក៏មាន។[2488] ក្រៅពីការស្លាប់ដោយសារជំងឺ នៅមានការស្លាប់របស់ប្រជាជនដែលកើតចេញពីការ យុទ្ធនាការនៃការបង្ក្រាប តាមរយៈការអនុវត្តនូវគោលនយោបាយនៃការបោសសម្អាត។ ជាក់ស្តែង ប្រជាជន

និងកម្មាភិបាលដែលត្រូវបានចាត់ថាជាខ្មាំង ឬ មិនគោរពតាមបទបញ្ជាអង្គការក៏ត្រូវបានសម្លាប់។[2489] នាពេលនោះ គ្មានទេការបន្ធូរបន្ថយដោយផ្ទេរទៅជាវិធានការវិន័យជាជំនួសនោះ មានន័យថាឱ្យតែមិនគោរពតាមគោលនយោបាយរបស់អង្គការ បើទោះបីជាកម្មាភិបាលថ្នាក់ណាក៏ត្រូវក្លាយជាមុខសញ្ញានៃការបោសសម្អាតដែររួមមាន ហ៊ូ យន់[2490] ហ៊ូ នឹម[2491] វន វ៉េត[2492] កុយ ធួន[2493] វស់ ញឹម[2494]និង សោ ភឹម[2495] ជាដើម។

៦៦០. ជាការកត់សម្គាល់ ក្នុងអំឡុងពេលគ្រប់គ្រងដឹកនាំប្រទេសរបស់របបកម្ពុជាប្រជាធិបតេយ្យប្រមាណជា ៣ (បី) ឆ្នាំ ៨ (ប្រាំបី) ខែ ២០ (ម្ភៃ) ថ្ងៃ ប៉ុណ្ណោះ គេសង្កេតឃើញថា មានកម្មាភិបាលជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យយ៉ាងតិចចំនួន ៦០ (ហុកសិប) រូប ត្រូវបានចាប់ខ្លួន និងសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ ។[2496] ជាសរុបប្រជាជនប្រមាណជាង ១.៧០០.០០០[2497] (មួយលានប្រាំពីរសែន) នាក់ ត្រូវបានសម្លាប់ និងស្លាប់ដោយសារការអត់ឃ្លាន[2498] ជំងឺ[2499] និង ធ្វើការងារហួសកម្លាំង។[2500]

៦៦១. នយោបាយដែលត្រូវបានដាក់ចេញដោយបក្សកុំម្មុយនីស្តកម្ពុជា ដូចបានរៀបរាប់ខាងលើបានបង្ហាញថា នៅទូទាំងប្រទេសកម្ពុជា មានបង្កើតឱ្យមាននូវប្រព័ន្ធតាមដានគ្រប់រូបភាពតាមរយៈកងឈ្លបតាមមូលដ្ឋានជាពិសេស រហូតដល់មានពាក្យថា "**អង្គការភ្នែកម្នាស់**" ដោយអង្គការមានមធ្យោបាយរឹតត្បិតគ្រប់សព្វ មិនត្រឹមតែលើប្រជាជនទេ រួមទាំងកម្មាភិបាលដែលត្រូវបានគេកំណត់ថាជាមុខសញ្ញាផងដែរ។[2501] មិនតែប៉ុណ្ណោះ ប្រសិនបើមានការដើរខុសគន្លងគោលនយោបាយបក្សកុំម្មុយនីស្តកម្ពុជា ជននោះនឹងក្លាយជាខ្មាំងរបស់អង្គការ ឬខ្មាំងបដិវត្តន៍។ អ្វីដែលចម្លែកបំផុតត្រង់ថា គោលនយោបាយនៃការលុបបំបាត់របបកម្មសិទ្ធិឯកជនមានការអនុវត្តស៊ីជម្រៅហួសពីការស្មាន ដោយហេតុថា បើសូម្បីតែដំណាំដែលប្រជាជនបានដាំជុំវិញផ្ទះខ្លួន ក៏ត្រូវបានគេចាត់ទុកជាកម្មសិទ្ធិសមូហភាព ឬ ជាទ្រព្យសហករណ៍។ ទង្វើរឹតត្បិតលើភាពជាកម្មសិទ្ធិនេះរហូតដល់អង្គការបានប្រើពាក្យស្លោកប្រាប់ទៅប្រជាជនដដែលៗថា "**ជាកម្មសិទ្ធិសមរម្យគឺស្លាបព្រាមួយគូច**"។

៦៦២. អង្គហេតុទាំងប៉ុន្មានខាងលើនេះមានលក្ខណៈជាសត្យានុម័តដែលដឹងឮជាសាធារណៈជាទូទៅនៅពេញផ្ទៃប្រទេស ពោលគឺប្រជាជនទាំងឡាយណាដែលនាពេលនេះមានអាយុចាប់

៤៤ (សែសិបបួន) ឆ្នាំ (គិតត្រឹមឆ្នាំ២០១៨) ឡើងទៅ កាលបើរស់នៅក្នុងរបបនោះសុទ្ធតែបានដឹងឮ និងឃើញទាំងអស់ដោយមិនចាំបាច់មានភស្តុតាងបញ្ជាក់។

៦៦៣. ម្យ៉ាងទៀត បរិបទនៃការប្រព្រឹត្ត និងទម្រង់នៃការគ្រប់គ្រងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺខុសពីអ្វីដែលកើតមាននៅប្រទេសយូហ្គោស្លាវី រវ៉ាន់ដា និងសេរ៉ាឡេអូន ដែលបង្កើតឱ្យមាននូវតុលាការព្រហ្មទណ្ឌអន្តរជាតិស្រដៀងគ្នានឹង អ.វ.ត.ក ដែរ។ របបកម្ពុជាប្រជាធិបតេយ្យ គឺជារបបប្រកាន់និន្នាការដឹកនាំរដ្ឋមួយជាក់លាក់ដែលឆ្លុះបញ្ចាំងក្នុងគោលនយោបាយធ្វើទុក្ខបុកម្នេញកម្រិតជាតិ អនុវត្តជាទូទៅនៅទូទាំងប្រទេសក្នុងរចនាសម្ព័ន្ធដឹកនាំសមូហភាពដែលកម្មាភិបាលគ្រប់ជាន់ថ្នាក់ត្រូវគោរព និងធ្វើតាមបញ្ជា។ សត្រូវ ឬខ្មាំងបដិវត្តន៍មានវិសាលភាពធំធេង គ្របដណ្ដប់លើប្រជាពលរដ្ឋខ្លួនឯង។ នេះខុសគ្នានឹងជម្លោះពូជសាសន៍រវាងទុតស៊ី និង ហ៊្វូទូ ដែលនាំឱ្យមានអំពើប្រល័យពូជសាសន៍នៅប្រទេសរវ៉ាន់ដា។[2502] នេះក៏ស្រដៀងគ្នានឹងអំពើប្រល័យពូជសាសន៍ ដោយពួកជាតិនិយមស៊ែបដែលដឹកនាំដោយ លោក Slobodan Milosevic ទៅលើប្រជាជនក្រូអាត និងបូស្នៀ។[2503]

៦៦៤. ការពិតទូទៅមួយទៀតដែលត្រូវចងចាំក្នុងចិត្តគឺ ទោះបីជាមានការប្រជុំទៀងទាត់ក៏ដោយ ក៏ការធ្វើសេចក្តីសម្រេចនៅក្នុងឋានានុក្រមខ្មែរក្រហម ពុំមែនធ្វើឡើងក្នុងដំណើរប្រជាធិបតេយ្យផ្លូវការមួយអាចឱ្យមានការលើក យោបល់ដោយសមភាពនៅចំពោះអ្នកមុខអ្នកការនៅគ្រប់ថ្នាក់ ហើយនាំឱ្យមានការពិភាក្សាគ្នារកច្រកចេញនោះទេ។ សេចក្តីសម្រេចត្រូវបានធ្វើឡើងនៅថ្នាក់កំពូល និងបន្ទាប់មកត្រូវបានអនុវត្តដោយថ្នាក់ក្រោមៗ ដោយមិនខ្វល់ពីផលវិបាកក្នុងលក្ខណៈបុគ្គលទោះនៅថ្នាក់ណាក៏ដោយ ប៉ុន្តែវានឹងកើតមានផលវិបាកកាន់តែខ្លាំងតាមរយៈខ្សែសង្វាក់នៃការបញ្ជា ប្រសិនបើបញ្ជាទាំងនោះពុំត្រូវបានគោរពតាម។ ករណីនេះមិនផ្ទុយពីការពិតដែលថា ជារឿយៗ គោលនយោបាយត្រូវបានសរសេរក្នុងន័យទូទៅដោយថ្នាក់លើ ហើយកម្មាភិបាលថ្នាក់ក្រោមៗ ត្រូវបានផ្តល់លទ្ធភាពស្វែងយល់លម្អិតនៅក្នុងពេលអនុវត្តគោលនយោបាយទាំងនោះ។ ការលំបាកកាន់តែខ្លាំងនៃការរក្សារចនាសម្ព័ន្ធអង្គការលេខរហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យពុំទាមទារឱ្យមាននូវការយល់ឃើញផ្សេងពីនេះឡើយ។ ករណីបុគ្គលម្នាក់បានបង្កើត ឬ ត្រូវបង្កើតគំនិតផ្តួចផ្តើមរបស់ខ្លួននៅក្នុងកាលៈទេសៈទាំងនេះ ឬក៏យ៉ាងណានោះ គឺពុំមែនជាលក្ខណៈវិនិច្ឆ័យមួយ ដែលអាចនឹងឱ្យបុគ្គលនោះស្ថិតក្នុងប្រភេទអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតឡើយ

ទេ។ អង្គហេតុនៅតែបង្ហាញថា ទោះក្នុងពេលណាៗក៏ដោយ ការកំណត់ន័យលើខ្លឹមសារនៃគោលនយោបាយ និងមធ្យោបាយអនុវត្តគោលនយោបាយស្ថិតនៅលើថ្នាក់កំពូលដែលអាចជ្រៀតជ្រែកតាមចិត្តចង់របស់ពួកគេ។

៦៦៥. ករណីនេះរួមផ្សំជាមួយនឹងការប្រើប្រាស់ស៊ីសង្វាក់គ្នាភាគច្រើន នូវប្រព័ន្ធទំនាក់ទំនងខ្សែបណ្ដោយនៅក្នុងខ្សែសង្វាក់នៃការបញ្ជា និងគោលការណ៍រក្សាការសម្ងាត់ជាប់មកជាមួយ ដែលជាទូទៅពុំអនុញ្ញាត ឬយ៉ាងហោចណាស់ ពុំលើកទឹកចិត្ត ឬជួយសម្រួលដល់ការផ្លាស់ប្ដូរព័ត៌មានយុទ្ធសាស្ត្រ និងប្រតិបត្តិ តាមលក្ខណៈសមភាពនៃខ្សែទទឹងនៅតាមថ្នាក់ក្រោមៗនៃការដឹកនាំថ្នាក់លើ។ តាមពិត ការណែនាំដែលបានពិភាក្សាគ្នាជាចំហពីអង្គការឧទាហរណ៍ រវាងមេបញ្ជាការវរសេនាធំ ឬ វរសេនាតូចអាចត្រូវបានពិចារណាដោយថ្នាក់លើថាជាវិធីដំបូងក្នុងការធ្វើឱ្យគេស្ថិតក្រោមបង្គាប់របស់ខ្លួន ហើយគ្មាននរណាម្នាក់អាចមានសុវត្ថិភាពនៅក្នុងការសន្មតថា ការសន្ទនាបែបនោះនឹងពុំត្រូវបានរាយការណ៍នៅក្នុងក្រុមពាក់ព័ន្ធដែលទទួលរងនូវផលប៉ះពាល់អវិជ្ជមានមកលើខ្លួន។

## ជំពូក៧. សំអាងហេតុ និងសេចក្ដីសន្និដ្ឋានបញ្ហាយុត្តាធិការបុគ្គលលើ យឹម ទិត្យ និងការបិទបញ្ចប់សំណុំរឿង ០០៤ ទាំងមូល

### ក. សំអាងហេតុ និងសេចក្ដីសន្និដ្ឋានបញ្ហាយុត្តាធិការបុគ្គលលើ យឹម ទិត្យ

៦៦៦. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា **យឹម ទិត្យ** ធ្លាប់ជាលេខាស្រុកគិរីវង់ លេខាតំបន់ ១៣ នៃភូមិភាគនិរតី។ ស្រុកគិរីវង់ ស្ថិតនៅក្នុងភូមិសាស្ត្រនៃតំបន់ ១៣។ គាត់ជាលេខាតំបន់ ១ នៃភូមិភាគពាយ័ព្យ ហើយដែលត្រូវបានគេអះអាងថា គាត់ជាសមាជិកនៃគណៈភូមិភាគនេះផងដែរ។ ភូមិភាគនិរតីស្ថិតក្រោមការគ្រប់គ្រងរបស់ តាម៉ុក ហើយ ភូមិភាគពាយ័ព្យគ្រប់គ្រងដោយ រស់ ញឹម រហូតដល់ពាក់កណ្ដាលឆ្នាំ ១៩៧៨ ត្រូវជំនួសដោយ តាម៉ុក មកពីភូមិភាគនិរតី។

៦៦៧. ភស្តុតាងដោះបន្ទុក និងដាក់បន្ទុកមិនបានបង្ហាញជាក់លាក់ អំពីកាលបរិច្ឆេទច្បាស់លាស់ ដែល យឹម ទិត្យ បានកាន់តំណែងទាំងនេះ ដោយសារការចងចាំរបស់សាក្សីពាក់ព័ន្ធមានកម្រិតក្រោយពេល ដែលអង្គហេតុបានកើតឡើងជាង ៣០ (សាមសិប) ឆ្នាំ មុន អ.វ.ត.ក ត្រូវបានបង្កើត និងក្នុងស្ថានភាពលំបាករងគ្រោះក្នុងអំឡុងពេលដែលពួកគេឃើញ ដឹង និងឮនូវអង្គហេតុទាំងឡាយ។ ភស្តុតាងបានបង្ហាញថា យឹម ទិត្យ ទំនងជា បានក្លាយជាលេខាស្រុកគិរីវង់ ចន្លោះខែ មិថុនា ឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៧ (កថាខណ្ឌ ១៨៧)។

៦៦៨. សាក្សី ៣ (បី) រូប បានអះអាងថា យឹម ទិត្យ ជាលេខាតំបន់ ១៣ ប្រហែលជា ៨ (ប្រាំបី) ខែមុនឆ្នាំ ១៩៧៩ (កថាខណ្ឌ ១៧៩)។ នេះមិនត្រឹមត្រូវទេ ដោយសារសាក្សីជាច្រើនបានអះអាងថា ក្រុមកម្មាភិបាលនៃភូមិភាគនិរតីនៅក្នុងនោះ មាន យឹម ទិត្យ បានចាកចេញទៅកាន់ភូមិភាគពាយ័ព្យក្នុងពាក់កណ្ដាលឆ្នាំ១៩៧៧ រួចទៅហើយ។ យឹម ទិត្យ បានក្លាយជាលេខាតំបន់ ១៣ តែ ១ (មួយ) ឆ្នាំ មុនចេញទៅភូមិភាគពាយ័ព្យ (កថាខណ្ឌ ១៧២) ដូចនេះគាត់អាចកាន់តំណែងនោះ នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៦ ដល់ ឆ្នាំ ១៩៧៧ ជំនួស តាវ៉ាន់ ដែលបានស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍។

៦៦៩. តំបន់ ១ មាន តាវ៉ាញ ជាលេខា ហើយក្រោយពេលចាប់ខ្លួនចុងឆ្នាំ ១៩៧៦ គាត់ត្រូវបានជំនួសដោយ តា ហេង ទាវ ហៅ តាប៉ែត រហូតដល់គាត់ត្រូវបានចាប់ខ្លួនក្នុងពេលដូចគ្នានឹងការចាប់ខ្លួន រស់ ញឹម ដែលជាលេខាភូមិភាគពាយ័ព្យក្នុងខែ សីហា ឆ្នាំ ១៩៧៨ (កថាខណ្ឌ ១៤៧)។ យឹម ទិត្យ ជំនួស តាប៉ែត ដូចនេះ គាត់ក្លាយជាលេខាតំបន់ ១ ក្នុងខែសីហា ឆ្នាំ ១៩៧៨។ យឹម ទិត្យ អាចក្លាយជាសមាជិកគណៈភូមិភាគផងដែរជំនួស តាប៉ែត ក្រោយគាត់ចាប់ខ្លួន (កថាខណ្ឌ ១៤៧)។ សាក្សីអះអាងថា យឹម ទិត្យ ជាលេខាភូមិភាគពាយ័ព្យ ទោះបីជាយ៉ាងនេះក្តី គឺ តាម៉ុក ទេ ដែលជំនួស រស់ ញឹម ក្នុងឋានៈជាលេខាភូមិភាគពាយ័ព្យ បន្ថែមលើតួនាទីជាលេខាភូមិភាគ ៣ (បី) ផ្សេងទៀត រួមទាំងភូមិភាគនិរតី។ គួរបញ្ជាក់ថា តំណែងទាំងនេះមិនមានឯកសារណាជាផ្លូវការបញ្ជាក់ ឬ ទទួលក្នុងពិធីប្រកាសទទួលតំណែងទេ។ តួនាទីនេះត្រូវបានបង្ហាញប្រាប់ដោយសាក្សី។

៦៧០. ការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតជាតិមិនបានបង្ហាញថា យឹម ទិត្យ ជាសមាជិក គណៈកម្មាធិការមជ្ឈិម ឬ ជាតំណាងរាស្ត្រទេ។ គាត់ក៏គ្មានតួនាទីអ្វីក្នុងកងទ័ពផងដែរ។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ស.ច.ស.ជ បានពិនិត្យឯកសារដើមចម្បងរបស់របបកម្ពុជាប្រជាធិបតេយ្យដែលមាននៅសេសសល់ដូចជា កំណត់ត្រាអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្ស សារទូរលេខឆ្លងឆ្លើយរវាងកម្មាភិបាលថ្នាក់តំបន់ ថ្នាក់ភូមិភាគ និងគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយមិនបានរំលេចឃើញឈ្មោះ **យឹម ទិត្យ** និងតួនាទីអ្វីរបស់គាត់ក្នុងឯកសារទាំងនេះឡើយ។

៦៧១. **យឹម ទិត្យ** ស្ថិតនៅក្នុងលំដាប់ទី៤ រាប់ពីគណៈកម្មាធិការអចិន្ត្រៃយ៍គណៈកម្មាធិការមជ្ឈិមបក្សរហូតដល់ថ្នាក់តំបន់ និងជាមនុស្សម្នាក់ក្នុងចំណោមមនុស្សយ៉ាងតិច ១០០ (មួយរយ) រូបក្នុងកម្រិតភូមិភាគ ឬ តំបន់។ គាត់គ្មានតួនាទីសំខាន់ក្នុងបក្ស ហើយមិនមែនស្ថិតក្នុងចំណោមបុគ្គលជាង ១៣ (ដប់បី) រូប ដែលមានសិទ្ធិកម្ទេចរួមមាន លេខាភូមិភាគ ដូចជា តាម៉ុក តាមសេចក្តីសម្រេច ថ្ងៃទី៣០ ខែ មីនា ឆ្នាំ១៩៧៦ ឡើយ។[2504] ទាំងនៅក្នុងភូមិភាគនិរតី និងពាយ័ព្យ គាត់ស្ថិតនៅក្រោមលេខាភូមិភាគដ៏មានឥទ្ធិពលគឺ តាម៉ុក និង រស់ ញឹម ដែល រស់ ញឹម ត្រូវបានចាប់ខ្លួន ៦ (ប្រាំមួយ) ខែ មុនពេលដួលរលំនៃរបបក្នុងចុងឆ្នាំ១៩៧៨។

៦៧២. សាក្សីជាច្រើនរួមមានសាក្សីសំខាន់ៗ (ជនរងគ្រោះផ្ទាល់នៃអំពើឧក្រិដ្ឋ ឆ្មាំសន្តិសុខប្រចាំមន្ទីរសន្តិសុខ) នៅពេលសាកសួរថា ស្គាល់ **តាទិត្យ (យឹម ទិត្យ)** ដែរឬទេ ភាគច្រើនអះអាងថា មិនបានឮ ឬ ស្គាល់។ សាក្សី ២ (ពីរ) រូប បានអះអាងថា ស្គាល់ឈ្មោះ **ទិត្យ** ក៏ប៉ុន្តែស្គាល់បុគ្គលឈ្មោះ **ទិត្យ** មិនមែនជា **យឹម ទិត្យ** ដោយសារមានកម្មាភិបាលមានឈ្មោះ **ទិត្យ** បម្រើការងារក្នុងភូមិភាគនិរតី និងពាយ័ព្យ។[2505] សាក្សីចំនួនប្រហែល ២៤ (ម្ភៃបួន) រូប ដែលអះអាងថាស្គាល់ **តាទិត្យ**។ សាក្សីម្នាក់អះអាងថា **តាទិត្យ**បញ្ជាឱ្យសម្លាប់ ទោះបីជាយ៉ាងនេះក្តី គាត់បានឮតាមគេតែប៉ុណ្ណោះ។

៦៧៣. មានទីតាំងឧក្រិដ្ឋកម្មចំនួន ៥០ (ហាសិប) ក្នុងនោះ មានការដ្ឋានធ្វើការងារដោយបង្ខំចំនួន ១០ (ដប់) មន្ទីរសន្តិសុខ ឬ គុកចំនួន ១៩ (ដប់ប្រាំបួន) ទីតាំងសម្លាប់មនុស្ស ចំនួន ១៨ (ដប់ប្រាំបី) និង ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬ ហិង្សាផ្លូវភេទដោយបង្ខំចំនួន ៣ (បី)។ ភាគច្រើននៃទីតាំងទាំងនេះត្រូវបានបង្កើតតាំងពីឆ្នាំ ១៩៧៥ ឬ ឆ្នាំ១៩៧៦ បន្តរហូតដល់ចុងឆ្នាំ ១៩៧៨ មុនពេលដែលកម្មាភិបាលនិរតីបានទៅដល់ភូមិភាគពាយ័ព្យ។ ...



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ទីតាំងចំនួនតិចដែលត្រូវបានដាក់ដំណើរការ ក្រោយពេលកម្មាភិបាលនិរតីបានទៅដល់ភូមិភាគពាយ័ព្យ (មន្ទីរសន្តិសុខត្រយោង)។ ក្នុងចំណោមទីតាំងទាំង ៥០ (ហាសិប) មានទីតាំងមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការមជ្ឈិម (មន្ទីរសន្តិសុខវត្តកណ្តាល)។ ទីតាំងខ្លះត្រូវបានបង្កើតមុនពេលដែល **យឹម ទិត្យ** បានទទួលតួនាទីជាលេខាស្រុកគិរីវង់ និងដោយឡែក ទីតាំងខ្លះនៅក្នុងតំបន់ ១ ត្រូវបានបិទដំណើរការក្នុងពាក់កណ្តាលឆ្នាំ ១៩៧៨ នាពេល **យឹម ទិត្យ** ត្រូវបានតែងតាំងជាលេខាតំបន់ ១ ជំនួស តា ហេង ទាវ ហៅ តាប៉ែត។

៦៧៤. មានទីតាំងចំនួន ២៤ (ម្ភៃបួន) ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យក្នុងនោះស្ថិតក្រោមស្រុកគិរីវង់ មានចំនួន ៤ (បួន) និង ៧ (ប្រាំពីរ) ទីតាំងស្ថិតក្នុងភូមិសាស្ត្រនៃតំបន់ ១។ ទីតាំង ចំនួន ២៦ (ម្ភៃប្រាំមួយ) ត្រូវបានលើកចោល ដោយសារមិនមានព័ត៌មានច្រើនពាក់ព័ន្ធនឹង **យឹម ទិត្យ** (២ ទីតាំង ស្ថិតក្រោមស្រុកគិរីវង់ និង ៦ ទីតាំងក្រោមតំបន់១)។

៦៧៥. ក្នុងចំណោម ២៤ (ម្ភៃបួន) ទីតាំង មានទីតាំងចំនួន ១១ (ដប់មួយ) ដែលត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ស្ថិតនៅក្នុងស្រុកគិរីវង់ តំបន់១៣ និងតំបន់១ (ភូមិភាគពាយ័ព្យ)។ អាស្រ័យហេតុនេះ ទីតាំងចំនួន ៣៩ (សាមសិបប្រាំបួន) (ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ និងដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ) ស្ថិតនៅប្រយោលពីការគ្រប់គ្រង ហើយត្រូវបានចោទឡើងដោយសារ **យឹម ទិត្យ** ជាលេខាតំបន់ ១៣ ឬ ជាសមាជិកគណៈភូមិភាគពាយ័ព្យ។ មានតែអង្គហេតុមួយចំនួនប៉ុណ្ណោះដែលអះអាងថា **យឹម ទិត្យ** បានពាក់ព័ន្ធដូចជា មន្ទីរសន្តិសុខវត្តប្រធាតុ, ការដ្ឋានទំនប់កង្ហត, ការដ្ឋានរោងចក្រស្លុរសកំពង់គុល និងការរៀបការដោយបង្ខំនៅស្រុកសំឡូត)។

៦៧៦. មន្ទីរសន្តិសុខវត្តប្រធាតុមានដំណើរការចុងឆ្នាំ ១៩៧៥ ក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគពាយ័ព្យ។ សាក្សីបានអះអាងអំពី ការទៅមើលមន្ទីរសន្តិសុខវត្តប្រធាតុដោយ **យឹម ទិត្យ** ការចេញបញ្ជាឱ្យដោះលែងអ្នកទោស និងការបញ្ជាក់ថា **យឹម ទិត្យ** បានដឹងពីការចាប់ខ្លួន និងសម្លាប់កម្មាភិបាល។ ទោះបីជាយ៉ាងនេះក្តី សាក្សីចំនួនប្រហែលគ្នាបានអះអាងថា មិនបានដឹងរឿងនេះទេ (កថាខណ្ឌ ២០០-២០១)។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៦៧៧. ការដ្ឋានទំនប់កង្ហតមានតាំងពីសម័យកម្មាភិបាលភូមិភាគពាយ័ព្យក្នុងឆ្នាំ ១៩៧៦ ហើយកម្មាភិបាលមកពីភូមិភាគនិរតីបានបន្តគ្រប់គ្រង។ សាក្សីមួយចំនួនអះអាង អំពីការចុះពិនិត្យការដ្ឋាននេះរបស់ **យឹម ទិត្យ** ជាមួយ តាម៉ុក ក្នុងចុងឆ្នាំ ១៩៧៨។ ទោះបីជាយ៉ាងនេះក្តី សាក្សីជាច្រើនអះអាងថា មិនបានឃើញ **យឹម ទិត្យ** ការទៅពិនិត្យ ឬ មិនបានស្គាល់ **យឹម ទិត្យ** ទេ (កថាខណ្ឌ ២៩១-២៩២)។

៦៧៨. ជាចុងក្រោយ ពាក់ព័ន្ធនឹងរោងចក្រផលិតស្ករសកំពង់គល់ មានការអះអាងថា តាម៉ុក បានចុះពិនិត្យ ហើយ **យឹម ទិត្យ** បានដឹកនាំប្រជុំនៅបាត់ដំបង (កថាខណ្ឌ ៣២៤)។ ទោះបីជាយ៉ាងនេះក្តី វាមានភាពមិនច្បាស់ថាប្រជុំនោះនៅក្នុងរោងចក្រ ឬ នៅទីកន្លែងផ្សេងក្នុងទីរួមខេត្តបាត់ដំបង។

៦៧៩. សាក្សីបានអះអាងអំពីការចូលរួមរបស់ **យឹម ទិត្យ** ជាមួយ តាម៉ុក រៀបចំការរៀបការនៅក្នុងស្រុកសំឡូត ក្នុងខែសីហា ឆ្នាំ១៩៧៨ (កថាខណ្ឌ ៣៣៨)។ វាជាព័ត៌មានត្រឹមត្រូវស្របនឹងសាក្សីដទៃទៀតដែលអះអាងថា **យឹម ទិត្យ** ក្លាយជាសមាជិកគណៈភូមិភាគពាយ័ព្យនៅពាក់កណ្តាលឆ្នាំ ១៩៧៨។

៦៨០. កថាខណ្ឌ ៥៨៩ ដល់កថាខណ្ឌ ៥៩០ បានបង្ហាញនូវចំនួនជនរងគ្រោះចំនួនជាង ៥០.០០០ (ប្រាំម៉ឺន) នាក់ ពាក់ព័ន្ធទីតាំងដែលត្រូវបានចោទក្នុងភូមិភាគទាំងពីរ។ ជនរងគ្រោះទាំងនេះត្រូវបានស្លាប់ ឬ ស្លាប់ដោយសារភាពអត់ឃ្លាន និងជំងឺដែលជាលទ្ធផលនៃការអនុវត្តគោលនយោបាយបង្ក្រាបរបស់ជាតិនៅភូមិភាគនិរតី និងពាយ័ព្យមុនពេលកម្មាភិបាលនិរតីទៅដល់ ឬ មុនពេលដែល **យឹម ទិត្យ** ទទួលឋានៈជាលេខាស្រុកគិរីវង់ និងលេខាតំបន់ ១៣ ចន្លោះឆ្នាំ ១៩៧៦ ដល់ពាក់កណ្តាល ឆ្នាំ១៩៧៧ និងលេខាតំបន់ ១ និងគណៈភូមិភាគពាយ័ព្យពាក់កណ្តាល ឆ្នាំ១៩៧៨។ ចំនួនជនរងគ្រោះទាំងនេះមិនមែនជាលទ្ធផលនៃអំពើឧក្រិដ្ឋផ្ទាល់របស់ **យឹម ទិត្យ** ទេ។ វាជាលទ្ធផលនៃការអនុវត្តគោលនយោបាយបង្ក្រាបដែល **យឹម ទិត្យ** គ្មានសិទ្ធិអំណាចចាត់ចែង ក្រៅតែពីការគោរពតាមមាគ៌ាបក្ស។ បន្ថែមពីលើនេះ ខណៈដែល **យឹម ទិត្យ** បានក្លាយជាលេខាតំបន់ ១ និងគណៈភូមិភាគពាយ័ព្យពាក់កណ្តាលឆ្នាំ ១៩៧៨ ប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន បានប្រកាសនូវការលើកលែងការសម្លាប់ដែលចង់មិនចង់នាំឲ្យមានថមថយនូវការបង្ក្រាប។[2506]

៦៨១. ប្រសិនបើប្រៀបធៀបនឹងជនត្រូវចោទ **អោ អាន** (លេខាតំបន់៤១ នៃភូមិភាគកណ្ដាល) និង **មាស មុត** (មេបញ្ជាការកងពលមជ្ឈិមលេខ ១៦៤) ដែលត្រូវបានលើកលែងចោទ មានភ័ស្ដុតាងជាប្រភេទសារទូរលេខ និងកំណត់ត្រាកិច្ចប្រជុំបានរំលេចឈ្មោះ **អោ អាន** (ក្នុងសារទូរលេខរបស់ **កែ ពក** ជូនទៅគណៈកម្មាធិការមជ្ឈិមបក្ស ឬ មន្ទីរ ៨៧០)[2507] និង **មាស មុត**។[2508] ក៏ប៉ុន្តែ យើងពុំឃើញមានករណី **យឹម ទិត្យ** ទេ។

៦៨២. **យឹម ទិត្យ** អាចមានឋានៈស្រដៀងនឹង **អោ អាន** និង **មាស មុត** និងខ្ពស់ជាង **ឌុច** មែន ក៏ប៉ុន្តែ ជាសត្យានុម័ត កម្មាភិបាលកាន់តំណែងធំខ្លះមិនប្រាកដថាមានអំណាចច្រើននោះទេ។ **យឹម ទិត្យ** មានតួនាទីក្នុងភូមិភាគពាយ័ព្យ ក៏ប៉ុន្តែ មិនមានអ្នកក្រោមបង្គាប់ជាក់លាក់ច្បាស់លាស់ដែលនេះផ្ទុយពី **ឌុច** ដែលគ្រប់គ្រងមន្ទីរសន្តិសុខមជ្ឈិម (ស-២១) មានរចនាសម្ព័ន្ធដឹកនាំក្រោមបង្គាប់យ៉ាងជាក់លាក់ដែលធ្វើឱ្យ **ឌុច** ចូលរួមសកម្មភាពឧក្រិដ្ឋយ៉ាងសកម្មបង្កឱ្យមនុស្សជាង ១២.០០០ (មួយម៉ឺនពីរពាន់) នាក់ ស្លាប់ ដោយអំពើផ្ទាល់ និងប្រយោលរបស់គាត់ តាមរយៈការដឹកនាំ ចាត់ចែង និងគ្រប់គ្រងមន្ទីរសន្តិសុខប្រកបដោយប្រសិទ្ធភាពក្នុងអំឡុងពេលស្ទើរពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។[2509]

៦៨៣. ជាសរុប ការចូលរួមក្នុងទីតាំងបទល្មើសខាងលើនេះ ត្រឹមតែជាការចូលរួមដឹងឮ ជាការចូលរួមមិនសកម្ម គ្មានគំនិតផ្ដួចផ្ដើម ឬ ចូលរួមក្នុងកម្រិតនៃកម្មាភិបាលម្នាក់ក្នុងចំណោមកម្មាភិបាលកម្រិតតំបន់ ឬ ភូមិភាគជាច្រើនរូបទៀត។ វាជាការចូលរួមអនុវត្តការងារតាមគោលនយោបាយបក្សដែលត្រូវតែគោរព និងធ្វើតាម។ **យឹម ទិត្យ** មិនមានកម្មាភិបាលក្រោមបង្គាប់ជាក់លាក់ចូលរួមអនុវត្តការងារឱ្យមានប្រសិទ្ធភាព និងមានវិសាលភាពទូលំទូលាយឡើយ។ ដោយឡែក គាត់កាន់តួនាទីក្នុងអំឡុងពេលដ៏ខ្លីក្នុងភូមិភាគពាយ័ព្យ។ ការចូលរួមដូចនេះ មិនស្ថិតក្នុងលក្ខណវិនិច្ឆ័យនៃជនទទួលខុសត្រូវខ្ពស់បំផុតរបស់ជនត្រូវចោទដែលផ្ដោតជាចម្បងទៅលើសកម្មភាពចូលរួមជាក់ស្ដែង និងដោយផ្ទាល់ មិនសំដៅលើឋានៈជាចម្បង។

៦៨៤. យើងយល់ឃើញថា មិនមានភ័ស្ដុតាងដែលអាចឱ្យយើងរកឃើញថា **យឹម ទិត្យ** គឺជាមេដឹកនាំជាន់ខ្ពស់ ឬ ក៏ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឡើយ។ អាស្រ័យហេតុនេះ អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើគាត់ឡើយ។

## ខ. ការបិទបញ្ចប់សំណុំរឿង ០០៤ ទាំងមូល

៦៨៥. ស.ច.ស.ជ បានធ្វើការស៊ើបសួរនូវអង្គហេតុដែលត្រូវចោទប្រកាន់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ផ្អែកលើកថាខណ្ឌ ៥៥ ខាងលើ ស.ច.ស.ជ ត្រូវសម្រេចលើអង្គហេតុ និងជនសង្ស័យទាំងអស់ដែលសេសសល់ក្នុងសំណុំរឿង ០០៤ ដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបិទបញ្ចប់សំណុំរឿង ០០៤ ទាំងមូល។

**តាមសំអាងហេតុខាងលើ យើងសម្រេចៈ**[2510]

៦៨៦. អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ **យឹម ទិត្យ** ឡើយ។

៦៨៧. **លើកលែងការចោទប្រកាន់**ប្រឆាំង **យឹម ទិត្យ**។

៦៨៨. ការស៊ើបសួរក្នុងសំណុំរឿង ០០៤ ដែលនៅសេសសល់នឹងត្រូវសម្រេចក្នុងដីកាសម្រេចរួមគ្នាចេញក្នុងថ្ងៃនេះ៕

ថ្ងៃ សុក្រ ១១ រោច ខែ ជេស្ឋ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៩

**សហចៅក្រមស៊ើបអង្កេតជាតិ**

**National Co-Investigating Judge**

**Co-Juge d'Instruction National**

**យូ ប៊ុនឡេង**

---

[1] សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សំណុំរឿងលេខ៖០០៤/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស ភាគីបញ្ជូន៖ការិយាល័យសហព្រះរាជអាជ្ញា។

[2] សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សំណុំរឿងលេខ៖០០៤/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស ភាគីបញ្ជូន៖ការិយាល័យសហព្រះរាជអាជ្ញា កថាខណ្ឌទី ១១៨ ទំ.៤៩-៥០។

[3] សំណុំរឿង ០០៤ ឯកសារ D1/1.3 ឧបសម្ព័ន្ធ I : សំណៅសាធារណៈមានកោសលុប សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩។ សំណុំរឿង ០០៤ ឯកសារ D1/1.1 ឧបសម្ព័ន្ធ II : សេចក្តីដកស្រង់ការពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩។

[4] សំណុំរឿង ០០៤ ឯកសារ D1/1 ឯកសារជាសេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ សំណុំរឿងលេខ ៖ ០០៤/២០-១១-២០០៨-អ.វ.ត.ក/ក.ស.ច.ស ភាគីអ្នកដាក់៖ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩។

[5] សំណុំរឿង ០០៤ ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១។

[6] សំណុំរឿង ០០៤ ឯកសារ D191 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤។

[7] សំណុំរឿង ០០៤ ឯកសារ D254/1 ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវត្តតាមះ ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៥។

[8] សំណុំរឿង ០០៤ ឯកសារ D272/1 ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរលើអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់ ១ និងតំបន់ ៤ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥។

[9] សំណុំរឿង ០០៤ ឯកសារ D358 សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរលើ **យឹម ទិត្យ** ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧។

[10] សំណុំរឿង ០០៤ ឯកសារ D361/4 ដីកាសម្រេចលើសំណើរបស់ យឹម ទិត្យ សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៧។ សំណុំរឿង ០០៤ ឯកសារ D361 សំណើរបស់ **យឹម ទិត្យ** សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧។ សំណុំរឿង ០០៤ ឯកសារ D361/2 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ **យឹម ទិត្យ** សុំបន្ថែមពេលវេលា ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៧។

[11] សំណុំរឿង ០០៤ ឯកសារ D351/1/4 សាលដីកាលើសំណើរបស់ **យឹម ទិត្យ** សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ PAOLO STOCCHI ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៧។

[12] សំណុំរឿង ០០៤ ឯកសារ D368 សេចក្តីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរលើ **យឹម ទិត្យ** ចុះថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០១៧។

[13] សំណុំរឿង ០០៤ ឯកសារ D378 ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធាន ៦៦ (៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៨។

[14] សំណុំរឿង ០០៤ ឯកសារ D378/1 ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិទាក់ទងករណី យឹម ទិត្យ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨។

[15] សំណុំរឿង ០០៤ ឯកសារ D378/2 ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាទាក់ទងករណី យឹម ទិត្យ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៨។

[16] សំណុំរឿង ០០៤ ឯកសារ D378/3 ការប៉ាន់ស្មានថិរវេលាចាំបាច់របស់ យឹម ទិត្យ ដើម្បីឆ្លើយតបនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៨។

[17] សំណុំរឿង ០០៤ ឯកសារ D378/4 ដីកាសម្រេចលើចំនួនពេលវេលាដែលផ្តល់ជូនមេធាវីការពារក្តី ដើម្បីឆ្លើយតបនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៨។

[18] សំណុំរឿង ០០៤ ឯកសារ D378/5 ចម្លើយតបរបស់របស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងគាត់ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨។

[19] ឯកសាររបស់ អ.ស.ប A/51/930-S/1997/488 សំបុត្ររបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ជូនចំពោះប្រធានក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និង នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៧។ ឯកសាររបស់ អ.ស.ប A/RES/52/135 សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ស្តីអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ កថាខណ្ឌទី១៦។ *សូមមើល* គេហទំព័រ អ.វ.ត.ក https://www.eccc.gov.kh/12278។

[20] ឯកសារជាកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ និងចូលជាធរមាននៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥។ ឯកសារ អ.ស.ប A/RES/57/228B (ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៣) ដែលអនុម័តយល់ព្រមលើសេចក្តីព្រាងកិច្ចព្រមព្រៀងទាក់ទិននឹងការបង្កើត អ.វ.ត.ក។ ឯកសារ អ.ស.ប A/60/565 ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌទី ៤។

[21] ច្បាប់ស្តីពី "ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងត្រូវបានធ្វើវិសោធនកម្ម ដោយព្រះរាជក្រម នស/រកម/១០០៤/០០៦ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")។

[22] សំណុំរឿង ០០៤ ឯកសារ D358 សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧។

[23] សំណុំរឿង ០០៤ ឯកសារ D361/4 ដីកាសម្រេចលើសំណើរបស់ យឹម ទិត្យ សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៧។ សំណុំរឿង ០០៤ ឯកសារ D361 សំណើរបស់ យឹម ទិត្យ សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧។ សំណុំរឿង ០០៤ ឯកសារ D361/2 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមពេលវេលា ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៧។



CO-INVESTIGATING JUDGES *CO-JUGES D' INSTRUCTION* E.C.C.C *C.E.T.C*

---

[24] សំណុំរឿង ០០៤ ឯកសារ D368 សេចក្តីជូនដំណឹងលើកទី២ អំពីការបិទកិច្ចស៊ើបសួរលើ **យឹម ទិត្យ** ចុះថ្ងៃទី០៥ ខែ កញ្ញា ឆ្នាំ២០១៧។

[25] សំណុំរឿង ០០៤ ឯកសារ D378 ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធាន ៦៦ (៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៨។

[26] សំណុំរឿង ០០៤ ឯកសារ D378/1 ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិទាក់ទងករណី **យឹម ទិត្យ** អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨។ សំណុំរឿង ០០៤ ឯកសារ D378/2 ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាទាក់ទងករណី **យឹម ទិត្យ** អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៨។

[27] សំណុំរឿង ០០៤ ឯកសារ D378/5 ចម្លើយតបរបស់របស់ **យឹម ទិត្យ** ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងគាត់ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨។

[28] សំណុំរឿង ០០២ ឯកសារ E350/8 ឯកសារក្នុងសំណុំរឿងលេខ៖០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើភ័ស្តុតាងដែលទទួលបានមកដោយការធ្វើទារុណកម្ម ចំណាត់ថ្នាក់ឯកសារ៖សាធារណៈ ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ ។

[29] សំណុំរឿង ០០២ ឯកសារ F26/12 សេចក្តីសម្រេចលើសេចក្តីជំទាស់ ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ (ប្រភេទឯកសារ៖ សាធារណៈ)។

[30] សំណុំរឿង ០០៤ ឯកសារ D351/1/4 សាលដីកាលើសំណើរបស់ **យឹម ទិត្យ** សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ **PAOLO STOCCHI** ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៧។

[31] សំណុំរឿង ០០៤ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨។

[32] សំណុំរឿង ០០៤ ឯកសារ D1/1.3 ឧបសម្ព័ន្ធ I : សំណៅសាធារណៈមានកោសលុប សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នា រវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩។

[33] សំណុំរឿង ០០៤ ឯកសារ D1/1 សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ សំណុំរឿងលេខ ៖ ០០៤/២០-១១-២០០៨-អ.វ.ត.ក/ក.ស.ច.ស ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩។

[34] ឯកសាររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត អំពីសេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០។

[35] សំណុំរឿង ០០៤ ឯកសារ D3 ដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិឈ្មោះ **Marcel LEMONDE** ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០។

[36] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានចេញសេចក្តីប្រកាសព័ត៌មាន៖ ស្តីអំពីការតែងតាំងលោកបណ្ឌិត **Siegfried BLUNK** ជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី ដោយបានបញ្ជាក់ថា លោកចៅក្រម **Siegfried BLUNK** ចាប់ផ្តើមចូលបម្រើក្នុងការិយាល័យរបស់លោក ចាប់ពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១០ នេះតទៅ។

[37] ឯកសារសេចក្ដីប្រកាសព័ត៌មានរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១១។

[38] សំណុំរឿង ០០៤ ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១។ សំណុំរឿង ០០៤ ឯកសារ D191 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬយេនឌ័រ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ។ សំណុំរឿង ០០៤ ឯកសារ D254/1 ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវត្តតាមៈ ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៥។ សំណុំរឿង ០០៤ ឯកសារ D272/1 ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរលើអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់ ១ និងតំបន់ ៤ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥។

[39] សំណុំរឿង ០០៤ ឯកសារ D281 កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥។

[40] សំណុំរឿង ០០៤ ឯកសារ D350 ដីកាសម្រេចកែប្រែបទចោទប្រកាន់ **យឹម ទិត្យ** ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧។ សំណុំរឿង ០០៤ ឯកសារ D350.1 ឧបសម្ព័ន្ធ៖ សេចក្ដីជូនដំណឹងអំពីបទចោទប្រកាន់ **យឹម ទិត្យ** ដែលបានកែប្រែ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧។

[41] សំណុំរឿង ០០៤ ឯកសារ D359 ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ យោងតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧។

[42] សំណុំរឿង ០០៤ ឯកសារ D358 សេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរលើ **យឹម ទិត្យ** ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧។

[43] សំណុំរឿង ០០៤ ឯកសារ D361 សំណើរបស់ **យឹម ទិត្យ** សុំពន្យារពេលរៀបចំឱ្យបានគ្រប់គ្រាន់ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧។

[44] សំណុំរឿង ០០៤ ឯកសារ D338/2 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំការបញ្ជាក់អំពីដីកាសម្រេចលើកិច្ចស៊ើបសួរ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៧។

